LABS Foundation

គម្រោងគំនិតផ្តួចផ្តើម LABS

វិធីសាស្ត្រសម្រាប់ការវាយតម្លៃ សុវត្ថិភាពបឋមនៅកម្ពុជា

ច្បាប់ទី06 **ថ្ងៃទី**22 **ខែមេសា ឆ្នាំ**2022

របាយការណ៍នេះគិតគូរអំពីការណែនាំជាក់លាក់ និង លក្ខខណ្ឌតម្រូវសម្រាប់អតិថិជនរបស់យើង។

របាយការណ៍នេះមិនមែនរៀបចំឡើងសម្រាប់ និងមិន អាស្រ័យទៅលើភាគីទីបីណាមួយឡើយ ហើយក៏គ្មានការ ទទួលខុសត្រូវចំពោះភាគីទីបីណាមួយដែរ។

Archetype

មជ្ឈមណ្ឌលភ្នំពេញ មហាវិថីព្រះសីហនុកែងផ្លូវសុធារស ច្រកចូល I, ជាន់ផ្ទាល់ដីភ្នំពេញ ប្រទេសកម្ពុជា

www.archetype-group.com

ការផ្លាស់ប្តូរឯកសារ

ចំណងជើងឯកសារ		វិធីសាស្ត្រសម្រាប់ការវាយតម្លៃសុវត្ថិភាពបឋមនៅកម្ពុជា		
កែសម្រួល	**កាលបរិច្ឆេទ**	**រៀបរៀងដោយ**	**ត្រួតពិនិត្យដោយ**	**អនុម័តដោយ**
V1	ថ្ងៃទី 29 ខែវិច្ឆិកា ឆ្នាំ 2021	Pichmuny Youk (វិស្វករសំណង់) Jaime Quilala (វិស្វករ MEP) Dilip Abye (ស្ថាបត្យករ)	Chantha Ny (វិស្វករ HSE)	Dilip Abye
V2	ថ្ងៃទី 20 ខែធ្នូ ឆ្នាំ 2021	Pichmuny Youk (វិស្វករសំណង់) Jaime Quilala (វិស្វករ MEP) Dilip Abye (ស្ថាបត្យករ)	Chantha Ny (វិស្វករ HSE)	Dilip Abye
V3	ថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2021	Pichmuny Youk (វិស្វករសំណង់) Jaime Quilala (វិស្វករ MEP) Sopha So (ស្ថាបត្យករ)	Chantha Ny (វិស្វករ HSE)	Dilip Abye
V4	ថ្ងៃទី 5 ខែមករា ឆ្នាំ 2022	Pichmuny Youk (វិស្វករសំណង់) Jaime Quilala (វិស្វករ MEP) Sopha So (ស្ថាបត្យករ)	Chantha Ny (វិស្វករ HSE)	Dilip Abye
V5	ថ្ងៃទី 11 ខែមីនា ឆ្នាំ 2022	Pichmuny Youk (វិស្វករសំណង់) Jaime Quilala (វិស្វករ MEP) Sopha So (ស្ថាបត្យករ)	Chantha Ny (វិស្វករ HSE)	Dilip Abye

V6 ចុងក្រោយ	ថ្ងៃទី22 ខែ មេសា ឆ្នាំ 2022	Dilip Abye (ស្ថាបត្យករ)	Dilip Abye (ស្ថាបត្យករ)	Dilip Abye

មាតិកា

1 សេចក្តីផ្តើម 6
1.1 គោលបំណង និងអ្នកអានគោលដៅ 6
1.2 បទដ្ឋាននៃគម្រោង គំនិតផ្តួចផ្តើម LABS 7
1.3 ការវាយតម្លៃសុវត្ថិភាពបឋម 8
1.4 វិធីសាស្ត្រ និងការអនុវត្តកម្មវិធី 9
1.5 តម្រូវការកម្លាំងពលកម្មតាមការប៉ាន់ស្មាន 9
1.6 គំនូសតាង 10
1.7 សេចក្តីប្រកាសមិនទទួលខុសត្រូវ 11
2 ការរៀបចំមុនការវាយតម្លៃ 12
2.1 ទំនាក់ទំនងរោងចក្រ និងកាលវិភាគនៃការវាយតម្លៃ 12
2.2 កម្រងសំណួរមុនការវាយតម្លៃ 12
2.3 ការរៀបចំផែនការវាយតម្លៃ 12
3 វិធីសាស្ត្រវាយតម្លៃទូទៅ 14
3.1 ទិដ្ឋភាពទូទៅ 14
3.2 ថ្ងៃចុះវាយតម្លៃនៅរោងចក្រ 20
3.3 ការណែនាំដល់អ្នកគ្រប់គ្រងរោងចក្រ 21
3.4 សម្ភាសន៍អ្នកគ្រប់គ្រងរោងចក្រ 24
3.5 កំណត់សម្គាល់ការវាយតម្លៃអគារទូទៅ 28
3.6 កិច្ចប្រជុំបញ្ចប់ 30
4 វិធីសាស្ត្រវាយតម្លៃសំណង់ 31
4.1 ចំណុចទូទៅ 31
4.2 ការវាយតម្លៃផ្នែកខាងក្រៅនៃអគារ 31
4.3 ការវាយតម្លៃផ្នែកខាងក្នុងនៃអគារ 32
4.4 ការធ្វើតេស្តមិនបំផ្លិចបំផ្លាញ (Non-Destructive Testing) 39
4.5 បញ្ជីត្រួតពិនិត្យព័ត៌មានសំណង់សំខាន់ៗ 41
4.6 ការវាយតម្លៃរសំណង់ និងការគណនា 42
5 វិធីសាស្ត្រវាយតម្លៃអគ្គិភ័យ 49
5.1 ចំណុចទូទៅ 49
5.2 ការវាយតម្លៃអគារ 49
5.3 សេចក្តីណែនាំអំពីបញ្ហាក្នុងបញ្ជីត្រួតពិនិត្យ 52
5.4 ការធ្វើតេស្តប្រព័ន្ធសុវត្ថិភាពអគ្គិភ័យ 84

6 វិធីសាស្ត្រវាយតម្លៃអគ្គិសនី 85
6.1 ចំណុចទូទៅ 85
6.2 ការវាយតម្លៃអគារ 85
6.3 សុវត្ថិភាពអគ្គិសនីនៅក្នុងអនុស្ថានីយ និងបន្ទប់បញ្ជា 85
6.4 អនុស្ថានីយ 86
6.5 ការស្ទង់កម្តៅ 87
6.6 ម៉ាស៊ីនភ្លើង 87
6.7 ការផ្គត់ផ្គង់ឧបករណ៍សុវត្ថិភាពអាយុជីវិត 88
6.8 ខ្សែម៉ាសដី និងការតភ្ជាប់ 89
6.9 ការការពារការលេចធ្លាយម៉ាស 90
6.10 ឌីសង់ទ័រ 91
6.11 គុណភាពបរិក្ខារ 91
6.12 ខ្សែចម្លង 91
6.13 ប្រព័ន្ធការពាររន្ទះ 92
6.14 ការធ្លាក់តង់ស្យុង 92
6.15 ការធ្វើតេស្តមុខងារប្រព័ន្ធសុវត្ថិភាពអគ្គិភ័យ និងប្រព័ន្ធពន្លត់អគ្គិភ័យ 93
6.16 សំណួរដែលត្រូវឆ្លើយមុនពេលចាកចេញពីរោងចក្រ 94
7. ការដាក់កូដពណ៌ទៅតាមប្រភេទហានិភ័យអគារជារួម 95
7.1 ទិដ្ឋភាពទូទៅ 95
7.2 រោងចក្រដែលមានអគារច្រើន 96
7.3 ការចាត់ថ្នាក់ហានិភ័យគ្រោងអគារ 96
7.4 ចំណាត់ថ្នាក់ហានិភ័យអគ្គិភ័យ 97
7.5 ការចាត់ថ្នាក់ហានិភ័យអគ្គិសនី 99
8 របាយការណ៍វាយតម្លៃសុវត្ថិភាពបឋម 101
8.1 ទិដ្ឋភាពទូទៅ 101
8.2 របាយការណ៍វាយតម្លៃសុវត្ថិភាពគ្រោងអគារ 101
8.3 របាយការណ៍វាយតម្លៃសុវត្ថិភាពអគ្គិភ័យ 107
8.4 របាយការណ៍វាយតម្លៃសុវត្ថិភាពអគ្គិសនី 136

1 សេចក្តីផ្តើម

1.1 គោលបំណង និងអ្នកអានគោលដៅ

ឯកសារនេះចែងអំពីវិធីសាស្ត្រក្នុងការអនុវត្ត និងការរាយការណ៍ស្តីពីការវាយតម្លៃសុវត្ថិភាពបឋមទៅតាមរោងចក្រកាត់ដេរសម្លៀកបំពាក់ស្រាប់ (RMG) សម្លៀកបំពាក់ ស្បែកជើង កាបូប និងគ្រឿងបន្សំសម្រាប់គម្រោង LABS Initiative នៅកម្ពុជា។

វិធីសាស្ត្រនេះត្រូវបានរៀបចំឡើងដោយ LABS Foundation សម្រាប់គម្រោង LABS Initiative សម្រាប់ការប្រើប្រាស់នៅតាមរោងចក្របុត្រសម្ព័ន្ធ។

ភាគីពាក់ព័ន្ធនឹងឯកសារនេះរួមមាន៖

- ម្ចាស់អគាររោងចក្រ និងអ្នកគ្រប់គ្រងដែលទទួលខុសត្រូវចំពោះសុវត្ថិភាពអគារនៅក្នុងរោងចក្របុត្រសម្ព័ន្ធរបស់ LABS
- អ្នកជំនាញផ្នែកវិស្វកម្មដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ និងក្រុមហ៊ុនប្រឹក្សាយោបល់ ដែលចូលរួមក្នុងការរៀបចំ និងផ្ញើរបាយការណ៍វាយតម្លៃសុវត្ថិភាពបឋម
- អ្នកជំនាញផ្នែកវិស្វកម្មដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ និងអ្នកប្រឹក្សាយោបល់ដែលចូលរួមក្នុងការបណ្តុះបណ្តាល ការធានាគុណភាព/ការត្រួតពិនិត្យគុណភាព (QA/QC) នៃកម្មវិធីវាយតម្លៃសុវត្ថិភាពបឋម
- បុគ្គលិកបច្ចេកទេស/វិស្វកម្មដែលមានតួនាទីមើលការខុសត្រូវ និងត្រួតពិនិត្យនៅក្នុង LABS
- បុគ្គលិកបច្ចេកទេស/វិស្វកម្មដែលមានតួនាទីមើលការខុសត្រូវ និងត្រួតពិនិត្យលើផលិតផលដែលជាសមាជិករបស់ LABS

អ្នកអានគួរកត់សម្គាល់នូវផ្នែកសំខាន់ៗនៃឯកសារនេះដូចខាងក្រោម៖

ជំពូកទី 1៖ សេចក្តីផ្តើម - អ្នកអានទាំងអស់

ជំពូកទី 2៖ ការរៀបចំមុនការវាយតម្លៃ - អ្នកអានទាំងអស់

ជំពូកទី 3៖ វិធីសាស្ត្រវាយតម្លៃទូទៅ – អ្នកអានទាំងអស់

ជំពូកទី 4៖ វិធីសាស្ត្រវាយតម្លៃសំណង់ – អ្នកអានដែលត្រូវការព័ត៌មានលម្អិតស្តីពីការវាយតម្លៃសំណង់

ជំពូកទី 5៖ វិធីសាស្ត្រវាយតម្លៃអគ្គិភ័យ - អ្នកអានដែលត្រូវការព័ត៌មានលម្អិតស្តីពីការវាយតម្លៃអគ្គិភ័យ

ជំពូកទី 6៖ វិធីសាស្ត្រវាយតម្លៃអគ្គិសនី - អ្នកអានដែលត្រូវការព័ត៌មានលម្អិតស្តីពីការវាយតម្លៃអគ្គិសនី

ជំពូកទី 7៖ ការចាត់ថ្នាក់ជារួមតាមរោងចក្រ – អ្នកអានទាំងអស់

ជំពូកទី 8៖ របាយការណ៍វាយតម្លៃសុវត្ថិភាពបឋម – អ្នកអានទាំងអស់ ផ្នែកដាច់ដោយឡែកសម្រាប់របាយការណ៍នីមួយៗនៃសំណង់ អគ្គភ័យ និងអគ្គិសនី

គោលបំណងនៃឯកសារនេះគឺដើម្បី៖

- រៀបចំដំណើរការដែលអាចអនុវត្តបានទូទាំងប្រទេសសម្រាប់ការវាយតម្លៃអគាររោងចក្រ សម្លៀកបំពាក់ស្រាប់ (RMG) សម្លៀកបំពាក់ ស្បែកជើង កាបូប និងគ្រឿងបន្សំដែលមានស្រាប់ស្របតាមការអនុវត្តជាអន្តរជាតិល្អបំផុត និងស្របតាមស្មារតី និងគោលបំណងនៃការដាក់ឲ្យដំណាក់កាលសំណង់/បទប្បញ្ញត្តិស្តីពីសំណង់កម្ពុជា។
- ផ្តល់ការណែនាំទូទៅចំពោះដំណើរការវាយតម្លៃសុវត្ថិភាពបឋម។
- ជួយក្នុងការរៀបចំចាត់ចែងវិសាលភាពការងារដែលសមស្រប និងមានសង្គតិភាពពីក្រុមហ៊ុនប្រឹក្សាយោបល់ផ្នែកវិស្វកម្មដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់
- ផ្តល់ការណែនាំអំពីសកម្មភាពមុនការវាយតម្លៃ ដើម្បីសម្រួលដល់ការអនុវត្តវិធីសាស្ត្រប្រកបដោយជោគជ័យ
- ផ្តល់ការណែនាំអំពីលក្ខណៈនៃការវាយតម្លៃដែលត្រូវការនៅតាមរោងចក្រដើម្បីធានាថាការវាយតម្លៃសុវត្ថិភាពបឋមត្រូវបានអនុវត្ត និងចងក្រងជាឯកសារក្នុងលក្ខណៈស្របគ្នា។
- ផ្តល់ដំបូន្មាន និងការណែនាំទូទៅលើការវាយតម្លៃដែលពាក់ព័ន្ធ និងការត្រួតពិនិត្យគំនូសប្លង់ដែលចាំបាច់ ដោយធានាថា លទ្ធផលនៃរបាយការណ៍ទាំងនេះមានភាពរឹងមាំ និងសមស្របតាមលក្ខណៈបច្ចេកទេស។
- ផ្តល់ការណែនាំអំពីការរៀបចំការវាយតម្លៃសុវត្ថិភាពបឋមក្នុងលក្ខណៈច្បាស់លាស់ និងស្របគ្នា ជាមួយនឹងការចាត់ថ្នាក់តាមស្តង់ដារនៃលទ្ធផលដែលបានរកឃើញ។

1.2 បទដ្ឋាននៃគម្រោង LABS Initiative

គោលបំណងចម្បងគម្រោង LABS Initiative គឺដើម្បីលើកកម្ពស់សុវត្ថិភាពអាយុជីវិតរបស់កម្មករក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ស្រាប់ (RMG) សម្លៀកបំពាក់ ស្បែកជើង កាបូប និងគ្រឿងបន្សំអន្តរជាតិ។ ចំណុចសំខាន់ក្នុងការសម្រេចបាននូវគោលបំណងនេះគឺការកែលម្អសុវត្ថិភាពនៃរចនាសម្ព័ន្ធសំណង់ អគ្គិភ័យ និងអគ្គិសនីនៃរោងចក្រកាត់ដេរសម្លៀកបំពាក់ស្រាប់ (RMG) សម្លៀកបំពាក់ ស្បែកជើង កាបូប និងគ្រឿងបន្សំ។ ស្តង់ដារគម្រោង LABS Initiative សម្រាប់សុវត្ថិភាពអគ្គិភ័យ អគ្គិសនី និងសំណង់នៅក្នុងវិស័យ RMG សម្លៀកបំពាក់ ស្បែកជើង កាបូប និងគ្រឿងបន្សំ នឹង

ជួយដល់ការកែលម្អបញ្ហាទាំងនោះ ហើយនឹងរួមចំណែកធ្វើឱ្យវិស័យកាត់ដេរកាន់តែមានសុវត្ថិភាពជាងមុនសម្រាប់កម្មករ។

គោលបំណងសំខាន់នៃស្តង់ដារនេះ គឺដើម្បីដោះស្រាយបញ្ហាសុវត្ថិភាពអាយុជីវិតដ៏សំខាន់នៅក្នុងរោងចក្រកាត់ដេរសម្លៀកបំពាក់ស្រាប់ (RMG) សម្លៀកបំពាក់ ស្បែកជើង កាបូប និងគ្រឿងបន្សំ។ វាជាស្តង់ដារអប្បបរមាសម្រាប់រោងចក្រ RMG សម្លៀកបំពាក់ ស្បែកជើង កាបូប និងគ្រឿងបន្សំ ដែលត្រូវបានរៀបចំឡើងដើម្បីដោះស្រាយបញ្ហាទាំងនោះដែលបង្កហានិភ័យធំបំផុតដល់សុវត្ថិភាពអាយុជីវិតរបស់កម្មករ។ គំនិតផ្តួចផ្តើមនេះគឺផ្អែកលើការអនុវត្តល្អបំផុតជាអន្តរជាតិសម្រាប់ការវាយតម្លៃពីសុវត្ថិភាពអាយុជីវិត វិស្វកម្មអគ្គិភ័យ អគ្គិសនី និងសំណង់ដែលមានស្រាប់។ ការអនុលោមតាមស្តង់ដារនេះ មិនអនុលោមតាមក្រមជាតិ ស្តង់ដារ ឬតម្រូវការច្បាប់ដែលអាចយកជាការបាន។

1.3 ការវាយតម្លៃសុវត្ថិភាពបឋម

សមាសធាតុសំខាន់នៃស្តង់ដារនេះ គឺជាលក្ខខណ្ឌតម្រូវក្នុងការវាយតម្លៃបឋមនៃរោងចក្រនីមួយៗ ដែលជាផ្នែកមួយនៃគម្រោងគំនិតផ្តួចផ្តើម LABS ដែលជាជំហានដំបូងនៅក្នុងកម្មវិធីដ៏ទូលំទូលាយនៃការកែលម្អសុវត្ថិភាពអាយុជីវិតសម្រាប់កម្មករ។ ទាំងនេះត្រូវបានហៅថា ការវាយតម្លៃសុវត្ថិភាពបឋម ដែលគ្របដណ្តប់លើរចនាសម្ព័ន្ធសំណង់ អគ្គិភ័យ និងអគ្គិសនី។

ចំណុចស្តីពីសុវត្ថិភាពអាយុជីវិតរបស់រោងចក្រនីមួយៗ។ មានលក្ខណៈពិសេសសំខាន់ៗមួយចំនួននៃការវាយតម្លៃសុវត្ថិភាពបឋមទាំងនេះ ដែលត្រូវបានរៀបចំឡើងដើម្បី៖

- ភាពហ័ស - ដើម្បីអនុញ្ញាតឱ្យធ្វើការត្រួតពិនិត្យលើចំនួនរោងចក្រឱ្យបានច្រើនច្រើនជាអតិបរមាក្នុងរយៈពេលដ៏ខ្លី។ ក្នុងន័យនេះ ព័ត៌មានបឋមពាក់ព័ន្ធដែលមានគុណភាពល្អត្រូវបានផ្តល់ដោយវិស្វករ/អ្នកវាយតម្លៃដែលមានសមត្ថភាពដែលជាជំហានដំបូងក្នុងកម្មវិធីដែលត្រូវបានផ្តល់អាទិភាពលើព័ត៌មានដែលមានភាពត្រឹមត្រូវខ្ពស់ និងលម្អិត ដែលត្រូវការពេលវេលា និងធនធានច្រើនក្នុងការរៀបចំ។
- ត្រូវមិនមានការបំផ្លិចបំផ្លាញ – គេមិនតម្រូវឱ្យមានការធ្វើតេស្តបែបបំផ្លិចបំផ្លាញ ឬដែលប៉ាល់ដែលមិនជាការចាំបាច់ និងចំណាយពេលច្រើនទៀតនោះ
- កំណត់បញ្ហាសំខាន់ៗពាក់ព័ន្ធសុវត្ថិភាពសំណង់ អគ្គិភ័យ និងអគ្គិសនីដែលមាននៅតាមរោងចក្រទាំងអស់

- ផ្តល់អាទិភាពដល់សកម្មភាពដែលត្រូវការដើម្បីដោះស្រាយបញ្ហាដែលបានកំណត់រួចហើយ
- ចាត់វិធានការតាមពេលវេលាកំណត់ ដើម្បីជួយសម្រួលដល់យុទ្ធសាស្ត្រតាមដានឱ្យបានច្បាស់លាស់។

1.4 វិធីសាស្ត្រ និងការអនុវត្តកម្មវិធី

វិធីសាស្ត្រវាយតម្លៃបឋមនេះត្រូវបានរៀបចំឡើង ដើម្បីផ្តល់ការណែនាំច្បាស់លាស់អំពីរបៀបធ្វើការវាយតម្លៃសុវត្ថិភាពបឋមនៅក្នុងប្រទេសកម្ពុជាដែលជាជំហានដំបូងនៅក្នុងកម្មវិធីនេះ។ ការអនុវត្តការវាយតម្លៃសុវត្ថិភាពបឋម តម្រូវឱ្យមានសមាសធាតុដូចខាងក្រោម បន្ថែមពីលើឯកសារវិធីសាស្ត្រនេះ៖

- បទបង្ហាញអំពីវិធីសាស្ត្រ
- ការបណ្តុះបណ្តាលអ្នកប្រឹក្សាយោបល់/អ្នកវាយតម្លៃពាក់ព័ន្ធ
- បន្តធ្វើការធានាគុណភាព/ការត្រួតពិនិត្យគុណភាព (QA/QC)

1.5 តម្រូវការកម្លាំងពលកម្មតាមការប៉ាន់ស្មាន

ជាធម្មតា ការចុះពិនិត្យរោងចក្រនឹងត្រូវការមនុស្សម្នាក់ក្នុងមួយថ្ងៃក្នុងមួយវិញ្ញាសារ។ ចំណែកការរាយការណ៍វិញ ជាធម្មតានឹងត្រូវការមនុស្ស 0.5-1 នាក់ / ថ្ងៃក្នុងមួយវិញ្ញាសា។

1.6 គំនូសតាង

រូបភាពទី 1៖ តារាងលំហូរការវាយតម្លៃសុវត្ថិភាពបឋម



1.7 សេចក្តីប្រកាសមិនទទួលខុសត្រូវ

ការណែនាំនេះត្រូវបានរៀបចំឡើងដោយ Archetype Group ក្នុងគោលបំណងធ្វើការវាយតម្លៃសុវត្ថិភាពបឋមនៅក្នុងប្រទេសកម្ពុជាសម្រាប់គម្រោង LABS Initiative។ ការណែនាំត្រូវបានបកស្រាយ និងតម្រូវទៅតាមរោងចក្រជាក់លាក់ដោយអ្នកជំនាញដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ដែលស្គាល់អំពីបរិបទ និងមានបទពិសោធន៍អំពីសំណង់អគារដែលមានស្រាប់។ អ្នកជំនាញដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ដែលត្រូវបានតែងតាំងត្រូវទទួលខុសត្រូវទាំងស្រុងសម្រាប់ការងាររបស់ពួកគេ ដោយឡែក Archetype Group នឹងមិនទទួលខុសត្រូវចំពោះរបៀបដែលការណែនាំនេះត្រូវបានយកទៅធ្វើការបកស្រាយ និងអនុវត្តនោះទេ។

2 ការរៀបចំមុនការវាយតម្លៃ

2.1 ទំនាក់ទំនងរោងចក្រ និងកាលវិភាគនៃការវាយតម្លៃ

គម្រោង LABS Initiative នឹងទទួលខុសត្រូវលើការកំណត់អាទិភាពបញ្ជីឈ្មោះ និងចាប់ផ្តើមទំនាក់ទំនងជាមួយរោងចក្រ។ ការងារនេះនឹងរួមមាន ការផ្តល់ព័ត៌មានសង្ខេបដល់អ្នកគ្រប់គ្រងរោងចក្រស្តីពីគោលបំណងនៃការចុះមកពិនិត្យមើល និងតម្រូវការរបស់ពួកគេសម្រាប់ការសម្របសម្រួលការវាយតម្លៃ រួមទាំងការផ្តល់សិទ្ធិចេញចូលទៅគ្រប់កន្លែងទាំងអស់នៃអគារ។
បន្ទាប់មកក្រុមហ៊ុនវាយតម្លៃនឹងតាមដានដើម្បីកំណត់ពេលនៃការចុះវាយតម្លៃ។ ក្នុងការវាយតម្លៃតាមកាលវិភាគគ្រោងទុកនេះ មានការណែនាំឱ្យអ្នកវាយតម្លៃធ្វើការងាររបស់ខ្លួនឈរលើមូលដ្ឋានខាងក្រោម (ឬស្រដៀងគ្នា)។

ថ្ងៃទី 1	ថ្ងៃទី 2	ថ្ងៃទី 3	ថ្ងៃទី 4	ថ្ងៃទី 5	ថ្ងៃទី 6
ការវាយតម្លៃ	ការវាយតម្លៃ	របាយការណ៍	ការវាយតម្លៃ	ការវាយតម្លៃ	របាយការណ៍

2.2 កម្រងសំណួរមុនការវាយតម្លៃ

ក្រុមហ៊ុនវាយតម្លៃនឹងចេញកម្រងសំណួរមុនការវាយតម្លៃ បញ្ជីត្រួតពិនិត្យឯកសារ និងការណែនាំអំពីរូបភាពសកម្មភាពដល់រោងចក្រនីមួយៗសម្រាប់ការបំពេញ ហើយផ្ញើទៅក្រុមហ៊ុនវាយតម្លៃវិញក្នុងរយៈពីរសប្តាហ៍មុនការវាយតម្លៃ។
នៅពេលបំពេញរួច កម្រងសំណួរនេះផ្តល់ព័ត៌មានមូលដ្ឋានអំពីរោងចក្រ រួមទាំងចំនួនអគារ ទំហំអគារនីមួយៗ និងព័ត៌មានលម្អិតអំពីលិខិតអនុញ្ញាតសាងសង់ជាដើម។ បញ្ជីត្រួតពិនិត្យមុនការវាយតម្លៃនេះជូនជាដំណឹងដល់អ្នកគ្រប់គ្រងរោងចក្រអំពីឯកសារសាងសង់ដែលគេរំពឹងថា វានឹងផ្តល់ឱ្យក្រុមការងារវាយតម្លៃក្នុងអំឡុងពេលសម្ភាសន៍អ្នកគ្រប់គ្រងរោងចក្រដែលធ្វើឡើងនៅពេលចាប់ផ្តើមធ្វើការវាយតម្លៃ។
សូមមើលឧបសម្ព័ន្ធ A1 សម្រាប់ព័ត៌មានលម្អិត។

2.3 ការរៀបចំផែនការវាយតម្លៃ

មុនពេលចេញដំណើរទៅកាន់រោងចក្រ ក្រុមការងារវាយតម្លៃត្រូវប្រាកដថា ពួកគេបានទទួលបានកម្រងសំណួរ ហើយបានពិនិត្យមើលកម្រងសំណួរមុនការវាយតម្លៃដែលបានបំពេញរួចនេះ។

ព័ត៌មានទាំងនោះ ដូចជា ទំហំអគារ និងចំនួនអគារនៅនឹងកន្លែងនឹងត្រូវបានបង្ហាញ ដែលនឹងជួយបង្កើតផែនការសម្រាប់ការវាយតម្លៃ។ សូមចំណាំថា ព័ត៌មានមួយចំនួនដែលដាក់បញ្ចូលក្នុងកម្រងសំណួរនោះ អាចមិនត្រឹមត្រូវ – ជាន់ទាំងអស់នៃអគារ ឬអគារខ្លួនឯង ជារឿយៗមិនត្រូវបានដាក់បញ្ចូលនោះទេ។

ប្រសិនបើទីតាំងពិតប្រាកដរបស់រោងចក្រត្រូវបានគេស្គាល់នោះ ត្រូវពិនិត្យមើលកន្លែងនេះលើ Google Maps ដើម្បីទទួលបានព័ត៌មានបន្ថែមមួយចំនួនជាមុន។ គេក៏អាចប្រើរូបភាពនៅលើ Google Earth ដើម្បីពិនិត្យមើលពីដំណាក់កាលសាងសង់ផងដែរ។ ប្រសិនបើកម្រងសំណួរមុនការវាយតម្លៃនេះបង្ហាញថា កន្លែងនោះមានអគារមួយចំនួន ត្រូវពិនិត្យទៅលើវិសាលភាពនៃការវាយតម្លៃដែលអាចផ្តល់ឱ្យដោយសមហេតុផលក្នុងថ្ងៃវាយតម្លៃបាន ឧ. ត្រូវការរយៈពេលពីរថ្ងៃជាដើម។ មតិដំបូងអំពីវិសាលភាពនៃការវាយតម្លៃនេះត្រូវបានបញ្ជាក់ដោយអ្នកវាយតម្លៃក្នុងអំឡុងពេលកិច្ចប្រជុំដំបូងនៅរោងចក្រ ឬប្រហែលជានៅពេលដែលការវាយតម្លៃកំពុងដំណើរការ ហើយបន្ទាប់មកត្រូវកំណត់ពេលវេលាជាក់ស្តែង។ អាទិភាពគឺត្រូវធ្វើការវាយតម្លៃអគារដែលមានកម្មករច្រើនស្នាក់នៅជាមុនសិនដែលឆ្លុះបញ្ចាំងពីការផ្តោតការយកចិត្តទុកដាក់លើសុវត្ថិភាពអាយុជីវិតនៃកម្មវិធីវាយតម្លៃនេះ។ ប្រសិនបើពេលវេលាអំណោយផល អគាររោងចក្រ/បរិក្ខារដែលមានកម្ពស់ទាប ក៏អាចត្រូវបានវាយតម្លៃផងដែរ ដោយការដើរឆ្លងកាត់ដោយរហ័សដើម្បីរកមើលស្ថានភាពដែលទាក់ទងនឹងគ្រោះថ្នាក់ដែលនឹងកើតឡើងដល់មនុស្សម្នាផងដែរ។

3 វិធីសាស្ត្រវាយតម្លៃទូទៅ

3.1 ទិដ្ឋភាពទូទៅ

គោលបំណងនៃផ្នែកនេះគឺដើម្បីដាក់ចេញនូវវិធីសាស្ត្រវាយតម្លៃដែលបានស្នើឡើងសម្រាប់ការវាយតម្លៃអំពីសុវត្ថិភាពបឋមទាក់ទង សំណង់ អគ្គិភ័យ និងអគ្គិសនីរបស់ LABS Initiative នៅក្នុងប្រទេសកម្ពុជា។ ការកំណត់អំពីបទពិសោធន៍ដែលត្រូវការរបស់ក្រុមការងារវាយតម្លៃត្រូវបានផ្តល់ជូន ហើយការពិពណ៌នាអំពីរបៀបអនុវត្តការវាយតម្លៃដែលអាចមើលឃើញផ្ទាល់ភ្នែកយ៉ាងឆាប់រហ័សត្រូវបានគូសបញ្ជាក់ត្រួសៗផងដែរ។

វិធីសាស្ត្រនេះត្រូវបានរៀបចំឡើងដើម្បីឆ្លើយតបទៅនឹងការវាយតម្លៃដែលត្រូវបានអនុវត្តទាំងការវាយតម្លៃវិន័យបុគ្គល (ឧ. ការវាយតម្លៃរចនាសម្ព័ន្ធ អគ្គិភ័យ ឬអគ្គិសនី) ឬសម្រាប់ការវាយតម្លៃមួយផ្នែក ឬទាំងអស់ដែលត្រូវអនុវត្តក្នុងពេលដំណាលគ្នា។ ផ្នែកនេះរួមបញ្ចូលទាំងទិដ្ឋភាពវិធីសាស្ត្រទាំងអស់ដែលជាចំណុចទូទៅនៅគ្រប់ផ្នែកទាំងអស់។ ផ្នែកបន្ថែមនៃវិធីសាស្ត្រនេះពិពណ៌នាអំពីបញ្ហាជាក់លាក់ដែលត្រូវយកមកពិចារណាក្នុងអំឡុងពេលវាយតម្លៃ និងក្រោយការវាយតម្លៃរួច។ ថ្ងៃចុះវាយតម្លៃត្រូវបានរៀបរាប់ជាបន្តបន្ទាប់តាមចំណងជើងខាងក្រោម៖

- ការរៀបចំមុនការវាយតម្លៃ
- ថ្ងៃចុះវាយតម្លៃរោងចក្រ
- ការណែនាំខ្លួនដល់អ្នកគ្រប់គ្រងរោងចក្រ
- សម្ភាសអ្នកគ្រប់គ្រងរោងចក្រ
- ការវាយតម្លៃអគារ (ផ្នែកខាងក្រៅ និងខាងក្នុង)
- ការធ្វើតេស្ត
- កិច្ចប្រជុំបញ្ចប់
- ការប្រគល់ និងការពិនិត្យរបាយការណ៍សង្ខេបរបស់ក្រុមការងារ

បុគ្គលិក និងគុណវុឌ្ឍិរបស់ក្រុមការងារវាយតម្លៃ

ជាទូទៅ រោងចក្រភាគច្រើនក្នុងប្រទេសកម្ពុជា ត្រូវបានវាយតម្លៃដោយក្រុមការងារដូចខាងក្រោម៖ **រចនាសម្ព័ន្ធ៖** គុណវុឌ្ឍិ និងបទពិសោធន៍អប្បបរមារបស់វិស្វករជាន់ខ្ពស់ម្នាក់ៗដែលត្រូវបានតែងតាំងជាអ្នកប្រឹក្សាយោបល់ផ្នែកវិស្វកម្មសំណង់មានលក្ខណសម្បត្តិគ្រប់គ្រាន់ (QSEC) ត្រូវមានដូចខាងក្រោម៖

- ត្រូវមានបរិញ្ញាបត្រផ្នែកវិស្វកម្មសំណង់ស៊ីវិលពីសាកលវិទ្យាល័យដែលទទួលស្គាល់ដោយវិទ្យាស្ថានជាតិវិស្វកម្ម ឬគុណវុឌ្ឍិវិជ្ជាជីវៈអន្តរជាតិដែលមានតម្លៃស្មើ។
- ត្រូវមានបទពិសោធន៍ផ្នែកគំនូសប្លង់អគារយ៉ាងតិច 10 ឆ្នាំ ឬបទពិសោធន៍ក្នុងការអនុវត្តការវាយតម្លៃអគារដែលមានស្រាប់។
- ត្រូវមានអាជ្ញាប័ណ្ណវិស្វករវិជ្ជាជីវៈដែលមានសុពលភាពក្នុងផ្នែកវិស្វកម្មសំណង់ស៊ីវិល និងឧស្សាហកម្ម ដែលចេញដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ គុណវុឌ្ឍិអន្តរជាតិដែលមានតម្លៃស្មើ ដូចជា សមាជិកភាពនៃស្ថាប័នវិស្វករសំណង់ ក៏នឹងត្រូវបានទទួលស្គាល់ថាជាការបំពេញតាមលក្ខខណ្ឌតម្រូវនេះតាមរយៈបទពិសោធន៍នៃការវាយតម្លៃអគារដែលមានស្រាប់យ៉ាងហោចណាស់បីក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ។
- អ្នកវាយតម្លៃត្រូវតែមានសមត្ថភាពក្នុងការអនុវត្តការងារដូចខាងក្រោម៖
- អនុវត្តការវាយតម្លៃអគារដែលមានស្រាប់ (ផ្ទុយពីសវនកម្ម) ដើម្បីឈានទៅដល់ការសម្រេចចិត្តផ្អែកលើការវិនិច្ឆ័យលើស្ថានភាពសំណង់ទាំងមូលនៃអគារ។ ការអនុវត្តនេះទាមទារទាំងការវិភាគបែបបរិមាណវិស័យ និងគុណវិស័យ
- អនុវត្តការវាយតម្លៃដែលមើលឃើញផ្ទាល់ភ្នែកនៃអគារដែលមានស្រាប់ និងអាចធ្វើការវិភាគរកមូលហេតុ និងផលប៉ះពាល់ដែលអាចកើតមានចំណុចខ្វះខាតនៃសំណង់ជាដើម
- រៀបចំការបែបចែកបន្ទុកលើសសរដែលផ្ទុកយ៉ាងធ្ងន់ វាយតម្លៃបន្ទុកដែលមានស្រាប់ និងរៀបចំការត្រួតពិនិត្យមើលសមត្ថភាពលើគ្រឿងបង្គុំសំណង់ (structural elements) ដែលមានស្រាប់
- កំណត់ដំណោះស្រាយគ្រោងជាគោលការណ៍ចំពោះបញ្ហាសំណង់ដែលបានបង្ហាញឱ្យឃើញច្បាស់ក្នុងអំឡុងពេលវាយតម្លៃ
- ការរៀបចំរបាយការណ៍សង្ខេប និងជាលាយលក្ខណ៍អក្សរដែលសង្ខេបច្បាស់ៗអំពីបញ្ហា សំខាន់ៗដែលបានកំណត់ក្នុងអំឡុងពេលវាយតម្លៃ

លក្ខខណ្ឌតម្រូវការទាំងនេះគឺដើម្បីធានាថា QSEC មានលក្ខណសម្បត្តិគ្រប់គ្រាន់ក្នុងការរៀបចំត្រួតពិនិត្យ អនុម័ត និងបញ្ជាក់របាយការណ៍វាយតម្លៃសុវត្ថិភាពសំណង់បឋមបាន។ ដើម្បីជៀសវាងមន្ទិលសង្ស័យ វិញ្ញាបនបត្រត្រូវមានត្រាក្រុមហ៊ុនផ្លូវការពីក្រុមហ៊ុនវាយតម្លៃ និងហត្ថលេខារបស់ QSEC ដែលនឹងធ្វើការទទួលខុសត្រូវចំពោះរបាយការណ៍អគារដែលមានស្រាប់។

ក្នុងករណីដែលសំណង់ RC ច្រើនជាន់លើសពីពីរជាន់ វិស្វករសំណង់ទីពីរអាចត្រូវបានដាក់បញ្ចូលនៅក្នុងក្រុមការងារនេះ។ គុណវុឌ្ឍិរបស់វិស្វករគាំទ្រសំណង់នេះ មានដូចខាងក្រោម៖

- ត្រូវមានបរិញ្ញាបត្រផ្នែកវិស្វកម្មសំណង់ស៊ីវិលពីសាកលវិទ្យាល័យដែលទទួលស្គាល់ដោយក្រុមវិស្វករក្នុងប្រទេសកម្ពុជា ឬគុណវុឌ្ឍិវិជ្ជាជីវៈអន្តរជាតិដែលមានតម្លៃស្មើ។
- ត្រូវមានបទពិសោធន៍ផ្នែកគំនូសប្លង់សំណង់យ៉ាងតិច 2 ឆ្នាំ
- បទពិសោធន៍នៃការវាយតម្លៃអគារដែលមានស្រាប់យ៉ាងហោចណាស់បីក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ

អគ្គិភ័យ៖ គុណវុឌ្ឍិ និងបទពិសោធន៍អប្បបរមារបស់អ្នកវាយតម្លៃសុវត្ថិភាពអគ្គិភ័យជាន់ខ្ពស់ម្នាក់ៗដែលត្រូវបានតែងតាំងជាអ្នកប្រឹក្សាយោបល់សុវត្ថិភាពអគ្គិភ័យដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ (QFSC) នឹងមានដូចខាងក្រោម៖

- ត្រូវមានបរិញ្ញាបត្រផ្នែកស្ថាបត្យកម្ម ឬសំណង់ស៊ីវិល ឧស្សាហកម្ម មេកានិក ឬអគ្គិសនី ពីសាកលវិទ្យាល័យដែលទទួលស្គាល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ត្រូវមានបទពិសោធន៍ផ្នែកគំនូសប្លង់យ៉ាងតិច 10 ឆ្នាំ ឬបទពិសោធន៍ក្នុងការអនុវត្តការវាយតម្លៃអគារដែលមានស្រាប់ និងស្គាល់ពីគោលការណ៍សុវត្ថិភាពអគ្គិភ័យសំខាន់ៗនៅក្នុងអគារឧស្សាហកម្ម។
- ត្រូវមានអាជ្ញាប័ណ្ណត្រឹមត្រូវសម្រាប់អនុវត្តជាស្ថាបត្យករ ឬវិស្វករ ដែលចេញដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬ
- ត្រូវមានវិញ្ញាបនបត្រផ្នែកការបង្ការ និងការពារអគ្គិភ័យ និងគំនូសប្លង់សុវត្ថិភាពអគ្គិភ័យពីវិទ្យាស្ថានដែលមានការទទួលស្គាល់។
- បទពិសោធន៍នៃការវាយតម្លៃអគារដែលមានស្រាប់យ៉ាងហោចណាស់បីក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ។
- អ្នកវាយតម្លៃសុវត្ថភាពអគ្គិភ័យត្រូវតែមានសមត្ថភាពក្នុងការអនុវត្តការងារដូចខាងក្រោម៖
  - អនុវត្តការវាយតម្លៃអគារដែលមានស្រាប់ (ផ្ទុយពីសវនកម្ម) ដើម្បីឈានទៅដល់ការសម្រេចចិត្តផ្អែកលើការវិនិច្ឆ័យលើស្ថានភាពសុវត្ថិភាពអគ្គិភ័យទាំងមូលនៃអគារ។
  - ការវាយតម្លៃចំនួន ការចែកចាយ និងសកម្មភាពរបស់អ្នករស់នៅក្នុងអគារ និងការវាយតម្លៃថាតើមានមធ្យោបាយនៃការរត់ចេញគ្រប់គ្រាន់ពីគ្រប់កន្លែងទាំងអស់ដើម្បីចាកចេញពីអគារដោយសុវត្ថិភាពនៅពេលមានអគ្គិភ័យដែរឬទេ។
  - ការកំណត់តំបន់នៅក្នុងអគារដែលមានអគ្គិភ័យកើតឡើងថាតើអាចដាក់អ្នករស់ក្នុងអគារនៅក្នុងកន្លែងតែមួយ ឬនៅជាប់គ្នាក្នុងពេលមានហានិភ័យដែលមិនអាចទទួលយកបានមុន

ពេលអាចចេញពីអាគារដែរឬទេ។

- ការកត់សម្គាល់ពីការមាន ប្រភេទ និងការគ្របដណ្តប់នៃប្រព័ន្ធសុវត្ថិភាពអគ្គិភ័យដែលបានផ្តល់ និងការវាយតម្លៃថា តើវាបំពេញបន្ថែមនូវវិធានការតាមគំនូសប្លង់អាគារ ដើម្បីផ្តល់កម្រិតសុវត្ថិភាពគ្រប់គ្រាន់សម្រាប់អ្នករស់ក្នុងអការក្នុងករណីមានអគ្គិភ័យដែរឬទេ។
- ការវាយតម្លៃពីវិធានការពន្លត់អគ្គិភ័យសង្គ្រោះបឋមនៅក្នុងអគារ និងការកំណត់ពីការផ្តល់សេវាពន្លត់អគ្គិភ័យដើម្បីជួយជម្លៀសចេញ ប្រសិនបើចាំបាច់ និងសម្រាប់ការពន្លត់អគ្គិភ័យនៅក្នុងអគារ។
- ការកំណត់ដំណោះស្រាយគ្រោងជាគោលការណ៍ចំពោះកង្វះសុវត្ថិភាពអគ្គិភ័យដែលបានគូសបញ្ជាក់ច្បាស់អំឡុងពេលវាយតម្លៃការរៀបចំរបាយការណ៍សង្ខេប និងជាលាយលក្ខណ៍អក្សរដែលសង្ខេបច្បាស់ៗអំពីបញ្ហាសំខាន់ៗដែលបានកំណត់ក្នុងអំឡុងពេលវាយតម្លៃ

លក្ខខណ្ឌតម្រូវទាំងនេះគឺដើម្បីធានាថា QSEC មានលក្ខណសម្បត្តិគ្រប់គ្រាន់ក្នុងការរៀបចំ ត្រួតពិនិត្យ អនុម័ត និងបញ្ជាក់របាយការណ៍វាយតម្លៃសុវត្ថិភាពអគ្គិភ័យបឋមបាន។ QSEC នឹងចុះហត្ថលេខា និងធ្វើការទទួលខុសត្រូវចំពោះរបាយការណ៍អគារដែលមានស្រាប់។

អគ្គិសនី៖ គុណវុឌ្ឍិ និងបទពិសោធន៍អប្បបរមារបស់វិស្វករជាន់ខ្ពស់ម្នាក់ៗដែលត្រូវបានតែងតាំងជាអ្នកប្រឹក្សាយោបល់វិស្វកម្មអគ្គិសនីដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ (QSEC) ត្រូវមានដូចខាងក្រោម៖

- ត្រូវមានបរិញ្ញាបត្រផ្នែកវិស្វកម្មអគ្គិសនីពីសាកលវិទ្យាល័យដែលទទួលស្គាល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ត្រូវមានបទពិសោធន៍ផ្នែកគំនូសប្លង់អគ្គិសនីយ៉ាងតិច 10 ឆ្នាំ ឬបទពិសោធន៍ក្នុងការអនុវត្តការវាយតម្លៃអគារដែលមានស្រាប់និងស្គាល់ពីគោលការណ៍សុវត្ថិភាពអគ្គភ័យសំខាន់ៗនៅក្នុងអគារឧស្សាហកម្ម។
- ត្រូវមានអាជ្ញាប័ណ្ណត្រឹមត្រូវដើម្បីអនុវត្តការងារជាវិស្វករផ្នែកវិស្វកម្មអគ្គិសនី ដែលចេញដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ត្រូវបទពិសោធន៍នៃការវាយតម្លៃអគារដែលមានស្រាប់យ៉ាងហោចណាស់បីក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ
- អ្នកវាយតម្លៃត្រូវមានសមត្ថភាពក្នុងការអនុវត្តការងារដូចខាងក្រោម៖
  - អនុវត្តការវាយតម្លៃអគារដែលមានស្រាប់(ផ្ទុយពីសវនកម្ម) ដើម្បីឈានទៅដល់ការសម្រេច

ចិត្តផ្អែកលើការវិនិច្ឆ័យលើស្ថានភាពសុវត្ថិភាពអគ្គិសនីទាំងមូលនៃអគារ។ ការងារនេះនឹងទាមទារទាំងការវិភាគបែបបរិមាណវិស័យ និងគុណវិស័យ

- អាន និងស្វែងយល់អំពីគំនូសបន្លង់អគ្គិសនីនិងគំនូសបន្លង់អគារ
- អាចបញ្ជាក់ (នៅកម្រិតខ្ពស់) ថា ឧបករណ៍ដែលបានដំឡើង និងការកំណត់រូបរាងរបស់វាត្រូវគ្នានឹងគំនូរបន្លង់អគ្គិសនី និងគំនូសបន្លង់អគារឬទេ
- អាចកំណត់ពីគំនូរបន្លង់ ប្រសិនបើខ្សែភ្លើងមិនត្រូវបានការពារគ្រប់គ្រាន់ដោយឧបករណ៍ផ្តាច់ចរន្តអគ្គិសនី (ហ្វុយហ្ស៊ីប (fuse), MCBs ជាដើម។ល។)
- អាចកំណត់បានពីការត្រួតពិនិត្យដោយមើលឃើញផ្ទាល់ភ្នែក ប្រសិនបើខ្សែភ្លើងមិនត្រូវបានការពារគ្រប់គ្រាន់ដោយឧបករណ៍ផ្តាច់ចរន្តអគ្គិសនី (ហ្វុយហ្ស៊ីប (fuse), MCBs ជាដើម។ល។)
- អាន និងស្វែងយល់អំពីបែបបទផ្សេងៗនៃការប៉ាន់ស្មានបន្ទុកអគ្គិសនី
- អាចអនុវត្តការបំប្លែងអគ្គិសនី
- ការបំប្លែងរវាង kW -> kVA & A -> kVA ឬ kW
- ពិនិត្យមើលបន្ទុកសុវត្ថិភាពអាយុជីវិតធៀបនឹងសមត្ថភាពម៉ាស៊ីនភ្លើង
- អាចពិពណ៌នាអំពីគោលការណ៍មូលដ្ឋាននៃប្រតិបត្តិការរបស់ម៉ាស៊ីនភ្លើង (ការផ្គត់ផ្គង់ប្រេងឥន្ធនៈ ចំហេះ ការបញ្ចេញកម្តៅ តម្រូវការខ្យល់ចេញចូល)
- អាសចដំណើរការឧបករណ៍វាស់កម្តៅ (thermographic camera) (ការបណ្តុះបណ្តាលដាច់ដោយឡែកអាចត្រូវបានទាមទារដោយអ្នកលក់ឧបករណ៍វាស់កម្តៅ ឬឧបករណ៍ផ្សេងទៀត)។ អាចពិពណ៌នាអំពីរបៀបដែលការបញ្ចេញកម្តៅនៃសម្ភារផ្សេងគ្នាប៉ះពាល់ដល់លទ្ធផល
- អាចពិពណ៌នាអំពីមូលដ្ឋានគ្រឹះនៃប្រព័ន្ធការពារភ្លើងបំភ្លឺតាមស្តង់ដារ LABS។ ដឹងនិងស្វែងយល់ពីភាពខុសគ្នារវាងទ្រុងការពារវិទ្យុសកម្មអេឡិចត្រូម៉ាញេទិក (Faraday Cage) និងប្រភេទផ្សេងទៀតនៃប្រព័ន្ធនានា
- អាចលើកឡើងពីប្រព័ន្ធសុវត្ថិភាពអាយុជីវិតធម្មតាដែលជាធម្មតាត្រូវគេឃើញមាននៅតាមរោងចក្រ ដែលអាចត្រូវការការផ្គត់ផ្គង់ថាមពលបម្រុង

3.1.1 សម្ភារបរិក្ខារ

ក្រុមការងារនីមួយៗគួរតែមានកញ្ចប់ឧបករណ៍វាយតម្លៃដែលមានសម្ភារដូចខាងក្រោម៖

- អាយផេត/ថេប្លេតអាចប្រើបានជាមួយឆ្នាំងសាកឥតខ្សែ និងមានខ្សែ មានស្រោមការពារ

- កាមេរ៉ាឌីជីថល
- ឧបករណ៍ Schmidt hammer
- ឧបករណ៍ស្កេនម៉ាក Hilti PS250 Ferro និងអេក្រង់ (ឬឧបករណ៍ដែលមានតម្លៃស្មើ) ដែលមានសមត្ថភាពផ្តល់នូវអង្កត់ផ្ចិតបេតុងអាមេ (reinforcement bar)។ លទ្ធផលនៃការស្កេន Ferro ត្រូវតែអានឱ្យយល់មុនពេលចេញដំណើរទៅកាន់រោងចក្រ។
- ឧបករណ៍វាស់កម្តៅ (Fluke ឬឧបករណ៍ដែលមានតម្លៃស្មើ)
- ទែម៉ូម៉ែត្រ (វាស់សីតុណ្ហភាពនៅជុំវិញ)
- ដែកត្រសេះ (Geological hammer) និង/ឬពន្លាក
- ស្កុតរុំប្រវែង 5 ម
- ឧបករណ៍វាស់ប្រើកាំរស្មីឡាស៊ែរ
- កែវយឺត
- ពិល
- សម្ភារការសង្គ្រោះបឋម
- សម្ភារការពារសុវត្ថិភាពផ្ទាល់ខ្លួន (PPE) (ស្រោមដៃ វ៉ែនតា របាំងមុខ)
- ក្តារឈ្នួនមានដង្កៀបនៅខាងលើសម្រាប់កៀបក្រដាស់ពេលសរសេរ (Clipboard)
- ដែកចូក (Paint scraper)
- ប្រពាយវាស់
- បន្ទាត់ក្រឹត្យ
- ថ្មម៉ាក AAA
- សម្លៀកបំពាក់ការពារ (Tyvek suit)

3.1.2 ឧបករណ៍អគ្គិសនី

ត្រូវប្រាកដថា ឧបករណ៍ទាំងអស់ត្រូវបានសាកថ្មពេញនៅពេលល្ងាចមុនពេលចុះធ្វើការវាយតម្លៃ។ ពិនិត្យឧបករណ៍វាស់ប្រើកាំរស្មីឡាស៊ែរ ពិល និងឧបករណ៍ផ្សេងទៀតដែលតម្រូវឱ្យមានថ្ម ហើយយកគ្រឿងបន្លាស់ទៅផង ប្រសិនបើចាំបាច់។

3.1.3 អាយផេត/ថេប្លេត

ដើម្បីធានាថា អ្នកមានថាមពលថ្មគ្រប់គ្រាន់សម្រាប់ឧបករណ៍ថេប្លេតណាមួយក្នុងអំឡុងពេលវាយតម្លៃ សូមអនុវត្តតាមការណែនាំទាំងនេះ៖

- ត្រូវប្រាកដថា អ្នកបានសាកថ្មពេញនៅពេលយប់
- បិទ 3G និង Wi-Fi នៅពេលនៅទៅដល់កន្លែង
- បន្ថយកម្រិតពន្លឺអេក្រង់
- ត្រូវប្រាកដថា កម្មវិធីផ្សេងទៀតទាំងអស់ត្រូវបានបិទ (ចុចពីរដងលើប៊ូតុងដើម(home) ដើម្បីមើលកម្មវិធីដែលបានបើក)

ការណែនាំផ្សេងៗទៀតរួមមាន៖

- រៀបចំដំណើរចុះទៅពិនិត្យរោងចក្រមួយថ្ងៃមុនធ្វើការវាយតម្លៃ
- ក្នុងករណីដែលថេប្លេតមិនដំណើរការ ត្រូវកត់ត្រាពីការវាយតម្លៃនៅលើក្រដាសដោយមានថតរូបថតផងដើម្បីផ្តល់ជាភស្តុតាង

3.2 ថ្ងៃចុះវាយតម្លៃនៅរោងចក្រ

3.2.1 ការធ្វើដំណើរ

ក្រុមការងារវាយតម្លៃត្រូវមកដល់រោងចក្រនៅព្រឹកព្រលឹមតាមពេលវេលាដែលបានរៀបចំទុកជាមុនជាមួយអ្នកគ្រប់គ្រងរោងចក្រ។ ត្រូវគិតគូរពីការធ្វើដំណើរ និងស្ថានភាពចរាចរណ៍ក្នុងតំបន់ដើម្បីចាប់ផ្តើមឱ្យបានពីព្រឹកបន្តិចដែលវាមានសារៈសំខាន់ចំពោះការបញ្ចប់ការងារវាយតម្លៃ។ មុនពេលកំណត់ការចេញដំណើរទៅកាន់រោងចក្រ អ្នកវាយតម្លៃត្រូវទទួលខុសត្រូវចំពោះព័ត៌មានលម្អិតក្នុងការទំនាក់ទំនងទៅកាន់បុគ្គលនៅក្នុងរោងចក្រនោះ ដែលអាចទាក់ទងនៅតាមផ្លូវពេលធ្វើដំណើរប្រសិនបើចាំបាច់។

3.2.2 ការមកដល់អាគាររោងចក្រ

ត្រូវធ្វើការសង្កេតមើលបរិវេណអគារមួយភ្លែតសិនមុនពេលអ្នកចូលទៅក្នុងរោងចក្រ។ ពេលមកដល់រោងចក្រ ត្រូវឆ្លៀតមើលទិដ្ឋភាពខាងក្រៅអគារសិន និងប្រមូលព័ត៌មានបឋមខ្លះៗអំពីស្ថានភាព និងការរៀបចំអគារ - សំណង់ថ្មី ការសាងសង់ជាដំណាក់កាល នៅជិតទន្លេ ជាន់ខាងលើកំពុងសាងសង់ ចម្ងាយគម្លាតរវាងអគារ ផ្លូវចូលទៅកាន់អគារ ត្រង់ស្វ៊ែរម៉ាទ័រដែលដាក់ជាប់នឹងបង្គោលខាងក្រៅ ច្រកចេញពេលមានអគ្គិភ័យ។ល។ អ្នកនឹងមានឱកាសបន្ថែមទៀតដើម្បីដើរនៅខាងក្រៅអគារនៅចុង បញ្ចប់នៃការវាយតម្លៃ។ ប៉ុន្តែ ការប្រមូលបានគំនិតដំបូងខ្លះៗនេះមានសារៈសំខាន់ណាស់មុននឹងធ្វើការសម្ភាសន៍អ្នកគ្រប់គ្រងរោងចក្រ។

ពិនិត្យមើលផ្នែកខាងក្រៅមុនពេលចូលក្នុងអគារ ដោយកត់សម្គាល់ពីចំនួនជាន់ ការសាងសង់បន្ថែមលើដំបូល ឬសញ្ញានៃជាន់បន្ថែម។ ប្រហែលជាមានការភាន់ច្រឡំត្រង់ការដាក់ឈ្មោះជាន់ (ជាទូទៅគេហៅជាន់ផ្ទាល់ដីថា "ជាន់ទី 1")។ សម្រាប់ហេតុផលនេះ វាសំខាន់ណាស់ក្នុងការដឹងអំពីចំនួនជាន់ មុនពេលពិភាក្សាជាមួយអ្នកគ្រប់គ្រងរោងចក្រ។ វាក៏មានប្រយោជន៍ផងដែរក្នុងការកត់ត្រាឱ្យបានច្រើនអំពីអគារនៅពេលអ្នកដើរកាត់ទៅកាន់បន្ទប់ប្រជុំ។

3.3 ការណែនាំដល់អ្នកគ្រប់គ្រងរោងចក្រ

នៅពេលមកដល់រោងចក្រ និងបន្ទាប់ពីពិនិត្យផ្នែកខាងក្រៅអគារបន្តិចមក ក្រុមការងារវាយតម្លៃនឹងដើរតម្រង់ទៅកាន់កន្លែងការិយាល័យរោងចក្រដោយផ្ទាល់ដើម្បីជួបជាមួយតំណាងអ្នកគ្រប់គ្រងរោងចក្រ។ នេះអាចរាប់បញ្ចូលអ្នកគ្រប់គ្រងរោងចក្រ អ្នកគ្រប់គ្រងផ្នែកអនុលោមភាព និងអាចជាវិស្វករោងចក្រ (ជាធម្មតាមិនមែនជាអ្នកគូសប្លង់អគារដើមឡើយ)។

គួរប្រើប្រាស់នាមប័ណ្ណដើម្បីធ្វើការណែនាំខ្លួន។ វាមានសារៈសំខាន់ក្នុងការកំណត់ថា តើនរណាជាអ្នកទំនាក់ទំនងសំខាន់របស់រោងចក្រទាក់ទងនឹងការងារវាយតម្លៃនេះ។
បន្ទាប់មកត្រូវធ្វើការណែនាំជាផ្លូវការដល់អ្នកគ្រប់គ្រងរោងចក្រដូចខាងក្រោម៖

- ការវាយតម្លៃកំពុងត្រូវបានអនុវត្តក្នុងនាមគំនិតផ្តួចផ្តើម LABS Initiative
- សូមមើលកម្រងសំណួរមុនការវាយតម្លៃ/បញ្ជីត្រួតពិនិត្យនិងស្នើសុំឯកសារពាក់ព័ន្ធទាំងអស់ (ឧ.លិខិតអនុញ្ញាតសាងសង់/គំនូសប្លង់ស្តាបត្យកម្ម/សំណង់/អគ្គិសនី និងរបាយការណ៍ពីគុណភាពដី) ត្រូវបានលើកយកមកពិភាក្សានៅកិច្ចប្រជុំ។ នេះជៀសវាងការពន្យារពេលនៅដំណាក់កាលក្រោយ ដោយសារអ្នកគ្រប់គ្រងរោងចក្រជារឿយៗមិនផ្តល់ឯកសារទេ លុះត្រាតែមានការស្នើសុំ។ បញ្ជាក់អំពីទំហំឯកសារដែលមាន ព្រោះការធ្វើដូចនេះអាចជូនដំណឹងដល់សំណួរតាមដាន។
- ធ្វើការត្រួតពិនិត្យឯកសារនៅដំណាក់កាលចុងក្រោយក្នុងដំណើរការនេះ។ ត្រូវពន្យល់ថាដំណើរការវាយតម្លៃជាសំខាន់ផ្តោតលើការប្រមូល និងការផ្ទៀងផ្ទាត់
- ព័ត៌មាន ការសង្កេតមើលជាក់ស្តែង និងការធ្វើតេស្តមួយចំនួនតាមការកំណត់
- រំលឹកប្រាប់រោងចក្រថា ជំនួយដែលបានស្នើសុំពីមុននឹងត្រូវបានទាមទារសម្រាប់សកម្មភាពដូចខាងក្រោម ដែលពាក់ព័ន្ធនឹង៖

- ការផ្តល់ជាជណ្តើរចេញចូលទៅកាន់កន្លែងនៅទីខ្ពស់
- ការបកការបូកបាយអរចេញចំពោះគ្រឿងបង្គុំសំណង់ដែលបានជ្រើសរើស (Removal of plaster locally to selected structural elements)
- ការបើកគំរបបន្ទះអគ្គិសនីដោយបុគ្គលិកដែលមានសមត្ថភាពសមស្រប
- ការបើកក្បឿងពិតាននៅពេលស្នើសុំ

ត្រូវបញ្ជាក់ប្រាប់អ្នកគ្រប់គ្រងរោងចក្រថា ការសង្កេតដែលបានកត់សម្គាល់ឃើញក្នុងអំឡុងពេលវាយតម្លៃជាធម្មតានឹងមិនត្រូវបានលើកយកមកពិភាក្សាទេ លុះត្រាតែមានការព្រួយបារម្ភអំពីសុវត្ថិភាពធ្ងន់ធ្ងរជាពិសេស។ ការរៀបរាប់សង្ខេបពេញលេញលើការសង្កេត និងបញ្ហាទាំងអស់ដែលបានកត់សម្គាល់ឃើញក្នុងអំឡុងពេលចុះមកពិនិត្យនេះនឹងមិនអាចធ្វើទៅបានទេ។ ប៉ុន្តែ ការរកឃើញអំពីសុវត្ថិភាពសំខាន់ៗមួយចំនួននឹងត្រូវបានពិភាក្សា ប្រសិនបើចាំបាច់។ ព័ត៌មានលម្អិតបន្ថែមត្រូវបានផ្តល់ជូននៅក្នុងចំណុច 3.6 ស្តីពីការបិទកិច្ចប្រជុំ។

- របៀបវារៈសម្រាប់ការវាយតម្លៃត្រូវបានពិពណ៌នាដូចខាងក្រោម៖
  - សម្ភាសអ្នកគ្រប់គ្រងរោងចក្រ - ដំណើរការវាយតម្លៃនឹងរួមបញ្ចូលការពិនិត្យមើលព័ត៌មានមុនធ្វើការវាយតម្លៃ ការសម្ភាសអ្នកគ្រប់គ្រងរោងចក្រ ការពិនិត្យមើលលិខិតអនុញ្ញាតសាងសង់ ការគណនាគំនូសប្លង់ដែលពាក់ព័ន្ធទាំងអស់ ការធ្វើតេស្តសម្ភារនិងប្រព័ន្ធ និងរបាយការណ៍ណាមួយពីការវាយតម្លៃមុនៗជាដើម។
- តម្រូវឱ្យដើរជុំវិញផ្នែកខាងក្រៅអគារ
- ដើរមើលផ្នែកខាងក្នុងនៃអគារ ដោយមានការផ្តល់សិទ្ធិចេញចូលទៅគ្រប់បន្ទប់ និងកន្លែងទំនេរទាំងអស់។ សូមចំណាំថា ត្រូវធ្វើការវាយតម្លៃលើសពីមួយកន្លែង (discipline) ក្រុមការងារវាយតម្លៃនឹងអនុវត្តការងាររបស់ពួកគេដោយឡែកពីគ្នា
- ហើយអ្នកគ្រប់គ្រងរោងចក្រត្រូវផ្តល់ចំនួនមនុស្សពាក់ព័ន្ធដើម្បីរួមដំណើរជាមួយក្រុមការងារវាយតម្លៃ
- អនុវត្តការធ្វើតេស្តតាមតម្រូវការ ពាក់ព័ន្ធនឹងការវាយតម្លៃជាក់លាក់
- កិច្ចប្រជុំបញ្ចប់។

3.3.1 បញ្ជាជាក់លាក់នៃសំណង់សម្រាប់ការណែនាំ

- សម្រាប់អគារបេតុង សូមពន្យល់ថា តាមការអនុញ្ញាតពីអ្នកគ្រប់គ្រងរោងចក្រ គោលបំណងគឺដើម្បីអនុវត្តការធ្វើតេស្តមួយចំនួនលើសសរបេតុងនៅកម្រិតជាន់ដែលទាបបំផុត ពោលគឺជាន់ផ្ទាល់ដី ឬជាន់ក្រោមដី។ សូមពន្យល់ថា ការស្កែន Ferro គឺជាការធ្វើតេស្តដែលមិនមានការ

បំផ្លិចបំផ្លាញនោះទេ ហើយឧបករណ៍ Schmidt Hammer ពាក់ព័ន្ធនឹងការចេញនូវការងារបូកបាយអរ (plasterwork)តែប៉ុណ្ណោះ។

- ស្នើសុំឱ្យផ្តល់ផងដែរនូវរបាយការណ៍គំនូសប្លង់សំណង់ ការគណនា វិញ្ញាបនបត្របញ្ជាក់ពីការធ្វើសេត្តសម្ភារ របាយការណ៍គុណភាពដី និងរបាយការណ៍វាយតម្លៃសំណង់ផ្សេងទៀត។

3.3.2 បញ្ជាជាក់លាក់នៃអគ្គិភ័យសម្រាប់ការណែនាំ

- ត្រូវពន្យល់ថា អ្នកវាយតម្លៃអគ្គិសនី ដូចដែលបានពន្យល់នៅក្នុងកំណត់ត្រាសង្ខេបមុនធ្វើការវាយតម្លៃនឹងអនុវត្តការធ្វើតេស្តកណ្តឹងរោទ៍ពេលមានអគ្គិភ័យ និងការធ្វើតេស្តភ្លើងបំភ្លឺពេលមានគ្រាអាសន្ន។ ការងារនេះនឹងត្រូវបានសម្របសម្រួលជាមួយអ្នកវាយតម្លៃសុវត្ថិភាពអគ្គិភ័យដើម្បីឱ្យគាត់អាចធ្វើជាសាក្សីក្នុងការធ្វើតេស្តនេះផងដែរ។ កំណត់ពីពេលវេលាដែលសមស្របនឹងរោងចក្រ និងកាត់បន្ថយការរំខានសម្រាប់ការអនុវត្តការធ្វើតេស្តទាំងនេះ មុនពេលចាប់ផ្តើមការវាយតម្លៃ
- ស្នើសុំមើលវិញ្ញាបនបត្របញ្ជាក់ពីការធ្វើផែនការរោងចក្រនិងកំណត់ចំណាំពីអ្វីដែលអាជ្ញាធរបានចុះហត្ថលេខាលើនោះ
- ស្នើសុំមើលច្បាប់ចម្លងនៃអាជ្ញាបណ្ណអគ្គិភ័យ និងកំណត់ចំណាំកាលបរិច្ឆេទនៃការចេញចុងក្រោយបំផុត និង រយៈពេលសុពលភាព
- ស្នើសុំឱ្យផ្តល់កំណត់ត្រារបាយការណ៍ត្រួតពិនិត្យរបស់នគរបាលពន្លត់អគ្គិភ័យកាលពីឆ្នាំមុន
- ស្នើសុំឱ្យផ្តល់កំណត់ត្រាការថែទាំសម្រាប់ឧបករណ៍ប្រាប់ពីអគ្គិភ័យ កណ្តឹងរោទ៍ ភ្លើងបំភ្លឺពេលមានគ្រាអាសន្ន និងម៉ាស៊ីនបូមទឹក
- ស្នើសុំឱ្យផ្តល់ឯកសារស្តីពីការហ្វឹកហាត់អំពីសុវត្ថិភាពអគ្គិភ័យ និងការបណ្តុះបណ្តាលផ្សេងទៀត និងកត់ត្រាពីកាលបរិច្ឆេទផង

3.3.3 បញ្ជាជាក់លាក់នៃអគ្គិសនីសម្រាប់ការណែនាំ

- ត្រូវពន្យល់ថា ទូអគ្គិសនីនីមួយៗនឹងត្រូវធ្វើតេស្ត ហើយអ្នកដែលមានជំនាញអគ្គីសនីតម្រូវឱ្យបើកទូរនោះ។ របាំងការពារពន្លឺ និងគម្របទូរគួរតែត្រូវបានដកចេញមុនពេលការវាយតម្លៃ ខណៈពេលដែលទូរនេះត្រូវបានផ្តាច់ចរន្ត (isolated)។ ព័ត៌មានលម្អិតនៃជំនួយដែលទាមទារពីរោងចក្រត្រូវបានដាក់បញ្ចូលនៅក្នុងកំណត់ត្រាសង្ខេបមុនការវាយតម្លៃ។
- ត្រូវពន្យល់ថា ការធ្វើតេស្តសំឡេងរោទ៍ពេលមានអគ្គិភ័យ និងការធ្វើតេស្តភ្លើងបំភ្លឺពេលមាន

អាសន្ននឹងត្រូវបានអនុវត្ត ដូចដែលបានពន្យល់នៅក្នុងកំណត់ត្រាសង្ខេបមុនការវាយតម្លៃ។ ត្រូវកំណត់ពេលវេលាដែលសមស្របនឹងរោងចក្រ និងកាត់បន្ថយការរំខានសម្រាប់ការអនុវត្តការធ្វើតេស្តទាំងនេះ មុនពេលចាប់ផ្តើមការវាយតម្លៃ។

- ស្នើសុំឱ្យផ្តល់កំណត់ត្រាការថែទាំសម្រាប់ឧបករណ៍ត្រង់ស្ទ័រម៉ាទ័រ កុងតាក់ដែលមានតង់ស្យុងទាប និងតង់ស្យុងមធ្យម ម៉ាស៊ីនភ្លើង ការចាប់សញ្ញាអគ្គិភ័យ សំឡេងរោទ៍ ភ្លើងបំភ្លឺពេលមានគ្រោះអាសន្ន និងបំពង់ពន្លត់អគ្គិភ័យ។

3.4 ការសម្ភាសន៍អ្នកគ្រប់គ្រងរោងចក្រ

3.4.1 ព័ត៌មានលម្អិតអំពីរោងចក្រ

នៅដើមដំបូងនៃការសម្ភាសអ្នកគ្រប់គ្រងរោងចក្រ ត្រូវទទួលបានព័ត៌មានអំពីទិដ្ឋភាពទូទៅជាមូលដ្ឋានមួយចំនួនអំពីរោងចក្រ។ ព័ត៌មានទាំងនេះ រួមមាន៖

- ឆ្នាំនៃការបញ្ចប់ការសាងសង់អគារ
- ឈ្មោះ និងមុខងារនៃអគារនីមួយៗ តាមជាន់នីមួយៗ
- ចំនួនកម្មករក្នុងមួយជាន់ ក្នុងមួយអគារ (ប្រហាក់ប្រហែល)
- តើធ្វើការងារប៉ុន្មានវេន?
- តើមានការកែប្រែ/ការផ្លាស់ប្តូរពីមុនមកទេ
- តើមានការព្រួយបារម្ភទាក់ទងនឹងសុវត្ថិភាពដែរឬទេ?

បើទោះជាមានការវាយតម្លៃច្រើនជាងមួយផ្នែកក៏ដោយ ក៏មានការណែនាំឱ្យបំពេញសំណួរទាំងអស់ដែលទាក់ទងនឹងផ្នែកទាំងអស់មុនពេលបំបែកជាផ្នែក។ នៅពេលប្រមូលបាននូវព័ត៌មានមូលដ្ឋានរួចហើយ ផ្នែកទាំងនោះអាចធ្វើដោយឡែកពីគ្នាដើម្បីពិនិត្យមើលឯកសារដែលបានផ្តល់ឱ្យ និងសួរសំណួរបន្តទៅអ្នកគ្រប់គ្រងរោងចក្រ។

3.4.2 ការត្រួតពិនិត្យឯកសារ

ដោយបានទទួលការឆ្លើយតបចំពោះសំណួរ និងបានកត់ត្រាទុក ការត្រួតពិនិត្យផ្ទាល់នៃឯកសារពាក់ព័ន្ធអគារដែលមានស្រាប់ត្រូវបានអនុវត្ត។
ជាធម្មតា ត្រូវពិនិត្យ និងធានាថា មានការយល់ដឹងច្បាស់លាស់អំពីចំណុចខាងក្រោម៖

- ផែនការចុះទៅកាន់ទីតាំងនៃបរិវេណរោងចក្រដែលបង្ហាញពីអគារទាំងអស់

- វិសាលភាពនៃអគារ/ដំណាក់កាលនៃការសាងសង់
- កាលបរិច្ឆេទសាងសង់អគារ និងដំណាក់កាលពាក់ព័ន្ធទាំងអស់
- ឯកសារស្តីពីលិខិតអនុញ្ញាតសាងសង់ – គំនូសប្លង់មូលដ្ឋាន គំនូសប្លង់លម្អិត ឬលិខិតអនុញ្ញាតសាងសង់។ ប្លង់ស្តាបត្យកម្ម គំនូសប្លង់អាជ្ញាប័ណ្ណស្តីពីការត្រួតពិនិត្យរោងចក្រ លិខិតអនុញ្ញាតកាន់កាប់។ តើទាំងនេះខុសពីស្ថានភាពដែលបានសាងសង់/គំនូសប្លង់ដែរឬទេ? តើមានការពង្រីក ឬការបន្ថែមណាមួយនៅលើគំនូសប្លង់ដែលបានអនុញ្ញាតឬទេ? ដែលបានផ្តល់ឱ្យឬទេ?
- ប្លង់ស្តាបត្យកម្ម និងផ្នែកសាងសង់ - តើនេះគឺ គំនូសប្លង់ដើម ឬប្លង់គូរក្រោយអាគារសង់រួច?
- តើពួកគេឃើញមានការពង្រីក និងការបន្ថែមដែរឬទេ?
- តើគំនូសប្លង់ទាំងអស់បង្ហាញព័ត៌មានស្របគ្នាដែរឬទេ?
- ឯកសារទាក់ទងនឹងការត្រួតពិនិត្យអគារដែលធ្វើឡើងដោយអាជ្ញាធរ ការរៀបចំផែនការនៅពេលមានស្ថានភាពអាសន្នរបស់រោងចក្រ និងការបណ្តុះបណ្តាល កំណត់ត្រាថែទាំសម្រាប់ប្រព័ន្ធបច្ចេកទេស និងនីតិវិធីថែទាំ។

ជាទូទៅ រាល់ឯកសារទាំងអស់ត្រូវបញ្ជាក់សុពលភាពត្រឹមត្រូវក្នុងអំឡុងពេលវាយតម្លៃអគារ ប្រសិនបើអាចធ្វើទៅបាន ផ្ទុយពីការពឹងផ្អែកលើឯកសារដែលបានផ្តល់ឱ្យនោះ។

ក្នុងករណីដែលឯកសារមានកំណត់ អ្នកវាយតម្លៃត្រូវសាកល្បង និងបង្កើតគំនូសប្លង់មូលដ្ឋានមួយចំនួន ដើម្បីជួយដោយមានការពន្យល់នៅក្នុងរបាយការណ៍នោះផង។

បញ្ជាជាក់លាក់តាមផ្នែកដែលត្រូវដោះស្រាយមានដូចខាងក្រោម៖

3.4.2.1 សំណង់

- គំនូសប្លង់សំណង់ - តើនេះគឺ គំនូសប្លង់ដើម ឬប្លង់គូរក្រោយអាគារសង់រួច? តើឃើញមានការពង្រីក និងការបន្ថែមដែរឬទេ?
- របាយការណ៍ភូមិសាស្ត្រ/ដី (Geotechnical/Soils) - តើរបាយការណ៍នេះបង្ហាញពីការណែនាំក្នុងការគណនាគ្រឹះអាគារដែរទេ និងពិពណ៌នាអំពីលក្ខណៈនៃស្ថានភាពដីដែរឬទេ?
- ពិនិត្យមើលថា តើរបាយការណ៍បង្ហាញពីការណែនាំក្នុងការគណនាគ្រឹះអាគារត្រូវបានដាក់បញ្ចូលទៅក្នុងគំនូសប្លង់ដែរឬទេ។
- ពិនិត្យមើលរបាយការណ៍គំនូសប្លង់ និងវិញ្ញាបនបត្របញ្ជាក់ពីការធ្វើតេស្តសម្ភារ ប្រសិនបើ

មាន

- ពិនិត្យរបាយការណ៍ស្តីពីការវាយតម្លៃសំណង់ពីមុន ឬលិខិត/វិញ្ញាបនបត្រទាក់ទងនឹងលទ្ធភាពទ្រទ្រង់បន្ទុកសំណង់/ប្រពន្ធ័លំនឹងសំណង់។ ទាំងនេះមានអត្ថប្រយោជន៍ជាពិសេសក្នុងការបង្ហាញឱ្យឃើញពីបញ្ហាជាក់លាក់ដែលយើងត្រូវប្រុងប្រយ័ត្ន។
- ពិនិត្យមើលថា តើមានប្លង់បាតដើម្បីបញ្ជាក់ពីបន្ទុកដែលអាចអនុញ្ញាតបានសម្រាប់ផ្ទាល់ដីដែលមានកំពស់ផុតពីដី (suspended floors) ដែរឬទេ?
- វាមានសារៈសំខាន់ណាស់ក្នុងការត្រួតពិនិត្យត្រួសៗពីកាលបរិច្ឆេទនៅលើឯកសារនីមួយៗ ដើម្បីធានាបាននូវវឌ្ឍនភាពចាប់ពីរបាយការណ៍ភូមិសាស្ត្រ/ដីរហូតដល់គំនូសប្លង់សំណង់ ឆ្នាំនៃការសាងសង់ និងការអនុម័តលើគំនូសប្លង់អនុញ្ញាត។ រូបថតនៃឯកសារពាក់ព័ន្ធទាំងអស់ដែលបានផ្តល់ឱ្យត្រូវធ្វើការកត់ត្រាទុក។

នៅពេលបញ្ចប់ការត្រួតពិនិត្យ វិស្វករសំណង់ត្រូវមានការយល់ដឹងល្អអំពីវិសាលភាពនៃអគារប្រព័ន្ធគ្រឿងបង្គុំសំណង់ ទំហំមុខកាត់គ្រឿងបង្គុំសំណង់សំខាន់ៗ គម្លាតអក្សរអាគារ (grid spacing) ការគណនារបស់បេតុងអាមេរត៍ (design reinforcement) និងលទ្ធផលនៃការវាយតម្លៃសំណង់ពីមុនៗ ឬការធ្វើតេស្តសម្ភារ។

3.4.2.2 សុវត្ថិភាពអគ្គិភ័យ

- គំនូសប្លង់ផលិតកម្មរបស់រោងចក្រ - តើគំនូសប្លង់ទាំងនេះឆ្លុះបញ្ចាំងពីសកម្មភាពនៅក្នុងផ្នែកផ្សេងៗនៃរោងចក្រដែរឬទេ?
- តើគំនូសប្លង់ស្តាបត្យកម្មបង្ហាញយ៉ាងច្បាស់ថា តើផ្នែកណាខ្លះត្រូវបានបំបែកចេញពីការប្រើប្រាស់ផ្សេងទៀត?
- តើចំនួនអ្នកធ្វើការដែលបានបញ្ជាក់នៅក្នុងតំបន់នីមួយៗនៃអគារមានប៉ុន្មាននាក់?
- តើគំនូសប្លង់បង្ហាញគ្រប់ជាន់ រួមទាំង ជាន់ឡៅតឿ ដែលអាចត្រូវបានបន្ថែមបន្ទាប់ពីបញ្ចប់ការសាងសង់ និងការតភ្ជាប់រវាងជាន់ដែរឬទេ?
- កំណត់វត្តមាន ប្រភេទ និងទីតាំងនៃប្រព័ន្ធសុវត្ថិភាពអគ្គិភ័យ ដូចជា ឧបករណ៍ចាប់សញ្ញាអគ្គិភ័យ (fire detection) និងកណ្តឹងរោទ៍ ភ្លើងបំភ្លឺពេលមានស្ថានភាពបន្ទាន់ ក្បាលម៉ាស៊ីនទឹកសម្រាប់ពន្លត់អគ្គិភ័យ (Fire hydrants) បំពង់កទុយោមានក្បាលបាញ់ពន្លត់អគ្គិភ័យ (fire hose reels,) ប្រព័ន្ធទប់ស្កាត់ដោយស្វ័យប្រវត្តិ (ឧ. ឧបករណ៍បាញ់ទឹក) ជាដើម។
- ត្រូវប្រាកដថា ទទួលបានព័ត៌មានអំពីប្រភេទ និងទីតាំងនៃកន្លែងស្តុកជាក់លាក់ណាមួយ

ម៉ាស៊ីនភ្លើង ឡចំហាយទឹក ត្រង់ស្វ័រម៉ាទ័រ កន្លែងស្តុកសារធាតុគីមី និងកន្លែងដែលប្រឈមហានិភ័យអគ្គិភ័យផ្សេងទៀត។

- ពិនិត្យប្រភពផ្គត់ផ្គង់ទឹកសម្រាប់ពន្លត់អគ្គិភ័យ បរិមាណ និងទីតាំងស្តុកទឹក និងទីតាំងបន្ទប់បូមទឹក
- ពិនិត្យរកភ័ស្តុតាងនៃការរៀបចំផែនការគ្រោអាសន្ន និងទំនួលខុសត្រូវក្នុងគ្រោអាសន្ន ការហ្វឹកហាត់ទាក់ទងសុវត្ថិភាពជាប្រចាំ និងការបណ្តុះបណ្តាលបុគ្គលិកដែលបានជ្រើសរើស។
- ភ័ស្តុតាងនៃរបាយការណ៍ត្រាថែទាំសម្រាប់ឧបករណ៍ចាប់សញ្ញាអគ្គិភ័យ និងប្រព័ន្ធកណ្តឹងរោទ៍ភ្លើងបំភ្លឺពេលមានអាសន្ន និងម៉ាស៊ីនបូមទឹក និងបំពង់ទុយោ។

នៅពេលបញ្ចប់ការត្រួតពិនិត្យ អ្នកវាយតម្លៃសុវត្ថិភាពអគ្គិភ័យគួរតែមានការយល់ដឹងច្បាស់អំពីគំនូសប្លង់របស់រោងចក្រ ការប្រើប្រាស់ផ្សេងៗគ្នា ទីតាំង និងការបែងចែកកម្មករនៅក្នុងបរិវេណរោងចក្រទាំងមូល។ វាមានសារៈសំខាន់នៅដំណាក់កាលនេះដើម្បីកំណត់កន្លែងដែលសកម្មភាពផលិតកម្មសំខាន់ៗកើតឡើង ចំនួនមនុស្សដែលពាក់ព័ន្ធនឹងសកម្មភាពទាំងនេះ និងទីតាំងនៃតំបន់ដែលមានហានិភ័យខ្ពស់ដែលពួកគេអាចប្រឈម ដូចជា ឡចំហាយទឹក ម៉ាស៊ីនភ្លើង កន្លែងស្តុកជាដើម។

3.4.2.3 អគ្គិសនី

- គំនូសប្លង់អគ្គិសនី - តើជាប្លង់ដើម រឺ ប្លង់គួរនៅពេលអាគារសង់រួច
- តើគំនូសប្លង់អគ្គិសនីដូចទៅនិងការដំឡើងបច្ចុប្បន្នដែរឬទេ? • តើគេឃើញការពង្រីក និងការបន្ថែមដែរឬទេ?
- តើការប៉ាន់ស្មានពីបន្ទុកអគ្គីសនីប្រើក្នុងអគារសមមាត្រទៅនិងការដំឡើងប្រពន្ធ័អគ្គីសនីបច្ចុប្បន្នដែរឬទេ? តើបន្ទុកអគ្គីសនីប្រើប្រាស់អតិបរមាតិចជាងទំហំនៃត្រង់ស្វ័រម៉ាទ័រមេដែរឬទេ?
- កំណត់ត្រាថែទាំប្រចាំឆ្នាំរបស់ម៉ាស៊ីនភ្លើង
- កំណត់ត្រាថែទាំប្រចាំឆ្នាំរបស់ត្រង់ស្វ័រម៉ាទ័រ
- កំណត់ត្រាថែទាំប្រចាំឆ្នាំរបស់កុងតាក់ដែលមានតង់ស្យុងខ្ពស់
- កំណត់ត្រាថែទាំប្រចាំឆ្នាំនៃកុងតាក់ដែលមានតង់ស្យុងទាប
- កំណត់ត្រាវាយតម្លៃប្រចាំឆ្នាំលើប្រព័ន្ធការពាររន្ទះ
- របាយការណ៍ពិនិត្យកម្តៅ (thermographic Assessment reports) ពីមុន

- កំណត់ត្រាវាយតម្លៃប្រចាំឆ្នាំនៃប្រព័ន្ធខ្សែរដឺ
- តើធ្លាប់ធ្វើការពិនិត្យកម្តៅពីមុនមកទេ? តើមានសីតុណ្ហភាពខ្ពស់ ឬខុសធម្មតានៅក្នុងទូអគ្គិសនី/ឬឧបករណ៍ត្រូវបានកត់ត្រាទុកទេ។ ការពិនិត្យកម្តៅនៅតែត្រូវបានអនុវត្តដោយមិនគិតពីការត្រួតពិនិត្យពីមុនមកនោះឡើយ។

នៅពេលបញ្ចប់ការត្រួតពិនិត្យ អ្នកវាយតម្លៃសុវត្ថិភាពអគ្គិសនីត្រូវមានការយល់ដឹងច្បាស់អំពីគំនូសបង្ហាងចក្រ ទីតាំងនៃសម្ភារសំខាន់ៗនៅក្នុងបរិវេណរោងចក្រទាំងមូល។ លើសពីនេះ អ្នកវាយតម្លៃត្រូវដឹងថា តើមានឧប្បត្តិហេតុកើតឡើងឬទេ ដូចជា (ការទុស្សេខ្សែភ្លើង (circuit faults) ការឆក់ផ្គាល់ខ្លួន រលាក) ដោយសារការដំឡើងប្រព័ន្ធអគ្គិសនីជាដើម។

3.4.2.4 ច្បាប់ចម្លងឯកសារ និងចំណុចចុងក្រោយនៃការត្រួតពិនិត្យ

- អ្នកវាយតម្លៃខ្លះប្រហែលជាចង់ផ្តល់យោបល់អំពីគំនូសបង្ហាងនៅពេលធ្វើការវាយតម្លៃ។ បើដូច្នេះមែន អ្នកវាយតម្លៃត្រូវស្នើសុំថតចម្លងនៃប្លង់ជាន់ដែលត្រូវការ និងប្លង់ពំនុះក្នុងអគារដែលត្រូវប្រើសម្រាប់កំណត់ចំណាំសរសេរដោយដៃក្នុងអំឡុងពេលការចុះវាយតម្លៃដល់ទីតាំង។ វាមានសារៈសំខាន់ណាស់ក្នុងការអនុញ្ញាតឱ្យមានពេលវេលាគ្រប់គ្រាន់សម្រាប់ការថតចម្លងទាំងនេះ និងឱ្យបានច្បាស់លាស់តាមលក្ខខណ្ឌតម្រូវ។ យើងស្នើសុំចំនួនច្បាប់ចម្លងអប្បបរមាប៉ុណ្ណោះសម្រាប់ភាពងាយស្រួល។
- គំនូសបង្ហាងទាំងនេះត្រូវដាក់បញ្ចូលនៅចុងបញ្ចប់នៃការវាយតម្លៃ។
- មុននឹងបញ្ចប់ការសម្ភាស កំណត់ត្រាពីទីកន្លែង/រូបថត និងការពិនិត្យមើលឯកសារ អ្នកវាយតម្លៃត្រូវរៀបចំកម្មវិធីគំរូឱ្យសមស្របទៅនឹងចំនួនជាន់ អគារ។ល
- ថតរូបនាមប័ណ្ណ ហើយដាក់បញ្ចូលក្នុងកម្មវិធីថេប្លេត
- ថតរូបគំនូសបង្ហាង។ អ្នកប្រហែលជាត្រូវដាក់វានៅលើកម្រាលឥដ្ឋដើម្បីទទួលបានគំនូសបង្ហាង A1 នៅក្នុងស៊ុមកាមេរ៉ាថេប្លេត។
- ក្រុមការងារវាយតម្លៃត្រូវកំណត់លើការបញ្ចប់ការណែនាំនិងការសម្ភាសអ្នកគ្រប់គ្រងរោងចក្រតាមគោលដៅក្នុងរយៈពេល 1 ម៉ោង ឬតិចជាងនេះ

3.5 កំណត់សម្គាល់ការវាយតម្លៃអគារទូទៅ

- ត្រូវផ្តល់សិទ្ធិចេញចូលទៅគ្រប់ផ្នែកទាំងអស់នៃអគារ រួមទាំងផ្នែកណាមួយដែលមិនស្ថិតនៅ

ក្នុងការគ្រប់គ្រងរបស់រោងចក្រជាដើម។ ប្រសិនបើមិនមានសិទ្ធិចូលទៅកាន់ផ្នែកជាក់លាក់ណាមួយទេនោះ យើងត្រូវធានាថា អ្នកតំណាងរោងចក្រដឹងថា ការងារវាយតម្លៃរបស់យើងតម្រូវឱ្យមានសិទ្ធិចេញចូលនេះ។ ប្រសិនបើសិទ្ធិចេញចូលនៅតែមិនត្រូវបានផ្តល់ឱ្យដដែល យើងត្រូវកំណត់ចំណាំវានៅក្នុងរបាយការណ៍របស់យើង។ ប្រសិនបើមិនមានសិទ្ធិចេញចូលទៅកាន់ផ្នែកសំខាន់ៗទេនោះ សូមពិចារណាថា តើការវាយតម្លៃនេះត្រូវបានចាត់ទុកថា ជាការវាយតម្លៃមិនពេញលេញ និងណែនាំវាឱ្យកំណត់ពេលឡើងឡើងវិញឬយ៉ាងណា។

- ទោះស្ថិតក្នុងកាល:ទេស:ណាក៏ដោយក្នុងអំឡុងពេលវាយតម្លៃ ត្រូវផ្តល់ជាគំនិតដល់អ្នកគ្រប់គ្រងរោងចក្រ ឬព័ត៌មានថា រោងចក្រ "អនុលោមតាម" ឬស្រដៀងគ្នា។ ការបញ្ចប់ការវាយតម្លៃនឹងសម្រេចបានលុះត្រាតែការចុះទៅពិនិត្យដល់ទីកន្លែងបានបញ្ចប់ ហើយមានការតាមដាន ឬការវាយតម្លៃណាមួយត្រូវបានធ្វើឡើង។
- ក្នុងការអនុវត្តការវាយតម្លៃដល់ទីកន្លែង ជាធម្មតាអ្នកតំណាងរោងចក្រមួយចំនួននឹងអមជាមួយក្រុមការងារវាយតម្លៃដើម្បីជួយតាមដែលអាចធ្វើបាន។ ដើម្បីគ្រប់គ្រងពេលវេលារបស់អ្នកឱ្យមានប្រសិទ្ធភាព អ្នកអាចស្នើសុំឱ្យមានមនុស្សតែម្នាក់ ឬពីរនាក់អមដំណើរនេះបានហើយ។
- វាជាការល្អបំផុតក្នុងការទទួលស្គាល់ និងបើអាចធ្វើទៅបាន ប្រើជំនួយពីអ្នកតំណាងរោងចក្រ ប៉ុន្តែមិនត្រូវចូលរួមក្នុងការពិភាក្សាអំពីការសង្កេតជាក់លាក់ទេ លុះត្រាតែអ្នកមានសំណួរជាក់លាក់។
- នៅពេលមានការអនុវត្តការវាយតម្លៃពីខាងក្រៅ វាមានអត្ថប្រយោជន៍ក្នុងការកំណត់សម្គាល់ដែលអាចត្រូវបានប្រើដើម្បីជួយតម្រង់ទិសនៅពេលអ្នកនៅក្នុងអគារ។ នៅពេលពិនិត្យមើលអគារដែលមានផ្ទៃក្រឡាជាការធំៗ ដែលមានក្រឡាស៊ីមេទ្រី និងគំនូសប្លង់ជាន់ដដែលៗនោះ វាអាចងាយនឹងមានភាពវង្វេងណាស់ (disorientated)។ សម្រាប់ហេតុផលនេះគឺ
- មានអត្ថប្រយោជន៍ក្នុងការបញ្ជាក់ថាទិសមួយណាជាទិសខាងជើង និងដើម្បីកំណត់ចំណុចយោងលើផ្ទៃផ្តេក ឬក្នុងអគារ
- ត្រូវប្រាកដថា អ្នកដឹងពីចំងាយពីអក្សអាគារទៅអ័ក្សមួយ (grid dimensions)សម្រាប់អគារនីមួយៗ ដោយសារប្រវែងទាំងនេះផ្តល់នូវជំនួយដ៏ងាយស្រួលដល់ការវិនិច្ឆ័យតំបន់ និងចម្ងាយខណៈពេលកំពុងធ្វើការវាយតម្លៃ
- ខណៈពេលនៅរោងចក្រ ត្រូវប្រាកដថា អ្នកទទួលបានកូអរដោនេ GPS សម្រាប់ទីតាំងរោងចក្រ។កូអរដោនេទាំងនេះត្រូវបានទាមទារដើម្បីដាក់បញ្ចូលទៅក្នុងរបាយការណ៍វាយតម្លៃ ហើយអាចពិបាកក្នុងការទាញយកនៅពេលក្រោយ។

ក្នុងករណីដែលមានវិស្វកររាប់ជាងមួយរូបក្នុងផ្នែកនីមួយៗ ពួកគេត្រូវនៅជាមួយគ្នាក្នុង

អំឡុងពេលវាយតម្លៃតាមដែលអាចធ្វើទៅបាន ឬយ៉ាងហោចណាស់ស្របតាមការមើលឃើញរបស់សហការី។ ចូរស្វែងរកបញ្ហា និងពិនិត្យមើលបញ្ហាទាំងនេះជាមួយសមាជិកក្រុមរបស់អ្នក។

3.6 កិច្ចប្រជុំបញ្ចប់

នៅពេលបញ្ចប់ការវាយតម្លៃដែលពាក់ព័ន្ធ និងការធ្វើតេស្តណាមួយ ផ្នែកវាយតម្លៃទាំងអស់ត្រូវរៀបចំកិច្ចប្រជុំបិទរួមគ្នាខ្លីមួយជាមួយអ្នកគ្រប់គ្រងរោងចក្រ។ នៅក្នុងកិច្ចប្រជុំនេះ សូមថ្លែងអំណរគុណដល់ អ្នកគ្រប់គ្រងរោងចក្រ និងរំលឹកឡើងវិញនូវជំហានវាយតម្លៃ ដែលយើងបានធ្វើ ដោយកត់សម្គាល់ថា យើងប្រមូលបានព័ត៌មានចាំបាច់សម្រាប់រៀបចំរបាយការណ៍របស់យើង។ ជាទូទៅផ្តល់យោបល់ដល់អ្នកគ្រប់គ្រងរោងចក្រថា ការសន្និដ្ឋាន និងសកម្មភាពពេញលេញនឹងត្រូវបានដាក់បញ្ចូលក្នុងរបាយការណ៍។

ទោះយ៉ាងណា ប្រសិនបើតម្រូវឱ្យមានវិធានការបន្ទាន់ ឧ. ការបាក់បេតុងនៅក្នុងគ្រឿងបង្គុំសំណង់ (structural element)សំខាន់ៗ បញ្ហាសុវត្ថិភាពអគ្គិភ័យ ឬខ្សែភ្លើងដាច់រលាត់ដែលអាចមានគ្រោះថ្នាក់ (exposed live cables) សូមពិភាក្សាអំពីបញ្ហានេះជាមួយអ្នកគ្រប់គ្រងរោងចក្រ ហើយថតចម្លងការណែនាំសម្រាប់ដាក់បញ្ចូលទៅក្នុងរបាយការណ៍ចុងក្រោយ។ ណែនាំពួកគេថា របាយការណ៍ចុងក្រោយនឹងត្រូវបានចុះផ្សាយនៅលើវេទិកា LABS FFC ក្នុងរយៈពេល 05 ថ្ងៃនៃថ្ងៃធ្វើការចាប់ពីកាលបរិច្ឆេទនៃការវាយតម្លៃ (អគ្គិភ័យ អគ្គិសនី និងសំណង់)។

យើងអាចប្រើប្រាស់ការប្រជុំនេះជាឱកាសដើម្បីស្វែងរកការបំភ្លឺអំពីបញ្ហាណាមួយ ប្រសិនបើយើងសង្ស័យថា អាចមានការឆ្លើយតបមិនច្បាស់លាស់កាលពីលើកមុន។

4 វិធីសាស្ត្រវាយតម្លៃសំណង់អគារ

4.1 ចំណុចទូទៅ

សេចក្តីសង្ខេបអំពីប្រព័ន្ធគ្រឿងបង្គុំសំណង់អគារដែលត្រូវរៀបចំជាផ្នែកនៃរបាយការណ៍វាយតម្លៃសុវត្ថិភាពសំណង់បឋម តម្រូវឱ្យបំពេញនូវទិន្នន័យសំខាន់ៗដែលអ្នកវាយតម្លៃគួរដឹងមុននឹងចាប់ផ្តើមការងារវាយតម្លៃ។ ការពិនិត្យមើលឯកសារសំណង់ និងការវាយតម្លៃរោងចក្រ ទាំងខាងក្រៅ និងខាងក្នុង អនុញ្ញាតឱ្យអ្នកវាយតម្លៃកំណត់ព័ត៌មានជាក់លាក់ដែលត្រូវការសម្រាប់អគារនីមួយៗ នៅក្នុងបរិវេណរោងចក្រ។

លើសពីនេះទៀត ការបញ្ចប់ការត្រួតពិនិត្យ និងការគណនាគ្រឿងបង្គុំសំខាន់ៗជាពិសេសលើធាតុបេតុង ដូចជា ធ្នឹមកុងស៊ុល (cantilever) ការផ្ទេរបន្ទុក (key transfer elements) ឬសសរដែលទ្របន្ទុកខ្ពស់ទាមទារឱ្យមានកំណត់ត្រាត្រឹមត្រូវនៃទំហំមុខកាត់ និងការប៉ាន់ស្មានពីបន្ទុកសង្កត់។ វាជាការសំខាន់ណាស់ដែលទំហំគ្រឿងបង្គុំ និងបន្ទុកដែលបានប៉ាន់ប្រមាណត្រូវបានកត់ត្រាជាប្រព័ន្ធសម្រាប់ផ្នែកនៃការបារម្ភទាក់ទងសំណង់។

4.2 ការវាយតម្លៃផ្នែកខាងក្រៅនៃអគារ

នៅពេលបញ្ចប់ការសម្ភាសអ្នកគ្រប់គ្រងរោងចក្រ និងការត្រួតពិនិត្យឯកសារ ចាប់ផ្តើមធ្វើការវាយតម្លៃទីតាំងនៃផ្នែកខាងក្រៅអគារម្តង។ ការវាយតម្លៃជាធម្មតាចាប់ផ្តើមដោយការដើរតាមបរិវេណជុំវិញនៃអគារ និងត្រួតពិនិត្យមើលផ្នែកខ្ពស់ៗទាំងអស់។ ជាធម្មតា ការវាយតម្លៃផ្នែកខាងក្រៅប្រើប្រាស់ដើម្បី៖

- បញ្ជាក់ចំនួនជាន់ - (ពិនិត្យ ពិនិត្យឡើងវិញ និងពិនិត្យម្តងទៀត)
- បញ្ជាក់ចំនួនអ័ក្សរបស់អាគារ (structural grids)
- កំណត់ទីតាំងនៃតំណសំណង់ (building movement joints)
- បញ្ជាក់ថា តើមានជាន់ក្រោមដីនៅក្រោមអគារទេ
- វាយតម្លៃស្ថានភាព និងទីតាំងអគារដែលនៅជាប់គ្នា និងលក្ខខណ្ឌទីតាំង
- កំណត់តំណសំណង់ ឬសូចនាករនៃការសាងសង់ជាដំណាក់កាល
- ពិនិត្យមើលថា តើមានការសាងសង់ជាន់បន្ថែមទេ
- ពិនិត្យមើលថា តើជាន់ខាងលើកំពុងសាងសង់នៅឡើយ ឬយ៉ាងណា
- កំណត់ថា តើជាន់ទេរ៉ាស់ ឬដំបូលត្រូវបានដកចេញហើយឬនៅ

- កំណត់ភស្តុតាងនៃសំរុតអាគារ
- ពិនិត្យធ្មឹមកុងស៊ុលរបស់អាគារ (building cantilevers)
- កំណត់ពីកន្លែងស្នាមប្រេះនៅក្នុងផ្នែកខាងមុខអគារ
- ពិនិត្យគ្រឿងបង្គុំសំខាន់ៗ ឧទាហរណ៍ សសរដែលប្រឈមហានិភ័យនៅក្នុងតំបន់ដែលមានចរាចរណ៍មមាញឹក។
- ពិនិត្យមើលប្លង់ចំហៀង រឺ ប្លង់មិនប្រក្រតី

កែវយឹតត្រូវដាក់បញ្ចូលក្នុងឧបករណ៍វាយតម្លៃដើម្បីពិនិត្យផ្ទៃខាងមុខអគារសម្រាប់រកមើលស្នាមប្រេះជាពិសេសនៅត្រង់ចំណុចតំណ(movement joints) និងចន្លោះជញ្ជាំងឥដ្ឋ និងគ្រឿងបង្គុំបេតុងអាមេ (reinforced concrete elements)។ ការវាយតម្លៃផ្នែកខាងក្រៅនៃអគារក៏ត្រូវកំណត់តំបន់ណាមួយដែលបេតុងមានសរសៃដែក (concrete reinforcement) ប្រឈមហានិភ័យ និងច្រែះស៊ី។ រាល់មតិយោបល់ និងរូបថតដែលបានកត់ត្រាទុកត្រូវបានដាក់បញ្ចូលក្នុងកម្មវិធីវាយតម្លៃ ឬបើមិនដូច្នេះទេត្រូវកត់ត្រា និងរក្សាទុក។

បន្ថែមពីលើការកត់ត្រាភស្តុតាងនៃបញ្ហាក្តីបារម្ភណាមួយ គន្លឹះសំខាន់ចំពោះដំណាក់កាលនៃការវាយតម្លៃនេះគឺដើម្បីទទួលបានការយល់ដឹងពេញលេញអំពីទំហំអគារ តំណភ្ជាប់ទៅអគារដែលនៅជាប់គ្នា និងប្រព័ន្ធសំណង់អគារទាំងមូលដោយរកមើលផ្នែកពង្រីកបន្ថែម និងសញ្ញានៃការសាងសង់ដែលកំពុងដំណើរការ។

4.3 ការវាយតម្លៃផ្នែកខាងក្នុងនៃអគារ

4.3.1 ប្រភេទនៃអគារពោងចក្រ

គេរំពឹងថា នៅក្នុងប្រទេសកម្ពុជា អគារពោងចក្រសំខាន់ៗនឹងចាត់ចូលទៅក្នុងប្រភេទមួយក្នុងចំណោមពីរប្រភេទដូចខាងក្រោម៖

- ប្រភេទទី 1៖ អាគារគ្រោងបេតុងដែលមានបីជាន់ ឬច្រើនជាន់ ដែលមានប្រតិបត្តិការពោងចក្រលាតសន្ធឹងលើជាន់ផ្សេងៗ។ ផ្នែកខាងមុខខាងក្រៅជាធម្មតាមានជញ្ជាំងធ្វើពីឥដ្ឋបូកបាយអរ។ ចំណាំ៖ សម្រាប់អគារបេតុងមួយជាន់ ឬពីរជាន់ វិធីសាស្ត្រដូចគ្នានឹងត្រូវអនុវត្ត។ ប៉ុន្តែ វាចាំបាច់ក្នុងការត្រួតពិនិត្យលទ្ធភាពទ្រទ្រង់របស់សសរនោះទេ។ នេះនឹងជាការ

សម្រេចចិត្តរបស់វិស្វករ។

- ប្រភេទទី 2៖ រោងចក្រសាងសង់ពីគ្រោងដែកមួយជាន់ និងពីរជាន់ ដែលមានផ្ទៃប្លង់ទូលាយ។ ជាធម្មតា សំណង់រោងចក្រទាំងនេះ រួមមានគ្រោងពង្រឹងដែក (braced steel portal frame) ឬចន្លល់ខ្វែងដោយគ្រឿងបង្គុំដែក ឬសសរបេតុងអាមេ (trusses with structural steel or reinforced concrete columns)។ ជាន់ទីពីរ (ប្រសិនបើមាន) ជាទូទៅមានកន្លែងការិយាល័យ ឃ្លាំងស្តុក ឬប្រតិបត្តិការរោងចក្របន្ទាប់បន្សំ។ ផ្នែកខាងមុខខាងក្រៅជាធម្មតាមានជញ្ជាំងឥដ្ឋបូកបាយអរ/បន្ទះបេតុងអាមេ/បន្ទះដែក(plastered brick walls/reinforced concrete panels/metal panels)។

នៅពេលដែលអគាររោងចក្រមិនស្ថិតក្នុងការពិពណ៌នានៃប្រភេទពីរមុននេះ ការវិនិច្ឆ័យផ្នែកវិស្វកម្មនឹងត្រូវបានទាមទារ។

4.3.2 ប្រភេទទី 1៖ គ្រោងបេតុង ឬដែកលើសពីបីជាន់

អគាររោងចក្រដែលមានបីជាន់ ឬច្រើនជាន់ ត្រូវត្រួតពិនិត្យពីដំបូលចុះមកក្រោម។ ក្រុមការងារវាយតម្លៃត្រូវធ្វើការតាមវិធីសាស្ត្រតាមរយៈអគារ (ជាន់អាចមើលទៅដូចគ្នា និងអាចបង់លេខខុសគ្នា – ពោលគឺ ជាន់ទី1នៅកម្រិតផ្ទាល់ដី ឬជា "ជាន់ផ្ទាល់ដី +1"?)។ កំណត់ប្រព័ន្ធលេខរៀង (ជាន់រោងចក្រទាបបំផុតប្រហែលជាមិនមែនជាជាន់ផ្ទាល់ដីនៅក្នុងអគាររួមទេ)។

នៅក្នុងករណីនៃអគារបេតុង សំណង់ធ្វើពីគ្រោងដែកអាចត្រូវបានបន្ថែមនៅជាន់ដំបូល។ ការវាយតម្លៃដែលមើលឃើញផ្ទាល់ភ្នែកត្រូវបានអនុវត្តដើម្បីពិនិត្យមើលឃ្នាបនៃសំណង់ធ្វើពីដែក និងដើម្បីបង្កើតជាចំណុច ថា តើយើងត្រូវស្នើសុំការត្រួតពិនិត្យគំនូសប្លង់លើសំណង់ធ្វើពីដែកដែរឬយ៉ាងណា។ សកម្មភាពដែលត្រូវបង្ហាញដោយក្រុមការងារវាយតម្លៃអាចរួមបញ្ចូល។

ការរុះរើសម្ភារសំណង់ ការជួសជុលកម្រាលខណ្ឌដំបូល (roof slab) ដើម្បីការពារការជ្រាបទឹក និងការដំឡើងប្រព័ន្ធលូរំដោះទឹកលើដំបូល។

ធុងទឹក (ប្លាស្ទិក ឬបេតុង) ដែលដាក់នៅលើដំបូល ឬកម្រិតពិតាន (suspended levels) ក៏សមនឹងការត្រួតពិនិត្យឡើងវិញ និងកត់ត្រាផងដែរ។ អាស្រ័យលើចំនួន និងទំហំនៃធុងទឹក និងទីតាំងរបស់វានៅលើសំណង់ ទាំងនេះអាចជាការពិនិត្យគំនូសប្លង់ដោយវិស្វករសំណង់អគារ។

បន្ទាប់ពីការវាយតម្លៃនៅជាន់ដំបូល ក្រុមការងារវាយតម្លៃធ្វើការជាបន្តបន្ទាប់រហូតដល់ជាន់ផ្ទាល់ដី។ វាសំខាន់ណាស់ក្នុងការយល់ព្រមជួបនៅច្រកចេញដូចគ្នានៅជាន់នីមួយៗ ដើម្បីឱ្យក្រុមការងារអាចចាកចេញពីជាន់ជាមួយគ្នា។ ប្លង់រត់ចេញពេលមានអគ្គិភ័យជាធម្មតាត្រូវបានផ្តល់នៅច្រកចូលទៅជាន់នីមួយៗ។ វាមានប្រយោជន៍ក្នុងការថតរូបនៃប្លង់នីមួយៗនៅពេលការវាយតម្លៃដំណើរការ។ នេះផ្តល់នូវ "កំណត់ចំណាំ" ដ៏មានប្រយោជន៍នៅក្នុងរូបភាពកាមេរ៉ា។

ជាធម្មតាកម្រិតជាន់ត្រូវបានជ្រើសរើស (ជាធម្មតាមួយ ឬពីរជាន់ក្រោមជាន់ដំបូល) សម្រាប់ការវាយតម្លៃលម្អិតដែលនឹងចំណាយពេលយូរជាងជាន់ផ្សេងទៀត។ នៅជាន់នេះ ជាធម្មតាយើងបង្កើតប្រព័ន្ធសំណង់ ធ្វើការត្រួតពិនិត្យលម្អិតលើទំហំនៃក្រុមសំណង់ ហើយអនុវត្តតាមការងារនេះជាមួយនឹងការវាយតម្លៃហ្មត់ចត់នៃផ្ទៃក្រឡាជាន់ រកមើលភស្តុតាងនៃបញ្ហាសំណង់ (structural distress) ណាមួយ។ ការត្រួតពិនិត្យលម្អិតលើប្រព័ន្ធសំណង់ និងទំហំគួរតែរួមបញ្ចូលដូចខាងក្រោម៖

- ផ្ទៀងផ្ទាត់គម្លាតអ័ក្សសសរនិងចំនួនអ័ក្សធៀបនឹងគំនូសប្លង់ដែលបានផ្តល់។ ត្រូវប្រាកដថាអ័ក្សទាំងអស់វាស់ពីចំនុចកណ្តាលសសរ
- កត់ត្រាប្រព័ន្ធសំណង់ដែលបានសង្កេត រួមទាំងប្រព័ន្ធស្ថិរភាពអគារផងដែរ
- វាស់គំរូនៃសសរខាងក្នុង និងខាងក្រៅដោយប្រៀបធៀបជាមួយគំនូសប្លង់ដែលបានផ្តល់។ ប្រសិនបើដូចធម្មតា ត្រូវបូកស៊ីម៉ងត៍សសរទាំងនោះ សូមប្រាកដថា ទំហំដែលបានកត់ត្រាត្រូវបានកាត់បន្ថយ ដើម្បីបូកបាយអរសរុបពី 15 ទៅ 25 មីល្លីម៉ែត្រ ហើយចំណាំថានេះគឺជាផ្នែក RC ដែលបានវាស់វែងដោយមិនរាប់បញ្ចូលការបូកបាយអរ (plaster)។
- ប្រសិនបើការសាងសង់ប្លង់កម្រាលខណ្ឌជាធ្នឹម និងកម្រាលខណ្ឌ ត្រូវវាស់កម្រាលជាន់ទៅនឹងផ្នែកនៃកម្រាលខណ្ឌ និងផ្នែកនៃធ្នឹម ដូច្នេះផ្តល់នូវទំហំធ្នឹមបញ្ឈរខាងក្រោម និងទទឹងធ្នឹម (down stand beam dimension and beam width)។
- ពិនិត្យ និងវាស់ប្លង់សេកុងស៊ុល (floor slab cantilevers) ហើយកត់សម្គាល់ថា តើមានបន្ទុកសំខាន់ៗនៅលើផ្នែកទាំងនេះដែរឬទេ។
- វាស់កម្រាស់ប្លង់សេយ៉ាងហោចណាស់ពីរទីតាំង – រួមទាំងការងារសម្រេច (finishes)តាមរយៈការបើកទូអគ្គិសនី (ប្រសិនបើអាច) និងនៅផ្លូវចុះទៅដល់ជណ្តើរ។ ត្រូវប្រាកដថាការគន់គូរពីកម្រាស់ពីដីទៅនឹងកម្រាស់កម្រាលខណ្ឌជាន់នៅក្នុងកន្លែងធ្វើការងារអនុញ្ញាតសម្រាប់ជំហានណាមួយនៅក្នុងផ្នែកនេះឬលើដំបូលនៃកម្រាលខណ្ឌជាន់។ នេះគឺជាទិន្នន័យសំខាន់មួយសម្រាប់អគារច្រើនជាន់ ដោយសារបញ្ហាសសរជាធម្មតាត្រូវបានគ្របដណ្តប់ដោយទម្ងន់អគារខ្លួនឯង។

- ការវាស់វែងការងារបញ្ចប់ ប្រសិនបើមើលឃើញ ជាធម្មតាការ៉ូ 12mm នៅលើ បាយអរ 28-35mm ។
- កត់ត្រាការកសាងជាន់បន្ថែមណាមួយ (ឧ. នៅកន្លែងបង្គន់ ឬកន្លែងបោកគក់)
- វាស់កម្ពស់ពីជាន់មួយទៅជាន់មួយ ជាពិសេសនៅផ្នែកជណ្តើរ។
- ការប៉ាន់ប្រមាណការផ្ទុកបន្ទុកនៅតាមជាន់ដែលកត់សម្គាល់ជាពិសេសការផ្ទុកឬការសាងសង់ជាន់សម្រាប់កន្លែងបោកគក់ ឬស្រដៀងគ្នា។ កត់ត្រាផ្នែកណាដែលផ្ទុកលើសចំណុះនៅជាន់នីមួយៗបញ្ឈរពីលើគ្នាជាដើម។
- ចំណាំពីកន្លែងតំណភ្ជាប់អគារដែលបានផ្តល់ឱ្យនៅក្នុងប្លង់។ ពិនិត្យកន្លែងទាំងនេះជាមួយគំនូសប្លង់។ កត់ចំនាំប្រសិនបើមាន កម្រាលខណ្ឌកុងស៊ុលនៅកន្លែងតំណភ្ជាប់នោះ ដូច្នេះការប្រមូលផ្តុំបន្ទុកនៅលើសសរដែលនៅជាប់គ្នា។ សសរនេះអាចតម្រូវឱ្យមានការត្រួតពិនិត្យគំនូសប្លង់ជាក់លាក់។
- ពិនិត្យមើលកម្រាស់ជញ្ជាំងខាងក្រៅ ដើម្បីប៉ាន់ប្រមាណការផ្ទុកបន្ទុកទៅលើគែមកម្រាលខណ្ឌកុងស៊ុល។

នៅពេលបញ្ចប់ការវាយតម្លៃខាងលើ ក្រុមការងារវាយតម្លៃដំណើរការជាមួយនឹងការវាយតម្លៃដោយមើលឃើញផ្ទាល់ភ្នែកនៃជាន់នោះ ដោយការកត់ត្រាភស្តុតាងណាមួយនៃស្នាមប្រេះ/ការផ្ទុកលើសទម្ងន់ ឬបញ្ហាសំណង់ផ្សេងទៀតនៅលើកម្មវិធីថេប្លេត។ វាក៏មានអត្ថប្រយោជន៍ផងដែរក្នុងការកត់ត្រាបណ្តុំនៃរូបថតជាន់ទូទៅដែលបង្ហាញពីសំណង់អគារជាកំណត់ហេតុជំនួយក្នុងការប៉ាន់ប្រមាណពីបន្ទុកតាមជាន់។

បើកត់សម្គាល់ឃើញចំណុចខ្វះខាតណាមួយ សូមកុំបញ្ឈប់ ហើយដៅចំណុចនេះទុក។ ពិភាក្សាជាមួយមិត្តរួមក្រុមរបស់អ្នកនៅទីតាំងដាច់ដោយឡែកទាក់ទងជាន់នេះ ហើយប្រគល់ព័ត៌មានសង្ខេបអំពីចំណុចខ្វះខាតនេះ ប្រសិនបើចាំបាច់។
វាត្រូវបានកត់សម្គាល់ដែរថា អគារភាគច្រើនទំនងជាបង្ហាញពីស្នាមប្រេះមួយចំនួនដូចសរសៃសក់ដែលមើលឃើញផ្ទាល់ភ្នែក។ អ្នកវាយតម្លៃត្រូវប្រើបទពិសោធន៍របស់ខ្លួនដើម្បីកំណត់រកមូលហេតុនៃការប្រេះនេះ នៅពេលណាដែលវាជាការព្រួយបារម្ភ និងយកល្អត្រូវកត់ត្រាទុកជាការសង្កេត។ កុំព្យាយាមកត់ត្រារាល់ស្នាមប្រេះនៅក្នុងអគារ ប្រសិនបើវាមិនមែនការបារម្ភទេនោះ។
ទោះជាយ៉ាងណា ស្នាមប្រេះត្រង់សសរត្រូវធ្វើការវាយតម្លៃ និងកត់ត្រាដោយការប្រុងប្រយ័ត្ន។

ដោយបានបញ្ចប់ការវាយតម្លៃនៅជាន់ដំបូង ក្រុមការងារគួរតែធ្វើការតាមរយៈអគារនេះ តាមដាន

និងស្វែងយល់ពីកន្លែងផ្ទេរបន្ទុករហូតដល់គ្រឹះ។ វិធីសាស្ត្រស្រដៀងគ្នាទៅនឹងខាងលើត្រូវបានអនុវត្តនៅកម្រិតជាន់នីមួយៗ។ នៅជាន់ទាំងនេះ ត្រូវផ្តោតសំខាន់ទៅលើការវាយតម្លៃដែលមើលឃើញផ្ទាល់ភ្នែក និងការកត់ត្រាពីការសង្កេតនានានៅលើកម្មវិធីថេប្លេត។ ជាទូទៅ ការត្រួតពិនិត្យចោះៗនៅលើប្រវែងអ័ក្សសសរនិងទីតាំងសសរ/ធ្នឹម និងទំហំធាតុនឹងជាការគ្រប់គ្រាន់ទៅហើយ។ ក្រុមការងារវាយតម្លៃអាចធ្វើការបែងចែកកម្រិតជាន់រវាងពួកគេ ដើម្បីពន្លឿនដំណើរការ។

ការណែនាំខាងលើអនុវត្តចំពោះតែអគារដែលមិនមានគ្រឿងបង្គុំសំណង់ផ្ទេរ (transfer structure)។ ប្រសិនបើមានគ្រឿងបង្គុំសំណង់ផ្ទេរ វានឹងមានសារៈសំខាន់ក្នុងការកំណត់ និងកត់ត្រាលក្ខណៈនៃប្រព័ន្ធសំណង់នៅជាន់នីមួយៗ។

ក្នុងអំឡុងពេលនៃការវាយតម្លៃជាន់ផ្ទាល់ដី/ជាន់ក្រោម ទំហំសសរសំខាន់ៗត្រូវធ្វើការកត់ត្រាទុក។ សសរដែលត្រូវពិនិត្យដោយការស្កេន Ferro និងការធ្វើតេស្តដោយឧបករណ៍ (តេស្តកំលាំងបេតុង) Schmidt hammer នឹងត្រូវពិនិត្យ ប្រសិនបើត្រូវបានកំណត់ឃើញដែរនោះ។

4.3.3 ប្រភេទទី 2៖ អគារគ្រោងដែកកម្ពស់ទាប

អគាររោងចក្រគ្រោងដែកកម្ពស់មួយជាន់ និងពីរជាន់ ជាធម្មតាមានផ្ទៃក្រឡាប្លង់ធំទូលាយដែលមិនមានសសរ ដោយផលិតកម្មរោងចក្រផ្តោតសំខាន់នៅកម្រិតជាន់ផ្ទាល់ដី។ ប្រតិបត្តិការគាំទ្ររបស់រោងចក្រ ដូចជា ការិយាល័យ និងកន្លែងស្តុកជាធម្មតាមានទីតាំងស្ថិតនៅជាន់ឡៅតឿ។ ផ្ទៃក្រឡាជាន់ឡៅតឿអាចត្រូវបានពង្រីក ឬសមត្ថភាពផ្ទុកកើនឡើងដោយការពង្រឹងការងារបន្ទាប់ពីការសាងសង់គ្រោងសំណង់រោងចក្រ។

បន្ទាប់ពីបញ្ចប់ការវាយតម្លៃនៃផ្នែកខាងក្រៅអគារហើយនោះ ការវាយតម្លៃផ្ទៃក្នុងត្រូវចាប់ផ្តើមនៅចំណុចដែលអាចកត់សម្គាល់បាននៅក្នុងអគារ – អាចជានៅក្នុងតំបន់ចំហធំល្វឹងល្វើយ (open high bay area) ប្លង់រត់គេចពេលមានអគ្គិភ័យជាធម្មតាត្រូវបានបិទនៅជុំវិញអគារ។ វាមានប្រយោជន៍ក្នុងការថតរូបប្លង់នីមួយៗនេះជា "កំណត់ចំណាំ" ដ៏មានប្រយោជន៍នៅក្នុងរូបភាពកាមេរ៉ា។ ផ្ទៃជាន់ឡៅតឿត្រូវធ្វើការត្រួតពិនិត្យបន្ទាប់ពីប្រព័ន្ធសំណង់ត្រូវបានបង្កើតឡើងសម្រាប់សំណង់សំខាន់ដែលមានតំបន់ចំហធំ។ ការត្រួតស៊ីគ្នាខ្លះរវាងការវាយតម្លៃនៃផ្ទៃឡៅតឿ និងតំបន់ចំហធំល្វឹងល្វើយ គឺជៀសមិនរួចឡើយដើម្បីកំណត់ស្ថានភាពសំណង់ក្នុងតំបន់។

ធុងទឹក (ប្លាស្ទិក ឬបេតុង) ដែលមានទីតាំងស្ថិតនៅដំបូល ឬជាន់ប្លង់សេ (suspended levels) ក៏ត្រូវធ្វើការការពិនិត្យ និងកត់ត្រាផងដែរ។ អាស្រ័យលើចំនួន និងទំហំនៃធុងទឹក និងទីតាំងរបស់វានៅលើអគារ ទាំងនេះអាចជាការពិនិត្យគំនូសប្លង់ដោយវិស្វករសំណង់អគារ។

ការវាយតម្លៃផ្នែកខាងក្នុងអាគារជាដំបូងត្រូវពិនិត្យនូវប្រព័ន្ធរចនាសម្ព័ន្ធគ្រោងសំណង់ រួមទាំងការត្រួតពិនិត្យលម្អិតលើប្រវែងពីគ្រឿងបង្គុំសំណង់ ចំណុចកណ្តាលខ្សែក្រឡា និងទំហំនៃគ្រឿងបង្គុំសំណង់សំខាន់ៗ ឧ. សសរគ្រោង និងធ្នឹម កុងសុីល។ល។ ដំណាក់កាលទី 2 នៃការវាយតម្លៃផ្នែកខាងក្នុងពាក់ព័ន្ធនឹងការវាយតម្លៃហ្មត់ចត់នៃផ្ទៃជាន់ទាំងអស់ដើម្បីរកមើលភស្តុតាងនៃបញ្ហាសំណង់ ឬព័ត៌មានលម្អិតនៃគំនូសប្លង់ដែលខុសពីធម្មតា។ ការត្រួតពិនិត្យលម្អិតលើប្រព័ន្ធសំណង់ និងវិមាត្រនៅក្នុងតំបន់ចំហធំៗ និងឡៅតឿ គួរតែរួមបញ្ចូលដូចខាងក្រោម៖

- ផ្ទៀងផ្ទាត់គម្លាតសសរ និងគម្លាតគ្រឿងបង្គុំ និងចំនួនអ័ក្សធៀបនឹងគំនូសប្លង់ដែលបានផ្តល់។ ត្រូវប្រាកដថា ទំហំទាំងអស់ស្ថិតនៅកណ្តាលចំកណ្តាលសសរ។ ពិនិត្យមើលដំបូលគ្រោងដែកសំខាន់ និងបន្ទាប់បន្សំ។
- កត់ត្រាប្រព័ន្ធសំណង់ដែលបានសង្កេត រួមទាំងទំហំ ឬចំណុចសំខាន់ៗ ជាពិសេសប្រព័ន្ធស្ថិរភាពនៃអគារ - ការពង្រឹងដំបូល និងពង្រឹងសសរ។ តើជញ្ជាំងបរិវេណជុំវិញបង្កើតជាផ្នែកនៃប្រព័ន្ធស្ថិរភាពគ្រោងទេ? ពិនិត្យមើលគ្រោងពេលបច្ចុប្បន្ន។ តើគ្រឿងបង្គុំមានពង្រឹងមិនពេញលេញ ឬធ្លាក់ស្រយាក?
- វាស់គំរូសសរខាងក្នុង និងខាងក្រៅដោយប្រៀបធៀបជាមួយគំនូសប្លង់ដែលបានផ្តល់។ ប្រសិនបើសសរជាសំណង់បេតុង និងបានបូកបាយអរ ត្រូវប្រាកដថា ទំហំដែលបានកត់ត្រានោះត្រូវបានកាត់បន្ថយ ដើម្បីអាចបូកបាយអរសរុបពី 15 ទៅ 25 មីលីម៉ែត្រ ហើយចំណាំថានេះគឺជាផ្នែកបេតុងអាមេដែលបានវាស់វែងដោយមិនរាប់បញ្ចូលាករបូកបាយអរនោះឡើយ។
- ប្រសិនបើការសាងសង់កម្រាលខណ្ឌជាន់ប្លង់សេ (suspended floor slab construction)ជាធ្នឹម និងកម្រាលខណ្ឌ ត្រូវវាស់ជាន់ទៅនឹងផ្នែកនៃកម្រាលខណ្ឌ និងផ្នែក នៃធ្នឹម ដូច្នេះផ្តល់នូវទំហំធ្នឹមបញ្ឈរខាងក្រោម និងទទឹងធ្នឹម។
- ពិនិត្យ និងវាស់កម្រាលខណ្ឌជាន់កុងសុីល ហើយកត់ចំណាំ ថា តើមានបន្ទុកសំខាន់ៗនៅក្នុងតំបន់ទាំងនេះឬទេ
- វាស់កម្រាស់ជាន់ប្លង់សេយ៉ាងហោចណាស់ពីរទីតាំង – រួមទាំងការបញ្ចប់ការវាស់វែងតាមរយៈប្រអប់សម្រាប់រត់ខ្សែភ្លើង (ប្រសិនបើអាច) និងនៅផ្លូវចុះដល់ជណ្តើរ។
- ការងារសម្រេចចំពោះផ្នែកខាងក្នុងដូចជាពិតានជាធម្មតាបិទបាំងគ្រឿងបង្គុំសំណង់។ ក្នុង

ករណីដែលអាចធ្វើទៅបាន ការចេញចូលគួរតែរៀបចំដោយប្រើកាំជណ្តើរ ដើម្បីត្រួតពិនិត្យកន្លែងនៅលើរចនាសម្ព័ន្ធសំណង់ខាងលើ។ យើងត្រូវធានាថា កន្លែងដែលអាចចេញចូលបានខាងលើពិតានត្រូវបានផ្តល់ជូន វិធានការសុវត្ថិភាពចាំបាច់ទាំងអស់ត្រូវបានអនុវត្តដើម្បីទប់ស្កាត់ហានិភ័យដែលអាចកើតមាន។ ប្រសិនបើមានការសង្ស័យ តម្រូវការដើម្បីអនុវត្តការវាយតម្លៃ

- ខាងលើពិតានខ្ពស់គួរតែត្រូវបានរួមបញ្ចូលជាសកម្មភាពតាមដានបន្តសម្រាប់វិស្វកររសំណង់
- វាស់កម្ពស់ដល់ដំបូល និងចុងនៃគ្រោងដែក (height to eaves and apex of steel frame)
- ការប៉ាន់ប្រមាណការផ្ទុកលើជាន់ដែលបានសង្កេតឃើញនៅលើជាន់ប្លង់សេ ជាពិសេសការផ្ទុកឬការដំឡើងជាន់សម្រាប់កន្លែងបោកគក់ឬស្រដៀងគ្នា។ កត់ត្រាតំបន់ណាដែលផ្ទុកលើសចំណុះនៅជាន់នីមួយៗបញ្ឈរពីលើគ្នាជាដើម។
- ចំណាំកន្លែងដែលតំណភ្ជាប់អគារត្រូវបានផ្តល់ឱ្យ។ ពិនិត្យតំណភ្ជាប់ទាំងនេះជាមួយគំនូសប្លង់។ បង្កើតប្រសិនបើមានកម្រាលខណ្ឌកុងស៊ុលនៅតំណសំណង ដូច្នេះការប្រមូលផ្តុំបន្ទុកនៅលើសរសរដែលនៅជាប់គ្នា។ សសរនេះអាចតម្រូវឱ្យមានការត្រួតពិនិត្យគំនូសប្លង់ជាក់លាក់។

នៅពេលបញ្ចប់ការរៀបរាប់ខាងលើ ក្រុមការងារវាយតម្លៃដំណើរការជាមួយនឹងការវាយតម្លៃដែលមើលឃើញផ្ទាល់ភ្នែកនៃតំបន់ជាន់ខ្ពស់ៗ និងជាន់ឡៅតឿ ដោយកត់ត្រានូវភស្តុតាងណាមួយនៃបញ្ហាសំណង់ ការផ្លាត ការខូចទ្រង់ទ្រាយសំណង់ (deflection, warping of structure) ឬស្នាមប្រេះ/ផ្ទុកលើសទម្ងន់នៅលើកម្មវិធីថេប្លេប។ វាក៏មានប្រយោជន៍ផងដែរក្នុងការកត់ត្រាបណ្តុំនៃរូបថតជាន់ទូទៅដែលបង្ហាញពីសំណង់អគារជាឯកសារជំនួយក្នុងការប៉ាន់ប្រមាណនៃបន្ទុកជាន់នៃជាន់ប្លង់សេ។

បើកត់សម្គាល់ឃើញមានបញ្ហាណាមួយ សូមកុំបញ្ឈប់ ហើយដៅចំណុចនេះទុក។ ពិភាក្សាជាមួយមិត្តរួមក្រុមរបស់អ្នកនៅទីតាំងដាច់ដោយឡែកមួយនៅលើជាន់នោះ ហើយប្រគល់ដោយសង្ខេបអំពីចំណុចខ្វះខាតនោះ ប្រសិនបើចាំបាច់។

វាត្រូវបានកត់សម្គាល់ថា អគារភាគច្រើនទំនងជាបង្ហាញពីស្នាមប្រេះដូចជាសរសៃសក់ដែលមើលឃើញផ្ទាល់ភ្នែក។ អ្នកវាយតម្លៃនាំមុខត្រូវប្រើបទពិសោធន៍របស់ខ្លួនដើម្បីកំណត់រកមូលហេតុនៃការប្រេះនេះ នៅពេលណាដែលវាជាការព្រួយបារម្ភ និងយកល្អត្រូវកត់ត្រាទុកជាការសង្កេត។ **កត់ត្រាពីស្នាមប្រេះនៅក្នុងអគារ ប្រសិនបើពួកគេមានការព្រួយបារម្ភ។**

ស្មាមប្រេះត្រង់សសរ ត្រូវធ្វើការវាយតម្លៃដោយប្រុងប្រយ័ត្ននិងកត់ត្រាទុកដោយបានបញ្ចប់ការវាយតម្លៃនៃផ្នែកខាងក្នុងនៃអគារ ធាតុផ្សំនៃសំណង់បេតុងត្រូវធ្វើការពិនិត្យឡើងវិញដើម្បីកំណត់ថាតើសមត្ថភាពរចនាសម្ព័ន្ធនៃសសរពិសេសត្រូវធ្វើការស៊ើបអង្កេតបន្ថែមទៀតដោយការប្រើប្រាស់ការធ្វើតេស្តឧបករណ៍ Ferroscan និង Schmidt hammer នៅកន្លែងណាដែលពាក់ព័ន្ធដែរឬយ៉ាងណា។

មុនពេលធ្វើតេស្តនៅក្នុងកន្លែងណាមួយ សូមពិនិត្យមើលថា តើមានការចូលជាអចិន្ត្រៃយ៍ និងសុវត្ថិភាពសម្រាប់តំបន់ដំបូលខាងក្រៅដែរឬទេ។ នេះនឹងអនុញ្ញាតឱ្យការវាយតម្លៃត្រូវបានអនុវត្តនៅកម្រិតដំបូលខាងក្រៅដើម្បីកំណត់ពីចំណុចខ្វះខាត ឬសក្តានុពលសម្រាប់ការប្រើប្រាស់តំបន់ទាំងនេះ និងការអនុវត្តបន្ទុកដែលបានដាក់។

4.4 ការធ្វើតេស្តមិនបំផ្លិចបំផ្លាញ (Non-Destructive Testing)

ការធ្វើតេស្តរចនាសម្ព័ន្ធត្រូវបានអនុវត្តនៅពេលបញ្ចប់ការវាយតម្លៃទីតាំង។ គោលបំណងនៃការធ្វើតេស្តលើគ្រឿងបង្គុំបេតុងគឺដើម្បីបង្កើត "ការប៉ាន់ប្រមាណ" ពីភាពធន់/គុណភាពបេតុង និងដើម្បីកំណត់ពីបេតុងអាមេនៅក្នុងគ្រឿងបង្គុំសំណង់សំខាន់ៗនៃអគារ។

ការធ្វើតេស្តសសរជាធម្មតាត្រូវបានអនុវត្តនៅកម្រិតជាន់ទាបបំផុត ហើយពាក់ព័ន្ធនឹងការស្កេន ធ្វើតេស្ត Ferro និង Schmidt Hammer - ជាពិសេសលើសសរពីរ (ដែលត្រូវបានវាយតម្លៃថាមានបន្ទុកធ្ងន់ជាង) នៅក្នុងអគារនីមួយៗ ឬដំណាក់កាលសាងសង់នៃអគារដែលកំពុងត្រួតពិនិត្យ។

4.4.1 ការប្រើប្រាស់ Ferro scanner

គ្រឿងបរិក្ខារនេះ ប្រសិនបើប្រើប្រាស់ដោយប្រុងប្រយ័ត្ន អាចបង្ហាញពីអ្វីដែលបេតុងអាមេនៅខាងក្នុងគ្រឿងបង្គុំបេតុង។ នេះគឺជាព័ត៌មានសំខាន់សម្រាប់សំណង់បេតុង នៅពេលអនុវត្តការត្រួតពិនិត្យបញ្ជាសសរ និងវាយតម្លៃសុវត្ថិភាពអគារ
បច្ចេកវិទ្យាចុងក្រោយបង្អស់នៅក្នុង Ferroscanner ត្រូវបានប្រើដូចជា PS250 ពី Hilti ដែលអនុញ្ញាតឱ្យយើងធ្វើការប៉ាន់ស្មានលើទំហំបេតុងតែមួយ (single concrete face)៖

- ចំនួននិងទីតាំងនៃសរសៃដែក
- អង្កត់ផ្ចិតសរសៃដែក

- ស្រទាប់ការពារបេតុង

សូមចំណាំថា លទ្ធផលគឺជាការប៉ាន់ស្មាន ហើយត្រូវបកស្រាយដោយប្រើការវិនិច្ឆ័យវិស្វកម្មប្រកបដោយហេតុផលរបស់អ្នក។

មានការធ្វើតេស្តពីរប្រភេទដែលអាចអនុវត្តបានដោយប្រើ Ferroscan – "ការស្កេនរហ័សដែលវាល់ពេលដែលសរែដែកត្រូវបានកំណត់ និងដោយប្រើអេក្រង់ Ferroscan" ការធ្វើតេស្តពេញលេញ" ដែលផលិតរូបភាពបែបបង្ហាញពីការពង្រឹងដែលបានផ្តល់ឱ្យនៅក្នុងធាតុផ្សំមួយ។
ការស្កេនរហ័សត្រូវបានអនុវត្តដើម្បីកំណត់គម្លាតតំណយ៉ាងហោចណាស់សសរពីរនិងធ្នឹមពីរនៅកម្រិតទាបបំផុត។ គោលបំណងគឺដើម្បីបង្កើតប្រសិនបើតំណភ្ជាប់ត្រូវបានផ្តល់នៅគម្លាតកាន់តែជិតនៅចំណុចប្រសព្វសសរ/ធ្នឹម ដោយអនុលោមតាមការអនុវត្តល្អិតល្អន់។

ការពិពណ៌នាលម្អិតអំពីការប្រើប្រាស់ Ferroscan ត្រូវបានដាក់បញ្ចូលនៅក្នុងឧបសម្ព័ន្ធ B1។ ការធ្វើតេស្តទាំងនេះត្រូវបានអនុវត្ត ហើយលទ្ធផលត្រូវបានត្រួតពិនិត្យមុនពេលចាកចេញពីរោងចក្រ។ វាត្រូវបានណែនាំឱ្យព្យាយាមក្រិតតាមខ្នាតពីលទ្ធផលរកឃើញទាំងនេះនៅគ្រប់ទីកន្លែងដែលអាចធ្វើទៅបានដោយប្រៀបធៀបលទ្ធផលជាមួយនឹងបេតុងអាមេសសរនៅក្នុងសសរនៅក្នុងអគារ។

4.4.2 ការប្រើឧបករណ៍ Schmidt និង Geological Hammer

ឧបករណ៍ Schmidt ឬ Rebound Hammer វាស់ពីភាពរឹងនៃផ្ទៃបេតុង។ វាមិនត្រូវបានស្នើឱ្យប្រើប្រាស់លទ្ធផលដែលបានពីការធ្វើតេស្តនេះជាការវាស់វែងដាច់ខាតពីភាពរឹងដែលបានបង្ហាប់របស់បេតុងនោះទេ ប៉ុន្តែជាសូចនាករដែលត្រូវវាយតម្លៃផ្នែកវិស្វកម្ម និងដើម្បីផ្តល់នូវ "អារម្មណ៍" ដ៏ល្អសម្រាប់បេតុង។ ភាពរឹងដែលទាក់ទងរវាងធាតុផ្សំក៏អាចផ្តល់នូវសូចនាករមានប្រយោជន៍ផងដែរ។ ឧបករណ៍ Schmidt Hammer មានតួនាទីដ៏មានសារៈសំខាន់ក្នុងការជួយវិស្វកសំណង់ដែលមានបទពិសោធន៍ក្នុងការធ្វើការវាយតម្លៃ។ ដំណើរការនៃការយកចេញនូវការបូកបាយអរធានាថាវិស្វករៀបចំផ្ទៃបេតុង (មិនមែនការបូកបាយអរ) សម្រាប់ការធ្វើតេស្ត Schmidt Hammer ។ បន្ទាប់ពីការបូក (render)ត្រូវបានដកចេញ អ្នកវាយតម្លៃត្រូវយកញញ្ជួរដំលើផ្ទៃបេតុងនោះ ជាពិសេសត្រង់ជ្រុងសសរ។ ការដំលើផ្ទៃបេតុងជាមួយនឹងញញ្ជួរភូមិសាស្ត្រផ្តល់នូវឱកាសដើម្បីទទួលបាននូវអារម្មណ៍សម្រាប់ភាពធន់នៃបេតុងជាមុននៃការធ្វើតេស្តដោយប្រើឧបករណ៍ Schmidt hammer ។ បេតុងល្អនឹងពិបាកនឹងបំបែកខ្លាំងណាស់ដោយការប្រើឧបករណ៍ដែកត្រសេះ (geological hammer b) ប៉ុន្តែ

បេតុងអន់វិញអាចបំបែកបានយ៉ាងងាយស្រួល។

ដំណើរការនេះផ្តល់នូវព័ត៌មានដែលមិនអាចកាត់ថ្លៃបាន ដើម្បីជួយដល់ការវិនិច្ឆ័យផ្នែកវិស្វកម្ម។ ការណែនាំបន្ថែមលើការធ្វើតេស្តសំណង់ត្រូវបានដាក់បញ្ចូលនៅក្នុងឧបសម្ព័ន្ធ B2។
លើសពីនេះ វាត្រូវបានផ្តល់អនុសាសន៍ថា បេតុងអាមេត្រូវបានបង្ហាញនៅក្នុងចំនួនសសរសំខាន់ៗ ដែលបានជ្រើសរើសដើម្បីកំណត់គំរូនៃគ្រោងនៅលើបេតុងអាមេ។

4.5 បញ្ជីត្រួតពិនិត្យព័ត៌មានសំណង់សំខាន់ៗ

ព័ត៌មានសំខាន់ដែលត្រូវការសម្រាប់ការបញ្ចប់ការវាយតម្លៃរចនាសម្ព័ន្ធសំណង់គឺដូចក្នុងឧបសម្ព័ន្ធ D1។ ក្រុមការងារវាយតម្លៃមិនត្រូវចាកចេញពីអោងចក្រដោយមិនបានបង្កើតព័ត៌មាននេះទេ។ ប្រើបញ្ជីត្រួតពិនិត្យនេះនៅពេលសម្ភាស នៅកម្រិតនីមួយៗ និងនៅលើការដើរមើលផ្នែកខាងក្រៅ។ ត្រូវពិចារណាលើការរៀបចំរចនាសម្ព័ន្ធសំណង់សំខាន់ៗជាមុនសិន (ឧ. ការផ្ទេរបន្ទុក និងប្រព័ន្ធស្ថិរភាព) បន្ទាប់មកចាប់ផ្តើមពិនិត្យមើលស្ថានភាព/ចំណុចខ្វះខាត។

ប្រព័ន្ធរចនាសម្ព័ន្ធសំណង់

ចំនួនជាន់ (រាស់ពីជាន់មួយទៅជាន់មួយ) បានរាស់គម្លាតអ័ក្សសំណង់ កម្រាស់ជាន់ កម្រាស់ការ៉ែនិងសាច់បាយអរ
ទំហំសសរ (ដោយគ្មានបូកបាយអរ) នៅកម្រិតទាបបំផុត និងតំបន់សំខាន់ៗ

ភាពរឹងមាំនៃបេតុង - ធ្វើការសង្កេតបន្ទាប់ពីការយកម្នាងសិលាចេញរហូតដល់សសរ និងការប្រើប្រាស់បឋឧបករណ៍ Schmidt hammer

ការប៉ាន់ប្រមាណនៃបេតុងអាមេនៅក្នុងធាតុផ្សំបេតុងសំខាន់ៗ (Ferroscanner) បានសង្កេតឃើញការផ្ទុកថ្នាល់នៅកម្រិតនីមួយៗ

កម្ពស់ពីជាន់ដល់ពិតាន

ទំហំធ្មឹមខាងបណ្ឋរក្រោមធម្មតា កន្លែងតំណភ្ជាប់

នៅចុងបញ្ចប់នៃការវាយតម្លៃជាន់នីមួយៗ វិស្វកត្រូវពិនិត្យមើលបញ្ជីនេះ ដើម្បីធានាថា ព័ត៌មានទាំងអស់ត្រូវបានទទួល។
ប្រសិនបើរោងចក្រត្រូវបានសាងសង់ជាដំណាក់កាល (ការពង្រីក ឬការសាងសង់អគារបន្ថែម) ព័ត៌មានដូចគ្នាត្រូវបានបង្កើតឡើងសម្រាប់ដំណាក់កាលនីមួយៗ។

4.6 ការវាយតម្លៃរសំណង់ និងការគណនា

ផ្នែកនេះផ្តល់នូវការអត្ថាធិប្បាយទូទៅ និងការណែនាំអំពីការវាយតម្លៃដោយការគណនានៅក្នុងប្រទេសកម្ពុជា។ ព័ត៌មានលម្អិតដែលមាននៅទីនេះទទួលបានតាមរយៈការពិភាក្សាជាមួយអ្នកអនុវត្តន៍ក្នុងស្រុក ការសង្កេតដោយផ្ទាល់ភ្នែកដោយអ្នកនិពន្ធ និងការស្រាវជ្រាវលើឯកសារនិងអត្ថបទដែលបានបោះពុម្ពផ្សាយ។

គេយល់ថា រោងចក្រភាគច្រើនជាសំណង់គ្រោងដែក ហើយព័ត៌មានអំពីកម្រិតដែកត្រូវបានដាក់បញ្ចូលនៅចុងបញ្ចប់នៃផ្នែកនេះដើម្បីសម្រួលដល់ការគណនាបឋមលើរចនាសម្ព័ន្ធសំណង់បែបនេះ ប្រសិនបើចាំបាច់។

ទោះយ៉ាងណា យ៉ាងហោចណាស់មានអាគារធ្វើពីបេតុងច្រើនជាន់ (RC) ដែលនឹងត្រូវការការវាយតម្លៃបន្ថែម។ ដោយសាររបៀបបរាជ័យសម្រាប់សសរ RC អាចនឹងផុយ និងផ្តល់ការព្រមានតិចតួចអំពីបញ្ហាគ្រោះមហន្តរាយ ការត្រួតពិនិត្យទាំងនេះគឺជាផ្នែកសំខាន់នៃវិធីសាស្ត្រនេះ។

ផ្នែកនេះត្រូវបានបង្កើតឡើងដើម្បីជួយក្រុមការងារវាយតម្លៃនៅលើមូលដ្ឋានក្នុងការធ្វើការសន្មតដំបូងលើភាពរឹងមាំនៃបេតុង ផលប៉ះពាល់នៃបរិមាណនៃបេតុងអាមេត្រង់សសរ និងការឈានដល់ការពិនិត្យមើលពីកម្រិតមូលដ្ឋាននៃបញ្ហាការងារ និងកត្តាសុវត្ថិភាពដែលអាចមាននៅក្នុងសសរក្នុងអំឡុងពេលវាយតម្លៃ។ កំណត់ចំណាំពន្យល់ពីសាវតារ និងការបង្កើតវិធីសាស្ត្រស្តីពីបញ្ហាការងារសម្រាប់កំណត់ "លំដាប់នៃ" បញ្ហាការងារ និងកត្តាសុវត្ថិភាពសម្រាប់ការវាយតម្លៃសុវត្ថិភាព។

4.6.1 ភាពធន់នៃសសរ និងបញ្ហាសសរ

ការវាយតម្លៃឈរលើមូលដ្ឋានដែលបានមើលឃើញផ្ទាល់ភ្នែកនឹងកំណត់ពីធាតុផ្សំដែលអាចបង្ហាញសញ្ញានៃបញ្ហា ការយារធ្លាក់/ខូចទ្រង់ទ្រាយ ឬស្នាមប្រេះ។ ចំណុចនៃភាពបរាជ័យនៃធាតុផ្សំអាចជាការលំបាកក្នុងការវិនិច្ឆ័យ ជាពិសេសនៅក្នុងអគារដែលលេចឡើងក្នុងលក្ខខណ្ឌសមហេតុផល។ ប្រសិនបើអគារមានការប្រេះស្រាំ ការបូកបាយអរឡើងវិញ និងត្រូវបានលាបថ្នាំទៀតនោះ

លក្ខណៈនៃបញ្ហាប្រហែលជាមិនត្រូវបានគេសង្កេតឃើញនោះទេ។
គ្រឿងបង្គុំ Flexural (ធ្នឹម និងកម្រាលខណ្ឌ) ទំនងជានឹងខូចក្នុងទម្រង់ជាបំពង់ (អាស្រ័យលើភាពរឹងមាំ និងបរិមាណបេតុងអាមេ) ហើយក្នុងករណីជាច្រើន នឹងផ្តល់ការព្រមានសមហេតុផលជាមួយនឹងភាពដាប និងមានស្នាមប្រេះដែលបង្ហាញពីការដួលរលំក្នុងរយៈពេលណាមួយ។
ប៉ុន្តែ សសរអាចបាក់ភ្លាមៗ ហើយអាចផ្តល់ការព្រមានតិចជាងមុន នៅពេលដែលវាខិតទៅរកការបាក់នោះ។ ដូច្នេះ ការផ្តោតសំខាន់នៃការវាយតម្លៃគួរតែបង្កើតទាំងស្ថានភាព និងលក្ខណៈទំហំនៃសសរទ្រទម្ងន់ និងការផ្ទុកដែលបានអនុវត្តសម្រាប់ទាំងសេណារីយ៉ូដែលមានស្រាប់ និងនាពេលអនាគត។

ជាទូទៅ វាត្រូវបានទទួលយកជាអន្តរជាតិថា វាមិនសមហេតុផលទេក្នុងការដាក់បន្ទុកលើអគារដែលមានស្រាប់ ដោយសារតែការមិនអនុលោមតាមកូដអគារបច្ចុប្បន្ន ដោយសារអគារបែបនេះជាច្រើនបានដំណើរការល្អតាមពេលវេលា។ ប្រព័ន្ធជាក់ស្តែងមួយត្រូវបានបង្កើតឡើងដោយផ្អែកលើវិធីសាស្ត្រវាយតម្លៃយ៉ាងឆាប់រហ័សដើម្បីកំណត់អត្តសញ្ញាណអគារសំខាន់ៗនៅដំណាក់កាលដំបូង និងផ្តល់អាទិភាពដល់សកម្មភាពនានា។ ដើម្បីអនុញ្ញាតឱ្យវិស្វករសំណង់អនុវត្តការវាយតម្លៃដើម្បីស្វែងយល់ពីស្ថានភាពសសរ វិធីសាស្ត្រស្តីពីបញ្ហាការងារត្រូវបានអនុម័តសម្រាប់ការវាយតម្លៃសុវត្ថិភាពបឋម។

វិធីសាស្ត្រនេះគឺជាវិធីសាស្ត្រដ៏រហ័ស លំដាប់លំដោយនៃវិធីសាស្ត្រ និងផ្តល់នូវវិធីនៃការបង្កើតបងញ្ហាការងារនៅក្នុងធាតុផ្សំមួយ ហើយប្រៀបធៀបវាទៅនឹងសមត្ថភាពរំពឹងទុកជាទូទៅដោយផ្អែកលើបរិមាណនៃបេតុងអាមេដែលបានអង្កេត/ប៉ាន់ស្មាន។ គោលការណ៍នៃវិធីសាស្ត្រនៃបញ្ហាការងារគឺដើម្បីគណនាភាពរឹងមាំនៃបេតុងដែលអាចបាក់ និងបញ្ហាការងារ (ផ្អែកលើលក្ខខណ្ឌដែលបានសង្កេត) ហើយពីការគណនានេះ ដែលហៅថា កត្តាសុវត្ថិភាព (FOS) ។

នេះផ្តល់នូវសូចនាករដ៏មានតម្លៃនៃកម្រិតសុវត្ថិភាពនៃរចនាសម្ព័ន្ធសំណង់ ដោយផ្អែកលើអ្វីដែលអាចត្រូវបានគេសង្កេតដោយសមហេតុផលពីការចុះទៅពិនិត្យរោងចក្រ។ វាមិនមែនជាការគណនាច្បាស់លាស់នៃសមត្ថភាពចុងក្រោយដើម្បីបំពេញតាមតម្រូវការកូដនោះទេ ចាត់ទុកវាជាភាពធន់ដែលមានសក្តានុពលនៅក្នុងអគារ។
កត្តាសសរស្តីពីជំហាននៃការគណនាសុវត្ថិភាពត្រូវបានសង្ខេបដូចខាងក្រោម៖

1. កំណត់សសរសំខាន់ៗ (សសរទ្រទម្ងន់ធ្ងន់ៗ ការបន្ថែមនៅដំបូល ធុងទឹក ឬបន្ទុកធ្ងន់ៗ (live

loads)។ តែម ឬជ្រុងសសរក៏អាចមានសារៈសំខាន់ផងដែរទាក់ទងនឹងទំហំ និងការផ្ទុក។ ជាធម្មតា យ៉ាងហោចណាស់សសរខាងក្នុង កាច់ជ្រុង និងសសរតែមត្រូវបានវាយតម្លៃ។

2. អនុវត្តលើទម្ងន់ផ្ទុកសម្រាប់សសរ។ សូមមើលការណែនាំអំពីការផ្ទុកនៅតាមរោងចក្រកាត់ដេរ សម្លៀកបំពាក់ ស្បែកជើង កាបូប និងគ្រឿងបន្សំនៅក្នុងឧបសម្ព័ន្ធ C។ គណនាពីទម្ងន់ផ្ទុកឱ្យបានត្រឹមត្រូវតាមដែលអាចធ្វើទៅបាន។ គណនាបញ្ហាការងារត្រង់សសរតាមចំណុច 4.6.7។ កំណត់កត្តាផ្ទុកមួយកន្លែងបូករួមនឹងកត្តាផ្ទុកធ្ងន់ៗសម្រាប់សសរនៅកម្រិតជាន់ទាបបំផុត ហើយគណនាកត្តាបញ្ហានៅត្រង់សសរនោះ។
3. កំណត់ភាពរឹងមាំជាក់ស្តែងសម្រាប់បេតុង និងបេតុងអាមេដោយផ្អែកលើឆ្នាំសាងសង់ ដូចដែលបានពិពណ៌នានៅក្នុងចំណុច 4.6.3 និងចំណុច 4.6.4។
4. គណនាសមត្ថភាពអ័ក្សដំណើរការរបស់សសរដោយប្រើរូបមន្តក្នុងចំណុច 4.6.6
5. កំណត់ FOS = សមត្ថភាពការងារ (ជំហានទី 4) / កត្តាបញ្ហា (ជំហានទី 2)
6. វាយតម្លៃសសរសម្រាប់ធាតុផ្សំសកម្មភាពដែលបានណែនាំដោយផ្អែកលើកម្រិត FOS ដូចដែលបានពិពណ៌នានៅក្នុងចំណុច 4.6.8 ។

4.6.2 កត្តាសុវត្ថិភាព

បទប្បញ្ញត្តិរបស់ប្រទេសកម្ពុជា និងក្រមអន្តរជាតិដែលពាក់ព័ន្ធ មានទាំងកត្តាសម្ភារ និងកត្តាផ្ទុក ហើយវិធីសាស្ត្រកម្រិតរបស់រដ្ឋត្រូវបានអនុម័ត។ ក្រមនេះចែងថា សម្រាប់អគារបេតុងដែលមានបន្ទុកធ្ងន់ៗ 2kN/m2 ឬច្រើនជាងនេះ កត្តាផ្ទុកនៃ 1.1 សម្រាប់បន្ទុកស្រាលៗ (dead load) និង 1.2 សម្រាប់បន្ទុកធ្ងន់ៗគួរតែត្រូវបានអនុវត្តនៅពេលកំណត់ចំពោះស្ថានភាពដែនកំណត់ចុងក្រោយ។ នៅពេលវាយតម្លៃរចនាសម្ព័ន្ធសំណង់ដែលមានស្រាប់ កូដអន្តរជាតិអនុញ្ញាតឱ្យប្រើកត្តាកាត់បន្ថយបន្ទុក (ឬការកើនឡើងកត្តាកាត់បន្ថយភាពរឹងមាំក្នុងករណីខ្លះ)។ ករណីបែបនេះអាចកើតឡើងនៅពេលដែល៖

- បន្ទុកមានចលនាអាចត្រូវបានគេវាយតម្លៃ សង្កេត និងគ្រប់គ្រងបានយ៉ាងត្រឹមត្រូវជាងមុន
- ក្នុងករណីដែលអាចធ្វើទៅបានដើម្បីវាស់វិមាត្ររចនាសម្ព័ន្ធសំណង់ (ពោលគឺភាពមិនប្រាកដប្រជានៅក្នុងបន្ទុកមួយកន្លែងត្រូវបានកាត់បន្ថយ)។

វិធីសាស្ត្របែបនេះចំពោះការកាត់បន្ថយកត្តាផ្ទុកសម្រាប់ការវាយតម្លៃរចនាសម្ព័ន្ធសំណង់ដែលមានស្រាប់ត្រូវបានកំណត់នៅក្នុង "ការវាយតម្លៃរចនាសម្ព័ន្ធសំណង់ដែលមានស្រាប់" ដោយវិទ្យាស្ថានវិស្វកររសំណង់ (2010) ។

ទោះជាយ៉ាងណា វាជាទស្សន:របស់យើងដែលថា វាមិនសមស្របសម្រាប់ការប្រើប្រាស់នៅក្នុងប្រទេសកម្ពុជានោះទេ ដោយសារកត្តានៃការផ្ទុកមានកម្រិតទាបរួចទៅហើយ បើប្រៀបធៀបជាមួយនឹងក្រមអន្តរជាតិ។ ដូចនេះ ការកាត់បន្ថយភាពមិនច្បាស់លាស់ដោយសារការកត់ត្រាទំហំនៃគ្រឿងបង្គុំសំណង់ដែលបានសាងសង់ ផ្តល់តែកម្រិតសុវត្ថិភាពបន្ថែមតិចតួចប៉ុណ្ណោះ។ ជាទូទៅនេះមិនត្រូវយកមកពិចារណានៅក្នុងការវាយតម្លៃបឋមនោះទេ។
សម្រាប់សសរបេតុងដែលមានលក្ខណ:សាមញ្ញដែលដើរតួក្នុងការបង្ហាប់តែមួយគត់ កត្តាសុវត្ថិភាពជាសាកលនៅក្នុងកូដអន្តរជាតិគឺប្រហែល 1.7 ដោយគិតគូរពីកត្តាផ្ទុក និងកត្តាសម្ភារ។

4.6.3 ភាពធន់នៃបេតុង

ភាពធន់នៃបេតុងដែលប្រើក្នុងអគារ RC គឺមានភាពប្រែប្រួល។ ក្នុងអំឡុងពេលនៃការចុះពិនិត្យទីតាំង ជាទូទៅគេមិនស្គាល់ពីភាពរឹងមាំនៃបេតុងនោះទេ ដូច្នេះយើងត្រូវមានគំនិតខ្លះៗអំពីលំដាប់នៃទំហំនៃភាពធន់នៃបេតុង។
តួលេខភាពធន់បង្ហាប់បេតុងលក្ខណ:អប្បបរមាដែលបានណែនាំរបស់យើង (ឧទាហរណ៍កម្រិត B) គឺ 15MPa ។
សូមចំណាំថា តួលេខភាពធន់នេះអាចមានការផ្លាស់ប្តូរ ដោយសារទិន្នន័យ និងព័ត៌មានថ្មីដែលមាន។

4.6.4 ភាពធន់នៃបេតុងអាមេ (fyk)

មានភាពធន់ជាច្រើននៃបេតុងអាមេដែលប្រើក្នុងប្រទេសកម្ពុជា ហើយវាទាក់ទងនឹងការនាំចូលដើម។ ដើម្បីកំណត់កម្រិតនៃបេតុងអាមេ យើងត្រូវលើយកគំរូសម្រាប់ការធ្វើតេស្ត។
ជាទូទៅ យើងសង្ខេបពីភាពរឹងមាំនៃបេតុងអាមេនៅក្នុងតារាងខាងក្រោម៖

បេតុងអាមេ				
កម្រិតបេតុងអាមេ	សរសៃដែកធម្មតា	សរសៃដែកថ្នាំងអំពៅ៖ ប្រភេទ 1	សរសៃដែកថ្នាំងអំពៅ៖ ប្រភេទ 2	សរសៃដែកថ្នាំងអំពៅ៖ ប្រភេទ 3
ភាពធំនៃសរសៃដែក (MPa)	230	230	230	230

4.6.5 បរិមាណបេតុងអាមេ

រាល់ការខិតខំប្រឹងប្រែងត្រូវធ្វើឡើងដើម្បីបង្កើតតំបន់និងភាគរយនៃបេតុងអាមេដោយប្រើ Ferroscanner ។

ប្រសិនបើតំបន់ប្រើប្រាស់បេតុងអាមេមិនអាចបង្កើតបាន ប៉ុន្តែចំនួនសរសៃដែក(តាមរយៈមធ្យោបាយ Ferroscanner) អាចសន្មតថា ចម្រឹងដែកដែលមានអង្កត់ផ្ចិត 12mm ហើយគណនាភាគរយនៃបេតុងអាមេពីនេះ។

ប្រសិនបើការប្រើប្រាស់ Ferroscanner មិនអាចផ្តល់ទាំងផ្ទៃ ឬអង្កត់ផ្ចិតនៃបេតុងអាមេនោះ ចម្រឹងដែកសំខាន់ៗត្រូវបានបង្ហាញដោយការដកគម្របបេតុងចេញដោយប្រុងប្រយ័ត្នបំផុតនៅក្នុងមូលដ្ឋាននៅក្នុងទីតាំងដែលបានជ្រើសរើស។

ប្រសិនបើគ្មានលទ្ធភាពខាងលើទេ ត្រូវសន្មតថា ភាគរយនៃបេតុងអាមេអប្បបរមាគឺ 0.1% ។ នេះជាសក្តានុពលអភិរក្សខ្លាំងណាស់ អាចមានឥទ្ធិពលច្រើនសម្រាប់រោងចក្រ ហើយដូច្នេះគួរត្រូវបានអនុម័តជាមធ្យោបាយចុងក្រោយដាច់ខាត។

4.6.6 សមត្ថភាពដំណើរការរបស់សសរ

សម្រាប់វិធីសាស្ត្របញ្ហាការងារ សមត្ថភាពដំណើរការរបស់សសរត្រូវបានគណនាដោយប្រើរូបមន្តខាងក្រោម៖

P = B(100-ρ)/100+ρ*fyk/100 បើ៖

P = សមត្ថភាពដំណើរការសសរក្នុង MPa

B = លក្ខណៈភាពធន់គូបបង្ហាប់ (characteristic compressive cube strength)

ρ = បេតុងអាមេ (ជា% នៃផ្ទៃផ្នែកឆ្លងកាត់នៃសសរ)

fyk = ភាពធន់នៃលក្ខណៈបេតុងអាមេ

4.6.7 កត្តាបញ្ហាផ្នែកសសរ

កត្តាបញ្ហាផ្នែកសសរសំខាន់គួរត្រូវបានកំណត់ ដោយប្រើការដកបន្ទុកត្រឹមត្រូវ ដោយពិចារណាលើកត្តាផ្ទុកសមស្រប។ ការដកបន្ទុកបែបនេះត្រូវគិតគូរពីឥទ្ធិពលនៃការសាងបន្ទុកធម្មតា ការសាងសង់ជាន់ និងបន្ទុកធ្ងន់ៗដែលបានសង្កេតឃើញ។ គេក៏ត្រូវពិចារណាផងដែរអំពីធរណីមាត្រនៃការសាងសង់ និងបណ្តាលឱ្យមានផលប៉ះពាល់បន្តលើសសរខាងក្នុងតាំងពីដំបូង។ ការលើកឡើងនៃ c. 10% នៃបន្ទុកគួរត្រូវបានពិចារណាសម្រាប់ស្ថានភាពបែបនេះ។

4.6.8 ការវាយតម្លៃសសរ

បញ្ហាការងារនៅក្នុងសសរគួរតែត្រូវបានប្រៀបធៀបទៅនឹងសមត្ថភាពការងារដើម្បីកំណត់កត្តាសុវត្ថិភាពសាកលដែលអាចកើតមាននៅក្នុងគំនូសប្លង់សសរ និងសកម្មភាពដែលបានកំណត់ដូច

ខាងក្រោម៖

កត្តាសុវត្ថិភាព (FOS) = សមត្ថភាពការងារ / កត្តាបញ្ហា

- ប្រសិនបើ FOS> 1.7 - មិនមានសកម្មភាពទៀតទេ
- ប្រសិនបើ 1.7>FOS>1.25 – ធាតុផ្សំសកម្មភាពអាទិភាព 1 ដែលនាំទៅដល់ការកំណត់កូដពណ៌ Amber ចាំបាច់ (សូមមើលជំពូកស្តីពីការចាត់ថ្នាក់ហានិភ័យអគារទាំងមូល)
- ប្រសិនបើ 1.25> FOS – ធាតុផ្សំសកម្មភាពអាទិភាព 1 ដែលនាំទៅដល់ការកំណត់កូដពណ៌ក្រហមជាចាំបាច់ និងការបិទអគារចោល
- សម្រាប់ FOS < 1.7 ណាមួយ សកម្មភាពខាងក្រោមក៏ចាំបាច់ផងដែរ៖
- ការវាយតម្លៃវិស្វកម្មលម្អិត (DEA) ទាមទារជាសកម្មភាពតាមដាន (សូមមើលស្តង់ដារ LABS សម្រាប់ព័ត៌មានលម្អិត)
- ស្នូលបេតុងគួរត្រូវបានគេយកទៅផ្ទៀងផ្ទាត់ភាពធន់នៃបេតុងនៅក្នុងសសរ (សូមមើលស្តង់ដារ LABS សម្រាប់ព័ត៌មានលម្អិត)

4.6.9 កម្រិតដែកសំណង់

តារាងខាងក្រោមរួមបញ្ចូលព័ត៌មានលម្អិតនៃកម្រិតដែកសំណង់ដែលគួរត្រូវអនុម័តប្រសិនបើចាំបាច់។

កម្រិតដែកសំណង់				
	SD235	**SD295**	**SD390**	**SD500**
ភាពធន់នៃកម្រិតដែក (MPa)	235	295	390	500
ភាពធន់នៃគំនូសប្លង់ (MPa)	235	295	390	500

4.6.10 គ្រោះថ្នាក់ក្រៅពីគ្រឿងបង្គុំ

គ្រោះថ្នាក់ក្រៅពីគ្រឿងបង្គុំសំណង់នឹងត្រូវបានពិចារណាដោយផ្អែកលើបញ្ជីត្រួតពិនិត្យមិនមែនជាសំណង់ ASCE 41- 17 មូលដ្ឋានខាងក្រោម។ ធាតុផ្សំទាំងនេះនឹងត្រូវបានប្រើជាគោលការណ៍ណែនាំដើម្បីបង្ហាញពីចំណុចដែលមិនមែនជាគ្រឿងបង្គុំសំណង់ដែលអាចប៉ះពាល់ដល់សុវត្ថិភាពអាយុជីវិត។ ការសង្កេតនឹងត្រូវបានសង្ខេបនៅក្នុងស្លាយមួយ/ពីរនៅក្នុងរបាយការណ៍នេះ ហើយការត្រួតពិនិត្យលម្អិតបន្ថែមទៀតលើធាតុផ្សំទាំងនេះនឹងត្រូវបានណែនាំជាសកម្មភាពបន្ថែម

ប្រសិនបើចាត់ទុកថាចាំបាច់។

បញ្ហាធម្មតាដែលអាចត្រូវបានគេសង្កេតឃើញនៅក្នុងរោងចក្រ RMG ស្បែកជើង ការបូប និងគ្រឿងបន្សំ អាចត្រូវបានសង្ខេបដូចខាងក្រោម៖

- វត្ថុគ្រោះថ្នាក់ធ្លាក់ពីផ្នែកខាងក្រៅណាមួយពីអគារ ដូចជាធុងទឹកដាក់នៅទីខ្ពស់ ផ្លាកសញ្ញា ឧបសម្ព័ន្ធ ប៉មទំនាក់ទំនង មិនត្រូវបានភ្ជាប់គល់ត្រឹមត្រូវ (not properly anchored)
- គ្រឿងបរិក្ខារដែលមានវត្ថុគ្រោះថ្នាក់ មិនត្រូវបានភ្ជាប់គល់ត្រឹមត្រូវទៅនឹងជាន់ណាមួយ និងដាក់បញ្ឈរចោល (freestanding)
- អំពូលភ្លើងតាំងធុនធ្ងន់មិនត្រូវបានទ្រភ្ជាប់ឱ្យបានត្រឹមត្រូវទៅនឹងផ្នែកកម្រាលខណ្ឌ ប៉ុន្តែចងទៅនឹងពិតានប្លង់សេទៅវិញ
- បំពង់ពន្លត់អគ្គិភ័យ មិនបានចង ឬកៀបឱ្យបានត្រឹមត្រូវ
- ការរៀបឥដ្ឋ/ការរៀបឥដ្ឋប្រហោងមិនបានកៀបពង្រឹងឱ្យបានត្រឹមត្រូវ (Brickwork/blockwork partitions walls not braced)រៀងរាល់ 3m ហើយងាយនឹងមានការធ្លាក់បាក់ណាស់
- ក្តារពិតានប្លង់សេ (Suspended gypsum board ceilings) ដែលមិនមានភ្ជាប់ត្រឹមត្រូវសម្រាប់រាល់ 1m2នៃតំបន់
- ធាតុផ្សំដែក/កញ្ចក់ មិនត្រូវបានចងឱ្យបានត្រឹមត្រូវនៅរៀងរាល់ 2 ម៉ែត្រ
- បង្គាន់ដៃ URM ដែលមិនត្រូវបានទ្រត្រឹមត្រូវដែលមានបង្គោលចម្ងាយមិនលើសពី 2.5 ម៉ែត្រ ដែលមានសមាមាត្រកម្ពស់ទៅកម្រាស់លើសពី 2.5 នៅក្នុងតំបន់ដែលមានកម្រិតមធ្យម ខ្ពស់ល្មម និងខ្ពស់ខ្លាំងនៃតំបន់ដែលមានការរញ្ជួយដី
- ធ្នើរដាក់អីវ៉ាន់/ទូ ដែលងាយនឹងក្រឡាប់ ខ្វះការកៀបចង និងមិនមានការចងឱ្យបានត្រឹមត្រូវ
- ប៉ារាំ (Canopies) នៅច្រកចេញនៃអគារមិនត្រូវបានចងឱ្យបានត្រឹមត្រូវទៅនឹងសំណង់នៅចម្ងាយមិនលើសពី 3 ម៉ែត្រ។

5 វិធីសាស្ត្រវាយតម្លៃអគ្គិភ័យ

5.1 ចំណុចទូទៅ

នៅពេលបញ្ចប់ការសម្ភាសអ្នកគ្រប់គ្រងរោងចក្រ និងការត្រួតពិនិត្យឯកសារួចមក ការវាយតម្លៃទីតាំងអគារចាប់ផ្តើម។
គោលបំណងនៃការវាយតម្លៃគឺដើម្បីសង្កេតមើល និងកត់ត្រារាល់ការធ្វេសប្រហែសនឹងសុវត្ថិភាពអគ្គិភ័យ និងការមិនអនុលោមតាមស្តង់ដារ LABS សម្រាប់សុវត្ថិភាពអគ្គិភ័យនៅក្នុងអគាររោងចក្រកាត់ដេរ សម្លៀកបំពាក់ ស្បែកជើង កាបូប និងគ្រឿងបន្សំ។
ក្នុងអំឡុងពេលកិច្ចប្រជុំអ្នកគ្រប់គ្រងរោងចក្រលម្អិតនៅក្នុងផ្នែកទី 3 ខាងលើ ព័ត៌មានខាងក្រោមគួរត្រូវទទួលបាន៖

- ការប្រើប្រាស់អគារនីមួយៗ ឬផ្នែកនៃអគារ ដែលអគារមានការប្រើប្រាស់ខុសៗគ្នា។ ដោយផ្អែកលើព័ត៌មាននេះ អ្នកវាយតម្លៃនឹងកំណត់ថាតើអគារចំនួនប៉ុន្មាន និងអគារណាខ្លះនឹងត្រូវបានចាត់ថ្នាក់ជាលក្ខណៈបុគ្គលនៅក្នុងរបាយការណ៍វាយតម្លៃ។
- ចំនួនអ្នកធ្វើការ នៅជាន់នីមួយៗ និងនៅផ្នែកផ្សេងៗនៃជាន់ ឬអគារ

5.2 ការវាយតម្លៃអគារ

នៅពេលអនុវត្តការវាយតម្លៃសុវត្ថិភាពអគ្គិភ័យនៃអគារ វាជារឿងសំខាន់ដើម្បីទទួលបានការកោតសរសើរដ៏ល្អពីដំបូងនៃទីធ្លា និងទំនាក់ទំនងគ្នាទៅវិញទៅមកអំឡុងការកាន់កាប់សំខាន់ៗ និងបន្ទាប់បន្សំ (ការប្រើប្រាស់) នៅក្នុងអគារ។ អ្នកវាយតម្លៃក៏គួរទទួលបានការយល់ដឹងច្បាស់អំពីផ្លូវដែលមានសម្រាប់អ្នកកាន់កាប់ពីគ្រប់តំបន់នៅក្នុងអគារទៅខាងក្រៅតាមរយៈច្រកចេញចុងក្រោយ។
ក្នុងអំឡុងពេលកិច្ចប្រជុំបឋមជាមួយអ្នកគ្រប់គ្រង អ្នកវាយតម្លៃត្រូវស្រមៃមើលបញ្ហាទាំងនេះពីឯកសារដែលបានផ្តល់ ប៉ុន្តែមុនពេលកត់ត្រាព័ត៌មានអំពីវិធានការសុវត្ថិភាពអគ្គិភ័យ អ្នកវាយតម្លៃគួរដើរជុំវិញអគារដើម្បីបំពេញរូបភាពដែលទទួលបានក្នុងអំឡុងពេលកិច្ចប្រជុំនោះ។

5.2.1 នីតិវិធីវាយតម្លៃ

សម្រាប់ការវាយតម្លៃ អ្នកវាយតម្លៃសុវត្ថិភាពអគ្គិភ័យនឹងត្រូវការដូចខាងក្រោម៖

- បញ្ជីត្រួតពិនិត្យសុវត្ថិភាព?
- កាមេរ៉ាដើម្បីចាប់យករូបភាពនៃការសង្កេត
- ឧបករណ៍វាស់ប្រើកាំរស្មីឡាស៊ែរ និងម៉ែត្រខ្សែ

មុនពេលចាប់ផ្តើម វាត្រូវបានណែនាំឱ្យអ្នកវាយតម្លៃកត់សម្គាល់បញ្ហាជាក់លាក់ដែលបានលើកឡើងនៅក្នុងកិច្ចប្រជុំគ្រប់គ្រង និងកំណត់តំបន់នៃអគារដែលនឹងត្រូវបានគ្របដណ្តប់ និងតាមលំដាប់លំដោយដែលពួកគេនឹងត្រូវធ្វើ ដើម្បីសម្រួលដល់ការកត់ត្រាព័ត៌មានក្នុងអំឡុងពេលវាយតម្លៃ។ ឧ. ជាន់ផ្ទាល់ដី ជាន់ទី 1 ជាដើម ឬប្រសិនបើអគារតែមួយជាន់ធំ បន្ទាប់មកបំបែកទៅជាផ្នែកដំណើរការផ្សេងៗគ្នា ហើយកំណត់វានៅលើការសម្គាល់។

នៅពេលដែលការយល់ដឹងជាមូលដ្ឋានបីគំនូសបង្ហាញអគារហើយ ទីតាំងនៃការប្រើប្រាស់ផ្សេងៗគ្នា និងផ្លូវចរាចរនៅក្នុងមុខងាររបស់អគារនោះ អ្នកវាយតម្លៃគួរចាប់ផ្តើមកត់ត្រាការសង្កេតតាមវិធីជាប្រព័ន្ធ ដើម្បីស្វែងយល់ពីបទប្បញ្ញត្តិសុវត្ថិភាពអគ្គិភ័យផ្សេងៗគ្នា ដែលរួមបញ្ចូលគ្នាដើម្បីការពារសុវត្ថិភាពអ្នកធ្វើការក្នុងករណីមានអគ្គិភ័យកើតឡើង។

ដោយសារមានបទប្បញ្ញត្តិសុវត្ថិភាពអគ្គិភ័យមួយចំនួនដែលធ្វើសកម្មភាពរួមគ្នាដើម្បីផ្តល់ការការពារចាំបាច់ អ្នកវាយតម្លៃគួរប្រើបញ្ជីត្រួតពិនិត្យដែលបានផ្តល់ឱ្យ (សូមមើលឧបសម្ព័ន្ធ E) ដើម្បីធានាថាទិដ្ឋភាពទាំងអស់ត្រូវបានកត់ត្រាមុនពេលបន្តដំណើរការទៅតំបន់ ឬអគារផ្សេងទៀត។ បញ្ជីត្រួតពិនិត្យគួរត្រូវបានប្រើដើម្បីឱ្យប្រធានបទនីមួយៗក្នុងចំណោមប្រធានបទផ្សេងៗគ្នាអាចដោះស្រាយជាប្រព័ន្ធ។ នេះមានសារៈសំខាន់ជាពិសេសនៅពេលដោះស្រាយបញ្ហាទាំងអស់ដែលទាក់ទងនឹងមធ្យោបាយនៃការរត់គេច ការទំនាក់ទំនងគ្នាទៅវិញទៅមករវាងតំបន់និងកម្រិត និងការកំណត់វិធានការសម្រាប់ការបំបែកចំណាត់ថ្នាក់អគ្គិភ័យចេញពីតំបន់ដែលមានហានិភ័យខ្ពស់។

បញ្ជីត្រួតពិនិត្យនេះធ្វើតាមលំដាប់លំដោយដូចគ្នា ហើយប្រើចំណងជើងស្រដៀងគ្នាទៅនឹងអ្វីដែលបានផ្តល់ក្នុងរបាយការណ៍គំរូ។ បញ្ជីត្រួតពិនិត្យមិនមែនជាបញ្ជីពេញលេញអំពីអ្វីដែលត្រូវកត់ត្រាទុកនោះឡើយ ហើយមិនអាចប្រើសម្រាប់លំហាត់ "ប្រអប់ធីក" បានទេ។ ចំណុចនៅក្នុងបញ្ជីត្រួតពិនិត្យគួរត្រូវបានគេមើលឃើញថាជាការជំរុញឱ្យអ្នកវាយតម្លៃអគ្គិភ័យផ្តោតការយកចិត្តទុកដាក់ចំពោះបញ្ហាដែលត្រូវយកមកពិចារណានៅលើទីតាំង និងសម្រាប់ធ្វើកំណត់ចំណាំពីបញ្ហាដែលពាក់ព័ន្ធ។ បញ្ជីត្រួតពិនិត្យនឹងដើរតួជាការរំលឹកអំពីចំណុចណាដែលត្រូវពិចារណា និងកត់សម្គាល់នៅក្នុងអគារនីមួយៗ ឬផ្នែកនៃអគារ ខណៈពេលកំពុងធ្វើការវាយតម្លៃ។

ការណែនាំលម្អិតបន្ថែមទៀតអំពីការអនុវត្តបញ្ជីត្រួតពិនិត្យក្នុងអំឡុងពេលវាយតម្លៃសុវត្ថិភាពអគ្គិភ័យត្រូវបានផ្តល់ជូននៅក្នុងចំណុច 5.3 ខាងក្រោម។

កំណត់ចំណាំដែលបានកត់ត្រាក្នុងអំឡុងពេលការវាយតម្លៃដែលត្រូវគ្នានឹងបញ្ហាដែលមាននៅក្នុងបញ្ជីត្រួតពិនិត្យទាំងអស់នឹងអាចឱ្យអ្នកវាយតម្លៃគ្របដណ្តប់លើប្រធានបទទាំងអស់ដែលបានផ្តល់នៅក្នុងរបាយការណ៍គំរូ។ ទោះយ៉ាងណា អ្នកវាយតម្លៃគួរកត់សម្គាល់អ្វីៗដែលពាក់ព័ន្ធ និងមិនពឹងផ្អែកទាំងស្រុងលើការរំលឹកដែលមាននៅក្នុងបញ្ជីត្រួតពិនិត្យនោះទេ។

5.2.2 ការវាយតម្លៃផ្នែកខាងក្នុងនៃអគារ

ដោយប្រើប្រាស់បញ្ជីត្រួតពិនិត្យសម្រាប់ជាមគ្គុទេសក៍ អ្នកវាយតម្លៃគួរអាចធ្វើការកត់ត្រានូវទិន្នន័យដើម្បីរាយការណ៍អំពីបញ្ហាដូចខាងក្រោម៖

- ចំនួនអ្នកនៅក្នុងអគារតាមជាន់ ឬផ្នែកនៃជាន់នីមួយៗ
- ចំនួន និងទំហំទទឹងនៃច្រកចេញពីជាន់នីមួយៗ
- ប្រភេទ ទំហំ និងស្ថានភាពផ្លូវជម្លៀសខ្លួនឆ្ពោះទៅកាន់ច្រកចេញតាមជាន់
- ប្រភេទ ទំហំទទឹង និងស្ថានភាពនៃទ្វារនៅផ្លូវជម្លៀសខ្លួនឆ្ពោះទៅកាន់ច្រកចេញតាមជាន់
- ចម្ងាយទៅកាន់ច្រកចេញតាមជាន់ ឬចម្ងាយរវាងច្រកចេញតាមជាន់
- ប្រភេទ ទំហំទទឹង និងស្ថានភាពនៃទ្វារច្រកចេញតាមជាន់ (ជាទូទៅទ្វារទៅកាន់ជណ្តើរ)
- ប្រភេទ ទំហំទទឹង និងស្ថានភាពនៃផ្លូវជណ្តើរ
- ប្រភេទ ទំហំទទឹង និងស្ថានភាពនៃទ្វារច្រកចេញចុងក្រោយ (ជាទូទៅទ្វារទៅកាន់ផ្នែកខាងក្រៅអគារ)
- ស្លាកសញ្ញាសម្រាប់ផ្លូវជម្លៀសខ្លួន
- ស្លាកសញ្ញាច្រកចេញមានភ្លើងបំភ្លឺនៅតាមច្រកចេញតាមជាន់
- ភ្លើងបំភ្លឺផ្លូវជម្លៀសខ្លួនពីបរិវេណទាំងអស់ទៅកាន់ច្រកចេញតាមជាន់
- ទីតាំងនៃបរិវេណដែលមានហានិភ័យខ្ពស់ (ឃ្លាំង ម៉ាស៊ីនភ្លើង ត្រង់ស្វូរ-ល-)
- ធាតុផ្សំរបាំងខណ្ឌធន់នឹងអគ្គិភ័យ (ជញ្ជាំង កម្រាលឥដ្ឋ ចន្លោះ (Shaft) បំពង់ថាមពល)
- ប្រភេទ និងការគ្របដណ្តប់នៃប្រព័ន្ធចាប់សញ្ញា
- ប្រភេទ និងការគ្របដណ្តប់នៃប្រព័ន្ធផ្តល់សញ្ញា
- ប្រភេទ និងការគ្របដណ្តប់នៃប្រព័ន្ធភ្លើងបំភ្លឺពេលមានអាសន្ន
- ការផ្គត់ផ្គង់ថាមពលបម្រុងសម្រាប់ប្រព័ន្ធគ្រោះអាសន្ន
- តើមានប្រព័ន្ធពន្លត់អគ្គិភ័យស្វ័យប្រវត្តិដែរឬទេ ប្រសិនបើមាន តើប្រព័ន្ធនោះការពារបរិវេណណាខ្លះ?
- ប្រព័ន្ធពន្លត់អគ្គិភ័យ – ប្រព័ន្ធទុយោបាញ់ពន្លត់អគ្គិភ័យរបស់អោងចក្រ
- បំពង់ពន្លត់អគ្គិភ័យកាន់ដៃសម្រាប់ការពន្លត់អគ្គិភ័យបឋម

- ស្លាកសញ្ញាសម្រាប់សម្ភារពន្លត់អគ្គិភ័យបឋម
- ច្រកចេញទៅកាន់ផ្នែកខាងក្នុងអគារដើម្បីពន្លត់អគ្គិភ័យ
- ការមាន និងភាពសុក្រឹតនៃផែនទីជម្លៀសខ្លួនពេលមានអគ្គិភ័យនៅតាមជាន់នីមួយ

5.2.3 ការវាយតម្លៃផ្នែកខាងក្រៅ

នៅពេលបានវាយតម្លៃផ្នែកខាងក្នុងអគារ ឬអគាររួចរាល់ហើយ អ្នកវាយតម្លៃគួរតែកត់ត្រាទិន្នន័យ ន័យដើម្បីរាយការណ៍អំពីបញ្ហានៅទូទាំងទីតាំងដូចខាងក្រោម៖

- ស្ថានភាពផ្លូវសម្រាប់មនុស្សធ្វើដំណើរពីទ្វារច្រកចេញចុងក្រោយទៅកាន់កន្លែងសុវត្ថិភាពឆ្ងាយពីអគារ
- បរិវេណប្រមូលផ្តុំដើម្បីដាក់មនុស្សនៅក្នុងអគារទាំងមូលក្នុងករណីមានការជម្លៀសខ្លួនបន្ទាន់
- ការផ្គត់ផ្គង់ទឹកសម្រាប់ប្រព័ន្ធពន្លត់អគ្គិភ័យ ការរក្សាទុកនៅក្នុងក្រុង និងនៅទីតាំង
- ប្រព័ន្ធម៉ាស៊ីនបូមទឹកសម្រាប់ទឹកពន្លត់អគ្គិភ័យ
- ប្រព័ន្ធពន្លត់អគ្គិភ័យ – ក្បាលម៉ាស៊ីនទឹក (hydrants) ខាងក្រៅ
- ច្រកចេញចូលទៅក្នុងអគារសម្រាប់រថយន្តពន្លត់អគ្គិភ័យ
- ទីតាំងអគារខាងក្រៅដាច់ដោយឡែកសម្រាប់ធ្វើជាបន្ទប់កណ្តាលដាក់ម៉ាស៊ីន (បរិក្ខារកម្តៅអនុស្ថានីយ ម៉ាស៊ីនភ្លើង បន្ទប់ម៉ាស៊ីនបូមទឹក ។ល។)

5.3 សេចក្តីណែនាំអំពីបញ្ហាក្នុងបញ្ជីត្រួតពិនិត្យ

បញ្ជីត្រួតពិនិត្យបង្គាប់ឱ្យធ្វើការវាយតម្លៃបញ្ហាសុវត្ថិភាពអគ្គិភ័យនៅក្រោមចំណងជើង "ប្រភេទបញ្ហា" "ប្រភេទអនុបញ្ហា" និង "ព័ត៌មានលម្អិតអំពីអនុបញ្ហា"។ បញ្ហាពាក់ព័ន្ធទាំងអស់នៅក្នុងបញ្ជីត្រួតពិនិត្យ ត្រូវតែអង្កេតឱ្យបានល្អិតល្អន់សម្រាប់អគារនីមួយៗ ឬផ្នែកនីមួយៗនៃអគារ មុនពេលបន្តទៅកាន់បរិវេណផ្សេងទៀត។ "ប្រភេទបញ្ហា" ដែលមាននៅក្នុងបញ្ជីត្រួតពិនិត្យមានដូចខាងក្រោម៖

1. ច្រកជម្លៀសខ្លួនគ្មានឧបសគ្គ
2. សំណង់មានសុវត្ថិភាពអគ្គិភ័យ
3. ប្រព័ន្ធសុវត្ថិភាពអគ្គិភ័យ
4. បទបញ្ជាសម្រាប់ការពន្លត់អគ្គិភ័យ
5. តំហែទាំ និងការថែរក្សារោងចក្រ។

នៅក្នុងផ្នែកខាងក្រោមនេះ ក្រោមចំណងជើង "ប្រភេទបញ្ហា" នីមួយៗ មានបង្ហាញអំពីចំណុច "ប្រភេទអនុបញ្ហា" ហើយនៅក្រោមចំណងជើង "ព័ត៌មានលម្អិតអំពីអនុបញ្ហា" មានសេចក្តីពណ៌នា

សង្ខេបអំពីប្រភេទបញ្ហា ដែលពាក់ព័ន្ធទៅនឹងចំណុចដែលរំពឹងឱ្យអ្នកវាយតម្លៃធ្វើការអង្កេត ក្នុងអំឡុងពេលធ្វើការវាយតម្លៃ។ បញ្ជីនេះមិនមែនជាបញ្ជីដែលមានគ្រប់បញ្ហាទាំងអស់អ្នកវាយតម្លៃអាចនឹងជួបប្រទះនោះទេ ប៉ុន្តែជាឯកសារយៀបរាប់អំពីបញ្ហាទូទៅទាំងអស់ដើម្បីជាមគ្គុទេសក៍ដល់អ្នកវាយតម្លៃ។

5.3.1 ច្រកជម្លៀសខ្លួនគ្មានឧបសគ្គ

ច្រកជម្លៀសខ្លួនគ្មានឧបសគ្គ និងបញ្ហាសំណង់ពាក់ព័ន្ធនឹងការខណ្ឌពីអគ្គិភ័យគឺជាប្រធានបទពីរដែលជាទូទៅត្រូវចំណាយពេលច្រើនដើម្បីធ្វើការកត់ត្រាឱ្យបានត្រឹមត្រូវ ហើយការស្វែងយល់ឱ្យបានច្បាស់អំពីចំណុះអគារ និងទីធ្លាតភ្ជាប់គ្នា គឺជាចំណុចដ៏សំខាន់ក្នុងការកំណត់រក និងកត់ត្រារាល់បញ្ហាទាំងអស់ ដោយធ្វើយ៉ាងណាឱ្យរបាយការណ៍វាយតម្លៃមានរៀបរាប់អំពីបញ្ហាទាំងនោះឱ្យបានល្អិតល្អន់គ្រប់គ្រាន់។

គោលការណ៍សំខាន់ៗនៃការជម្លៀសខ្លួនពីអគ្គិភ័យ អាចសង្ខេបបានដូចខាងក្រោម៖

- ផ្លូវច្រកចេញគ្រប់គ្រាន់សម្រាប់មនុស្សគេចចេញពីគ្រោះថ្នាក់
- ច្រកចេញគួរមានចំនួន និងទំហំទទឹងគ្រប់គ្រាន់ដើម្បីចៀសវាងកុំឱ្យកកស្ទះ។
- ចម្ងាយដែលមនុស្សត្រូវធ្វើដំណើរទៅកាន់ "ទីកន្លែងមានសុវត្ថិភាព" គួរតែកំណត់ឱ្យច្បាស់។
- "ទីកន្លែងមានសុវត្ថិភាព" គួរមានការពារឱ្យបានគ្រប់គ្រាន់ពីឥទ្ធិពលនៃអគ្គិភ័យ និងផ្សែង។
- "ទីកន្លែងមានសុវត្ថិភាព" គួរតែនាំដោយផ្ទាល់ទៅកាន់ "ទីកន្លែងមានសុវត្ថិភាពចុងក្រោយ" នៅខាងក្រៅអគារ

គំនូសព្រាងខាងក្រោមនេះអាចប្រើដើម្បីបង្ហាញថា ជាទូទៅ ច្រកគេចខ្លួនតែងតែបង្កើតឡើងដោយមានសមាសធាតុចំនួនបី។ សូមមើល រូបភាព 2 ខាងក្រោម – និងមានរៀបរាប់ដូចខាងក្រោម៖

ការជម្លៀសខ្លួនតាមទិសដេក៖ ការជម្លៀសខ្លួនពីជាន់ដែលមានមនុស្សតាមបណ្តោយផ្លូវដែលមិនបានការពារទៅកាន់ច្រកចេញនៅតាមជាន់ (ទាំងតាមផ្លូវដណ្តើរ ឬច្រកដើរដែលបានការពារ) ឬទៅខាងក្រៅអគារដោយផ្ទាល់ក្នុងករណីជាអគារកម្ពស់មួយជាន់។ បញ្ញត្តិដែលតម្រូវឱ្យមានការជម្លៀសខ្លួនតាមទិសដេក ដោយអាស្រ័យយ៉ាងខ្លាំងទៅលើប្រភេទអគារ (ការប្រើប្រាស់) ចំនួនអ្នកនៅក្នុងអគារ និងចម្ងាយធ្វើដំណើរទៅកាន់ច្រកចេញតាមជាន់។

ការជម្លៀសខ្លួនតាមទិសបញ្ឈរ (ទៅកាន់ទីកន្លែងមានសុវត្ថិភាព)៖ ការជម្លៀសខ្លួនតាមទិសបញ្ឈរមានពាក់ព័ន្ធទៅនឹងជណ្តើរដែលបានការពារ ដែលនាំអ្នកនៅក្នុងអគារពីជាន់ខាងលើទៅកាន់ជាន់ចាកចេញពីអគារ ដែលជាទូទៅគឺនៅជាន់ផ្ទាល់ដី។ ចំនួនអ្នកនៅក្នុងអគារដែលជម្លៀសខ្លួនទៅ

កាន់ជណ្តើរនីមួយៗ កំណត់ពីទំហំផ្លូវជណ្តើរដែលបានតម្រូវជាចាំបាច់។ ផ្លូវជណ្តើរដែល ឬច្រកដើរដែលមានការការពារ ហៅថា "ទីកន្លែងមានសុវត្ថិភាព" និងផ្តល់នូវផ្លូវមួយដែលការពារពីឥទ្ធិពលនៃអគ្គិភ័យ និងផ្សែងរហូតទៅដល់ច្រកចេញពីអគារ។ ចំពោះអគារតូច ឬអគារដែលមានកម្ពស់ពី ឬបីជាន់ពីជាន់ផ្ទាល់ដី ជណ្តើរមិនបានការពារ អាចទទួលយកជាផ្នែកមួយនៃការជម្លៀសខ្លួនតាមទិសបញ្ឈរបាន។

ច្រកចេញទៅកាន់ខាងក្រៅអគារ ("ទីកន្លែងសុវត្ថិភាព" ចុងក្រោយ)៖ ការជម្លៀសខ្លួនពីអគ្គិភ័យមិនទាន់ចប់នោះទេ ពោលគឺ រហូតទាល់តែអ្នកនៅក្នុងអគារបានទៅដល់ខាងក្រៅអគារ និងអាចចាកចេញឆ្ងាយពីអគារដែលរងផលប៉ះពាល់ទៅដល់ "ទីកន្លែងសុវត្ថិភាពចុងក្រោយ" ដែលជាទូទៅជាចំណុចប្រមូលផ្តុំដែលឯកភាពគ្នានៅខាងក្រៅអគារ។



រូបភាព 2 សមាសធាតុទូទៅទាំងបីនៃច្រកគេចខ្លួន

5.3.1.1 ច្រកចេញតាមជាន់

ជាទូទៅ ត្រូវមានច្រកអគ្គិភ័យយ៉ាងតិចពីរ ប៉ុន្តែចំនួន និងទីតាំងជាក់ស្តែងនៃច្រកអគ្គិភ័យត្រូវកំណត់តាមចំនួនអ្នកនៅក្នុងអគារ និងចម្ងាយធ្វើដំណើរ។

បទដ្ឋាន LABS មានចែងគោលការណ៍ណែនាំអំពីចំនួនអប្បបរមានៃច្រកចេញដែលតម្រូវដោយផ្អែកលើបន្ទុកអ្នកនៅក្នុងអគារ ដូចខាងក្រោម៖

- 500 នាក់ចុះក្រោម ច្រកចេញអប្បបរមាចំនួន 2
- 501-1000 នាក់ ច្រកចេញអប្បបរមាចំនួន 3
- លើសពី 1000 នាក់ ច្រកចេញអប្បបរមាចំនួន 4

ចំនួនច្រកចេញចុងក្រោយ ត្រូវមានការកត់សម្គាល់ ហើយការប៉ាន់ស្មានទំហំច្រកចេញត្រូវមានបង្ហាញនៅតាមច្រកចេញចុងក្រោយទាំងអស់។ ដោយអាស្រ័យទៅលើចំនួនអ្នកនៅក្នុងអគារដែលផ្តល់ជូនដោយគណៈគ្រប់គ្រង និងការអង្កេតផ្ទាល់ ការប៉ាន់ស្មានត្រួសៗអាចធ្វើឡើងទៅបានថាតើទំហំច្រកចេញគឺគ្រប់គ្រាន់សម្រាប់ចំនួនមនុស្សដែរឬទេ (អាស្រ័យលើទំហំទទឹង 5 មីលីម៉ែត្រសម្រាប់មនុស្សម្នាក់)។ ចំណាំ៖ ទំហំទទឹងអប្បបរមានៃច្រកចេញនានា ត្រូវមានទំហំយ៉ាងតិច 800 មីលីម៉ែត្រ។

ប្រសិនបើការប៉ាន់ស្មានបង្ហាញថា ចំណុះច្រកចេញតាមជាន់មានទំហំស្ទើរបន្តិចបន្តួច ឬមិនគ្រប់គ្រាន់ នោះចាំបាច់ត្រូវធ្វើការវាស់វែងសុក្រឹតទំហំទ្វារដែលមានប្រសិទ្ធភាព ដើម្បីកំណត់ថាតើចំណុះច្រកចេញត្រូវបង្កើនដែរឬទេ ហើយប្រសិនបើត្រូវបង្កើន តើត្រូវបង្កើនដល់កម្រិតណា។

ច្រកធ្វើដំណើរទៅកាន់ច្រកចេញពីគ្រប់ផ្នែកទាំងអស់នៃជាន់ នឹងត្រូវវាយតម្លៃ ហើយចម្ងាយទៅកាន់ច្រកចេញដែលបានវាយតម្លៃ ដោយផ្អែកលើផ្លូវធ្វើដំណើរជម្រើសផ្សេងទៀតដែលមាន ឬផ្លូវធ្វើដំណើរឯកទិស។

ចម្ងាយធ្វើដំណើរអតិបរិមាដែលអនុញ្ញាតទៅកាន់ច្រកចេញតាមជាន់ ឬច្រកចេញអគ្គិភ័យនៃអគារដែលស្ថិតនៅជិតបំផុត អាស្រ័យទៅលើផ្លូវដែលមានទៅកាន់ច្រកចេញ។ មានលទ្ធភាពជាច្រើនដែលត្រូវបានយកមកពិភាក្សាខាងក្រោមកាន់តែលម្អិតបន្ថែម៖

- ទិសធ្វើដំណើរជម្រើសផ្សេងទៀត
- ផ្លូវធ្វើដំណើរឯកទិស ឬផ្លូវធ្វើដំណើររួម
- ផ្លូវទាល់

គោលការណ៍ទូទៅនៃការរចនាច្រកគេចខ្លួន គឺបុគ្គលទាំងឡាយគួរមានទិសដៅគេចខ្លួនតាមជម្រើសផ្សេងទៀតដើម្បីធានាថា ក្នុងករណីមានអគ្គិភ័យ អ្នកនៅក្នុងអគារអាចគេចខ្លួនបានដោយមិនចាំបាច់រត់ទៅកាន់ប្រភពអគ្គិភ័យ។

រូបភាព 3 ទិសដៅគេចខ្លួនជម្រើសផ្សេងទៀត

ទោះបីជាមានផ្លូវគេចខ្លួនជម្រើសផ្សេងទៀតដូចមានបង្ហាញខាងលើនេះក៏ដោយ ក៏ចម្ងាយដែលមនុស្សត្រូវធ្វើដំណើរដើម្បីទៅដល់ទីកន្លែងមានសុវត្ថិភាព (ឧទាហរណ៍ ចំណុចស្នូលជណ្តើរដែលមានការពារ) ក៏ត្រូវកំណត់ឱ្យច្បាស់ដែរ។
ក្នុងកាល:ទេស:ពិសេសមួយចំនួន ការធ្វើដំណើររបស់មនុស្សតាមទិសដៅឯកទិស អាចចាត់ទុកថាមានលក្ខណ:សមស្របអាចទទួលយកបាន លុះត្រាតែចម្ងាយបានកំណត់សមស្រប។ ផ្អែកលើការសន្មតទាំងនេះ ជាការសន្មតថា មនុស្សអាចធ្វើដំណើរវាងអគ្គិភ័យ ហើយទៅដល់ទីកន្លែងសុវត្ថិភាពក្នុងរយ:ពេលខ្លីមុនពេលដែលអគ្គិភ័យចាប់ផ្តើមឆាបឆេះកាន់តែខ្លាំងឡើងៗ។
ចម្ងាយធ្វើដំណើរអតិបរិមានៅក្នុងករណីទាំងនេះ សម្រាប់អគាររោងចក្រកាត់ដេរសម្លៀកបំពាក់ស្បែកជើង កាបូប និងផលិតផលធ្វើដំណើរមានចែងនៅក្នុងបទដ្ឋាន LABS សម្រាប់ស្ថានភាពផ្សេងៗ។
ផ្លូវទាល់នៅតាមផ្លូវដើរ ឬច្រកដើរ គួរមានចម្ងាយធ្វើដំណើរមានកម្រិត។ ចម្ងាយប្រហាក់ប្រហែលជាទូទៅគឺល្អគ្រប់គ្រាន់ក្នុងការសម្រេចថាតើចម្ងាយនោះឆ្ងាយពេកឬយ៉ាងណា ហើយ ជាជារឿយៗចម្ងាយទាំងនោះអាចវាយតម្លៃក្នុងអំឡុងពេលវាយតម្លៃដោយផ្អែកលើវិមាត្រទូទៅនៃបណ្តាញគ្រោង ឬអាចវាស់វែងបានតាមរយ:ការដាក់ផ្ទៀងផ្ទាត់ខាងក្រៅ។

គួរយកចិត្តទុកដាក់ជាពិសេសទៅលើការជម្លៀសខ្លួនពីឡៅតឿដើម្បីពិនិត្យមើលថាតើចាំបាច់ត្រូវការច្រកបន្ថែមចេញពីឡឿតឿដែរឬទេ។

5.3.1.2 ផ្លូវជម្លៀសខ្លួន

ផ្លូវជម្លៀសខ្លួនត្រូវស្របតាមលក្ខណ:វិនិច្ឆ័យផ្សេងៗដើម្បីធានាថាផ្លូវទាំងនោះគឺជាផ្លូវជម្លៀសខ្លួនដែលមានសុវត្ថិភាព។ លក្ខណ:វិនិច្ឆ័យទាំងនេះរួមមាន៖

- មិនថានៅពេលណាក៏ដោយ ផ្លូវជម្លៀសខ្លួនទាំងនេះមិនត្រូវមានឧបសគ្គ
- ផ្លូវដើរទាំងអស់នៅតាមបណ្តោយផ្លូវជម្លៀសខ្លួនត្រូវអាចសម្រួលលំហូរអ្នកនៅក្នុងអគារ ដែលប្រើប្រាស់ផ្លូវដើរនោះ និងមានទំហំទទឹងយ៉ាងតិចបំផុតត្រឹម 915 មីលីម៉ែត្រ។
- ផ្លូវធ្វើដំណើរត្រូវតែមានជំរាលតិចជាង 1 ភាគ 10
- ផ្លូវជម្លៀសខ្លួនមិនត្រូវឆ្លងកាត់កន្លែងហានិភ័យអគ្គិភ័យពិសេស ជាប់ទៅនឹងបរិវេណដែលមានគ្រោះថ្នាក់អគ្គិភ័យកម្រិតខ្ពស់នោះទេ
- ប្រសិនបើផ្លូវជម្លៀសខ្លួននាំមនុស្សទៅកាន់បរិវេណជាប់នោះ ទ្វារនាំឆ្លងកាត់ ត្រូវតែមិនអាចចាក់សោរបាន ឬជាទ្វារទាញទៅចំហៀង ហើយផ្លូវមិនគួរមានអ្វីរារាំងឡើយ

ស្ថានភាពរូបសាស្ត្រនៃផ្លូវជម្លៀសខ្លួននឹងកត់សម្គាល់ ទំហំទទឹងដែលមាន មិនថាមាន ឬគ្មាន ឧបសគ្គ ហើយមិនថាមានស្ថានភាពផ្លូវទាល់ណាមួយដែលតភ្ជាប់ទៅនឹងផ្លូវទាំងនេះទេ។ កម្ពស់ពីពិតានទៅក្រោមឧបសគ្គទាំងអស់ និងតាមច្រកទ្វារ ត្រូវកត់សម្គាល់។

5.3.1.3 ស្លាកសញ្ញាច្រកចេញ

ស្លាកសញ្ញាច្រកចេញ ត្រូវមានព័ត៌មានច្បាស់ និងមិនស្រពិចស្រពិលដើម្បីអាចឱ្យមនុស្សចាកចេញពីអគារបានដោយសុវត្ថិភាពនៅក្នុងករណីមានគ្រោះអាសន្ន។

ត្រូវមានផ្តល់ស្លាកសញ្ញា ដែលគួរតែមានសង្គតិភាពទាំងអស់នៅទូទាំងអគារ។ ស្លាកសញ្ញាគួរតែណែនាំ ច្បាស់ឱ្យអ្នកដែលនៅក្នុងអគារស្ថិតនៅគ្រប់កន្លែងទាំងអស់តាមជាន់ទៅកាន់ច្រកចេញនៅជិតបំផុត។ នៅក្នុងករណីខ្លះ ត្រូវមានស្លាកសញ្ញាបន្ថែមដើម្បីបំពេញបន្ថែមច្រកចេញនៅខាងលើទ្វារច្រកចេញនីមួយៗ ស្លាកសញ្ញាទាំងនេះក៏អាចត្រូវការចាំបាច់នៅពេលដែលមានការផ្លាស់ប្តូរទិសដៅនៅតាមបណ្តោយផ្លូវជម្លៀសខ្លួន។

ចំណុចសំខាន់ដើម្បីកត់ត្រាអំពីស្លាកសញ្ញាមាន៖

- ស្លាកសញ្ញាគួរមានពណ៌ឆ្លុះជាមួយផ្ទៃខាងក្រោយ និងគួរអាចមើលឃើញច្បាស់។ ពណ៌ និងការរចនាអក្សរ សញ្ញាព្រួញ និងនិមិត្តសញ្ញាផ្សេងៗនៅលើស្លាកសញ្ញាច្រកចេញ ត្រូវមានពណ៌ឆ្លុះគ្នា
- ស្លាកសញ្ញាគួរតែមានសង្គតិភាពនៅទូទាំងអគារ ហើយយកល្អ គួរមាននិមិត្តសញ្ញាអមជាមួយនឹងអក្សរ។
- នៅពេលចាំបាច់ ស្លាកសញ្ញាផ្លូវជម្លៀសខ្លួននានា គួរតែរួមបញ្ចូល ឬអមជាមួយនឹងសញ្ញាព្រួញទិសដៅ។ សញ្ញាព្រួញ មិនគួរដាក់តែឯងនៅទេ
- ប្រសិនបើផ្លូវជម្លៀសខ្លួនទៅកាន់ច្រកចេញជិតបំផុតមិនច្បាស់ ច្រកចេញនោះគួរតែបង្ហាញដោយសញ្ញាមួយ (ឬច្រើន)
- ស្លាកសញ្ញាគួរតែដាក់នៅទីតាំងណាដែលមនុស្សកំពុងជម្លៀសខ្លួនអាចមើលឃើញសញ្ញាច្រកជម្លៀសខ្លួនគ្មានឧបសគ្គបន្ទាប់ជានិច្ច
- ស្លាកសញ្ញា មិនគួរបាំងដោយគ្រោង សម្ភារបំពាក់ ឬស្លាកសញ្ញាផ្សេងទៀតនោះទេ។
- ស្លាកសញ្ញាគួរតែបំពាក់នៅកម្ពស់ស្មើគ្នានៅពេញផ្លូវជម្លៀសខ្លួនទាំងមូល ដោយដាក់នៅកម្ពស់ណាដែលអាចអនុវត្តទៅបាន
- ចម្ងាយមើលឃើញ – ស្លាកសញ្ញាត្រូវតែកំណត់ទំហំស្របទៅតាមចម្ងាយដែលចាំបាច់ត្រូវមើលឃើញពីចម្ងាយ (ស្លាកសញ្ញាធំសម្រាប់ចម្ងាយឆ្ងាយ)។

ស្លាកសញ្ញា អាចមានទាំងស្លាកសញ្ញាជាន់ និងស្លាកសញ្ញានៅលើពិតាន ហើយមានទាំងពីរយ៉ាង និងស្ថានភាពនៃស្លាកសញ្ញាទាំងពីរនឹងត្រូវបានកត់ត្រា។

ស្លាកសញ្ញាចាំបាច់ត្រូវមានភ្លើងបំភ្លឺ។ ការបំភ្លឺនេះអាចបំពាក់ដំឡើងភ្លើងបំភ្លឺពីខាងក្នុង ឬពីខាងក្រៅស្លាកសញ្ញា។ អំពូលបំភ្លឺស្លាកសញ្ញានេះ ត្រូវតភ្លើងចេញពីប្រភពថាមពលផ្គត់ផ្គង់មេ ប៉ុន្តែក៏ត្រូវមានថាមពលផ្គត់ផ្គង់បម្រុងដែរ ដែលអាចភ្ជាប់អាគុយបម្រុង ឬតាមរយៈការតខ្សែភ្លើងធន់នឹងអគ្គិភ័យទៅនឹងប្រភពថាមពលមួយទៀត ឧទាហរណ៍ ម៉ាស៊ីនភ្លើង ឬអាគុយបម្រុងបញ្ជាពីចម្ងាយ ជាដើម។

ទ្វារច្រកចេញនីមួយៗគួរតែមានស្លាកសញ្ញាច្រកចេញភ្លឺ ដោយមានក្រាហ្វិក និងពណ៌ដូចគ្នានៅទូទាំងអគារ។

5.3.1.4 ទ្វារច្រកចេញ

ជាទូទៅ ទ្វារច្រកចេញគួរតែបំពេញស្របតាមលក្ខខណ្ឌតម្រូវដូចខាងក្រោម៖

- ផ្លូវជម្លៀសខ្លួនមិនអាចប្រើទ្វារទាញទៅចំហៀង ឬទ្វារវិញឡើងលើបានឡើយ។ ទ្វារទាំងនេះរួមមានច្រកទ្វារសន្តិសុខដែលអាចចាក់សោរបានដែលបានអង្កេតឃើញនៅក្នុងរោងចក្រកាត់ដេរសម្លៀកបំពាក់ ស្បែកជើង កាបូប និងផលិតផលបន្ទាប់បន្សំមានស្រាប់ជាច្រើន។

ទ្វារទាំងអស់នៅតាមបណ្តោយផ្លូវច្រកចេញបន្ទាន់ គួរងាយស្រួលបើកតាមទិសដៅធ្វើដំណើរ។ ចំណុចសំខាន់ដែលត្រូវកត់ត្រាជាពិសេសអំពីគន្លឹះដែលបំពាក់នៅទ្វារច្រកចេញចុងក្រោយ។ ជាទូទៅ ទ្វារទាំងនេះត្រូវអាចចាក់សោរបានពីខាងក្រៅក្នុងគោលបំណងសន្តិសុខ ប៉ុន្តែទ្វារទាំងនេះត្រូវតែជាទ្វារដែលបើកបានទូលាយ ដែលអាចបើកបានពីខាងក្នុងដោយមិនចាំបាច់ប្រើកូនសោរនៅពេលត្រូវជម្លៀសខ្លួន។ នៅពេលចាក់សោរពីខាងក្រៅ គន្លឹះសម្រាប់បើកទ្វារពីខាងក្នុង ត្រូវតែអាចបើកសោរនោះបាន។
គួរកត់សម្គាល់មើលថាតើទ្វារទាំងនោះអាចចាក់សោរដែលមិនស្របតាមលក្ខខណ្ឌតម្រូវទ្វារច្រកចេញដែរឬទេ។
ជាការសំខាន់ដែលត្រូវធានាថា ទំហំទទឹងច្រកចេញគឺសមស្របសម្រាប់ចំនួនអ្នកនៅក្នុងអគារនៅជាន់នោះ។ ច្រកចេញគួរតែកំណត់ទំហំដើម្បីធានាថា៖

- អ្នកនៅក្នុងអគារអាចចូលទៅក្នុងទីកន្លែងមានសុវត្ថិភាពបាននៅក្នុងរយៈពេលខ្លី ដែលអាចទទួលយកបាន និង
- មានសមត្ថភាពគ្រប់គ្រាន់ក្នុងការបញ្ចៀសការកកស្ទះ និងការតម្រង់ជួរដើម្បីអាចទៅដល់ទី

កន្លែងមានសុវត្ថិភាព

ទំហំទទឹងទ្វារច្រកចេញតាមទិសដេក គឺផ្អែកលើអត្រាលំហូរ 5.0 មីលីម៉ែត្រក្នុងមនុស្សម្នាក់ ដោយយោងតាមបទដ្ឋាន LABS (ដោយមានទំហំទទឹងតម្រូវអប្បបរមា 810 មីលីម៉ែត្រ)។

5.3.1.5 ជណ្តើរច្រកចេញ

ការជម្លៀសខ្លួនតាមទិសបញ្ឈរទៅកាន់ជាន់ផ្ទាល់ដីពីជាន់ខាងលើ ជាទូទៅគឺតាមផ្លូវជណ្តើរចំហ ឬជណ្តើរឃ្លុប។

ទំហំទទឹងជណ្តើរត្រូវធំល្មមដែលអាចសម្រួលដល់ចំនួនអ្នកនៅក្នុងអគារក្នុងការជម្លៀសខ្លួនចេញពីគ្រប់ជាន់ទាំងអស់បាន។

យោងតាមបទដ្ឋាន LABS ទំហំទទឹងនៃផ្លូវជណ្តើរ ជាទូទៅ គឺអាស្រ័យទៅលើអត្រាលំហូរ 7.6 មីលីម៉ែត្រ ក្នុងមនុស្សម្នាក់ក្នុងអគារមាន ឬមិនមានឧបករណ៍បាញ់ទឹក។ បទដ្ឋាននេះគួរអនុវត្តចំពោះជាន់ណាដែលមានអ្នកនៅក្នុងអគារច្រើនជាងគេបំផុត ដោយសារតែបន្ទុកនេះតំណាងឱ្យស្ថានភាពមិនល្អ។

ទំហំទទឹងអប្បបរមានៃផ្លូវជណ្តើរ គឺ 915 មីលីម៉ែត្រសម្រាប់អគារពាណិជ្ជកម្ម ការិយាល័យ សិក្ខាសាលា ការដ្ឋាន ការផលិត ឃ្លាំង ការលក់រាយ ការកក់ទុក និងផលិតផលបន្ទាប់បន្សំ

ក្នុងដំណាក់កាលនេះ អ្នកវាយតម្លៃកត់ត្រាទំហំទទឹង និងស្ថានភាពនៃទ្វារច្រកចូល និងទំហំទទឹងនៃជណ្តើរដើម្បីពិនិត្យមើលថាតើ ទំហំទាំងពីរនេះអាចសម្រួលបានគ្រប់គ្រាន់ទៅតាមចំនួនអ្នកនៅក្នុងអគារដែលរំពឹងទុកដែរឬទេ។ ជំរាល និងចន្លោះកាំជណ្តើរ ក៏នឹងត្រូវកត់ត្រាផងដែរ ដើម្បីកំណត់ថាតើជណ្តើរទាំងនេះគួរតែចាត់ទុកថាជាផ្នែកនៃផ្លូវជម្លៀសខ្លួនបន្ទាន់ ដែរឬទេ។

បង្កាន់ដៃគឺត្រូវការជាចាំបាច់សម្រាប់ជណ្តើរអាសន្ន។ ប្រវែងបង្កាន់ដៃ គួរតែអនុលោមតាមវិមាត្រដូចដែលបានបង្ហាញនៅក្នុង រូបភាព 6 ខាងក្រោម៖

រូបភាព 4៖ ប្រវែងបង្កាន់ដៃជណ្តើរ



រូបភាព 4៖ ប្រវែងបង្កាន់ដៃជណ្តើរ

ជាការសំខាន់ណាស់ដែលត្រូវធ្វើការពិចារណាទៅលើឥទ្ធិពលនៃបង្កាន់ដៃនៅក្នុងការគណនាទំហំជណ្តើរ តែប្រសិនបើបង្កាន់ដៃទាំងនេះមិនបានបង្កប់ចូលទៅក្នុងជណ្តើរលើសពី 100 មីលីម៉ែត្រទេ នោះយើងមិនចាំបាច់ធ្វើការពិចារណាទៅលើវានោះទេ។
អ្នកវាយតម្លៃ គួរកត់ត្រាថាតើជណ្តើរចេញទៅដល់កន្លែងណា តើជណ្តើរនេះនាំទៅកាន់បរិវេណស្នាក់នៅមួយទៀត ឬនាំចេញទៅក្រៅផ្ទាល់។ ប្រសិនបើជណ្តើរនេះនាំទៅកាន់កន្លែងស្នាក់នៅផ្សេងទៀត នោះត្រូវកត់ត្រាទុកចម្ងាយ និងស្ថានភាពផ្លូវពីចំណុចចាកចេញទៅកាន់ច្រកចេញចុងក្រោយ។ ផ្លូវនេះនាំទៅកាន់ច្រកចេញចុងក្រោយអាចត្រូវការពារ ជាពិសេសប្រសិនបើមិនមានច្រកចេញជម្រើសផ្សេងទៀតដែលផ្តល់ជូននៅជាន់ខាងលើៗ។
អាចត្រូវការជណ្តើរខាងក្រៅនៅតាមផ្លូវបណ្តើរជម្លៀសខ្លួន ហើយអ្នកវាយតម្លៃនឹងធ្វើការកត់ត្រាថាតើ ជណ្តើរទាំងនេះត្រូវបានការពារពីកន្លែងស្នាក់នៅជាប់គ្នានោះសម្រាប់ប្រវែងផ្លូវជណ្តើរទាំងមូលយ៉ាងដូចម្តេច។

5.3.1.6 ច្រកចេញចុងក្រោយ

ទីកន្លែងមានសុវត្ថិភាពចុងក្រោយសម្រាប់អ្នកនៅក្នុងអគារ គឺស្ថិតនៅខាងក្រៅអគារ។
ជាការអនុវត្តការរចនាល្អប្រសើរ គឺការផ្តល់ជណ្តើរជម្លៀសខ្លួន ឬច្រកចេញចុងក្រោយដែលនាំទៅខាងក្រៅអគារនៅជាន់ផ្ទាល់ដី។
លើសពីនេះ អ្នកនៅក្នុងអគារអាចជម្លៀសខ្លួនទៅកាន់អគារនៅជាប់គ្នានោះ ប្រសិនបើអគារនោះ៖

- ជាបរិវេណខណ្ឌពីអគ្គិភ័យដាច់ដោយឡែក

- មានទំហំធំល្មមដើម្បីសម្រួលលំហូរអ្នកនៅក្នុងអគារដែលធ្វើដំណើរចូលក្នុងអគារពីអគារផ្សេងទៀត
- ច្រកជម្លៀសខ្លួនគ្មានឧបសគ្គទៅកាន់អគារជាប់គ្នាជានិច្ចកាលអាចនឹងមាន ហើយអគារគឺស្ថិតនៅក្រោមម្ចាស់កម្មសិទ្ធិតែមួយដូចទៅនឹងអគារដែលអ្នកនៅក្នុងអគារកំពុងជម្លៀសចេញ។
- អគារនៅជាប់គ្នានោះមានជណ្តើរជម្លៀសខ្លួនគ្រប់គ្រាន់សម្រាប់ការជម្លៀសខ្លួនរបស់មនុស្សបន្ថែមទៅខាងក្រៅអគារ។

ទំហំទទឹងសរុបនៃច្រកចេញចុងក្រោយ ហើយចំណុះរបស់វា នឹងត្រូវកំណត់ និងវាយតម្លៃដោយធៀបនឹងចំនួនមនុស្សនៅជាន់ច្រកចេញ គួបផ្សំជាមួយនឹងចំនួនមនុស្សទាំងអស់ដែលចុះមកពីជាន់ផ្សេងៗ។
នៅពេលដែលបានកត់ត្រាចំនួនបន្ទុក សមត្ថភាព និងការចែកចាយច្រកចេញរួចហើយ អ្នកវាយតម្លៃនឹងពិនិត្យមើលថាតើមនុស្សអាចធ្វើដំណើរចេញឆ្ងាយពីអគារបានបានដែរឬទេនៅពេលទៅដល់ច្រកចេញនោះ។ ប្រសិនបើមនុស្សត្រូវការធ្វើដំណើរតាមចំហៀងអគារមុននឹងចាកចេញទៅឆ្ងាយ នោះត្រូវជញ្ជាំងទីធ្លាការពារខាងមុខនៅតាមបណ្តោយផ្លូវនោះ ដែលជាចំណុចត្រូវធ្វើការអង្កេតដើម្បីពិនិត្យមើលថាតើត្រូវការការការពារពីខាងក្រៅបន្ថែមទៀតដែរឬទេ។

5.3.2 សំណង់សុវត្ថិភាពអគ្គិភ័យ

បន្ទាប់ពីពិនិត្យមើលបញ្ហាទាំងអស់ពាក់ព័ន្ធទៅនឹងផ្លូវជម្លៀសខ្លួនទៅខាងក្រៅអគាររួច អ្នកវាយតម្លៃគួរអង្កេតមើលបញ្ហាពាក់ព័ន្ធបរិវេណខណ្ឌ និងខណ្ឌពីអគ្គិភ័យទាំងអស់ផ្សេងទៀត។ បរិវេណដែលត្រូវការខណ្ឌចែកពីបរិវេណនីមួយៗ ត្រូវកត់ត្រាទុក ក៏ដូចជាច្រកចំហតាមទិសបញ្ឈរនៅចន្លោះជាន់ផងដែរ។
គោលដៅ និងដំណោះស្រាយរចនាសម្រាប់ការផ្តល់វិធានការការពារអគ្គិភ័យចំពោះសំណង់ អាចសង្ខេបបានដូចខាងក្រោមក្នុងករណីមានអគ្គិភ័យ៖

សំណង់ - គោលដៅសុវត្ថិភាពអគ្គិភ័យក្នុងករណីមានអគ្គិភ័យកើតឡើង	ដំណោះស្រាយការរចនា
	ផ្តល់របាំងធន់នឹងអគ្គិភ័យទៅកាន់បរិវេណអគារដែលចាត់ទុកថាជា "ទីកន្លែងមានសុវត្ថិភាព"
	ការបំពាក់សំណង់ របាំងការពារ ទ្វារធន់នឹងអគ្គិភ័យ ។ល។ នៅតាមអគារ និងបរិវេណដែលមានហានិភ័យខ្ពស់

ការផ្តល់ការការពារធន់នឹងអគ្គិភ័យដល់ធាតុគ្រឿងបង្គុំទ្របន្ទុក
ការបិទប្រហោងចោះ និងបរិវេណបិទជិតជាដើម ដោយប្រព័ន្ធបញ្ឈប់អគ្គិភ័យ

វិធានការការពារអគ្គិភ័យសំណង់ដែលត្រូវការជាចាំបាច់ដើម្បីសម្រេចគោលដៅសុវត្ថិភាពអគ្គិភ័យដែលមានរៀបរាប់ខាងលើនេះ ភាគច្រើនមានលក្ខណៈអកម្ម។ វិធានការទាំងនោះរួមមាន ការប្រើប្រាស់វត្ថុធាតុ (មិនងាយឆាបឆេះ មានសារធាតុឆាបឆេះមានកម្រិត) ឱ្យស្របតាមលក្ខណៈវិនិច្ឆ័យសមត្ថភាពដែលមានចែងនៅក្នុងបទដ្ឋាន LABS។
ការឆេះរាលដាលនៃភ្លើងនៅក្នុងអគារអាចកំហិតបានតាមរយៈការដាក់បញ្ចូលបន្ទុកទាំងអស់ទៅក្នុងបរិវេណខណ្ឌដែលខណ្ឌដាច់ដោយឡែកពីបរិវេណផ្សេងទៀតដោយជញ្ជាំង និង/ឬកម្រាលឥដ្ឋនៃសំណង់ធន់នឹងអគ្គិភ័យ។ គោលបំណងគឺមានពីរ៖

- ដើម្បីទប់ស្កាត់កុំឱ្យភ្លើងឆាប់ឆេះរាលដាលលឿន ដែលធ្វើឱ្យអ្នកនៅក្នុងអគារជាប់នៅក្នុងអគារ មិនអាចចេញរួច និង
- ដើម្បីកាត់បន្ថយហានិភ័យភ្លើងឆេះកាន់តែខ្លាំង ដោយឈរលើមូលដ្ឋានថា ភ្លើងកាន់តែធំ កាន់តែគ្រោះថ្នាក់ មិនមែនត្រឹមតែគ្រោះថ្នាក់ដល់អ្នកនៅក្នុងអគារ បុគ្គលិកអគ្គិភ័យ និងបុគ្គលិកសង្គ្រោះប៉ុណ្ណោះទេ តែថែមទាំងមនុស្សនៅតំបន់ជុំវិញអគារផងដែរ



អគ្គិភ័យបរិវេណខណ្ឌបញ្ឈរកម្រិតការឆេះរាលដាលតាមទិសដេក ប៉ុន្តែអាចឆេះរាលដាលតាមទិសបញ្ឈរតាមច្រកចំហតាមជាន់



អគ្គិភ័យបរិវេណខណ្ឌទាមទិសដេកកម្រិតការឆេះរាលដាលតាមទិសបញ្ឈរ ប៉ុន្តែអាចឆេះរាលដាលតាមទិសដេកពេញបរិវេណខណ្ឌ

រូបភាព 5៖ គំនូសព្រាងដែលបង្ហាញពីបរិវេណខណ្ឌទាមទិសដេក និងទិសបញ្ឈរ

បរិវេណខណ្ឌ គឺតម្រូវឱ្យខណ្ឌបរិវេណកាន់កាប់ផ្សេងៗគ្នា ជាន់ក្រោមដី ជាន់នីមួយៗ និងការប្រើប្រាស់ផ្សេងៗគ្នាដូចដែលបានរៀបរាប់នៅក្នុងផ្នែកនេះ។
លើសពីនេះ គោលការណ៍ការពារអគ្គិភ័យនេះអនុវត្តចំពោះការខណ្ឌបរិវេណដែលមានហានិភ័យខ្ពស់ និងការការពារផ្លូវជម្លៀសខ្លួន។

5.3.2.1 ការការពារច្រកចំហ

ច្រកចំហតាមទិសបញ្ឈរភាគច្រើននៅចន្លោះជាន់ដែលឃើញមាននៅក្នុងអគារពោងចក្រ គឺជាច្រកចំហសម្រាប់ជណ្តើរឆ្លងកាត់។ នៅពេលដែលផ្លូវជណ្តើរឆ្លងកាត់លើសពីពីរជាន់ នោះជណ្តើរទាំងនោះត្រូវខណ្ឌពីបរិវេណនៅជាប់នោះដោយសំណង់ធន់នឹងអគ្គិភ័យ។

បទដ្ឋាន LABS មានបញ្ជាក់ថា ប្រអប់ជណ្តើរគួរតែការពារពីរបាំងការពារធន់នឹងអគ្គិភ័យឱ្យបាន 2 ម៉ោង ហើយច្រកចំហនៃទ្វារដែលនាំទៅកាន់ប្រអប់ជណ្តើរទាំងនេះត្រូវមានទ្វារដែលធន់ទៅនឹងអគ្គិភ័យបាន 90 នាទី ដែលត្រូវតែបំពាក់មកជាមួយនឹងឧបករណ៍បិទដោយស្វ័យប្រវត្តិផងដែរ



<u>រូបភាព 6 ការរៀបចំទូទៅសម្រាប់ការការពារជណ្តើរសម្រាប់អគារ</u>

ផ្លូវជណ្តើរច្រកចេញមិនត្រូវសាងសង់នៅជុំវិញច្រកផ្លូវជណ្តើរយោងនោះទេ លើកលែងតែរបាំង

ការពារច្រកផ្លូវជណ្តើរយោងមានភាពរឹងមាំ និងធ្វើឡើងពីវត្ថុធាតុដែលមានកម្រិតធន់នឹងអគ្គិភ័យសម្រាប់ប្រភេទសំណង់អគារ។

ការទម្លុះចោះប្រហោងណាមួយសម្រាប់ថាមពលនៅក្នុងធាតុខណ្ឌពីអគ្គិភ័យត្រូវបិទឱ្យជិតជាមួយប្រព័ន្ធបញ្ឈប់អគ្គិភ័យ ឬត្រូវមានសន្ទះបិទ។

ប្រហោងចោះផ្សេងទៀត គឺជាទ្វារ ហើយអ្នកវាយតម្លៃនឹងកត់ត្រាមើលថាតើបានបំពាក់ទ្វារធន់នឹងអគ្គិភ័យដែរឬទេ ហើយថាតើទ្វារទាំងនោះមានបំពាក់ឧបករណ៍បិទដោយខ្លួនឯងដែរឬទេ ដើម្បីធានាថាទ្វារទាំងនោះបិទដោយស្វ័យប្រវត្តិបន្ទាប់ពីប្រើប្រាស់ហើយ។

ជណ្តើរជម្លៀសខ្លួនខាងក្រៅ ក៏ត្រូវបានអនុញ្ញាតផងដែរ លុះត្រាណាតែជណ្តើរទាំងនេះនាំទៅកាន់ជាន់ផ្ទាល់ដីដោយផ្ទាល់ ខណ្ឌដាច់ពីផ្នែកខាងក្នុងអគារដោយគ្រឿងបង្គុំ ឬជញ្ជាំងធន់នឹងអគ្គិភ័យ និងសាងសង់ឡើងពីវត្ថុធាតុមិនឆាបឆេះ។

ជណ្តើរខាងក្រៅត្រូវតែមានបំពាក់ជាមួយនឹងជាន់ការការពារពីអគ្គិភ័យ ដើម្បីទប់ស្កាត់អណ្តាតភ្លើង និងផ្សែងដែលសាយភាយចេញតាមទីធ្លាខាងមុខនៃអគារ និងប៉ះពាល់ដល់មនុស្សដែលជម្លៀសខ្លួនដោយប្រើប្រាស់ជណ្តើរ។

រូបភាពខាងក្រោមបង្ហាញអំពីរបៀបដែលការការពារគ្រប់គ្រាន់អាចបំពាក់បានយោងតាម NFPA 5000 ប្រការ 11.2.2.5។ ទីធ្លាខាងមុខផ្ទាល់ ព្រមទាំងបង្ហួច និងទ្វារនានានៅក្នុងបរិវេណម្លប់ នឹងត្រូវការពារដោយសំណង់ធន់នឹងអគ្គិភ័យនៅក្នុងតំបន់ជុំវិញផ្លូវធ្វើដំណើរទៅកាន់ជណ្តើរ។

កម្រិតធន់នឹងអគ្គិភ័យរបស់រចាំងខណ្ឌពីជណ្តើរតម្រូវឱ្យមានកម្រិតធន់នឹងអគ្គិភ័យយ៉ាងតិច 1 ម៉ោង ដែលច្រកចំហត្រូវមានកម្រិតការពារពីអគ្គិភ័យមិនតិចជាង ¾ ម៉ោងឡើយ៖

- ស្ថិតនៅចម្ងាយ 3.0 ម៉ែត្រតាមទិសដេកពីជញ្ជាំងមិនមានកម្រិតការពារ ឬច្រកចំហដែលមិនបានការពារ។
- តចេញពីជាន់ផ្ទាល់ដីដែលមានកម្ពស់ផុតពីដីរហូតដល់ចំណុច 3.0 ម៉ែត្រពីលើចំណតនៅចុងបំផុតនៃជណ្តើរ ឬរហូតដល់មេដំបូលដោយយកតាមចំណុចណាដែលទាបជាងគេ។



<u>រូបភាព 7 ការការពារជណ្តើរជម្លៀសខ្លួនខាងក្រៅ</u>

ប្រហោងចោះតាមទិសបញ្ឈរណាមួយផ្សេងទៀតសម្រាប់ច្រកផ្លូវជណ្តើរយោង បំពង់ថាមពល ឬមុខងារផ្សេងទៀត និងរបាំងខណ្ឌធន់នឹងអគ្គិភ័យរបស់ច្រកចំហាទាំងនេះ ត្រូវកត់ត្រាដើម្បីធានាថាមិនមានផ្លូវតាមទិសបញ្ឈរដែលមិនបានការពារនៅចន្លោះជាន់តាមបរិវេណខណ្ឌឡើយ។

របាំងការពារបរិវេណខណ្ឌ និងរបាំងខណ្ឌធន់នឹងអគ្គិភ័យទាំងអស់ កម្រាលឥដ្ឋ និងជញ្ជាំង ត្រូវធានាថា ប្រហោងចោះចូលតាមបរិវេណទាំងនេះ អាចមានសម្រាប់បំពង់ ទុយោ ខ្សែភ្លើង ឬវត្ថុផ្សេងៗទៀត គឺត្រូវបានការពារបានគ្រប់គ្រាន់។ អាស្រ័យលើប្រភេទនៃប្រហោងចោះ មានវិធីសាស្ត្រផ្សេងៗគ្នាក្នុងការបញ្ចៀសការលេចធ្លាយផ្សែង និងកម្តៅតាមរយៈប្រហោងចោះដែលបានចោះដើម្បីដាក់វត្ថុទាំងនេះ។

ជាន់ក្រោមដីត្រូវការការជាពិសេសពីជាន់ខាងលើ ដូច្នេះ អ្នកវាយតម្លៃនឹងកត់ត្រាអំពីរបៀបដែលអាចសម្រេចបានការខណ្ឌនេះ ជាពិសេស ថាតើមានច្រកចូលដែលបានផ្តល់ជូនជាផ្នែកមួយនៃគន្លឹះខណ្ឌសម្រាប់ប្រហោងចោះនៅជណ្តើរដែរឬទេ។ របាំងខណ្ឌនេះ គួរជារបាំងខណ្ឌធន់នឹងអគ្គិភ័យដែលមានទ្វារបិទដោយខ្លួនឯង និងច្រកចូលដូចដែលមានបង្ហាញនៅក្នុង រូបភាព 10 ខាង

ក្រោម៖



<u>រូបភាព 8 គំនូសព្រាងបង្ហាញអំពីលក្ខខណ្ឌតម្រូវមូលដ្ឋានសម្រាប់ការការពារច្រកចំហជាន់ក្រោមដី</u>

5.3.2.2 ការខណ្ឌបរិវេណកាន់កាប់

វិធានការសុវត្ថិភាពអគ្គិភ័យដែលបទដ្ឋាន LABS បានតម្រូវមានកំណត់តាមចំណាត់ថ្នាក់បរិវេណកាន់កាប់នៃអគារ។

អគាររោងចក្រកាត់ដេរសម្លៀកបំពាក់ ស្បែកជើង កាបូប និងផលិតផលធ្វើដំណើរ គឺត្រូវបានចាត់ថ្នាក់ជា អគារ "ការកាន់កាប់សម្រាប់ឧស្សាហកម្មទូទៅ"។

បរិវេណកាន់កាប់ផ្សេងទៀតដែលឃើញមានជាទូទៅនៅក្នុងអគាររោងចក្រកាត់ដេរសម្លៀកបំពាក់ ស្បែកជើង កាបូប និងផលិតផលធ្វើដំណើរមាន៖

- បរិវេណកាន់កាប់សម្រាប់ការប្រមូលផ្តុំនៅក្នុងបរិវេណទទួលទានអាហារ
- បរិវេណកាន់កាប់អាជីវកម្មសម្រាប់ការិយាល័យ
- បរិវេណកាន់កាប់សម្រាប់ការរក្សាទុក

បទដ្ឋាន LABS តម្រូវឱ្យបរិវេណកាន់កាប់ផ្សេងៗនៅតាមអគារដែលបានចាត់ថ្នាក់រួមជាតំបន់ "ឧស្សាហកម្មទូទៅ" ឱ្យធ្វើការខណ្ឌចែកពីការប្រើប្រាស់ឧស្សាហកម្ម និងខណ្ឌពីគ្នាដោយជញ្ជាំង

ខណ្ឌធន់នឹងអគ្គិភ័យ លើកលែងតែបានបំពេញតាមលក្ខខណ្ឌជាក់លាក់ដូចខាងក្រោម៖
ក្នុងករណីដែលបរិវេណកាន់កាប់អាចកំណត់ជា "បរិវេណកាន់កាប់បន្ទាប់បន្សំ" នោះមិនចាំបាច់ខណ្ឌដាច់ដោយឡែកពីជាន់ទាំងមូល ឬពីបរិវេណកាន់កាប់នៃអគារឡើយ។ ឧទាហរណ៍ខ្លះអំពីបរិវេណកាន់កាប់បន្ទាប់បន្សំរួមមាន៖

- បរិវេណទទួលទានអាហារសម្រាប់មនុស្សតិចជាង 50 នាក់
- មណ្ឌលថែទាំកុមារសម្រាប់កុមារតិចជាងបួននាក់ និងមានចម្ងាយធ្វើដំណើរអតិបរិមា 9 ម៉ែត្រទៅកាន់ច្រកចេញចុងក្រោយ។
- ការិយាល័យដែលកាន់កាប់អតិបរិមារហូតដល់ 10% នៃផ្ទៃក្រឡាជាន់ផលិតកម្ម
- បរិវេណឃ្លាំងអតិបរិមារហូតដល់ 25% នៃផ្ទៃក្រឡាជាន់ផលិតកម្ម ស្របបតាមដែនកំណត់ដែលផ្តល់ជូននៅក្នុងផ្នែក 5.3.2.3 ខាងក្រោម
- "បរិវេណដែលមានហានិភ័យខ្ពស់" ជាក់លាក់ តែងតែតម្រូវឱ្យបាំងដោយរបាំងខណ្ឌធន់នឹងអគ្គិភ័យពីបរិវេណផលិតកម្ម ដូចមានរៀបរាប់នៅក្នុងផ្នែក 5.3.2.4 ខាងក្រោម។

5.3.2.3 បរិវេណឃ្លាំង

បរិវេណសម្រាប់ស្តុកសម្ភារបានចាត់ទុកថាជាបរិវេណមានបន្ទុកអគ្គិភ័យខ្ពស់ ហេតុដូច្នេះហើយ គួរតែខណ្ឌឱ្យដាច់ពីបរិវេណនៅជាប់នោះដោយសំណង់ធន់នឹងអគ្គិភ័យ។ សំណង់នេះគួរតែតាមទិសបញ្ឈរហូតដល់ផ្នែកខាងក្រោមនៃជាន់បរិវេណខណ្ឌ និងចាំបាច់ត្រូវមានការត្រួតពិនិត្យជាពិសេសនៅបរិវេណចន្លោះប្រហោងពិតាន និងផ្នែកខាងក្រោមកម្រាលខណ្ឌ។
ឃ្លាំងដំណើរការ ឬឃ្លាំងបណ្តោះអាសន្នដែលនៅជាប់ទៅនឹងប្រតិបត្តិការរបស់រោងចក្រកាត់ដេរ សម្លៀកបំពាក់ ស្បែកជើង កាបូប និងផលិតផលធ្វើដំណើរ ហេតុដូច្នេះមានភាពចាំបាច់ក្នុងការរក្សាទុកទំនិញ ឬសម្ភារដែលនៅជាប់នឹងបរិវេណផលិតកម្ម។
ឃ្លាំងសម្ភារបណ្តោះអាសន្ន ត្រូវអនុញ្ញាតដោយមិនចាំបាច់ខណ្ឌពីបរិវេណកាន់កាប់ផ្សេង។ លុះត្រាណាតែឃ្លាំងនោះបំពេញតាមលក្ខណៈវិនិច្ឆ័យខាងក្រោម៖

- ឃ្លាំងមានផ្ទៃក្រឡាមិនលើសពី 23ម2 និងមានកម្ពស់មិនលើសពី 2.45 ម៉ែត្រ (8 ហ្វីត) នៅបរិវេណណាមួយសម្រាប់ជាន់ដែលគ្មានឧបករណ៍បាញ់ទឹក
- ឃ្លាំងមានផ្ទៃក្រឡាមិនលើសពី 93ម2 និងមានកម្ពស់មិនលើសពី 3.66 ម៉ែត្រ (12 ហ្វីត) នៅបរិវេណណាមួយសម្រាប់ជាន់ដែលមានឧបករណ៍បាញ់ទឹក
- ក្នុងករណីដែលឃ្លាំងបណ្តោះអាសន្នលើសពីលក្ខណៈវិនិច្ឆ័យទាំងនេះ ឃ្លាំងនោះគួរតែខណ្ឌទៅជា "ប្លុក" ឃ្លាំងដែលបំពេញតាមលក្ខណៈវិនិច្ឆ័យទាំងនេះ និងមានចម្ងាយទំនេរចន្លោះ "ផ្លូវដើរ (islands)" មិនតិចជាង 3 ម៉ែត្រ។ (សូមមើលបទដ្ឋាន LABS 3.11.5.6)

- ឃ្លាំង គឺជាឃ្លាំងបន្ទាប់បន្សំសម្រាប់បរិវេណកាន់កាប់ផ្សេងៗ ឧទាហរណ៍ ផ្ទៃក្រឡាសរុបនៃឃ្លាំងបណ្តោះអាសន្នមិនលើសពី 25% នៃផ្ទៃក្រឡាផលិតកម្មនៃជាន់ដែលដាក់ឃ្លាំងនោះទេ

ក្នុងករណីដែលឃ្លាំងមិនបំពេញតាមលក្ខណៈវិនិច្ឆ័យទាំងនេះទេ នោះត្រូវខណ្ឌឃ្លាំងនេះពីបរិវេណកាន់កាប់ផ្សេងទៀតដោយមានសំណង់ធន់នឹងអគ្គិភ័យ 1 ម៉ោង។
ការអនុវត្តលក្ខណៈវិនិច្ឆ័យទាំងនេះមានបង្ហាញនៅក្នុងរូបភាពខាងក្រោមសម្រាប់ករណីពុំមានឧបករណ៍បាញ់ទឹក។



<u>រូបភាព 9 ការរៀបចំឃ្លាំងបណ្តោះអាសន្ន</u>

អ្នកវាយតម្លៃ នឹងធ្វើការកត់ត្រាថាតើដែនកំណត់ផ្ទៃក្រឡាសម្រាប់ "ប្លុក" នៃឃ្លាំងកំពុងដំណើរការអនុលោមតាមលក្ខណៈវិនិច្ឆ័យដែរឬទេ ហើយក៏កត់ត្រាថាតើ "ប្លុក" នៃឃ្លាំងកំពុងដំណើរការកាន់កាប់ផ្ទៃក្រឡាជាន់សរុបចំនួនប៉ុន្មានភាគរយ។
ការហាមឃាត់បន្ថែមទៅលើផ្ទៃក្រឡាអតិបរិមានៃឃ្លាំងនៅក្នុងបរិវេណខណ្ឌណាមួយដែលអាចនឹងតម្រូវជញ្ជាំងខណ្ឌធន់នឹងអគ្គិភ័យ ដោយអាស្រ័យទៅលើប្រភេទសំណង់ និងចំនួនជាន់ គឺមានផ្តល់ជូននៅក្នុងតារាង 3.12.3 នៃបទដ្ឋាន LABS។
ប្រការ 5.3.2.2 នៃបទដ្ឋាន LABS ផ្តល់ការកែសម្រួលមួយចំនួនទៅលើតារាង 3.12.3 ដោយអនុញ្ញាតឱ្យមានផ្ទៃក្រឡារហូតដល់ 2.000 ម2 សម្រាប់ជាន់មិនមានឧបករណ៍បាញ់ទឹក។

5.3.2.4 បរិវេណដែលមានហានិភ័យខ្ពស់ផ្សេងទៀត

បន្ទប់មួយចំនួននៅរោងចក្រកាត់ដេរសម្លៀកបំពាក់ ស្បែកជើង កាបូប និងផលិតផលធ្វើដំណើរមានគ្រោះថ្នាក់អគ្គិភ័យកម្រិតខ្ពស់ ដោយសារតែវាបន្ទុកចំហេះ និងមានលក្ខណៈបង្កើនគ្រោះថ្នាក់អគ្គិភ័យ។ ជារឿយៗ បរិវេណដែលមានហានិភ័យខ្ពស់គឺមានពាក់ព័ន្ធនឹងរោងចក្រកាត់ដេរសម្លៀកបំពាក់ ស្បែកជើង កាបូប និងផលិតផលធ្វើដំណើរ ដែលមានម៉ាស៊ីនភ្លើង បរិក្ខារកម្តៅ កុំប្រៃសស័រ ត្រង់ស្ទ័រ និងឃ្លាំងទុកសារធាតុគីមី។

ចំណាត់ថ្នាក់ហានិភ័យខ្ពស់ជាចម្បងពឹងផ្អែកទៅលើបរិមាន និងប្រភេទនៃវត្ថុធាតុងាយឆាបឆេះ ល្បឿនដែលភ្លើងឆាបឆេះ និងដំណើរការនានាដែលនឹងបង្កស្ថានភាពធ្ងន់ធ្ងរឱ្យភ្លើងឆេះរាលដាល។ គោលការណ៍នេះគឺដើម្បីការពារ និងខណ្ឌបរិវេណទាំងនេះពីបរិវេណផ្សេងៗទៀតនៃអោងចក្រកាត់ដេរសម្លៀកបំពាក់ ស្បែកជើង កាបូប និងផលិតផលធ្វើដំណើរ ដូច្នេះការឆេះរាលដាលអគ្គិភ័យ គឺមានកំណត់ ឬអាចគ្រប់គ្រងបាន។ ជាលទ្ធផល បរិវេណទាំងនេះនឹងមិនរាលដាល ឬការរាលដាលនៃបរិវេណទាំងនេះ គឺត្រូវបានពន្យារពេលក្នុងករណីដែលអគ្គិភ័យឆាបឆេះនៅក្រៅបរិវេណទាំងនេះ។

អ្នកវាយតម្លៃ នឹងកត់ត្រាអំពីទីតាំងនៃបរិវេណទាំងនេះ ហើយប្រសិនបើទីតាំងទាំងនេះស្ថិតនៅទល់មុខបរិវេណផលិតកម្ម ឬបរិវេណកាន់កាប់ផ្សេងទៀត នោះបរិវេណទាំងនោះត្រូវតែខណ្ឌពីបរិវេណជាប់គ្នាដោយសំណង់ធន់នឹងអគ្គិភ័យ។

ទ្វារទៅកាន់បន្ទប់ខណ្ឌទាំងនេះ ក៏ត្រូវការពារពីអគ្គិភ័យផងដែរ ហើយប្រសិនបើទ្វារទាំងនោះបើកចំហទៅកាន់ជណ្តើរ ឬច្រកផ្លូវ ដែលបានការពារ ចាំបាច់ត្រូវតែខណ្ឌដោយបំពង់នៅចំណុចច្រកចូល។

5.3.2.5 គ្រឿងបង្គុំ និងកម្រាលផ្ទៃ

បទដ្ឋាន LABS កំណត់អំពីកម្រិតនៃភាពធន់នឹងអគ្គិភ័យទៅតាមប្រភេទសំណង់ដូចខាងក្រោម៖ ការចាត់ថ្នាក់តាមប្រភេទសំណង់៖

- ប្រភេទ 1៖ កម្រិតធន់នឹងអគ្គិភ័យខ្ពស់បំផុត
- ប្រភេទ 2៖ កម្រិតធន់នឹងអគ្គិភ័យមធ្យម
- ប្រភេទ 3៖ កម្រិតធន់នឹងអគ្គិភ័យទាបបំផុត

ដោយអាស្រ័យទៅលើកម្ពស់អគារ អគារអោងចក្រកាត់ដេរសម្លៀកបំពាក់ ស្បែកជើង កាបូប និងផលិតផលធ្វើដំណើរ អាចជាអគារប្រភេទ 1 ឬប្រភេទ 2។

អ្នកវាយតម្លៃនឹងកត់ត្រាប្រភេទសំណង់ និវត្ថុធាតុគ្រឿងបង្គុំដែលប្រើប្រាស់។ ចំពោះបេតុង យើងសន្មត់ថាបេតុងនឹងផ្តល់ការការពារអគ្គិភ័យគ្រប់គ្រាន់រួចទៅហើយ ប៉ុន្តែក៏គួរកត់ត្រាពីទីតាំងប្រើប្រាស់បេតុង ដែក ឈើ ឬវត្ថុធាតុគ្រឿងបង្គុំផ្សេងទៀតដែរ។

កម្រាលផ្ទៃនៅក្នុងអោងចក្រកាត់ដេរសម្លៀកបំពាក់ ស្បែកជើង កាបូប និងផលិតផលធ្វើដំណើរ ជាទូទៅគឺមានកម្រាលបេតុងទទេ បេតុងបៀក ឬកម្រាលឥដ្ឋ និងការ៉ូសេរ៉ាមិក ដែលវត្ថុធាតុទាំងអស់នេះជាកម្រាលផ្ទៃកម្រិត A មិនងាយឆាបឆេះ។ ដូច្នេះ ភ្លើងឆេះរាលដាលតាមបណ្តោយជញ្ជាំង កម្រាលឥដ្ឋ ឬពិតាន ជាទូទៅ មិនមានជាបញ្ហានោះទេនៅក្នុងអគារប្រភេទនេះ។

ទោះជាយ៉ាងនេះក្តី នៅបរិវេណជាក់លាក់ របាំងខណ្ឌអាចធ្វើឡើងពីវត្ថុធាតុផ្សេងៗគ្នា ជាពិសេស

សម្រាប់ការិយាល័យ បន្ទប់ប្រជុំ និងទីតាំងសម្រាប់ប្រើប្រាស់ស្រដៀងគ្នាដែលមានដំឡើងពិតាន (false ceilings)។

កម្រាលផ្ទៃដែលក្រាលលើកម្រាលឥដ្ឋ ពិតាន ជញ្ជាំងខាងក្នុង និងទីធ្លាខាងមុខនៅខាងក្រៅរោង ចក្រកាត់ដេរសម្លៀកបំពាក់ ស្បែកជើង កាបូប និងផលិតផលធ្វើដំណើរ អាចរួមចំណែកដល់អគ្គិភ័យជាឥន្ធនៈ ដោយសារតែលក្ខណៈនៃផ្ទៃទាំងនោះ ហេតុដូច្នេះបង្កើតបានជាផ្សែង និងផលិតផលពុលក្នុងអំឡុងពេលមានអគ្គិភ័យឆាបឆេះ។ ជម្រើសវត្ថុធាតុសម្រាប់ជញ្ជាំង និងពិតានមានឥទ្ធិពលយ៉ាងខ្លាំងចំពោះការឆេះរាលដាលនៃអគ្គិភ័យ និងអត្រាឆាបឆេះ ទោះបីជាវត្ថុធាតុទាំងនោះមិនមែនជាវត្ថុធាតុដែលឆេះមុនគេក៏ដោយ។

កត្តានេះមានសារៈសំខាន់ជាពិសេសនៅក្នុងបរិវេណមានចរាចរណ៍ទៅវិញទៅមកជាកន្លែង ដែលក្រណាត់ទ្រនាប់អាចប្រភពចម្បងដែលភ្លើងអាចឆេះរាលដាលបាន និងជាកន្លែងដែលភ្លើងឆេះរាលដាលលឿន ដែលទំនងជានឹងរារាំងអ្នកនៅក្នុងអគារមិនឱ្យជម្លៀសខ្លួនចេញបាន។ លក្ខណៈសមាសធាតុមួយចំនួននៃវត្ថុធាតុមាន ឥទ្ធិពលទៅលើការឆេះរាលដាលនៃអគ្គិភ័យ។ ឥទ្ធិពលទាំងនេះរួមមាន ភាពងាយស្រួលនៃចំហេះ និងអត្រាដែលវត្ថុធាតុក្រណាត់ទ្រនាប់ទាំងនេះផលិតកម្តៅនៅពេលវាឆាប់ឆេះ។

កម្រាលផ្ទៃដែលប្រើប្រាស់សម្រាប់ជញ្ជាំង និងពិតានត្រូវតែផ្សំឡើងពីវត្ថុធាតុដែលកម្រិតទៅលើការរាលដាលនៃអគ្គិភ័យ ដូច្នេះអ្នកវាយតម្លៃនឹងកត់ត្រាអំពីវត្តមាននៃវត្ថុធាតុកម្រាលផ្ទៃនានា (ជាពិសេសប្លាស្ទិក) ដែលប្រើប្រាស់នៅលើជញ្ជាំង និង/ឬពិតាននៅក្នុងអគារ។

5.3.3 ប្រព័ន្ធសុវត្ថិភាពអគ្គិភ័យ

ប្រព័ន្ធសុវត្ថិភាពអគ្គិភ័យត្រូវលើកឡើងដោយអ្នកវាយតម្លៃសុវត្ថិភាពអគ្គិភ័យ និងអ្នកវាយតម្លៃសុវត្ថិភាពអគ្គិសនី ហើយចំណុចខាងក្រោមនេះក៏កត់ត្រាពីចំណុចដែលអ្នកវាយតម្លៃអគ្គិភ័យត្រូវការដើម្បីលើកឡើងនៅក្នុងការវាយតម្លៃ និងរបាយការណ៍។

របាយការណ៍អគ្គិភ័យ នឹងលើកឡើងអំពីប្រភេទនៃប្រព័ន្ធចាប់សញ្ញា និងផ្តល់សញ្ញា ប្រភេទប្រព័ន្ធភ្លើងបំភ្លឺពេលមានអាសន្ន និងការគ្របដណ្តប់នៃប្រព័ន្ធទាំងនេះ។ កំណត់ត្រានេះក៏កត់ត្រាអំពីរបៀបបើកដំណើរការប្រព័ន្ធទាំងនេះដែរ។

ការវាយតម្លៃ និងរបាយការណ៍អគ្គិសនី មានរៀបរាប់អំពីមុខងារនៃប្រព័ន្ធទាំងនេះដោយលម្អិតប្រភពថាមពលផ្គត់ផ្គង់បម្រុងដែលផ្តល់ជូន និងតំណភ្ជាប់ទៅកាន់ជានែលគ្រប់គ្រង។ ការធ្វើតេស្តប្រព័ន្ធផ្តល់សញ្ញា និងប្រព័ន្ធគ្រោះអាសន្ន នឹងត្រូវបានរៀបចំជាផ្នែកមួយនៃការវាយតម្លៃអគ្គិសនី។

ប្រព័ន្ធចាប់សញ្ញា និងប្រព័ន្ធផ្តល់សញ្ញាអគ្គិភ័យគ្រប់គ្រាន់ គឺមានសារៈសំខាន់ណាស់ក្នុងការធានា

បាននូវសុវត្ថិភាពអាយុជីវិតរបស់អ្នកនៅក្នុងអគារ និងកាត់បន្ថយលទ្ធភាពនៃការឆេះរាលដាលនៃអគ្គិភ័យដែលមិនអាចចាប់សញ្ញាបាន។ លក្ខខណ្ឌតម្រូវចម្បងសម្រាប់ប្រព័ន្ធចាប់សញ្ញាអគ្គិភ័យ គឺជាសមត្ថភាព៖

- ឆ្លើយតបទៅនឹងផលិតផលចំហេះដែលទំនងជានឹងបង្កការគម្រាមកំហែងដល់អគារ អ្នកនៅក្នុងអគារ និង/ឬដំណើរការក្នុងអគារ
- ញែកដាច់ពីគ្នារវាងអគ្គិភ័យពិតប្រាកដ និងកណ្តឹងរោទ៍ខុស
- ផ្តល់សញ្ញាឱ្យបើកដំណើរការប្រព័ន្ធព្រមានអគ្គិភ័យ ឬប្រព័ន្ធគ្រប់គ្រងនៅក្នុងរយៈពេលដែលអាចទទួលយកបាន
- មានប្រព័ន្ធគ្រប់គ្រាន់ និងអាចទុកចិត្តបានសម្រាប់ប្រើប្រាស់នៅពេលត្រូវការ និងតាមបំណង។



<u>រូបភាព 10 សមាសធាតុទូទៅនៃប្រព័ន្ធចាប់សញ្ញា និងប្រព័ន្ធផ្តល់សញ្ញាអគ្គិភ័យ</u>

5.3.3.1 ប្រព័ន្ធចាប់សញ្ញាអគ្គិភ័យ

ប្រព័ន្ធសាមញ្ញ គឺជាវិធីសាស្ត្រមូលដ្ឋាននៃការចាប់សញ្ញាអគ្គិភ័យ ដែលជាទូទៅ ជាជម្រើសមានប្រសិទ្ធភាពចំណាយខ្ពស់បំផុត។ ប្រព័ន្ធនេះមានកុងតាក់យ៉ាងសាមញ្ញ ដែលជាកុងតាក់ "បើក" ឬ "បិទ"។ ប្រព័ន្ធនេះមិនអាចបែងចែកដាច់ដោយឡែកពីគ្នារវាងអគ្គិភ័យពិតប្រាកដ និងហេតុការណ៍មិនមែនអគ្គិភ័យ ដែលនឹងបើកដំណើរការកណ្តឹងរោទ៍ខុស ដូចជាដោយសារតែ ផ្សែងបារី ធូលី និងចំហាយ ហើយប្រព័ន្ធនេះមិនអាចបង្ហាញអំពីទីតាំងជាក់លាក់នៅក្នុងតំបន់នោះបានទេ។

ប្រព័ន្ធផ្តល់សញ្ញាអគ្គិភ័យដំណើរការដោះស្រាយអាណាឡូក បញ្ជូនសញ្ញាទៅវិញទៅមកបានភ្លាមៗជាមួយនឹងជានៃលគ្រប់គ្រងអគ្គិភ័យ។ ប្រសិនបើមានការកើនឡើងសីតុណ្ហភាពខុសប្រក្រតីណាមួយ ឬកសុតាងនៃផ្សែង គឺត្រូវបានបញ្ជូនទៅកាន់ជានៃលអគ្គិភ័យ ដែលបន្ទាប់ពីវិភាគសញ្ញានោះហើយ ប្រព័ន្ធនេះសម្រេចបើកដំណើរការកណ្តឹងរោទ៍ និងបង្ហាញថាតើឧបករណ៍ចាប់សញ្ញាណាមួយដែលបង្ហាញអំពីអគ្គិភ័យនៅក្នុងផ្នែកជាក់លាក់នៃអគារ។
ប្រព័ន្ធដោះស្រាយអាណាឡូក ជាទូទៅត្រូវបានដំឡើងនៅតាមអគារធំៗ ដែលយើងមិនអាចដឹងច្បាស់ពីទីតាំងរបស់សញ្ញាកណ្តឹងរោទ៍មនៅក្នុងរយៈពេលខ្លីបានឡើយ។

	
អាចដោះស្រាយបាន • កំណត់រកទីតាំងអគ្គិភ័យកាន់តែងាយស្រួល • ព័ត៌មានគឺបញ្ជូនតត្រលប់ទៅកាន់ជានៃលគ្រប់គ្រងវិញជានិច្ច រួមមានកំហុសជាដើម ដូច្នេះការថែទាំគឺកាន់តែងាយស្រួល។	**ធម្មតា** • សៀគ្វី radial នីមួយៗនឹងមានឧបករណ៍ជាច្រើនភ្ជាប់ជាមួយ ដូច្នេះការកំណត់ទីតាំងអគ្គិភ័យគឺកម្រិតត្រឹមសៀគ្វីនោះឯង។

<u>រូបភាព 11 ភាពខុសគ្នាសំខាន់ៗរវាងប្រព័ន្ធផ្តល់សញ្ញាអាចដោះស្រាយបាន និងប្រព័ន្ធផ្តល់សញ្ញាធម្មតា</u>

ដោយសារតែដែនកំណង់នៃប្រព័ន្ធនេះ ប្រព័ន្ធធម្មតាគួរតែប្រើប្រាស់សម្រាប់តែអគារតូចមានតែមួយជាន់។ ចំពោះអគារ ឬហេដ្ឋារចនាសម្ព័ន្ធមានច្រើនជាន់ដែលទាមទារឱ្យមានចំណុចចាប់សញ្ញាច្រើន ប្រព័ន្ធដោះស្រាយបានគឺសមស្របជាងគេ។
អ្នកវាយតម្លៃនឹងកត់ត្រាពីប្រភេទនៃប្រព័ន្ធចាប់សញ្ញាអគ្គិភ័យដែលប្រើប្រាស់សម្រាប់អគារ ឬបរិវេណ ក៏ដូចជាឧបករណ៍ចាប់សញ្ញាផ្សេងៗគ្នាដែលបានអង្កេតឃើញដែរ។ នៅពេលកត់ត្រាការគ្របដណ្តប់ ត្រូវយកចិត្តទុកដាក់ថាតើគម្លាត និងទីតាំងមានលក្ខណៈគ្រប់គ្រាន់ដើម្បីឱ្យប្រព័ន្ធអាចដំណើរការបានត្រឹមត្រូវដែរឬទេ។
អ្នកវាយតម្លៃក៏នឹងកត់ត្រាថាតើឧបករណ៍ចាប់សញ្ញាជាឧបករណ៍ចាប់សញ្ញាតាមចំណុចដំណើរការ

ដោយអាគុយភ្ជាប់ស្រេច ឬឧបករណ៍ចាប់សញ្ញាទាំងនោះតម្រូវភ្ជាប់ទៅនឹងប្រភពថាមពល ហើយទីតាំងនៃចំណុចផ្តល់សញ្ញាបញ្ជាដោយដៃ ក៏ត្រូវកត់ត្រាដែរ។

5.3.3.2 ឧបករណ៍ផ្តល់សញ្ញាអគ្គិភ័យ

ផ្នែកសំខាន់នៃប្រព័ន្ធនេះ គឺការធានាថានៅពេលដែលចាប់ផ្តើមចាប់សញ្ញា អ្នកនៅក្នុងអគារទាំងអស់នឹងទទួលបានសញ្ញាប្រកាសអាសន្នតាមរយៈឧបករណ៍បំពងសំឡេង និងនៅពេលចាំបាច់តាមរយៈឧបករណ៍បញ្ជាំងឱ្យឃើញ។

ជាទូទៅ ការប្រកាសអាសន្នធ្វើឡើងតាមឧបករណ៍បំពងសំឡេង (កណ្តឹង ឬឧបករណ៍បំពងសំឡេងអេឡិចត្រូនិក)។ ក្នុងករណីខ្លះ កណ្តឹងសំឡេងអាចប្រើប្រាស់បាន ប៉ុន្តែកណ្តឹងនេះគឺអាចប្រើប្រាស់បានតែនៅក្នុងកាលៈទេសៈពិសេសប៉ុណ្ណោះក្នុងករណីដែលមានមហាជនច្រើន។ សូមកត់សម្គាល់ថា ប្រព័ន្ធជូនដំណឹងសាធារណៈ (PA) នេះអាចប្រើប្រាស់បាន ប៉ុន្តែមិនអាចពឹងផ្អែកទាំងស្រុងបានឡើយ។ ដូច្នេះ តម្រូវឱ្យមានឧបករណ៍បំពងសំឡេងជាជំនួយ ទោះបីជាបានបំពាក់ប្រព័ន្ធជូនដំណឹងសាធារណៈហើយក៏ដោយ។

លើសពីនេះទៅទៀត ប្រព័ន្ធជូនដំណឹងសាធារណៈមិនត្រូវភាន់ច្រលំគ្នាជាមួយនឹងប្រព័ន្ធផ្តល់សញ្ញាជាសំឡេង (VA) នោះទេ។ ប្រព័ន្ធផ្តល់សញ្ញាជាសំឡេងចាក់ផ្សេងសារជាសំឡេង និង/ឬ សញ្ញាប្រកាសអាសន្ននៅក្នុងករណីគ្រោះអាសន្នតែប៉ុណ្ណោះ ហើយត្រូវរចនាឡើងឱ្យសមស្របដោយមានខ្សែភ្លើងការពារអគ្គិភ័យ និងប្រអប់ស្តីកយ៉ែរ ដូច្នេះប្រព័ន្ធនេះគឺអាចពឹងផ្អែកបានក្នុងករណីដូច្នេះ។

ជាការសំខាន់ណាស់ដែលត្រូវធ្វើយ៉ាងណាឱ្យកណ្តឹងរោទ៍ អាចស្តាប់ឮ ដូច្នេះឧបករណ៍បំពងសំឡេងគួរមានកម្រិតសំឡេងអប្បបរមាប្រហែល 65dB នៅពេញមួយអគារ ប៉ុន្តែសំខាន់ត្រូវមានកម្រិតសំឡេង 5dBA លើសំឡេងនៅក្នុងធម្មជាតិនានា។ កម្រិតសំឡេងនេះកាន់តែមានសំខាន់ នៅតាមកន្លែងអ៊ូអរច្រើន ដូចជា រោងចក្រ ឬកន្លែងដែលមនុស្សអាចប្រើឧបករណ៍ការពារត្រចៀក។ ក្នុងករណីខ្លះ ឧបករណ៍បំពងសំឡេង នឹងត្រូវតែបន្ថែមជាមួយនឹងភ្លើងសញ្ញាព្រមាន។

<u>រូបភាព 12 ឧទាហរណ៍នៃឧបករណ៍បំពងសំឡេង (ខាងឆ្វេងដៃ) និងឧបករណ៍ជូនដំណឹងបង្ហាញឱ្យឃើញ (ខាងស្តាំដៃ)</u>

ប្រព័ន្ធនេះគួររួមបញ្ចូលយ៉ាងតិចឧបករណ៍បំពងសំឡេងជូនដំណឹងអគ្គិភ័យចំនួនពីរ ទោះបីជាកម្រិតសម្ពាធសំឡេងដែលណែនាំអាចសម្រេចបានដោយឧបករណ៍បំពងសំឡេងតែមួយក៏ដោយ។ យ៉ាងតិចគួរមានឧបករណ៍បំពងសំឡេងមួយបំពាក់នៅក្នុងបរិវេណខណ្ឌពីអគ្គិភ័យនីមួយៗ។ សញ្ញាជូនដំណឹងអាចមើលឃើញ គួរបំពាក់នៅក្នុងបរិវេណដែលកម្រិតសំឡេងជុំវិញលើសពី 90 dB(A) និងនៅក្នុងបរិវេណផ្សេងទៀតដែលទំនងជាអាចប្រើឧបករណ៍ការពារត្រចៀកនៅក្នុងកាលៈទេស:ធម្មតា ប្រភេទនៃឧបករណ៍ផ្តល់សញ្ញាគួរតែកត់ត្រា – ឧបករណ៍បំពងសំឡេង ស្តីកយ៍រជូនដំណឹងជាសំឡេង ឬឧបករណ៍ផ្តល់សញ្ញាមើលឃើញ។ គម្លាតនៃឧបករណ៍ផ្តល់សញ្ញានឹងត្រូវកត់ត្រាដើម្បីវាយតម្លៃថាតើឧបករណ៍ទាំងនោះផ្តល់កម្រិតដេស៊ីបែលចាំបាច់ដល់ផ្នែកទាំងអស់នៃអគារដែរឬទេ។

អ្នកវាយតម្លៃអគ្គិភ័យ គួរតែកត់ត្រាថាតើប្រព័ន្ធផ្តល់សញ្ញាបានតខ្សែភ្ជាប់ដើម្បីឱ្យមានប្រតិបត្តិការដោយស្វ័យប្រវត្តិទៅលើឧបករណ៍ចាប់សញ្ញាអគ្គិភ័យ ឬមានតែចំណុចផ្តល់សញ្ញាបញ្ជាដោយដៃ (MCPs) ដែលបានបំពាក់សម្រាប់ការបើកដំណើរការប្រព័ន្ធផ្តល់សញ្ញាឬយ៉ាងណា។

5.3.3.3 ភ្លើងបំភ្លឺពេលមានអាសន្ន

អ្នកនៅក្នុងរោងចក្រត្រូវតែអាចស្វែងរកផ្លូវទៅកាន់ទីកន្លែងមានសុវត្ថិភាពចុងក្រោយបំផុត ប្រសិនបើមានអគ្គិភ័យកើតឡើងដោយប្រើប្រាស់ផ្លូវដម្លៀសខ្លួនដែលមានភ្លើងបំភ្លឺគ្រប់គ្រាន់។
នៅក្នុងបរិវេណអគារកម្ពស់មួយជាន់សាមញ្ញ ឧបករណ៍បំភ្លឺភ្លើងដម្លៀសខ្លួន "តែមួយ" អាចគ្រប់គ្រាន់ ហើយឧបករណ៍បំភ្លឺទាំងនេះជូនកាលអាចផ្សំគ្នាជាមួយនឹងសញ្ញាច្រកចេញ ឬសញ្ញាទិសដៅ។ កម្រិតនៃភ្លើងបំភ្លឺទូទៅមិនគួរកាត់បន្ថយខ្លាំងដោយស្លាកសញ្ញានោះទេ។
នៅក្នុងបរិវេណធំៗដែលមានភាពស្មុគស្មាញជាងនេះ ទំនងជាចាំបាច់ត្រូវការបំពាក់ប្រព័ន្ធភ្លើងបំភ្លឺ

អចល័តស្វ័យប្រវត្តិគ្រប់ជ្រុងជ្រោយដើម្បីបំភ្លឺគ្រប់ផ្លូវជម្លៀសខ្លួនទាំងអស់ឱ្យបានសព្វកន្លែង។
វិធីសាស្ត្របំពាក់បំភ្លឺផ្លូវជម្លៀសខ្លួននៅក្នុងគ្រាអាសន្នឱ្យមានប្រសិទ្ធភាព និងប្រសិទ្ធផល គឺត្រូវប្រើអំពូលភ្លើងបញ្ចាំង (spotlights)។ ជាទូទៅ អំពូលភ្លើងប្រភេទនេះគឺជាអំពូលភ្លើងមួយសំណុំដែលមានអាកុយ កុងតាក់បើកបិទ និងអំពូលបញ្ចាំងដែលបំពាក់ដើម្បីប្រតិបត្តិការដោយស្វ័យប្រវត្តិនៅលើសៀគ្វី ឬនៅពេលប្រភពថាមពលមេមិនដំណើរការ។ ឧបករណ៍មួយសំណុំនេះអាចបំពាក់នៅលើដំបូល ដៃកគ្រោងអគារ ដូចជាសសរ ឬធ្នឹម ធ្នើខ្ពស់ដែលបំពាក់បណ្តោះអាសន្ន ឬភ្ជាប់ទៅនឹងជញ្ជាំងជាដើម និងអាចមានសមត្ថភាពបំភ្លឺផ្លូវជម្លៀសខ្លួនបានយ៉ាងងាយស្រួល។ អំពូលទាំងនេះគួរតែបំពាក់នៅទីខ្ពស់ និងបញ្ចាំងចុះមកក្រោម។
អំពូលបំភ្លឺពេលមានអាសន្ន (អំពូលបំភ្លឺ) អាចជាសំណុំឧបករណ៍ទោល ឬអាចបញ្ចូលទៅក្នុងឧបករណ៍បំពាក់អំពូលធម្មតា។



<u>រូបភាព 13 ឧទាហរណ៍អំពីភ្លើងបំភ្លឺពេលមានអាសន្ន និងសញ្ញាជម្លៀសខ្លួនភ្លឺ (ខាងឆ្វេងដៃ) និងអំពូលបញ្ចាំងពេលមានអាសន្នទោល (ជាទូទៅប្រើភ្លើងអាគុយ)</u>

គោលបំណងនៃការបំភ្លឺផ្លូវជម្លៀសខ្លួនគឺដើម្បីជួយសម្រួលដល់ការជម្លៀសខ្លួន ឬការចាកចេញរបស់មនុស្សពីបរិវេណដោយសុវត្ថិភាព ហើយជួយឱ្យពួកគាត់អាចរកឃើញបរិក្ខារការពារអគ្គិភ័យ និងឧបករណ៍ពន្លត់អគ្គិភ័យ។ ក្នុងករណីនៅក្នុងផ្លូវដើរ កម្រិតពន្លឺមធ្យមនៅជាន់តាមបណ្តោយបន្ទាត់កណ្តាលនៃផ្លូវដើរ គួរតែមានកម្រិតពន្លឺយ៉ាងតិច 2.5 lux។



<u>រូបភាព 14 ការបំភ្លឺនៃភ្លើងបំភ្លឺផ្លូវជម្លៀសខ្លួន</u>

ផ្លូវជម្លៀសខ្លួនផ្សេងទៀតទាំងអស់ ត្រូវតែបំភ្លឺដោយកម្រិតពន្លឺមិនតិចជាង 10 lux ឡើយ។
ប្រសិនបើចំណុចពន្លត់អគ្គិភ័យបឋម ឬសម្ភារពន្លត់អគ្គិភ័យ និងចំណុចបើកឧបករណ៍ផ្តល់សញ្ញាអគ្គិភ័យមិនស្ថិតនៅតាមបណ្តោយផ្លូវជម្លៀសខ្លួន ឬស្ថិតនៅក្នុងបរិវេណចំហទេ ចំណុចទាំងនោះត្រូវមានភ្លើងបំភ្លឺដើម្បីឱ្យកម្រិតពន្លឺយ៉ាងតិច 10lx អាចមាននៅតាមជាន់ដែលស្ថិតនៅជិតចំណុចទាំងនេះ។
ភ្លើងបំភ្លឺពេលមានអាសន្ន គួរតែមានបំពាក់ដើម្បីផ្តល់នូវកម្រិតពន្លឺអប្បបរមានៅតាមបណ្តោយផ្លូវជម្លៀសខ្លួនពីដើមដល់ចប់។ អ្នកវាយតម្លៃអគ្គិភ័យនឹងកត់ត្រាថាតើភ្លើងបំភ្លឺពេលមានអាសន្នគឺត្រូវបានបំពាក់នៅតាមបណ្តោយផ្លូវជម្លៀសខ្លួន និងនៅច្រកចេញចុងក្រោយដែរឬទេ ឬគ្រាន់តែបំពាក់តែនៅច្រកចេញចុងក្រោយប៉ុណ្ណោះ ឬមួយយ៉ាងណា (ដែលជាករណីទូទៅ)។

5.3.4 បញ្ញត្តិសម្រាប់ការពន្លត់អគ្គិភ័យ

ប្រព័ន្ធពន្លត់អគ្គិភ័យខាងក្នុង មានពាក់ព័ន្ធជាចម្បងជាមួយនឹងការផ្តល់ និងការបែងចាយប្រព័ន្ធពន្លត់អគ្គិភ័យកាន់ដៃ និងប្រព័ន្ធទុយោបាញ់ពន្លត់អគ្គិភ័យ។ នៅខាងក្រៅត្រូវមានទឹកដែលស្តុកទុកសម្រាប់បម្រុង និងបណ្តុំម៉ាស៊ីនបូមទឹកសម្រាប់បំពេញទុយោទឹកបាញ់ពន្លត់អគ្គិភ័យ។

5.3.5 ការផ្គង់ផ្គត់ទឹក

ការផ្គង់ផ្គត់ទឹកបានគ្រប់គ្រាន់ជារឿងសំខាន់ណាស់ដើម្បី៖

- ធានាថាទុយោទឹកបញ្ឈរ និងប្រព័ន្ធបាញ់ទឹកមានទឹកគ្រប់គ្រាន់ដើម្បីប្រតិបត្តិការបានដោយប្រសិទ្ធភាព

- ដើម្បីឱ្យក្រុមពន្លត់អគ្គិភ័យអាចគ្រប់គ្រង និងពន្លត់អគ្គិភ័យបានដោយប្រសិទ្ធភាព។ ការផ្គង់ផ្គត់ទឹកអាចប្រើប្រាស់ដោយផ្ទាល់ដោយក្រុមពន្លត់អគ្គិភ័យដោយប្រើប្រាស់បរិក្ខារផ្ទាល់ខ្លួនរបស់ពួកគេ ឬប្រសិនបើមានផ្តល់ជូន ប្រើប្រាស់ដោយប្រព័ន្ធទុយោទឹកបញ្ឈរ ដែលស្ថិតនៅខាងក្នុងរោងចក្រ។

អ្នកវាយតម្លៃអគ្គិភ័យនឹងបញ្ជាក់ថាតើមានការផ្គត់ផ្គង់ទឹកគ្រប់គ្រាន់សម្រាប់ពន្លត់អគ្គិភ័យតាមប្រព័ន្ធ ទឹកមេនៅក្នុងក្រុងដែរឬទេ។ ប្រសិនបើករណីនេះគ្មានបញ្ហាទេ នោះទឹកពន្លត់អគ្គិភ័យទាំងអស់នឹងត្រូវផ្តល់ជូនតាមរយៈធុងទឹកនៅក្នុងបរិវេណ។ គួរកត់សម្គាល់ទៅលើចំណុះនៃអាងស្តុកទឹកនេះដើម្បីអាចឱ្យអ្នកវាយតម្លៃរាយការណ៍នៅពេលក្រោយអំពីការផ្គត់ផ្គង់ដោយធៀបនឹងតម្រូវការ។ ម៉ូទ័របូមទឹកសម្រាប់អគ្គិភ័យគួរមានទីតាំងស្ថិតនៅក្នុងបន្ទប់ដាច់ដោយឡែក ដែលសាងសង់ឡើងពីសំណង់មិនមានចំហោះ។ បន្ទប់គួរតែងាយស្រួលចេញចូលសម្រាប់ក្រុមពន្លត់អគ្គិភ័យចូលពីខាងក្រៅតាមច្រកដើរ និងជណ្តើរដែលបានមានការការពារ។

ម៉ូទ័របូមទឹកសម្រាប់អគ្គិភ័យមានសារៈសំខាន់ណាស់ដើម្បីឱ្យឧបករណ៍បាញ់ទឹក និងប្រព័ន្ធទុយោបាញ់ពន្លត់អគ្គិភ័យដំណើរការបានត្រឹមត្រូវ ហេតុដូច្នេះ ត្រូវធានាថាប្រព័ន្ធទាំងនោះដំណើរការបានត្រឹមត្រូវនៅក្នុងពេលមានតម្រូវការបន្ទាន់។ កិច្ចការនេះអាចសម្រេចបានដូចខាងក្រោម៖

- ម៉ាស៊ីនបូមទឹកពីរដែលមានចំណុះស្មើគ្នាគឺត្រូវតែមានបំពាក់ ដែលម៉ូទ័រនីមួយៗមានសមត្ថភាពក្នុងការផ្តល់លំហូរទឹកដែលត្រូវការចាំបាច់ និងសម្ពាធដែលតម្រូវដោយប្រព័ន្ធការពារអគ្គិភ័យបានដោយខ្លួនឯង។ ម៉ាស៊ីនបូមទឹកទាំងពីរនេះដំណើរការតាមការរៀបចំ "ដំណើរការ និងបម្រុង" ធ្វើដូច្នេះទើបប្រសិនបើម៉ូទ័រមួយមិនដំណើរការ ម៉ាស៊ីនបូមទឹកមួយទៀតនឹងដំណើរការជំនួស។
- ជាទូទៅ ម៉ាស៊ីនបូមទឹកត្រូវតែដំណើរការដោយអគ្គិសនី។
- ម៉ាស៊ីនបូមទឹកបម្រុងក៏អាចជាម៉ូទ័រអគ្គិសនីផងដែរ ប៉ុន្តែត្រូវតែផ្គត់ផ្គង់ថាមពលពីប្រភពផ្គត់ផ្គង់ថាមពលអាសន្នពីម៉ាស៊ីនភ្លើងអាសន្ន។ ម្យ៉ាងវិញទៀត ម៉ាស៊ីនបូមទឹកដើរដោយម៉ាស៊ីនម៉ាស៊ូតអាចនឹងត្រូវបានបំពាក់ជាម៉ាស៊ីនបូមទឹកបម្រុង។

ម៉ាស៊ីនម៉ាស៊ូតតម្រូវឱ្យមានខ្យល់ចេញចូលច្រើន ដែលត្រូវធ្វើការពិចារណា ក៏ដូចជាប្រព័ន្ធផ្គត់ផ្គង់ឥន្ធនៈផងដែរ។

គួរកត់សម្គាល់អំពីប្រភេទឈុតម៉ាស៊ីនបូមទឹកសម្រាប់ផ្គត់ផ្គង់ទុយោទឹកបាញ់ពន្លត់អគ្គិភ័យនូវទឹកពន្លត់អគ្គិភ័យពីអាងស្តុកទឹក ជាពិសេសកត់ត្រាអំពីប្រភេទ និងស្ថានភាពនៃម៉ាស៊ីនបូមទឹកមេ និងម៉ាស៊ីនបូមទឹកបម្រុង។

គួរកត់ត្រាថាតើម៉ាស៊ីនបូមទឹកបើកដំណើរការដោយស្វ័យប្រវត្តិតាមឧបករណ៍ផ្តល់សញ្ញាអគ្គិភ័យ ឬដោយដៃ។

5.3.5.1 ប្រព័ន្ធពន្លត់អគ្គិភ័យ

អ្នកវាយតម្លៃអគ្គិភ័យគួរកត់ត្រាអំពីប្រភេទ ទីតាំង និងស្ថានភាពនៃទុយោទឹកបាញ់ពន្លត់អគ្គិភ័យដែលបំពាក់ទាំងនៅខាងក្នុង និងខាងក្រៅអគារ។ ទុយោទាំងនេះគួរតែបំពាក់នៅទីតាំងដែលស្ថិតនៅក្បែរច្រកចេញពេលមានអាសន្ន ក៏ដូចជានៅខាងក្នុងអគារដើម្បីអាចគ្របដណ្តប់បានពេញលេញនៅទូទាំងអគារដែលមានទុយោប្រវែងសមស្រប។

បំពង់ពន្លត់អគ្គិភ័យដែលបានបំពាក់ គួរតែសមស្របចំពោះហានិភ័យជាក់លាក់ដែលបានរកឃើញនៅក្នុងរោងចក្រ។ ហានិភ័យគឺត្រូវបានចាត់ជាក្រុមទៅក្នុងកម្រិតផ្សេងៗគ្នាដោយផ្អែកលើប្រភេទវត្ថុធាតុដែលទំនងជាអាចនឹងឆេះ។ ហានិភ័យទាំងនេះគឺត្រូវបានរៀបរាប់នៅក្នុង តារាង 1 ខាងក្រោម។

តារាង 1 សេចក្តីពណ៌នាអំពីប្រភេទខុសៗគ្នានៃកម្រិតអគ្គិភ័យ

កម្រិតនៃ	**បរិយាយ**
កម្រិត A	អគ្គិភ័យកម្រិត A គឺជាអគ្គិភ័យនៅក្នុងវត្ថុធាតុចំហេះធម្មតា ដូចជាឈើ ក្រណាត់ ក្រដាស កៅស៊ូ និងប្លាស្ទិកជាច្រើន។
កម្រិត B	អគ្គិភ័យកម្រិត B គឺជាអគ្គិភ័យនៅក្នុងអង្គធាតុរាវងាយឆាបឆេះ អង្គធាតុរាវចំហេះ ខ្លាញ់គោឥន្ធនៈ កៅស៊ូ ប្រេង ថ្នាំលាបមានជាតិប្រេង អង្គធាតុរំលាយ ថ្នាំលាបឈើ អាល់កុល និងឧស្ម័នងាយឆាបឆេះ។
កម្រិត C	អគ្គិភ័យកម្រិត C គឺជាអគ្គិភ័យដែលរួមបញ្ចូលបរិក្ខារមានថាមពលអគ្គិសនី។
កម្រិត D	អគ្គិភ័យកម្រិត D គឺជាអគ្គិភ័យនៅក្នុងលោហៈចំហេះដូចជា ម៉ាញ៉េស្យូម ទីតាញ៉ូម សៀកូនីញ៉ូម សូដ្យូម លីចូម និងប៉ូតាស្យូម។
កម្រិត K (ហៅថា កម្រិត	អគ្គិភ័យកម្រិត K គឺជាអគ្គិភ័យនៅក្នុងសម្ភារបរិក្ខារចម្អិនអាហារដែលរួមមានសារធាតុចម្អិនអាហារដៃឡបង្កចំហេះ (ប្រេងបន្លែ ឬខ្លាញ់សត្វ)។

ប្រភេទបំពង់ពន្លត់អគ្គិភ័យទូទៅបំផុត និងពណ៌សម្គាល់មានបង្ហាញនៅក្នុងរូបភាពខាងក្រោម – បំពង់ពន្លត់អគ្គិភ័យនីមួយៗសម្រាប់ពន្លត់អគ្គិភ័យកម្រិតផ្សេងៗគ្នា។ កំណត់សម្គាល់៖ ការប្រើបំពង់ពន្លត់អគ្គិភ័យដើម្បីពន្លត់អគ្គិភ័យដែលពាក់ព័ន្ធនឹងចំហាយគឺមិនមានសុវត្ថិភាពនោះទេ។

សារធាតុនៃបំពង់ពន្លត់អគ្គិភ័យគឺត្រូវបានបង្ហាញដោយពណ៌ឆ្លុតនៅលើតួបំពង់ពណ៌ក្រហម។

រូបភាព 15 ប្រភេទបំពង់ពន្លត់អគ្គិភ័យសំខាន់ៗ និងពណ៌សម្គាល់

គួរកត់ត្រាពីប្រភេទ និងការចែកចាយបំពង់ពន្លត់អគ្គិភ័យចល័ត និងកត់ត្រាអំពីភាពគ្រប់គ្រាន់នៃប្រភេទបំពង់ពន្លត់អគ្គិភ័យសម្រាប់ការប្រើប្រាស់នៅតាមបរិវេណទីតាំងនីមួយៗ។
ប្រសិនបើមានប្រព័ន្ធពន្លត់អគ្គិភ័យស្វ័យប្រវត្តិបំពាក់នៅក្នុងអគារ អ្នកវាយតម្លៃអគ្គិភ័យនឹងកត់ត្រាអំពីប្រភេទ និងការគ្របដណ្តប់នៃប្រព័ន្ធពន្លត់អគ្គិភ័យនីមួយៗ។ ជាទូទៅ ប្រព័ន្ធនេះជាប្រព័ន្ធឧបករណ៍បាញ់ទឹកស្វ័យប្រវត្តិ ឬជាប្រព័ន្ធបាញ់ "គ្រាប់បែក" ម្សៅស្វ័យប្រវត្តិ។
ការវាយតម្លៃអគ្គិភ័យគួរកត់ត្រាអំពីស្ថានភាព និងការគ្របដណ្តប់នៃប្រព័ន្ធទុយោបាញ់ពន្លត់អគ្គិភ័យ និងការតភ្ជាប់នៃប្រព័ន្ធទាំងនោះទៅកាន់ម៉ូទ័របូមទឹកសម្រាប់អគ្គិភ័យ។
ការកើនឡើងនៃផ្សែង និងកម្តៅដោយសារតែអគ្គិភ័យ អាចរារាំងយ៉ាងខ្លាំងដល់សមត្ថភាពរបស់ក្រុមពន្លត់អគ្គិភ័យក្នុងការអនុវត្តប្រតិបត្តិការសង្គ្រោះ និងពន្លត់អគ្គិភ័យនៅក្នុងអគារ។
ផលិតផលចំហោះពីអគ្គិភ័យនៅជាន់ក្រោមដីអាចហុយចេញតាមផ្លូវជណ្តើរ ដែលធ្វើឱ្យបុគ្គលិកពន្លត់អគ្គិភ័យពិបាកចូលទៅក្នុងអគារ។ ការផ្តល់ច្រកចេញសម្រាប់ផ្សែងអាចកាត់បន្ថយបញ្ហានេះបាន។ ប្រព័ន្ធខ្យល់ចេញចូលអាចបង្កើនលទ្ធភាពមើលឃើញ និងសីតុណ្ហភាព ដែលធ្វើឱ្យការស្វែងរក ការសង្គ្រោះ និងការពន្លត់អគ្គិភ័យកាន់តែមានប្រសិទ្ធភាព។
ប្រព័ន្ធស្រូបផ្សែងអាចនឹងមានបំពាក់ដើម្បីជំនួយដល់ការពន្លត់អគ្គិភ័យ និងប្រសិនបើនេះគឺជាចំណុចចាប់អារម្មណ៍ អ្នកវាយតម្លៃអគ្គិភ័យគួរតែកត់ត្រាអំពីចំណុចនេះ។

5.3.5.2 ច្រកចេញចូលសម្រាប់រថយន្តសង្គ្រោះបន្ទាន់

ស្ថានភាពនៅក្នុងមូលដ្ឋាន និងហេដ្ឋារចនាសម្ព័ន្ធ ជាទូទៅកំណត់លក្ខខណ្ឌតម្រូវសម្រាប់ច្រកចេញចូលដោយសារតែច្រកចេញចូលទាំងនេះ គឺអាស្រ័យលើប្រភេទយានយន្តដែលរបស់ក្រុមពន្លត់អគ្គិភ័យក្នុងមូលដ្ឋាន។ លក្ខខណ្ឌតម្រូវទាំងនេះរួមមាន៖

- ទំហំយានយន្តសង្គ្រោះបន្ទាន់
- រង្វង់សម្រាប់បត់
- លក្ខខណ្ឌតម្រូវក្បាលម៉ាស៊ីនទឹកខាងក្រៅ

អ្នកវាយតម្លៃអគ្គិភ័យក៏ធ្វើការកត់ត្រាពីផ្លូវថ្នល់ ដែលបានផ្តល់ជូននៅជុំវិញបរិវេណអគារដើម្បីអាចធ្វើការវាយតម្លៃថាតើច្រកចេញចូលសម្រាប់រថយន្តពន្លត់អគ្គិភ័យគ្រប់គ្រាន់ដើម្បីអនុញ្ញាតឱ្យក្រុមពន្លត់អគ្គិភ័យអាចចូលបានកាន់តែកៀកនឹងអគារសម្រាប់ធ្វើការពន្លត់អគ្គិភ័យដោយប្រសិទ្ធភាពដែរឬទេ។

អ្នកវាយតម្លៃអគ្គិភ័យគួរតែត្រួតពិនិត្យមើលផ្លូវថ្នល់ខាងក្នុងបរិវេណរោងចក្រ និងកត់ត្រាអំពីកម្រិតបរិវេណច្រកចេញចូលដែលផ្តល់ជូនសម្រាប់រថយន្តពន្លត់អគ្គិភ័យ និងរថយន្តសង្គ្រោះបន្ទាន់ផ្សេងៗ។

5.3.6 តំហែទាំ និងការថែរក្សារោងចក្រ

5.3.6.1 ឯកសារផ្លូវច្បាប់

គួរកត់ត្រាថាតើរោងចក្រមានអាជ្ញាបណ្ណអគ្គិភ័យដែរឬទេ ទោះបីជាអាជ្ញាបណ្ណនេះមិនមែនធ្លុះបញ្ចាំងអំពីស្ថានភាពអង្កេតនៃអគារក៏ដោយ។

ក្នុងដែនយុត្តាធិការភាគច្រើន រោងចក្រត្រូវមានរបាយការណ៍អធិការកិច្ចនគរបាលអគ្គិភ័យ ដែលមានបច្ចុប្បន្នភាព ដែលបង្ហាញពីការណែនាំរបស់អាជ្ញាធរមូលដ្ឋានឱ្យធ្វើការកែលម្អទៅលើប្រព័ន្ធសុវត្ថិភាពអគ្គិភ័យប្រសិនបើចាំបាច់។

5.3.6.2 តំហែទាំ

លក្ខណៈល្អប្រសើរបំផុតសម្រាប់អ្នកវាយតម្លៃអគ្គិភ័យក្នុងការវិនិច្ឆ័យទៅលើសមត្ថភាពរបស់ប្រព័ន្ធសុវត្ថិភាពអគ្គិភ័យដែលបានអង្កេតក្នុងអំឡុងពេលវាយតម្លៃ គឺការស្នើសុំមើលកំណត់ត្រាថែទាំ និងធ្វើតេស្តឧបករណ៍ផ្តល់សញ្ញាអគ្គិភ័យ និងប្រព័ន្ធភ្លើងបំភ្លឺពេលមានអាសន្ន និងការធ្វើតេស្តម៉ូទ័របូមទឹកសម្រាប់អគ្គិភ័យ និងលំហូរតាមទុយោទឹកបាញ់ពន្លត់អគ្គិភ័យ។

អ្នកវាយតម្លៃអគ្គិភ័យនឹងស្នើសុំពិនិត្យមើលកំណត់ត្រាទាំងនេះ និងធ្វើការកត់ត្រាកាលបរិច្ឆេទ និង

ភាពទៀងទាត់នៃការអនុវត្តការងារតំហែទាំទាំងនេះ។
ប្រព័ន្ធពន្លត់អគ្គិភ័យស្វ័យប្រវត្តិនានាក៏តែមានកំណត់ត្រាថែទាំ ដែលបានអនុវត្តដោយភាគីទីបី ហើយអ្នកវាយតម្លៃអគ្គិភ័យគួរតែកត់ត្រាអំពីកំណត់ត្រាទាំងនេះ។

5.3.6.3 ផែនការគ្រោះអាសន្ន

គួរតែមានការចាត់តាំងប្រធានផ្នែកសុវត្ថិភាពអគ្គិភ័យមួយរូបឱ្យទទួលខុសត្រូវបង្កើតផែនការជម្លៀសខ្លួនពេលមានអគ្គិភ័យ។ ផែនការជម្លៀសខ្លួន ក៏ត្រូវមានបញ្ញត្តិដើម្បីជំនួយដល់បុគ្គលដែលមានពិការភាពដែរ។
ផែនទីជម្លៀសខ្លួនពេលមានអគ្គិភ័យ ត្រូវតែបិទនៅតាជណ្តើរច្រកចេញនីមួយៗ និងគួរតែបង្ហាញឱ្យបានច្បាស់អំពី៖

- នីតិវិធីហៅទៅកាន់សេវាអគ្គិភ័យ និងសង្គ្រោះបានត្រឹមត្រូវ
- ច្រកចេញអាសន្ន
- ផ្លូវជម្លៀសខ្លួនចម្បង និងបន្ទាប់បន្សំ
- ទីតាំងបំពង់ពន្លត់អគ្គិភ័យ
- ទីតាំងស្ថានីយបើកកណ្តឹងរោទ៍អគ្គិភ័យ
- ចំណុចប្រមូលផ្តុំ
- ប្រើប្រាស់ជណ្តើរក្នុងករណីមានអគ្គិភ័យ និងមិនមែនប្រើប្រាស់ជណ្តើរយោងនោះទេ។

រោងចក្រគួរតែចេះបង្កើតផែនការអាសន្នដើម្បីឱ្យអ្នកវាយតម្លៃអគ្គិភ័យត្រួតពិនិត្យ និងកត់ត្រាអំពីការបណ្តុះបណ្តាលដែលផ្តល់ជូនដល់អ្នកនៅក្នុងអគារ និងភារកិច្ចសង្គ្រោះបន្ទាន់ដែលបានចាត់តាំងទៅឱ្យបុគ្គលិកដែលបានជ្រើសរើស។ ភារកិច្ចទាំងនេះគួរតែអាចធានាថា ប្រព័ន្ធទាំងអស់ដែលពឹងផ្អែកលើការបើកដំណើរការដោយដៃ ត្រូវរ៉ាបរងដោយបុគ្គលិកដែលបានកំណត់រកនៅក្នុងផែនការអាសន្ន។
កំណត់ត្រាអំពីការហាត់សមពេលមានអគ្គិភ័យទៀតទាត់ក៏អាចនឹងត្រូវបានស្នើសុំផងដែរ ដើម្បីកំណត់អំពីថាតើអ្នកនៅក្នុងអគារត្រៀមរៀបចំបានល្អកម្រិតណានៅក្នុងករណីមានគ្រោះអាសន្នកើតឡើង។

5.3.6.4 ការថែរក្សារោងចក្រ

ការថែរក្សារោងចក្របានល្អ គឺជាធាតុផ្សំដ៏សំខាន់មួយនៅក្នុងការគ្រប់គ្រងសុវត្ថិភាពអគ្គិភ័យ។ កិច្ចការនេះអាចកាត់បន្ថយលទ្ធភាពនៃការឆាបឆេះ កាត់បន្ថយអត្រាដែលភ្លើងអាចឆេះរាលដាល់

កាន់តែធំ និងធានាថាមុខងារការពារអគ្គិភ័យនៅក្នុងអគារគឺដំណើរការតាមបំណងនៅក្នុងករណីមានអគ្គិភ័យកើតឡើង។

ការថែរក្សារោងចក្រមានទិដ្ឋភាពចម្បងៗចំនួនពីរ ដែលមាន៖

- កាត់បន្ថយលទ្ធភាពបង្កអគ្គិភ័យ ឬការបង្កឱ្យឆាបឆេះ និង
- ការពារផ្លូវជម្លៀសខ្លួន។

ការត្រួតពិនិត្យសុវត្ថិភាពទៀងទាត់ និងវិធានការដោះស្រាយពាក់ព័ន្ធប្រសិនបើមាន គួរតែធានាថាមានវិធានការការពារអគ្គិភ័យគ្រប់ពេលទាំងអស់។

គួរចាត់វិធានការដើម្បីគ្រប់គ្រងហានិភ័យអគ្គិភ័យដែលបង្កដោយវត្តមានរបស់វត្ថុធាតុចំហេះ រួមទាំង វិធានការជាច្រើនតាមការសមស្របដូចខាងក្រោម៖

- កាត់បន្ថយបន្ទុកអគ្គិភ័យ ឧទាហរណ៍តាមរយៈការកាត់បន្ថយបរិមាណស្តុកដែលរក្សាទុកនៅក្នុងអគារ។
- កែសម្រួលរបៀបរក្សាទុកទំនិញ។ ស្តើងនឹងឆេះខ្លាំងឡើងៗយ៉ាងរហ័សចំពោះទំនិញដែលរក្សាទុកតាមទិសបញ្ឈរ ដូចជាកេសឈើដែលដាក់គរលើគ្នា ឬនៅក្នុងឃ្លាំងខ្ពស់ៗ ជាងទំនិញដែលរក្សាទុកលើផ្ទៃដេកច្រលនជាង ដូចជារក្សាទុកនៅលើកម្រាលឥដ្ឋនៃឃ្លាំងជាដើម។
- រក្សាទំនិញ និងគ្រឿងសង្ហារិមតែក្នុងលក្ខណៈសមស្របប៉ុណ្ណោះ ឧទាហរណ៍នៅក្នុងបន្ទប់ដាក់ឥវ៉ាន់ដាច់ដោយឡែក។
- ធានាថាគ្របសារធាតុងាយឆាបឆេះបំផុត គឺត្រូវបានប្រើប្រាស់ និងរក្សាទុកយ៉ាងមានប្រសិទ្ធភាព និងប្រសិនបើចាំបាច់រក្សាទុកនៅក្នុងធុងឱ្យបានសមស្រប។
- គ្រប់គ្រងបរិមាន និងការរក្សាទុកសំរាម ដោយរក្សាទុកនៅក្នុងទីតាំងសុវត្ថិភាពឆ្ងាយពីអគារ នៅក្នុងបរិវេណដាច់ដោយឡែក។
- យករបស់របរឈប់ប្រើប្រាស់ចេញឱ្យអស់ ដូចជាខ្សែទំនាក់ទំនង ជាពិសេសនៅក្នុងប្រហោងអគារ ដោយសារតែខ្សែទាំងនេះអាចបង្កើតឱ្យមានបន្ទុកអគ្គិភ័យកម្រិតខ្ពស់។
- ថែទាំ ឬរក្សាគ្រឿងម៉ាស៊ីន និងបរិក្ខារឱ្យបានគ្រប់គ្រាន់ ដូច្នេះទើកការបង្គរនៃធូលី និងខ្លាញ់នៅក្នុងបរិក្ខារមិននាំឱ្យមានចំហេះនោះទេ។
- ដើម្បីធានាថា ផ្លូវជម្លៀសខ្លួនគឺមានសម្រាប់ប្រើប្រាស់គ្រប់ពេលវេលា ដាច់ខាតត្រូវតែសម្រេចបាននូវចំណុចខាងក្រោម៖
- គ្រប់ច្រកជម្លៀសខ្លួនគ្មានឧបសគ្គទាំងអស់ រួមទាំងបរិវេណជម្រក ត្រូវតែស្រឡះ និងមិនមានអ្វីរារាំងគ្រប់ពេលវេលា
- ទំនិញ វត្ថុធាតុ គ្រឿងសង្ហារិមមិនបានប្រើប្រាស់ ជាដើម មិនគួររក្សាទុកនៅក្នុងផ្លូវជម្លៀសខ្លួនឡើយ។ របស់របរវារាំងផ្លូវនានាត្រូវតែយកចេញជាបន្ទាន់

- ទ្វារការពារអគ្គិភ័យដែលត្រូវបិទជិតជានិច្ច គួរតែបិទជិត និងមិនមានអ្វីមកបាំងឡើយ
- ទ្វារការពារអគ្គិភ័យដែលមានបំពាក់ឧបករណ៍បើករង់ចាំ គួរតែអាចបើកបាន និងមិនមានអ្វីមកបាំងឡើយ
- ផ្នែកខាងក្រៅអគារគួរតែត្រួតពិនិត្យដើម្បីធានាថាច្រកចេញចុងក្រោយ និងផ្លូវទៅកាន់ចំណុចប្រមូលផ្តុំគឺមិនមានអ្វីបាំង។

អ្នកវាយតម្លៃអគ្គិភ័យ រកត់ត្រានូវកម្រិតនៃការថែរក្សារោងចក្រនៅពេញបរិវេណទាំងមូលក្នុងអំឡុងពេលវាយតម្លៃ។ ចំណុចដែលត្រូវកត់ត្រាជាពិសេសគឺ សណ្តាប់ធ្នាប់ និងរបៀបរៀបរយទូទៅនៅក្នុងរោងចក្រ ស្ថានភាពនៃផ្លូវជម្លៀសខ្លួន និងថាតើមានរបស់រារាំងនៅបាំងផ្លូវធ្វើដំណើរ និង/ឬ ផ្លូវជណ្តើរដែរឬទេ។
វត្ថុធាតុចំហេះ កម្ទេចក្រណាត់ និងក្រណាត់ ដែលរក្សាទុកជិត ឬជាប់ទៅនឹងប្រភពកម្តៅគឺជាចំណុចមួយទៀតដែលគួរកត់ត្រាផងដែរ។

5.3.7 សំណួរដែលត្រូវឆ្លើយមុនពេលចាកចេញពីរោងចក្រ

បញ្ជីសំណួរខាងក្រោមនេះ គឺសម្រាប់អ្នកវាយតម្លៃសុវត្ថិភាពអគ្គិភ័យគួរប្រើសម្រាប់សួរខ្លួនឯងមុនពេលចាកចេញពីបរិវេណរោងចក្រ ដោយធ្វើការត្រួតពិនិត្យបន្ថែមថាព័ត៌មានដែលបានកត់ត្រាដោយប្រើប្រាស់បញ្ជីត្រួតពិនិត្យបានផ្តល់ការយល់ដឹងគ្រប់គ្រាន់អំពីបញ្ហាសុវត្ថិភាពអគ្គិភ័យពាក់ព័ន្ធ នឹងអគាររោងចក្រហើយឬនៅ៖

1. តើមានចំនួនផ្លូវជម្លៀសខ្លួនគ្រប់គ្រាន់ដែរឬទេ ហើយតើផ្លូវទាំងនេះបន្តជាប់គ្នារហូត ហើយមានការការពារគ្រប់គ្រាន់ពីគ្រប់បរិវេណតាមជាន់ទៅកាន់ច្រកចេញនៅខាងក្រៅដែរឬទេ?
2. តើមានផ្លូវជណ្តើរដែលនាំទៅក្នុងអគារវិញនៅជាន់ចាកចេញពីអគារដែរឬទេ ប្រសិនបើមានតើផ្លូវទាំងនោះចាកចេញទៅកាន់បរិវេណត្រង់កន្លែងណាដែរ?
3. ស្ថានភាពអំពីបរិវេណអគារ – តើមនុស្សអាចធ្វើដំណើរចេញឆ្ងាយពីអគារដែរឬទេ នៅពេលដែលពួកគាត់ចាកចេញនៅជាន់ផ្ទាល់ដី?
4. តើបរិវេណដែលមានហានិភ័យខ្ពស់ទាំងត្រូវបានកំណត់រកឬនៅ ហើយតើបានកត់ត្រាអំពីប្រភេទនៃរបាំងការងារ ឬកង្វះរបាំងការងារឬនៅ?
5. តើច្រកចំហតាមទិសបញ្ឈរទាំងអស់នៅចន្លោះជាន់ត្រូវបានកំណត់រកឬនៅ ហើយបានកត់ត្រាអំពីប្រសិទ្ធភាពនៃការបិទច្រកទាំងនោះដែរឬទេ?
6. តើទ្វារនានានៅតាមផ្លូវជម្លៀសខ្លួនងាយស្រួលបើកតាមទិសដៅធ្វើដំណើរ និងមានឧបករណ៍ដែលអាចចាក់សោរបានដែរឬទេ?

7. តើស្ថានភាពរបស់រោងចក្រមានលក្ខណៈបែបណាពាក់ព័ន្ធនឹងឃ្លាំងបណ្តោះអាសន្ន និងសណ្តាប់ធ្នាប់ទូទៅ តើមានរបស់របរបាំងផ្លូវច្រកចេញនៅក្នុងច្រកដើរ ច្រកជណ្តើរ-ល- ដែរឬទេ?
8. ផ្អែកលើការត្រួតពិនិត្យកំណត់ត្រាថែទាំប្រព័ន្ធ តើតំហែទាំ និងការថែទាំដែលបានបង្ហាញដោយគណៈគ្រប់គ្រងរបស់រោងចក្រស្ថិតនៅកម្រិតណា?
9. តើនីតិវិធីអ្វីសម្រាប់ការហៅក្រុមពន្លត់អគ្គិភ័យពីរោងចក្រ តើនីតិវិធីនេះស្ថិយប្រវត្តិដែរឬទេ? តើអ្នកបានឃើញផែនការជម្លៀសខ្លួនពេលមានអាសន្នដែរឬទេ និងតើមានកំណត់ត្រាអំពីការហាត់សមដែលបានអនុវត្តសម្រាប់ការបណ្តុះបណ្តាលបុគ្គលិកដែរឬទេ?

លើសពីនេះទៅទៀត ព័ត៌មានខាងក្រោមតម្រូវជាចាំបាច់ដើម្បីបំពេញរបាយការណ៍វាយតម្លៃ ហើយប្រមូលសម្រាប់ជាឯកសារយោងសម្រាប់រៀបចំរបាយការណ៍៖

- គំនូសព្រាងស្តាបត្យកម្មដែលបង្ហាញអំពីស្ថានភាព និងការប្រើប្រាស់ជាក់ស្តែងនៃអគាររោងចក្រ និងអគារខាងក្រៅ
- ចំនួនមនុស្សសម្រាប់គ្រប់ផ្នែកទាំងអស់នៃអគារ

5.4 ការធ្វើតេស្តប្រព័ន្ធសុវត្ថិភាពអគ្គិភ័យ

អ្នកវាយតម្លៃសុវត្ថិភាពអគ្គិភ័យនឹងមិនធ្វើតេស្តប្រព័ន្ធជាផ្នែកនៃនីតិវិធីវាយតម្លៃនោះទេ ដោយហេតុថា ការធ្វើតេស្តមុខងារដំណើរការរបស់ប្រព័ន្ធសុវត្ថិភាពអគ្គិភ័យ នឹងអនុវត្តអ្នកវាយតម្លៃអគ្គិសនី ហើយអ្នកវាយតម្លៃសុវត្ថិភាពអគ្គិភ័យគួរសម្រួលជាមួយនឹងអ្នកវាយតម្លៃអគ្គិសនីដើម្បីធានាថាមានប្រព័ន្ធទាំងនៅពេលធ្វើតេស្តដូចខាងក្រោម៖

- ការបើកដំណើរការឧបករណ៍ផ្តល់សញ្ញាអគ្គិភ័យតាមរយៈការបើកដំណើរការឧបករណ៍ចាប់សញ្ញា ឬតាមរយៈការចុចប៊ូតុងដោយដៃ
- ការបើកដំណើរការនៃប្រព័ន្ធភ្លើងបំភ្លឺពេលមានអាសន្នតាមរយៈការកាត់ផ្តាច់ប្រភពផ្គត់ផ្គង់ថាមពលមេ
- ការបង្ហាញសាកល្បងអំពីមុខងារដំណើរការនៃឈុតម៉ូទ័របូមទឹកសម្រាប់អគ្គិភ័យ និងនីតិវិធីបើកដំណើរការ។ របាយការណ៍វាយតម្លៃអគ្គិសនីនឹងធ្វើការអង្កេតទៅលើលទ្ធផលនៃការធ្វើតេស្តទាំងនេះ។

6 វិធីសាស្ត្រវាយតម្លៃអគ្គិសនី

6.1 ចំណុចទូទៅ

សេចក្តីសង្ខេបអំពីប្រព័ន្ធអគ្គិសនីអគារ ដែលត្រូវរៀបចំជាផ្នែកមួយនៅក្នុងរបាយការណ៍វាយតម្លៃ ទាមទារឱ្យមានការបំពេញទិន្នន័យសំខាន់ៗ ដែលអ្នកវាយតម្លៃអគ្គិសនីយល់ដឹងអំពីទិន្នន័យទាំងនេះនៅមុនពេលចាប់ផ្តើមការងារវាយតម្លៃនេះ។ អ្នកវាយតម្លៃគួរបង្កើតលេខ និងទីតាំងនៃបរិក្ខារអគ្គិសនីសំខាន់ៗ (អនុស្ថានីយ ម៉ាស៊ីនភ្លើង ទូអគ្គិសនី)។ ផ្លូវដែលមានលក្ខណៈយុទ្ធសាស្ត្រគួររៀបចំជាផែនការដើម្បីដើរមើលនៅតាមមូលដ្ឋានរោងចក្រ។ ចំពោះមូលដ្ឋានភាគច្រើន ផែនការនេះជួយឱ្យយើងអាចចាប់ផ្តើមពីកន្លែងភ្ជាប់ថាមពលប្រើប្រាស់ និងដើរតាមថាមពលទៅក្នុង និងជុំវិញអគារ។

6.2 ការវាយតម្លៃអគារ

នៅពេលអនុវត្តការវាយតម្លៃសុវត្ថិភាពអគ្គិសនីរបស់អគារ ជាការសំខាន់ណាស់ដែលត្រូវយល់អំពីប្រព័ន្ធដែលស្ថិតនៅក្នុងអគារ ឧទាហរណ៍ តើថាមពលប្រើប្រាស់ចូលទៅក្នុងបរិវេណរោងចក្រដូចម្តេច តើម៉ាស៊ីនភ្លើងមានទីតាំងនៅឯណា និងតើម៉ាស៊ីនភ្លើងទាំងនោះមានមុខងារអ្វីខ្លះ។
ប្រសិនបើមាន ឯកសារគួរតែសម្របជាមួយចំណុចដែលគណៈគ្រប់គ្រងរោងចក្របានណែនាំនៅក្នុងអំឡុងពេលសម្ភាសន៍គណៈគ្រប់គ្រងរោងចក្រ។
បុគ្គលិករោងចក្រដែលមានគុណវុឌ្ឍិសមស្រប ត្រូវអនុវត្តការងារអគ្គិសនីទាំងអស់ ការបើក ឬការបិទផ្ទាំងទូអគ្គិសនី ឬបរិក្ខារអគ្គិសនី។
អ្នកវាយតម្លៃ នឹង៖

- ត្រួតពិនិត្យដោយផ្ទាល់តែទៅលើការដំឡើងបរិក្ខារអគ្គិសនី។
- មិនយកចេញ ឬផ្លាស់ប្តូរគម្រប ឬបើក ឬបិទទូដាក់បរិក្ខារអគ្គិសនីឡើយ។
- មិនវាស់ស្ទង់បន្ទុកអគ្គិសនីនៃបរិក្ខារឡើយ។
- មិនប៉ះពាល់បរិក្ខារដែលបានត្រួតពិនិត្យ និងរក្សាចម្ងាយសុវត្ថិភាពពីបរិក្ខារទាំងនោះ។
- អនុលោមតាមការអនុវត្ត និងវិធានសុវត្ថិភាពរបស់អ្នកប្រើប្រាស់ និងបទដ្ឋានសុវត្ថិភាពជាតិពាក់ព័ន្ធ។

6.3 សុវត្ថិភាពអគ្គិសនីនៅក្នុងអនុស្ថានីយ និងបន្ទប់បញ្ជា

នៅពេលចូលទៅក្នុងបរិវេណដែលមានផ្ទុកបរិក្ខារចែកចាយអគ្គិសនី វិស្វករត្រួតពិនិត្យត្រូវពិនិត្យរកមើលស្ថានភាពខុសប្រក្រតី។ បុគ្គលដែលអនុញ្ញាតឱ្យចូលទៅក្នុងអនុស្ថានីយ ឬបន្ទប់អគ្គិសនី ត្រូវមានការយល់ដឹងអំពីអ្វីដែលត្រូវស្វែងរក។ ប្រសិនបើសង្ស័យថាមានគ្រោះថ្នាក់ ការវាយតម្លៃនៅក្នុងបរិវេណនោះគួរតែផ្អាកសិន ហើយគួរតែធ្វើការស៊ើបអង្កេតដោយបុគ្គលដែលមានចំណេះដឹងនិងបទពិសោធន៍ដែលអាចមានសមត្ថភាពដាក់ចេញនូវវិធានការកែតម្រូវនៅពេលរកឃើញមូល

ហេតុ។
ស្លាកសញ្ញាព្រមានអំពីភាពមិនប្រក្រតី រួមមានជាអាទិ៍៖

- សីតុណ្ហភាពកើនឡើងខ្ពស់នៅក្នុងអគារ
- វត្តមាននៃផ្សែង
- ក្លិនសារធាតុ "ក្តៅ" (ប្រេង សារធាតុផ្សំជាដើម)
- ការបញ្ចេញសំឡេង ឬផ្កាភ្លើង
- ក្លិនស៊ុយរលួយ
- ក្លិនស្អុយខ្លាំង (អាចជាសញ្ញានៃការបញ្ចេញ SF6)
- សញ្ញានៃប្រេងធ្លាយនៅក្នុងបរិវេណជុំវិញបរិក្ខារដែលចាក់ប្រេង
- សញ្ញានៃការលេចធ្លាយសារធាតុផ្សំថ្មីៗ និង
- ការខូចទ្រង់ទ្រាយ ឬភ័ស្តុតាងនៃផេះនៅលើរបាំងការពារ។

នេះមិនមែនជាបញ្ជីលម្អិតគ្រប់ជ្រុងជ្រោយនោះទេ ហើយវិស្វករត្រូវប្រាកដថាខ្លួនបានអនុលោមតាមលក្ខខណ្ឌតម្រូវសុខភាព និងសុវត្ថិភាពរបស់អង្គភាព និងលក្ខខណ្ឌតម្រូវសុខភាព និងសុវត្ថិភាពថ្នាក់ជាតិ/មូលដ្ឋានបានត្រឹមត្រូវ។

6.4 អនុស្ថានីយ

តាមរយៈការប្រើប្រាស់បញ្ជីត្រួតពិនិត្យនៅក្នុងឧបសម្ព័ន្ធ ច ជាមគ្គុទេសក៍ អ្នកវាយតម្លៃគួរកត់ត្រានូវទិន្នន័យដើម្បីរាយការណ៍អំពីបញ្ហាដូចខាងក្រោម៖

- តើមានការកំណត់រក និងការបិទស្លាកសញ្ញានៅអនុស្ថានីយបានគ្រប់គ្រាន់ដែរឬទេ?
- តើមានការបង្ហាញអំពីការព្រមាន និងការជូនដំណឹងអំពីគ្រោះថ្នាក់គ្រប់គ្រាន់ដែរឬទេនៅក្នុងអនុស្ថានីយ?
- តើប្រភពផ្គត់ផ្គង់ថាមពលមេគ្រប់គ្រាន់សម្រាប់លក្ខខណ្ឌតម្រូវថាមពលរបស់អគារដែរឬទេ?
- តើអនុស្ថានីយស្ថិតក្នុងទីតាំងសមស្របដែរឬទេ?
- តើមានបំពាក់ឧបករណ៍ខ្យល់ចេញចូលក្នុងបន្ទប់ត្រង់ស្វូរដែរឬទេ?
- តើមានបំពាក់តម្រងប្រេងរបស់ត្រង់ស្វូរ និងមានទំហំត្រឹមត្រូវដែរឬទេ?
- តើមានសញ្ញាបង្ហាញការចូលទឹកដែរឬទេ?
- បន្ទប់ស្អាត មានរបៀបរៀបរយ និងមិនបានប្រើប្រាស់ជាបរិវេណស្តុកឥវ៉ាន់
- ថាមពល (អំពូលបំភ្លឺ ព្រីភ្លើង) ដំណើរការ
- ទ្វារ និងបង្អួចមានសុវត្ថិភាព ហើយនៅពេលចាំបាច់ ត្រូវចាក់សោរ
- មិនមានសញ្ញាអំពីការខូចខាតចំពោះបរិក្ខារ ឬបន្ទប់
- បន្ទប់មិនមានរុក្ខជាតិដុះស្អេកស្កះ ហើយច្រកចេញចូលគឺអាចទទួលយកបាន
- តើមានសញ្ញានៃសកម្មភាពកណ្តុរដែរឬទេ?
- ប្រព័ន្ធខ្យល់ចេញចូល (ប្រព័ន្ធខ្យល់ចេញចូលត្រូវតែរចនាឡើងដោយអនុលោមតាមសេចក្តីណែនាំរបស់រោងចក្រផលិតបរិក្ខារ)

- ស្លាកសញ្ញា និងឧបករណ៍សង្គ្រោះបឋមពេលមានអាសន្ន
- តម្រងប្រេងសម្រាប់ត្រង់ស្វូរមិនមានប្រេងលើសពី 2000 លីត្រឡើយ។

6.5 ការស្ទង់កម្តៅ

ការស្ទង់កម្តៅគួរតែធ្វើឡើងដោយបុគ្គលិកមានគុណវុឌ្ឍិ និងទទួលបានការបណ្តុះបណ្តាល ដែលមានចំណេះដឹងអំពីបច្ចេកវិទ្យាអាំងហ្វ្រា និងការថែទាំបរិក្ខារអគ្គិសនី និងដែលមានចំណេះដឹងអំពីបញ្ហាសុវត្ថិភាពពាក់ព័ន្ធនានា។

បរិក្ខារខាងក្រោម ត្រូវតែដាក់បញ្ចូល និងកត់ត្រានៅក្នុងការស្ទង់៖

- ត្រង់ស្វូរ
- ទូអគ្គិសនីទាំងអស់នៅក្នុងរោងចក្រ

ចំពោះបរិក្ខារនីមួយៗដែលបានរៀបរាប់ខាងលើ ចាំបាច់ត្រូវធ្វើការស្ទង់នូវបរិក្ខារដូចតទៅ៖

- តំណាខ្សែភ្លើងទាំងអស់
- តភ្ជាប់ខ្សែឧបករណ៍ការពារសៀគ្វីទាំងអស់
- ឧបករណ៍ការពារ
- បរិក្ខារបន្ទាប់បន្សំនៅក្នុងទូអគ្គិសនី ឧទាហរណ៍ កុងតាក់ទ័រជាដើម។

ការធ្វើតេស្តគួរតែអនុវត្តក្នុងអំឡុងពេលដែលទូចែកចាយកំពុងតែមានបន្ទុក។ ឧបករណ៍ ឧបករណ៍ការពារការឆ្លងចរន្ត ត្រូវដំឡើងនៅក្នុងទូអគ្គិសនីមួយចំនួន ឬទាំងអស់។ នៅក្នុងបញ្ជីត្រួតពិនិត្យមុនវាយតម្លៃ រោងចក្រត្រូវបានស្នើសុំឱ្យរៀបចំឱ្យដកឧបករណ៍ការពារការឆ្លងចរន្តចេញរយៈពេលមួយថ្ងៃនៃការវាយតម្លៃ។

ចំពោះសំណង់មានស្រាប់ ការត្រួតពិនិត្យស្ថានភាពកម្តៅ (thermographic) នៃបរិក្ខារអគ្គិសនី ត្រូវតែធ្វើឡើងមួយឆ្នាំបីដង។ ការស្ទង់នេះត្រូវតែប្រើប្រាស់ដើម្បីគូសបញ្ជាក់អំពីការឡើងកម្តៅហួសប្រមាណដែលអាចកើតមានចំពោះសមាសធាតុនានា។

(1) ប្រសិនបើសីតុណ្ហភាពកើនឡើងហួសពី 60°C ករណីនេះត្រូវធ្វើការស៊ើបអង្កេតបន្ថែមទៀត។
(2) ប្រសិនបើសីតុណ្ហភាពកើនឡើងហួសពី 70°C វិធានការភ្លាមៗត្រូវតែអនុវត្ត ដើម្បីបញ្ចុះសីតុណ្ហភាព។

6.6 ម៉ាស៊ីនភ្លើង

ក្នុងករណីប្រើប្រាស់ម៉ាស៊ីនភ្លើងផ្គត់ផ្គង់ថាមពលទៅកាន់ប្រព័ន្ធសុវត្ថិភាពអាយុជីវិត អមជាមួយថាមពលធម្មតា ចាំបាច់ត្រូវត្រួតពិនិត្យចំណុចដូចខាងក្រោម៖

- សមត្ថភាពផ្គត់ផ្គង់ថាមពលរបស់ម៉ាស៊ីនភ្លើងទៅកាន់ឧបករណ៍សុវត្ថិភាពអាយុជីវិតនៅក្នុងអំឡុងពេលដាច់ចរន្ត និង
- ស្ថានភាពរបស់ម៉ាស៊ីនភ្លើង និងហានិភ័យនៃការបញ្ឆេះ ឬបង្កឱ្យមានអគ្គិភ័យ
- សីតុណ្ហភាពជុំវិញ ត្រូវចាត់ទុកថាជាសីតុណ្ហភាពខ្យល់នៅជុំវិញបរិក្ខារដែលកំពុងត្រួតពិនិត្យ។ ក្នុងករណីដែលម៉ាស៊ីនភ្លើងមិនផ្គត់ផ្គង់ថាមពលដល់ឧបករណ៍សុវត្ថិភាពអាយុជីវិត ត្រូវពិនិត្យ

ចំណុចដូចខាងក្រោម៖

- ស្ថានភាពរបស់ម៉ាស៊ីនភ្លើង និងហានិភ័យនៃការបញ្ឆេះ ឬរួមចំណែកដល់អគ្គិភ័យ។ ប្រព័ន្ធខ្យល់ចេញចូលត្រឹមត្រូវនៃបន្ទប់ម៉ាស៊ីនភ្លើងគឺចាំបាច់ណាស់ក្នុងការគាំទ្រដល់ដំណើរការបញ្ឆេះម៉ាស៊ីន បន្ថយកម្តៅដែលផលិតឡើងក្នុងអំឡុងពេលប្រតិបត្តិការ (កម្តៅម៉ាស៊ីន កម្តៅ
- អាល់ទែណាទ័រ ជាដើម) ព្រមទាំងបំបាត់ក្លិន និងផ្សែង។
- តាមរយៈការប្រើប្រាស់បញ្ជីត្រួតពិនិត្យសម្រាប់ជាមគ្គុទេសក៍ អ្នកវាយតម្លៃគួរតែកត់ត្រានូវទិន្នន័យដើម្បីរាយការណ៍អំពីបញ្ហាដូចខាងក្រោម៖
- ពិនិត្យមើលថាប្រភេទម៉ាស៊ីនភ្លើងគឺបានបញ្ជាក់ច្បាស់លាស់នៅក្នុងឯកសារ និងនៅលើបរិក្ខារ
- ពិនិត្យមើលថាសមត្ថភាពម៉ាស៊ីនភ្លើងដូចគ្នាទៅនឹងសមត្ថភាពដែលបានបញ្ជាក់នៅក្នុងតារាងថាមពល
- ការចែកចាយអគ្គិសនី ការចាក់សោរសុវត្ថិភាព ខ្សែម៉ាសដី និងបណ្តាញមូលដ្ឋានត្រូវបានធ្វើឡើងដែរឬទេ?
- ពិនិត្យមើលថាលក្ខខណ្ឌតម្រូវបេនឥន្ធនៈគឺគ្រប់គ្រាន់សម្រាប់ការប្រើប្រាស់ដែរឬទេ
- ពិនិត្យមើលការតភ្ជាប់ខ្សែម៉ាសដីពីគ្រោងម៉ាស៊ីនភ្លើង
- ពិនិត្យបេនឥន្ធនៈរកមើលការលេចធ្លាយ
- ប្រសិនបើការបញ្ជូនឥន្ធនៈម៉ាស៊ីនភ្លើងពឹងផ្អែកលើម៉ាស៊ីនបូមឥន្ធនៈ: សូមពិនិត្យថាតើថាមពលទៅកាន់ម៉ាស៊ីនបូមនោះត្រូវបានបម្រុងទុកដែរឬទេ
- ពិនិត្យមើលថាអាគុយម៉ាស៊ីនភ្លើងបានតាមដានត្រួតពិនិត្យដែរឬទេ (ការតាមដានត្រួតពិនិត្យនេះអាចធ្វើឡើងដោយដៃ ឬដោយស្វ័យប្រវត្តិ)
- ពិនិត្យរកមើលសារធាតុរាវដែលលេចចេញពីម៉ាស៊ីនភ្លើង ធុង និងទុយោ
- ពិនិត្យរកមើលសញ្ញានៃប្រព័ន្ធខ្យល់ចេញចូលថាគ្រប់គ្រាន់ដែរឬទេ
- ពិនិត្យមើលថាច្រកខ្យល់ចូលគួរតែស្ថិតនៅឆ្ងាយពីប្រភពកម្តៅតាមជាក់ស្តែង និងឱ្យមានកម្រិតទាបតាមដែលអាចធ្វើបាន។
- ពិនិត្យមើលថាច្រកខ្យល់ចូល និងច្រកខ្យល់ចេញគួរតែកំណត់ទីតាំងដើម្បីការពារខ្យល់ចេញពីបំពង់ស៊ីមុាំងត្រូវបានស្រូបចូលទៅក្នុងច្រកខ្យល់ចូល (ចរន្តខ្យល់ចេញចូល)។

6.7 ការផ្គត់ផ្គង់ឧបករណ៍សុវត្ថិភាពអាយុជីវិត

ប្រភពសុវត្ថិភាពអាយុជីវិត គឺជាប្រភពថាមពលសម្រាប់ឧបករណ៍សុវត្ថិភាពអាយុជីវិត។ ឧបករណ៍សុវត្ថិភាពអាយុជីវិតរួមមាន៖

- អំពូលបំភ្លឺពេលមានអាសន្ន (ជម្លៀសខ្លួន)
- ឧបករណ៍ចាប់សញ្ញាអគ្គិភ័យ និងឧបករណ៍ផ្តល់សញ្ញាអគ្គិភ័យ
- ម៉ូទ័របូមទឹកសម្រាប់អគ្គិភ័យ1 (ម៉ាស៊ីនបូមទឹកនៃឧបករណ៍បាញ់ទឹក ដុំទុយោ (ø25 mm)
- ជណ្តើរយោងសង្គ្រោះពេលមានអគ្គិភ័យ
- ប្រព័ន្ធជម្លៀសខ្លួន

- ប្រព័ន្ធស្រូបផ្សែងចេញ
- ប្រព័ន្ធសុវត្ថិភាពឧស្សាហកម្ម
- ប្រព័ន្ធទំនាក់ទំនងពេលមានអគ្គិភ័យ
- ឧបករណ៍ចាប់សញ្ញា CO និងផ្តល់ដំណឹង

បញ្ហានេះមិនមែនជាបញ្ហាលម្អិតនោះទេ និងត្រូវធ្វើការពិចារណាទៅលើប្រព័ន្ធផ្សេងៗទៀត ព្រមទាំងឥទ្ធិពលនៃប្រព័ន្ធទាំងនោះទៅលើសុវត្ថិភាពរបស់អ្នកនៅក្នុងអគារ។ (សូមមើលបទដ្ឋាន LABS សម្រាប់ព័ត៌មានបន្ថែម)។

ប្រភពសុវត្ថិភាពត្រូវបានកំណត់និយមន័យជា៖

- អាគុយផ្ទុកភ្លើង
- អាគុយចម្បង
- បណ្តុំម៉ាស៊ីនភ្លើងដែលឯករាជ្យពីការផ្គត់ផ្គង់ថាមពលធម្មតា។

ជាទូទៅ អាគុយនឹងប្រើប្រាស់ដោយប្រព័ន្ធតូចៗភាគច្រើន (ជាទូទៅ ប្រព័ន្ធចាប់សញ្ញាអគ្គិភ័យ និងទូអគ្គិសនីផ្តល់សញ្ញា និងភ្លើងបំភ្លឺពេលមានអាសន្ន)។ ផ្នែកនេះជាទូទៅលើកឡើងអំពីប្រព័ន្ធដែលប្រើប្រាស់អាគុយជាប្រភពសុវត្ថិភាពអាយុជីវិត (បម្រុង)។

ចាំបាច់ត្រូវត្រួតពិនិត្យបរិក្ខារខាងក្រោម៖

- ប្រព័ន្ធខ្សល់ចេញចូលអាគុយ
- ដំណើរការសាកអាគុយ
- កណ្តឹងរោទ៍ផ្តល់សញ្ញាអាគុយមិនដំណើរការ ឧទាហរណ៍ ប្រសិនបើអាគុយត្រូវបានផ្តាច់ពីទូអគ្គិសនី តើទូអគ្គិសនីនោះបង្ហាញអំពីកំហុស និងបន្តប្រតិបត្តិការដែរឬទេ

ក្នុងអំឡុងពេលវាយតម្លៃ ការធ្វើតេស្តគួរតែរួមមាន ការបិទថាមពលមេ (ចម្បង) ទៅកាន់ប្រព័ន្ធចាប់សញ្ញាអគ្គិភ័យ និងទូអគ្គិសនីផ្តល់សញ្ញា និងភ្លើងបំភ្លឺពេលមានអាសន្នដើម្បីបញ្ជាក់ពីដំណើរការរបស់ប្រព័ន្ធទាំងនោះ។

ការធ្វើតេស្តមុខងារដំណើរការរបស់ម៉ាស៊ីនភ្លើង មិនចាំបាច់ត្រូវតែអនុវត្តជាផ្នែកមួយនៃការវាយតម្លៃឡើយ។ ប៉ុន្តែប្រសិនបើការធ្វើតេស្តនេះមានប្រយោជន៍ ហើយគណៈគ្រប់គ្រងរោងចក្រឯកភាព អាចធ្វើតេស្តម៉ាស៊ីនភ្លើងបាន។

ប្រសិនបើម៉ាស៊ីនភ្លើងផ្គត់ផ្គង់ប្រព័ន្ធសុវត្ថិភាពអាយុជីវិត ម៉ាស៊ីនភ្លើងទាំងត្រូវតែធ្វើតេស្ត។

6.8 ខ្សែម៉ាសដី និងការតភ្ជាប់

ការដំឡើងទាំងមូល ត្រូវតែតម៉ាសដី និងតភ្ជាប់ឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាព ដោយមានខ្សែម៉ាសដីការពារ និងការតភ្ជាប់បរិក្ខារចម្បង និងបរិក្ខារបន្ទាប់បន្សំពេញទាំងអស់។

- ពីគំនូសដែលបានកែសម្រួល សូមកំណត់អំពីប្រភេទប្រព័ន្ធខ្សែម៉ាសដីដែលបានដំឡើង។

ក្នុងអំឡុងពេលពិនិត្យមើលឯកសារកែសម្រួល ត្រូវធ្វើការពិនិត្យមើលខ្សែចម្លងការពារធៀបនឹងតារាង A54.7 ពី IEC 60364-5-54។ ត្រូវអនុវត្តការត្រួតពិនិត្យសំណាក 10% នៃសៀគ្វីទាំងអស់។

ផ្នែកមុខកាត់នៃខ្សែចម្លង S	ផ្នែកមុខកាត់អប្បបរមានៃខ្សែចម្លងការពារពាក់ព័ន្ធ	
	ប្រសិនបើខ្សែចម្លងការពារមានវត្ថុធាតុដើមដូចគ្នាទៅនឹងខ្សែចម្លង	ប្រសិនបើខ្សែចម្លងការពារមិនមានវត្ថុធាតុដើមដូចគ្នាទៅនឹងខ្សែចម្លង
(mm^2)	(mm^2)	(mm^2)
S<=16	S	(k1/k2) x S
16<S<=35	16	(k1/k2) x 16
S>35	S/2	(k1/k2) x (S/2)

IEC 60364-5-54 តារាង A54.7

ផ្នែកមុខកាត់អប្បបរមានៃខ្សែចម្លងម៉ាសដីទង់ដែងធៀបទៅនឹងផ្នែកខ្សែចម្លងហ្វាពាក់ព័ន្ធ

6.9 ការការពារការលេចធ្លាយម៉ាស

វត្តមាន អត្រា និងប្រភេទនៃការការពារការលេចធ្លាយចរន្តម៉ាសត្រូវតែត្រួតពិនិត្យមើលនៅតាមទូអគ្គិសនីនីមួយៗ។ ដោយរោងចក្រត្រូវធ្វើការកត់ត្រា និងចាត់វិធានការនៅក្នុងករណីដែលការលេចធ្លាយម៉ាសនេះមិនបំពេញតាមបទដ្ឋាន LABS ទេនោះ។

ពិនិត្យដើម្បីបញ្ជាក់ថានៅគ្រប់បរិក្ខារទាំងអស់នៃទូចែកចាយពិតជាបានដំឡើងខ្សែម៉ាស និងបានតភ្ជាប់ត្រឹមត្រូវទៅកាន់សៀគ្វីនីមួយៗ។

បញ្ជាក់ការតភ្ជាប់នៅចំណុចនីមួយៗខាងក្រោម៖

- ថាមពលវិស្វកម្មមេ (ទុយោហ្គាស និងទឹក បំពង់ HVAC ធុង ផ្នែកដែកគ្រឿងបង្គុំ-ល-) គឺត្រូវបានតភ្ជាប់ទៅនឹងប៉ូលដីមេ។
- ធុងទាំងអស់ត្រូវតែតភ្ជាប់ដោយប្រើប្រាស់ខ្សែម៉ាសដីអប្បបរមា 16mm^2 ។
- ឡាបូលោហៈ អាងទឹក-ល- (រួមទាំងទុយោ) ត្រូវតែតភ្ជាប់ទៅកាន់ប៉ូលម៉ាសដីនៃព្រីភ្លើង 13A ដែលនៅជិតបំផុតដោយប្រើប្រាស់ខ្សែម៉ាសដីអប្បបរមា 2.5mm^2 ។
- ឡាបូលោហៈ អាងទឹក-ល- (រួមទាំងទុយោ) ត្រូវតែតភ្ជាប់ទៅកាន់ប៉ូលម៉ាសដីនៃព្រីភ្លើង 13A ដែលនៅជិតបំផុតដោយប្រើប្រាស់ខ្សែម៉ាសដីអប្បបរមា 2.5mm^2 ។
- ខ្សែចម្លងតភ្ជាប់ និងឧបករណ៍ភ្ជាប់ត្រូវតែដំឡើងធ្វើយ៉ាងណាឱ្យអាចមើលឃើញច្បាស់ និងមិនត្រូវគ្របដោយអ៊ីសូឡង់ ឬក៏កំបាំងនោះទេ

ការធ្វើតេស្តមុខងារដំណើរការនៃប្រព័ន្ធម៉ាសដី មិនចាំបាច់ត្រូវបង្កើតជាផ្នែកមួយនៃការវាយតម្លៃឡើយ។

6.10 ឌីសង់ទ័រ

ការធ្វើតេស្តមុខងារដំណើរការនៃឌីសង់ទ័រមិនត្រូវបង្កើតជាផ្នែកមួយនៃការវាយតម្លៃឡើយ។ ភស្តុតាង អំពីការថែទាំ និងការធ្វើតេស្តទៀងទាត់ត្រូវតែស្វែងរកក្នុងអំឡុងពេលជួបប្រជុំជាមួយគណៈគ្រប់គ្រងរោងចក្រ។

6.11 គុណភាពបរិក្ខារ

អ្នកវាយតម្លៃពិនិត្យរកមើលឧបករណ៍ដែលមិនអនុលោមតាមបទដ្ឋានផលិតផលដែលបានទទួលស្គាល់។ ការប្រើប្រាស់ឧបករណ៍បរិក្ខារនេះ អាចបង្កឱ្យមានការខូចខាតធ្ងន់ធ្ងរ អគ្គិភ័យ ឬអាចបណ្តាលឱ្យបាត់បង់អាយុជីវិតទៀតផង។

6.12 ខ្សែចម្លង

ក្នុងអំឡុងពេលវាយតម្លៃផ្ទាល់ ចាំបាច់ត្រូវត្រួតពិនិត្យចំណុចដូចខាងក្រោម៖

- ពិនិត្យមើលថាខ្សែភ្លើងគឺត្រូវបានទ្របានត្រឹមត្រូវ
- ពិនិត្យមើលថាខ្សែភ្លើងបានរៀបចំស្របតាមការរចនាដែរឬទេ?
- សមត្ថភាពចម្លងចរន្តរបស់ខ្សែភ្លើង គឺសមស្របសម្រាប់ការប្រើប្រាស់ដែរឬទេ?
- តើមានការកំណត់រក និងការបិទស្លាកសញ្ញានៅបន្ទះចែកចាយទាំងអស់បានគ្រប់គ្រាន់ដែរឬទេ?
- តើមានការកំណត់រក និងការបិទស្លាកសញ្ញាលើសៀគ្វីទាំងអស់នៅក្នុងបន្ទះចែកចាយបានគ្រប់គ្រាន់ដែរឬទេ?
- តើមានការបង្ហាញអំពីការព្រមាន និងការជូនដំណឹងអំពីគ្រោះថ្នាក់គ្រប់គ្រាន់ដែរឬទេនៅក្នុងបន្ទះចែកចាយ?
- តើការការពារប្រព័ន្ធខ្សែភ្លើងប្រឆាំងទៅនឹងមូលហេតុនៃការខូចខាត និងការខូចទ្រង់ទ្រាយផ្សេងៗ ឧទាហរណ៍កម្តៅ ទឹក ជាដើម មានលក្ខណៈគ្រប់គ្រាន់ដែរឬទេ?
- តើមានខ្សែភ្លើង ឬខ្សែចម្លងស្រាត ដោយសារតែការខូចខាត ការច្រែះ បាត់គម្រប-ល- ដែរឬទេ?
- តើមានរបាំង ឬរបាំងការពារគ្រប់គ្រាន់ក្នុងការការពារពីការប៉ះផ្ទាល់ដែរឬទេ? តើរបាំង ឬរបាំងការពារទាំងនោះប៉ះទង្គិចដែរឬទេ ឧទាហរណ៍ដោយសារតែការខូចខាត?
- ពិនិត្យរកមើលធូលីដី និងកម្ទេចក្រណាត់នៅក្នុងទូអគ្គិសនីអគ្គិសនី
- ពិនិត្យរកមើលធូលីដី និងកម្ទេចក្រណាត់នៅខ្សែភ្លើង
- តើមានការទុយោទន់ខូចខាតដែរឬទេ?
- ពិនិត្យរកវត្ថុធាតុងាយឆាបឆេះនៅក្នុងទូអគ្គិសនីអគ្គិសនី
- តើខ្សែភ្លើងត្រូវបានបែងចែកដាច់ពីគ្នានៅក្នុងត្រែខ្សែភ្លើងដែរឬទេ?
- តុល្យភាពបន្ទុកនៅក្រោមស្ថានភាពធម្មតាត្រូវបានផ្តល់ជូនដែរឬទេ?
- តុល្យភាពបន្ទុកនៅក្រោមស្ថានភាពអាសន្នត្រូវបានផ្តល់ជូនដែរឬទេ?

- ខ្សែចម្លងត្រូវតែកឹបក្បាល ឬមានព្រីខ្សែភ្លើង
- ខ្សែចម្លងត្រូវតែកឹបក្បាល ឬមានព្រីខ្សែភ្លើង

នៅក្នុងការត្រួតពិនិត្យដ្យាក្រាមបន្ទាត់ទោល (SLD) ការត្រួតពិនិត្យសំណាកនៃទំហំខ្សែចម្លងធៀបនឹងឧបករណ៍ការពារ ត្រូវតែអនុវត្តដើម្បីអាចផ្តល់ការបង្ហាញបានថាតើខ្សែភ្លើងដែលមិនបានការពារដែរឬទេ។
ការធ្វើតេស្តមុខងារដំណើរការនៃខ្សែចម្លងមិនត្រូវបង្កើតជាផ្នែកមួយនៃការវាយតម្លៃឡើយ។

6.13 ប្រព័ន្ធការពារផ្លេះ

ការដំឡើងប្រព័ន្ធការពារផ្លេះ (LPS) ត្រូវធ្វើការពិភាក្សា និងហើយកំណត់ត្រាអំពីការធ្វើតេស្តប្រចាំឆ្នាំ ត្រូវតែពិនិត្យមើលក្នុងកិច្ចប្រជុំគណៈគ្រប់គ្រងរោងចក្រ។
ប្រសិនបើបានដំឡើង ធាតុផ្សំខាងក្រោមត្រូវតែត្រួតពិនិត្យ៖

- បណ្តាញចាប់រន្ទះ (air termination network) នៅជាន់ដំបូល។ ជាទូទៅ បណ្តាញនេះបំពាក់នៅនឹងដំបូលដោយមានលោហៈគ្របពីលើអគារខ្សែចម្លងទ្រុងហ្វារ៉ាដាយ ដែលប្រើស្តុតសំណាញ់ និង/ឬ ដងខ្យល់បញ្ឈរ (vertical air rods)។
- តើការតភ្ជាប់ពីបណ្តាញចាប់រន្ទះនៅលើដំបូលតទៅកាន់ខ្សែចម្លងបញ្ចុះថាមពល (down conductors) ដាច់ដោយឡែកដែរឬទេ? ឬ
- តើខ្សែចម្លងបញ្ចុះថាមពល (down conductors) មាននូវសសរដែកគ្រឿងបង្គុំ ឬដែកថែបនៅខាងក្នុងសសរទ្រគ្រោងអគារ និង/ឬខ្សែចម្លងបញ្ចុះថាមពលដាច់ដោយឡែកដែរឬទេ?
- ការតភ្ជាប់ខ្សែចម្លងបញ្ចុះថាមពល (down conductors) ដាច់ដោយឡែកទៅកាន់ប្រអប់អេឡិចត្រូតម៉ាសដី ដែលនៅជាប់គ្នាជាកន្លែងដែលដងម៉ាសដីនឹងត្រូវបុកចូលទៅក្នុងដី។ ខ្សែចម្លងបញ្ចុះថាមពលនីមួយៗត្រូវតែមានប៉ូលម៉ាសដីដាច់ដោយឡែកពីគ្នា។
- ពិនិត្យមើលថាតើមានចំណុចធ្វើតេស្តដែរឬទេ។
- តើមានការតភ្ជាប់នៃលោហៈខាងក្រៅដូចជា ដែកគ្រោងអគារ ទរលោហៈ ទុយោបង្ហូរចុះក្រោមជាដើម និងរោងចក្រមេកានិចភ្ជាប់លើដំបូលនានា បំពង់ផ្សែងបរិក្ខារកម្តៅ AHUs ត្រែខ្សែភ្លើងរបាំងការពារ ស្លាបព្រិល ទុយោខ្យល់ចេញចូល ដែរឬទេ?
- តើមានការតភ្ជាប់គ្នាតាមរយៈដែកទទឹងធ្វើតេស្តទៅនឹងរបារដែកម៉ាសដីអគ្គិសនីមេរបស់អគារដែរឬទេ?
- តើមានគំនូសព្រាងបង្ហាញពីប្លង់ដំឡើងឧបករណ៍ការពារផ្លេះ និងមានបច្ចុប្បន្នភាពដែរឬទេ?
- ពិនិត្យមើលការបាញ់របស់រន្ទះ និងចំនួនដងនៃការបាញ់ចំ។
- ការធ្វើតេស្តមុខងារដំណើរការរបស់ប្រព័ន្ធការពារផ្លេះ មិនមែនជាផ្នែកនៃការវាយតម្លៃឡើយ។

6.14 ការផ្លាក់តង់ស្យុង

កម្រិតនៃការផ្លាក់ចុះតង់ស្យុងអតិបរមាដែលអាចទទួលយកបានសម្រាប់ការដំឡើង LV មានរៀបរាប់នៅក្នុងឯកសារ IEC 60364-1។ ជាទូទៅ កម្រិតរបស់វា គឺពិបាកក្នុងការកំណត់រកនៅក្នុង

អំឡុងពេលចុះពិនិត្យវាយតម្លៃណាស់ ហើយមិនគួរផ្តោតលើចំណុចនេះពេករហូតមិនបានត្រួតពិនិត្យសមាសធាតុផ្សេងនោះទេ។ នៅក្នុងអំឡុងពេលប្រជុំជាមួយគណៈគ្រប់គ្រងរោងចក្រ ត្រូវសួរពួកគេថាតើមានពេលណាមួយដែលឧបករណ៍នេះដំណើរការខុសប្រក្រតី ឬមិនដំណើរការដោយសារហេតុផលដោយមិនដឹងមូលហេតុនោះទេ។
ដោយសារតែស្ថានភាពសុវត្ថិភាពរបស់អ្នកកាន់កាប់ គឺពឹងផ្អែកទៅលើសេវាកម្មការពារសុវត្ថិភាពអាយុជីវិតដែលធ្លាប់បានជួបប្រទះបញ្ហាដែលបានពិពណ៌នាខាងលើហើយ ដូច្នេះជាការល្អ ត្រូវកត់ត្រាចំណុចទាំងនេះនៅក្នុងរបាយការណ៍វាយតម្លៃដើម្បីចាត់វិធានការតាមដាន។

6.15 ការធ្វើតេស្តមុខងារប្រព័ន្ធសុវត្ថិភាពអគ្គិភ័យ និងប្រព័ន្ធពន្លត់អគ្គិភ័យ

ការធ្វើតេស្តមុខងារប្រព័ន្ធសុវត្ថិភាពអគ្គិភ័យមួយចំនួននឹងត្រូវបានរៀបចំឡើងដោយអ្នកវាយតម្លៃអគ្គិសនី ហើយអ្នកវាយតម្លៃសុវត្ថិភាពអគ្គិភ័យគួរតែសហការជាមួយអ្នកវាយតម្លៃផ្នែកអគ្គិសនីដើម្បីធានាថាពួកគេមានវត្តមាននៅនឹងកន្លែង ក្នុងពេលធ្វើតេស្តទៅលើចំណុចដូចខាងក្រោម៖

ការធ្វើតេស្ត	**លទ្ធផលរំពឹងទុក**
ការបើកដំណើរការសំឡេងរោទ៍អគ្គិភ័យតាមរយៈការបើកដំណើរការឧបករណ៍រាវរកឬការចុចប៊ូតុងដោយដៃ។	ឧបករណ៍បញ្ចេញសំឡេងរោទ៍មានដំណើរការ។
អំឡុងពេលធ្វើតេស្តថាមពលមេទៅកាន់ផ្នែកនៃលសំឡេងរោទ៍ត្រូវបានបិទ ដូច្នេះបន្ទះនោះដំណើរការថាមពលបម្រុង (អាគុយធម្មតា)	ឧបករណ៍បញ្ចេញសំឡេង នឹងបញ្ចេញសំឡេងពីគ្រប់អគារទាំងអស់ (មុខងារនេះអាចត្រូវបានគេប៉ាន់ស្មានដោយការស្តាប់តាមតំបន់មួយចំនួនដែលបានជ្រើសរើស) សំឡេងរោទ៍នៅតែបន្តដំណើរការលើថាមពលបម្រុង (អាគុយធម្មតា)
ការបើកដំណើរការប្រព័ន្ធភ្លើងគ្រាអាសន្នតាមរយៈការផ្តាច់ការផ្គត់ផ្គង់ថាមពលមេ។	ភ្លើងគ្រាអាសន្នបើកដំណើរការនៅតាមផ្នែកដែលថាមពលមេដាច់។ ភ្លើងនេះនឹងដំណើរការក្នុងរយៈពេលសមស្រប (សូមណែនាំថារយៈពេល 10 នាទីគឺគ្រប់គ្រាន់សម្រាប់ការធ្វើ

	តេស្តនេះ)។[1]
ការបង្ហាញអំពីមុខងារដំណើរការឧបករណ៍បូមទឹកពន្លត់អគ្គិភ័យ។	ម៉ាស៊ីនបូមដំណើរការដោយប្រើប្រាស់ ថាមពលបឋម និងបន្ទាប់បន្សំ។ ម៉ាស៊ីនបូមអាចអាចបូមទឹកបញ្ជូនទៅកាន់ចំណុចតភ្ជាប់ដែលនៅឆ្ងាយបំផុតនៃបណ្តាញទុយោក្នុងសម្ពាធសមស្រប។

6.16 សំណួរដែលត្រូវឆ្លើយមុនពេលចាកចេញពីរោងចក្រ

ខាងក្រោមនេះគឺជាកម្រងសំណួរដែលអ្នកវាយតម្លៃសុវត្ថិភាពអគ្គិសនីគួរតែសួរខ្លួនឯងមុនពេលចាកចេញពីបរិវេណ ដើម្បីធ្វើការពិនិត្យមើលបន្ថែមទៀតថាព័ត៌មានដែលបានកត់ត្រាតាមរយៈការប្រើប្រាស់បញ្ជីត្រួតពិនិត្យនេះ ផ្តល់នូវព័ត៌មានគ្រប់គ្រាន់អំពីបញ្ហាសុវត្ថិភាពអគ្គិសនីទាក់ទងនឹងអគាររោងចក្រ៖

1. តើអ្នកបានពិនិត្យមើលអនុស្ថានីយទាំងអស់ហើយឬនៅ?
2. តើអ្នកបានពិនិត្យមើលម៉ាស៊ីនភ្លើងទាំងអស់ហើយឬនៅ?
3. តើអ្នកបានពិនិត្យមើលខ្សល់ក្នុងបន្ទប់ហើយឬនៅ?
4. តើជានែលអគ្គិសនី និងម៉ាស៊ីនត្រង់ស្វូរទាំងអស់ត្រូវបានពិនិត្យមើលដោយប្រើប្រាស់កាមេរ៉ាវាស់សីតុណ្ហភាពហើយឬនៅ? តើការវាស់វែងនេះត្រូវបានធ្វើឡើងជាមួយនឹងឧបករណ៍អគ្គិសនីកំពុងមានបន្ទុកមែនទេ?
5. តើប្រព័ន្ធការពារសុវត្ថិភាពអាយុជីវិតទាំងអស់មានប្រភពចម្បង និងបន្ទាប់បន្សំដែរឬទេ? តើប្រភពទាំងនេះបានត្រួតពិនិត្យឬនៅ?
6. តើមានប្រព័ន្ធការពារនេះទេ? តើបានត្រួតពិនិត្យហើយឬនៅ?

[1] មិនអនុញ្ញាតឱ្យតេស្តលើសពី 10 នាទី ដោយសារអាគុយអាចនឹងអស់ ហើយត្រូវចំណាយពេលយូរដើម្បីបញ្ចូល ដើម្បីអាចដំណើរការឡើងវិញបាន។

7. ការដាក់កូដពណ៌ទៅតាមប្រភេទហានិភ័យអគារជារួម

7.1 ទិដ្ឋភាពទូទៅ

ផ្នែកខាងក្រោមផ្តល់នូវការណែនាំអំពីវិធីសាស្ត្រសម្រាប់ចាត់ថ្នាក់ហានិភ័យអគារទាំងមូល ឬការកំណត់កូដពណ៌ទៅតាមលទ្ធផលនៃការវាយតម្លៃសុវត្ថិភាពគ្រោងអគារ ប្រព័ន្ធអគ្គិភ័យ និងអគ្គិសនីជាមុន។ លទ្ធផលនេះ គឺជាលទ្ធផលបន្ថែមដ៏មានអត្ថប្រយោជន៍ដែលបានមកពីការវាយតម្លៃសុវត្ថិភាព ពោលគឺជាសេចក្តីសង្ខេបអំពីលទ្ធផលរកឃើញដែលបានរៀបចំឡើងក្នុងលក្ខណៈមួយដែលមានភាពច្បាស់លាស់ និងងាយស្រួលយល់។ លទ្ធផលនេះ នឹងជួយសម្រួលដល់ការកំណត់អាទិភាពសកម្មភាពតាមដាន និងធានាថាបញ្ហាសុវត្ថិភាពធ្ងន់ធ្ងរគឺត្រូវបានរកឃើញយ៉ាងច្បាស់ទាន់ពេលវេលា។ នេះគឺជាវិធីសាស្ត្រដ៏មានគុណភាព សមស្របទៅនឹងលក្ខណៈនៃការវាយតម្លៃហ័សនៃកម្មវិធីវាយតម្លៃសុវត្ថិភាពបឋម ប៉ុន្តែមិនមែនជាវិធីសាស្ត្របែបកំណត់ចំនួនច្បាស់លាស់កម្រិតខ្ពស់នោះទេ។

ការចាត់ថ្នាក់ហានិភ័យនៃការសាងសង់តាមរយៈការកំណត់កូដពណ៌នេះ គឺជាវិធីសាស្ត្រដែលបានបង្កើតឡើងយ៉ាងច្បាស់លាស់សម្រាប់ការវាយតម្លៃអគារដែលមានស្រាប់ ហើយយើងស្នើសុំឱ្យប្រើប្រាស់ការចាត់ថ្នាក់ហានិភ័យនេះនៅទីនេះ។

ឯកសារនេះ ផ្តល់នូវការណែនាំអំពីការចាត់ថ្នាក់កូដពណ៌ទៅតាមហានិភ័យអគារទាំងមូល។ ទោះជាយ៉ាងណាក៏ដោយ វិស្វករ/អ្នកវាយតម្លៃអាចជួបប្រទះនឹងស្ថានភាពបញ្ហាសុវត្ថិភាពមួយដែលគ្រោះថ្នាក់ចំពោះសុវត្ថិភាពអាយុជីវិត ឬបញ្ហាសុវត្ថិភាពច្រើនរួមបញ្ចូលគ្នាដែលធ្វើឱ្យអគារអាចនឹងក្លាយជាប្រភេទអគារដែលមានហានិភ័យខ្ពស់ ទោះបីជាឯកសារណែនាំនេះមិនបានបង្ហាញអំពីចំណុចនេះក៏ដោយ។ ដូច្នេះ ក្នុងករណីនេះ វិស្វករ/អ្នកវាយតម្លៃ ត្រូវប្រើប្រាស់ការវិនិច្ឆ័យរបស់ខ្លួន ដើម្បីកែសម្រួលប្រភេទហានិភ័យឱ្យបានត្រឹមត្រូវ។

មុននឹងពិនិត្យជាស្តាពរលើការចាត់ថ្នាក់ហានិភ័យនៃអគារ វិស្វករ/អ្នកវាយតម្លៃ គួរតែប្រើប្រាស់ការវិនិច្ឆ័យរបស់ខ្លួនដើម្បីវាយតម្លៃថាតើការដាក់ពិន្ទុនេះឆ្លុះបញ្ចាំងអំពីស្ថានភាពសុវត្ថិភាពអាយុជីវិតរបស់អគារឬទេ។ ប្រសិនបើការចាត់ថ្នាក់នេះ បង្ហាញអំពីកម្រិតសុវត្ថិភាពអាយុជីវិតផ្សេងពីនេះស្របតាមអ្វីដែលវិស្វករ/អ្នកវាយតម្លៃយល់ឃើញតាមរយៈការសង្កេតតាមទីតាំងផ្ទាល់ នោះអគារនេះគួរតែត្រូវបានផ្តល់ប្រភេទពណ៌ដែលត្រូវនឹងលក្ខខណ្ឌដែលវិស្វករ/អ្នកវាយតម្លៃយល់ឃើញ។

វិធីសាស្ត្រនេះពឹងផ្អែកទាំងស្រុងលើសមាសភាពចំនួនបីយ៉ាង៖

- ការប្រើប្រាស់វិស្វករដែលមានបទពិសោធន៍សមស្របដូចដែលបានកំណត់ក្នុងផ្នែក 3.1.1 ដែលប្រើប្រាស់ការវិនិច្ឆ័យផ្នែកវិស្វកម្ម ដើម្បីដាក់ចំណាត់ថ្នាក់ហានិភ័យនៃអគារ។
- ការបណ្តុះបណ្តាលក្រុមវិស្វករ/អ្នកវាយតម្លៃ និងការផ្តល់ការណែនាំដល់ពួកគេដើម្បីឱ្យពួកគេធ្វើការសម្រេចចិត្តបាន។

ដំណើរការ QA/QC ហើយធ្វើបច្ចុប្បន្នភាពវិធីសាស្ត្រដោយផ្អែកលើមតិត្រលប់

7.2 រោងចក្រដែលមានអគារច្រើន

ប្រសិនបើរោងចក្រមានអគារសំខាន់ៗលើសពីមួយ នោះអគារទាំងនេះគួរតែត្រូវបានចាត់ថ្នាក់ជាអគារដាច់ដោយឡែកពីគ្នា ដោយប្រើប្រាស់ប្រព័ន្ធដាក់ចំណាត់ថ្នាក់ដែលមានផ្តល់ជូននៅទីនេះ។ ការចាត់ថ្នាក់រោងចក្រទាំងមូល គឺជាការចាត់ថ្នាក់អគារដាច់ដោយឡែកពីគ្នាដ៏សំខាន់បំផុត។ សេចក្តីសង្ខេបប្រតិបត្តិ ក៏ត្រូវបញ្ចូលព័ត៌មានលម្អិតអំពីប្រភេទអគារនីមួយៗផងដែរ។

7.3 ការចាត់ថ្នាក់ហានិភ័យគ្រោងអគារ

ក្ងៀសម្រាប់ការវាយតម្លៃជារួម (អគាររោងចក្រនីមួយៗ ឬអគាររោងចក្រនៅក្នុងបរិវេណរោងចក្រ)		**សកម្មភាពដែលបានកំណត់អត្តសញ្ញាណ**	
ខ្មៅ	**មិនអាចធ្វើការវាយតម្លៃបានពេញលេញ** និង/ឬ ធ្វើសេចក្តីសន្និដ្ឋានសមស្របដោយសារតែមិនអាចចូលបាន ខ្វះការសហការ មិនអាចពិនិត្យមើលគ្រោងនៅជាន់ក្រោម/ផ្ទាល់ដីបានជាដើម	អាទិភាពទី 1	មិនអនុវត្ត
		អាទិភាពទី 2	សំខាន់ (រៀបចំសម្រាប់ការវាស់វែង
		អាទិភាពទី 3	មិនអាចអនុវត្តបាន
ក្រហម	**បិទអគាររោងចក្រភ្លាមៗ** ឬផ្នែកសំខាន់ណាមួយនៅក្នុងរោងចក្រ។ បិទស្របទៅតាមពិធីសារ។ ដោយសារតែកម្រិតគ្រោះថ្នាក់ខ្លាំងពេកនៅក្នុងចំណោមគ្រោង ការបារម្ភអំពីការបាក់ស្រុត និង/ឬ បញ្ហាដែលអាចបង្កឱ្យមានគ្រោះថ្នាក់ភ្លាមៗចំពោះគ្រោងអគារ និងបុគ្គលិក។ យ៉ាងហោចណាស់បញ្ហាអាទិភាព 1 ត្រូវបានរកឃើញ។	អាទិភាពទី 1	សំខាន់ខ្លាំង៖ បិទរោងចក្រភ្លាមៗ
		អាទិភាពទី 2	សំខាន់
		អាទិភាពទី 3	រយៈពេលវែង/ការថែទាំ
ក្រហម/ទឹកក្រូចចាស់	ប្រសិនបើ QSEC យល់ថាមានសារសំខាន់ក្នុងការចាត់វិធានការភ្លាមៗដើម្បីថែទាំតំបន់ពណ៌ទឹកក្រូចចាស់ របាយការណ៍នេះ អាចនឹងត្រូវកំណត់តែសម្រាប់តំបន់ពណ៌ទឹកក្រូចចាស់ដែលមានសកម្មភាពក្រហមប៉ុណ្ណោះ។ សកម្មភាពពណ៌ក្រហម ត្រូវតែធ្វើឡើងនៅក្នុងរយៈពេលពីរសប្តាហ៍ បើមិនដូច្នោះទេ តំបន់រោងចក្រទាំងមូល នឹងក្លាយទៅជាពណ៌ក្រហម។ យ៉ាងហោចណាស់មានចំណុចបញ្ហាអាទិភាពទី 1 ត្រូវបានរកឃើញ។	អាទិភាពទី 1	សំខាន់ខ្លាំង ឧ.ការបិទទីធ្លាខាងក្នុង កាត់បន្ថយបន្ទុក
		អាទិភាពទី 2	សំខាន់
		អាទិភាពទី 3	រយៈពេលវែង/ការថែទាំ
ទឹកក្រូច	**គ្មានមូលហេតុក្នុងការផ្អាកប្រតិបត្តិការនៅក្នុងរោងចក្រ** ប៉ុន្តែសកម្មភាពអាចនឹងត្រូវការជាចាំបាច់។ កម្រិតគ្រោះថ្នាក់សំខាន់ៗ នៅក្នុងផ្នែកគ្រោងពាក់ព័ន្ធនឹងសក្តានុពលសម្រាប់ការបាក់ស្រុត ឬបញ្ហាដែលអាចបង្កឱ្យមានគ្រោះថ្នាក់ភ្លាមៗចំពោះគ្រោងអគារ និងបុគ្គលិក។ ផ្នែកផលិតកម្ម អាចបន្តកិច្ចការស្របទៅតាមកិច្ចព្រមព្រៀងចំពោះការវាយតម្លៃបន្ថែម និងការធ្វើតេ	អាទិភាពទី 1	សំខាន់ខ្លាំង ឧ.ការបិទទីធ្លាខាងក្នុង កាត់បន្ថយបន្ទុក
		អាទិភាពទី 2	សំខាន់
		អាទិភាពទី 3	រយៈពេលវែង/ការថែទាំ

	ស្តសកម្មភាព ដើម្បីដោះស្រាយបញ្ហាដែលបានលើកឡើងនៅក្នុងសកម្មភាពអាទិភាពនៅក្នុងរបាយការណ៍។ យ៉ាងហោចណាស់បញ្ហាអាទិភាពទី 1 ត្រូវបានរកឃើញ។		
ល្បឿង	មានការបារម្ភតិចតួច ប៉ុន្តែមានសំនួរអំពីការរៀបចំគ្រោង និងព័ត៌មានលម្អិត កម្រិតវិការដែលអាចមើលឃើញដែលមិនមានគ្រោះថ្នាក់ភ្លាមៗចំពោះគ្រោង ឬបុគ្គលិក។ ផ្នែកផលិតកម្ម អាចបន្តកិច្ចការស្របទៅតាមកិច្ចព្រមព្រៀងចំពោះការវាយតម្លៃបន្ថែម និងការធ្វើតេស្តសកម្មភាព ដើម្បីដោះស្រាយបញ្ហាដែលបានលើកឡើងនៅក្នុងសកម្មភាពអាទិភាពនៅក្នុងរបាយការណ៍។ យ៉ាងហោចណាស់បញ្ហាអាទិភាពទី 2 ត្រូវបានរកឃើញ។	អាទិភាពទី 1	មិនអនុវត្ត
		អាទិភាពទី 2	សំខាន់
		អាទិភាពទី 3	រយៈពេលវែង/ការថែទាំ
បៃតង	ជាទូទៅ ចំណុចទាំងអស់គឺគ្មានបញ្ហានោះទេ គឺស្របទៅតាមការព្រមព្រៀងដើម្បីដោះស្រាយអំពីមតិយោបល់ដែលបានកំណត់អាទិភាព។ ពុំមានវិការធ្ងន់ធ្ងរនោះទេ ឬបញ្ហាគ្រោង និងគ្មានហានិភ័យផ្ទាល់ចំពោះបុគ្គលិកនោះទេ។ ផ្នែកផលិតកម្មអាចបន្តការងារបាន។ បញ្ហាចំណុចអាទិភាពទី 3 គឺជាកម្រិតខ្ពស់បំផុតដែលបានរកឃើញ។	អាទិភាពទី 1	មិនអនុវត្ត
		អាទិភាពទី 2	មិនអនុវត្ត
		អាទិភាពទី 3	រយៈពេលវែង/ការថែទាំ

7.4 ចំណាត់ថ្នាក់ហានិភ័យអគ្គិភ័យ

ចំណុចអាទិភាពដែលត្រូវសង្កេតមើល និងចាត់វិធានការនីមួយៗនោះ (ចាប់ពី FP-1 ដល់ FP-3) ត្រូវបានប្រើប្រាស់ ដើម្បីកំណត់ចំណាត់ថ្នាក់ហានិភ័យនៃអគារសំខាន់ៗនីមួយៗនៅក្នុងរោងចក្រ។ តាមការណែនាំ "អគារសំខាន់" ត្រូវបានចាត់ទុកថាជាអគារផលិតកម្ម ឃ្លាំងដែលមានទំហំជាង 1,500 ម2 ហើយសម្រាប់អគារផ្សេងទៀត គឺអ្នកវាយតម្លៃជាអ្នកកំណត់អំពីភាពសំខាន់របស់វា។ ចំណាត់ថ្នាក់ហានិភ័យ គឺត្រូវបែងចែកដោយពណ៌ដោយផ្អែកលើចំណុចធាតុអាទិភាព FP-1 ដូចបង្ហាញក្នុងតារាងខាងក្រោម។ បន្ទាប់មក ចំណាត់ថ្នាក់ទាំងនេះត្រូវបានប្រើប្រាស់ ដើម្បីកំណត់ចំណាត់ថ្នាក់ហានិភ័យអគ្គិភ័យដែលសមរម្យសម្រាប់រោងចក្រ។ ពណ៌នៃចំណាត់ថ្នាក់ហានិភ័យដែលបានផ្តល់ឱ្យអគារដែលមានហានិភ័យខ្ពស់បំផុត ក្លាយជាចំណាត់ថ្នាក់ហានិភ័យសម្រាប់អគាររោងចក្រ។

កូដសម្រាប់ការខោយតម្លៃជារួម (អគារពោងចក្រនីមួយៗ ឬអគារពោងចក្រនៅក្នុងបរិវេណពោងចក្រ)		**សកម្មភាពដែលបានកំណត់អត្តសញ្ញាណ**	
ខ្មៅ	**មិនអាចធ្វើការវាយតម្លៃបានពេញលេញ** និង/ឬ ធ្វើសេចក្តីសន្និដ្ឋានសមស្របដោយសារតែមិនអាចចូលបាន ខ្វះការសហការ ជាដើម	អាទិភាពទី 1	មិនអនុវត្ត
		អាទិភាពទី 2	សំខាន់ (រៀបចំសម្រាប់ការវាស់វែង
		អាទិភាពទី 3	មិនអាចអនុវត្តបាន
ក្រហម	**បិទអគារពោងចក្រភ្លាមៗ** ឬផ្នែកសំខាន់ណាមួយនៅក្នុងពោងចក្រទៅតាមការណែនាំ។ បិទស្របទៅតាមពិធីសារ។	អាទិភាពទី 1	>15៖ សំខាន់ខ្លាំង៖ បិទពោងចក្រភ្លាមៗ
		អាទិភាពទី 2	លេខណាមួយ
		អាទិភាពទី 3	លេខណាមួយ
ក្រហម/ទឹកក្រូចចាស់	ប្រសិនបើអ្នកវាយតម្លៃយល់ថាមានសារសំខាន់ក្នុងការចាត់វិធានការភ្លាមៗដើម្បីថែទាំតំបន់ពណ៌ទឹកក្រូចចាស់ របាយការណ៍នេះ អាចនឹងត្រូវកំណត់តែសម្រាប់តំបន់ពណ៌ទឹកក្រូចចាស់ដែលមានសកម្មភាពក្រហមប៉ុណ្ណោះ។ សកម្មភាពពណ៌ក្រហម ដែលត្រូវបានកំណត់ដោយអ្នកវាយតម្លៃនៅក្នុងរបាយការណ៍សង្ខេបត្រូវតែធ្វើឡើងក្នុងរយៈពេលពីរសប្តាហ៍ បើមិនដូច្នោះទេ តំបន់ពោងចក្រទាំងមូល នឹងក្លាយទៅជាពណ៌ក្រហម។	អាទិភាពទី 1	7<n=<15 សំខាន់ខ្លាំង ឧ.ការបិទទីធ្លាខាងក្នុងកាត់បន្ថយបន្ទុក
		អាទិភាពទី 2	លេខណាមួយ-សំខាន់
		អាទិភាពទី 3	លេខណាមួយ- រយៈពេលវែង/ការថែទាំ
ទឹកក្រូច	**គ្មានមូលហេតុក្នុងការផ្អាកប្រតិបត្តិការនៅក្នុងពោងចក្រ** ប៉ុន្តែសកម្មភាពអាចនឹងត្រូវការជាចាំបាច់។ ផ្នែកផលិតកម្ម អាចបន្តកិច្ចការស្របទៅតាមសកម្មភាពភ្លាមៗដែលបានកំណត់ដោយអ្នកវាយតម្លៃនៅក្នុងសេចក្តីសង្ខេបប្រតិបត្តិនៃរបាយការណ៍ដែលត្រូវធ្វើឡើងនៅក្នុងរយៈពេលពីរសប្តាហ៍។	អាទិភាពទី 1	0<n=<7 សំខាន់ខ្លាំង ឧ.ការបិទទីធ្លាខាងក្នុងកាត់បន្ថយបន្ទុក សំខាន់ខ្លាំង ឧ.ការបិទទីធ្លាខាងក្នុង កាត់បន្ថយបន្ទុក
		អាទិភាពទី 2	លេខណាមួយ-សំខាន់
		អាទិភាពទី 3	លេខណាមួយ- រយៈពេលវែង/ការថែទាំ
លឿង	មានការបារម្ភតិចតួច ប៉ុន្តែមានសំនួរអំពីការរៀបចំប្រព័ន្ធអគ្គិភ័យ និងព័ត៌មានលម្អិត។ ផ្នែកផលិតកម្ម អាចបន្តកិច្ចការស្របទៅតាមកិច្ចព្រមព្រៀង ដើម្បីដោះស្រាយបញ្ហាដែលបានលើកឡើងនៅក្នុងសកម្មភាពអាទិភាពនៅក្នុងរបាយការណ៍។	អាទិភាពទី 1	0
		អាទិភាពទី 2	លេខណាមួយ-សំខាន់
		អាទិភាពទី 3	លេខណាមួយ- រយៈពេលវែង/ការថែទាំ
បៃតង	ជាទូទៅ ចំណុចទាំងអស់គឺគ្មានបញ្ហានោះទេ គឺស្របទៅតាមការព្រមព្រៀងដើម្បីដោះស្រាយអំពីមតិយោបល់ដែលបានកំណត់អាទិភាព។ ពុំមានវិការធ្ងន់ធ្ងរនោះទេ និងគ្មានហានិភ័យផ្ទាល់ចំពោះបុគ្គលិកនោះទេ។ ផ្នែកផលិតកម្មអាចបន្តការងារបាន។	អាទិភាពទី 1	0
		អាទិភាពទី 2	0
		អាទិភាពទី 3	លេខណាមួយ- រយៈពេលវែង/ការថែទាំ

គោលបំណងនៃការចាត់ចំណាត់ថ្នាក់ហានិភ័យសុវត្ថិភាពអគ្គិភ័យនេះ គឺដើម្បីតម្រង់ទិសអ្នកវាយតម្លៃក្នុងការចាត់ថ្នាក់ហានិភ័យនៃអគារ។ ប៉ុន្តែដូចដែលបានបញ្ជាក់ពីខាងដើមដែរ វិស្វករ/អ្នកវាយតម្លៃត្រូវប្រើប្រាស់ការវិនិច្ឆ័យរបស់ខ្លួន ដើម្បីវាយតម្លៃថាតើការដាក់ពិន្ទុនេះឆ្លុះបញ្ចាំងពីស្ថានភាពសុវត្ថិភាពអាយុជីវិតរបស់អគារឬទេ។

7.5 ការចាត់ថ្នាក់ហានិភ័យអគ្គិសនី

កូដសម្រាប់ការវាយតម្លៃជារួម (អគាររោងចក្រនីមួយៗ ឬអគាររោងចក្រនៅក្នុងបរិវេណរោងចក្រ)		**សកម្មភាពដែលបានកំណត់អាទិភាព**	
ខ្មៅ	**មិនអាចធ្វើការវាយតម្លៃបានពេញលេញ** និង/ឬ ធ្វើសេចក្តីសន្និដ្ឋានសមស្របដោយសារតែមិនអាចចូលបាន ខ្វះការសហការជាដើម។	អាទិភាពទី 1	មិនអនុវត្ត
		អាទិភាពទី 2	សំខាន់ (រៀបចំសម្រាប់ការវាស់វែង
		អាទិភាពទី 3	មិនអាចអនុវត្តបាន
		អាទិភាពទី 4	មិនអាចអនុវត្តបាន
ក្រហម	**បិទអគាររោងចក្រភ្លាមៗ** ឬផ្នែកសំខាន់ណាមួយនៅក្នុងរោងចក្រទៅតាមការណែនាំ។ បិទស្របទៅតាមពិធីសារ។ ចំណុចអាទិភាពទី 1 ត្រូវបានរកឃើញនៅក្នុងផ្នែកធំៗរបស់អគារ ដូច្នេះចាំបាច់ត្រូវតែអនុវត្តសកម្មភាពនៅគ្រប់អគារទាំងអស់។	អាទិភាពទី 1	សំខាន់ខ្លាំង៖ បិទរោងចក្រភ្លាមៗ
		អាទិភាពទី 2	សំខាន់
		អាទិភាពទី 3	មិនសូវសំខាន់
		អាទិភាពទី 4	រយៈពេលវែង/ការថែទាំ
ក្រហម/ទឹកក្រូចចាស់	ប្រសិនបើអ្នកវាយតម្លៃយល់ថាមានសារសំខាន់ក្នុងការអនុវត្តសកម្មភាពអាទិភាពទី 1 នៅក្នុងទីតាំងតូចចង្អៀត ឬក្នុងអគារ។	អាទិភាពទី 1	សំខាន់ខ្លាំង ឧ.ការបិទទីធ្លាខាងក្នុង កាត់បន្ថយបន្ទុក
		អាទិភាពទី 2	សំខាន់
		អាទិភាពទី 3	មិនសូវសំខាន់
		អាទិភាពទី 4	រយៈពេលវែង/ការថែទាំ
ទឹកក្រូច	**គ្មានមូលហេតុក្នុងការផ្អាកប្រតិបត្តិការនៅក្នុងរោងចក្រ** ប៉ុន្តែសកម្មភាពអាចនឹងត្រូវការជាចាំបាច់។ ចំណុចអាទិភាពទី 2 គឺត្រូវបានរកឃើញថាជាកម្រិតខ្ពស់បំផុត។	អាទិភាពទី 1	មិនអនុវត្ត
		អាទិភាពទី 2	សំខាន់ (រៀបចំសម្រាប់ការវាស់វែង
		អាទិភាពទី 3	មិនអាចអនុវត្តបាន
		អាទិភាពទី 4	មិនអាចអនុវត្តបាន
លឿង	**មានការបារម្ភតិចតួច** ប៉ុន្តែមានសំនួរអំពីការរៀបចំប្រព័ន្ធអគ្គិសនី និងព័ត៌មានលម្អិត។ ចំណុចអាទិភាពទី 3 គឺត្រូវបានរកឃើញថាជាកម្រិតខ្ពស់បំផុត។	អាទិភាពទី 1	មិនអនុវត្ត
		អាទិភាពទី 2	មិនអនុវត្ត
		អាទិភាពទី 3	សំខាន់
		អាទិភាពទី 4	រយៈពេលវែង/ការថែទាំ
បៃតង	ជាទូទៅ ចំណុចទាំងអស់គឺគ្មានបញ្ហានោះទេ គឺស្របទៅតាមការព្រមព្រៀងដើម្បីដោះស្រាយអំពីមតិយោបល់ដែលបានកំណត់អាទិភាព។ ពុំមានវិការធ្ងន់ធ្ងរនោះទេ និងគ្មានហានិភ័យថ្នាល់ចំពោះ	អាទិភាពទី 1	មិនអនុវត្ត
		អាទិភាពទី 2	មិនអនុវត្ត
		អាទិភាពទី 3	រយៈពេលវែង/ការថែទាំ
		អាទិភាពទី 4	មិនអនុវត្ត

	បុគ្គលិកនោះទេ។ ផ្នែកផលិតកម្មអាចបន្តការងារបាន។ ចំណុចអាទិភាពទី 4 គឺជាកម្រិតខ្ពស់បំផុតដែលបានរកឃើញ។		

8 របាយការណ៍វាយតម្លៃសុវត្ថិភាពបឋម

8.1 ទិដ្ឋភាពទូទៅ

របាយការណ៍រោងចក្រគួរតែមានលក្ខណៈសង្ខេប ដោយផ្តោតជាសំខាន់ទៅលើលទ្ធផលក្រាហ្វ ដោយមានសេចក្តីពន្យល់ជាអក្សរតិចតួចបានហើយ។ របាយការណ៍នេះ គួរប្រើប្រាស់ទម្រង់ដូចៗគ្នាសម្រាប់ការវាយតម្លៃទាំងអស់ និងសរសេរសេចក្តីពន្យល់ខ្លីៗរៀបរាប់អំពីការវាយតម្លៃ លក្ខខណ្ឌតម្រូវនៃសកម្មភាពតាមដាន និងការកំណត់អំពីការវាយតម្លៃ។
មុនពេលចេញរបាយការណ៍ចុងក្រោយទៅកាន់ LABS វិស្វករជាន់ខ្ពស់ដែលលក្ខណៈសម្បត្តិក៏ត្រូវធ្វើការត្រួតពិនិត្យឡើងវិញ ហើយបន្ទាប់មកត្រូវអនុម័តដោយនាយកគម្រោង។ តារាងលំហូរដែលបានស្នើឡើងដែលកំណត់អំពីជំហានសំខាន់ៗក្នុងដំណើរការត្រួតពិនិត្យគុណភាព និងការត្រួតពិនិត្យ មាននៅក្នុងឧបសម្ព័ន្ធ ប។

8.2 របាយការណ៍វាយតម្លៃសុវត្ថិភាពគ្រោងអគារ

ឯកសារណែនាំមួយចំនួនគឺមានផ្តល់ជូនសម្រាប់ការរៀបចំរបាយការណ៍វាយតម្លៃសុវត្ថិភាពគ្រោងអគារ៖

- បញ្ជីត្រួតពិនិត្យការវាយតម្លៃសុវត្ថិភាពគ្រោងអគារ (ឧបសម្ព័ន្ធ ឃ)
- ការចាត់ថ្នាក់ និងការកំណត់អាទិភាពបញ្ហាគ្រោងអគារ (ឧបសម្ព័ន្ធ ឆ)។
- របាយការណ៍វាយតម្លៃសុវត្ថិភាពគ្រោងអគារ - គំរូ (ឧបសម្ព័ន្ធ ញ1) ដែលជាគំរូទទេរដែលត្រូវយកទៅប្រើក្នុងការបង្កើតរបាយការណ៍
- របាយការណ៍វាយតម្លៃសុវត្ថិភាពគ្រោងអគារ - គំរូ (ឧបសម្ព័ន្ធ ដ1) សម្រាប់ជាឯកសារយោងនិងការណែនាំអំពីរបៀបប្រើប្រាស់គំរូ។

របាយការណ៍នេះត្រូវមានផ្នែកដូចខាងក្រោម និងការពិពណ៌នាសម្រាប់ការសរសេររបាយការណ៍ដែលផ្អែកលើការវាយតម្លៃដែលបានបញ្ចប់នេះ ត្រូវបានរៀបរាប់អំពី៖

- គម្របខាងមុខ
- ទំព័រមាតិកា
- សេចក្តីសង្ខេបប្រតិបត្តិ
- ការពិពណ៌នាអំពីផ្នែករោងចក្រ
- ការពិពណ៌នាអំពីគ្រោងអគារអគារ
- ការសង្កេត
- សកម្មភាពអាទិភាព
- សេចក្តីសង្ខេបអំពីសកម្មភាពអាទិភាព
- ការវាយតម្លៃវិស្វកម្មលម្អិត (ប្រសិនបើចាំបាច់)

- ដែនកំណត់ និងការសន្មត់

8.2.1 គម្របខាងមុខ

គម្របខាងមុខ ត្រូវតែមានឈ្មោះ អាសយដ្ឋាន និងកូអរដោនេរបស់អោងចក្រ។ នៅពេលដែលរបាយការណ៍នេះត្រូវបានបញ្ចប់ និងមុនពេលពិនិត្យមើល ត្រូវពិនិត្យមើលចំណាត់ថ្នាក់ពណ៌ដែលត្រូវផ្តល់ជូន។ ឈ្មោះក្រុមវាយតម្លៃ កាលបរិច្ឆេទនៃការវាយតម្លៃ និងរូបថតនៃអគារក៏ត្រូវដាក់បញ្ចូលផងដែរ។ នៅពេលបញ្ចប់ការត្រួតពិនិត្យ លេខសំណៅកែប្រែ កាលបរិច្ឆេទ និងឈ្មោះអ្នកត្រួតពិនិត្យ និងអ្នកអនុម័តនឹងត្រូវដាក់បន្ថែមដោយវិស្វករត្រួតពិនិត្យ។ នៅពេលវាយតម្លៃ និងចាត់ចំណាត់ថ្នាក់ពណ៌ដល់អគារលើសពីមួយ នោះការចាត់ថ្នាក់ពណ៌ដ៏ពិបាកបំផុតលើអគារមួយនឹងត្រូវតែបង្ហាញនៅលើគម្របខាងមុខសម្រាប់អោងចក្រនោះ។

8.2.2 ទំព័រមាតិកា

មាតិការបាយការណ៍ គឺជាស្តង់ដារសម្រាប់របាយការណ៍ទាំងអស់ ប៉ុន្តែបញ្ជីរៀបរាប់អំពីចំណងជើងរបាយការណ៍សំខាន់ នឹងត្រូវបានផ្តល់ឱ្យជាមួយនឹងលេខទំព័រដែលត្រូវគ្នា។ លេខទំព័រនឹងត្រូវបញ្ចូលដោយដៃ ដោយរបាយការណ៍ FFC Actions PDF ត្រូវតែបញ្ចូលនៅក្រោមចំណងជើង "សកម្មភាពអាទិភាព" ។

8.2.3 សេចក្តីសង្ខេបប្រតិបត្តិ

សេចក្តីសង្ខេបប្រតិបត្តិ ត្រូវបញ្ចូលនូវការពិពណ៌នាអំពីសកម្មភាពវាយតម្លៃ ការសង្កេត និងសកម្មភាពអាទិភាព។ អ្នកគួរប្រើប្រាស់ទម្រង់ដូចខាងក្រោម៖

- នៅថ្ងៃXX ខែ ឆ្នាំ ឈ្មោះរបស់អ្នកវាយតម្លៃ ឈ្មោះក្រុមហ៊ុនវាយតម្លៃ បានអនុវត្តការវាយតម្លៃគ្រោងអគារដែលពិនិត្យមើល ឈ្មោះ អាសយដ្ឋាន និងកូអដោណេរបស់អោងចក្រដែលបាន
- ផ្តល់ឱ្យនៅលើគម្របខាងមុខនៃរបាយការណ៍នេះ។
- បរិយាយអំពីការប្រើប្រាស់អគារ។
- រៀបរាប់អំពីចំណុចដែលយើងបានពិនិត្យ និងមិនបានពិនិត្យ។
- ផ្តល់យោបល់លើស្ថានភាពនៃគំនូសបួង/របាយការណ៍ដែលបានផ្តល់ – លិខិតអនុញ្ញាត
- ស្តាបត្យកម្ម វិស្វករ ការសាងសង់ជាក់ស្តែង និងចំណុចផ្សេងទៀត។
- ផ្តល់មតិយោបល់លើភាពត្រឹមត្រូវនៃគំនូសបួង។ តើគំនូសបួង និងការសាងសង់ជាក់ស្តែងមានលក្ខណៈស្រដៀងគ្នាឬទេ?
- ប្រសិនបើអោងចក្រមានអគារច្រើន សូមផ្តល់ការពិពណ៌នាសង្ខេបអំពីអគារនីមួយៗ។
- ដាក់ស្លាកឈ្មោះអគារនីមួយៗ ដើម្បីងាយស្រួលក្នុងការយោងនៅក្នុងរបាយការណ៍។
- ការកំណត់កូដពណ៌គ្រោងអគារទាំងមូលសម្រាប់របាយការណ៍នេះគឺផ្អែកលើអគារដែលមានគុណភាពអន់ជាងគេនៅតាមទីតាំងជាក់ស្តែង។
- ផ្តល់មតិយោបល់លើកូដពណ៌អោងចក្រ៖ "ប្រភេទកូដពណ៌ទាំងមូលរបស់អោងចក្រនេះគឺហៅ

ថាកូដពណ៌។ ចំណុចនេះមានន័យថា យ៉ាងហោចណាស់ មានសកម្មភាពមួយចំនួនដែលត្រូវតែដោះស្រាយក្នុងពេលភ្លាមៗ"។

ប្រសិនបើអគារច្រើននៅក្នុងរោងចក្រ នោះប្រភេទនីមួយៗគួរតែត្រូវបានកត់ត្រាដូចខាងក្រោម៖ "ប្រភេទកូដពណ៌សម្រាប់អគាររោងចក្រនីមួយៗដែលសំខាន់ដែលត្រូវវាយតម្លៃ ត្រូវលើកឡើងដូចខាងក្រោម៖

អគារ 1៖ កូដពណ៌
អគារ 2៖ កូដពណ៌
អគារ 3៖ កូដពណ៌

- ចំណុចគួរឱ្យបារម្ភសំខាន់ៗត្រូវបានកត់សម្គាល់ដូចតទៅ៖ ចំណុចព្រួយបារម្ភជាអាទិភាពខ្ពស់បំផុតត្រូវលើកឡើងមុនគេ។ ប្រសិនបើមានការព្រួយបារម្ភដែលបានលើកឡើងដែលធ្វើឱ្យរបាយការណ៍ស្ថិតនៅក្នុងប្រភេទគ្រោះថ្នាក់ ឬខ្ពស់ជាងនេះ ត្រូវសរសេរជាអក្សរដិត ហើយចំណុចនេះ ត្រូវសរសេរនៅទំព័រដើមដំបូងនៃរបាយការណ៍។ បន្ទាប់មក ផ្តល់នូវតារាងនៃចំណុច ព្រួយបារម្ភបន្ថែម
- ផ្តល់មតិយោបល់លើកម្រិតនៃបទបញ្ជាផ្ទៃក្នុង និងការថែទាំដែលបានបង្ហាញនៅក្នុងរោងចក្រ ដោយផ្អែកលើក្តីបារម្ភសំខាន់ៗដែលបានលើកឡើង និងភស្តុតាងឯកសារផ្សេងទៀតដែលបានបង្ហាញ
- ប្រសិនបើតម្រូវឱ្យធ្វើការវាយតម្លៃផ្នែកវិស្វកម្មលម្អិតនៅក្នុងរោងចក្រដែលមានអគារច្រើន សូមបញ្ជាក់ឱ្យច្បាស់លាស់អំពីអគារណាមួយ។ សូមចងចាំផងដែរថា DEA គឺសម្រាប់អគារទាំងមូលតែម្តង។
- ផ្តល់មតិយោបល់អំពីតម្រូវការក្នុងការផ្អាកប្រតិបត្តិការរោងចក្រដោយផ្នែក ឬទាំងស្រុង ប្រសិនបើបញ្ហាសុវត្ថិភាពត្រូវបានរកឃើញ។
- ផ្តល់មតិយោបល់លើសកម្មភាព "សកម្មភាពបន្ថែមស្របតាមអាទិភាព និងគ្រោងពេលនេះមានផ្តល់ជូននៅផ្នែកចុងបញ្ចប់នៃរបាយការណ៍នេះ។ សូមចងចាំថា សកម្មភាពទាំងនេះត្រូវតែបានបញ្ចប់ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ហើយត្រូវប្រាកដណាស់ត្រូវធ្វើឡើងនៅក្នុងរយៈពេលដែលបានជូនដំណឹង។
- ផ្តល់យោបល់លើដែនកំណត់ "ដែនកំណត់ និងការសន្មត់របស់យើងក៏ត្រូវផ្តល់ជូននៅផ្នែកចុងបញ្ចប់នៃរបាយការណ៍នេះផងដែរ។"

8.2.4 រោងចក្រ

ផ្នែកនេះ រៀបរាប់អំពីការពិពណ៌នាក្រាហ្វរបស់អគារ និងវិសាលភាពនៃជាន់អគាររោងចក្រដែលបានវាយតម្លៃនៅក្នុងទីតាំងផ្ទាល់។ រូបភាព Google Maps ក៏អាចប្រើប្រាស់ជាប្លង់ទីតាំងដើម្បីបង្ហាញអំពីវិសាលភាពនៃអគារផងដែរ។ រូបភាពទាំងនេះក៏អាចបំពេញបន្ថែមបានដោយរូបថតទីតាំងជាក់ស្តែង គំនូសព្រាង និងអត្ថបទដើម្បីពណ៌នាអំពី៖

- ចំនួនជាន់
- ឆ្នាំនៃការសាងសង់ប្រហាក់ប្រហែល
- ការអភិវឌ្ឍជាដំណាក់កាល
- ចលនា និងការសាងសង់រួម
- ជាន់ដែលបានប្រើប្រាស់ដោយរោងចក្រនៅក្នុងអគារពហុមុខងារ
- ផ្នែកបន្ថែមបញ្ឈរ ឬផ្តេក
- ស្ថានភាពនៃការកំណត់អត្តសញ្ញាណការអនុញ្ញាតនៃការអភិវឌ្ឍដែលមិនមានការអនុញ្ញាត
- សុពលភាពនៃគំនូសប្លង់
- លក្ខណៈពិសេសផ្សេងទៀតដែលត្រូវកត់សម្គាល់

8.2.5 ប្រព័ន្ធគ្រោងអគារ

ផ្នែកនេះ រៀបរាប់អំពីការពិពណ៌នាក្រាហ្វនៃគ្រោងអគារអគារ។ ប្រព័ន្ធគ្រោងអគារនេះទំនងជាមានភាពខុសប្លែកគ្នា ជាពិសេសនៅក្នុងអគារដែលជាន់ និងផ្នែកបន្ថែម។ ទោះជាយ៉ាងណាក៏ដោយ យើងនៅតែអាចផ្តល់សេចក្តីសង្ខេបកម្រិតខ្ពស់អំពីអគារនីមួយៗបានដោយក្នុងសេចក្តីសង្ខេមមួយមួយទំព័រសម្រាប់អគារមួយ។
មិនចាំបាច់ផ្តល់នូវការពិពណ៌នាលម្អិតអំពីអគារមិនសំខាន់ ដែលមិនផ្ទុកមនុស្សយ៉ាងនោះទេ។
ប្រព័ន្ធនីមួយៗគួរតែត្រូវបានពិពណ៌នា ដើម្បីផ្តល់នូវសេចក្តីសង្ខេបអំពីព័ត៌មានដូចខាងក្រោម៖

- ប្រភេទគ្រោងអគារ – ធ្នឹម និងការចាក់សាប / ប្លង់សេ / ផ្សេងៗ
- ប្រព័ន្ធលំនឹង – គ្រោងចលនា / ជញ្ជាំងទប់ខ្យល់ / ការរៀបគ្រោងដែក / ផ្សេងទៀត
- ចំនួនជាន់
- ទំហំក្រឡា
- ទំហំសរសេរធម្មតានៅជាន់ក្រោម ឬតំបន់សំខាន់ៗ
- ទំហំធ្នឹមធម្មតា
- កម្រាស់ប្លង់សេ
- ប្រភេទគ្រឹះ (ប្រសិនបើមាន)
- ទីតាំងតំណ
- លក្ខណៈពិសេសផ្សេងទៀតដែលត្រូវកត់សម្គាល់

8.2.6 ការសង្កេត

ផ្នែកនេះ ត្រូវមានព័ត៌មានក្រាហ្វដែលបង្ហាញអំពីការសង្កេត ដោយប្រើរូបថត និងគំនូសព្រាងរួមបញ្ចូលគ្នាដើម្បីពណ៌នាអំពីបញ្ហាដែលជាការព្រួយបារម្ភ។ ការសង្កេតនីមួយៗគួរតែត្រូវបានពិពណ៌នាដាច់ដោយឡែកពីគ្នា ដោយរាប់តាមលំដាប់លេខពី STR 1 ដល់ STR n។ ប្រសិនបើពាក់ព័ន្ធ និងមានប្រយោជន៍ ទីតាំងសង្កេតគួរតែត្រូវបានផ្តល់ជូនដោយគំនូសប្លង់ គំនូសព្រាង ឬ

រូបថតដែលបានសម្គាល់។
ការសង្កេតគួរត្រូវធ្វើឡើងតាមលំដាប់អាទិភាពនៃកង្វល់ខ្ពស់បំផុតជាមុនសិន (ឧ. ភាពតានតឹងការងារខ្ពស់អំពីសរសរគ្រឹះនៅជាន់ផ្ទាល់ដី) បន្ទាប់មកគឺបញ្ជាបន្ទាប់បន្សំដែលមានការព្រួយបារម្ភតិចតួច។

8.2.7 សកម្មភាពអាទិភាព

ផ្នែកនេះ ត្រូវរៀបចំឡើងតាមរយៈ FFC ដែលជាកម្មវិធីគ្រប់គ្រងទិន្នន័យដែលត្រូវបានប្រើប្រាស់ដោយ LABS ដើម្បីប្រមូលផ្តុំរាល់ការសង្កេត និងសកម្មភាពនានានៅក្នុងរោងចក្រនីមួយៗ។ អ្នកវាយតម្លៃនឹងទទួលបានការបណ្តុះបណ្តាលដាច់ដោយឡែកយ៉ាងលម្អិតអំពីរបៀបប្រើប្រាស់កម្មវិធីនេះ។
សម្រាប់ចំណុចដែលបានសង្កេតនីមួយៗ បញ្ជីសកម្មភាព ត្រូវតែរៀបចំឡើងដើម្បីកំណត់អំពីសកម្មភាពតាមដានដែលត្រូវការជាក់លាក់ និងផ្តល់អាទិភាពដូចខាងក្រោម៖

- អាទិភាពទី 1 (SP1) - សកម្មភាពភ្លាមៗ ឧ. ការជម្លៀសមនុស្សទាំងស្រុង ឬដោយផ្នែក បញ្ឈប់ការសាងសង់ ដកបន្ទុកចេញ ។ល។ (ក្រហម សកម្មភាពគ្រោះថ្នាក់)។
- អាទិភាពទី 2 (SP2) - សកម្មភាពត្រូវបញ្ចប់ក្នុងរយៈពេល 6 សប្តាហ៍។
- អាទិភាពទី 3 (SP3) - សកម្មភាពត្រូវបញ្ចប់ក្នុងរយៈពេល 6 ខែ។
- ក្រុមវាយតម្លៃ ត្រូវពិនិត្យមើលតារាងកូដពណ៌ និងឧបសម្ព័ន្ធ G2 នៅពេលកំណត់ចំណុចអាទិភាព។

សកម្មភាពទាំងអស់ក៏ត្រូវចាត់ថ្នាក់ទៅជាប្រភេទបញ្ហា និងបញ្ហារងស្របទៅតាមការណែនាំដែលមាននៅក្នុងឧបសម្ព័ន្ធ ឆ1។ លេខប្រការពាក់ព័ន្ធនឹងស្តង់ដារ LABS ត្រូវតែដាក់បញ្ចូល សម្រាប់ជាឯកសារយោងដើម្បីកំណត់រកប្រការពាក់ព័ន្ធដែលត្រូវដាក់បញ្ចូលក្នុងសកម្មភាព ។
ក្រុមវាយតម្លៃនឹងរៀបចំផ្នែកនេះទាំងស្រុងតាមរយៈ FFC ហើយប្រើប្រាស់របាយការណ៍លទ្ធផល PDF ដើម្បីបញ្ចូលទៅក្នុងផ្នែកនៃរបាយការណ៍នេះ។
ប្រសិនបើតម្រូវឱ្យមានការវាយតម្លៃវិស្វកម្មលម្អិត (DEA) ដើម្បីបង្កើតការត្រួតពិនិត្យស៊ីជម្រៅបន្ថែមទៀតលើគ្រោងអគារ ដូច្នេះទំព័រដែលពិពណ៌នាអំពីតម្រូវការស្តង់ដារសម្រាប់ការងារនេះគួរតែបញ្ចូលនៅផ្នែកចុងបញ្ចប់នៃផ្នែកនេះ។ អត្ថបទស្តង់ដារ ត្រូវបានដាក់បញ្ចូលនៅក្នុងស្តង់ដារ LABS ហើយមិនត្រូវផ្លាស់ប្តូរទេ។ DEAs គួរបញ្ចូលជាសកម្មភាពក្នុងករណីដែលវិស្វករចនាសម្ព័ន្ធមានការសង្កេតមួយ ឬច្រើន ដែលបង្កើតនូវការព្រួយបារម្ភយ៉ាងធ្ងន់ធ្ងរទាក់ទងនឹងសុវត្ថិភាពគ្រោងអគារនៃអគារដោយខ្លួនគេផ្ទាល់ ឬជារួម។ DEA គួរតែត្រូវបានស្នើសុំតែនៅកន្លែងដែលមានករណីនេះ។

8.2.8 សេចក្តីសង្ខេបអំពីសកម្មភាពអាទិភាព

ផ្នែកនេះ គឺជាសេចក្តីសង្ខេបចំនួនមួយទំព័រដែលរៀបរាប់អំពីសកម្មភាពដែលត្រូវអនុវត្តដោយអ្នកគ្រប់គ្រងរោងចក្រ រួមទាំងពេលវេលាកំណត់ផងដែរ។ ផ្នែកនេះ ត្រូវបានបង្កើតឡើងដោយ

ស្វ័យប្រវត្តិពី FFC ជាតារាង ដែលនឹងត្រូវបញ្ចូលទៅក្នុងរបាយការណ៍ផងដែរ។

8.2.9 ដែនកំណត់ និងការសន្មត់

អត្ថបទស្តង់ដាររបស់យើងស្តីពីការកំណត់ និងការសន្មត់ទៅលើការវាយតម្លៃ ត្រូវបានដាក់បញ្ចូលទៅក្នុងផ្នែកចុងក្រោយនៃរបាយការណ៍នេះ។ អត្ថបទនេះមិនគួរកែប្រែទេ។
លើសពីនេះទៅទៀត ក៏ត្រូវបញ្ចូលការប្រកាសមិនទទួលខុសត្រូវពី LABS ផងដែរ៖

សេចក្តីប្រកាសមិនទទួលខុសត្រូវរបស់ LABS

*របាយការណ៍នេះ គឺជាលទ្ធផលនៃការវាយតម្លៃដែលបានធ្វើឡើងដោយអនុវត្តន៍វិធីសាស្ត្រវាយតម្លៃសុវត្ថិភាពបឋមសម្រាប់ប្រទេសកម្ពុជា (“**វិធីសាស្ត្រ**”) និងស្តង់ដារ និងពិធីសារដែលស្របទៅនឹង LABS (“**LABS ស្តង់ដារ**”)។*

ស្តង់ដារ LABS និងវិធីសាស្ត្រ រៀបរាប់អំពីលក្ខខណ្ឌតម្រូវក្នុងការដោះស្រាយបញ្ហាសុវត្ថិភាពអាយុជីវិតនៅក្នុងរោងចក្រពាក់ព័ន្ធនឹងសុវត្ថិភាពគ្រោងអគារ អគ្គិសនី និងអគ្គិភ័យ ប៉ុន្តែ LABS Foundation មិនទទួលខុសត្រូវនោះទេ ហើយក៏មិនអាចធានាបានថារោងចក្រនោះទទួលបានការធានាយ៉ាងពេញលេញនូវសុវត្ថិភាពអាយុជីវិតលើប្រព័ន្ធគ្រោងអគារ អគ្គិសនី និងអគ្គិភ័យផងដែរ។ LABS Foundation មិនទទួលខុសត្រូវចំពោះការធានាថារោងចក្រ និង/ឬក្រុមហ៊ុនត្រួតពិនិត្យដែលបានធ្វើការវាយតម្លៃ បានអនុលោមតាមលក្ខខណ្ឌតម្រូវនៃស្តង់ដារ LABS និង/ឬវិធីសាស្ត្រនោះទេ។

ក្រុមហ៊ុនត្រួតពិនិត្យដែលធ្វើការវាយតម្លៃត្រូវតែបកស្រាយ និងកែសម្រួលស្តង់ដារ LABS និងវិធីសាស្ត្រតាមភាពចាំបាច់ចំពោះរោងចក្រជាក់លាក់នីមួយៗ និងបរិបទក្នុងតំបន់ដែលបានធ្វើការវាយតម្លៃនោះ។ ក្រុមហ៊ុនត្រួតពិនិត្យត្រូវទទួលខុសត្រូវទាំងស្រុងចំពោះការវាយតម្លៃ និងលទ្ធផលនៃការវាយតម្លៃរួមមានជាអាទិ៍របាយការណ៍នេះ។ ពាក់ព័ន្ធនឹងរបាយការណ៍នេះ ឬផ្នែកណាមួយនោះ LABS Foundation មិនជាប់កាតព្វកិច្ចនៃការថែទាំ (មិនថានៅក្នុងកិច្ចសន្យា ឬនៅក្នុងច្បាប់រដ្ឋប្បវេណី ឬស្ថិតក្រោមលក្ខន្តិក: ឬក្នុងចំណុចផ្សេងៗ) ចំពោះបុគ្គល ឬភាគីដែលរបាយការណ៍នេះត្រូវផ្តោតលើ ហើយ LABS Foundation មិនទទួលខុសត្រូវចំពោះភាគីណាមួយដែលប្រើប្រាស់ ពឹងផ្អែក ឬធ្វើសកម្មភាពលើរបាយការណ៍នេះឡើយ។ LABS Foundation មិនទទួលខុសត្រូវ និងមិនអាចទទួលខុសត្រូវចំពោះការបាត់បង់ និង/ឬការខូចខាតណាមួយដែលកើតឡើងចំពោះរោងចក្រ ក្រុមហ៊ុនត្រួតពិនិត្យ និង/ឬភាគីទីបីណាមួយដែលបង្កឡើងដោយ ឬពាក់ព័ន្ធនឹងសុវត្ថិភាពអាយុជីវិតគ្រោងអគារ អគ្គិសនី និងអគ្គិភ័យនៅក្នុងរោងចក្រ ស្តង់ដារ LABS វិធីសាស្ត្រ ការវាយតម្លៃ របាយការណ៍ លទ្ធផលនៃការវាយតម្លៃ និង/ឬផលវិបាកនៃការវាយតម្លៃ លុះត្រាតែរោងចក្រ ក្រុមហ៊ុនត្រួតពិនិត្យ ឬភាគីទីបីណាមួយបង្ហាញពីការប្រព្រឹត្តខុសដោយចេតនា ឬការធ្វេសប្រហែសទាំងស្រុងរបស់ LABS Foundation ។

តាមរយៈការអានរបាយការណ៍ អ្នកអានរបាយការណ៍ត្រូវចាត់ទុកថាបានទទួលយកលក្ខខណ្ឌ

ដែលបានរៀបរាប់ខាងលើ។

8.2.10 ការបង្ហោះរបាយការណ៍ FFC

បន្ថែមពីលើការបង្ហោះរបាយការណ៍វាយតម្លៃសុវត្ថិភាពតាមគ្រោងអគារទៅ FFC ឯកសារខាងក្រោមនេះ ក៏ត្រូវបង្ហោះផងដែរ៖

- ការត្រួតពិនិត្យភាពរឹងមាំនៃសរសរគ្រឹះ
- ការត្រួតពិនិត្យភាពរឹងមាំនៃធ្នឹម

8.3 របាយការណ៍វាយតម្លៃសុវត្ថិភាពអគ្គិភ័យ

ឯកសារណែនាំមួយចំនួនគឺមានផ្តល់ជូនសម្រាប់ការរៀបចំរបាយការណ៍វាយតម្លៃសុវត្ថិភាពអគ្គិភ័យ៖

- បញ្ជីត្រួតពិនិត្យការវាយតម្លៃសុវត្ថិភាពអគ្គិភ័យ (ឧបសម្ព័ន្ធ ង)
- ចំណាត់ថ្នាក់បញ្ហាអគ្គិភ័យ ឯកសារសកម្មភាពអាទិភាព និងស្តង់ដារ (ឧបសម្ព័ន្ធ ជ)។ សំណៅឯកសារ Excel នេះមានចំណងជើងថា "Fire categorization- actions.xlsx" ក៏មានផ្តល់ជូនផងដែរ ដើម្បីជួយក្នុងការចងក្រងរបាយការណ៍។
- របាយការណ៍វាយតម្លៃសុវត្ថិភាពអគ្គិភ័យ - គំរូ (ឧបសម្ព័ន្ធ ញ2) ដែលជាគំរូទទេដែលអាចត្រូវបានប្រើក្នុងការបង្កើតរបាយការណ៍
- វាយតម្លៃសុវត្ថិភាពអគ្គិភ័យ - គំរូ (ឧបសម្ព័ន្ធ ដ2) សម្រាប់ជាឯកសារយោង និងការណែនាំអំពីរបៀបប្រើប្រាស់គំរូនេះ។

ទិន្នន័យអគាររោងចក្រដែលត្រូវបានកត់ត្រា ដោយអ្នកវាយតម្លៃសុវត្ថិភាពអគ្គិភ័យបន្ទាប់ពីបញ្ជីត្រួតពិនិត្យ អាចត្រូវបានប្រើប្រាស់រួមគ្នាជាមួយគំរូរបាយការណ៍សុវត្ថិភាពអគ្គិភ័យ និងសៀវភៅបញ្ជី "Fire categorisation-actions.xlsx" ដើម្បីបំពេញរបាយការណ៍។

របាយការណ៍នេះត្រូវមានផ្នែកដូចខាងក្រោម និងការពិពណ៌នាសម្រាប់ការសរសេររបាយការណ៍ដែលផ្អែកលើការវាយតម្លៃដែលបានបញ្ចប់នេះ ត្រូវបានរៀបរាប់អំពី៖

- គម្របខាងមុខ
- ទំព័រមាតិកា
- សេចក្តីសង្ខេបប្រតិបត្តិ
- ព័ត៌មានទូទៅអំពីរោងចក្រ និងអគារ
- ការពិពណ៌នាអំពីវិធានការសុវត្ថិភាពអគ្គិភ័យ
- ការសង្កេត
- សកម្មភាពអាទិភាព
- សេចក្តីសង្ខេបអំពីសកម្មភាពអាទិភាព
- ដែនកំណត់ និងការសន្មត់

ផ្នែកនីមួយៗ នឹងរៀបរាប់យ៉ាងលម្អិតបន្ថែមទៀតខាងក្រោម តាមរយៈការយោងទៅលើការព័ត៌មាន និងតារាងដែលមាននៅក្នុងរបាយការណ៍វាយតម្លៃសុវត្ថិភាពអគ្គិភ័យ - គំរូ។ ការណែនាំអំពីថាតើទិន្នន័យណាត្រូវបញ្ចូលនៅក្នុងតារាងណា ហើយមតិមួយចំនួនអំពីភាពពាក់ព័ន្ធនៃទិន្នន័យនេះមានផ្តល់ជូននៅក្នុងអក្សរទ្រេតក្នុងតារាងដែលដកស្រង់ចេញពីគំរូនោះ។

8.3.1 គម្របខាងមុខ

គម្របខាងមុខ ត្រូវតែមានឈ្មោះ អាសយដ្ឋាន និងកូអរដោនេរបស់អាងចក្រ។ នៅពេលដែលរបាយការណ៍នេះត្រូវបានបញ្ចប់ និងមុនពេលពិនិត្យមើល ត្រូវពិនិត្យមើលចំណាត់ថ្នាក់ពណ៌ដែលត្រូវផ្តល់ជូន។ នៅពេលវាយតម្លៃ និងចាត់ចំណាត់ថ្នាក់ពណ៌ដល់អគារលើសពីមួយ នោះការចាត់ថ្នាក់ពណ៌ដ៏ពិបាកបំផុតលើអគារមួយ ត្រូវតែបង្ហាញនៅលើគម្របខាងមុខសម្រាប់អាងចក្រនោះ។

ឈ្មោះក្រុមវាយតម្លៃ កាលបរិច្ឆេទនៃការវាយតម្លៃ និងរូបថតនៃអគារក៏ត្រូវដាក់បញ្ចូលផងដែរ។ នៅពេលបញ្ចប់ការត្រួតពិនិត្យ លេខសំណៅកែប្រែ កាលបរិច្ឆេទ និងឈ្មោះអ្នកត្រួតពិនិត្យ និងអ្នកអនុម័តនឹងត្រូវដាក់បន្ថែមដោយវិស្វករត្រួតពិនិត្យ។

8.3.2 ទំព័រមាតិកា

មាតិការបាយការណ៍ គឺជាស្តង់ដារសម្រាប់របាយការណ៍ទាំងអស់ ប៉ុន្តែបញ្ជីរៀបរាប់អំពីចំណងជើងរបាយការណ៍សំខាន់ នឹងត្រូវបានផ្តល់ឱ្យជាមួយនឹងលេខទំព័រដែលត្រូវគ្នា។ លេខទំព័រនឹងត្រូវបញ្ចូលដោយដៃ ដោយរបាយការណ៍ FFC Actions PDF ត្រូវតែបញ្ចូលនៅក្រោមចំណងជើង "សកម្មភាពអាទិភាព" ។

8.3.3 សេចក្តីសង្ខេបប្រតិបត្តិ

សេចក្តីសង្ខេបប្រតិបត្តិ ត្រូវបញ្ចូលនូវការពិពណ៌នាអំពីសកម្មភាពវាយតម្លៃ ការសង្កេត និងសកម្មភាពអាទិភាព។ អ្នកគួរប្រើប្រាស់ទម្រង់ដូចខាងក្រោម៖

- នៅថ្ងៃXX ខែ ឆ្នាំ ឈ្មោះរបស់អ្នកវាយតម្លៃ ឈ្មោះក្រុមហ៊ុនវាយតម្លៃ បានអនុវត្តការវាយតម្លៃប្រព័ន្ធអគ្គិសនីដែលកាពិនិត្យមើលអាងចក្រឈ្មោះ អាងចក្រនៅអាសយដ្ឋាន និងកូអរដោណេដែលបានផ្តល់ឱ្យនៅលើគម្របខាងមុខនៃរបាយការណ៍នេះ។
- រៀបរាប់អំពីការប្រើប្រាស់អគារ។
- រៀបរាប់អំពីចំណុចដែលយើងបានពិនិត្យ និងមិនបានពិនិត្យ។
- ផ្តល់យោបល់លើស្ថានភាពនៃគំនូសបួង/របាយការណ៍ដែលបានផ្តល់ – លិខិតអនុញ្ញាត
- ស្តាបត្យកម្ម វិស្វករ ការសាងសង់ជាក់ស្តែង និងចំណុចផ្សេងទៀត។
- ផ្តល់យោបល់លើភាពត្រឹមត្រូវនៃគំនូសបួង។ តើគំនូសបួង និងការសាងសង់ជាក់ស្តែងមានលក្ខណៈស្រដៀងគ្នាឬទេ?
- ប្រសិនបើអាងចក្រមានអគារច្រើន សូមផ្តល់ការពិពណ៌នាសង្ខេបអំពីអគារនីមួយៗ។

- ដាក់ស្លាកឈ្មោះអគារនីមួយៗ ដើម្បីងាយស្រួលក្នុងការយោងនៅក្នុងរបាយការណ៍។
- ការកំណត់កូដពណ៌អគ្គិភ័យទាំងមូលសម្រាប់របាយការណ៍នេះគឺផ្អែកលើអគារដែលគ្មានគុណភាពបំផុតនៅតាមទីតាំងជាក់ស្តែង។
- ផ្តល់មតិយោបល់លើកូដពណ៌រោងចក្រ៖ "ប្រភេទកូដពណ៌ទាំងមូលរបស់រោងចក្រនេះគឺហៅថាកូដពណ៌។ ចំណុចនេះមានន័យថា យ៉ាងហោចណាស់ មានសកម្មភាពមួយចំនួនដែលត្រូវតែដោះស្រាយក្នុងពេលភ្លាមៗ"។
- ប្រសិនបើមានអគារច្រើននៅក្នុងរោងចក្រ នោះការចាត់ថ្នាក់នីមួយៗគួរតែត្រូវបានកត់ត្រាដូចខាងក្រោម៖
- "ប្រភេទកូដពណ៌សម្រាប់អគាររោងចក្រនីមួយៗដែលសំខាន់ដែលត្រូវវាយតម្លៃ ត្រូវលើកឡើងដូចខាងក្រោម៖
- • អគារ 1៖ កូដពណ៌ អគារ 2៖ កូដពណ៌ អគារ 3៖ កូដពណ៌
- ចំណុចគួរឱ្យបារម្ភសំខាន់ៗត្រូវបានកត់សម្គាល់ដូចតទៅ៖ ចំណុចព្រួយបារម្ភជាអាទិភាពខ្ពស់បំផុតត្រូវលើកឡើងមុនគេ។ ប្រសិនបើមានការព្រួយបារម្ភដែលបានលើកឡើងដែលធ្វើឱ្យរបាយការណ៍ស្ថិតនៅក្នុងប្រភេទគ្រោះថ្នាក់ ឬខ្ពស់ជាងនេះ ត្រូវសរសេរជាអក្សរដិត។
- ផ្តល់មតិយោបល់អំពីតម្រូវការក្នុងការផ្អាកប្រតិបត្តិការរោងចក្រដោយផ្នែក ឬទាំងស្រុង ប្រសិនបើបញ្ហាសុវត្ថិភាពត្រូវបានរកឃើញ។
- ផ្តល់មតិយោបល់លើថាតើត្រូវអនុវត្តសកម្មភាពបន្ទាន់សម្រាប់បញ្ហាអាទិភាព 1 ដែលត្រូវបានដោះស្រាយក្នុងរយៈពេល 2 សប្តាហ៍ ដូចជាការបើកសោទ្វារច្រកចុងក្រោយ។
- ផ្តល់មតិយោបល់លើកម្រិតនៃបទបញ្ជាផ្ទៃក្នុង និងការថែទាំដែលបានបង្ហាញនៅក្នុងរោងចក្រ ដោយផ្អែកលើក្តីបារម្ភសំខាន់ៗដែលបានលើកឡើង និងភស្តុតាងឯកសារផ្សេងទៀតដែលបានបង្ហាញ។
- ផ្តល់មតិយោបល់លើដៃនកំណត់ "ដៃនកំណត់ និងការសន្មត់របស់យើងក៏ត្រូវផ្តល់ជូននៅផ្នែកចុងបញ្ចប់នៃរបាយការណ៍នេះផងដែរ។

8.3.4 ព័ត៌មានទូទៅអំពីរោងចក្រ និងអគារ

ព័ត៌មានដែលត្រូវការសម្រាប់ការពិពណ៌នាអំពីស្ថានភាពអគារទូទៅ គឺជាព័ត៌មានធម្មតាសម្រាប់ការវាយតម្លៃគ្រោងអគារ ប្រព័ន្ធសុវត្ថិភាពអគ្គិភ័យ និងអគ្គិសនី ហើយព័ត៌មានទាំងនេះត្រូវស្នើសុំរួមគ្នាមុនពេលត្រួតពិនិត្យអគារ ពោលគឺនៅក្នុងពេលកិច្ចប្រជុំគណៈគ្រប់គ្រងរោងចក្រដំបូង។

8.3.4.1 ព័ត៌មានអំពីរោងចក្រទូទៅ

តារាងមួយដែលបានផ្តល់ជូន មានបង្ហាញអំពីទិន្នន័យអប្បបរមាដែលត្រូវពិនិត្យមើលសម្រាប់ "ព័ត៌មានទូទៅអំពីរោងចក្រ" និងជាសេចក្តីពន្យល់សម្រាប់ខ្លួនឯង។

8.3.4.2 ព័ត៌មានទូទៅអំពីអគារ

ព័ត៌មានទូទៅអំពីអគារនេះ មានគោលបំណងក្តោបយកព័ត៌មានទាំងអស់របស់អគារនីមួយៗដែលពាក់ព័ន្ធនឹងការវាយតម្លៃសុវត្ថិភាពអគ្គិភ័យរបស់រោងចក្រ។ ព័ត៌មាននេះ មានផ្តល់ជូនក្នុងតារាងខាងក្រោម៖

ចំនួនអគារ		*ចំនួនអគារដែលត្រូវវាយតម្លៃ និងចាត់ចំណាត់ថ្នាក់ហានិភ័យ។* *ជាទូទៅ អគារទាំងនេះគឺជាអគារផលិតកម្មទាំងអស់ និងអគារឃ្លាំងមួយចំនួន។* *តាមការណែនាំ អគារឃ្លាំងដែលមានអ្នកបម្រើការងារក្នុងនោះចាប់ពី 50 នាក់ឡើងទៅ ឬមានទំហំចាប់ពី 1.500 ម² ឡើងទៅ (ផ្អែកលើកត្តាដង់ស៊ីតេនៃការរចនា 30 ម²/នាក់) នឹងត្រូវវាយតម្លៃ ហើយចាត់ចំណាត់ថ្នាក់ហានិភ័យ។* *ជាធម្មតា ក្នុងរោងចក្រមានអគារផ្សេងទៀត (ម៉ាស៊ីនភ្លើង ត្រង់ស្វូរ ឡចំហាយ បន្ទប់សង្គ្រោះបឋម ទារកដ្ឋាន បន្ទប់ស្នប់ប្លម ឃ្លាំងតូចៗ ជាដើម) នៅតាមទីតាំងផ្ទាល់ ដែលនឹងបង្កើតបានជាផ្នែកមួយនៃការវាយតម្លៃសុវត្ថិភាពអគ្គិភ័យនិងដូចបានបញ្ជាក់ខាងលើ។ សម្រាប់អគារទាំងនេះ ក៏ដូចជាអគារឃ្លាំងដែលមានទំហំក្រោម 1.500 ម² នៅក្នុងតំបន់នោះ អ្នកវាយតម្លៃអាចធ្វើការសម្រេចចិត្តថាតើត្រូវចាត់ចំណាត់ថ្នាក់ហានិភ័យឬអត់។*
ការជ្រើសរើស និងការប្រើប្រាស់អគារ	*ផលិតកម្ម អគារ xx*	*ត្រូវដាក់ឈ្មោះឱ្យអគារនីមួយៗ ដើម្បីងាយស្រួលយោងទៅក្នុងរបាយការណ៍ និងកំណត់អំពីការប្រើប្រាស់អគារ*
	ផលិតកម្ម yy	*ដូចទៅនឹងចំណុចដែលបានរៀបរាប់ខាងលើ*
	ឃ្លាំង xx	*ដូចទៅនឹងចំណុចដែលបានរៀបរាប់ខាងលើ*
	ផ្សេងៗ zz	*ដូចទៅនឹងចំណុចដែលបានរៀបរាប់ខាងលើ*
ជាន់ក្រោមដី	*ត្រូវបញ្ជាក់ថាមានជាន់ក្រោមដីឬទេ* *បង្ហាញអគារទាំងអស់ដែលមានជាន់ក្រោមដី ដោយប្រើប្រាស់ស្លាកសញ្ញាអគារដែលបានកំណត់ខាងលើ*	
ជាន់ឡៅតឿ	*ត្រូវបញ្ជាក់ថាតើមានឡៅតឿឬទេ* *បង្ហាញអគារទាំងអស់ដែលមានឡៅតឿ ហើយស្ថិតនៅជាន់ណា*	
ជាន់ខាងលើជាន់ផ្ទាល់ដី	*ផលិតកម្ម xx*	*ចំនួនជាន់ n; ផ្ទាល់ដី +(n-1)*
	ផលិតកម្ម yy	*ដូចទៅនឹងចំណុចដែលបានរៀបរាប់ខាងលើ*
	ឃ្លាំង xx	*ដូចទៅនឹងចំណុចដែលបានរៀបរាប់ខាងលើ*

	ផ្សេងៗ zz	*ដូចទៅនឹងចំណុចដែលបានរៀបរាប់ខាងលើ*
កម្ពស់អគារ (m)	*ផលិតកម្ម xx*	*កម្ពស់ (m) នៃជាន់ដែលប្រើប្រាស់ខាងលើគេបំផុត ដែលនៅលើកម្រិតនៃការចូលដោយក្រុម ពន្លត់អគ្គិភ័យ*
	ផលិតកម្ម yy	*ដូចទៅនឹងចំណុចដែលបានរៀបរាប់ខាងលើ*
	ឃ្លាំង xx	*ដូចទៅនឹងចំណុចដែលបានរៀបរាប់ខាងលើ*
ជាន់ ទំហំ/ផ្ទៃក្រលា	*ផលិតកម្ម zz* *ផ្សេងៗ xx*	*ដូចទៅនឹងចំណុចដែលបានរៀបរាប់ខាងលើ ទទឹង x ប្រវែង = ផ្ទៃក្រឡា (ម²) សម្រាប់ជាន់នីមួយៗ*
		អគារ
	ផលិតកម្ម yy	*ដូចទៅនឹងចំណុចដែលបានរៀបរាប់ខាងលើ*
	ឃ្លាំង xx	*ដូចទៅនឹងចំណុចដែលបានរៀបរាប់ខាងលើ*
	ផ្សេងៗ zz	*ដូចទៅនឹងចំណុចដែលបានរៀបរាប់ខាងលើ*
ចំនួនអ្នកប្រើប្រាស់	*ផលិតកម្ម xx*	*ផ្នែកនេះត្រូវបែងចែកទៅតាមចំនួនអ្នកប្រើប្រាស់តាមជាន់*
		សម្រាប់ការប្រើប្រាស់តាមទំហំផ្ទៃក្រឡាធំៗ នោះគេអាចនឹងបែងចែកអ្នកប្រើប្រាស់ទៅតាមផ្ទៃក្រលា/ប្រើប្រាស់
	ផលិតកម្ម yy	*ដូចទៅនឹងចំណុចដែលបានរៀបរាប់ខាងលើ*
	ឃ្លាំង xx	*ដូចទៅនឹងចំណុចដែលបានរៀបរាប់ខាងលើ*
	ផ្សេងៗ zz	*ដូចទៅនឹងចំណុចដែលបានរៀបរាប់ខាងលើ*

ចំនួនវេនធ្វើការ *បញ្ជាក់អំពីវេនធ្វើការងារ និងម៉ោងតាមវេនប្រសិនបើមាន*
ឆ្នាំសាងសង់ *ឆ្នាំនៃការសាងសង់អគារនីមួយៗ*

ប្រភេទនៃការសាងសង់	*ផលិតកម្មសំណង់* xx	*បេតុងអាមេ ដែកគ្រោងអគារ*
		ឈើ ឬរៀបរាប់ចូលគ្នា សម្រាប់
	ផលិតកម្ម yy	*អគារនីមួយៗ ដូចទៅនឹងចំណុចដែលបានរៀបរាប់ខាងលើ*
	ឃ្លាំង xx *ផ្សេងៗ* zz	*ដូចទៅនឹងចំណុចដែលបានរៀបរាប់ខាងលើ* *ដូចទៅនឹងចំណុចដែលបានរៀបរាប់ខាងលើ*

ការបន្ថែម/ការកែលម្អ បញ្ជាក់អំពីការបន្ថែម/ការកែលម្អទៅលើអគារ និងឆ្នាំនៃការបន្ថែម ឬកែលម្អនោះ

ប្លង់ជាន់ដែលបានផ្តល់ជូន	*ផលិតកម្ម* xx	*គំនូរស្តាប់ត្យកម្ម*
		ប្លង់របស់អ្នកវាយតម្លៃរោងចក្រ *ប្លង់ផែនការ* *ឬ*
		ឯកសារផ្សេងទៀតដែលប្រើជាឯកសារយោងនៅក្នុង
	ផលិតកម្ម yy	*របាយការណ៍។ ដូចទៅនឹងចំណុចដែលបានរៀបរាប់ខាងលើ*
	ឃ្លាំង xx *ផ្សេងៗ zz*	*ដូចទៅនឹងចំណុចដែលបានរៀបរាប់ខាងលើ* *ដូចទៅនឹងចំណុចដែលបានរៀបរាប់ខាងលើ*
លិខិតិអនុញ្ញាតដែលបានផ្តល់ជូន	*បញ្ជាក់អំពីលិខិតអនុញ្ញាតដែលគណៈគ្រប់គ្រងបានរៀបចំឡើងនៅថ្ងៃវាយតម្លៃ។* *លិខិតនេះត្រូវរួមបញ្ចូលចំណុចដូចជា៖* – *អាជ្ញាបណ្ណអនុញ្ញាតឱ្យរៀបចំប្លង់ដើម្បីសាងសង់អគាររោងចក្ររួមជាមួយនឹងកាលបរិច្ឆេទអនុម័ត* – *របាយការណ៍នគរបាលអគ្គិភ័យ រួមជាមួយនឹងកាលបរិច្ឆេទត្រួតពិនិត្យលើកចុងក្រោយ* – *អាជ្ញាបណ្ណអគ្គិភ័យ ជាមួយនឹងកាលបរិច្ឆេទសុពលភាព*	
មតិយោបល់ផ្សេងៗ	*លក្ខណៈផ្សេងទៀតដែលមិនមាននៅក្នុងតារាងនេះ ដែលអាចពាក់ព័ន្ធនឹងការវាយតម្លៃសុវត្ថិភាពអគ្គិភ័យ ត្រូវបានបញ្ចូលនៅក្នុងផ្នែកនេះ។*	

ការពិពណ៌នាអំពីក្រាហ្វនៃអគារក៏ត្រូវបង្ហាញនៅក្នុងផ្នែកនេះផងដែរ ដោយប្រើប្រាស់នូវ៖

- ប្លង់បរិវេណរោងចក្រ ដែលបង្ហាញអំពីអគារដែលត្រូវវាយតម្លៃ និងមានដាក់ស្លាកសញ្ញា។
- ប្លង់តាមជាន់ធម្មតាត្រូវស្នើសុំមុនពេលត្រួតពិនិត្យ ឬផ្តល់ជូននៅក្នុងកិច្ចប្រជុំគណៈគ្រប់គ្រង។ ផ្នែក ឬការប្រើប្រាស់ផ្សេងៗគ្នាដែលនឹងត្រូវបានយោងនៅក្នុងរបាយការណ៍នេះ ត្រូវបង្ហាញ និងដាក់ស្លាកឈ្មោះទាំងអស់។
- ផ្នែកដែលត្រូវប្រើប្រាស់ខុសៗគ្នានៅតាមជាន់នីមួយៗ ត្រូវកំណត់ និងដាក់ស្លាកឈ្មោះសម្គាល់។

8.3.5 វិធានការសុវត្ថិភាពអគ្គិភ័យ

ការពិពណ៌នាអំពីវិធានការសុវត្ថិភាពអគ្គិភ័យសម្រាប់អគារ អាចធ្វើឡើងបានតាមរយៈការបំពេញទិន្នន័យដែលទទួលបានក្នុងអំឡុងពេលវាយតម្លៃនៅក្នុងតារាងដែលត្រូវគ្នានឹងបញ្ជីត្រួតពិនិត្យ (សូមមើលឧបសម្ព័ន្ធ ជ និងសន្លឹកឯកសារ "Fire categorization-actions.xlsx")។
ចំណងជើង និងចំណងជើងរងរបាយការណ៍ ត្រូវប្រើប្រាស់ចំណងជើង "ប្រភេទបញ្ហា" និង "ប្រភេទបញ្ហារង" ពីបញ្ជីត្រួតពិនិត្យ។

ការប្រើប្រាស់រូបថត

គំរូរបាយការណ៍សុវត្ថិភាពអគ្គិភ័យ មានប្រអប់មួយចំនួនក្រោមពាក្យថា "វិធានការសុវត្ថិភាពអគ្គិភ័យ" ដែលផ្នែកនោះយើងអាចបញ្ចូលរូបថតបាន ដើម្បីបង្ហាញអំពីអត្ថបទពិពណ៌នាមួយចំនួននៅក្នុងតារាងនោះ។ ទីតាំង ឬចំនួនតួលេខដែលបានប្រើប្រាស់គឺអាស្រ័យទៅលើការសម្រេចចិត្តរបស់អ្នកធ្វើរបាយការណ៍ ពោលគឺពួកគេអាចបញ្ចូលទៅក្នុងផ្នែករងណាមួយខាងលើ ប៉ុន្តែផ្នែកនេះមិនចាំបាច់បញ្ចូលរូបថតឡើយ។
ដើម្បីសន្សំសំចៃពេលវេលាក្នុងការរៀបចំរបាយការណ៍ អ្នកអាចបញ្ចូលរូបថតតិចតួចបានហើយនៅក្នុងផ្នែកនេះ ពីព្រោះគេរំពឹងថានៅពេលដែលពិភាក្សាអំពី "ការសង្កេត" នៅក្នុងផ្នែកបន្ទាប់ នោះចំណុចសង្កេតជាច្រើននឹងមានអមទៅដោយរូបថតដើម្បីពន្យល់បន្ថែម។
គន្លឹះក្នុងការបញ្ចូលរូបថត៖ ប្រសិនបើប្រើកម្មវិធី Word ដើម្បីបង្កើតរបាយការណ៍ សូមបំប្លែងរូបថតទាំងអស់ទៅជាទម្រង់ទំហំតូចៗ ឬប្រើកម្មវិធី Windows Snipping Tool ដើម្បីបញ្ចូលរូបថតដោយងាយចូលទៅក្នុងប្រអប់ដែលបានផ្តល់ជូន។

8.3.5.1 ប្រភេទនៃការប្រើប្រាស់អគារ

ប្រភេទនៃការប្រើប្រាស់អគារ កំណត់អំពីវិធានការសុវត្ថិភាពអគ្គិភ័យដែលស្តង់ដារ LABS ត្រូវការ ហើយគួរត្រូវបានកំណត់សម្រាប់អគារសំខាន់ៗនីមួយៗនៅក្នុងរបាយការណ៍នេះ ឧ.៖
អគារផលិតកម្ម - ផ្នែកឧស្សាហកម្មទូទៅ (ឧស្សាហកម្មក្រុម ឆ)
អគារឃ្លាំង - ឃ្លាំងរក្សាសារធាតុគ្រោះថ្នាក់ធម្មតា (ឃ្លាំងក្រុម ជ) អគារអាហារដ្ឋាន - អគារអន្តេវាសិកដ្ឋាន - លំនៅដ្ឋាន

8.3.5.2 មធ្យោបាយនៃការជម្លៀសខ្លួន

ផ្នែកនេះអនុវត្តតាមលំដាប់លំដោយនៃបទប្បញ្ញត្តិស្តីពីការជម្លៀសខ្លួនខ្សែផ្តេក ខ្សែបញ្ឈរ ហើយបន្ទាប់មកការជម្លៀសខ្លួនចុងក្រោយទៅខាងក្រៅ និងឆ្ងាយពីអគារ។
ជាការណែនាំ យ៉ាងហោចណាស់ត្រូវមានដ្យាក្រាមចំនួនពីរនៅពេលចាប់ផ្តើមផ្នែកនេះ ដើម្បីធ្វើឱ្យការពិពណ៌នាខាងក្រោមកាន់តែមានភាពងាយស្រួល៖

- ដ្យាក្រាមដែលបង្ហាញអំពីច្រកចេញតាមជាន់ពីជាន់ធម្មតានៃអគារ។ ដ្យាក្រាមនេះក៏ត្រូវបែងចែកឱ្យច្បាស់រវាងច្រកចេញតាមបន្ទប់/តំបន់ និងច្រកចេញតាមជាន់ផងដែរ ដោយសារតែលក្ខខណ្ឌតម្រូវការសម្រាប់ផ្នែកនីមួយៗគឺខុសៗគ្នា។
- ដ្យាក្រាមបង្ហាញអមពីច្រកចេញចុងក្រោយពីជាន់ផ្ទាល់ដីរបស់អគារ។ ដ្យាក្រាមនេះក៏ត្រូវបែង

ចែកឱ្យច្បាស់រវាងច្រកចេញតាមបន្ទប់/តំបន់ និងច្រកចេញតាមជាន់ផងដែរ ដោយសារតែលក្ខខណ្ឌតម្រូវការសម្រាប់ផ្នែកនីមួយៗគឺខុសៗគ្នា។



រូបភាពទី 16 ប្លង់បង្ហាញអំពីច្រកចេញពីជាន់ធម្មតារបស់អគារ



រូបភាពទី 17 ប្លង់បង្ហាញអំពីច្រកចេញពីច្រកចេញចុងក្រោយពីជាន់ផ្ទាល់ដីរបស់អគារ និងផ្លូវចេញពីអគារ

សម្រាប់អគារមានតែមួយជាន់ ទិន្នន័យនេះអាចបង្ហាញនៅលើប្លង់តែមួយបាន។ ដ្បាក្រាមនេះ ក៏អាចបង្កើតឡើងបានយ៉ាងរហ័ស តាមរយៈការប្រើប្រាស់ប្លង់ជាន់ដែលប្រមូលបាន ក្នុងអំឡុងពេលវាយតម្លៃ និងបន្ថែមទិន្នន័យដែលពាក់ព័ន្ធ។
ដ្បាក្រាមទាំងនេះក៏គួរត្រូវបានប្រើប្រាស់សម្រាប់ការដាក់ស្លាកឈ្មោះតំបន់ ជណ្តើរ លេខច្រកចេញដែលអាចយោងទៅបាន នៅក្នុងផ្នែកពិពណ៌នាដែលបានផ្តល់ជូននៅក្នុងប្រអប់ទិន្នន័យ។
តារាងទិន្នន័យដែលបានពីគំរូរបាយការណ៍សុវត្ថិភាពអគ្គិភ័យត្រូវបានផលិតឡើងវិញខាងក្រោមនេះ រួមជាមួយនឹងការរៀបរាប់ខ្លីអំពីព័ត៌មានដែលត្រូវកត់ត្រានៅទីនេះ និងគោលបំណងរបស់វា៖

ច្រកចេញតាមជាន់
តារាងនេះមានគោលបំណងកំណត់រកទិន្នន័យដែលត្រូវការដើម្បីវាយតម្លៃថាតើចំនួន និងទំហំនៃច្រកចេញតាមជាន់នីមួយៗមានទំហំធំគ្រប់គ្រាន់សម្រាប់ការប្រើប្រាស់តាមជាន់ឬទេ

អគារ/ជាន់/តំបន់	**ការប្រើប្រាស់**	**ទំហំទ្វារដែលត្រូវការ**	**ចំនួនច្រកចេញដែលបានផ្តល់ជូន**	**ទំហំទ្វារសរុប**	**សមត្ថភាពទ្វារដែលបានផ្តល់ជូន**
ប្រសិនបើ មានអគារច្រើន អគារនីមួយៗ ត្រូវតែកំណត់ដាច់ដោយឡែកពីគ្នា។ *សម្រាប់អគារដែលមានច្រើនជាន់ ទិន្នន័យសម្រាប់ជាន់នីមួយៗក្នុងអគារចាំបាច់ត្រូវតែ កត់ត្រាទុក*	*ចំនួនអ្នកប្រើប្រាស់ច្រើនដែលបានកត់ត្រានៅក្នុងរបាយការណ៍វាយតម្លៃ* *(ទិន្នន័យពោងចក្រ ឬទិន្នន័យ សង្កេត) ហើយគណនាដោយប្រើកត្តាដង់ស៊ីតេ x ផ្ទៃក្រឡាជាន់*	*ការប្រើប្រាស់ x 5 មម/ម្នាក់*	*លេខ*	*ផលបូកនៃទំហំទ្វារ*	*ទំហំទ្វារសរុបដែលបានផ្តល់ជូន / 5មម / ម្នាក់*

ចំណុចបន្ថែមដែលត្រូវកត់សម្គាល់៖

- នៅពេលកត់ត្រាទិន្នន័យសម្រាប់ជាន់ផ្ទាល់ដី ការរួមចំណែកពីអ្នកប្រើប្រាស់ពីជណ្តើរណាមួយដែលបញ្ចេញ ត្រូវតែយកមកពិចារណាក្នុងការវាយតម្លៃសមត្ថភាពទ្វារ។

ខាងក្រោមនេះ គឺជាលំហាត់វាយតម្លៃថាតើចំនួន និងទំហំនៃជណ្តើរច្រកចេញពីជាន់នីមួយៗ គឺមានភាពគ្រប់គ្រាន់សម្រាប់ការប្រើប្រាស់តាមជាន់ និងច្រកចេញតាមជាន់ដែលបានផ្តល់ជូន។
ចំណុចមួយចំនួនដែលត្រូវកត់សម្គាល់៖

អគារ/ជាន់/តំបន់	**ការប្រើប្រាស់**	**ទំហំទ្វារដែលត្រូវការ**	**ចំនួនច្រកចេញដែលបានផ្តល់ជូន**	**ទំហំទ្វារសរុប**	**សមត្ថភាពទ្វារដែលបានផ្តល់ជូន**
ដូចចំណុចខាងលើ	*ដូចចំណុចខាងលើ*	*ការប្រើប្រាស់ x 7.6 មម/ម្នាក់*	*លេខ*	*ផលបូកនៃទំហំទ្វារ*	*ទំហំទ្វារសរុបដែលបានផ្តល់ជូន / 7.6 មម / ម្នាក់*

នៅពេលទិន្នន័យទាំងនេះត្រូវបានរកឃើញ នោះរបាយការណ៍នឹងផ្តល់នូវតារាងដែលនិយាយអំពីចម្ងាយទៅកាន់ច្រកចេញ៖

ផ្លូវផ្សេងសម្រាប់ជម្លៀសខ្លួនដែលបានផ្តល់ជូនពីគ្រប់ផ្នែកទាំងអស់	*ត្រូវកត់ត្រាទុកថា "មែន" លើមិនដូច្នោះទេ ត្រូវបង្ហាញអំពីទីតាំងដែលមានទិសដៅធ្វើដំណើរតែមួយ។*
ចម្ងាយឆ្ងាយបំផុត ទៅច្រកចេញតាមជាន់ដែលនៅជិតបំផុត	*តើមានចំណុចណាមួយដែលចម្ងាយទៅកាន់ច្រកចេញជិតបំផុតមានចម្ងាយលើសពី 61ម (ឬ 76ម ពីទុយោបាញ់ទឹក)?* *សូមកត់សម្គាល់ផងដែរទៅលើផ្លូវធ្វើដំណើរដែលមានសមាសធាតុធ្វើដំណើរធំជាង 15ម (30ម ពីទុយោបាញ់ទឹក) ដែលមានទិសដៅ ធ្វើដំណើរតែមួយគត់គឺអាចធ្វើទៅបាន (ផ្លូវទូទៅ) មុនពេលការបង្វែរទៅផ្លូវជំនួស*
ការជម្លៀសខ្លួនចេញពីឡៅតឿ	*ច្រកចេញមួយ ឬច្រើនចេញពីឡៅតឿ និងចម្ងាយផ្លូវធម្មតានៅលើឡៅតឿ។ សូមគិតអំពីចម្ងាយផ្លូវសរុបពីឡៅតឿទៅកាន់ច្រកចេញតាមជាន់។*

ផ្លូវជម្លៀសខ្លួនទៅកាន់ច្រកចេញតាមជាន់

គោលបំណងនៃផ្នែកនេះគឺដើម្បីកត់ត្រាស្ថានភាពនៃផ្លូវជម្លៀសតាមខ្សែផ្តេកពីគ្រប់ចំណុចទាំងអស់នៅតាមជាន់រហូតដល់ច្រកចេញពីជាន់នោះ។

ជាទូទៅ គឺមិនចាំបាច់កត់ត្រាទិន្នន័យនេះតាមជាន់នីមួយៗសម្រាប់ផ្នែកខាងក្រោមនោះទេ ប៉ុន្តែប្រសិនបើនៅពេលសង្កេត គេបានកត់សម្គាល់ឃើញថាការកត់ត្រានេះអាចអនុវត្តបានចំពោះតំបន់ជាក់លាក់ណាមួយ ឬអគារនោះ ដូច្នេះព័ត៌មានអំពីអគារ/ជាន់/តំបន់នោះគួរតែត្រូវបានកត់ត្រា។

ផ្លូវជម្លៀសខ្លួនដែលមានទំហំគ្រប់គ្រាន់ពីគ្រប់តំបន់ទាំងអស់	*ជាទូទៅ និយាយអំពីច្រកផ្លូវដើរវាងកន្លែងធ្វើការនីមួយៗ។ សូមកត់សម្គាល់ច្រកផ្លូវដើរណាមួយនៅលើផ្លូវជម្លៀសខ្លួនដែលមានទំហំមិន*

	គ្រប់គ្រាន់ (តិចជាង 915មម)
ពីផ្លូវទាល់ទៅកាន់ផ្លូវដើរ ឬច្រកតូចៗឆ្ងាយពេក	*កត់ត្រាថាតើមានផ្លូវទាល់ដែលលើសពី 15ម ឬទេ*
ផ្លូវដើរត្រូវបានបញ្ជាក់យ៉ាងច្បាស់នៅតាមជាន់	*លក្ខខណ្ឌនៃការដាក់ស្លាកសញ្ញាតាមជាន់*
ផ្លូវជម្លៀសខ្លួន ដែលពុំមានវត្ថុរាំងស្ទះដែលអាចផ្លាស់ទីបាន	*សំដៅទៅលើការទុកដាក់ដែលមិនអាចគ្រប់គ្រងបាន កន្លែងធ្វើការដែលលយចូលច្រកផ្លូវដើរ ឬរបស់របរផ្សេងទៀតដែលអាច ដោះស្រាយបានតាមរយៈការរៀបចំឱ្យមានរបៀបរៀបរយជាងមុន*
ផ្លូវជម្លៀសខ្លួនដែលពុំមានវត្ថុរាំងស្ទះដែលមិនអាចផ្លាស់ទីបាន	*វត្ថុរាំងស្ទះដែលមិនអាចផ្លាស់ទីបានមានដូចជាសរសេរ គ្រឿងចក្រ គ្រឿងសង្ហារិមធំៗដែលកាត់បន្ថយទំហំច្រកផ្លូវទៅតិចជាងកម្រិតអនុញ្ញាត*
ទ្វារនៅតាមច្រកចេញបើកបិទបានត្រឹមត្រូវស្របតាមទិសដៅធ្វើដំណើរ	*ទ្វាររវាងចំណុចណាមួយនៅតាមជាន់ និងច្រកចេញតាមជាន់ (ទ្វារច្រកចេញតាមជាន់ នឹងរៀបរាប់នៅពេលក្រោយ)*
ទ្វារនៅតាមផ្លូវចេញអាចបើកបានយ៉ាងងាយស្រួល គ្មានឧបករណ៍ចាក់សោ	*ប្រសិនបើមានឧបករណ៍ចាក់សោ ទ្វារនោះត្រូវតែឧបករណ៍ដោះសោ ដើម្បីអាចបើកបានស្របតាមទិសដៅធ្វើដំណើរ។*

ស្លាកសញ្ញាច្រកចេញ

ផ្នែកនេះ និយាយអំពីស្លាកសញ្ញាដែលបានផ្តល់ជូន ដើម្បីបង្ហាញផ្លូវទៅច្រកចេញតាមជាន់ពីគ្រប់ចំណុចទាំងអស់នៅក្នុងជាន់នោះ។

ស្លាកសញ្ញាតាមជាន់បង្ហាញយ៉ាងច្បាស់អំពីផ្លូវជម្លៀសខ្លួនទាំងអស់	*តើមានស្លាកសញ្ញាតាមជាន់ដែរឬទេ និងលក្ខខណ្ឌនៃការដាក់ស្លាកសញ្ញា*
ផ្លូវជម្លៀសខ្លួនត្រូវបានបិទស្លាកសញ្ញាបានយ៉ាងត្រឹមត្រូវ	*តើស្លាកសញ្ញាដែលបានផ្តល់ជូននេះ បាននាំមនុស្សទៅរកច្រកចេញបានត្រឹមត្រូវដែរឬទេ?* *តើមានស្លាកសញ្ញានៅខាងលើដែលបានផ្តល់ជូននៅខាងចុង ដែលបង្ហាញអំពីការផ្លាស់ប្តូរទិសដៅដែរឬទេ (ជាធម្មតានៅខាងចុងផ្លូវដើរ ចន្លោះកន្លែងធ្វើការងារ)?*
ស្លាកសញ្ញាច្រកចេញមានភ្លើងបំភ្លឺនៅគ្រប់ច្រកចេញពេលមានអាសន្នទាំងអស់	*ស្លាកសញ្ញាច្រកចេញនៅខាងលើច្រកទ្វារ ចេញតាមជាន់ទាំងអស់។ សូមផ្តល់យោបល់ទៅលើទំហំស្លាកសញ្ញាទាំងនេះ ថាតើវាស័ក្តិសមនឹងទំហំដែរ*

	ឬទេ?
ស្លាកសញ្ញាដូចៗគ្នានៅតាមផ្លូវចេញទាំងអស់	*តើស្លាកសញ្ញាមានភាពត្រឹមត្រូវទៅតាមជាន់ណាមួយ និងនៅទូទាំងអគារទាំងមូលឬទេ*

ទ្វារច្រកចេញតាមជាន់

ផ្នែកនេះ រៀបរាប់អំពីទ្វារទៅកាន់ច្រកចេញតាមជាន់ ដែលជាទ្វារដែលនាំទៅដល់ជណ្តើរច្រកតូចៗដែលមានការការពារ ឬផ្លូវដម្រាលដែលប្រើសម្រាប់ជាផ្លូវចេញពីជាន់ខ្ពស់ៗ។
ផ្នែកនេះ មានគោលបំណងពិនិត្យមើលគ្រប់ទ្វារច្រកចេញតាមជាន់ទាំងអស់នៅជាន់ខាងលើ។ នៅជាន់ផ្ទាល់ដី ទ្វារទាំងនេះអាចជាទ្វារច្រកចេញចុងក្រោយ ដែលយើងនឹងលើកឡើងនៅផ្នែកពេលក្រោយៗ។

ច្រកចេញតាមជាន់មានទំហំទ្វារ និងកម្ពស់គ្រប់គ្រាន់	*ការផ្តល់មតិយោបល់ទៅលើទំហំ គឺត្រូវ ផ្អែកលើទិន្នន័យទំហំអាចចូលបានរបស់ទ្វារដែលបានរៀបចំទុកមុន។ ប្រសិនបើត្រូវកត់ត្រាទំហំទ្វារផ្សេងទៀត សូមកត់សម្គាល់នៅទីនេះ*
ទ្វារនៅតាមច្រកចេញបើកបិទបានត្រឹមត្រូវស្របតាមទិសដៅធ្វើដំណើរ	*ទ្វារយោលចំហៀង ឬប្រភេទផ្សេងទៀត (ទ្វាររុញបើកបិទ ជាដើម)*
ទ្វារនៅតាមផ្លូវចេញអាចបើកបានយ៉ាងងាយស្រួល គ្មានឧបករណ៍ចាក់សោ	*តើទ្វារអាចនឹងជាប់សោដែរឬទេ ប្រសិនបើជាប់ តើទ្វានោះមានបំពាក់ឧបករណ៍ដោះសោរពីខាងក្នុងទេ?*

ជណ្តើរច្រកចេញ

របាយការណ៍នេះវាយតម្លៃទៅលើសមាសធាតុទី 2 ដែលជាផ្នែកបញ្ឈរនៃផ្លូវជម្លៀសខ្លួន ដែលជាទូទៅរួមមានទាំងជណ្តើរជើងផងដែរ៖

តើជណ្តើរមានទំហំគ្រប់គ្រាន់ទេ	*ការផ្តល់មតិយោបល់ទៅលើទំហំ គឺត្រូវ ផ្អែកលើទិន្នន័យសមត្ថភាពទ្វារដែលបានធ្វើតារាងមុននេះ។ ប្រសិនបើត្រូវកត់ត្រាទំហំទ្វារផ្សេងទៀត សូមកត់សម្គាល់នៅទីនេះ*
បាតកាំជណ្តើរ/កាំជណ្តើរបញ្ឈរស្របនិងមិនចោតពេក	*កត់ត្រានៅទីនេះ ប្រសិនបើមានភាពខុសប្លែកគ្នាគួរឱ្យកត់សម្គាល់នៅក្នុងកាំណាមួយ និងថាតើបាតកាំជណ្តើរ/កាំជណ្តើរបញ្ឈរធ្វើឱ្យជណ្តើរចោតពេកទេ (ធំជាង 45°)*

បង្កាន់ដៃ មានផ្តល់ជូនទាំងសងខាងនៅតាមជណ្តើរទាំងអស់	*កត់ត្រាថាតើមានផ្តល់ជូនឬអត់*
ជណ្តើរដែលជាប់ដោយផ្ទាល់ទៅកាន់បរិវេណខាងក្រៅដែលមានកម្ពស់ដែលអាចចេញបាន	*ត្រូវកត់ត្រាថាតើមានជណ្តើរចេញនៅខាងក្នុងឬអត់។ ប្រសិនបើជណ្តើរចេញទៅក្នុងតំបន់គ្របដណ្តប់ ដែលអាចរងផលប៉ះពាល់ដោយអគ្គិភ័យ/ផ្សែងនៅខាងក្នុងអគារ ដោយមិនអាចនាំចេញទៅខាងក្រៅបាន ហើយចំណុចនេះគួរតែកត់ត្រាចូល*
ចំនួនជណ្តើរចេញនៅក្នុងអគារ ចម្ងាយដែលមិនមានការការពារពីច្រកចេញចុងក្រោយ	*ចំនួនជណ្តើរដែលចេញទៅកន្លែងស្នាក់នៅនៅជាន់ផ្ទាល់ដី (អនុញ្ញាតឱ្យមានការចេញរហូតដល់ 50% ក្រោមលក្ខខណ្ឌជាក់លាក់)។ ប្រសិនបើអនុញ្ញាតឱ្យនៅខាងក្នុង សូមកត់ត្រាអំពីការប្រើប្រាស់តំបន់ និងចម្ងាយទៅកាន់ច្រកចេញចុងក្រោយ។*
ជណ្តើរខាងក្នុងនាំទៅរកច្រកតូចៗដែលមានការការពារត្រឹមត្រូវ	*កត់ត្រាថាតើជណ្តើរទៅកាន់ច្រកចេញខាងក្នុងចូលទៅក្នុងតំបន់ការពារមុននឹងចេញទៅខាងក្រៅឬទេ*

ច្រកចេញចុងក្រោយ

សមាសធាតុចុងក្រោយនៃមធ្យោបាយជម្លៀសខ្លួនគឺជាច្រកចេញចុងក្រោយទៅកាន់បរិវេណខាងក្រៅ។ ផ្នែកនេះ គឺបែងចែកដាច់ដោយឡែកពីផ្នែកច្រកចេញតាមជាន់ ពីព្រោះទោះបីជាមានបញ្ហាទូទៅដូចគ្នាជាច្រើនក៏ដោយ ប៉ុន្តែលក្ខខណ្ឌ និងតម្រូវការគឺខុសគ្នាៗ។

ទ្វារច្រកចេញចុងក្រោយអាចបើកបិទបានត្រឹមត្រូវស្របតាមទិសដៅធ្វើដំណើរ	*ទ្វារយោលចំហៀង ឬប្រភេទផ្សេងទៀត (រំអិលបើកបិទ ជាដើម)*
ទ្វារច្រកចេញចុងក្រោយអាចបើកបានយ៉ាងងាយស្រួលពីខាងក្នុង លុបលើឧបករណ៍ចាក់សោសុវត្ថិភាពនានា	*តើទ្វារអាចនឹងជាប់សោដែរឬទេ ប្រសិនបើជាប់ តើទ្វានោះមានបំពាក់ឧបករណ៍ចាក់សោរពីខាងក្នុងទេ?* *ជាទូទៅ នៅជាន់ផ្ទាល់ដី ត្រូវមានលក្ខខណ្ឌតម្រូវសន្តិសុខសម្រាប់ទ្វារដែលអាចចាក់សោបាន ដូច្នេះរបាររុញ ឬការរៀបចំស្រដៀងគ្នាគឺត្រូវការជាចាំបាច់ ដើម្បីដោះសោពីខាងក្នុង។*
ទ្វារច្រកចេញចុងក្រោយបើកចេញទៅខាងក្រៅ	*ស្រដៀងទៅនឹងអ្វីដែលបានលើកឡើងសម្រាប់ទ្វារជណ្តើរដែរ តើច្រកចេញនាំទៅខាងក្រៅ ឬចូលទៅក្នុងតំបន់គ្របដណ្តប់ដែលអាចរងផល*

	ប៉ះពាល់ដោយអគ្គិភ័យ/ផ្សែងនៅខាងក្នុងកន្លែងស្នាក់នៅដែរឬទេ
ពីទ្វារច្រកចេញចុងក្រោយ តើមនុស្សអាចផ្លាស់ទីដោយសុវត្ថិភាពចេញពីអគារបានដែរឬទេ	*តើមនុស្សអាចផ្លាស់ទីដោយផ្ទាល់ចេញពីអគារដែលប្រឈមនឹងភ្លើងឆេះ ឬតើទ្វារនេះនាំចូលទៅក្នុងកន្លែងបិទជិត ដូចជាច្រកតូចបើកចំហ ឬផ្លូវដើរដែលនាំមនុស្សនៅជិត (ក្រោម 3ម) ទៅកាន់ខាងមុខអគារ សម្រាប់ចម្ងាយខ្លះក្នុងចម្ងាយណាមួយមុនពេលដែលពួកគេអាចផ្លាស់ទីឆ្ងាយពីអគារបានទេ។*
ការការពារផ្លូវជម្លៀសខ្លួនទៅខាងក្រៅត្រូវតែមាន	*ប្រសិនបើផ្លូវជម្លៀសខ្លួនចេញនៅខាងក្រៅអាចឱ្យមនុស្សស្ថិតនៅជិតគ្នាក្នុងចន្លោះ 3ម នៃបរិវេណមុខអគារ តើមានរនាំងខាងមុខដែលគេវាយតម្លៃថាមានភ្លើងឆេះ ឬមានរនាំងខាងមុខដែលមិនការពារនៅតាមផ្លូវ?*

8.3.5.3 សុវត្ថិភាពអគ្គិភ័យនៅក្នុងការសាងសង់

គោលបំណងនៃផ្នែកនេះ គឺដើម្បីកំណត់អំពីលក្ខខណ្ឌតម្រូវនៃការសាងសង់សម្រាប់ការការពារកម្រិតអគ្គិភ័យនៃផ្លូវជម្លៀសខ្លួន ការបែងចែកជាផ្នែកដើម្បីកំណត់ទំហំនៃអគ្គិភ័យ និងការបំបែកតំបន់ដែលមានហានិភ័យខ្ពស់ពីកន្លែងប្រើប្រាស់ផ្សេងទៀត។

ការការពារប្រឡោះបញ្ឈរ

ប្រភេទទូទៅបំផុតនៃប្រឡោះបញ្ឈរ ដែលត្រូវវាយតម្លៃគឺប្រឡោះបញ្ឈររវាងជាន់ដើម្បីដាក់ជណ្តើរជណ្តើរយន្ត ឬបំពង់សំរាម។

ជណ្តើរដែលភ្ជាប់លើសពី 2 ជាន់ត្រូវតែការពារជា "កន្លែងសុវត្ថិភាពដែលទាក់ទង" នៅក្នុងធាតុផ្សំបញ្ឈរនៃមធ្យោបាយនៃការរត់ជម្លៀសខ្លួន។

ការបិទជណ្តើរខាងក្នុងដែលភ្ជាប់ជាមួយអគារលើសពី 2 ជាន់	***បង្ហាញ****អំពីជណ្តើរណាដែលពាក់ព័ន្ធ និងវិសាលភាពនៃការបិទជិតជាមួយនឹងការសាងសង់សំណង់ដែលមានការការពារគ្រោះអគ្គិភ័យ។*
ទ្វារបិទដោយខ្លួនឯងទៅកាន់ជណ្តើរដែលមានការការពារ	*ទ្វារចូលទៅក្នុងបន្ទប់ជណ្តើរត្រូវតែជាទ្វារដែលមានការការពារពីគ្រោះអគ្គិភ័យ បើកទៅទិសដៅធ្វើដំណើរ និងមានឧបករណ៍បិទទ្វារដោយខ្លួនឯង។ កន្លែងណាដែលគ្មានការបិទជិត នោះនឹងគ្មានទ្វារទេ។ សម្រាប់ការបិទជិតដែលមានស្រាប់ ត្រូវកត់ត្រាទិន្នន័យនោះ។*

ការជ្រៀតចូលតាមសៀលនៅក្នុងជណ្តើរដែលមានការការពារ	*នៅកន្លែងដែលមានការបិទជិតដែលមានស្រាប់សមាសធាតុនេះ បញ្ជាក់អំពីស្ថានភាពនៃការបើកចំហ តាមរយៈជញ្ជាំងបិទជិតសម្រាប់បំពង់ខ្សែភ្លើងអគ្គិសនី ឬការជ្រៀតចូលផ្សេងទៀត។ តើប្រឡោះទាំងនេះត្រូវបានបិទជិតយ៉ាងត្រឹមត្រូវជុំវិញផលិតផលការពារគ្រោះអគ្គិភ័យគ្រប់គ្រាន់ដែរឬទេ?*
ការការពារជណ្តើរខាងក្រៅពីអគ្គិភ័យនៅខាងក្នុង	*ជណ្តើរខាងក្រៅក៏ត្រូវការការការពារពីគ្រោះអគ្គិភ័យនៅខាងក្នុងអគារផងដែរ។ សូមកត់សម្គាល់ប្រឡោះចំហណាមួយនៅក្នុងជញ្ជាំងខាងក្រៅដែលមានចម្ងាយ 3 ម៉ែត្រពីជណ្តើរខាងក្រៅរហូតដល់ជាន់ផ្ទាល់ដី។ ទ្វារទៅកាន់ជណ្តើរទាំងនេះក៏ត្រូវការការពារអគ្គិភ័យ និងការបិទដោយខ្លួនឯងផងដែរ។*
រនាំងការពារបង្គោលឡើងចុះឆ្លងកាត់តាមជាន់	*បង្គោលសម្រាប់ការតភ្ជាប់ឡើងចុះមានការប្រើប្រាស់ជាទូទៅ ហើយរុំព័ទ្ធដោយជញ្ជាំងការពារភ្លើងឆេះ។ ប្រឡោះច្រកចូលទៅបំពង់បង្គោលទាំងនេះក៏គួរត្រូវការពារពីអគ្គិភ័យផងដែរ។*
រនាំងការពារបង្គោលឡើងចុះឆ្លងកាត់តាមជាន់	*រនាំងការពារបង្គោលឡើងចុះឆ្លងកាត់តាមជាន់ បង្គោលសម្រាប់ការតភ្ជាប់ឡើងចុះមានការប្រើប្រាស់ជាទូទៅ ហើយរុំព័ទ្ធដោយជញ្ជាំងការពារភ្លើងឆេះ។ ប្រឡោះច្រកចូលទៅបំពង់បង្គោលទាំងនេះក៏គួរត្រូវការពារពីអគ្គិភ័យផងដែរ។*
ការបែងចែករនាំងជណ្តើរយន្តការពារគ្រោះអគ្គិភ័យ	*រនាំងជណ្តើរយន្តគឺជាការលើកជាខ្សែបញ្ឈរធម្មតាផ្សេងទៀតតាមរយៈជាន់ ហើយចាំបាច់ត្រូវរុំព័ទ្ធដោយសំណង់ដែលប្រព័ន្ធការពារគ្រោះអគ្គិភ័យ*
ការបើកចំហជាខ្សែបញ្ឈរផ្សេងទៀតតាមជាន់ក្នុងបន្ទប់	*ការបើកចំហបញ្ឈរផ្សេងទៀតក៏គួរត្រូវកត់សម្គាល់ផងដែរ (កំណាត់សម្លៀកបំពាក់ ។ល។) ក៏ដូចជា កម្រិតនៃការការពារគ្រោះអគ្គិភ័យដើម្បីការពារភ្លើង និងផ្សែងដែលរីករាលដាលតាមរយៈប្រឡោះចំហទាំងនេះ។*

ការពារបន្ទប់ក្រោមដីជាមួយនឹងកន្លែងទទួលភ្ញៀវ FR ជញ្ជាំង និងទ្វារបិទដោយខ្លួនឯង	*ជាន់ក្រោមដី ចាំបាច់ត្រូវតែបំបែកចេញពីជាន់ផ្ទាល់ដីខាងលើដែលមានការសាងសង់ប្រព័ន្ធការពារគ្រោះអគ្គិភ័យ និងកន្លែងទទួលភ្ញៀវដល់ជណ្តើរបើកចំហដោយមិនគិតពីកម្ពស់អគារឡើយ។*

ការបែកចែងការប្រើប្រាស់

ប្រភេទនៃការប្រើប្រាស់សំខាន់នៃអគារត្រូវបានកំណត់នៅក្នុងផ្នែក 8.3.3.1 ខាងលើ។ កន្លែងដែលមានការប្រើប្រាស់ផ្សេងទៀត ដូចជាការិយាល័យ ឬកន្លែងទទួលទានអាហារ និងកន្លែងដែលត្រូវតាមលក្ខខណ្ឌតម្រូវសម្រាប់ "ការប្រើប្រាស់មានគ្រោះថ្នាក់" ទេ ត្រូវដាក់បញ្ចូលនៅទីនេះ។ បរិវេណឃ្លាំង ត្រូវរៀបចំដាច់ដោយឡែកនៅក្នុងផ្នែកបន្ទាប់។

ការប្រើប្រាស់ទីធ្លាដែលមានផ្ទៃធំពេកដែលអាចចាត់ទុកថាជា "ការប្រើប្រាស់មានគ្រោះថ្នាក់"	*កំណត់ថាតើមានតំបន់ប្រើប្រាស់ណាមួយនៅលើជាន់ផលិតកម្ម ដែលដោយសារតែការប្រើប្រាស់និងផ្នែកនៃតំបន់នោះ មិនអាចចាត់ទុកថាជា "ការប្រើប្រាស់មានគ្រោះថ្នាក់" បាន។ តំបន់បែបនេះនឹងត្រូវបំបែកចេញពីកន្លែងកាន់កាប់សំខាន់ជាមួយនឹងសំណង់ដែលមានប្រព័ន្ធការពារអគ្គិភ័យ។*
ជញ្ជាំងញែកការពារគ្រោះអគ្គិភ័យ	*បញ្ជាក់ថាតើការប្រើប្រាស់តាមការកាន់កាប់ផ្សេងទៀតត្រូវបានបំបែកចេញពីកន្លែងប្រើប្រាស់សំខាន់ដោយសំណង់ដែលមានការការពារគ្រោះអគ្គិភ័យដែរឬទេ*
ការជ្រៀតចូលតាមជញ្ជាំងខណ្ឌ	*ជាកន្លែងមានប្រព័ន្ធការពារគ្រោះអគ្គិភ័យ ត្រូវបានផ្តល់ជូនរវាងកន្លែងប្រើប្រាស់ ត្រូវកំណត់រកការជ្រៀតចូលតាមជញ្ជាំងខណ្ឌទាំងនេះ (ទ្វារ បង្ហួច បំពង់បង្ហូរ គម្លាតរវាងខាងលើជញ្ជាំង និងពិតាន។ ល។) និងបញ្ជាក់ពីថាតើជ្រៀតចូលតាមរបៀបណា?*

បរិវេណឃ្លាំង

បរិវេណឃ្លាំងគឺមានច្រើននៅក្នុងរោងចក្រកាត់ដេរ សំលៀកបំពាក់ ស្បែកជើង កាបូប និងគ្រឿងបន្ទាប់បន្សំ និងមានភាពខុសៗគ្នា ដើម្បីផ្តល់នូវវិធីសាស្ត្រដែលមានភាពបត់បែនបានបន្ថែមទៀត

ដើម្បីជួយសម្រួលដល់ដំណើរការផលិត និងបង្កើនចំនួនអតិបរមានៃទំហំផ្ទុកដែលមិនអាចបំបែកបានដែលបានអនុញ្ញាតនៅក្នុងអគារដែលមានស្រាប់។
ផ្នែកនេះរៀបរាប់តែអំពីឃ្លាំងស្តុកទុកប៉ុណ្ណោះ ដែលជាធម្មតាប្រើប្រាស់ជាប់អគារសំខាន់ៗ និងកន្លែងផ្ទុកបណ្តោះអាសន្ន ឬ "កំពុងដំណើរការ" ដែលត្រូវបានចែកចាយច្រើនជាងនៅជាន់ផលិតកម្ម។
មានកត្តាជាច្រើនដែលជះឥទ្ធិពលដល់បរិមាណនៃការផ្ទុកដែលអាចដាក់បាននៅក្នុងតំបន់ជាក់លាក់ណាមួយ ហើយតារាងខាងក្រោមនេះមានន័យព័ត៌មានដែលត្រូវការដើម្បីណែនាំអ្នកវាយតម្លៃថាតើវិធានការដោះស្រាយអាចនឹងមានភាពចាំបាច់ឬអត់៖

ទីតាំងឃ្លាំង	**ទំហំឃ្លាំងផ្ទុកប្រហាក់ប្រហែល ($м^2$)**	**ផ្ទៃក្រឡាជាន់សរុប ($м^2$)**	**បន្ទប់ចិទជិត** FR	**ជាន់ដែលមានប្រព័ន្ធបាញ់ទឹក**
អគារ			*មាន/មិនមាន*	*មាន/មិនមាន*
ជាន់ - ទីតាំង			*មាន/មិនមាន*	*មាន/មិនមាន*

ឃ្លាំងដែលកំពុងប្រើប្រាស់ ឬឃ្លាំងបណ្តោះអាសន្នអាចបើកចំហបាននៅក្នុងជាន់ផលិតកម្ម ប៉ុន្តែត្រូវការដាក់កំហិតទៅលើបរិមាណនៃការផ្ទុកនៅក្នុងតំបន់ណាមួយ។ ប្រសិនបើកំណត់រកឃើញនូវឃ្លាំងដែលកំពុងប្រើប្រាស់ដែលមិនត្រូវតាមលក្ខខណ្ឌតម្រូវការទាំងនេះទេ ប៉ុន្តែប្រសិនបើកន្លែងនោះអ្នកវាយតម្លៃវាសរែងទៅយល់ឃើញថាអាចអនុវត្តបាន ដើម្បីអនុលោម និងជៀសវាងការរុំព័ទ្ធដោយការសាងសងប្រព័ន្ធការពារគ្រោះអគ្គិភ័យ ការពិពណ៌នាអំពីករណីទាំងនេះគួរតែត្រូវបានកត់ត្រាបញ្ចូលទៅក្នុងតារាងខាងក្រោម៖

ទីតាំង	**ការពិពណ៌នា**
អគារ	
ជាន់ - ទីតាំង	*ឧ. "កំពុងដំណើរការ" ចម្ងាយឃ្លាំងលើសពី 232 នៅក្នុងតំបន់ដែលមិនមានប្រព័ន្ធបាញ់ទឹកអមតាមផ្លូវតូចទៅកាន់ផ្នែកបញ្ចប់នៅផ្នែក* S *នៃជាន់ទី 2 ។ ផ្ទៃក្រឡា ប្រហែល ៦០ $м^2$ ។*

តំបន់ដែលមានហានិភ័យខ្ពស់ផ្សេងទៀត
មានការប្រើប្រាស់ច្រើនដែលទាមទារឱ្យមានការញែកប្រព័ន្ធអគ្គិភ័យចេញពីតំបន់ផលិតកម្ម និងផ្លូវជម្លៀសខ្លួនក្នុងគ្រប់កាល:ទេស:ទាំងអស់។
ប្រសិនប្រព័ន្ធនេះស្ថិតនៅខាងក្នុងអគារ ប្រព័ន្ធនេះត្រូវតែដាក់ក្នុងធុងបន្ទប់ដែលដែលមានប្រព័ន្ធ

ការពារអគ្គិភ័យជិត ប្រសិនបើស្ថិតនៅខាងក្នុងអគារ នោះប្រព័ន្ធការពារគ្រោះអគ្គិភ័យគឺត្រូវការជាចាំបាច់ នៅក្នុងទីតាំងដែលមានទីធ្លាទំនេរយ៉ាងហោចណាស់ 3ម បើកចំហនៅផ្នែកខាងមុខ ឬទំហំនៃផ្លូវជម្លៀសខ្លួនគឺស្រឡះ។
ទិន្នន័យសម្រាប់តំបន់ទាំងនេះត្រូវបានកត់ត្រាក្នុងតារាងខាងក្រោម៖

ការដំឡើង	**ប្រភេទ**	**ទីតាំង**	**ការបំបែកចេញពីតំបន់ផលិតកម្ម**	ការបំបែកចេញពីផ្លូវចេញ
ម៉ាស៊ីនភ្លើង	*អគ្គិសនី ម៉ាស៊ូត ហ្គាស*	*ពិពណ៌នាទីតាំង*	បាទ/ចាស បំបែកដោយរបៀបណា ឬអត់	បាទ/ចាស បំបែកដោយរបៀបណា ឬគ្មាន
ឡចំហាយ	ដូចចំណុចខាងលើ	ដូចចំណុចខាងលើ	ដូចចំណុចខាងលើ	ដូចចំណុចខាងលើ
ត្រង់ស្វូ	ដូចចំណុចខាងលើ	ដូចចំណុចខាងលើ	ដូចចំណុចខាងលើ	ដូចចំណុចខាងលើ
កុំប្រេស័រ	ដូចចំណុចខាងលើ	ដូចចំណុចខាងលើ	ដូចចំណុចខាងលើ	ដូចចំណុចខាងលើ
ឃ្លាំងផ្ទុកសារធាតុគីមី	ដូចចំណុចខាងលើ	ដូចចំណុចខាងលើ	ដូចចំណុចខាងលើ	ដូចចំណុចខាងលើ
ផ្សេងទៀត	ដូចចំណុចខាងលើ	ដូចចំណុចខាងលើ	ដូចចំណុចខាងលើ	ដូចចំណុចខាងលើ

ការងារគ្រោង និងការងារបញ្ចប់
ការការពារគ្រោង គឺទាក់ទងច្រើនជាង ប្រើការងារគ្រោងដែក ជាជាងសំណង់បេតុង។

ប្រព័ន្ធការការពារអគ្គិភ័យគ្រោង	*សម្រាប់ការងារគ្រោង* RC *គេបានសន្មត់ថាបេតុងគ្របពីបេតុងអាមេផ្តល់នូវការការពារអគ្គិភ័យគ្រប់គ្រាន់សម្រាប់គ្រោងអគារ។* *សម្រាប់ការងារគ្រោងដែក ត្រូវធ្វើការកំណត់ថាតើប្រព័ន្ធការពារភ្លើងត្រូវបានគេសង្កេតឃើញឬអត់ ហើយប្រភេទណាប្រសិនបើអាចធ្វើទៅបាន*
ការងារបញ្ចប់របស់ជញ្ជាំង	*ជាធម្មតាគឺជាការងាររៀបឥដ្ឋ ម្នាងសិលា/លាបថ្នាំ* *ត្រូវកត់ត្រាថាតើមានការងារបញ្ចប់របសជញ្ជាំងណាមួយហាក់*

	ដូចជាងាយឆាបឆេះ និងមិនឆ្លើយតបទៅនឹងតម្រូវការនៃការរីករាលដាលនៃអគ្គិភ័យ។ ស្តង់ដារ LABS សម្រាប់ការងារបញ្ចប់របស់ជញ្ជាំង
ការងារបញ្ចប់របស់ពិតាន	*ជាធម្មតាគឺជាការងារវៀបឥដ្ឋ ម្នាងសិលា/លាបថ្នាំ* *ត្រូវកត់ត្រាថាតើមានការងារបញ្ចប់របសជញ្ជាំងណាមួយហាក់ដូចជាងាយឆាបឆេះ និងមិនឆ្លើយតបទៅនឹងតម្រូវការនៃការរីករាលដាលនៃអគ្គិភ័យ។ ស្តង់ដារ LABS សម្រាប់ការងារបញ្ចប់របស់ជញ្ជាំង*

8.3.5.4 ប្រព័ន្ធសុវត្ថិភាពអគ្គិភ័យ

នៅក្នុងរបាយការណ៍ស្តីពីសុវត្ថិភាពអគ្គិភ័យ ប្រភេទ និងវិសាលភាពនៃប្រព័ន្ធចាប់សញ្ញា និងផ្តល់សញ្ញាត្រូវបានកត់ត្រា។ ព័ត៌មានលម្អិតបន្ថែមអំពីប្រព័ន្ធខ្សែភ្លើង និងការផ្គត់ផ្គង់ថាមពលបម្រុងមានបង្ហាញជូននៅក្នុងរបាយការណ៍អគ្គិសនី។
គួរកត់សម្គាល់អំពីការប្រែប្រួលនៅតាមអគារ ជាន់ ឬបរិវេណផ្សេងៗគ្នា៖

ប្រភេទចាប់សញ្ញាអគ្គិភ័យ	*ប្រភេទទូទៅដែលកត់សម្គាល់នៅក្នុងផ្នែកនេះអាចជាឧបករណ៍ចាប់សញ្ញា (ប្រើថ្ម) ឧបករណ៍ចាប់សញ្ញាផ្សែង ឧបករណ៍ចាប់សញ្ញាកាំពន្លឺ ឧបករណ៍ចាប់សញ្ញាកម្តៅជាដើម។*
វិសាលភាពចាប់សញ្ញាអគ្គិភ័យ	*តើឧបករណ៍ចាប់សញ្ញាមានវិសាលភាពគ្រប់គ្រាន់ស្របតាមលក្ខខណ្ឌគម្លាតស្តង់ដារ LABS ដែរឬទេ? សូមពិនិត្យថាតើការចាប់សញ្ញាមាននៅក្នុងកន្លែងបិទជិតក្នុងបរិវេណជាន់ធំដែរឬទេ។*
ប្រភេទឧបករណ៍ផ្តល់សញ្ញាអគ្គិភ័យ	*ប្រភេទទូទៅដែលត្រូវកត់សម្គាល់នៅក្នុងផ្នែកនេះអាចជាសំឡេង សំឡេងដែលមានរូបភាព ការផ្តល់សញ្ញាជាសំឡេង។*
វិសាលភាពឧបករណ៍ផ្តល់សញ្ញាអគ្គិភ័យ	*តើការផ្តល់សញ្ញាមានវិសាលភាពគ្រប់គ្រាន់ស្របតាមលក្ខខណ្ឌគម្លាតស្តង់ដារ LABS ដែរឬទេ? ដោយផ្អែកលើការធ្វើតេស្តដែលបានធ្វើឡើងទៅលើប្រព័ន្ធ សូមផ្តល់មតិយោបល់ទៅលើកម្រិតសំឡេង*

	នៅក្នុងបរិវេណដែលបានសាកល្បង។ តើមានបរិវេណបិទជិត ឬបរិវេណដែលមានសំឡេងរំខានពីក្រៅខ្ពស់ ដែលតម្រូវឱ្យមានឧបករណ៍ផ្តល់សញ្ញាបន្ថែមដែរឬទេ?
ថាមពលបម្រុងសម្រាប់ឧបករណ៍ចាប់សញ្ញាអគ្គិភ័យ និងការផ្តល់សញ្ញា	*សូមបញ្ជាក់អំពីចំណុចដែលបានដឹងនៅក្នុងអំឡុងពេលវាយតម្លៃ សូមមើលរបាយការណ៍អគ្គិសនីសម្រាប់ព័ត៌មានលម្អិតបន្ថែម*
ការបំពាក់ភ្លើងអាសន្ននៅច្រកចេញ	*សូមកត់ត្រាថាតើ ច្រកចេញតាមជាន់ និងច្រកចេញចុងក្រោយមានបំពាក់ភ្លើងអាសន្នបំភ្លឺផ្លូវ នៅជិតច្រកចេញដែរឬទេ។*
ភ្លើងអាសន្ននៅផ្លូវជម្លៀសខ្លួន	*មតិយោបល់អំពីការចែកចាយភ្លើងអាសន្នពីចម្ងាយពីច្រកចេញ រួចបញ្ជាក់ថាតើការចែកចាយមើលទៅគ្រប់គ្រាន់សម្រាប់ផ្តល់ពន្លឺគ្រប់គ្រាន់នៅគ្រប់ផ្នែកនៃផ្លូវជម្លៀសខ្លួនដែរឬទេ។* *ការធ្វើតេស្តភ្លើងអាសន្ននឹងត្រូវអនុវត្ត ប៉ុន្តែ មិនផ្តល់ព័ត៌មានគ្រប់គ្រាន់អំពីកម្រិត lux ឡើយ*
ថាមពលបម្រុងសម្រាប់ភ្លើងអាសន្ន	*សូមលើកឡើងអំពីចំណុចដែលបានដឹងនៅក្នុងពេលវាយតម្លៃ សូមមើលរបាយការណ៍អគ្គិសនីសម្រាប់ព័ត៌មានលម្អិតបន្ថែម*

8.3.5.5 វិធានស្តីពីការពន្លត់អគ្គិភ័យ

ផ្គត់ផ្គង់ទឹក		*បណ្តាញរបស់សាលាក្រុង ការផ្ទុកនៅហ្នឹងកន្លែង ឬទាំងពីរ។* ***តើទំហំផ្ទុកត្រូវបានកាត់បន្ថយដោយអាស្រ័យលើការផ្គត់ផ្គង់ដោយ***

		សាលាក្រុងដែលបានធានា ឬការផ្គត់ផ្គង់សាលាក្រុងត្រូវបានប្រើប្រាស់សម្រាប់តែការពង្រីកកន្លែងផ្ទុក?
ការស្តុកទឹក		*សូមកំណត់បរិមាណទឹកសម្រាប់ពន្លត់អគ្គិភ័យដែលបានរក្សាទុកនៅនឹងកន្លែង និងទីតាំងផ្ទុក* *នៅកន្លែងដែលមានកម្ពស់ដី ក៏ដូចជាការផ្ទុកកម្រិតដំបូល ត្រូវផ្តល់បរិមាណដែលមាននៅជាប់ដំបូល។* ***ប្រព័ន្ធបំពង់ពន្លត់អគ្គិភ័យត្រូវបានចាត់ទុកជាផ្នែកមួយនៃប្រព័ន្ធសុវត្ថិភាពអាយុជីវិត ដូច្នេះហើយអ្នកវាយតម្លៃត្រូវកំណត់ថាតើមានទឹកគ្រប់គ្រាន់ (ជាមួយនឹងឧបករណ៍បូមដែលពាក់ព័ន្ធ) សម្រាប់ប្រព័ន្ធនេះដែរឬទេ***
ម៉ូទ័របូមទឹកពន្លត់អគ្គិភ័យ	**ប្រភេទ**	*សូមបញ្ជាក់អំពីប្រភេទម៉ូទ័របូមដែលបានផ្តល់ជូន៖* - *ដើម្បីឱ្យទឹកឡើងដល់កម្រិតគ្រប់គ្រាន់* - *ម៉ាស៊ីនជំនួយបូមទឹក ឬដើម្បីរក្សាសម្ពាធនៅក្នុង* ***ក្បាលបូមទឹក បំពង់ទុយោ និងប្រព័ន្ធបាញ់ទឹក (ប្រសិនបើមានដំឡើង)***
	សមត្ថភាព	***- កត់ត្រាសមត្ថភាពម៉ូទ័របូម; លំហូរ (lpm) និងសម្ពាធ (kPa)***
	បម្រុងទុក	*បញ្ជាក់អំពីចំណុចដែលបានដឹងក្នុងអំឡុងពេលវាយតម្លៃម៉ូទ័របូមបម្រុង នៅកម្ពស់ទាប និងខ្ពស់* ***យោងទៅរបាយការណ៍អគ្គិសនីសម្រាប់ព័ត៌មានលម្អិតអំពីខ្សែភ្លើងអគ្គិភ័យ ការបើកដំណើរការម៉ូទ័របូម***
ក្បាលបូមទឹក		*សំដៅដល់កន្លែងបូមទឹកខាងក្រៅនៅលើដី និងកន្លែងបញ្ចេញទឹកសម្រាប់ក្បាលបូមទឹកនៅខាងក្នុងអគារ ជាទូទៅនៅជិតច្រកចេញ ឬជណ្តើរ នៅកន្លែងរាបស្មើត្រង់ជណ្តើរបត់ ឬកន្លែងរាបស្មើត្រង់ពាក់កណ្តាលជណ្តើរបត់។*

		សូមបញ្ជាក់អំពីទីតាំង និងទំហំប្រហាក់ប្រហែល (ជាទូទៅ-75mm) តើទីតាំងទាំងនេះមើលទៅមានភាពគ្រប់គ្រាន់សម្រាប់ប្រើប្រាស់ក្នុងអគារទាំងមូលដែរឬទេ?
ក្បាលបាញ់ពន្លត់អគ្គិភ័យ		*ក្បាលបាញ់ពន្លត់អគ្គិភ័យគួរដាក់ភ្ជាប់ជាមួយបណ្តាញផ្គត់ផ្គង់ទឹកនិងស្ថិតនៅក្រោមសម្ពាធ។ សូមសាកល្បង និងពិនិត្យមើលអំណានសម្ពាធនៅលើប្រព័ន្ធ* *សូមបញ្ជាក់អំពីទីតាំង និងប្រវែងអង្កត់ផ្ចិតប្រហាក់ប្រហែល* *បំពង់ពន្លត់អគ្គិភ័យត្រូវបានចាត់ទុកជាផ្នែកមួយនៃវិធានការសុវត្ថិភាពអាយុជីវិត ដូច្នេះបំពង់ទាំងនេះគួរតែត្រូវបានភ្ជាប់ទៅប្រព័ន្ធដែលមានការផ្គត់ផ្គង់ម៉ូទ័របូមឈរ។* *សូមបញ្ជាក់អំពីចំណុចដែលបានដឹងនៅក្នុងអំឡុងពេលវាយតម្លៃ* *សូមមើលរបាយការណ៍អគ្គិសនីសម្រាប់ព័ត៌មានលម្អិតបន្ថែម* ***អំពីការរៀបចំបណ្តាញខ្សែភ្លើង ម៉ូទ័របូមទឹកបម្រុង***
បំពង់កាន់បាញ់ពន្លត់អគ្គិភ័យ (HHFE)		*សូមបញ្ជាក់ប្រភេទឧបករណ៍ពន្លត់អគ្គិភ័យដែលបានសង្កេតឃើញ និងថាតើស្លាកបង្ហាញអំពីកាលបរិច្ឆេទថែទាំថ្មីៗនៃការវាយតម្លៃដែរឬទេ។ សូមមតិយោបល់អំពីការចែកចាយឧបករណ៍ពន្លត់អគ្គិភ័យដែលបានសង្កេតឃើញ និងបញ្ជាក់ថាតើការចែកចាយមើលទៅគ្រប់គ្រាន់ដែលស្របតាមលក្ខខណ្ឌស្តង់ដារ LABS ពាក់ព័ន្ធនឹងវិសាលភាពបំពង់ពន្លត់អគ្គិភ័យដែរឬទេ*
ប្រព័ន្ធពន្លត់អគ្គិភ័យស្វ័យប្រវត្តិ		*សូមកត់សម្គាល់ប្រភេទ និងទីតាំងប្រព័ន្ធពន្លត់ស្វ័យប្រវត្តិនៅពេលត្រូវបានផ្តល់ជូន សូមបញ្ជាក់ថាតើមានសម្រាប់ជាន់ទាំងមូល ឬមានតែនៅក្នុងផ្នែកខ្លះ។ ប្រសិនបើមានតែនៅក្នុងផ្នែកខ្លះ តើបរិវេណដែលត្រូវបានការពារ ត្រូវបានរៀបចំដាច់ដោយឡែកពីបរិវេណដែលពុំមានការការពារដែលមានការបិទផ្តាច់ចេញពីគ្នាដែលការពារអគ្គិភ័យដែរឬទេ?*
ផ្លូវចូលសម្រាប់រថយន្តពន្លត់		*សូមបញ្ជាក់ផ្លូវចូលបរិវេណសម្រាប់រថយន្តពន្លត់អគ្គិភ័យ។ ផ្លូវចូលដែលមានទទឹង និងកម្ពស់ច្បាស់លាស់គ្រប់គ្រាន់ដើម្បីរថយន្តពន្លត់*

អគ្គិភ័យ		*អគ្គិភ័យអាចចូលបាន* *សូមពិនិត្យមើលថា ចំណុចភ្ជាប់ក្បាលបូមទឹកខាងក្នុងស្ថិតនៅលើដី និងផ្លូវចូលសម្រាប់សេវាពន្លត់អគ្គិភ័យទៅកាន់ចំណុចទាំងនោះ។*

8.3.5.6 ការគ្រប់គ្រង និងការថែទាំ

គោលបំណងនៃផ្នែកនេះ គឺដើម្បីកត់ត្រាថាតើឧបករណ៍នេះមើលទៅមានការរៀបចំបានល្អកម្រិតណា ហើយថាការថែទាំប្រព័ន្ធសុវត្ថិភាពអគ្គិភ័យត្រូវបានអនុវត្តដោយម៉ត់ចត់ឬទេ។

ឯកសារផ្លូវច្បាប់	*គួរកត់សម្គាល់ថាតើពោងចក្រមានអាជ្ញាប័ណ្ណអគ្គិភ័យដែរឬទេ បើទោះបីជាចំណុចនេះអាចមិនឆ្លុះបញ្ចាំងអំពីស្ថានភាពដែលបានសង្កេតឃើញនៃអគារក៏ដោយ។* *នៅក្នុងយុត្តាធិការភាគច្រើន របាយការណ៍នគរបាលអគ្គិភ័យគួរតែបង្ហាញពីការណែនាំសម្រាប់ការកែលម្អប្រព័ន្ធសុវត្ថិភាពអគ្គិភ័យដែលផ្តល់ដោយអាជ្ញាធរដែនដី។*
ផែនការគ្រោះអាសន្ន	*រោងចក្រនីមួយៗគួរមានផែនការគ្រោះអាសន្ន ដែលការទទួលខុសត្រូវសម្រាប់សកម្មភាពផ្សេងៗគ្នាក្នុងករណីមានអាសន្នត្រូវបានបែងចែក។* *ចូលកត់សម្គាល់អំពីចំណុចផ្សេងៗ ដូចជាអត្ថិភាពនៃផែនការគ្រោះអាសន្ននេះ និងថាតើការទទួលខុសត្រូវត្រូវបានបែងចែកដែរឬទេ។* *ស្លាកប្លង់គ្រោះអាសន្នដែលបានបិទនៅច្រកចេញជាន់នីមួយៗក៏អាចលើកឡើងផងដែរ និងព័ត៌មានអំពីផែនការគ្រោះអាសន្នដែលមាននៅលើស្លាកទាំងនេះ ដូចជា (លេខទូរស័ព្ទ អ្នកទទួលខុសត្រូវតាមជាន់នីមួយៗ។ល។*
ការហ្វឹកហាត់ការពន្លត់អគ្គិភ័យ	*ចូរកត់សម្គាល់តើការហ្វឹកហាត់ពន្លត់អគ្គិភ័យត្រូវបានចងក្រងជាឯកសារ បុគ្គលិកណាខ្លះបានចូលរួម និងកាលបរិច្ឆេទនៃការហ្វឹកហាត់អគ្គិភ័យដែលបានកត់ត្រាលើកចុង*

	ក្រោយ
វគ្គបណ្តុះបណ្តាលសុវត្ថិភាពអគ្គិភ័យ	*ចូរកត់សម្គាល់តើការបណ្តុះបណ្តាលអ្វីខ្លះដែល បានផ្តល់ជូនដល់បុគ្គលិកសម្រាប់ការពន្លត់អគ្គិភ័យជំនួយលើកទី 1 ថាតើអ្នកទទួលខុសត្រូវចំពោះសកម្មភាពដែលបានកំណត់នៅក្នុងផែនការគ្រោអាសន្នទទួលបានការបណ្តុះបណ្តាលដើម្បីអនុវត្តសកម្មភាពទាំងនោះដែរឬទេ។*
កំណត់ត្រាថែទាំសម្រាប់ប្រព័ន្ធសុវត្ថិភាពអគ្គិភ័យ	*ការថែទាំ និងកំណត់ត្រាការធ្វើតេស្តនៃប្រព័ន្ធសុវត្ថិភាពអគ្គិភ័យត្រូវកត់សម្គាល់នៅក្នុងផ្នែកនេះសម្រាប់ប្រព័ន្ធខាងក្រោម ក៏ដូចជាកាលបរិច្ឆេទសម្រាប់ការធ្វើតេស្តដែលបានកត់ត្រាចុងក្រោយផងដែរឬ៖* - *ប្រព័ន្ធផ្តល់សញ្ញា និងឧបករណ៍ចាប់សញ្ញា* - *ប្រព័ន្ធភ្លើងអាសន្ន* - *ម៉ូទ័របូមទឹក* - *ការបើកដំណើរការថាមពលបម្រុង* *ការធ្វើតេស្តហេតុ និងផលក៏គួរកត់សម្គាល់ផងដែរ ឧទាហរណ៍ ការធ្វើតេស្តដែលបើកដំណើរការឧបករណ៍ចាប់សញ្ញា ដើម្បីពិនិត្យមើលថាតើឧបករណ៍ផ្តល់សញ្ញា និងម៉ូទ័របូមត្រូវបានបើកដំណើរការដោយស្វ័យប្រវត្តិ*
ការថែរក្សាទីតាំង	*ឯកសារផ្សេងទៀតដែលពាក់ព័ន្ធក្រអាចផ្តល់ជូនដើម្បីបង្ហាញអំពីរបៀបដែលវិធានការសុវត្ថិភាពអគ្គិភ័យទាំងអស់ត្រូវបានអនុវត្ត ឬរក្សាទុក។* *សូមបញ្ជាក់ផងដែរអំពីស្ថានភាពទូទៅនៃការថែរក្សាទីតាំងដែលបានសង្កេតឃើញក្នុងពេលវាយតម្លៃ៖* - *តើផ្លូវជម្លៀសខ្លួនជាទូទៅមានវត្ថុរាំងផ្លូវទេ?* - *តើជណ្តើរជម្លៀសខ្លួនត្រូវបានការពារមិនឱ្យមានទំនិញរក្សាទុកដែរឬទេ?* - *តើកន្លែងរក្សាទុកត្រូវបានកំណត់ នៅលើទីតាំងដែល*

	បានកំណត់ ឬបែងចែកដោយគ្មានសណ្តាប់ធ្នាប់នៅជុំវិញជាន់ផលិតកម្មឬ?

8.3.6 ការសង្កេត

ផ្នែកនេះគួររៀបរាប់អំពីការសង្កេតដោយប្រើការរួមបញ្ចូលគ្នានៃអត្ថបទ រូបថត និងគំនូរព្រាង។ ការសង្កេតនីមួយៗគួររៀបរាប់ដាច់ដោយឡែកពីគ្នា ដោយដាក់លេខតាមលំដាប់លំដោយពី FIRE-1 ដល់ FIRE-n។ ប្រសិនបើពាក់ព័ន្ធ និងមានប្រយោជន៍ ទីតាំងសម្រាប់ការសង្កេតគួរផ្តល់តាមរយៈមធ្យោបាយនៃគំនូរ គំនូរព្រាង ឬរូបថតដែលបានកត់សម្គាល់។

ការមិនគោរពតាមច្បាប់ដែលបានកត់សម្គាល់ឃើញក្នុងពេលវាយតម្លៃនឹងត្រូវកត់សម្គាល់ថាកំពុងធ្វើការសង្កេតនៅក្នុងតារាងដែលបានរៀបចំទម្រង់ត្រឹមត្រូវ ហើយជួរទីមួយផ្តល់នូវប្រអប់សម្រាប់ការសង្កេតលេខយោង ប្រភេទបញ្ហា និងប្រភេទបញ្ហាបន្ទាប់បន្សំ។

លេខយោង	**ប្រភេទបញ្ហា**	**ប្រភេទបញ្ហាបន្ទាប់បន្សំ**
FIRE-xx *ប្រើលេខរៀងតាមលំដាប់*	*ពីជួរឈរ C នៅក្នុង excel spreadsheet "សកម្មភាពចាត់ថ្នាក់អគ្គិភ័យ" សូមជ្រើសរើសប្រភេទបញ្ហាដែលពាក់ព័ន្ធ*	*ពីជួរឈរ E នៅក្នុង excel spreadsheet "សកម្មភាពចាត់ថ្នាក់អគ្គិភ័យ" សូមជ្រើសរើសប្រភេទបញ្ហាបន្ទាប់បន្សំដែលពាក់ព័ន្ធ*
ការសង្កេត		**អគារ** *សូមផ្តល់អគារ ឯកសារយោងត្រង់នេះ (សម្រាប់អគារដែលបានកំណត់សម្រាប់ការបែងចែកប្រភេទហានិភ័យ)*
ក្នុងករណីជាច្រើន អ្នកគួរតែស្វែងរកអត្ថបទដែលពាក់ព័ន្ធនៅក្នុងជួរឈរ F នៅក្នុង excel spreadsheet "សកម្មភាពបែងចែកប្រភេទហានិភ័យ" នៅក្រោមផ្នែកព័ត៌មានលម្អិតអំពីបញ្ហាបន្ទាប់បន្សំ ដែលផ្តល់សេចក្តីពណ៌នាយ៉ាងទូលំទូលាយអំពីបញ្ហាបន្ទាប់បន្សំ។ *ចំណុចនេះអាចនឹងត្រូវដាក់បញ្ចូលទៅក្នុងប្រអប់សេចក្តីពណ៌នាអំពីការសង្កេត (Observation Description) ហើយបន្ទាប់មករៀបរាប់លម្អិតដើម្បីពិពណ៌នាអំពីការសង្កេត ដោយសារវាពាក់ព័ន្ធនឹងរោងចក្រនេះ។*		
ប្រសិនបើគ្មានអត្ថបទសមស្របណាមួយត្រូវបានរកឃើញនៅក្នុង excel spreadsheet "សកម្មភាពបែងចែកប្រភេទហានិភ័យ" ទេ នោះការសង្កេតអាចនឹងត្រូវពិពណ៌នាយ៉ាងសាមញ្ញដោយផ្អែកលើចំណុចដែលបានសង្កេត។		
រូបភាពទី 20 *រូបភាពនីមួយៗដែលត្រូវផ្តល់ចំណងជើងសេចក្តីពណ៌នា*		**រូបភាពទី 21** *រូបភាពនីមួយៗដែលត្រូវផ្តល់ចំណងជើងសេចក្តីពណ៌នា*

8.3.7 សកម្មភាពអាទិភាព

ផ្នែករបាយការណ៍នេះត្រូវបានរៀបចំឡើងតាមរយៈ FFC ដែលវេទិកាមូលដ្ឋានទិន្នន័យត្រូវបានប្រើប្រាស់ដោយ LABS ដើម្បីប្រមូលរាល់ការសង្កេត និងសកម្មភាពនីមួយៗនៅក្នុងរោងចក្រ។ កំពុងមានការផ្តល់ជូនការបណ្តុះបណ្តាលដាច់ដោយឡែកសម្រាប់អ្នកវាយតម្លៃដោយលម្អិតអំពីរបៀប

អនុវត្ត។

ការណែនាំត្រូវបានផ្តល់ជូននៅក្នុងឧបសម្ព័ន្ធ នៅក្នុងលក្ខណៈដែលសកម្មភាព និងការកំណត់អាទិភាពទាំងនេះនឹងត្រូវបានកត់ត្រាទុក។
នៅក្នុងតារាងឧបសម្ព័ន្ធ H មានផ្តល់ជូននៅក្នុងឯកសារ "ការចាត់ថ្នាក់បញ្ហាអគ្គិភ័យ ការកំណត់អាទិភាព និងសកម្មភាពស្តង់ដារ" សម្រាប់ប្រភេទបញ្ហានីមួយៗ និងប្រភេទបញ្ហាបន្ទាប់បន្សំ សម្រាប់បញ្ហាសុវត្ថិភាពអគ្គិភ័យ ហើយបន្ទាប់មកទៀត សកម្មភាពធម្មតាដែលអាចត្រូវការដើម្បីដោះស្រាយបញ្ហាទាំងនេះត្រូវបានផ្តល់ឱ្យ។ សកម្មភាពទាំងអស់ក៏ត្រូវចាត់ថ្នាក់ទៅជាបញ្ហា និងប្រភេទបញ្ហាបន្ទាប់បន្សំស្របទៅតាមការណែនាំដែលមាននៅក្នុងឧបសម្ព័ន្ធ H។

ឯកសារ Excel នៃឯកសារនេះមានចំណងជើងថា "Methodology Fire Checklist Actions និង Scoring.xlsx" ក៏មានផងដែរ ដើម្បីជួយក្នុងការចងក្រងរបាយការណ៍ ដែលផ្តល់នូវអត្ថបទស្តង់ដារសម្រាប់សកម្មភាពធម្មតាជាច្រើនដែលអាចនឹងត្រូវការ។

ទន្ទឹមនឹងសកម្មភាពនីមួយៗដែលបានរៀបរាប់គឺជាអាទិភាពដែលអាចប្រើប្រាស់ជាការណែនាំសម្រាប់សកម្មភាពនីមួយៗ សម្រាប់អគារ ឬទីតាំងដែលកំពុងពិចារណា។ មូលដ្ឋានសម្រាប់អាទិភាពដែលបានកំណត់នៅក្នុងតារាងគឺផ្អែកទៅលើគោលការណ៍ដូចខាងក្រោម៖

- អាទិភាពទី 1 (FP1) - សកម្មភាពដែលត្រូវបានគិតថាប៉ះពាល់ដល់លទ្ធភាពរបស់មនុស្សក្នុងការជម្លៀសចេញពីអគារដោយសុវត្ថិភាពនៅពេលមានអគ្គិភ័យ គួរផ្តោតការយកចិត្តទុកដាក់លើការដោះស្រាយបញ្ហាទាំងនេះតាំងពីដំបូង។ សកម្មភាពភ្លាមៗ ដូចជា ការបិទមួយផ្នែក/ទាំងស្រុង ការបិទទីតាំងនៅកន្លែងជាក់លាក់។ល។
- អាទិភាពទី 2 (FP2)៖ សកម្មភាពដែលគិតថានឹងត្រូវបញ្ចប់នៅក្នុងរយៈពេល 6 សប្តាហ៍។
- អាទិភាពទី 3 (FP3)៖ បញ្ហាដែលត្រូវបានគិតថា មិនសូវមានការប៉ះពាល់នៅក្នុងការជម្លៀសខ្លួនពីអគារដោយសុវត្ថិភាពនៅពេលមានអគ្គិភ័យ។ សកម្មភាពនឹងត្រូវបញ្ចប់នៅក្នុងរយៈពេល 6 ខែ។

អ្នកវាយតម្លៃសុវត្ថិភាពអគ្គិភ័យត្រូវតែដឹងថា បញ្ហាមួយចំនួន នៅក្នុងករណីទូទៅ អាចផ្តល់ការវាយតម្លៃជាអាទិភាពទាបជាង ប៉ុន្តែនៅក្រោមកាលៈទេសៈផ្សេងទៀតអាចមានសារសំខាន់ខ្លាំងជាង។ បញ្ហានេះទុកធ្វើការវិនិច្ឆ័យផ្នែកវិស្វកម្មពីសំណាក់អ្នកវាយតម្លៃ ដើម្បីកែប្រែការវាយតម្លៃអាទិភាពណាមួយ ប្រសិនបើវាមិនបង្ហាញអំពីផលប៉ះពាល់ដែលភាពខ្វះខាតនេះអាចនឹងបង្កឡើង។

បញ្ជីសកម្មភាពត្រូវបង្កើតឡើងសម្រាប់អគារនីមួយៗដែលនឹងទទួលបានចំណាត់ថ្នាក់ហានិភ័យ (អគារទាំងឡាយដែលបានកំណត់នៅក្នុងតារាងទីមួយនៃរបាយការណ៍) ដោយសារការវាយតម្លៃហានិភ័យត្រូវបានគណនាពីចំនួន និងអាទិភាពនៃសកម្មភាពដែលបានកំណត់ចំពោះអគារនីមួយៗ។ ក្រុមវាយតម្លៃនឹងរៀបចំផ្នែកទាំងមូលតាមរយៈ FFC និងប្រើរបាយការណ៍លទ្ធផល PDF ដើម្បីបញ្ចូលទៅក្នុងផ្នែកនៃរបាយការណ៍នេះ។

សកម្មភាពដែលបានផ្តល់ជូននៅក្នុងឧបសម្ព័ន្ធ មិនមែនជាបញ្ជីសកម្មភាពពេញលេញដែលពាក់ព័ន្ធទៅនឹងបញ្ហាទាំងអស់ដែលអាចកំណត់ដោយអ្នកវាយតម្លៃសុវត្ថិភាពអគ្គិភ័យឡើយ ប៉ុន្តែជាបញ្ជីបញ្ហាទូទៅ និងវិធានការដោះស្រាយ។ សកម្មភាពនេះនឹងបម្រើដល់ការធ្វើស្តង់ដារ រៀបកត់ត្រាសកម្មភាពតាមដែលអាចធ្វើបាន ដែលនឹងជួយនៅក្នុងការកត់ត្រា និងតាមដានសកម្មភាពរបស់រោងចក្រជាច្រើន។

អ្នកវាយតម្លៃសុវត្ថិភាពអគ្គិភ័យនឹងទទួលខុសត្រូវក្នុងការវិនិច្ឆ័យភាពគ្រប់គ្រាន់នៃសកម្មភាពដើម្បីដោះស្រាយការមិនគោរពស្តង់ដារដែលបានសង្កេតឃើញ ហើយគួរតែបន្ថែមសកម្មភាពរបស់អ្នកវាយតម្លៃសុវត្ថិភាពអគ្គិភ័យទៅក្នុងបញ្ជីនៃ "សកម្មភាពជួសជុលទូទៅ" ប្រសិនបើចាំបាច់។

ប្រភេទហានិភ័យចុងក្រោយសម្រាប់រោងចក្រ គឺអគារដែលទទួលបានចំណាត់ថ្នាក់ហានិភ័យខ្ពស់បំផុត ដូចជា រោងចក្រដែលមានអគារផលិតកម្មចំនួនពីរទទួលបានចំណាត់ថ្នាក់ "ពណ៌លឿង" និង "ពណ៌លឿង/ពណ៌ក្រហម" និងអគារឃ្លាំងចំនួនមួយដែលទទួលបានចំណាត់ថ្នាក់ "ពណ៌លឿង" រោងចក្រនឹងមាន "ពណ៌លឿង/ពណ៌ក្រហម"។

8.3.8 សេចក្តីសង្ខេបអំពីសកម្មភាពអាទិភាព

នេះគឺជាការសង្ខេបចំនួនមួយទំព័រអំពីសកម្មភាពដែលត្រូវអនុវត្តដោយអ្នកគ្រប់គ្រងរោងចក្រ រួមទាំងការកំណត់ពេលវេលាផងដែរ។ សេចក្តីសង្ខេបនេះត្រូវបានបង្កើតដោយស្វ័យប្រវត្តិពី FFC ជាតារាង ដែលនឹងត្រូវដាក់បញ្ចូលទៅក្នុងរបាយការណ៍។

8.3.9 ការកម្រិត និងការសន្មត់

អត្ថបទស្តង់ដាររបស់យើងស្តីពីការកម្រិត និងការសន្មត់លើការវាយតម្លៃគួរត្រូវបានដាក់បញ្ចូលនៅ

ផ្នែកបញ្ចប់នៃរបាយការណ៍។ អត្ថបទនេះមិនគួរធ្វើការកែប្រែឡើយ។
ជាងនេះទៅទៀត អត្ថបទស្តីពីការប្រកាសមិនទទួលខុសត្រូវខាងក្រោមពី LABS គួរតែដាក់បញ្ចូលនៅក្នុងរបាយការណ៍ផងដែរ៖

សេចក្តីប្រកាសមិនទទួលខុសត្រូវរបស់ LABS

*របាយការណ៍នេះ គឺជាលទ្ធផលនៃការវាយតម្លៃដែលបានធ្វើឡើងដោយអនុវត្តន៍វិធីសាស្ត្រវាយតម្លៃសុវត្ថិភាពបឋមសម្រាប់ប្រទេសកម្ពុជា (**"វិធីសាស្ត្រ"**) និងស្តង់ដារ និងពិធីសារដែលស្របទៅនឹង LABS (**"LABS ស្តង់ដារ"**)។*

ស្តង់ដារ LABS និងវិធីសាស្ត្រ រៀបរាប់អំពីលក្ខខណ្ឌតម្រូវក្នុងការដោះស្រាយបញ្ហាសុវត្ថិភាពអាយុជីវិតនៅក្នុងរោងចក្រពាក់ព័ន្ធនឹងសុវត្ថិភាពគ្រោងអគារ អគ្គិសនី និងអគ្គិភ័យ ប៉ុន្តែ LABS Foundation មិនទទួលខុសត្រូវនោះទេ ហើយក៏មិនអាចធានាបានថារោងចក្រនោះទទួលបានការធានាយ៉ាងពេញលេញន៍វសុវត្ថិភាពអាយុជីវិតលើប្រព័ន្ធគ្រោងអគារ អគ្គិសនី និងអគ្គិភ័យផងដែរ។ LABS Foundation មិនទទួលខុសត្រូវចំពោះការធានាថារោងចក្រ និង/ឬក្រុមហ៊ុនត្រួតពិនិត្យដែលបានធ្វើការវាយតម្លៃ បានអនុលោមតាមលក្ខខណ្ឌតម្រូវនៃស្តង់ដារ LABS និង/ឬវិធីសាស្ត្រនោះទេ។

ក្រុមហ៊ុនត្រួតពិនិត្យដែលធ្វើការវាយតម្លៃត្រូវតែបកស្រាយ និងកែសម្រួលស្តង់ដារ LABS និងវិធីសាស្ត្រតាមភាពចាំបាច់ចំពោះរោងចក្រជាក់លាក់នីមួយៗ និងបរិបទក្នុងតំបន់ដែលបានធ្វើការវាយតម្លៃនោះ។ ក្រុមហ៊ុនត្រួតពិនិត្យត្រូវទទួលខុសត្រូវទាំងស្រុងចំពោះការវាយតម្លៃ និងលទ្ធផលនៃការវាយតម្លៃរួមមានជាអាទិ៍របាយការណ៍នេះ។ ពាក់ព័ន្ធនឹងរបាយការណ៍នេះ ឬផ្នែកណាមួយនោះ LABS Foundation មិនជាប់កាតព្វកិច្ចនៃការថែទាំ (មិនថានៅក្នុងកិច្ចសន្យា ឬនៅក្នុងច្បាប់រដ្ឋប្បវេណី ឬស្ថិតក្រោមលក្ខន្តិក: ឬក្នុងចំណុចផ្សេងៗ) ចំពោះបុគ្គល ឬភាគីដែលរបាយការណ៍នេះត្រូវផ្តោតលើ ហើយ LABS Foundation មិនទទួលខុសត្រូវចំពោះភាគីណាមួយដែលប្រើប្រាស់ ពឹងផ្អែក ឬធ្វើសកម្មភាពលើរបាយការណ៍នេះឡើយ។ LABS Foundation មិនទទួលខុសត្រូវ និងមិនអាចទទួលខុសត្រូវចំពោះការបាត់បង់ និង/ឬការខូចខាតណាមួយដែលកើតឡើងចំពោះរោងចក្រ ក្រុមហ៊ុនត្រួតពិនិត្យ និង/ឬភាគីទីបីណាមួយដែលបង្កឡើងដោយ ឬពាក់ព័ន្ធនឹងសុវត្ថិភាពអាយុជីវិតគ្រោងអគារ អគ្គិសនី និងអគ្គិភ័យនៅក្នុងរោងចក្រ ស្តង់ដារ LABS វិធីសាស្ត្រ ការវាយតម្លៃ របាយការណ៍ លទ្ធផលនៃការវាយតម្លៃ និង/ឬផលវិបាកនៃការវាយតម្លៃ លុះត្រាតែរោងចក្រ ក្រុមហ៊ុនត្រួតពិនិត្យ ឬភាគីទីបីណាមួយបង្ហាញពីការប្រព្រឹត្តខុសដោយចេតនា ឬការធ្វេសប្រហែសទាំងស្រុងរបស់ LABS Foundation ។

តាមរយៈការអានរបាយការណ៍ អ្នកអានរបាយការណ៍ត្រូវចាត់ទុកថាបានទទួលយកលក្ខខណ្ឌដែលបានរៀបរាប់ខាងលើ។

8.4 របាយការណ៍វាយតម្លៃសុវត្ថិភាពអគ្គិសនី

មានឯកសារណែនាំមួយចំនួនសម្រាប់ការរៀបចំរបាយការណ៍វាយតម្លៃសុវត្ថិភាព

- អគ្គិសនី៖ បញ្ជីផ្ទៀងផ្ទាត់ការវាយតម្លៃសុវត្ថិភាពអគ្គិសនី (ឧបសម្ព័ន្ធ ច)
- ការបែងចែកប្រភេទ និងការកំណត់អាទិភាពបញ្ហាអគ្គិសនី (ឧបសម្ព័ន្ធ ឈ)
- របាយការណ៍វាយតម្លៃសុវត្ថិភាពអគ្គិសនី៖ គំរូ (ឧបសម្ព័ន្ធ ញ3) ដែលជាគំរូទទេដែលត្រូវប្រើប្រាស់នៅក្នុងការរៀបចំរបាយការណ៍
- របាយការណ៍វាយតម្លៃសុវត្ថិភាពអគ្គិសនី - គំរូ (ឧបសម្ព័ន្ធ ដ3) សម្រាប់ជាឯកសារយោង និងការណែនាំអំពីរបៀបប្រើប្រាស់គំរូ។

របាយការណ៍នេះត្រូវមានផ្នែកដូចខាងក្រោម និងការពិពណ៌នាសម្រាប់ការសរសេររបាយការណ៍ដែលផ្អែកលើការវាយតម្លៃដែលបានបញ្ចប់នេះ ត្រូវបានរៀបរាប់អំពី៖

- គម្របខាងមុខ
- ទំព័រមាតិកា
- សេចក្តីសង្ខេបប្រតិបត្តិ
- សេចក្តីពណ៌នាអំពីផ្នែករោងចក្រ
- សេចក្តីពណ៌នាអំពីប្រព័ន្ធអគ្គិសនីក្នុងអគារ
- ការសង្កេត
- បញ្ជីសកម្មភាពអាទិភាព
- សេចក្តីសង្ខេបអំពីសកម្មភាពអាទិភាព
- ការកម្រិត និងការសន្មត់

8.4.1 គម្របខាងមុខ

គម្របគួរតែមានឈ្មោះ អាសយដ្ឋាន និងចំណុចយោងរបស់រោងចក្រ។ នៅពេលដែលរបាយការណ៍ត្រូវបានបញ្ចប់ និងមុនពេលពិនិត្យមើលការវាយតម្លៃ គួរបង្ហាញការចាត់ថ្នាក់ជាពណ៌។ ឈ្មោះក្រុមវាយតម្លៃ កាលបរិច្ឆេទនៃការវាយតម្លៃ និងរូបថតនៃអគារក៏ត្រូវដាក់បញ្ចូលផងដែរ។ នៅពេលបញ្ចប់ការត្រួតពិនិត្យ លេខកែប្រែ កាលបរិច្ឆេទ និងឈ្មោះអ្នកត្រួតពិនិត្យ និងអ្នកអនុម័តនឹងត្រូវដាក់បញ្ចូលបន្ថែមដោយវិស្វករត្រួតពិនិត្យ។ នៅពេលដែលអគារលើសពីមួយត្រូវបានវាយតម្លៃ និងផ្តល់ចំណាត់ថ្នាក់ជាពណ៌ ការចាត់ថ្នាក់ពណ៌ដ៏អាក្រក់បំផុតគឺអគារដែលគួរតែបង្ហាញនៅលើសន្លឹកគម្របសម្រាប់រោងចក្រ។

8.4.2 ទំព័រមាតិកា

ខ្លឹមសាររបាយការណ៍នេះ គឺជាស្តង់ដារសម្រាប់របាយការណ៍ទាំងអស់ ប៉ុន្តែបញ្ជីដែលផ្តល់ចំណងជើងរបាយការណ៍សំខាន់នឹងត្រូវផ្តល់ជូនជាមួយនឹងលេខទំព័រដែលត្រូវគ្នា។ លេខទំព័រនឹងត្រូវបញ្ចូលដោយដៃដែលរបាយការណ៍ FFC Actions pdf ត្រូវដាក់បញ្ចូលនៅក្រោមចំណងជើង "សកម្មភាពអាទិភាព" ។

8.4.3 សេចក្តីសង្ខេបប្រតិបត្តិ

សេចក្តីសង្ខេបពិស្តារគួរមានសេចក្តីពណ៌នាអំពីសកម្មភាពវាយតម្លៃ ការសង្កេត និងសកម្មភាពផ្សេងៗ។ ទម្រង់ខាងក្រោមគួរធ្វើការអនុម័ត៖

- នៅថ្ងៃ XX ខែ ឆ្នាំ អ្នកវាយតម្លៃ (ឈ្មោះក្រុមហ៊ុនវាយតម្លៃ) បានអនុវត្តការវាយតម្លៃផ្នែកអគ្គិសនីដោយមើលនឹងភ្នែកទៅលើរោងចក្រ (ឈ្មោះរោងចក្រ) នៅអាសយដ្ឋាន និងសម្របសម្រួលដែលបានផ្តល់ជូននៅលើទំព័រគម្របនៃរបាយការណ៍នេះ។
- រៀបរាប់អំពីការប្រើប្រាស់អាគារ។
- រៀបរាប់អំពីចំណុចដែលត្រូវ និងមិនត្រូវត្រួតពិនិត្យ។
- មតិយោបល់អំពីស្ថានភាពនៃគំនូរ/របាយការណ៍ដែលបានផ្តល់ជូន ពោលគឺលិខិតអនុញ្ញាតវិស្វករ ដូចដែលបានសាងសង់ផ្សេងៗទៀត។
- មតិយោបល់លើសុពលភាពនៃគំនូរប្លង់៖ តើជិតដូចទៅនឹងលក្ខខណ្ឌដែលបានសាងសង់ដែរឬទេ?
- ប្រសិនបើរោងចក្រមានអគារច្រើន ត្រូវផ្តល់សេចក្តីពណ៌នាសង្ខេបអំពីអគារនីមួយៗ។
- ដាក់ស្លាកអគារនីមួយៗ ដើម្បីងាយស្រួលក្នុងការយោងនៅក្នុងរបាយការណ៍។ ការដាក់កូដជាពណ៌លើរចនាសម្ព័ន្ធទាំងមូលសម្រាប់របាយការណ៍នឹងផ្តែកទៅលើអគារករណីដ៏អាក្រក់បំផុតនៅលើទីតាំងផ្ទាល់។
- មតិយោបល់លើកូដពណ៌រោងចក្រ៖ "ប្រភេទកូដពណ៌ទាំងមូលរបស់រោងចក្រនេះគឺកូដពណ៌ដែលមានន័យថា យ៉ាងហោចណាស់មានសកម្មភាពមួយចំនួនដែលត្រូវតែដោះស្រាយឱ្យបាននៅក្នុងរយៈពេលណាមួយ។
- ប្រសិនបើមានអគារច្រើននៅក្នុងរោងចក្រ នោះប្រភេទនីមួយៗគួរកត់ត្រានៅក្នុងផ្នែកនេះដូចខាងក្រោម៖

"ប្រភេទកូដពណ៌សម្រាប់អគាររោងចក្រធំៗនីមួយៗដែលត្រូវបានវាយតម្លៃត្រូវបានបង្ហាញជូនដូចខាងក្រោម៖

អគារទី 1៖ កូដពណ៌

អគារទី 2៖ កូដពណ៌

អគារទី 3៖ កូដពណ៌

- បញ្ហីការព្រួយបារម្ភសំខាន់ៗដែលបានកត់សម្គាល់៖ ការព្រួយបារម្ភជាអាទិភាពខ្ពស់បំផុតគួរធ្វើការកត់សម្គាល់ជាមុនសិន។ ប្រសិនបើមានការលើកឡើងអំពីការព្រួយបារម្ភ ដែលធ្វើឱ្យរបាយការណ៍មានស្ថានភាពពណ៌លឿង ពណ៌នេះគួរធ្វើការគូសរំលេចជាពណ៌ដិត។ ចំណុចនេះគួរតែមាននៅក្នុង 2 ទំព័រដំបូងនៃរបាយការណ៍។ បន្ទាប់មក សូមផ្តល់ឧបសម្ព័ន្ធនៃការព្រួយបារម្ភផ្សេងទៀត។
- មតិយោបល់អំពីកម្រិតនៃការរៀបចំ និងការថែទាំដែលបានបង្ហាញនៅក្នុងរោងចក្រ ដោយផ្អែកលើការព្រួយបារម្ភសំខាន់ៗដែលបានរៀបរាប់ និងឯកសារភស្តុតាងផ្សេងទៀតដែលបានបង្ហាញ។
- មតិយោបល់អំពីសកម្មភាព "សកម្មភាពផ្សេងទៀតដែលមានអាទិភាពពាក់ព័ន្ធ ហើយពេលវេលាត្រូវបានផ្តល់ជូននៅផ្នែកបញ្ចប់នៃរបាយការណ៍នេះ។ សូមបញ្ជាក់ថា សកម្មភាពទាំងនេះគួរតែបញ្ចប់ឱ្យបានឆាប់តាមដែលអាចធ្វើបាន និងមានរយៈពេលច្បាស់លាស់ដូចដែលបានកត់សម្គាល់។ "
- មតិយោបល់អំពីភាពចាំបាច់ក្នុងការផ្អាកប្រតិបត្តិការរោងចក្រនៅក្នុងផ្នែកណាមួយ ឬទាំងអស់របស់រោងចក្រ ប្រសិនបើរកឃើញបញ្ហាសុវត្ថិភាពណាមួយ។
- មតិយោបល់អំពីការកម្រិត៖ "ការកម្រិត និងការសន្មត់របស់យើងក៏ត្រូវបានកត់សម្គាល់ផងដែរនៅផ្នែកបញ្ចប់នៃរបាយការណ៍នេះ។"

8.4.4 វិសាលភាពរោងចក្រ

ផ្នែកនៃរបាយការណ៍នេះគួរមានសេចក្តីពិពណ៌នាជារូបភាពរបស់អគារ និងវិសាលភាពនៃជាន់រោងចក្រដែលបានវាយតម្លៃនៅក្នុងទីតាំង។ រូបភាពផែនទី Google អាចមានប្រយោជន៍ក្នុងការផ្តល់ប្លង់ទីតាំងសម្រាប់បង្ហាញអំពីវិសាលភាពអគារ។ រូបភាពទាំងនេះ អាចបំពេញបន្ថែមដោយរូបថតទីតាំង គំនូរព្រាង និងអត្ថបទដើម្បីពណ៌នាដូចខាងក្រោម៖

- ចំនួនជាន់
- ចំនួនឆ្នាំប្រហាក់ប្រហែលនៃការសាងសង់
- ការអភិវឌ្ឍតាមដំណាក់កាល
- ចំនួនស្ថានីយរង និងទីតាំងទូទៅ
- ចំនួនម៉ាស៊ីនភ្លើង និងទីតាំងទូទៅ
- ជាន់ដែលជាទីតាំងរបស់រោងចក្រនៅក្នុងអគារដែលមានការប្រើប្រាស់ចម្រុះ

- សុពលភាពនៃ គំនូសប្លង់
- លក្ខណៈពិសេសផ្សេងទៀតនៃកំណត់សម្គាល់។

8.4.5 ប្រព័ន្ធអគ្គិសនី

ផ្នែកនៃរបាយការណ៍នេះគួរតែមានសេចក្តីពណ៌នាជារូបភាពអំពីប្រព័ន្ធអគ្គិសនីរបស់អគារ។
ចំណងជើងខាងក្រោមគួរតែប្រើនៅក្នុងរបាយការណ៍៖

- ការផ្គត់ផ្គង់សម្រាប់ប្រព័ន្ធសុវត្ថិភាពអាយុជីវិត
- ការរៀបចំប្រព័ន្ធម៉ាស និងការផ្តុំជាសំណុំ
- ម៉ាស៊ីនភ្លើង
- ស្តានីយរង
- ការចែកចាយ

8.4.6 ការសង្កេត

ផ្នែកនេះគួរតែមានការបង្ហាញជារូបភាពអំពីការសង្កេត ដោយប្រើរូបថត និងគំនូរព្រាងបញ្ចូលគ្នា ដើម្បីរៀបរាប់អំពីបញ្ហាដែលជាការព្រួយបារម្ភ។ ការសង្កេតនីមួយៗគួរធ្វើការ ពិពណ៌នាដាច់ដោយឡែកពីគ្នា ដោយរាប់លេខតាមលំដាប់ពី Elec-1 ដល់ Elec-n ។ ទីតាំងសម្រាប់ការសង្កេតគួរតែត្រូវបានផ្តល់ដោយមធ្យោបាយនៃការគូសចំណាំ គំនូរព្រាង ឬរូបថត។ សេចក្តីសង្ខេបអំពីសកម្មភាពដែលត្រូវអនុវត្ត ក៏គួរផ្តល់ជូនផងដែរ (ព័ត៌មានលម្អិតបន្ថែមនឹងត្រូវផ្តល់ជូននៅក្នុងផ្នែកសកម្មភាពអាទិភាពនៃរបាយការណ៍)។

8.4.7 សកម្មភាពអាទិភាព

ផ្នែកនៃរបាយការណ៍នេះត្រូវបានរៀបចំតាមរយៈ FFC ដែលវេទិកាមូលដ្ឋានទិន្នន័យដែលត្រូវបានប្រើប្រាស់ដោយ LABS ដើម្បីប្រមូលផ្តុំរាល់ការសង្កេត និងសកម្មភាពនានានៅក្នុងរោងចក្រនីមួយៗ។ ការបណ្តុះបណ្តាលដាច់ដោយឡែកកំពុងផ្តល់ជូនសម្រាប់អ្នកវាយតម្លៃដោយលម្អិតអំពីរបៀបអនុវត្តកិច្ចការនេះ។
សម្រាប់ចំណុចដែលបានសង្កេតនីមួយៗ បញ្ជីសកម្មភាពគួររៀបចំឡើងដើម្បីកំណត់សកម្មភាពតាមដានជាក់លាក់ដែលត្រូវអនុវត្ត និងផ្តល់អាទិភាពដូចខាងក្រោម៖

- អាទិភាពទី 1 (EP1)៖ សកម្មភាពភ្លាមៗ ឧ. ការបិទឧបករណ៍ទាំងស្រុង ឬដោយផ្នែក
- អាទិភាពទី 2 (EP2)៖ សកម្មភាពដែលត្រូវបញ្ចប់នៅក្នុងរយៈពេល 2 សប្តាហ៍
- អាទិភាពទី 3 (EP3)៖ សកម្មភាពដែលត្រូវបញ្ចប់នៅក្នុងរយៈពេល 4 សប្តាហ៍។

- អាទិភាពទី 4 (EP4)៖ សកម្មភាពដែលត្រូវបញ្ចប់នៅក្នុងរយៈពេល 2 ខែ។

ក្រុមវាយតម្លៃគួរពិនិត្យមើលតារាងសរសេរកូដពណ៌ និងឧបសម្ព័ន្ធ I2 នៅពេលធ្វើការកំណត់អាទិភាព។

សកម្មភាពទាំងអស់ក៏ត្រូវបែងចែកប្រភេទទៅជាបញ្ហា និងប្រភេទរងដោយអនុលោមតាមការណែនាំដែលមាននៅក្នុងឧបសម្ព័ន្ធ I1។ លេខប្រការពាក់ព័ន្ធពីស្តង់ដារ LABS គួរដាក់បញ្ចូលផងដែរ សម្រាប់ជាឯកសារយោងដើម្បីកំណត់ប្រការពាក់ព័ន្ធដែលសកម្មភាពកំពុងត្រូវបានដាកបញ្ចូល។ ក្រុមវាយតម្លៃនឹងរៀបចំផ្នែកទាំងស្រុងតាមរយៈ FFC និងប្រើរបាយការណ៍លទ្ធផល PDF ដើម្បីដាក់បញ្ចូលទៅក្នុងផ្នែកនៃរបាយការណ៍នេះ។

8.4.8 សេចក្តីសង្ខេបអំពីសកម្មភាពអាទិភាព

នេះគឺជាការសង្ខេបចំនួនមួយទំព័រអំពីសកម្មភាពដែលត្រូវអនុវត្តដោយអ្នកគ្រប់គ្រងរោងចក្រ រួមទាំងការកំណត់ពេលវេលាផងដែរ។ សេចក្តីសង្ខេបនេះត្រូវបានបង្កើតដោយស្វ័យប្រវត្តិពី FFC ជាតារាង ដែលនឹងត្រូវដាក់បញ្ចូលទៅក្នុងរបាយការណ៍។

ឧបសម្ព័ន្ធ A

ការរៀបចំមុនពេលវាយតម្លៃ

A1 គំនិតផ្តួចផ្តើម LABS ក្របខ័ណ្ឌការងារវាយតម្លៃសុវត្ថិភាព

ការវាយតម្លៃគ្រឿងបង្គុំ អគ្គិភ័យ និងអគ្គិសនី
កម្រងសំណួរមុនពេលវាយតម្លៃរបស់រោងចក្រ គំនិតផ្តួចផ្តើម LABS

សេចក្តីផ្តើម

ជូនចំពោះលោក/លោកស្រី យើងខ្ញុំគ្រោងនឹងចុះផ្ទាល់ទៅកាន់រោងចក្ររបស់លោក/លោកស្រីនាពេលខាងមុខ ដើម្បីសិក្សាអំពីស្ថានភាពគ្រឿងបង្គុំ អគ្គិភ័យ និងអគ្គិសនីនៃអគារ និងវាយតម្លៃបរិវេណទាំងអស់នៃអគារផងដែរ។ ការចុះវាយតម្លៃនេះនឹងធ្វើឡើងដោយវិស្វករគ្រឿងបង្គុំ អគ្គិភ័យ និងអគ្គិសនី ដែលតំណាងឱ្យគំនិតផ្តួចផ្តើម LABS។

យើងខ្ញុំសូមស្នើសុំឱ្យលោក/លោកស្រីមេត្តាឆ្លើយនូវសំណួរខាងក្រោមក្នុងទម្រង់ជា pdf និងប្រគល់មកកាន់យើងខ្ញុំវិញក្នុងរយៈពេល 5 ថ្ងៃធ្វើការនៃកាលបរិច្ឆេទចុះវាយតម្លៃដែលបានស្នើឡើង។

ប្រសិនបើមានអគារច្រើននៅក្នុងបរិវេណរោងចក្រ សូមលោក/លោកស្រីថតចម្លងទម្រង់នេះ និងបំពេញផ្នែក 2 & 3 សម្រាប់អគារនីមួយៗ។ សូមលោក/លោកស្រីដាក់លេខ ឬឈ្មោះសម្រាប់អគារនីមួយៗ។

សំណួរ

ផ្នែកទី 1៖ អាសយដ្ឋានរោងចក្រ កម្មសិទ្ធិ និងចំនួនអគារ

ឈ្មោះរោងចក្ររបស់អ្នក៖	
អាសយដ្ឋានពេញនៃរោងចក្រ៖	
និយាមការរោងចក្រ៖ (សូមមើលសេចក្តីណែនាំ)	
លេខទូរសព្ទ៖	
អ៊ីមែល៖	
តើអ្នកគឺជាម្ចាស់អគារ ឬជាអ្នកជួល? ប្រសិនបើជាអ្នកជួល សូមបង្ហាញអំពីប្រភេទនៃការជួលអគារ	

☐ អគារជួលទោល ☐ អគារជួលច្រើន

ឈ្មោះម្ចាស់អគារ៖	
លេខទូរសព្ទ៖	
អ៊ីមែល៖	

ផ្នែកទី 1៖ (ត)

ចំនួនអគារនៅក្នុងបរិវេណរោងចក្រ? [ ]

(ក្នុងករណីដែលមានអគារច្រើនជាង 1 នៅក្នុងបរិវេណរោងចក្រ ប្លង់ទីតាំងជាទម្រង់ PDF
ត្រូវតែដាក់ជូនអមជាមួយកម្រងសំណួរនេះ
កំណត់អត្តសញ្ញាណអគារនីមួយៗទាំងអស់ដែលបានកត់ត្រាខាងក្រោម។)

<u>អគារ 1៖</u>

ឈ្មោះ/ការប្រើប្រាស់អគារ៖ [ ] ចំនួនជាន់៖ [ ]

ផ្ទៃក្រឡាប្លង់នៃជាន់ទូទៅ
ធ្នឹម (ម៉ែត្រការ៉ែ) [ ]

<u>អគារ 2៖</u>

ឈ្មោះ/ការប្រើប្រាស់អគារ៖ [ ] ចំនួនជាន់៖ [ ]

ផ្ទៃក្រឡាប្លង់នៃជាន់ទូទៅ
ធ្នឹម (ម៉ែត្រការ៉ែ) [ ]

<u>អគារ 3៖</u>

ឈ្មោះ/ការប្រើប្រាស់អគារ៖ [ ] ចំនួនជាន់៖ [ ]

ផ្ទៃក្រឡាប្លង់នៃជាន់ទូទៅ
ធ្នឹម (ម៉ែត្រការ៉ែ) [ ]

<u>អគារ 4៖</u>

ឈ្មោះ/ការប្រើប្រាស់អគារ៖ [ ] ចំនួនជាន់៖ [ ]

ផ្ទៃក្រឡាប្លង់នៃជាន់ទូទៅ
ធ្នឹម (ម៉ែត្រការ៉ែ) [ ]

<u>អគារ 5៖</u>

ឈ្មោះ/ការប្រើប្រាស់អគារ៖ [ ] ចំនួនជាន់៖ [ ]

ផ្ទៃក្រឡាប្លង់នៃជាន់ទូទៅ
ធ្នឹម (ម៉ែត្រការ៉ែ) [ ]

<u>អគារ 6៖</u> _____

ឈ្មោះ/ការប្រើប្រាស់អគារ៖ ចំនួនជាន់៖

ផ្ទៃក្រឡាប្លង់នៃជាន់ទូទៅ ធ្មឹម (ម៉ែត្រការ៉ែ)

<u>អគារ 7៖</u>

ឈ្មោះ/ការប្រើប្រាស់អគារ៖ ចំនួនជាន់៖

ផ្ទៃក្រឡាប្លង់នៃជាន់ទូទៅ ធ្មឹម (ម៉ែត្រការ៉ែ)

<u>អគារ 8៖</u>

ឈ្មោះ/ការប្រើប្រាស់អគារ៖ ចំនួនជាន់៖

ផ្ទៃក្រឡាប្លង់នៃជាន់ទូទៅ ធ្មឹម (ម៉ែត្រការ៉ែ)

អគារ 8៖

ឈ្មោះ/ការប្រើប្រាស់អគារ៖ ចំនួនជាន់៖

ផ្ទៃក្រឡាប្លង់នៃជាន់ទូទៅ ធ្មឹម (ម៉ែត្រការ៉ែ)

ប្រសិនបើមានអគារច្រើននៅក្នុងបរិវេណរោងចក្រ សូមលោក/លោកស្រីថតចម្លងទម្រង់នេះ និងបំពេញផ្នែក 2 & 3 សម្រាប់អគារនីមួយៗ។ សូមលោក/លោកស្រីដាក់លេខ ឬឈ្មោះសម្រាប់អគារនីមួយៗ។

ផ្នែកទី 2៖ ព័ត៌មានលម្អិតអំពីអាងចក្រ

លេខ ឬឈ្មោះអគារ៖			
ចំនួនជាន់ក្រោមដី៖			
ចំនួនជាន់៖ (រួមទាំងជាន់ផ្ទាល់ដី និងដំបូល [ប្រសិនប្រើប្រាស់])			
តើអ្នកកាន់កាប់ជាន់ទាំងអស់ដែរឬទេ?		ប្រសិនបើមិនមែន តើអ្នកណាកាន់កាប់ជាន់ផ្សេងទៀត និងតើពួកគេធ្វើប្រតិបត្តិការអ្វី៖	
តើជាន់ទាំងអស់អាចចូលស្នង់បានឬទេ៖		ប្រសិនបើមិនបាន ហេតុអ្វី៖	
ចំពោះជាន់នីមួយៗ សូមពណ៌នាអំពីសកម្មភាពនៅជាន់នោះ៖ (ឧ. ជាន់ទី 1 - 3 ជាន់ដេរ កាត់ និង ដាក់ឥវ៉ាន់)			

ផ្នែកទី 3៖ ឯកសារអោងចក្រ

តើអគារត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់សម្រាប់អ្វី?			
តើមានលិខិតអនុញ្ញាតប្លង់ឬទេ?		លេខលិខិតអនុញ្ញាត/ព័ត៌មានលម្អិត៖	
តើមានលិខិតអនុញ្ញាតសាងសង់ឬទេ?		លេខលិខិតអនុញ្ញាត/ព័ត៌មានលម្អិត៖	
តើមានលិខិតអនុញ្ញាតការងារឬទេ?		លេខលិខិតអនុញ្ញាត/ព័ត៌មានលម្អិត៖	
ចំនួនជាន់ដែលអនុញ្ញាត៖ តើជាន់ទាំងអស់រចនាឡើងសម្រាប់ការប្រើប្រាស់របស់អោងចក្រ?		ប្រសិនបើមិនមែន សូមពន្យល់៖	
តើមានលិខិតអនុញ្ញាតប្លង់ និងព័ត៌មានលម្អិតអំពីការអនុញ្ញាតនៅត្រឹមកាលបរិច្ឆេទចុះស្នងឬទេ?			
តើមានលិខិតអនុញ្ញាតសាងសង់ និងព័ត៌មានលម្អិតអំពីការអនុញ្ញាតនៅត្រឹមកាលបរិច្ឆេទចុះស្នងឬទេ?			
តើមានលិខិតអនុញ្ញាតការងារ និងព័ត៌មានលម្អិតអំពីការអនុញ្ញាតនៅត្រឹមកាលបរិច្ឆេទចុះស្នងឬទេ?			
តើមានការបន្ថែម ឬការកែលម្អការត តការសង់បន្ថែមថ្មីៗតាមជាន់ឬតើមានគម្រោងឬទេ?		ប្រសិនបើមាន សូមពន្យល់៖	
តើអ្នកបានអនុវត្តការងារជួសជុលគ្រឿងបង្គុំបន្ទាប់ពីសាងសង់ឬទេ? (ឧ. ជួសជុលស្នាមប្រេះ បូកជញ្ជាំងឡើងវិញ)		ប្រសិនបើមាន សូមពន្យល់ និងគូសបញ្ជាក់អំពីចំណុចទាំងនេះនៅក្នុងអំឡុងពេលចុះស្នង់៖	

ឈ្មោះវិស្វករអគ្គិសនីដើម៖

លេខទូរសព្ទ៖ អ៊ីមែល៖

តើវិស្វកររគ្រឿងបង្គុំដើមអាចចូលរួមនៅទីតាំងក្នុងអំឡុងចុះវាយតម្លៃឬទេ?

ឈ្មោះវិស្វករអគ្គិសនីដើម៖

លេខទូរសព្ទ៖ អ៊ីមែល៖

តើវិស្វករអគ្គិសនីដើមអាចចូលរួមនៅទីតាំងក្នុងអំឡុងចុះវាយតម្លៃឬទេ?

ឈ្មោះស្ថាបត្យករអគារ៖

ឈ្មោះរបស់អ្នក៖

តួនាទីរបស់អ្នក៖ កាលបរិច្ឆេទ៖

កំណត់សម្គាល់៖ សូមរក្សាទុកទម្រង់ PDF នេះដោយប្រើប្រាស់ឈ្មោះរោងចក្ររបស់អ្នក និងលេខ / ឈ្មោះអគារ (ប្រសិនបើសមស្រប) ជាឈ្មោះហ្វាល និងផ្ញើត្រលប់តាមរយៈអ៊ីមែល។
សូមអរគុណចំពោះការសហការរបស់អ្នក។

A2 គំនិតផ្តួចផ្តើម LABS បញ្ជីត្រួតពិនិត្យការវាយតម្លៃសុវត្ថិភាព

ការវាយតម្លៃគ្រឿងបង្គុំ អគ្គិភ័យ និងអគ្គិសនី
កម្រងសំណួរមុនពេលវាយតម្លៃរបស់រោងចក្រ **គំនិតផ្តួចផ្តើម LABS**

បញ្ជីត្រួតពិនិត្យឯកសារ

សូមរក្សាឯកសារខាងក្រោមទុកនៅរោងចក្រសម្រាប់ឱ្យក្រុមវាយតម្លៃ។ សូមចេញឯកសារគំនូសបង្ហាញកែសម្រួលក្នុងទម្រង់ PDF ជាសំណៅអេឡិចត្រូនិកនៅពេលប្រគល់កម្រងសំណួរមុនពេលវាយតម្លៃមកវិញ (5 ថ្ងៃធ្វើការមុនពេលកាលបរិច្ឆេទស្នើចុះវាយតម្លៃ)។

គំនូសបង្ហាញស្ថាបត្យកម្មកែសម្រួល	☐	2 ច្បាប់តាមមាត្រដ្ឋានពេញ ឬទំហំ A3 (1 ច្បាប់សម្រាប់ឱ្យក្រុមវាយតម្លៃ)
គំនូសបង្ហាញគ្រឿងបង្គុំ និងអគ្គិសនីកែសម្រួល	☐	2 ច្បាប់តាមមាត្រដ្ឋានពេញ ឬទំហំ A3 (1 ច្បាប់សម្រាប់ឱ្យក្រុមវាយតម្លៃ)
ប្លង់ទីតាំង៖	☐	12 ច្បាប់តាមមាត្រដ្ឋានពេញ ឬទំហំ A3

សូមធានាថាវិស្វករអគារបានចុះមើលរោងចក្រ ដើម្បីធានាថាគំនូសបង្ហាញកែសម្រួលតំណាងឱ្យស្ថានភាពសាងសង់នៃអគារ។

លិខិតអនុញ្ញាតពាក់ព័ន្ធទាំងអស់៖	☐	1 ច្បាប់នៃលិខិតអនុញ្ញាតនីមួយៗ
វិញ្ញាបនបត្រធ្វើតេស្តវត្ថុធាតុ	☐	1 ច្បាប់ទំហំ A4 ឬ A3
(ការធ្វើតេស្តបេតុង ការធ្វើតេស្តដែកថែប វិញ្ញាបនបត្រដែកគ្រឿងបង្គុំ វិញ្ញាបនបត្រធ្វើតេស្តតំណផ្សារ។ល។...)	☐	
របាយការណ៍អង្កេតដី៖	☐	1 ច្បាប់ទំហំ A4 សម្រាប់ឱ្យក្រុមវាយតម្លៃ
លិខិតប្រកាសអំពីសុវត្ថិភាពអគារ/ វិញ្ញាបនបត្របន្ទុក៖	☐	ចុះហត្ថលេខាដោយវិស្វករអគារ
របាយការណ៍សុវត្ថិភាពអគ្គិភ័យនៃការងារ៖	☐	1 ច្បាប់ទំហំ A4 តាមការត្រួតពិនិត្យ
របាយការណ៍ត្រួតពិនិត្យអគារពីមុន៖	☐	1 ច្បាប់ទំហំ A4 តាមការត្រួតពិនិត្យ

ព័ត៌មានអំពីគ្រឿងបង្គុំ
ប្លង់បន្ទុក និងព័ត៌មានអំពីបន្ទុក៖

សូមរៀបចំត្រៀមចែករំលែកព័ត៌មាននានា និងឆ្លើយរាល់សំណួរអំពីបញ្ហាដូចខាងក្រោម

- ☐ គ្រឿងបង្គុំ/គំនូសបង្ហាញ/ការគណនាដែលបង្ហាញអំពីបន្ទុកដែលអនុញ្ញាតនៅតាមជាន់នីមួយៗ (ប្លង់បន្ទុក)។
- ☐ បរិវេណបន្ទុកទាំងអស់ដែលធ្ងន់ជាងរោងជាង កន្លែងដេរ កាត់ និងសកម្មភាពប្រតិបត្តិការទូទៅ ឧទាហរណ៍ ការរក្សាទុកវត្ថុធាតុ បរិវេណឃ្លាំងផ្ទុកទំនិញបញ្ជាទិញមុន ធុងទឹកបណ្តោះអាសន្ន និងអ

ចិន្ត្រៃយ៍ ម៉ាស៊ីនភ្លើង បរិក្ខារកម្តៅ។ល។

- ☐ សូមណែនាំអំពីរបៀបគ្រប់គ្រងបន្ទុកជាន់។ តាមរយៈ ការកម្រិតទៅលើកម្ពស់ ឬតំបន់បន្ទុក?
- ☐ សូមណែនាំអំពីបរិវេណស្តុកឥន្ធនៈនានានៅក្នុងអគារក្បែរអគ្គិភ័យ។

ព័ត៌មានអំពីអគ្គិភ័យ

សូមរៀបចំត្រៀមចែករំលែកព័ត៌មាននានា និងឆ្លើយរាល់សំណួរអំពីបញ្ហាដូចខាងក្រោម

- ☐ របាយការណ៍ត្រួតពិនិត្យសុវត្ថិភាពអគ្គិភ័យប្រចាំឆ្នាំ
- ☐ កំណត់ត្រាតំហែទាំប្រព័ន្ធអគ្គិភ័យ
- ☐ ការផ្គង់ផ្គត់ទឹកក្រុងពីប្រព័ន្ធទឹកមេ
- ☐ ណែនាំអំពីមូលដ្ឋានផ្គត់ផ្គង់ទឹកសម្រាប់បរិវេណរោងចក្រ
- ☐ ណែនាំអំពីការផ្គត់ផ្គង់ថាមពលបម្រុងសម្រាប់ប្រព័ន្ធគ្រោះអាសន្ន
- ☐ ស្ថានីយអគ្គិភ័យនៅជិតបំផុត និងរយៈពេលឆ្លើយតបរំពឹងទុកសម្រាប់កងពន្លត់អគ្គិភ័យ
- ☐ ការហាត់សមជម្លៀសខ្លួនបន្ទាន់
- ☐ សូមណែនាំអំពីបរិវេណស្តុកឥន្ធនៈនានានៅក្នុងអគារ។

ព័ត៌មានអំពីអគ្គិសនី

សូមរៀបចំត្រៀមចែករំលែកព័ត៌មាននានា និងឆ្លើយរាល់សំណួរអំពីបញ្ហាដូចខាងក្រោម

- ☐ កំណត់ត្រាត្រួតពិនិត្យ និងថែទាំប្រព័ន្ធផ្តល់សញ្ញាអគ្គិភ័យស្វ័យប្រវត្តិ
  កំណត់ត្រាត្រួតពិនិត្យ និង/ឬធ្វើតេស្ត
- ☐ ការការពាររន្ទះ
- ☐ ឌីសង់ទ័រ
- ☐ ត្រង់ស្វូរ
- ☐ ម៉ាស៊ីនភ្លើង
- ☐ ខ្សែម៉ាសដី

ជំនួយដែលត្រូវការចាំបាច់ពីរោងចក្រ៖

- ការផ្តល់ការចេញចូលមានសុវត្ថិភាពទៅកាន់បរិវេណទាំងអស់នៃរោងចក្រ
- ការផ្តល់ជណ្តើរគ្រោងអក្សរ A សមស្រប
- ការចូលរួមពីបុគ្គលមានសមត្ថកិច្ចដើម្បីផ្តល់ការចេញចូលទៅកាន់ទូអគ្គិសនី និងបរិក្ខារអគ្គិសនី។ យើងខ្ញុំ

សូមទាញចំណាប់អារម្មណ៍របស់រោងចក្រទៅលើហានិភ័យដែលបង្កឡើងដោយការឆក់ខ្សែភ្លើង និងការឆ្លងចរន្ត ព្រមទាំងលក្ខខណ្ឌតម្រូវនៃ NFPA 70E ផងដែរ។

- ក្នុងរយៈពេលមួយថ្ងៃមុនពេលចុះវាយតម្លៃ ឧបករណ៍ការពារការឆ្លងចរន្តទាំងអស់នៅក្នុងទូអគ្គិសនីអគ្គិសនី ត្រូវតែដកចេញប្រកបដោយសុវត្ថិភាព។ កិច្ចការនេះជាទូទៅត្រូវតែធ្វើឡើងខណៈពេលដែលទូអគ្គិសនីបានផ្តាច់ចេញពីចរន្ត (បិទ)។ រាល់ការងារនៅក្នុងឬនៅលើទូអគ្គិសនីមិនត្រូវអនុវត្តឡើយ ខណៈពេលដែលឧបករណ៍ការពារការឆ្លងចរន្តត្រូវបានដកចេញ។ រាល់ឧបករណ៍ការពារការឆ្លងចរន្តនឹងត្រូវដកចេញ ដើម្បីអនុញ្ញាតឱ្យធ្វើការស្ទង់កម្តៅបានពេញលេញ។ បន្ទាប់ពីការចុះវាយតម្លៃរួច គ្រប់ឧបករណ៍ការពារការឆ្លងចរន្តទាំងអស់ត្រូវតែបំពាក់ឡើងវិញ។
- ការគាស់ផ្នាំងពិតានក្នុងអគារ អាចនឹងត្រូវអនុវត្តដោយបុគ្គលិករោងចក្រ
- ការគាស់ផ្នែកតូចៗដើម្បីពិនិត្យវត្ថុធាតុបេតុង ត្រូវធ្វើឡើងដោយបុគ្គលិករោងចក្រ (អាចនឹងត្រូវការញញួរ និងដែកដាប់)
- ការកោសថ្នាំពណ៌ចេញមួយបរិវេណតូចនៅលើធាតុគ្រោងដែក ត្រូវធ្វើឡើងដោយបុគ្គលិករោងចក្រ (អាចនឹងត្រូវការដែកកោសថ្នាំពណ៌ និងឧបករណ៍បាញ់កម្តៅ)

កំណត់សម្គាល់៖ ឯកសារទាំងនេះ ត្រូវតែមានសម្រាប់គ្រប់អគារទាំងអស់នៅក្នុងបរិវេណរោងចក្រ។

A3 គំនិតផ្តួចផ្តើម LABS ការវាយតម្លៃសុវត្ថិភាព – មគ្គុទេសក៍ជារូបភាព

មគ្គុទេសក៍
ក្នុងការអនុវត្ត
សកម្មភាពស្ងប់អគារ

ជួបជាមួយម្ចាស់រោងចក្រ

ត្រួតពិនិត្យកម្រងសំណួរ និងគំនូសប្លង់របស់វិស្វករ

ធ្វើការវាយតម្លៃពីខាងក្រៅ
ដោយប្រើកាមេរ៉ា និងកែវយឹត

ថតរូបអគារ

វាស់អគារដោយប្រើ៖

ម៉ែត្រឡាសែរ

ម៉ែត្រធម្មតា

ត្រួតពិនិត្យផ្នែកខាងក្រោមនៃកម្រាលខណ្ឌ

បើកផ្ទាំងពិតានមើល ប្រសិនបើចាំបាច់



ពិនិត្យមើលបេតុងអាមេ

ប្រើឧបករណ៍ស្កែន Ferro Scanner

ប្រើម៉ែត្រ Cover Meter

ពិនិត្យមើលបេតុង

ដោយប្រើញញ្ជរវុញសង្កត់ (Rebound Hammer)

ការស្កែនកម្តៅ

ប្រើប្រាស់កាមេរ៉ាអាំងហ្វ្រាដើម្បីស្កែនបរិក្ខារអគ្គិសនីដែលប្រតិបត្តិការនៅលក្ខខណ្ឌធម្មតា។

កំណត់តំណភ្ជាប់ដែលធ្វើប្រតិបត្តិការនៅសីតុណ្ហភាពខ្ពស់ជាងសីតុណ្ហភាពធម្មតា។

ឧបសម្ព័ន្ធ B

ការវាយតម្លៃការធ្វើតេស្តបរិក្ខារ

B1 ឧបករណ៍ស្កែន Ferroscan

ឧបករណ៍ Ferroscan

ប្រសិនបើអ្នកប្រើប្រាស់ឧបករណ៍នេះដោយប្រុងប្រយ័ត្ន វាអាចបង្ហាញពីដែកថែបអបនៅក្នុងបេតុងបាន។

យើងកំពុងប្រើប្រាស់បច្ចេកវិទ្យាទំនើបបំផុត PS250 ពី Hilti ដែលអនុញ្ញាតឱ្យយើងប៉ាន់ស្មានលើមុខបេតុងតែមួយ៖

- ចំនួន និងទីតាំងរបស់ដែក bars
- អង្កត់ផ្ចិតរបស់ដែក bar
- ស្រទាប់ការពារបេតុង

សូមកត់សម្គាល់ថាលទ្ធផលគឺជាការប៉ាន់ស្មាន ហើយត្រូវតែធ្វើការបកស្រាយដោយប្រើចំណេះដឹងវិស្វកម្មសំលេងរបស់អ្នក។

គំនូសណែនាំសម្រាប់ប្រើប្រាស់ឧបករណ៍មានដូចតទៅ ...



ជំហានទី 1 ការណែនាំអំពីខ្សែផ្តេក

បង្កើតជាគំនូសណែនាំសម្រាប់ផ្ទៃឈរនៅលើផ្ទៃបេតុង ដោយប្រើប្រាស់ដៃយូរនៅលើឧបករណ៍ស្តែននោះ (ឃ្លាតពីគ្នា 150mm)

គន្លឹះ៖

- នៅពេលដែលធ្វើការស្តែនសសរនីមួយៗ សូមស្តែនឱ្យបានខ្ពស់តាមដែលអាចធ្វើទៅបាន ដើម្បីចៀសវាងដែក starter bars/laps (ដែលអ្នកធ្វើឱ្យទិន្នន័យបង្ហាញអង្កត់ផ្ចិតរបស់ដែក bar មិនច្បាស់) ប្រើប្រាស់មុខងារ "ស្តែនរូបភាព" ហើយអ្នកត្រូវស្តែនសសរបញ្ឈរ 4 ជួរ

ជំហានទី 2 ការណែនាំអំពីខ្សែបញ្ឈរ

គូសគំនូសណែនាំបញ្ឈរនៅលើផ្ទៃរបស់បេតុង

គន្លឹះ៖

- សម្រាប់សសរតូចដូចមានបង្ហាញនៅក្នុងរូបភាពនេះ ការស្ពែនបញ្ឈរតែមួយដងគឺគ្រប់គ្រាន់ដើម្បីចាប់យកដែក shear link steel ហើយ
- ការស្ពែនផ្តេកនឹងចាប់បានដែកថែបបញ្ឈរចម្បង

ជំហានទី 3 ការស្កែនរូបភាព

I. បើកដំណើរការម៉ាស៊ីននេះដោយចុចប៊ូតុង

II. ជ្រើសយកមុខងារ "ស្កែនរូបភាព" ដូចដែលបានបង្ហាញនៅក្នុងរូបភាព ដោយប្រើប៊ូតុងព្រួញ

និងប៉ូតុង

គន្លឹះ៖

- "ការស្កែនរូបភាព" ត្រូវបានណែនាំឱ្យប្រើប្រាស់ ដោយវាអនុញ្ញាតឱ្យមានការស្កែនផ្ទៃ 4x4 (ផ្ទៃ 600 x 600mm) និងផ្តល់ជូនព័ត៌មានលម្អិតសម្រាប់ទំហំដែក bar និងកម្រាល
- "ការស្កែនលឿន" គឺស្កែនតែមួយជួរ ហើយផ្តល់ព័ត៌មានអំពីដែកថែបដែលមានកម្រាល ប៉ុន្តែមិនមានព័ត៌មានអង្កត់ផ្ចិតឡើយ
- មុខងារទីបីគឺជាបណ្តុំរូបភាពស្កែន 9 រូប សម្រាប់ផ្ទៃ 1.8 m x1.8m

ជំហានទី 4 ការស្កែនខ្សែផ្តេកជួរទី 1 ចាប់ផ្តើម

I. ដាក់ម៉ាស៊ីនស្កែនឱ្យបាន

- ចំណុចកណ្តាលស្របជាមួយនឹងផ្នែកខាងក្រៅរបស់សសរ (មានដៃយូរប្លាស្ទិកនៅកណ្តាលផ្នែកខាងមុខរបស់ម៉ាស៊ីនស្កែនដែលបង្ហាញថាត្រូវចាប់ផ្តើមស្កែនពីកន្លែងណាមក)
- ដៃយូរប្លាស្ទិកនៅចំហៀងម៉ាស៊ីនស្កែនស្របជាមួយនឹងគំនូសណែនាំ (សូមមើលរូបភាពខាងក្រោម)

II ចុចប៊ូតុង ដើម្បីឱ្យឮសំលេង "ប៊ីប" ដែលនឹងចាប់ផ្តើមធ្វើការស្កែន។ សូមអូសម៉ាស៊ីនស្កែននេះយឺតៗ ទៅចំហៀងពីខាងឆ្វេងមកស្តាំងកាត់សសរ (ចំណាយពេល ~5 វិនាទីដើម្បីស្កែនបានប្រវែង 600mm)

ជំហានទី 5 ការស្កែនខ្សែផ្តេកជួរទី 1 បញ្ចប់

អូសនៅលើសសរ។ ប្រសិនបើអ្នកបានស្កែន ផ្ទៃប្រវែង 600mm ម៉ាស៊ីន
ស្កែននឹងបញ្ឈប់ដោយស្វ័យប្រវត្តិ។ ប្រសិនបើអត់ទេ អ្នកគួរតែចុចប៊ូតុង

ឱ្យឮសំលេង "ប៊ីប" ដែលនឹងបញ្ឈប់ការស្កែន។

គន្លឹះ៖

- ប្រសិនបើអ្នកមិនសប្បាយចិត្តជាមួយនឹងលទ្ធផលស្កែនទេ (ឧ. អ្នក
  មិនបានអូសត្រង់តាមគំនូសល្អ អ្នកអាចបញ្ឈប់ការអូសនោះបាន
  ដោយ ចុចប៊ូតុង និង
  ចាប់ផ្តើមជំហានទី 4 ម្តងទៀត។

ជំហានទី 6 បញ្ចប់ការស្កែនផ្តេក

ធ្វើដូចគ្នាសម្រាប់ជួរទី 2, 3, និង 4 ដោយអនុវត្តតាមគំនូសណែនាំ
នោះឱ្យបានត្រឹមត្រូវ

គន្លឹះ៖

- នៅពេលដែលបានគូសគំនូសសម្រាប់ជួរដំបូងហើយ ម៉ាស៊ីនស្កែននេះ
  នឹងកំណត់ខ្លួនឯងដោយស្វ័យប្រវត្តិសម្រាប់ការស្កែននៅជួរបន្ទាប់ អ្នក
  ត្រូវចុចប៊ូតុង ដើម្បីចាប់ផ្តើមធ្វើការស្កែននៅពេលដែលអ្នក
  ត្រៀមលក្ខណៈរួចរាល់ហើយ។



ជំហានទី 7 ការស្កែនបញ្ឈរ

គំនូសស្កែនមានបង្ហាញដោយសញ្ញា សូមធ្វើដំណើរការបែបនេះសម្រាប់ការស្កែនផ្តេកសម្រាប់គំនូសពីលើចុះក្រោម។

គន្លឹះ៖

- ប្រសិនបើអ្នកចង់ស្កែនតែមួយជួរនៅកណ្តាលសសរ, សូមចុចប៊ូតុង ពីដងដើម្បីរំលងមួយជួរ។

ជំហានទី 8 បញ្ចប់ការស្កែន

បន្ទាប់ពីបានស្កែនគ្រប់ជ្រុងអស់ហើយ, សូមចុចប៊ូតុង ដើម្បីបញ្ចប់ការស្កែនរូបភាព។

អ្នកនឹងចូលមកដល់ Home Screen វិញដែលអ្នកនឹងឃើញការស្កែនរបស់អ្នកចូលទៅក្នុងរូបភាពមួយក្នុងចំណោមប្រាំបួន (សមត្ថភាពរបស់ម៉ាស៊ីនស្កែន)



ជំហានទី 9 ផ្ទៀរូបភាពស្តែនចូល Monitor

ពីអេក្រង់ home screen, សូមជ្រើសយក "Open Project" ហើយជ្រើសយក ឬបង្កើតគម្រោងរបស់អ្នក។

គន្លឹះ៖

- Monitor មិនមែនជាអេក្រង់ touch screen ឡើយ – សូមប្រើប្រាស់ប៊ូតុងបញ្ជានៅចំហៀង!



ពីអេក្រង់ projects screen, សូមជ្រើសយក “Import” ហើយចុច “OK”

ជំហានទី 9 ផ្ទេររូបភាពស្តែនចូល Monitor



I. ភ្ជាប់ឧយ infrared របស់ម៉ាស៊ីនស្កែនជាមួយនឹង monitor

II. នៅលើម៉ាស៊ីនស្កែន សូមចុចប៊ូតុង ដើម្បី
ចាប់ផ្តើមធ្វើការផ្ទេរហ្វាល់

គន្លឹះ៖

- សូមធ្វើសកម្មភាពនេះនៅលើតុ ឬលើផ្ទៃណាមួយដើម្បីឱ្យមានភាពងាយស្រួល

ជំហានទី 9 ផ្ទេររូបភាពស្កែនទៅ Monitor



ជំហានទី 9 ផ្ទេររូបភាពស្ពែនទៅ Monitor

នៅពេលដែលបានធ្វើការផ្ទេររួច, បញ្ជីរូបភាពស្ពែនរបស់អ្នកគួរតែមានរូបភាពនោះនៅក្នុង project របស់អ្នកដោយស្វ័យប្រវត្តិ។ អ្នកអាចឃើញរូបភាពទាំងនោះទៅតាមកាលបរិច្ឆេទ និងពេលវេលា។

សូមចុច "OK" ដើម្បីជ្រើសយករូបភាពដែលបានស្ពែនរួច។

គន្លឹះ៖

- ឧបករណ៍ស្ពែននេះ គួរតែជាការស្ពែនជោគជ័យ សូមមើលខាងក្រោម



ពណ៌ខៀវបង្ហាញដែកថែប

I. ប្រើប្រាស់ប៊ូតុងព្រួញដើម្បីសឺរ៉ូបភាព ដើម្បីជ្រើសយករបារផ្សេងៗដើម្បីផ្តល់ជូនជាកូអរដោនេ និងអង្កត់ផ្ចិត។
II. សូមថតរូបណាដែលអាចមានអត្ថប្រយោជន៍ដោយប្រើប្រាស់ IPAD ហើយដាក់ចូលទៅកាន់ PDF site survey record

គន្លឹះ៖

- ចន្លោះនីមួយៗអាចប៉ាន់ស្មានបានពី grid ឬ វាស់វែងបានពីកូអរដោនេបាន
- អង្កត់ផ្ចិតដែក Bar គឺជាទំហំស្តង់ដារបស់ដែក bar ដែលងាយនឹងមាន error ជាងគេ។ ការប៉ាន់ស្មានគួរតែធ្វើឡើងដោយផ្អែកលើទិន្នន័យជាមធ្យម និងពិចារណាទៅលើទីតាំង lap locations

ជំហានទី 10 បកស្រាយរូបភាព

B2 Schmidt Hammer

Schmidt ឬ Rebound Hammer វាស់ភាពរឹងនៃផ្ទៃបេតុង។ ប្រសិនបើក្រិតតាមខ្នាតត្រឹមត្រូវ វាអាចផ្តល់នូវការបង្ហាញពីកម្លាំងបង្ហាប់នៅក្នុងទីតាំង ប៉ុន្តែយើងត្រូវយល់ថាភាពរឹងនៃផ្ទៃនេះអាចរងឥទ្ធិពលដោយកត្តាមួយចំនួន។ Schmidt Hammer មិនមែនជាមធ្យោបាយតែមួយសម្រាប់ការវាស់វែងកម្លាំងបង្ហាប់នោះទេ។ Schmidt Hammer នៅតែមានតួនាទីដ៏មានប្រយោជន៍ក្នុងការជួយវិស្វកររចនាសម្ព័ន្ធដែលមានបទពិសោធន៍ក្នុងការធ្វើការវាយតម្លៃ។ ដំណើរការនៃការដកចេញការ render ធានាថាវិស្វករកំណត់ប្រភេទសរុប ហើយក្នុងការរៀបចំផ្ទៃសម្រាប់ការធ្វើតេស្ត Schmidt Hammer ដើម្បីឱ្យវិស្វករទទួលបាន 'ស្វែងយល់បន្ថែម' ពីបេតុង។ ដំណើរការនេះផ្តល់នូវព័ត៌មានដែលមិនអាចកាត់ថ្លៃបាន ដើម្បីជួយដល់ការវិនិច្ឆ័យវិស្វកម្ម។

ជំហានទី 1. ជ្រើសយកសសរ

I. ដើរមើលជុំវិញរោងចក្រទាំងមូលជាមុនសិន។ ធ្វើការកំណត់សសរដែលសមរម្យសម្រាប់ការធ្វើតេស្ត។ ការឈូស render ចេញគឺជាដំណើរការហុយដី ដូច្នេះយើងត្រូវតែទាក់ទងទៅម្ចាស់រោងចក្រជាមុនសិន។

II. ម្ចាស់អគារអាចនឹងទទួលយកសសរដែលមាន render ខូចខាតស្រាប់ជាង។

III. ប្រសិនបើមានសសរណាមួយដែលមានបង្ហាញថាធ្លាប់មាន core ពីមុនស្រាប់ សូមធ្វើតេស្ត Schmidt Hammer នៅទីនេះ។

IV. ការដក render នេះចេញក្នុងអំឡុងពេលបាយថ្ងៃអាចមានអំណោយផលដោយដំណើរការនេះនឹងទាក់ទាញចំណាប់អារម្មណ៍ច្រើនពីកម្មករ។

V. សូមជ្រើសយកសសរធម្មតានៅជាន់

ដែលទាបជាងគេបំផុត។

VI. ជ្រើសយកសសរធម្មតានៅជាន់លើ។

VII. ប្រសិនបើមានពេលវេលាគ្រប់គ្រាន់ ឬ ប្រសិនបើការធ្វើតេស្តមានកម្រិតទាប ឬ អថេរ សូមជ្រើសរើសសសរផ្សេងទៀត។

VIII. ប្រតិកម្មកាបូនបង្កើនភាពរឹងរបស់បេតុង។ ដូច្នេះ សសរ ខាងក្រៅដែលគ្មាន render ទំនងជានឹងផ្តល់លទ្ធផលខ្ពស់ជាងសសរខាងក្នុងដែលត្រូវមាន render

ជំហានទី 2. ឈូស render ចេញ

I. គូសការ៉ែមួយដោយប្រើឧបករណ៍ Ferro scan ដែលមានប្រវែងប្រហែល 150mm x 150mm។

II. ពាក់ស្រោមដៃ និងវ៉ែនតាការពារភ្នែក ដែលមាននៅក្នុងកញ្ចប់ឧបករណ៍។

III. ដោយប្រើញញ្ជួរដំថ្ម ឬញញ្ជួរ និងដែកដាប់ ដើម្បីបំបែកផ្ទៃ render។

IV. សូមចំណាំថាអ្នកនឹងមិនអាច 'ឈូស' ផ្ទៃរហូតទៅដល់គែមនៃ 'breakout' បានឡើយ។

ជំហានទី 3. ការរៀបចំផ្ទៃបេតុងលាត

I. ពាក់ស្រោមដៃ និងម៉ាស់ធូលីដែលមាននៅក្នុងថង់ឧបករណ៍ (ប្រើម៉ាស់ថ្មីជារៀងរាល់ថ្ងៃ)។

II. ប្រើថ្មខាត់ ហើយឈូសទៅលើផ្ទៃដែលគ្រើម ឬរលោង ឬផ្ទៃដែលមានបាយអមិនស្មើរហាប់ រហូតទាល់តែផ្ទៃនោះរលោង ហើយស្អាតលែងមានសារធាតុផ្សេងៗទៀតនៅលើផ្ទៃនោះ យ៉ាងហោចណាស់ 100mm x 100mm។ ប្រសិនបើមានចំណុចគ្រើមច្រើននៅលើផ្ទៃនោះ យើងត្រូវធ្វើការដួសខាត់លើផ្ទៃបន្ថែមទៀត។ ផ្ទៃរលោងអាចធ្វើ

III. តេស្តបានដោយមិនចាំបាច់ធ្វើការដុសខាត់។

IV. សូមប្រើច្រាស់ដែលមានផ្តល់ជូននៅក្នុងកញ្ចប់បរិក្ខារដើម្បីបោសធូលី។

V. ជូតទឹកដែលមាននៅលើផ្ទៃបេតុងចេញ។

ជំហានទី 4. ការប្រើប្រាស់ Schmidt Hammer



I. យកអំណានត្រឹមត្រូវចំនួនប្រាំបួន ដើម្បីធ្វើការប៉ាន់ស្មានដ៏គួរឱ្យទុកចិត្តសម្រាប់ទីតាងធ្វើតេស្ត។

II. ធានាមិនមានចំណុចប៉ះពាល់ចំនួនពីរស្ថិតនៅជិតគ្នាក្រោម 25 មម ហើយមិនមានចំណុចណាមួយស្ថិតនៅក្នុងកម្រិតជ្រុង 25 មម (ដូច្នេះ ទីតាងដែលបានរៀបចំត្រូវតែមានទំហំ 100 មម ការ៉ែ)

III. កាន់ញញួរឱ្យជាប់នៅក្នុងលក្ខណៈមួយដែលកន្ទុយបុកបស់វាបុកទៅនឹងផ្ទៃធ្វើតេស្ត

IV. បង្កើនសម្ពាធសង្កត់កន្ទុយរហូតទាល់តែញញួរប៉ះ

V. ទប់ជំហរបែបនេះ ហើយអានលទ្ធផលដែលបានបង្ហាញនៅលើខ្នាតនៅចំហៀង។ ចុចប៊ូតុងនៅចំហៀងញញួរ ដើម្បីឡុកអាននោះទុកដើម្បីអាចដកញញួរចេញពីផ្ទៃបាន។

VI. ពិនិត្យមើលផ្នែកនីមួយៗនៅលើផ្ទៃ បន្ទាប់ពីបុករួច ថាតើមានការបែក ឬខូចនៅក្បែៗផ្ទៃនោះដែរឬទេ

VII. បិទ លុបលទ្ធផល

VIII. ហាមដាក់ញញួរផ្ទាល់ខ្លាំងៗ ដោយសារតែវាអាចនឹងធ្វើឱ្យទទួលបានលទ្ធផលមិនត្រឹមត្រូវ។

ជំហានទី 5. កត់ត្រាលទ្ធផល

I. សរសេរលទ្ធផលនៅក្នុងសៀវភៅ ឬកត់ចូលទៅក្នុងថាស្លេត។ ប្រើ iPad ដើម្បីថតរូប។

II. បន្ទាប់ពីវាយតម្លៃរួច ត្រូវបញ្ចូលលទ្ធផលទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យមេ។



ឧបសម្ព័ន្ធ គ

Garment, Apparel, Footwear, Bags and Accessories Factory Loading Guidance

C1 ការណែនាំអំពីបន្ទុក

ដង់ស៊ីតេបេតុង

ដង់ស៊ីតេនៃការដាក់លាយថ្មធម្មតា និងថ្មអងដឺ គឺមានរៀបរាប់ដូចខាងក្រោម។

បេតុងប្រើថ្មតូច	ដង់ស៊ីតេ (kN/m^3)
បេតុងប្រើថ្មតូច	25.0

បន្ទុកមានចលនា

ទីតាំងជាន់ភាគច្រើន ត្រូវបានអង្កេតឃើញនៅក្នុងរោងចក្រកាត់ដេរ សម្លៀកបំពាក់ ស្បែកជើង ការបូប និងគ្រឿងបន្សំ គឺមានប្រតិបត្តិការកាត់ និងដេរ។ ការងារជាទូទៅ អាចនឹងមានកម្រិតស្រាល (កន្លែងធ្វើការមានតុ និងម៉ាស៊ីនដេរ ឬឆ្នាំងអ៊ុត)។ ជាទូទៅជាន់កាត់ដេរ មានបន្ទុកការងារ 1-2kN/m^2។ ស្តង់ដារ LABS តម្រូវឱ្យមានបន្ទុករស់អប្បបរមា 2kN/m^2 សម្រាប់ទីតាំងសម្រាប់គោលបំណងវាយតម្លៃដោយភ្នែកផ្ទាល់។
សូមកត់សម្គាល់ថា ផ្នែកទាំងនេះ ត្រូវបានសង្កេតមើលទៅលើបន្ទុករស់ គឺមានកម្រិតលើសបន្ទុក បន្ទុកដែលបានសង្កេត ត្រូវបានប្រើប្រាស់នៅក្នុងការគណនាតាមដានណាមួយ។

បន្ទុកឃ្លាំង

សូមយកចិត្តទុកដាក់លើទីតាំងដែលប្រើសម្រាប់ការផ្ទុកឥវ៉ាន់ ដែលអាច ឬមិនអាចមើលឃើញនៅពេលវាយតម្លៃ។ ឃ្លាំងធម្មតា រួមមានការដាក់គរគ្នានូវវត្ថុធាតុដើម (ក្រណាត់ ប្រអប់ក្រដាសកាតុងធ្វើកេស។ល។)។ រោងចក្រដែលមានច្រើនជាន់អាចនឹងរៀបចំបែបនោះ វត្ថុធាតុដើមត្រូវបានចែកចាយ និងរក្សាទុកដំបូងនៅជាន់រោងចក្រទាបបំផុត។ បន្ទាប់មកសម្ភារៈនឹងត្រូវប្រើប្រាស់ត្រូវដាក់តាមកម្រិតជាន់រោងចក្រ ដោយសារវាត្រូវបានកាត់ និងភ្ជាប់គ្នា។ សម្លៀកបំពាក់ដែលបានបញ្ចប់ត្រូវបោកគក់ ហើយចុងក្រោយត្រូវដាក់ក្នុងប្រអប់សម្រាប់ការដឹកជញ្ជូន។ ជាលទ្ធផល ជាន់ខាងលើបំផុតរបស់រោងចក្រភាគច្រើនអាចមានឧបករណ៍បោកគក់ និងសម្ភូតធុនធ្ងន់ (សូមមើលខាងក្រោម) ហើយជាន់ទាំងនេះក៏អាចមាននូវប្រអប់សម្លៀកបំពាក់ជាច្រើនផងដែរ។
ដង់ស៊ីតេធម្មតាសម្រាប់សម្ភារៈដែលបានដាក់បញ្ចូលនៅទីនេះ។ ដោយសារដង់ស៊ីតេអាចមានកម្រិតខុសគ្នា គេបានណែនាំឱ្យធ្វើការវាស់វែងនៅនឹងកន្លែងដើម្បីកំណត់ដង់ស៊ីតេធម្មតានៃសម្ភារៈនៅក្នុងប្លង់ដែលបានមាននៅក្នុងរោងចក្រ។

ក្រណាត់	ដង់ស៊ីតេ (kN/m3)	យោង
ក្រដាសកាតុង	2.5	
ក្រណាត់ដែលមិនបានធ្វើការ ឧ. គីបកាតុង គីបខោបូយ រោមសត្វ)	3.5	
សម្លៀកបំពាក់សម្រេច ដែលបានវេចខ្ចប់	2.0	
សម្លៀកបំពាក់សម្រេច គំនរលុង	1.5	
ស្បែក	8.0-9.0	
សន្លឹក PVC	16.1-17.1	សូមមើលលក្ខណៈផលិតផលនៃសន្លឹក PVC (ដង់ស៊ីតេ a=1.38 g/cm^3)
ខ្សែក្រណាត់រុំ	13.5	សូមមើលលក្ខណៈផលិតផលពូលីស្ទើ (ដង់ស៊ីតេ a=1.38 g/cm^3)

បន្ទុកម៉ាស៊ីន និងបន្ទុកឌីណាមិក

សូមយកចិត្តទុកដាក់ចំពោះជើងទម្រនៅលើឧបករណ៍នីមួយៗដែលអាចរកឃើញ និងកម្រិតរំញ័រពីម៉ាស៊ីន។

- គួរដំឡើងសន្ទះបិទខ្យល់នៅតាមជើងម៉ាស៊ីន ដើម្បីកាត់បន្ថយបន្ទុកឌីណាមិក
- ការប្រើប្រាស់បន្ទុកថេរ ជំនួយឱ្យបន្ទុកឌីណាមិកនៅលើជាន់ជណ្តើរយន្តនៅក្នុងកូឡោនគណនា FOS
- បន្ទុកឌីណាមិក ត្រូវតែពិចារណាសម្រាប់សមត្ថភាពប្រព័ន្ធតាមជាន់ និងត្រូតពិនិត្យផលរំខានដោយវិស្វករជំនាញ
- ប្រសិនបើរោងចក្រគ្រឿងចក្រមិនបានផ្តល់ព័ត៌មានអ្វីនោះទេ សូមស្នើសុំប្រើប្រាស់មេគុណបន្ទុកឌីណាមិក 1.20~1.5។

ករណីមួយចំនួនដែលមានរៀបរាប់នៅក្នុងប្រការ 16.07.8.2 នៃ IBC-2009៖

- ម៉ាស៊ីនធន់ស្រាល ដែលដំណោះរការដោយស្លៅ ឬម៉ូទ័រ៖ មេគុណបន្ទុកឌីណាមិក 1.2
- ឧបករណ៍ព្យួរសម្រាប់ជាន់ ឬរានហាល៖ មេគុណបន្ទុកឌីណាមិក 1.33
- ម៉ាស៊ីនត្រលប់ ឬផ្នែកដំណើរការដោយថាមពល៖ មេគុណបន្ទុកឌីណាមិក 1.5

ឧទាហរណ៍នៃបន្ទុក

ប្រភេទឧទាហរណ៍នៃបន្ទុក ដែលបានអង្កេតនៅក្នុងរោងចក្រដែលបានត្រួតពិនិត្យមានបង្ហាញជូនដូចខាងក្រោម។

6.3kN/m^2 (កម្ពស់ 1.8m) គំនរកម្ពស់ 1.8m នៃគីបក្រណាត់ **ប៉ានស្មានដង់ស៊ីតេក្រណាត់ដែលមិនប្រើប្រាស់ ឧ.** **3.5kN/m^2/m កម្ពស់** គំនរកម្ពស់ 1.8m ស្មើនឹងបន្ទុកផ្ទៃ 6.3kN/m^2 សូមមើលការចូលផ្ទៃកណ្តាល សន្មត់ថាដុំគីបក្រណាត់មានទម្ងន់ 55kg ក្នុងមួយដុំ ដើម្បីគណនា	
2.7kN/m^2 (កម្ពស់ 1.5m) កញ្ចប់ក្រណាត់មិនរៀបរយកម្ពស់ 1.5m **សន្មត់ថាដង់ស៊ីតេក្រណាត់រលុង ឧ. 1.8kN/m²/m កម្ពស់** គំនរកម្ពស់ 1.5m ស្មើនឹងផ្ទៃបន្ទុក 2.7kN/m^2	

មានកើនឡើងរហូតដល់ 4.0kN/m^2 (2.0m កម្ពស់) អាស្រ័យលើសមាសធាតុក្នុងប្រអប់ រោងចក្រក្រណាត់ខោប្លួយ ប្រអប់ទំហំ 45cm x 37cm x 11cm **សន្មត់ថាដង់ស៊ីតេក្រណាត់ដែវេចខ្ចប់ ឧ. 2. 0kN/m²/m កម្ពស់** កម្ពស់គំនរ 2.0m ស្មើនឹងផ្ទៃ 4.0kN/m^2 ពិនិត្យទម្ងន់ប្រអប់ និងទំហំ ហើយធ្វើការគណនាបន្ទុក	
2.5kN/m^2(កម្ពស់ 2.0m) តម្រៀបក្រដាសកាតុងរៀបស្មើកម្ពស់ 2m **សន្មត់ថាដង់ស៊ីតេក្រដាសកាតុងរៀបស្មើ ឧ. 1.25kN/m^2/m កម្ពស់** ដូច្នេះគំនរកម្ពស់2m = 2.5kN/m^2 ការវាស់វែងម្យ៉ាងទៀត៖ - ដង់ស៊ីតេ = 125kg/m^3 កត្តានេះត្រូវកំណត់ដោយការថ្លឹងទម្ងន់ក្រដាសកាតុងសំណាក 8cm x 14cm x 0.5cm កម្រាស់ (7g). ដាក់គរគ្នាកម្ពស់ 2m ស្មើនឹងបន្ទុកផ្ទៃគឺ 2.5kN/m^2។	

ការថ្លឹងទម្ងន់ម៉ាស៊ីនធុនធ្ងន់នៅតាមទីតាំង	
10 kN/m^2/m កម្ពស់ វាស់កម្ពស់ជើងកំណល់ ហើយគណនាទម្ងន់ កត់ត្រាចំណុះធុង និងគិតអំពីបន្ទុយកសរុបនៅលើសាប ធ្នឹម និងសរសរ	 

D1 បញ្ជីត្រួតពិនិត្យសុវត្ថិភាពរចនាសម្ព័ន្ធ

លរ.	សំណួរសំខាន់ៗសម្រាប់វិស្វកររផ្នែករចនាសម្ព័ន្ធ	មែន	មិនមែន	មតិយោបល់
S1	**ប្រព័ន្ធរចនាសម្ព័ន្ធបញ្ឈរ (បន្ទុកទំនាញ)**			
	តើប្រព័ន្ធទម្របញ្ឈរមើលឃើញច្បាស់ និងសមស្របទេ?			
	តើប្រើប្រាស់ប្រភេទប្រព័ន្ធរចនាសម្ព័ន្ធអ្វី?			
	តើរចនាសម្ព័ន្ធនេះមានប៉ុន្មានជាន់?			
	តើបណ្តាញរចនាសម្ព័ន្ធដែលបានវាស់វែងបានប៉ុន្មាន?			
	តើការវាស់ពីឥដ្ឋទៅពិតានមានកម្ពស់ប៉ុន្មាន?			
	តើសរសរ និងជញ្ជាំងភ្ជាប់ដោយផ្តាល់ពីដំបូលទៅកាន់ជាន់ឥដ្ឋ/គ្រឹះ ឬមានការផ្ទេរចនាសម្ព័ន្ធ?			
	តើចាំបាច់ត្រូវការការពិនិត្យការរចនា ដើម្បីផ្ទៀងផ្ទាត់សមត្ថភាពសរសរដែរឬទេ? ត្រូវពិចារណាថាតើផ្ទៃជាន់ដែលមានបន្ទុកខ្ពស់ដោយសារការដាក់បង្គរគ្នានោះនាំឱ្យមានការដាក់បន្ទុកទៅលើសរសរកម្រិតខ្ពស់ដែរឬទេ?			
	កំណត់រកផ្នែកដែលមិនអាចចូលទៅបាន ឬដែលមិនអាចបិតបាំងដោយការងារបញ្ចប់			
	តើអគារនេះប្រើប្រាស់រួមគ្នា ឬស្ថិតក្រោមការគ្រប់គ្រងរបស់អ្នកគ្រប់គ្រងរោងចក្រតែឯង? តើមានជាន់ណាដែលមិនអាចចូលបានដែរឬទេ?			
	តើដំបូល និងប្រព័ន្ធរចនាសម្ព័ន្ធជាន់មើលឃើញច្បាស់ និងសមស្របឬទេ?			
	តើដំបូល និងប្រព័ន្ធរចនាសម្ព័ន្ធជាន់មានចាក់ប្លង់សេរមួយ ឬពីរខាង?			
	តើកម្រាសជាន់ធម្មតាជាអ្វី៕			

លរ.	សំណួរសំខាន់ៗសម្រាប់វិស្វករផ្នែករចនាសម្ព័ន្ធ	មែន	មិនមែន	មតិយោបល់
	តើដំបូល និងប្រព័ន្ធរចនាសម្ព័ន្ធជាន់ មានប្លង់សេរឬទេ? ត្រូវប្រាកដថាជម្រៅប្លង់សេ (មិនរាប់បញ្ចូលការងារបញ្ចប់) គឺត្រូវបានវាស់វែង។ តើកម្លាំងបុកក្បាលសរសរ មានបញ្ហាទេនៅក្នុងផ្នែកដែលមានបន្ទុកធ្ងន់? តើការពិនិត្យរចនាសម្ព័ន្ធតម្រូវឱ្យពិនិត្យកម្លាំងបុកក្បាលសរសរដែរឬទេ?			
	តើ "ប្លង់បន្ទុកជាន់ដែលអាចអនុញ្ញាតបាន" មានសម្រាប់គ្រប់ជាន់ដែលបានផ្អាកដំណើរការ និងផ្នែកដំបូងដែរឬទេ (ប្រសិនបើអាចចូលមើលបាន)?			
	តើអ្វីជាបន្ទុករស់ដែលបានសង្កេតនៅតាមជាន់នីមួយៗ?			
	តើមានធុងស្តុកទឹកនៅតាមជានដែលបានផ្អាក់ដំណើរការ ឬជាន់ដំបូលដែលមានបន្ទុកខ្ពស់ឬទេ?			
	តើបន្ទុកជាន់ និងបន្ទុកដំបូលត្រូវបានគ្រប់គ្រងបានល្អ និងអនុលោមទៅតាមបន្ទុកជាន់រចនាដែលបានអនុញ្ញាតដែរឬទេ?			
	តើជានដែលបានសាងសង់/ពិនិត្យ និងផ្នែកបញ្ចប់មានបង្ហាញនៅផ្នែកទាំងនោះដែរឬទេ?			
	តើជានសម្រេចមានជម្រៅប៉ុន្មាន?			
	តើជាន់ឡៅតឿសាងសង់ពីបេតុង ដែក ឬឈើស្ថិតនៅក្នុងលក្ខណមួយដែលគួរជាទីពេញចិត្តឬទេ?			
	តើចំណុចតភ្ជាប់ស្ថិតនៅកន្លែងណា ប្រសិនបើមានផ្តល់ជូន?			
	ប្រសិនបើតំណចលនាអគារមានផ្តល់ជូន តើឃ្នាបប្លង់សេជាន់ នាំឱ្យមានការបន្ថែមបន្ទុកលើសរសរដែលនៅជាប់នឹងតំណទាំងនេះឬទេ?			

លរ.	សំណួរសំខាន់ៗសម្រាប់វិស្វកររៃ្មកចនាសម្ព័ន្ធ	មែន	មិនមែន	មតិយោបល់
S2	**ប្រព័ន្ធរចនាសម្ព័ន្ធដែលនៅចំហៀង (បន្ទុកខ្យល់)**			
	តើប្រព័ន្ធលំនឹងចំហៀងមានភាពច្បាស់លាស់ និងសមស្របឬទេ?			
	តើប្រព័ន្ធទម្រប្រហោងចំហាមានភាពជាន់គ្នាឬទេ?			
	សម្រាប់អគារដែក - តើមានការពង្រឹងដំបូល តាមទិសនីមួយៗទេ ហើយបើសិនជាអត់តើមានអ្វីសម្រាប់ទប់ម៉ូម៉ង់ទេ? - តើមានការពង្រឹងសសរទេ ដើម្បីបញ្ជូនបន្ទុកទៅកាន់គ្រឹះ តាមទីតាំងរបស់ដំបូលដែលត្រូវបានពង្រឹង - តើប្រព័ន្ធទប់លំនឹងមានគ្រប់គ្រាន់ទេ មានប្រើប៉ូឡុងត្រឹមត្រូវ ដើម្បីទប់កំលាំងទាញទេ?			
	សម្រាប់អគារបេតុង - តើលំនឹងចំហៀង ដែលផ្តល់ដោយជាន់ និងដ្យាក្រាមសាបដំបូលដែលមានជញ្ជាំងបេតុងនៅក្នុងជណ្តើរជើង/ស្វូលជណ្តើរយន្ត? - ប្រសិនបើជញ្ជាំងបេតុងមិនមានផ្តល់ជូនទេ ត្រូវពិនិត្យមើលប្រព័ន្ធលំនឹងថាតើមានផ្តល់ជូនដោយ សកម្មភាពស៊ុម moment frame action នៃស៊ុមបេតុងដៃរឬទេ។ តើសកម្មភាពស៊ុម moment frame action នេះមានជំនួយពីដោយការតភ្ជាប់ដំបូលនិងធ្នឹមជាន់ ឬជួរឈរយ៉ាងច្រើនឬ? - ប្រសិនបើកម្រាលឥដ្ឋជាសំណាង់រាបស្មើនិងជញ្ជាំងទប់ខ្យល់ មិនត្រូវបានផ្តល់ឱ្យទេ			

លរ.	សំណួរសំខាន់ៗសម្រាប់វិស្វកររផ្នែករចនាសម្ព័ន្ធ	មែន	មិនមែន	មតិយោបល់
	តើមានកន្លែងណាមួយដែលបង្ហាញពីភាព ភាពមិនប្រក្រតីនៃរចនាសម្ព័ន្ធដោយសារ ផ្នែកខាងក្រោយដែរឬទេ។			
	ប្រសិនបើមានគន្លាក់ចលនារបស់អគារ - សូមធ្វើការពិនិត្យ និងកត់ត្រាប្រព័ន្ធជំនួយ នៅពេលក្រោយដែលផ្តល់ជូនដល់ផ្នែក នីមួយៗនៃអគារ។			
	តើជញ្ជាំងឥដ្ឋ/ថ្ម នេះបានបង្កើតជាផ្នែកមួយ នៃប្រព័ន្ធលំនឹងសងខាងដែរឬទេ?			
	សូមកំណត់កន្លែងដែលមិនអាចប៉ះបាន ឬត្រូវ បានបិទបាំងដោយការបូកបញ្ចប់។			
S3	**ធាតុសំខាន់ៗ**			
	តើសសរទាំងនោះមានទំហំប៉ុណ្ណា (ដោយមិន គិតពីម្នាងសិលា) នៅកម្រិតទាបបំផុត និង តំបន់សំខាន់?			
	តើទំហំធ្នឹមខាងក្រោមធម្មតាមានអ្វីខ្លះ?			
	កំណត់សមាសធាតុរចនាសម្ព័ន្ធសំខាន់ៗ - ឧ. សមាសធាតុដែលនៅពេលបាក់បែកនឹង បង្កឱ្យមានការខូចខាតច្រើន។			
	ការប៉ាន់ស្មាននៃការដាក់សារធាតុបេតុងសំខា ន់ៗ (ម៉ាស៊ីនស្ពែន)			
	ការប៉ាន់ស្មានភាពរឹងមាំរបស់បេតុង - រាល់ការ អង្កេតបន្ទាប់ពីដកម្នាងសិលាចេញពីសសរ ហើយប្រើ Schmidt Hammer។			
	តើមានបន្ទះផ្ទេរ ឬធ្នឹមដែលចំណុចនៃការអនុវត្ត បន្ទុករបស់សសរត្រូវបានផ្ទេរដែរឬទេ?			
	តើមានសសរស្តើង - កម្ពស់ទ្វេរដងនៅបរិវេណ ច្រកចូល ឬនៅសម្ភារៈចូល/ចេញ ដែលផ្ទុក			

លរ.	សំណួរសំខាន់ៗសម្រាប់វិស្វកររៃ្នកររចនាសម្ព័ន្ធ	មែន	មិនមែន	មតិយោបល់
	ផលប៉ះពាល់ពីយានជំនិះដែរឬទេ?			
	កំណត់បរិវេណដែលមានប្លង់សេកុងស៊ុល cantilever; ពិចារណាថាតើការត្រួតពិនិត្យការរចនាចាំបាច់ឬទេ នៅលើប្លង់សេកុងស៊ុល cantilever ឬជួរឈរដោយសារតែការផ្ទុក cantilever និង ប៉ារ៉ាម៉ែត្ររបស់ជញ្ជាំង។ តើមានការដាក់បន្ទុកយ៉ាងសំខាន់លើតំបន់ cantilever ដែរឬទេ?			
S4	**ភាពរឹងមាំរបស់គ្រឹះ**			
	តើមានកន្លែងណាមួយដែលបង្ហាញថាការចាក់សាប មានការប្រេះនៅបរិវេណដែលនៅជាប់នឹងសសរ/ជញ្ជាំងដែរឬទេ?			
	តើមានភស្តុតាងនៃចលនាឌីផេរ៉ង់ស្យែលនៃធាតុផ្សំនៃរចនាសម្ព័ន្ធដូចជាជួរឈរ និងជញ្ជាំងជាប់គ្នាដែរឬទេ?			
S5	**ការខូចខាតដែលអាចឃើញច្បាស់នៅលើផ្ទៃគ្រឹះ**			
	តើមានកន្លែងណាដែលបង្ហាញការបាក់បែកលើផ្ទៃគ្រឹះដែរឬទេ? ប្រសិនបើមាន តើបណ្តាលមកពីមូលហេតុអ្វីខ្លះ?			
	តើមានកន្លែងណាដែលបង្ហាញការរមួល ការបង្វិល ឬការផ្លាតខ្លាំងពេកផ្ទៃគ្រឹះដែរឬទេ? ប្រសិនបើមាន តើបណ្តាលមកពីមូលហេតុអ្វីខ្លះ?			
S6	**ការខូចខាតដែលអាចមើលឃើញច្បាស់នៅលើផ្ទៃមិនមែនគ្រឹះ**			

លរ.	សំណួរសំខាន់ៗសម្រាប់វិស្វកររផ្នែករចនាសម្ព័ន្ធ	មែន	មិនមែន	មតិយោបល់
	តើមានសញ្ញានៃការខូចខាតណាមួយនៅលើផ្ទៃដែលមិនមែនជាគ្រឹះដែលអាចបង្ហាញពីបញ្ហាចលនារំកិលដែរឬទេ? ឧ. ការបាក់បែកផ្ទៃខាងមុខ ការប្រេះជញ្ជាំងខាងក្នុង និងការខូចខាតគ្រឹះ។ ប្រសិនបើដូច្នេះ តើបណ្តាលពីមូលហេតុអ្វីខ្លះ?			
S7	**ភាពរឹងមាំរបស់សំណង់បន្ថែម**			
	តើសំណង់បន្ថែមទាំងអស់ (បញ្ឈរ និងផ្តេក) មានរួមបញ្ចូលនៅលើឯកសារគ្រឹះដែលមានផ្តល់ជូនដែរឬទេ?			
	តើមានសំណង់បន្ថែមណាដែលជាសំណង់ក្រៅផ្លូវការដែរឬទេ?			
	តើមានកន្លែងណាដែលបង្ហាញថាផ្នែកណាមួយនៃអគារធ្លាប់បានបំបែកពីមុន ឬមានសំណង់បន្ថែមដែលមិនបានរាប់បញ្ចូលនៅក្នុងសំណង់ដើមរបស់អគារដែរឬទេ?			
S8	**ឯកសាររបស់គ្រឹះ**			
	តើមានរបាយការណ៍សវនកម្មលើគ្រឹះពីមុនពីផ្នែកគ្រប់គ្រងរោងចក្រដែរឬទេ? សូមពិនិត្យមើលថាតើសកម្មភាពដែលបានលើកឡើងនៅលើរបាយការណ៍ទាំងនេះត្រូវបានបំពេញឬអត់។			
	តើឯកសារនោះមានស្ថានភាព និងកាលបរិច្ឆេទអ្វី?			
	តើមានរបាយការណ៍តេស្តដី ដែរឬទេ ហើយប្រភេទគ្រឹះដែលបានណែនាំមានបង្ហាញនៅក្នុងការគូរប្លង់ដែរឬទេ?			
	តើប្លង់បន្ទុកដែលអាចអនុញ្ញាតបានមានសម្រាប់គ្រប់ជាន់ និងនៅលើបរិវេណដំបូលដែរឬទេ?			

លរ.	សំណួរសំខាន់ៗសម្រាប់វិស្វករផ្នែករចនាសម្ព័ន្ធ	មែន	មិនមែន	មតិយោបល់
	តើប្លង់គ្រឹះដែលបានផ្តល់ជូនជាទូទៅសមស្របជាមួយនឹងគ្រឹះនៅតាមមូលដ្ឋានដូចបានត្រួតពិនិត្យដែរឬទេ? មានចំណុចណាខ្លះដែលមិនសមស្រប?			
S9	**ការថែទាំ**			
	តើមានកន្លែងណាដែលបង្ហាញថាខ្វះការថែទាំដែលនឹងបណ្តាលឱ្យមានបញ្ហាគ្រឹះដែរឬទេ?			
	តើដែកគ្រឹះមានការច្រែសដែរឬទេ?			
	តើមានការដក់ទឹកនៅលើដំបូល ឬនៅជាន់ណាផ្សេងដែលអាចបង្កឱ្យមានការពុកអគារដែរឬទេ?			

ឧបសម្ព័ន្ធ ខ
បញ្ជីទាយតម្លៃសុខត្ថិភាពអគ្គិភ័យ

E1 បញ្ជីវាយតម្លៃសុវត្ថិភាពអគ្គិភ័យ

ល.រ		អនុ-ប្រភេទ	ការអង្កេត	ការពណ៌នាអគារ / បរិវេណ		
1		**ច្រកចេញ**				
	1-1	ច្រកចេញតាមជាន់នីមួយៗ	ចំនួនច្រកចេញមិនគ្រប់គ្រាន់			
			ទទឹងសរុបនៃទ្វារចេញតូចពេក			
			មិនមានផ្តល់ជូនទិសដៅជំនួយសម្រាប់ការចាកចេញ			
			ចម្ងាយទៅច្រកចេញឆ្ងាយពេក			
			ទ្បៅតឿមិនមានច្រកចេញគ្រប់គ្រាន់			
			បន្ទប់ក្រោមដីមិនមានច្រកចេញគ្រប់គ្រាន់			
	1.2	ច្រកចេញ	ទទឹងនៃច្រកចេញតូចពេក			
			ទ្វារខាងក្នុងរបស់ច្រកចេញ មិនចូលចំហៀង និង/ឬមិនមានឧបករណ៍ដែលអាចចាក់សោបានទេ។			
			ច្រកចេញមានវត្ថុរារាំងដែលអាចរើចេញបាន			
			ច្រកចេញមានវត្ថុរារាំងជាប់មិនអាចរើចេញបាន			
			ផ្លូវទាល់លើសទៅច្រកផ្លូវ ឬច្រករបៀង			
			ទ្វារច្រកចេញទាប ហើយមានខណ្ឌនៅច្រកចេញ			
	1.3	ស្លាកសញ្ញានៅច្រកចេញ	ច្រកចេញមិនបង្ហាញច្បាស់លាស់នៅតាមជាន់នីមួយៗ			

			ស្លាកច្រកភៀសខ្លួនមិនមានដាក់ត្រឹមត្រូវ			
			អំពូលរបស់ស្លាកនៅច្រកចេញមិនភ្លឺ ឬភ្លឺមិនគ្រប់គ្រាន់			
			រូបភាព និង/ឬពណ៌មិនស៊ីគ្នាសម្រាប់ស្លាកនៅច្រកចេញ			
	1.4	ទ្វារនៅច្រកចេញ	ទ្វារចេញបើកមិនសមស្របជាមួយទិសដៅច្រកចេញ			
			ទ្វារចេញពិបាកបើកចេញ, ទ្វារមានសោរចាក់			
			ច្រកចេញផ្សេងៗទៀត			
	1.5	ជណ្តើរច្រកចេញ	ជណ្តើរ និងទ្វារចេញចូលមានទទឹងខ្លីពេក			
			កាំជណ្តើរមិនសមស្របជាមួយនឹងជណ្តើរ			
			កាំជណ្តើរចោទពេកសម្រាប់ការគេចខ្លួនពេលមានអាសន្ន			
			ជណ្តើរមិនមានបង្កាន់ដៃ			
			មិនមានច្រកសុវត្ថិភាពពីជណ្តើរទៅខាងក្រៅ			
	1.6	ច្រកចេញចុងក្រោយ	ទទឹងនៃច្រកចេញទៅជាន់ផ្ទាល់ដីខ្លីពេក			

ល.រ		**អនុ- ប្រភេទ**	**ការអង្កេត**	**ការពណ៌នាអគារ / បរិវេណ**		
			មនុស្សមិនអាចផ្លាស់ទីដោយសុវត្ថិភាពចេញពីអគារដោយផ្ទាល់នៅពេលចេញទៅខាងក្រៅ			
			ច្រកចេញផ្សេងទៀត			
2		**សំណង់ដែលការពារអគ្គិភ័យ**				

	2.1	ការការពារច្រកចេញ	ខ្វះរបាំងជណ្តើរជាប់គ្នាលើសពី 2 ជាន់			
			មិនមានទ្វារបិទដោយស្វ័យប្រវត្តិដែលអាចការពារជណ្តើរបាន។			
			ចន្លោះដែលមិនមានសុវត្ថិភាពនៅតាមរបាំងជណ្តើរ			
			ជណ្តើរមិនមានរបាំងការពារត្រឹមត្រូវពីអគ្គិភ័យនៅខាងក្នុង			
			បំពង់បញ្ឈរនៅតាមអគារមិនមានរបាំងការពារត្រឹមត្រូវពីជាន់មួយទៅជាន់មួយ			
			មិនមានការបែងចែក FR ពីជណ្តើរយោង			
			បំពង់បញ្ឈរផ្សេងៗនៅតាមជាន់តូចៗ			
			មានរបាំងការពារជាន់ក្រោមដីជាមួយនឹង FR lobby ជញ្ជាំង និងទ្វារបិទដោយស្វ័យប្រវត្តិ			
	2.2	ការបែងចែកបន្ទុក	ការប្រើប្រាស់បរិវេណដែលមានបរិវេណច្រើនពេកដែលមិនអាចចាត់ទុកថាជា 'បន្ទុកដោយឧបទ្ទវហេតុ'			
			ការបែងចែកបន្ទុកផ្សេងៗមិនមានផ្តល់ជូន ឬមិនគ្រប់គ្រាន់			
	2.3	បរិវេណផ្ទុកសម្ភារៈ	បរិវេណសម្រាប់ផ្ទុកសម្ភារៈដែលមិនមានបែងចែកពីសំណង់ FR			
			បរិវេណផ្ទុកសម្ភារៈដែលបែរមុខទៅកាន់ច្រកចេញ			
			បរិវេណច្រើនលើសសម្រាប់ផ្ទុកសម្ភារៈ 'កំពុងដំណើរការ' បើកទៅបរិវេណផលិតកម្ម			
			បរិវេណច្រើនលើសសម្រាប់ផ្ទុក			

			សម្ភារៈ 'កំពុងដំណើរការ' បើកទៅកាន់បរិវេណផលិតកម្ម			
			បរិវេណច្រើនលើសសម្រាប់ផ្ទុកសម្ភារៈ 'កំពុងដំណើរការ' បើកទៅកាន់បរិវេណផលិតកម្ម			
			បរិវេណផ្ទុកសម្ភារៈផ្សេងៗ (ឧ. នៅក្រោម ឬនៅលើជណ្តើរ)			
	2.4	បរិវេណហានិភ័យខ្ពស់ផ្សេងៗ	ម៉ាស៊ីនភ្លើងមិនមានរបាំងការពារគ្រប់គ្រាន់			
			បន្ទប់ដាក់ម៉ាស៊ីនកម្តៅមិនមានរបាំងការពារគ្រប់គ្រាន់			
			ម៉ាស៊ីនសម្ពាធខ្យល់ធំដែលមិនមានរបាំងការពារគ្រប់គ្រាន់			
			ម៉ាស៊ីនត្រង់ស្វូមិនមានរបាំងការពារត្រឹមត្រូវ			
			បន្ទប់ដាក់សារធាតុគីមីមិនមានរបាំងការពារត្រឹមត្រូវ			
			ផ្សេងៗ			

ល.រ		អនុ- ប្រភេទ	ការអង្កេត	ការពណ៌នាអគារ / បរិវេណ		
	2.5	គ្រឹះ និង ផ្នែចុងក្រោយ	ផ្នែកការពារគ្រឹះពីអគ្គិភ័យ			
			ផ្នែជញ្ជាំងដែលមិនមានអនុលោមភាព			
			ផ្នែពិដានដែលមិនមានអនុលោមភាព			
3		**ប្រព័ន្ធការពារអគ្គិភ័យ**				
	3.1	ការចាប់បានអគ្គិភ័យ	ប្រភេទឧបករណ៍ចាប់ភ្លើងមិនសមស្រប			
			ការគ្របដណ្តប់ឧបករណ៍ចាប់ភ្លើងមិនគ្រប់គ្រាន់			
			ទីតាំងឧបករណ៍ចាប់ភ្លើងមិនត្រឹមត្រូវ			
			ថាមពលបម្រុងទុកមិនគ្រប់គ្រាន់ចំពោះឧបករណ៍ចាប់សញ្ញា			
	3.2	សំឡេងរោទ៍អគ្គិភ័យ	ប្រភេទសំឡេងរោទ៍ភ្លើងមិនស័ក្តិសម (ជាសំឡេង និងរូបភាព)			
			ការគ្របដណ្តប់សំឡេងរោទ៍អគ្គិភ័យមិនគ្រប់គ្រាន់			
			ការលោតសំឡេងរោទ៍អគ្គិភ័យមិនត្រឹមត្រូវ			
			ថាមពលបម្រុងទុកមិនគ្រប់គ្រាន់សម្រាប់សំឡេងរោទ៍អគ្គិភ័យ			
	3.3	ភ្លើងពេលមានអាសន្ន	ពន្លឺភ្លើងអាសន្នមិនគ្រប់គ្រាន់សម្រាប់ផ្លូវចាកចេញ			
			ភ្លើងអាសន្ននៅច្រកចេញ			
			មិនបានផ្តល់ភ្លើងបំភ្លឺសង្គ្រោះបន្ទាន់ទេ។			

			ថាមពលបម្រុងទុកមិនគ្រប់គ្រាន់សម្រាប់ភ្លើងអាសន្ន			
			ការកំណត់ខ្សែភ្លើងនៃប្រព័ន្ធភ្លើងអាសន្នមិនត្រឹមត្រូវ			
4		**ឧបករណ៍សម្រាប់ការពន្លត់អគ្គិភ័យ**				
	4.1	ការផ្គត់ផ្គង់ទឹក	គ្មានប្រភពទឹកចម្បងពីទីក្រុង			
			មិនមានទឹកគ្រប់គ្រាន់នៅក្នុងបរិវេណសម្រាប់ប្រព័ន្ធពន្លត់អគ្គិភ័យ			
			មិនមាន ឬមានម៉ាស៊ីនបូមទឹកមិនគ្រប់គ្រាន់។			
			ការផ្ទុកទឹកមិនគ្រប់គ្រាន់សម្រាប់បំពង់ទុយោពន្លត់អគ្គិភ័យសម្រាប់ម៉ាស៊ីនបូមទឹកដែលមាន			
			ម៉ាស៊ីនបូមទឹកមិនមានស្តុកទឹកគ្រប់គ្រាន់			
			ម៉ាស៊ីនបូមទឹកត្រូវបើកដោយដៃផ្ទាល់			
	4.2	ប្រព័ន្ធពន្លត់អគ្គិភ័យ	ប្រព័ន្ធបូមទឹកមិនគ្រប់គ្រាន់			
			មិន ឬមានប្រព័ន្ធបំពង់ទុយោភ្លើងខាងក្នុងមិនគ្រប់គ្រាន់			
			ឧបករណ៍ពន្លត់អគ្គិភ័យចល័តមិនគ្រប់គ្រាន់			
			ឧបករណ៍ពន្លត់អគ្គិភ័យចល័តមិនមានសញ្ញាសម្គាល់ទេ។			
			ឧបករណ៍ពន្លត់អគ្គិភ័យចល័តមិនត្រូវបានពិនិត្យ និងដាក់ស្លាកទេ។			
			មិនមានប្រព័ន្ធពន្លត់ដោយស្វ័យប្រវត្តិទេ។			
	4.3	ផ្លូវចូល	មិនមានផ្លូវចូលគ្រប់គ្រាន់សម្រាប់រថយន្តពន្លត់អគ្គិភ័យ			

			បញ្ហាផ្សេងៗ			
5		**ការថែទាំ និងការរៀបចំ**				
	5.1	ឯកសារផ្លូវច្បាប់	ការចាត់ថ្នាក់អគ្គិភ័យ; តើរោងចក្រមានព័ត៌មានអ្វីខ្លះក្នុងឧបសម្ព័ន្ធ			
			ឯកសារផ្សេងទៀតរបស់អាជ្ញាធរពន្លត់អគ្គិភ័យ			
	5.2	កំណត់ត្រាថែទាំ	កំណត់ត្រាថែទាំមិនគ្រប់គ្រាន់សម្រាប់ប្រព័ន្ធសំឡេងរោទ៍			
			កំណត់ត្រាថែទាំមិនគ្រប់គ្រាន់សម្រាប់ភ្លើងអាសន្ន			
			កំណត់ត្រាថែទាំមិនគ្រប់គ្រាន់សម្រាប់បំពង់ទឹកបាញ់ពន្លត់អគ្គិភ័យ			
			កំណត់ត្រាថែទាំប្រព័ន្ធពន្លត់មិនគ្រប់គ្រាន់			
	5.3	ផែនការសង្គ្រោះបន្ទាន់	មានឯកសារមិនគ្រប់គ្រាន់ ឬគ្មានផែនការសង្គ្រោះបន្ទាន់			
			អ្នកទទួលខុសត្រូវដែលបានចាត់តាំង និងប្រគល់ភារកិច្ចដែលបានចងក្រងជាឯកសារ			
			ប្លង់សង្គ្រោះបន្ទាន់បានបិទបង្ហាញនៅច្រកចេញនៅជាន់នីមួយៗ			
	5.4	ការបណ្តុះបណ្តាលសុវត្ថិភាពអគ្គិភ័យ	មិនមានភស្តុតាងនៃការបណ្តុះបណ្តាលបុគ្គលិក និងកាតព្វកិច្ចសង្គ្រោះបន្ទាន់ទេ។			
			កំណត់ត្រាមិនគ្រប់គ្រាន់នៃសមយុទ្ធពន្លត់អគ្គិភ័យធម្មតា។			
	5.5	ការរៀបចំ	ទំនិញដែលបានរក្សាទុក ឧបសគ្គនៅលើច្រកចេញ			

			ទំនិញដែលស្តុកទុក ឧបសគ្គនៅតាមជណ្តើរ			
			ទំនិញដែលអាចឆេះបានដាក់នៅជិតប្រភពកំដៅ/អគ្គិសនី			
			ផ្សេងៗ			

ឧបសម្ព័ន្ធ F
បញ្ជីត្រួតពិនិត្យការវាយតម្លៃសុវត្ថិភាពអគ្គិសនី

F1 បញ្ជីត្រួតពិនិត្យសម្រាប់ការវាយតម្លៃសុវត្ថិភាពអគ្គិសនី

ល.រ	អនុប្រភេទ	ការអង្កេត	សេចក្តីពណ៌នាអំពីអគារ/ទីធ្លារ		
1	**ការផ្គត់ផ្គង់ទៅកាន់ប្រព័ន្ធសុវត្ថិភាពអាយុជីវិត**				
		ការធ្លាក់ចុះតង់ស្យុងសម្រាប់បរិក្ខារអាសន្ន ដែលផ្តល់ជូននៅក្នុង SLD?			
		ពិនិត្យមើលប្រភពផ្គត់ផ្គង់ថាមពលមេ និងបន្សំទៅកាន់ទូអគ្គិសនីឧបករណ៍ផ្តល់សញ្ញាអគ្គិភ័យ			
		ពិនិត្យមើលប្រភពផ្គត់ផ្គង់ថាមពលមេ និងបន្សំទៅកាន់ភ្លើងបំភ្លឺពេលមានអាសន្ន			
		ពិនិត្យមើលប្រព័ន្ធខ្យល់ចេញចូលអាគុយ			
		ពិនិត្យមើលថាតើការសាកអាគុយដំណើរការដែរឬទេ			
		ពិនិត្យមើលថាតើកណ្តឹងរោទ៍ផ្តល់សញ្ញាអាគុយដំណើរការដែរឬទេ ឧទាហរណ៍ ប្រសិនបើអាគុយបានផ្តាច់ចេញពីផ្នាំងជានែល តើទូអគ្គិសនីនោះបង្ហាញពីកំហុសដែរឬទេ			
2	**ខ្សែម៉ាសដី និងការតភ្ជាប់**				
		ពិនិត្យមើលតំណភ្ជាប់ផ្នែកការងារលោហៈ (គ្រឿងម៉ាស៊ីន គ្រឿងបង្គុំ បំពង់ថាមពលលោហៈ) ទៅកាន់ម៉ាសដី			
		ពិនិត្យមើលថាតើតំណខ្សែណឺតមានបែកបាក់ដែរឬទេនៅទូទាំងបរិវេណអគារ។			
		តើមានប្រព័ន្ធខ្សែម៉ាសដីខូចខាត ឬដាច់ដែរឬទេ?			
		តើមានគំនូសនៃដែលមេនៃម៉ាសដី និងតំណភ្ជាប់ដែរឬទេ?			
		តើអាំងប៉េដង់អេឡិចត្រូតម៉ាសដីត្រឹមត្រូវដែរឬទេ?			
		តើឧបករណ៍ចរន្តសំណល់បានប្រើប្រាស់ត្រឹមត្រូវដែរឬទេ			
		ពិនិត្យមើលទំហំនៃខ្សែចម្លងមេតភ្ជាប់មានប៉ូតង់ស្យែលស្មើគ្នា			

		តើបានផ្តល់រង្វាស់អាំងប៉េដង់រង្វង់ម៉ាសដីដែរឬទេ?			
		ស្ថានភាពទូទៅនៃប្រព័ន្ធការពាររន្ទះ៖ រកឃើញមានខ្សែចម្លង និងសមាសធាតុដែលខូចខាត ឬមិនបានជួសជុលដែរឬទេ?			
		ស្ថានភាពទូទៅអំពីប្រព័ន្ធការពាររន្ទះ៖ តើមានឃើញការឡើងច្រែះដែរឬទេ?			
		ពិនិត្យមើលគ្រឿងបង្គុំដែលមិនបានគ្របដណ្តប់ដោយប្រព័ន្ធការពាររន្ទះ។			
		ការតភ្ជាប់ប៊ូតង់ស្បែលស្មើគ្នាសម្រាប់គ្រប់ប្រព័ន្ធទាំងអស់ដែលឧបករណ៍បរិក្ខារត្រូវបានតភ្ជាប់ដោយផ្ទាល់ទៅកាន់ប្រព័ន្ធការពាររន្ទះ			
		តើមានផ្តល់ជូនការគណនាអំពីការការពាររន្ទះដែរឬទេ?			
		តើមានព័ត៌មានអំពីប្រភេទ និងការការពាររន្ទះដែរឬទេ?			
3	**ម៉ាស៊ីនភ្លើង**				
		ពិនិត្យមើលថាប្រភេទម៉ាស៊ីនភ្លើងមានបញ្ជាក់ច្បាស់លាស់នៅក្នុងឯកសារ និងនៅលើបរិក្ខារដែរឬទេ			
		ពិនិត្យមើលថាសមត្ថភាពម៉ាស៊ីនភ្លើងដូចគ្នាទៅនឹងសមត្ថភាពដែលមានបញ្ជាក់នៅក្នុងតារាងថាមពល			
		ការចែកចាយអគ្គិសនី ការចាក់សោរសុវត្ថិភាពខ្សែម៉ាសដី និងបណ្តាញមូលដ្ឋានបានធ្វើឡើងដែរឬទេ?			
		ពិនិត្យមើលថាលក្ខខណ្ឌតម្រូវបេនឥន្ធនៈមានភាពគ្រប់គ្រាន់សម្រាប់ការប្រើប្រាស់ដែរឬទេ			
		ពិនិត្យមើលការតភ្ជាប់ខ្សែម៉ាសដីពីគ្រោងម៉ាស៊ីនភ្លើង			
		ពិនិត្យបេនឥន្ធនៈរកមើលការលេចធ្លាយ			
		ប្រសិនបើការបញ្ជូនឥន្ធនៈម៉ាស៊ីនភ្លើងពឹងផ្អែកលើម៉ាស៊ីនបូមឥន្ធនៈ សូមពិនិត្យថាតើថាមពលទៅកាន់ម៉ាស៊ីនបូម ត្រូវបានបម្រុងទុកដែរឬទេ			

		ពិនិត្យមើលថាអាគុយម៉ាស៊ីនភ្លើងបានតាមដានត្រួតពិនិត្យដែរឬទេ (ការតាមដានត្រួតពិនិត្យនេះអាចធ្វើឡើងដោយដៃ ឬដោយស្វ័យប្រវត្តិ)			
		ពិនិត្យរកមើលសារធាតុរាវដែលលេចចេញពីម៉ាស៊ីនភ្លើង ធុង និងទុយោ			
		ពិនិត្យរកមើលសញ្ញារបស់ប្រព័ន្ធខ្យល់ចេញចូលមានការគ្រប់គ្រាន់ដែរឬទេ			
		ពិនិត្យមើលថាច្រកខ្យល់ចូលគួរស្ថិតនៅឆ្ងាយពីប្រភពកម្តៅតាមជាក់ស្តែង និងឱ្យមានកម្រិតទាបតាមដែលអាចធ្វើបាន។			
		ពិនិត្យមើលថាតើបំពង់ផ្សែងស្ថិតនៅទីតាំងខ្ពស់បំផុតដែរឬទេ ជាការល្អគួរតែស្ថិតនៅពីលើម៉ាស៊ីនចំតែម្តង។			
		ពិនិត្យមើលដើម្បីបញ្ជាក់ថាច្រកខ្យល់ចូលនិងច្រកខ្យល់ចេញ គួរតែកំណត់ទីតាំងដើម្បីការពារខ្យល់ចេញពីបំពង់ស៊ីម៉ាំងត្រូវស្រូបចូលទៅក្នុងច្រកខ្យល់ចូល (ចរន្តខ្យល់ចេញចូល)។			
4	**អនុស្ថានីយ**				
		ពិនិត្យមើលដើម្បីប្រាកដបន្ទប់អគ្គិសនីមិនត្រូវបានប្រើប្រាស់សម្រាប់ទុកដាក់សម្ភារនិងបរិក្ខារនោះទេ			
		តើមានការកំណត់ និងការបិទស្លាកសម្គាល់នៅអនុស្ថានីយបានគ្រប់គ្រាន់ដែរឬទេ?			
		តើនៅក្នុងអនុស្ថានីយ មានសញ្ញាព្រមាននិងការជូនដំណឹងអំពីគ្រោះថ្នាក់គ្រប់គ្រាន់ដែរឬទេ?			
		តើប្រភពផ្គត់ផ្គង់ថាមពលមេគ្រប់គ្រាន់សម្រាប់លក្ខខណ្ឌតម្រូវថាមពលរបស់អគារដែរឬទេ?			
		តើទីតាំងអនុស្ថានីយសមស្របដែរឬទេ?			
		តើមានបំពាក់ឧបករណ៍ខ្យល់ចេញចូលក្នុងបន្ទប់ត្រង់ស្វរដែរឬទេ?			
		តើមានបំពាក់តម្រងប្រេងត្រង់ស្វរតាមទំហំត្រឹមត្រូវដែរឬទេ?			

		តើមានសញ្ញាបង្ហាញពីការចូលទឹកដែរឬទេ?			
		តើមានព័ត៌មានលម្អិតអំពីប្រភេទ និងការការពាររន្ធះដែរឬទេ			
		បន្ទប់ស្អាត មានរបៀបរៀបរយ និងមិនត្រូវបានប្រើប្រាស់ជាទីតាំងស្តុកឥវ៉ាន់			
		ថាមពល (អំពូលបំភ្លឺ ព្រីភ្លើង) ដំណើរការ			
		ទ្វារ និងបង្អួចមានសុវត្ថិភាព ហើយនៅពេលចាំបាច់ ត្រូវចាក់សោរ			
		មិនមានសញ្ញាអំពីការខូចខាតចំពោះបរិក្ខារឬបន្ទប់			
		បន្ទប់មិនមានរុក្ខជាតិដុះស្អេកស្កះ ហើយច្រកចេញចូលគឺអាចទទួលយកបាន			
		តើមានសញ្ញានៃសកម្មភាពកណ្តុរដែរឬទេ?			
		ប្រព័ន្ធខ្យល់ចេញចូល (ប្រព័ន្ធខ្យល់ចេញចូលត្រូវតែរចនាឡើងដោយអនុលោមតាមសេចក្តីណែនាំរបស់រោងចក្រផលិតបរិក្ខារ)			
		មានស្លាកសញ្ញាព្រមាន			
		ស្លាកសញ្ញា និងឧបករណ៍សង្គ្រោះបឋមពេលមានអាសន្ន			
		តម្រងប្រេងសម្រាប់ត្រង់ស្វូរមិនមានប្រេងលើសពី 2000 លីត្រឡើយ។			
5	**បន្ទះចែកចាយ**				
		ពិនិត្យមើលថាខ្សែភ្លើងត្រូវបានទ្រត្រឹមត្រូវ			
		ពិនិត្យមើលថាខ្សែភ្លើងត្រូវបានរៀបស្របតាមការរចនាដែរឬទេ?			
		សមត្ថភាពចម្លងចរន្តរបស់ខ្សែភ្លើងសមស្របសម្រាប់ការប្រើប្រាស់ដែរឬទេ?			
		តើមានការកំណត់អត្តសញ្ញាណ និងការបិទស្លាកសម្គាល់នៅបន្ទះចែកចាយទាំងអស់បានគ្រប់គ្រាន់ដែរឬទេ?			
		តើមានការកំណត់អត្តសញ្ញាណ និងការបិទស្លាកសម្គាល់បានគ្រប់គ្រាន់នៅលើសៀគ្វីទាំងអស់នៅលើបន្ទះចែកចាយដែរឬទេ?			
		តើនៅក្នុងបន្ទះចែកចាយ មានសញ្ញាព្រមាន និងការជូនដំណឹងអំពីគ្រោះថ្នាក់			

		គ្រប់គ្រាន់ដែរឬទេ?			
		តើមានការការពារគ្រប់គ្រាន់សម្រាប់ប្រព័ន្ធខ្សែភ្លើងពីការខូចខាត និងការខូចទ្រង់ទ្រាយផ្សេងៗ ឧទាហរណ៍ កម្តៅ ទឹក ដែរឬទេ?			
		តើមានខ្សែភ្លើង ឬខ្សែចម្លងស្រាត ដោយសារតែការខូចខាត ការច្រែះ បាត់គម្រប -ល- ដែរឬទេ?			
		តើមានរបាំង ឬរបាំងការពារគ្រប់គ្រាន់ដើម្បីការពារពីការប៉ះផ្ទាល់ដែរឬទេ? តើរបាំង ឬរបាំងការពារទាំងនោះប៉ះទង្គិចដែរឬទេ ឧទាហរណ៍ ដោយសារតែការខូចខាត?			
		ពិនិត្យរកមើលធូលីដី និងកម្ទេចក្រណាត់នៅក្នុងទូអគ្គិសនីអគ្គិសនី			
		ពិនិត្យរកមើលធូលីដី និងកម្ទេចក្រណាត់នៅខ្សែភ្លើង			
		តើមានទុយោទន់ខូចខាតដែរឬទេ?			
		ពិនិត្យរកវត្ថុធាតុងាយឆាបឆេះនៅក្នុងទូអគ្គិសនីអគ្គិសនី			
		តើមានព័ត៌មានអំពីប្រភេទ និងការការពារន្ទះដែរឬទេ?			
		តើខ្សែភ្លើងត្រូវបានបែងចែកដាច់ពីគ្នានៅក្នុងត្រែខ្សែភ្លើងដែរឬទេ?			
		តុល្យភាពបន្ទុកនៅក្រោមស្ថានភាពធម្មតាត្រូវបានផ្តល់ជូនដែរឬទេ?			
		តុល្យភាពបន្ទុកនៅក្រោមស្ថានភាពអាសន្នត្រូវបានផ្តល់ជូនដែរឬទេ?			
		ខ្សែចម្លងត្រូវតែកឹបក្បាល ឬមានព្រីខ្សែភ្លើង			
6	**គំនូសប្លង់**				
		តើរោងចក្រមា នSLD ដែរឬទេ?			
		តើនៅរោងចក្រមានដ្យាក្រាមខ្សែម៉ាសដីបច្ចុប្បន្នភាពដែរឬទេ?			
		តើរោងចក្រមានដ្យាក្រាមឧបករណ៍ផ្តល់សញ្ញាអគ្គិភ័យ បច្ចុប្បន្នភាពដែរឬទេ?			
		តើរោងចក្រមានគំនូសព្រាងបន្ទះចែកចាយ			

		បច្ចុប្បន្នភាពដែរឬទេ?			
		តើរោងចក្រមានគំនូសព្រាងថាមពលគួច បច្ចុប្បន្នភាពដែរឬទេ?			
		តើរោងចក្រមានគំនូសព្រាងអំពូលបំភ្លឺ និងភ្លើងបំភ្លឺពេលមានអាសន្នបច្ចុប្បន្នភាពដែរឬទេ?			
		តើរោងចក្រមានគំនូសព្រាងឧបករណ៍ផ្តល់សញ្ញាអគ្គិភ័យ បច្ចុប្បន្នភាពដែរឬទេ?			
		តើរោងចក្រមានគំនូសព្រាងការការពាររន្ទះ បច្ចុប្បន្នភាពដែរឬទេ?			
		តើរោងចក្រមានគំនូសព្រាងខ្សែម៉ាសដី បច្ចុប្បន្នភាពដែរឬទេ?			
		តើរោងចក្រមានកាលវិភាគតុល្យភាព ថាមពលបច្ចុប្បន្នភាពដែរឬទេ?			
		តើដ្យាក្រាមអំពីបណ្តាញអគ្គិសនីត្រូវបានបិទនៅលើជញ្ជាំងនៅក្នុងអនុស្ថានីយដែរឬទេ?			
		តើដ្យាក្រាមអំពីឌីសង់ទ័រនីមួយៗត្រូវបានដាក់នៅក្នុងបន្ទះចែកចាយដែរឬទេ?			
		ផ្ទៃមុខកាត់នៃខ្សែដែលបានផ្តល់ទៅកាន់ដ្យាក្រាមបន្ទាត់ទោល?			
		លក្ខខណ្ឌតម្រូវការពារត្រូវបានផ្តល់ទៅកាន់ដ្យាក្រាមបន្ទាត់ទោលដែរឬទេ?			
		តើទំហំខ្សែភ្លើងមានបង្ហាញនៅលើដ្យាក្រាមបន្ទាត់ទោលដែរឬទេ?			
		ចរន្តការពារការឆ្លងភ្លើងមានបង្ហាញនៅលើដ្យាក្រាមបន្ទាត់ទោលដែរឬទេ?			
		កម្រិតការខូច - ណូមីណាល់ចរន្តឆ្លងភ្លើងនៃបន្ទះចែកចាយតង់ស្យុងទាប និងឧបករណ៍ផ្តាច់ចរន្តបានបង្ហាញនៅលើដ្យាក្រាមបន្ទាត់ទោលដែរឬទេ?			
		ប្រភេទឧបករណ៍ផ្តាច់ចរន្តមានបង្ហាញនៅលើដ្យាក្រាមបន្ទាត់ទោលដែរឬទេ?			
7	**តំហែទាំ និងកំណត់ត្រា**				
		តើមានព័ត៌មានលម្អិតអំពីប្រភេទ និងការការពាររន្ទះដែរឬទេ			
		កំណត់ត្រាតំហែទាំដែលត្រូវស្នើសុំសម្រាប់			

		ម៉ាស៊ីនភ្លើង			
		កំណត់ត្រាតំហែទាំដែលត្រូវស្នើសុំសម្រាប់ត្រង់ស្វរ			
		កំណត់ត្រាតំហែទាំដែលត្រូវស្នើសុំសម្រាប់ឌីសង់ទ័រតង់ស្យុងខ្ពស់			
		កំណត់ត្រាតំហែទាំដែលត្រូវស្នើសុំសម្រាប់ឌីសង់ទ័រតង់ស្យុងទាប			
		តុល្យភាពថាមពលអគារ/បន្ទុកប៉ាន់ស្មាន (នៅសំណង់ដើម ឬគម្រោងធំចុងក្រោយនៅនឹងទីតាំង?)			
		កំណត់ត្រាតំហែទាំ/វាយតម្លៃដែលនឹងត្រូវស្នើសុំសម្រាប់ប្រព័ន្ធការពារផ្ទះ			
		កំណត់ត្រាសម្រាប់របាយការណ៍ស្ទង់កម្តៅពីមុន			
		កំណត់ត្រាតំហែទាំដែលនឹងត្រូវស្នើសុំសម្រាប់ប្រព័ន្ធខ្សែម៉ាសដី			
8	**ការស្ទែនកម្តៅ**				
		តំណខ្សែភ្លើងទាំងអស់			
		តំណខ្សែឧបករណ៍ការពារសៀគ្វីទាំងអស់			
		ឧបករណ៍ការពារ			
		បរិក្ខារបន្សំនៅក្នុងទូអគ្គិសនី			
9	**ការការពារផ្ទះ**				
		បណ្តាញចាប់រន្ទះ (air termination network) បំពាក់នៅលើដំបូល។ ជាទូទៅបណ្តាញនេះបំពាក់ជាដំបូលលោហៈគ្របពីលើអគារ ដែលខ្សែចម្លងទ្រុងហ្វារ៉ាដេយមានប្រើស្តុតសំណាញ់ និង/ឬ ដងខ្សល់បញ្ឈរ។			
		តើការតភ្ជាប់ពីបណ្តាញចាប់រន្ទះនៅលើដំបូល មានតភ្ជាប់ទៅកាន់ខ្សែចម្លងបញ្ចុះថាមពល (down conductors) ដាច់ដោយឡែកដែរឬទេ?			
		តើខ្សែចម្លងបញ្ចុះថាមពល (down conductors) មាននូវសសរដែកគ្រឿងបង្គុំឬដែកថែបនៅខាងក្នុងសសរទ្រគ្រោងអគារ និង/ឬ ខ្សែចម្លងបញ្ចុះថាមពលដាច់ដោយឡែកដែរឬទេ?			

		ការតភ្ជាប់ខ្សែចម្លងបញ្ចុះថាមពល (down conductors) ដាច់ដោយឡែកទៅកាន់ប្រអប់អេឡិចត្រូតម៉ាសដី ដែលនៅជាប់គ្នាជាកន្លែងដែលដងម៉ាសដីនឹងត្រូវបុកចូលទៅក្នុងដី។ ខ្សែចម្លងបញ្ចុះថាមពលនីមួយៗត្រូវមានប៉ូលម៉ាសដីដាច់ដោយឡែក។			
		ពិនិត្យមើលថាតើមានចំណុចធ្វើតេស្តដែរឬទេ។			
		តើការតភ្ជាប់ជាមួយលោហៈបន្ថែម ដូចជាដែកគ្រោងអគារ លោហៈទុយោបង្ហូរចុះក្រោម ជាដើម និងបរិក្ខារភ្ជាប់នឹងដំបូលមេកានិចដែរឬទេ			
		តើមានព័ត៌មានលម្អិតអំពីប្រភេទ និងការការពារផ្លេកបន្ទោរដែរឬទេ			
		តើមានរោងចក្រ បំពង់ផ្សែង AHUs ទ្រខ្សែភ្លើង របាំងការពារ ស្លាបព្រិល បំពង់ខ្យល់ចេញចូល-ល-ដែរឬទេ?			
		ការតភ្ជាប់គ្នាតាមរយៈដែកទទឹងធ្វើតេស្តទៅនឹងរបារដែកម៉ាសដីអគ្គិសនីមេរបស់អគារ។			
		តើមានគំនូសព្រាងអំពីការដំឡើងប្រព័ន្ធការពារផ្លេកបន្ទោរ និងមានបច្ចុប្បន្នភាពដែរឬទេ?			
		ពិនិត្យមើលការបាញ់របស់ផ្លេកបន្ទោរ និងចំនួនដងនៃការបាញ់ចំ។			

ឧបសម្ព័ន្ធ G

ការចាត់ប្រភេទ និងការកំណត់អាទិភាពបញ្ហាគ្រឿងបង្គុំ

G1 ការចាត់ថ្នាក់បញ្ហាគ្រឿងបង្គុំ

តារាងខាងក្រោមនេះមានផ្តល់ប្រភេទសមស្របសម្រាប់ការចាត់វិធានការនៅក្នុង FFC។

ប្រភេទបញ្ហា	អនុបញ្ហា
S1៖ ប្រព័ន្ធគ្រឿងបង្គុំបញ្ឈរ	
	ប្រព័ន្ធគាំទ្របញ្ឈរមិនទំនងជា/មិនសមស្រប
	គ្រឿងបង្គុំផ្ទេរ
	សម្ពាធសសរខ្ពស់
	បរិវេណមិនអាចចូលបាន/បិទបាំងដោយគ្រឿងបំពាក់
	បរិវេណ/ជាន់មិនអាចចូលបាន - អគាររួម
	ប្រព័ន្ធគ្រឿងបង្គុំដំបូល និងជាន់មិនត្រឹមត្រូវ/សមស្រប
	សសរផ្ចង (Punching shear)
	មិនមាន 'ប្លង់បន្ទុកអនុញ្ញាត'
	ធុងទឹកនៅលើចន្លោះជាន់/ដំបូល
	បន្ទុកចំធ្ងន់នៅលើចន្លោះជាន់/ដំបូល
	បន្ទុកជាន់មិនបានគ្រប់គ្រង
	ស្រទាប់ក្រាលលើកម្រាលឥដ្ឋមានទម្ងន់ធ្ងន់
	ស្ថានភាពនៃជាន់ឡៅតឿ
	បន្ទុកសសរបន្ថែមនៅតំណចល័ត
S2៖ ប្រព័ន្ធគ្រឿងបង្គុំសងខាង	
	ប្រព័ន្ធគ្រឿងបង្គុំសងខាងមិនទំនងជា/មិនសមស្រប
	មិនមានភាពជាន់គ្នានៅក្នុងប្រព័ន្ធគ្រឿងបង្គុំសងខាង
	អគារគ្រោងដែក៖ គ្រោងដែក (bracing) បាត់/មិនពេញលេញ
	អគារគ្រោងដែក៖ សមត្ថភាពគ្រោងម៉ូម៉ង់មិនគ្រប់គ្រាន់
	អគារបេតុង៖ សមត្ថភាពគ្រោងម៉ូម៉ង់មិនគ្រប់គ្រាន់
	អគារបេតុង៖ សម្ពាធក្នុងប្រព័ន្ធកម្រាលខណ្ឌរាបស្មើដោយសារតែចលនាសងខាង
	មិនមានប្រព័ន្ធគ្រឿងបង្គុំសងខាងនៅគ្រប់ផ្នែកទាំងអស់នៃអគារ
	ផ្នែកជញ្ជាំងកំបោរមិនមែនវិស្វកម្មនៃប្រព័ន្ធទប់លំនឹងទម្រេត
	បរិវេណមិនអាចចូលបាន/បិទបាំងដោយគ្រឿងបំពាក់

S3៖ ធាតុផ្សំសំខាន់ៗ	
	ធាតុផ្សំគ្រឿងបង្គុំសំខាន់ៗ
	គ្រឿងបង្គុំផ្សេរ
	សសរវែង/សសរកម្ពស់ពីរជាន់
	ធ្នឹមកុស៊ុលនៃកម្រាលខណ្ឌហូសបន្ទុក
S4៖ សមត្ថភាពគ្រឹះ	
	សម្រុតគ្រឹះ
	ចលនាដេផារ៉ង់ស្យែល
S5៖ សម្ភារៈដែលអាចមើលឃើញនៅក្នុងទម្រគ្រឿងបង្គុំ	
	ស្នាមប្រេះ
	រមួល រៀច ឬកោងខ្លាំង
	តំណភ្ជាប់គ្រឿងបង្គុំមានគុណភាពមិនល្អ
	បំណែកបេតុង
	វត្ថុធាតុគ្រឿងបង្គុំមានគុណភាពមិនល្អ
	ការខូចខាត
S6៖ សម្ភារៈដែលអាចមើលឃើញនៅក្នុងទម្រមិនមែនគ្រឿងបង្គុំ	
	ស្នាមប្រេះ
	រមួល រៀច ឬកោងខ្លាំង
	ការខូចខាត
S7៖ សមត្ថភាពសំណង់ត/សំណង់បន្ថែម	
	ឯកសារគ្រឿងបង្គុំ

	សំណង់បន្ថែមគ្រឿងបង្គុំមិនមែនវិស្វកម្ម
	បញ្ញត្តិសម្រាប់សំណង់តនៃអគារ
	ច្រកចំហថ្មីនៅក្នុងធាតុនៃគ្រឿងបង្គុំ
S8៖ ឯកសារគ្រឿងបង្គុំ	
	មិនមានឯកសារ
	ស្ថានភាពឯកសារ
	របាយការណ៍ដី
	ប្លង់បន្ទុកដែលបានអនុញ្ញាត
	គំនូសប្លង់គ្រឿងបង្គុំមិនស្របតាមគ្រឿងបង្គុំកែសម្រួល
S9៖ តំហែទាំ	
	កង្វះការថែទាំ
	ដែកគ្រោងអគារច្រេះ
	ការដក់ទឹក
	ទឹកចូល/សំណើម

G2 ការកំណត់អាទិភាពវិធានការសុវត្ថិភាពគ្រឿងបង្គុំ

ដោយហេតុថាការវាយតម្លៃសុវត្ថិភាពគ្រឿងបង្គុំបឋម ភាគច្រើនផ្អែកទៅលើការវិនិច្ឆ័យទៅលើស្ថានភាពរបស់អគារមានស្រាប់ ហើយសូចនាករផ្អែកលើភស្តុតាងផ្សេងៗនៃសមត្ថភាពគ្រឿងបង្គុំ ទើបមិនអាចធ្វើការកំណត់អាទិភាពស្តាពរសម្រាប់បញ្ហានីមួយៗក្នុងបញ្ជីត្រួតពិនិត្យគ្រឿងបង្គុំ គឺមិនអាចធ្វើទៅបាននោះទេ។

ចំណុចនេះជាប្រធានបទដ៏សំខាន់មួយនៃការបណ្តុះបណ្តាលរបស់ក្រុមហ៊ុនវាយតម្លៃ។ ឧទាហរណ៍ អំពីវិធានការទូទៅពាក់ព័ន្ធនឹងបញ្ហាចម្បងៗដែលទំនងជាអាចរកឃើញ ហើយសេចក្តីណែនាំអំពីការកំណត់អាទិភាពអាចផ្តល់ជូននៅពេលនោះ។

ទោះជាយ៉ាងណាក៏ដោយ សេចក្តីណែនាំខាងក្រោមនេះមានផ្តល់ជូនដើម្បីជួយដល់វិស្វករដែលមានគុណវុឌ្ឍិសមស្របក្នុងការកំណត់កម្រិតអាទិភាពសមស្របបំផុតសម្រាប់លទ្ធផលរកឃើញជាក់លាក់។ ចំណុចនេះគួរតែអានអមជាមួយគោលការណ៍ដែលមានចែងនៅក្នុងផ្នែក 7.1។

SP3៖ វិធានការរយៈពេល 6 ខែ

ជាទូទៅ បញ្ហាដែលអាចចាត់ប្រភេទតាមវិធីសាស្ត្រនេះរួមមាន៖

- សម្ពាធសសរនៅត្រឹមកម្រិតដែលមានបង្ហាញនៅក្នុងផ្នែក 4.6
- ការខូចខាតផ្ទាល់ទៅលើធាតុនៃគ្រឿងបង្គុំដែលត្រូវធ្វើការជួសជុល ប៉ុន្តែមិនប៉ះពាល់ខ្លាំងទៅដល់សមត្ថភាពគ្រឿងបង្គុំទាំងមូលសម្រាប់រយៈពេលខ្លីឡើយ
- ការឡើងច្រែះដែលមានផលប៉ះពាល់តិចតួចទៅលើសមត្ថភាពគ្រឿងបង្គុំក្នុងរយៈពេលខ្លី
- ធាតុនៃគ្រឿងបង្គុំនីមួយៗ ឬផ្នែកនៃគ្រឿងបង្គុំ ដែលទាមទារឱ្យមានការពិនិត្យមើលការរចនា ប៉ុន្តែមានសមត្ថភាពសមស្របតាមការសាកល្បងគ្រប់ពេលទាំងអស់។ ធាតុទាំងនេះអាចរួមមាន សំណង់ត/បន្ថែម ឬការកែលម្អ។ ឧទាហរណ៍ កម្រាលខណ្ឌ ឬធ្នឹមដែលត្រធុងទឹក ឬបរិក្ខារធ្ងន់ៗ ជណ្តើរដែកខាងក្រៅអគារដែលបានសង់បន្ថែម គ្រឿងដំបូលដែកថ្មី
- ការកែលម្អ ឬការបាត់ធាតុសំខាន់នៃប្រព័ន្ធទប់លំនឹងទម្រេតក្នុងករណីដែលមានច្រកបន្ទុកជម្រើសផ្សេងទៀតដែលបានបញ្ជាក់
- មានចលនាគ្រឿបង្គុំដែលអាចមើលឃើញក្នុងពេលមានខ្យល់បក់ខ្លាំង
- ធាតុនៃគ្រឿងបង្គុំដែលអាចហានិភ័យកម្រិតទាបក្នុងការធ្វើឱ្យប៉ះទង្គិចដោយយានយន្ត
- បញ្ហាសម្រុតដេដាវ៉ង់ស្បែលដែលមិនបង្ហាញថាជាបញ្ហាកើតឡើងបន្តរហូតទេ
- ស្នាមប្រេះនៅក្នុងធាតុមិនមែនគ្រឿងបង្គុំ
- សំណើម/ ការជ្រាបទឹកដែលមិនពាក់ព័ន្ធនឹងការថយចុះគុណភាពគ្រឿងបង្គុំធ្ងន់ធ្ងរ
- គ្រឿងបង្គុំមិនមែនវិស្វកម្មដែលទាមទារឱ្យមានការពិនិត្យមើលការរចនា – ហានិភ័យទាប/ចំនួនអ្នកនៅក្នុងអគារតិច ឬបង្ហាញពីសមត្ថភាពសមស្របគ្រប់ពេល

- កង្វះគំនូសបន្លង់កែសម្រួល ឬប្លង់បន្ទុក
- គំនូសបន្លង់មិនស្របតាមស្ថានភាពកែសម្រួល

អគារដែលមានតែលទ្ធផល EP3 ជារួម មានលេខកូដពណ៌បៃតង។

ពណ៌បៃតង៖ ជាទូទៅ គ្មានបញ្ហាអ្វីទាំងអស់ គឺត្រូវមានការព្រមព្រៀងដើម្បីដោះស្រាយមតិយោបល់ដែលបានចាត់អាទិភាព។ ពុំអង្កេតឃើញចំណុចបញ្ហាធ្ងន់ធ្ង ឬបញ្ហាគ្រឿងបង្គុំ និងមិនមានហានិភ័យភ្លាមៗដល់កម្មករឡើយ។ ដំណើរការផលិតកម្មអាចបន្តបាន។

SP2៖ វិធានការរយៈពេល 6 សប្តាហ៍

ជាទូទៅ បញ្ហាដៃ។អាចចាត់ប្រភេទតាមវិធីសាស្ត្រនេះរួមមាន៖

- សម្ភាធសសរនៅកម្រិតដែលបានបង្ហាញនៅក្នុងផ្នែក 4.6
- គ្រឿងបង្គុំកម្រាលខណ្ឌរាបស្មើដែលមានការបារម្ភចំពោះសមត្ថភាពសសរផុង (punching shear។
- ការខូចខាតផ្ទាល់ទៅលើធាតុនៃគ្រឿងបង្គុំដែលត្រូវជួសជុល ប៉ុន្តែមិនប៉ះពាល់ខ្លាំងទៅលើសមត្ថភាពគ្រឿងបង្គុំទាំងមូលនៅក្នុងរយៈពេលខ្លីនោះឡើយ
- ស្នាមប្រេះនៅក្នុងធាតុនៃគ្រឿងបង្គុំដែលធ្វើឱ្យមិនដំណើរការ ឬមានសម្ភាធខ្លាំងពេកទៅលើគ្រឿងបង្គុំ
- ធាតុនៃគ្រឿងបង្គុំនីមួយៗ ឬផ្នែកនៃគ្រឿងបង្គុំដែលត្រូវធ្វើការពិនិត្យមើលលើការរចនា និងមានសញ្ញាបង្ហាញពីការមិនដំណើរការ។ ឧទាហរណ៍ រួមមាន កម្រាលខណ្ឌ ឬធ្នឹមដែលត្រធុងទឹក ឬបរិក្ខារធ្ងន់ៗដែលមានស្នាមប្រេះ ការកោង ឬការខូចទ្រង់ទ្រាយដែលអាចចាត់ទុកថា មានជាប់ពាក់ព័ន្ធជាមួយនឹងការប្រើប្រាស់បន្ទុកទាំងនោះ។
- គ្រឿងបង្គុំមិនមែនវិស្វកម្មដែលទាមទារឱ្យមានការពិនិត្យការរចនា។ គ្រឿងបង្គុំទាំងនេះរួមមានគ្រឿងបង្គុំដែលមានហានិភ័យខ្ពស់ ឬគ្រឿងបង្គុំសម្រាប់បរិវេណកាន់កាប់ ឬគ្រឿងបង្គុំដែលត្រូវបានកំណត់ជាពិសេសថាមានបញ្ហាបញ្ហា។ គ្រឿងបង្គុំទាំងនេះ រួមមាន គ្រឿងបង្គុំដំបូលដែលការប្រក់ដំបូលប្រឈមនឹងហានិភ័យធ្លាក់ចុះមក។
- ច្រែះដែលប៉ះពាល់លើសមត្ថភាពគ្រឿងបង្គុំក្នុងរយៈពេលខ្លី។
- ការកែលម្អសំខាន់ៗ ឬការបាត់ធាតុសំខាន់នៃប្រព័ន្ធទប់លំនឹងទម្រេតនៅក្នុងករណីដែលមានច្រកបន្ទុកជម្រើសផ្សេងទៀតដែលបានបញ្ជាក់ បញ្ហានេះអាចពាក់ព័ន្ធនឹងភស្តុតាងនៃចលនាសងខាងទាំងមូល។
- ធាតុនៃគ្រឿងបង្គុំដែលស្ថិតក្នុងហានិភ័យអាចទទួលយកបាននៃការប៉ះទង្គិចពីយានយន្ត។
- ធាតុនេះនឹងរួមបញ្ចូលសសរនៅបរិវេណដឹកជញ្ជូន ជាកន្លែងដែលការខូចខាតទៅលើសសរ

អាចនឹងនាំឱ្យអគារនោះបាក់រលំ។

- សសរគ្រឿងបង្គុំដែលប្រឈមនឹងហានិភ័យពីរញ្ជ្រៀវដែលកើតចេញពីគ្រឿងម៉ាស៊ីនធុនធ្ងន់
- បញ្ហាសម្រុតដេជារ៉ង់ស្សៀលដែលបង្ហាញថាជាបញ្ហាកើតឡើងបន្តរហូត
- ស្នាមប្រេះនៅក្នុងធាតុមិនមែនគ្រឿងបង្គុំដែលស្នាមប្រេះនេះគឺមានលក្ខណៈធ្ងន់ធ្ងរអាចនឹងប៉ះពាល់ដល់លំនឹងនៃធាតុមិនមែនគ្រឿងបង្គុំ។
- សំណើម/ ការជ្រាបទឹកដែលពាក់ព័ន្ធនឹងការថយចុះគុណភាពគ្រឿងបង្គុំធ្ងន់ធ្ងរ។
- កង្វះប្លង់បន្ទុកនៅក្នុងស្ថានភាពដែលមានក្តីបារម្ភចំពោះបរិវេណបន្ទុកកម្រិតខ្ពស់ធំៗ ឬនៅពេលដែលអាចនឹងមានការប្រែប្រួលបន្ទុកខ្លាំងក្នុងរយៈពេលខ្លី។

អគារដែលមានតែលទ្ធផល SP2 មិនល្អខ្លាំង ជារួម មានលេខកូដពណ៌លឿង។

ពណ៌លឿង៖ ក្តីបារម្ភមានកម្រិត ប៉ុន្តែនៅមានមន្ទិលទៅលើការរៀបចំ និងព័ត៌មានលម្អិតនៃគ្រឿងបង្គុំ បញ្ហាអង្កេតឃើញមានកម្រិតដែលមិនបង្កគ្រោះថ្នាក់ភ្លាមៗទៅលើគ្រឿងបង្គុំ ឬកម្មកររនោះទេ។ ផលិតកម្មអាចបន្តបានដោយត្រូវមានការព្រមព្រៀងដោះស្រាយបញ្ហាដែលបានលើកឡើង និងវិធានការអាទិភាពនៅក្នុងរបាយការណ៍។

SP1៖ វិធានការភ្លាមៗ

- សម្ភាធសសរនៅកម្រិតដែលបានបង្ហាញនៅក្នុងផ្នែក 4.6
- កង្វះប្រព័ន្ធទប់លំនឹងទម្រេតដែលអាចទុកចិត្តបាន ឬកង្វះភាពបត់បែននៃប្រព័ន្ធទប់លំនឹងទម្រេត
- ការខូចខាតផ្ទាល់ទៅលើធាតុនៃគ្រឿងបង្គុំដែលអាចធ្វើឱ្យធាតុផ្សំទាំងនោះមិនដំណើរការ
- ស្នាមប្រេះនៅក្នុងធាតុនៃគ្រឿងបង្គុំដែលជាលទ្ធផលនៃការមិនដំណើរការ ឬមានសម្ភាធខ្លាំងពេកទៅលើគ្រឿងបង្គុំ។ ស្នាមប្រេះសសរតាមទិសបញ្ឈរជានិច្ចកាលគឺជាចំណុចដែលត្រូវចាត់វិធានការបន្ថែម លុះត្រាណាតែមានកត្តាបញ្ជៀសល្អប្រសើរ។
- ស្នាមប្រេះទៅដល់ផ្នែខាងលើនៃកម្រាលខណ្ឌនៅក្នុងបរិវេណជុំវិញសសរនៅក្នុងគ្រឿងបង្គុំ កម្រាលខណ្ឌរាបស្មើ ក៏ជាចំណុចដែលត្រូវចាត់វិធានការភ្លាមៗផងដែរ។
- ធាតុនៃគ្រឿងបង្គុំនីមួយៗ ឬផ្នែកនៃគ្រឿងបង្គុំដែលទាមទារឱ្យមានការពិនិត្យមើលការរចនា និងមានជាប់ពាក់ព័ន្ធទៅនឹងសញ្ញាបង្ហាញអំពីការមិនដំណើរការ។
- ឧទាហរណ៍នេះក៏រួមបញ្ចូលនូវគន្លឹះពុកផុយដែលអាចកើតមានឡើងផងដែរ។
- គ្រឿងបង្គុំមិនមែនវិស្វកម្មដែលទាមទារឱ្យមានការអន្តរាគមន៍ភ្លាមៗដើម្បីកាត់បន្ថយហានិភ័យនៃការបាក់រលំ។

- ច្រែះដែលធ្វើឱ្យធាតុនៃគ្រឿងបង្គុំមិនមានប្រសិទ្ធភាព ឧទាហរណ៍ ច្រែះបានកាត់បន្ថយបរិវេណផ្ទៃមុខកាត់នៃធាតុនៃគ្រឿងបង្គុំ
- បញ្ហាសម្រុតធ្ងន់ធ្ងរដែលជាបញ្ហាកើតឡើងជាបន្តបន្ទាប់ និងមានផលប៉ះពាល់ទៅលើលំនឹងអគារទាំងមូល
- ស្នាមប្រេះនៅក្នុងធាតុមិនមែនគ្រឿងបង្គុំដែលស្នាមប្រេះនេះគឺមានលក្ខណៈធ្ងន់ធ្ងរដែលធាតុទាំងនោះអាចនឹងបាក់រលំ
- សំណើម/ ការជ្រាបទឹកដែលជំរុញឱ្យធាតុនៃគ្រឿងបង្គុំមិនមានប្រសិទ្ធភាព។

អគារដែលមានតែលទ្ធផល SP1 មិនល្អ ជារួម មានលេខកូដពណ៌ដូចខាងក្រោម។

លឿងទុំ៖ មិនមានមូលហេតុដែលត្រូវផ្អាកប្រតិបត្តិការនៅក្នុងរោងចក្រឡើយ ប៉ុន្តែអាចតម្រូវឱ្យចាត់វិធានការនៅក្នុងរោងចក្រ។ កម្រិតសម្ពាធខ្លាំងនៅក្នុងទម្រគ្រឿងបង្គុំ ការបារម្ភចំពោះលទ្ធភាពនៃការបាក់រលំ ឬបញ្ហាដែលអង្កេតឃើញដែលមិនបង្កគ្រោះថ្នាក់ភ្លាមៗដល់គ្រឿងបង្គុំ ឬកម្មករនោះទេ។ ផលិតកម្មអាចបន្តដំណើរការបានដោយត្រូវមានការព្រមព្រៀងវាយតម្លៃ និងធ្វើតេស្តបន្ថែមទៀត ព្រមទាំងត្រូវចាត់វិធានការកែតម្រូវបញ្ហាដែលបានលើកឡើងជាមួយនឹងវិធានការអាទិភាពនៅក្នុងរបាយការណ៍។

ពណ៌ក្រហម/ពណ៌លឿងទុំ៖ ប្រសិនបើអ្នកពិគ្រោះយោបល់វិស្វកម្មគ្រឿងបង្គុំដែលមានគុណវុឌ្ឍិ (QSEC) យល់ថាមាន**វិធានការភ្លាមៗសំខាន់ក្នុងការរក្សាការចាត់ពណ៌លឿងទុំ** របាយការណ៍អាចត្រូវបានចាត់ពណ៌លឿងទុំជាមួយនឹងវិធានការពណ៌ក្រហម។ វិធានការពណ៌ក្រហមត្រូវបំពេញក្នុងរយៈពេលពីរសប្តាហ៍ បើមិនដូច្នោះទេ រោងចក្រទាំងមូលនឹងត្រូវចាត់ប្រភេទថាមានពណ៌ក្រហម។ ឧទាហរណ៍អំពីចំណុចនេះ អាចក្នុងករណីដែលសម្ពាធសសរគឺមានលក្ខណៈធ្ងន់ធ្ងរពេលដែលចាំបាច់ត្រូវកាត់បន្ថយបន្ទុកភ្លាមៗ ហើយយកល្អ ត្រូវកែតម្រូវហានិភ័យសុវត្ថិភាពអាយុជីវិតភ្លាមៗ។ **ពណ៌ក្រហម៖ ណែនាំឱ្យបិទអគាររោងចក្រភ្លាមៗ** ឬផ្នែកសំខាន់នៃអគារ។ ការបិទអគារស្របតាមពិធីសារ។ កម្រិតសម្ពាធខ្លាំងនៅក្នុងទម្រគ្រឿងបង្គុំ ការព្រួយបារម្ភអំពីលទ្ធភាពនៃការបាក់រលំ និង/ឬ បញ្ហា ដែលអង្កេតឃើញ ដែលនាំឱ្យមានគ្រោះថ្នាក់ភ្លាមៗដល់គ្រឿងបង្គុំ ឬកម្មករ។

ឧបសម្ព័ន្ធ ៥

ការចាត់ថ្នាក់បញ្ហា ការកំណត់អាទិភាព និង ទិដ្ឋភាពទូទៅ

ជ1 ការកំណត់អត្តសញ្ញាណការគ្រប់គ្រងសុវត្ថិភាពអគ្គិភ័យ

H1.1 ច្រកជម្លៀសខ្លួន

ល.រ	ប្រភេទបញ្ហា	ល.រ	ប្រភេទអនុបញ្ហា	ព័ត៌មានលម្អិតអំពីអនុបញ្ហា		វិធានការដែលណែនាំជាទូទៅ	អាទិភាព
1	មធ្យោបាយច្រកចេញ	1.1	ច្រកចេញតាមជាន់	ច្រកចេញតាមជាន់មានចំនួនមិនគ្រប់គ្រាន់	ក.	ផ្តល់ច្រកចេញតាមជាន់បន្ថែមដោយស្របតាមប្រការ 6.6 នៃបទដ្ឋាន LABS	FP1
					ខ.	កាត់បន្ថយបន្ទុកអ្នកនៅក្នុងអគារនៅតាមជាន់ដែលមានបញ្ហាដើម្បីធានាបាននូវចំនួនច្រកចេញជាអប្បបរមាដោយផ្អែកលើចំនួនមនុស្សដោយស្របតាមប្រការ 6.6 នៃបទដ្ឋាន LABS	FP1
				ទំហំទទឹងសរុបនៃទ្វារច្រកចេញមានទំហំមិនគ្រប់គ្រាន់	ក.	ផ្តល់ច្រកចេញតាមជាន់បន្ថែមដោយស្របតាមប្រការ 6.5 នៃបទដ្ឋាន LABS	FP2
					ខ.	កាត់បន្ថយបន្ទុកអ្នកនៅក្នុងអគារនៅតាមជាន់ ដែលមានបញ្ហាដើម្បីធានាថាសមត្ថភាពនៃច្រកជម្លៀសខ្លួនត្រូវគ្នាជាមួយនឹងចំនួនមនុស្សនៅក្នុងអគារដោយស្របតាមប្រការ 6.5 នៃបទដ្ឋាន LABS	FP2
					គ.	បង្កើនទំហំទទឹងនៃច្រកចេញមានស្រាប់ដោយស្របតាមប្រការ 6.5 នៃបទដ្ឋាន LABS	FP2
				មិនមានផ្តល់ជូនទិសដៅជម្រើសផ្សេងទៀតសម្រាប់ជម្លៀសខ្លួន	ក.	ផ្តល់ច្រកចេញតាមជាន់បន្ថែម ដើម្បីធានាបាននូវផ្លូវធ្វើដំណើរជម្រើសផ្សេងទៀតក្នុងករណីដែលចម្ងាយជម្លៀសខ្លួនឯកទិសមានចម្ងាយឆ្ងាយពេក ដោយស្របតាមប្រការ 6.6 និង 6.7 នៃបទដ្ឋាន LABS	FP1
				ចម្ងាយធ្វើដំណើរទៅកាន់ច្រកចេញជម្រើសផ្សេងទៀតមានចម្ងាយឆ្ងាយពេក	ក.	ផ្តល់ច្រកចេញតាមជាន់បន្ថែមដើម្បីធានាថាចម្ងាយជម្លៀសខ្លួនមិនឆ្ងាយពេកស្របប្រការ 6.7 នៃបទដ្ឋាន LABS	FP2
				ច្រកគេចខ្លួនពីឡៅតឿមិនគ្រប់គ្រាន់	ក.	ផ្តល់ជណ្តើរបន្ថែមពីឡៅតឿ ដើម្បីធានាថាចម្ងាយជម្លៀសខ្លួនគឺមិនឆ្ងាយពេក ដោយអនុលោមតាមប្រការ 3.13 និង 6.6 នៃបទដ្ឋាន LABS	FP2
				ច្រកគេចខ្លួនពីជាន់ក្រោមដីមិនគ្រប់គ្រាន់	ក.	ផ្តល់ច្រកចេញបន្ថែមពីជាន់ក្រោមដី ដោយស្របតាមប្រការ 6.6.2 នៃបទដ្ឋាន LABS	FP1
		1.2	ផ្លូវជម្លៀសខ្លួន	ទំហំទទឹងផ្លូវជម្លៀសខ្លួនមិនគ្រប់គ្រាន់	ក.	បង្កើនទំហំទទឹងនៃផ្លូវជម្លៀសខ្លួន ឱ្យស្របតាមលក្ខខណ្ឌតម្រូវនៃប្រការ 6.5 នៃបទដ្ឋាន LABS	FP3
				ទ្វារខាងក្នុងនៅតាមផ្លូវ	ក.	គ្រប់ទ្វារទាំងអស់នៅតាមច្រកជម្លៀសខ្លួន ត្រូវតែជា	FP1

				ជម្លៀសខ្លួន មិនលើកទៅចំហៀងសងខាង និង/ឬ មានឧបករណ៍ដែលអាចចាក់សោបាន		ទ្វារប្រភេទត្រចៀកចំហៀង និងមិនត្រូវចាក់សោរតាមទិសដៅជម្លៀសខ្លួននោះទេទោះក្នុងស្ថានភាពណាក៏ដោយ ស្របតាមប្រការ 6.9 នៃបទដ្ឋាន LABS	
				ផ្លូវជម្លៀសខ្លួននៅមានឧបសគ្គរាំងបណ្តោះអាសន្ន	ក.	ធានាថាផ្លូវធ្វើដំណើរនៅតាមផ្លូវច្រកចេញគ្មានការទុកដាក់ឥវ៉ាន់ជាបណ្តោះអាសន្ន និងរបស់របរបាំងផ្លូវផ្សេងៗឡើយស្របតាមប្រការ 6.3 នៃបទដ្ឋាន LABS	FP1
				ផ្លូវជម្លៀសខ្លួននៅមានឧបសគ្គរាំងជាអចិន្ត្រៃយ៍	ក.	បង្វែរផ្លូវធ្វើដំណើរនៅជុំវិញរបាំងរាំងអចិន្ត្រៃយ៍ ឬបង្កើតផ្លូវថ្មីទៅកាន់ច្រកចេញអាសន្ន ដោយស្របតាមប្រការ 6.5 នៃបទដ្ឋាន LABS	FP2
				ផ្លូវទាល់ច្រើនពេកទៅកាន់ផ្លូវដើរ ឬច្រកផ្លូវដើរ	ក.	បង្កើតផ្លូវថ្មីទៅកាន់ច្រកចេញដោយស្របតាមប្រការ 6.7 នៃបទដ្ឋាន LABS និងចៀសវាងមានផ្លូវទាល់ច្រើនពេក	FP2
				កម្ពស់ទ្វារមិនគ្រប់គ្រាន់មានពិដានខាងលើក្បាលនៅតាមផ្លូវជម្លៀសខ្លួន	ក.	រុះរើមេទ្វារនៅខាងលើច្រកចំហ និងរៀបចំឡើងវិញដើម្បីធានាថា កម្ពស់ពីកម្រាលទៅពិតានស្របតាមកម្ពស់អប្បបរមាដែលបានបញ្ជាក់នៅក្នុងប្រការ 6.3 នៃបទដ្ឋាន LABS	FP2
		1.3	ស្លាកសញ្ញាច្រកចេញ	ផ្លូវជម្លៀសខ្លួនមិនបានបង្ហាញច្បាស់លាស់នៅតាមជាន់នោះទេ	ក.	គូសសញ្ញាចំណាំនៅតាមជាន់ ឬធ្វើឱ្យផ្លូវជម្លៀសខ្លួនកាន់តែច្បាស់ ឬដាក់ស្លាកសញ្ញានៅខាងលើឱ្យបានគ្រប់គ្រាន់ ដើម្បីបង្ហាញអំពីផ្លូវទៅកាន់ច្រកចេញអាសន្នបានច្បាស់ដោយស្របតាមប្រការ 6.8 និងប្រការ 6.12 នៃបទដ្ឋាន LABS	FP3
				ផ្លូវជម្លៀសខ្លួនមិនច្បាស់ ឬបិទស្លាកសម្គាល់បានត្រឹមត្រូវ	ក.	គូសសញ្ញាចំណាំនៅតាមជាន់ឱ្យបានត្រឹមត្រូវ និង/ឬ ដាក់ស្លាកសញ្ញានៅខាងលើឱ្យបង្ហាញបានច្បាស់អំពីផ្លូវទៅកាន់ច្រកចេញអាសន្នបានច្បាស់ដោយស្របតាមប្រការ 6.12 នៃបទដ្ឋាន LABS	FP3
					ខ.	ដាក់ស្លាកសញ្ញានៅចុងច្រកផ្លូវវែងដើម្បីបង្ហាញអំពីការផ្លាស់ប្តូរទិសដៅនៃផ្លូវជម្លៀសខ្លួនទៅកាន់ច្រកចេញតាមជាន់ដែលនៅជិតបំផុតដោយស្របតាមប្រការ 6.12 នៃបទដ្ឋាន LABS	FP3

ល.រ	ប្រភេទបញ្ហា	ល.រ	ប្រភេទអនុបញ្ហា	ព័ត៌មានលម្អិតអំពីអនុបញ្ហា		វិធានការដែលណែនាំជាទូទៅ	អាទិភាព
		1.3	ស្លាកសញ្ញាច្រកចេញ	ស្លាកសញ្ញាច្រកចេញភ្លឺនៅតាមច្រកចេញអាសន្ន គឺ	ក.	ដាក់ស្លាកសញ្ញាច្រកចេញភ្លឺនៅខាងលើទ្វារច្រកចេញអាសន្ននីមួយដោយស្របតាម	FP2
					ខ.	ដាក់ស្លាកសញ្ញាច្រកចេញភ្លឺនៅខាងលើទ្វារច្រកចេញអាសន្ននីមួយៗដែលមានទំហំធំល្មមដើម្បីអាចសម្គាល់បានពីទីតាំងនានានៅក្នុងអគារពោងច្រកស្របតាមប្រការ 6.12 នៃបទដ្ឋាន LABS	FP3
				រូបភាពក្រាហ្វិក និង/ឬ ពណ៌សម្រាប់ស្លាកសញ្ញាច្រកចេញមិនត្រូវគ្នា	ក.	ផ្តល់រូបភាពក្រាហ្វិកដល់ស្លាកសញ្ញាច្រកចេញទាំងអស់ឱ្យត្រូវគ្នាដោយស្របតាមប្រការ 6.12 នៃបទដ្ឋាន LABS	FP3
		1.4	ទ្វារច្រកចេញ	ទ្វារច្រកចេញមិនមែនជាទ្វារដែលបើកទៅចំហៀងត្រឹមត្រូវតាមទិសដៅជម្លៀសខ្លួន	ក.	ផ្លាស់ប្តូរទ្វារជាមួយនឹងទ្វារបើកទៅចំហៀងដែលបើកតាមទិសដៅជម្លៀសខ្លួនស្របតាមប្រការ 6.1, 6.3 និង 6.9 នៃបទដ្ឋាន LABS	FP1
					ខ.	ផ្តល់ផ្ទាំងទ្វារបើកទៅចំហៀងនៅក្នុងផ្ទាំងទ្វារអូសទៅចំហៀងដើម្បីធានាថា មានទ្វារច្រកចេញដែលបើកទៅតាមទិសដៅធ្វើដំណើរក្នុងករណីដែលទ្វារអូសចំហៀសត្រូវបានបិទដោយស្របតាមប្រការ 6.1, 6.3 និង 6.9 នៃបទដ្ឋាន LABS។	FP1
				ទ្វារច្រកចេញគឺមិនងាយស្រួលបើកបាននៅគ្រប់ពេល និង/ឬ ទ្វារមានចាក់សោ	ក.	ផ្លាស់ប្តូរសោខាងក្រៅជាមួយនឹងគន្លឹះដែលអនុញ្ញាតឱ្យអាចបើកបានងាយស្រួលពីខាងក្នុងដោយមិនចាំបាច់ប្រើកូនសោស្របតាមប្រការ 6.1 និង 6.9 នៃបទដ្ឋាន LABS	FP1
					ខ.	ផ្លាស់ប្តូរសោនៅខាងក្នុងទ្វារជាមួយនឹងគន្លឹះដែលអនុញ្ញាតឱ្យបើកទ្វារបានងាយស្រួលពីខាងក្នុងដោយមិនចាំបាច់ប្រើកូនសោ ដោយស្របតាមប្រការ 6.1 និង 6.9 នៃបទដ្ឋាន LABS	FP1
				ច្រកចេញផ្សេងទៀត	ក.	ពណ៌នាអំពីច្រកចេញផ្សេងទៀតដែលអាចប្រើប្រាស់ជាផ្នែកមួយនៃផ្លូវជម្លៀសខ្លួនទោះបីជាច្រកទាំងនោះត្រូវឆ្លងកាត់បរិវេណផ្សេងៗនៅតាមផ្លូវទៅខាងក្រៅអគារក៏ដោយ	
		1.5	ជណ្តើរច្រកចេញ	ទំហំទទឹងជណ្តើរ និង/ឬ ទ្វារច្រកចូលមានទំហំមិនគ្រប់គ្រាន់	ក.	ផ្តល់ជណ្តើរបន្ថែមដោយស្របតាមប្រការ 6.5 និង 6.10 នៃបទដ្ឋាន LABS	FP2
					ខ.	កាត់បន្ថយបន្ទុកអ្នកនៅក្នុងអគារនៅតាមជាន់ដែលមានបញ្ហាដើម្បីធានាថាសមត្ថភាពជណ្តើរត្រូវគ្នាជាមួយនឹងចំនួនមនុស្សនៅក្នុងអគារឱ្យស្របតាមប្រការ 6.5 នៃបទដ្ឋាន LABS	FP1
					គ.	បង្កើនទំហំទទឹងជណ្តើរ ដោយស្របតាមប្រការ 6.5 និង 6.10 នៃបទដ្ឋាន LABS	FP2
				ទំនាក់ទំនងក្រឡា/ចន្លោះកាំជណ្តើរនៅលើផ្លូវ	ក.	ក្នុងករណីដែលមានភាពមិនស្របគ្នាខ្លាំងចំពោះចន្លោះកាំជណ្តើរនៅកាំណាមួយដែលអាចធ្វើឱ្យ	FP2

				ជណ្តើរមិនត្រូវគ្នា		ជណ្តើរមិនមានសុវត្ថិភាពសម្រាប់ប្រើក្នុងការជម្លៀសខ្លួនបន្ទាន់ យកចេញនូវស្លាកសញ្ញាដែលបង្ហាញថាជណ្តើរជាផ្នែកមួយនៃផ្លូវជម្លៀសខ្លួនបន្ទាន់។ សូមមើលប្រការ 6.10 នៃបទដ្ឋាន LABS សម្រាប់សេចក្តីណែនាំអំពីទំនាក់ទំនងនៃចន្លោះកាំជណ្តើរ/ក្រឡាជណ្តើរ	
				ជណ្តើរចោតពេកសម្រាប់ការជម្លៀសខ្លួនបន្ទាន់	ក.	ក្នុងករណីដែលជណ្តើរចោតពេកសម្រាប់ប្រើក្នុងគ្រាអាសន្នដោយសុវត្ថិភាព សូមដកស្លាកសញ្ញាដែលបង្ហាញថាជណ្តើរជាផ្នែកមួយនៃផ្លូវជម្លៀសខ្លួនអាសន្ននោះចេញ។ សូមមើលប្រការ 6.10 នៃបទដ្ឋាន LABS ជាសេចក្តីណែនាំអំពីទំនាក់ទំនងនៃចន្លោះកាំជណ្តើរ/ក្រឡាជណ្តើរ	FP3
				បង្កាន់ដៃជណ្តើរមិនគ្រប់គ្រាន់ ឬមិនមានបង្កាន់ដៃ	ក.	ផ្តល់បង្កាន់ដៃជណ្តើរដោយស្របតាមប្រការ 6.10 នៃបទដ្ឋាន LABS	FP3
				ផ្លូវពីជណ្តើរចេញទៅខាងក្រៅអគារមិនមានអ្វីការពារ	ក.	ផ្តល់ផ្លូវដែលមានការការពារពីជណ្តើរចេញទៅច្រកចេញនៅខាងក្រៅដោយស្របតាមប្រការ 6.17 នៃបទដ្ឋាន LABS។	FP1
		1.6	ច្រកចេញចុងក្រោយ	ទំហំទទឹងសរុបនៃច្រកចេញជាន់ផ្ទាល់ដីមិនគ្រប់គ្រាន់	ក.	ផ្តល់ច្រកចេញតាមជាន់បន្ថែមដោយស្របតាមប្រការ 6.5 នៃបទដ្ឋាន LABS	FP2
					ខ.	កាត់បន្ថយបន្ទុកអ្នកនៅក្នុងអគារនៅតាមជាន់ដែលមានបញ្ហាដើម្បីធានាសមត្ថភាពនៃច្រកជម្លៀសខ្លួនត្រូវគ្នាជាមួយនឹងចំនួនមនុស្សនៅក្នុងអគារដោយស្របតាមប្រការ 6.5 នៃបទដ្ឋាន LABS	FP1
					គ.	បង្កើនទំហំទទឹងនៃច្រកចេញមានស្រាប់ ដោយស្របតាមប្រការ 6.5 នៃបទដ្ឋាន LABS	FP2
				មនុស្សមិនអាចធ្វើដំណើរចេញពីអគារដោយផ្ទាល់តាមច្រកចេញទៅខាងក្រៅបានដោយមានសុវត្ថិភាពនោះទេ	ក.	យកចេញនូវរបស់របរដែលរារាំងអ្នកនៅក្នុងអគារមិនឱ្យធ្វើដំណើរចេញឆ្ងាយពីអគារទៅកាន់ច្រកចេញនៅខាងក្រៅបាន ដោយស្របតាមប្រការ 6.17 នៃបទដ្ឋាន LABS	FP2
					ខ.	ផ្តល់របាំងការពារធន់នឹងអគ្គិភ័យដើម្បីការពារអ្នកនៅក្នុងអគារពីឥទ្ធិពលនៃអគ្គិភ័យនៅក្នុងអគារក្នុងករណីដែលពួកគាត់មិនអាចធ្វើដំណើរចេញឆ្ងាយពីអគារបានដោយផ្ទាល់ ស្របតាមប្រការ 6.17 នៃបទដ្ឋាន LABS	FP1
				ច្រកចេញផ្សេងទៀត	ក.	រៀបរាប់អំពីច្រកចេញចុងក្រោយផ្សេងទៀតដែលអាចប្រើប្រាស់ជាផ្នែកមួយនៃផ្លូវជម្លៀសខ្លួនបាន	

H1.2 សំណង់សុវត្ថិភាពអគ្គិភ័យ

ល.រ	ប្រភេទបញ្ហា	ល.រ	ប្រភេទអនុបញ្ហា	ព័ត៌មានលម្អិតអំពីអនុបញ្ហា		វិធានការដែលណែនាំជាទូទៅ	អាទិភាព
2	សំណង់សុវត្ថិភាពអគ្គិភ័យ	2.1	ការការពារច្រកចំហតាមទិសបញ្ឈរ	កង្វះរបាំងការពារជណ្តើរដែលតភ្ជាប់ច្រើនជាង 2 ជាន់	ក.	ផ្តល់របាំងការពារធន់នឹងអគ្គិភ័យតាមជណ្តើរដោយស្របតាមប្រការ 4.8, 4.10 និង 6.14 នៃបទដ្ឋាន LABS	FP2
				មិនមានទ្វារបិទខ្លួនឯងធន់នឹងអគ្គិភ័យនៅជណ្តើរការពារទេ	ក.	បំពាក់ឧបករណ៍បិទខ្លួនឯងនៅតាមទ្វារស្របតាមប្រការ 4.5 នៃបទដ្ឋាន LABS	FP1
				ប្រហោងចោះដែលមិនបានការពារនៅក្នុងរបាំងជណ្តើរ	ក.	ច្រកចំហនៅក្នុងរបាំងជណ្តើរត្រូវតែការពារដោយប្រើបង្គុំការពារច្រកចំហដែលអនុលោមតាមប្រការ 4.6, 4.7 និង 6.14 នៃបទដ្ឋាន LABS	FP1
				ការការពារមិនគ្រប់គ្រាន់ចំពោះជណ្តើរខាងក្រៅពីអគ្គិភ័យនៅខាងក្នុងអគារ	ក.	ជណ្តើរច្រកចេញខាងក្រៅត្រូវតែការពារពីផ្នែកខាងក្នុងអគារដោយសំណង់ធន់នឹងអគ្គិភ័យដោយស្របតាមប្រការ 6.3 និងប្រការ 6.10 នៃបទដ្ឋាន LABS	FP1
				ការការពារមិនគ្រប់គ្រាន់ចំពោះច្រកថាមពលតាមទិសបញ្ឈរដែលឆ្លងកាត់តាមជាន់	ក.	ច្រកថាមពលដែលឆ្លងកាត់តាមបរិវេណខណ្ឌតាមជាន់ត្រូវតែមានរបាំងការពារធន់នឹងអគ្គិភ័យដោយស្របតាមប្រការ 4.4 និង 4.7 នៃបទដ្ឋាន LABS	FP2
				មិនមានរបាំងខណ្ឌធន់នឹងអគ្គិភ័យគ្រប់គ្រាន់នៅច្រកផ្លូវជណ្តើរយោង	ក.	ច្រកផ្លូវជណ្តើរយោងត្រូវមានរបាំងការពារដោយសំណង់ធន់នឹងអគ្គិភ័យដោយស្របតាមប្រការ 4.8 និង 5.11 នៃបទដ្ឋាន LABS	FP2
				ច្រកចំហតាមទិសបញ្ឈរផ្សេងទៀតដែលឆ្លងកាត់តាមបរិវេណខណ្ឌតាមជាន់	ក.	ចន្លោះទំនេរ (Atrium) ដែលតភ្ជាប់តាមជាន់ ត្រូវខណ្ឌពីបរិវេណនៅជាប់គ្នាដោយប្រើប្រាស់វិធីសាស្ត្រនៅក្នុងចំណោមវិធីសាស្ត្រដែលមានចែងនៅក្នុងប្រការ 4.12 នៃបទដ្ឋាន LABS	FP2
				ការការពារជាន់ក្រោមដីដោយបរិវេណទទួលភ្ញៀវ FR ជញ្ជាំង និងទ្វារបិទខ្លួនឯង	ក.	តំណភ្ជាប់រវាងជាន់ក្រោមដី និងជាន់ផ្ទាល់ដីត្រូវតែខណ្ឌដោយសំណង់ធន់នឹងអគ្គិភ័យរួមទាំងច្រកចូលដោយស្របតាមប្រការ 4.4.5 និង 6.14 នៃបទដ្ឋាន LABS	FP1
		2.2	ការខណ្ឌបរិវេណកាន់កាប់	ប្រើប្រាស់ទីធ្លាដែលមានផ្ទៃក្រឡាធំពេកក្នុងការចាត់ទុកថាជា "បរិវេណកាន់កាប់បន្សំ"	ក.	ផ្តល់ជញ្ជាំងខណ្ឌធន់នឹងអគ្គិភ័យរយៈពេល 1 ម៉ោង ជាមួយនឹងទ្វារបទខ្លួនឯងធននឹងអគ្គិភ័យ 45 នាទី នៅចន្លោះបរិវេណ និងបរិវេណប្រើប្រាស់ចម្រុះ ស្របតាមប្រការ 3.10 និង 3.11 នៃបទដ្ឋាន LABS	FP2

				មិនបានផ្តល់ការខណ្ឌ ឬ ការខណ្ឌបរិវេណកាន់កាប់ផ្សេងៗគ្នាមិនបានគ្រប់គ្រាន់	ក.	ផ្តល់ជញ្ជាំងខណ្ឌធន់នឹងអគ្គិភ័យរយៈពេល 1 ម៉ោង ជាមួយទ្វារបត់ខ្លួនឯងធននឹងអគ្គិភ័យ 45 នាទីនៅចន្លោះបរិវេណកាន់កាប់ស្របតាមប្រការ 3.10 និង 3.11 នៃបទដ្ឋាន LABS	FP2
					ខ.	តជញ្ជាំងខណ្ឌរហូតដល់ជាន់ដំបូលដោយសំណង ធន់នឹងអគ្គិភ័យរយៈពេល 1 ម៉ោង ដើម្បីខណ្ឌបរិវេណកាន់កាប់ផ្សេងៗគ្នានៅក្នុងអគារដោយស្របតាមប្រការ 4.4 នៃបទដ្ឋាន LABS	FP2
					គ.	បិទច្រកចំហនៅក្នុងជញ្ជាំងដែលខណ្ឌបរិវេណកាន់កាប់ដោយសំណង់ធន់នឹងអគ្គិភ័យ និង/ឬដំឡើងទ្វារធន់នឹងអគ្គិភ័យដល់ច្រកចំហនៅក្នុងជញ្ជាំងបរិវេណដោយស្របតាមប្រការ 4.4 និង 4.10 នៃបទដ្ឋាន LABS	FP2
					ឃ.	បិទប្រហោះចោះច្រកចំហនៅក្នុងជញ្ជាំងដែលខណ្ឌបរិវេណកាន់កាប់ដោយប្រព័ន្ធបញ្ឈប់អគ្គិភ័យដោយស្របតាមប្រការ 4.11 នៃបទដ្ឋាន LABS	FP2
		2.3	បរិវេណឃ្លាំង	បរិវេណឃ្លាំងដែលកំណត់មិនបានខណ្ឌដោយសំណង់ធន់នឹងអគ្គិភ័យ	ក.	ខណ្ឌបរិវេណឃ្លាំងពីបរិវេណនៅក្បែរខាងដោយសំណង់ធន់នឹងអគ្គិភ័យរយៈពេល 1 ម៉ោង ដោយស្របតាមប្រការ 3.10 និង 3.11 នៃបទដ្ឋាន LABS	FP2
				បរិវេណឃ្លាំងទល់នឹងនឹងផ្លូវច្រកចេញ	ក.	បរិវេណឃ្លាំងត្រូវតែខណ្ឌពីច្រកផ្លូវជណ្តើរ ឬច្រកផ្លូវដើរដែលបានការពារដោយសំណង់ធន់នឹងអគ្គិភ័យរយៈពេល 1 ម៉ោង និងច្រកចូលដោយស្របតាមប្រការ 6.14 នៃបទដ្ឋាន LABS	FP1
				បរិវេណ 'កំពុងដំណើរការ' ធំពេកដែលមិនមានឧបករណ៍បាញ់ទឹកឃ្លាំងទល់មុខនឹងបរិវេណផលិតកម្ម	ក.	រៀបចំឃ្លាំងបណ្តោះអាសន្នឡើងវិញទៅជា "ប្លុក" ដែលមានបរិវេណទំហំមិនធំជាង 23ម² កម្ពស់ 2,45 ម និងខណ្ឌ 3ម រវាង "ប្លុក" នៅជាប់គ្នាដោយស្របតាមប្រការ 3.11.5.6 នៃបទដ្ឋាន LABS	FP2
				បរិវេណឃ្លាំង 'កំពុងដំណើរការ' មានទំហំធំពេក មានឧបករណ៍បាញ់ទឹកដែលទល់មុខបរិវេណផលិតកម្ម	ក.	រៀបចំឃ្លាំងបណ្តោះអាសន្នឡើងវិញទៅជា 'ប្លុក' ដែលមានបរិវេណទំហំមិនធំជាង 93ម² កម្ពស់ 3,66 ម និងខណ្ឌ 7.62ម រវាង 'ប្លុក' នៅជាប់គ្នាដោយស្របតាមប្រការ 3.11.5.6 នៃបទដ្ឋាន LABS	FP2
				បរិវេណឃ្លាំង 'កំពុងដំណើរការ' មានទំហំធំ	ក.	កាត់បន្ថយបរិមាណឃ្លាំងបណ្តោះអាសន្នជា 'ប្លុក' ដើម្បីធានាថាបរិវេណបូកសរុបនៃឃ្លាំង	FP2

				ពេក ដែលទល់មុខបរិវេណផលិតកម្ម		បណ្តោះអាសន្នមិនលើសពី 25% នៃផ្ទៃក្រឡាជាន់ សរុបដោយស្របតាមប្រការ 3.11.2 នៃបទដ្ឋាន LABS	

ល.រ	**ប្រភេទបញ្ហា**	**ល.រ**	**ប្រភេទអនុបញ្ហា**	**ព័ត៌មានលម្អិតអំពីអនុបញ្ហា**		**វិធានការដែលណែនាំជាទូទៅ**	**អាទិភាព**
		2.3	បរិវេណឃ្លាំង	បរិវេណឃ្លាំង 'កំពុងដំណើរការ' មានទំហំធំពេក ដែលស្ថិតនៅទល់មុខបរិវេណផលិតកម្ម	ខ.	ខណ្ឌបរិវេណឃ្លាំងពីបរិវេណនៅក្បែរខាងដោយសំណង់ធន់នឹងអគ្គិភ័យរយៈពេល 1 ម៉ោង ដោយស្របតាមប្រការ 3.11 នៃបទដ្ឋាន LABS	FP2
				ឃ្លាំងផ្សេងៗ (ឧទាហរណ៍ នៅក្រោមជណ្តើរ)	ក.	ឃ្លាំងត្រូវដកចេញពីរចាំងជណ្តើរ ឬខណ្ឌដោយសំណង់ធន់នឹងអគ្គិភ័យរយៈពេល 1 ម៉ោង ដោយស្របតាមប្រការ 3.11.5.4 នៃបទដ្ឋាន LABS	FP2
		2.4	បរិវេណហានិភ័យខ្ពស់ផ្សេងទៀត	រចាំងការពារការពារម៉ាស៊ីនភ្លើងមិនគ្រប់គ្រាន់	ក.	បណ្តុំម៉ាស៊ីនភ្លើងត្រូវតែខណ្ឌដាច់ដោយឡែកពីបរិវេណកាន់កាប់ផ្សេងទៀតទាំងអស់ដោយសំណង់ធន់នឹងអគ្គិភ័យរយៈពេលអប្បបរមា 2 ម៉ោងដោយស្របតាមប្រការ 3.11.5.3 នៃបទដ្ឋាន LABS	FP2
				រចាំងការពារបន្ទប់បរិក្ខារកម្តៅមិនគ្រប់គ្រាន់	ក.	បន្ទប់បរិក្ខារកម្តៅត្រូវតែខណ្ឌពីបរិវេណកាន់កាប់ផ្សេងទៀតទាំងអស់ដោយសំណងធន់នឹងអគ្គិភ័យរយៈពេល 1 ម៉ោងជាមួយនឹងប្រព័ន្ធពន្លត់អគ្គិភ័យស្វ័យប្រវត្តិ ឬសំណង់ធន់នឹងអគ្គិភ័យ 2 ម៉ោងដោយស្របតាមប្រការ 3.11.5.2 នៃបទដ្ឋាន LABS	FP2
				កុំប្រៃសស័រធំមិនមានរចាំងការពារ	ក.	កុំប្រៃសស័រត្រូវតែខណ្ឌនៅដាច់ដោយឡែកពីបរិវេណកាន់កាប់ផ្សេងទៀតទាំងអស់ដោយសំណង់ធន់នឹងអគ្គិភ័យរយៈពេលអប្បបរមា 1 ម៉ោងដោយស្របតាមប្រការ 3.11.5.4 នៃបទដ្ឋាន LABS	FP2
				រចាំងការពារត្រង់ស្វូរមិនគ្រប់គ្រាន់	ក.	ត្រង់ស្វូរត្រូវតែខណ្ឌដាច់ដោយឡែកពីបរិវេណកាន់កាប់ផ្សេងទៀតទាំងអស់ដោយសំណង់ធន់នឹងអគ្គិភ័យរយៈពេលអប្បបរមា 1 ម៉ោងដោយស្របតាមប្រការ 3.11.5.4 នៃបទដ្ឋាន LABS	FP2
				រចាំងការពារឃ្លាំងស្តុកសារធាតុគីមីមិនគ្រប់គ្រាន់	ក.	ឃ្លាំងស្តុកសារធាតុគីមីត្រូវតែខណ្ឌដាច់ដោយឡែកពីបរិវេណកាន់កាប់ផ្សេងទៀតទាំងអស់ដោយសំណង់ធន់នឹងអគ្គិភ័យរយៈពេលអប្បបរមា 1 ម៉ោងដោយស្របតាមប្រការ 3.11.6.3 នៃបទដ្ឋាន LABS	FP2
				ផ្សេងៗ	ក.	បរិវេណគ្រោះថ្នាក់ផ្សេងៗត្រូវតែខណ្ឌដាច់ដោយឡែកពីបរិវេណកាន់កាប់ផ្សេងទៀតទាំងអស់ដោយសំណង់ធន់នឹងអគ្គិភ័យរយៈពេលអប្បបរមា 1 ម៉ោង	FP3

						ដោយស្របតាមប្រការ 3.11.5.4 នៃបទដ្ឋាន LABS	
		2.5	គ្រឿងបង្គុំ និងកម្រាលផ្ទៃ	ការការពារអគ្គិភ័យនៃគ្រឿងបង្គុំ	ក.	ផ្តល់គ្រឿងបង្គុំដេកដែកមានការការពារអគ្គិភ័យសម្រាប់រយៈពេលកំណត់នៅក្នុងប្រការ 3.12, 3.13 និង 4.3 នៃបទដ្ឋាន LABS ដោយស្របតាមប្រភេទនៃសំណង់	FP3
				ផ្ទៃជញ្ជាំងមិនមានអនុលោមភាព	ក.	ផ្ទៃរបាំងខណ្ឌត្រូវតែកោសចេញ និងផ្លាស់ប្តូរដោយវត្ថុធាតុដែលបំពេញតាមលក្ខខណ្ឌតម្រូវលក្ខណៈរាលដាលនៃអគ្គិភ័យនៃប្រការ 6.3.2 នៃបទដ្ឋាន LABS	FP3
				ផ្ទៃពិតានមិនមានអនុលោមភាព	ក.	ផ្ទៃពិតានត្រូវតែកោសចេញ និងផ្លាស់ប្តូរដោយវត្ថុធាតុដែលបំពេញតាមលក្ខខណ្ឌតម្រូវលក្ខណៈរាលដាលនៃអគ្គិភ័យនៃប្រការ 6.3.2 នៃបទដ្ឋាន LABS	FP2

H1.3 ប្រព័ន្ធសុវត្ថិភាពអគ្គិភ័យ

ល.រ	ប្រភេទបញ្ហា	ល.រ	ប្រភេទអនុបញ្ហា	ព័ត៌មានលម្អិតអំពីអនុបញ្ហា		វិធានការដែលណែនាំជាទូទៅ	អាទិភាព
3	ប្រព័ន្ធសុវត្ថិភាពអគ្គិភ័យ	3.1	ប្រព័ន្ធចាប់សញ្ញាអគ្គិភ័យ	ប្រភេទឧបករណ៍ចាប់សញ្ញាអគ្គិភ័យមិនសមស្រប	ក.	ផ្លាស់ប្តូរឧបករណ៍ចាប់សញ្ញាអគ្គិភ័យ/ផ្សែងដោយឧបករណ៍ចាប់សញ្ញាដែលសមស្របតាមប្រភេទបរិយាកាសនៃបរិវេណដោយស្របតាមប្រការ 5.9 នៃបទដ្ឋាន LABS	FP2
				ការគ្របដណ្តប់នៃឧបករណ៍ចាប់សញ្ញាអគ្គិភ័យមិនគ្រប់គ្រាន់	ក.	ផ្តល់ឧបករណ៍ចាប់សញ្ញាទៅដល់បរិវេណបិទជិតទាំងអស់ដើម្បីធានាបាននូវអនុលោមភាពតាមប្រការ 5.9 នៃបទដ្ឋាន LABS	FP2
				ការកំណត់ទីតាំងឧបករណ៍ចាប់សញ្ញាអគ្គិភ័យមិនត្រឹមត្រូវ	ក.	ទីតាំងឧបករណ៍ចាប់សញ្ញាអគ្គិភ័យ/ផ្សែង គឺមិនស្របតាមលក្ខណៈបច្ចេកទេសនៃចម្ងាយពីពិតាន/ចន្លោះរវាងឧបករណ៍ចាប់សញ្ញា/ចៀសវាងពីការបាំង។ ដំឡើងប្រព័ន្ធចាប់សញ្ញាស្របតាមលក្ខខណ្ឌតម្រូវនៃប្រការ 5.9 នៃបទដ្ឋាន LABS	FP2
				ថាមពលបម្រុងទៅកាន់ឧបករណ៍ចាប់សញ្ញាមិនគ្រប់គ្រាន់	ក.	ថាមពលបម្រុងសម្រាប់ប្រព័ន្ធចាប់សញ្ញាអគ្គិភ័យត្រូវតែបំពាក់ដោយស្របតាមប្រការ 5.13 នៃបទដ្ឋាន LABS	FP1
		3.2	ឧបករណ៍ផ្តល់សញ្ញាអគ្គិភ័យ	ប្រភេទឧបករណ៍ផ្តល់សញ្ញាអគ្គិភ័យ (សំឡេង រូបភាព) មិនសមស្រប	ក.	បំពាក់ប្រព័ន្ធផ្តល់ដំណឹងអគ្គិភ័យ ដោយស្របតាមប្រការ 4.12, 5.2.4 និង 5.9 នៃបទដ្ឋាន LABS	FP1
				ការគ្របដណ្តប់នៃឧបករណ៍ផ្តល់សញ្ញាអគ្គិភ័យមិនគ្រប់គ្រាន់	ក.	ផ្តល់ប្រព័ន្ធផ្តល់សញ្ញាអគ្គិភ័យដោយស្របតាមប្រការ 5.9 នៃបទដ្ឋាន LABS	FP1
					ខ.	ធ្វើតេស្តកម្រិតដេស៊ីបែលរបស់ឧបករណ៍សំឡេងផ្តល់សញ្ញានៅគ្រប់បរិវេណទាំងអស់។ បន្ថែមឧបករណ៍សំឡេងសម្រាប់បរិវេណទាំងអស់ដែលកម្រិតដេស៊ីបែលផ្តល់សញ្ញាមិនគ្រប់គ្រាន់ស្របតាមប្រការ 5.9 នៃបទដ្ឋាន LABS។	FP2
				ការបើកដំណើរការឧបករណ៍ផ្តល់សញ្ញាអគ្គិភ័យមិនត្រឹមត្រូវ ឬមិនស្ងួយប្រវត្តិ	ក.	ផ្តល់គន្លឹះបើកដំណើរការឧបករណ៍ផ្តល់សញ្ញាអគ្គិភ័យដោយស្របតាមប្រការ 5.9 នៃបទដ្ឋាន LABS	FP1
				ថាមពលបម្រុងទៅកាន់ឧបករណ៍ផ្តល់សញ្ញាមិនគ្រប់គ្រាន់		ថាមពលបម្រុងសម្រាប់ប្រព័ន្ធផ្តល់សញ្ញាអគ្គិភ័យត្រូវតែបំពាក់ដោយស្របតាមប្រការ 5.13 នៃបទដ្ឋាន LABS	FP1
		3.3	ភ្លើងបំភ្លឺពេលមានអាសន្ន	ភ្លើងបំភ្លឺពេលមានអាសន្នសម្រាប់ផ្លូវដង្ហែសុខនមិនគ្រប់គ្រាន់	ក.	ផ្តល់ភ្លើងបំភ្លឺពេលមានអាសន្នដោយអនុលោមតាមប្រការ 6.8 នៃបទដ្ឋាន LABS នៅតាមផ្លូវដង្ហែសុខនទាំងអស់	FP2
				មិនបានបំពាក់ភ្លើងបំភ្លឺ	ក.	ផ្តល់ភ្លើងបំភ្លឺពេលមានអាសន្នដោយអនុលោមតាម	FP1

				ពេលមានអាសន្ន		ប្រការ 6.8 នៃបទដ្ឋាន LABS នៅតាមផ្លូវដង្ហៀសខ្លួនទាំងអស់	
				ថាមពលបម្រុងទៅកាន់ភ្លើងបំភ្លឺពេលមានអាសន្នមិនគ្រប់គ្រាន់	ក.	ថាមពលបម្រុងសម្រាប់ស្លាកសញ្ញាច្រកចេញ និងភ្លើងបំភ្លឺពេលមានអាសន្នទៅកាន់ផ្លូវដង្ហៀសខ្លួនត្រូវផ្តល់ជូនដោយស្របតាមប្រការ 6.8.3 នៃបទដ្ឋាន LABS	FP1
				ការតម្រៃភ្លើងប្រព័ន្ធភ្លើងបំភ្លឺពេលមានអាសន្នគឺមិនត្រឹមត្រូវ	ក.	តម្រៃភ្លើងប្រព័ន្ធភ្លើងបំភ្លឺពេលមានអាសន្នឡើងវិញដើម្បីធានាថាអំពូលភ្លឺនៅពេលដែលដាច់ថាមពលនៅក្នុងតំបន់ដែលប៉ះពាល់ដោយស្របតាមប្រការ 6.8 នៃបទដ្ឋាន LABS	FP1

H1.4 បញ្ញត្តិសម្រាប់ការពន្លត់អគ្គិភ័យ

ល.រ	ប្រភេទបញ្ហា	ល.រ	ប្រភេទអនុបញ្ហា	ព័ត៌មានលម្អិតអំពីអនុបញ្ហា		វិធានការដែលណែនាំជាទូទៅ	អាទិភាព
4	បញ្ញត្តិសម្រាប់ការពន្លត់អគ្គិភ័យ	4.1	ការផ្គង់ផ្គត់ទឹក	មិនមានការផ្គត់ផ្គង់ទឹកមេពីក្រុង	ក.	ផ្តល់ធុងស្តុកទឹក និងម៉ូទ័របូមទឹកសម្រាប់អគ្គិភ័យនៅទីតាំងផ្ទាល់ស្របតាមប្រការ 5.7.2 នៃបទដ្ឋាន LABS	FP2
				ធុងស្តុកនៅទីតាំងសម្រាប់ប្រព័ន្ធពន្លត់អគ្គិភ័យទឹកមិនគ្រប់គ្រាន់	ក.	ពិនិត្យមើលតម្រូវការទឹកសម្រាប់គ្រប់ប្រព័ន្ធពន្លត់អគ្គិភ័យទាំងអស់ និងផ្តល់ធុងស្តុកទឹកគ្រប់គ្រាន់នៅទីតាំងស្របតាមប្រការ 5.7 នៃបទដ្ឋាន LABS។	FP2
				មិនមាន ឬឈុតម៉ូទ័របូមទឹកមិនគ្រប់គ្រាន់	ក.	ផ្តល់ម៉ាស៊ីនបូមទឹកសម្រាប់អគ្គិភ័យគ្រប់គ្រានដោយមានសមត្ថភាពតាមការតម្រូវដោយប្រការ 5.7 នៃបទដ្ឋាន LABS	FP1
					ខ.	ផ្តល់ម៉ាស៊ីនបូមទឹកថ្មីដែលបំពេញតាមលក្ខខណ្ឌតម្រូវសម្ពាធនិងសមត្ថភាពលំហូរនៃបទដ្ឋាន LABS ប្រការ 5.3, 5.5 & 5.6	FP2
					គ.	ពិនិត្យមើលសម្ពាធ និងសមត្ថភាពលំហូររបស់ម៉ូទ័របូមទឹកសម្រាប់អគ្គិភ័យ ដើម្បីធានាថាម៉ូទ័រទាំងនោះបំពេញតាមលក្ខខណ្ឌតម្រូវដែលមានចែងនៅក្នុងបទដ្ឋាន LABS ប្រការ 5.3, 5.5 & 5.6	FP2
				ធុងស្តុកទឹកមិនគ្រប់គ្រាន់សម្រាប់បណ្តុំទុយោទឹកបាញ់ពន្លត់អគ្គិភ័យដោយស្របតាមប្រព័ន្ធម៉ាស៊ីនបូមទឹកដែលបានបំពាក់	ក.	ផ្តល់ធុងស្តុកទឹកគ្រប់គ្រាន់ដើម្បីបម្រើដល់ប្រព័ន្ធបណ្តុំទុយោ និងឧបករណ៍បាញ់ទឹក ប្រសិនបើមាន ដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវលំហូរ និងរយៈពេលនៃប្រការ 5.7 នៃបទដ្ឋាន LABS	FP2
				ឈុតម៉ូទ័របូមបម្រុងមិនបានបំពាក់ ឬមិនគ្រប់គ្រាន់	ក.	ផ្តល់ឈុតម៉ូទ័របូមបម្រុងសម្រាប់ប្រព័ន្ធបណ្តុំទុយោ និងឧបករណ៍បាញ់ទឹក ប្រសិនបើមាន ដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវលំហូរ និងរយៈពេលនៃប្រការ 5.6 នៃបទដ្ឋាន LABS	FP2
				ការបើកដំណើរការម៉ូទ័របូមទឹកសម្រាប់អគ្គិភ័យដោយដៃ	ក.	ធានាឱ្យបាននូវនីតិវិធីច្បាស់លាស់សម្រាប់ការបើកដំណើរការម៉ូទ័របូមទឹកសម្រាប់អគ្គិភ័យដោយដៃ ដោយបានកំណត់បុគ្គលទទួលបន្ទុកការងារនេះនៅក្នុងផែនការអាសន្នស្របតាមប្រការ 5.13 នៃបទដ្ឋាន LABS	FP2
					ខ.	តភ្ជាប់ម៉ូទ័របូមទឹកសម្រាប់អគ្គិភ័យទៅនឹងប្រភពថាមពលផ្គត់ផ្គង់ស្វ័យប្រវត្តិដែលបើកដំណើរការនៅ	FP3

						ពេលដែលឧបករណ៍ផ្តល់សញ្ញាអគ្គិភ័យបើកដំណើរការ ស្របតាមប្រការ 5.13 នៃបទដ្ឋាន LABS	
		4.2	ប្រព័ន្ធពន្លត់អគ្គិភ័យ	ក្បាលម៉ាស៊ីនពន្លត់អគ្គិភ័យ/ ប្រព័ន្ធចែកចាយទឹកមិនគ្រប់គ្រាន់	ក.	ផ្តល់ប្រព័ន្ធក្បាលម៉ាស៊ីនទឹកដែលមានទីតាំងភ្ជាប់ទឹកគ្រប់គ្រាន់ដើម្បីធានាបាននូវការគ្របដណ្តប់ពេញលេញនៅគ្រប់ផ្នែកទាំងអស់នៃអគារស្របតាមប្រការ 5.5 និង 5.6 នៃបទដ្ឋាន LABS	FP2
					ខ.	ផ្តល់ចំណុចតភ្ជាប់បន្ថែមដល់ប្រព័ន្ធទឹកអគ្គិភ័យដើម្បីធានាបាននូវការគ្របដណ្តប់ពេញលេញនៅគ្រប់ផ្នែកទាំងអស់នៃអគារស្របតាមប្រការ 5.6.3 នៃបទដ្ឋាន LABS	FP3
				មិនមាន ឬប្រព័ន្ធបណ្តុំទុយោបាញ់ពន្លត់អគ្គិភ័យក្នុងអគារមិនគ្រប់គ្រាន់	ក.	ផ្តល់ប្រព័ន្ធបណ្តុំទុយោបាញ់ពន្លត់អគ្គិភ័យក្នុងអគារបន្ថែមស្របតាមប្រការ 5.6 នៃបទដ្ឋាន LABS ឬកែសម្រួលការមិនបំពាក់នេះដោយឈរលើមូលដ្ឋាននៃបញ្ញត្តិនៃការពន្លត់អគ្គិភ័យជម្រើសផ្សេងទៀត	FP1
					ខ.	ផ្លាស់ប្តូរទុយោមានស្រាប់ដែលខូចគុណភាពជាមួយនឹងទុយោដែលសមស្របសម្រាប់គោលបំណងដោយស្របតាមប្រការ 5.5 & 5.6 នៃបទដ្ឋាន LABS	FP3
				បំពង់ពន្លត់អគ្គិភ័យចល័តមិនគ្រប់គ្រាន់	ក.	ផ្តល់បំពង់ពន្លត់អគ្គិភ័យប្រភេទត្រឹមត្រូវឱ្យ និងចែកចាយឱ្យបានគ្រប់គ្រាន់ តាមការតម្រូវនៃប្រការ 5.8 នៃបទដ្ឋាន LABS	FP2
				បំពង់ពន្លត់អគ្គិភ័យចល័តមិនបានបិទស្លាកសម្គាល់	ក.	ដាក់ស្លាកសញ្ញាសម្រាប់ទីតាំងបំពង់ពន្លត់អគ្គិភ័យចល័ត ធ្វើដូច្នេះទើបអ្នកនៅក្នុងអគារអាចមើលឃើញពីកន្លែងធ្វើការរបស់ខ្លួនបានស្របតាមប្រការ 5.8 នៃបទដ្ឋាន LABS	FP3
				បំពង់ពន្លត់អគ្គិភ័យចល័តមិនបានត្រួតពិនិត្យ និងមិនមានបិទស្លាក	ក.	អនុវត្តការថែទាំជាទៀងទាត់សម្រាប់បំពង់ពន្លត់អគ្គិភ័យទាំងអស់ និងថានាថាបានកត់ត្រាការត្រួតពិនិត្យនោះបានគ្រប់គ្រាន់ស្របតាមប្រការ 5.8 នៃបទដ្ឋាន LABS	FP3
				មិនមានប្រព័ន្ធពន្លត់អគ្គិភ័យស្វ័យប្រវត្តិ	ក.	ត្រូវដំឡើងប្រព័ន្ធឧបករណ៍បាញ់ទឹកស្វ័យប្រវត្តិស្របតាមប្រការ 5.3 នៃបទដ្ឋាន LABS	FP3
		4.3	ច្រកចេញចូល	មិនមានច្រកចេញចូលគ្រប់គ្រាន់សម្រាប់រថយន្តពន្លត់អគ្គិភ័យ	ក.	ច្រកចេញចូលសម្រាប់រថយន្តពន្លត់អគ្គិភ័យត្រូវតែផ្តល់ជូនស្របតាមប្រការ 5.12 នៃបទដ្ឋាន LABS	FP3
				បញ្ហាផ្សេងៗ			

H1.5 តំហែទាំ និងការថែរក្សារោងចក្រ

ល.រ	ប្រភេទបញ្ហា	ល.រ	ប្រភេទអនុបញ្ហា	ព័ត៌មានលម្អិតអំពីអនុបញ្ហា		វិធានការដែលណែនាំជាទូទៅ	អាទិភាព
5	តំហែទាំ និងការថែរក្សារោងចក្រ	5.1	ឯកសារផ្លូវច្បាប់	តើរោងចក្រមានរបាយការណ៍ត្រួតពិនិត្យរបស់នគរបាលអគ្គិភ័យដែរឬទេ ហើយតើនៅក្នុងឧបសម្ព័ន្ធមានព័ត៌មានអ្វីខ្លះ	ក.	ស្នើសុំរបាយការណ៍ត្រួតពិនិត្យរបស់នគរបាលអគ្គិភ័យ ឬឯកសារស្រដៀងគ្នាពីអាជ្ញាធរអគ្គិភ័យមូលដ្ឋានជាអំណះអំណាងនៅរោងចក្រដោយស្របតាមប្រការ 3.3 នៃបទដ្ឋាន LABS	FP2
				ឯកសារផ្សេងៗទៀតរបស់អាជ្ញាធរអគ្គិភ័យ	ក.	ស្នើសុំអាជ្ញាប័ណ្ណ លិខិតអនុញ្ញាតស្របតាមបទប្បញ្ញត្តិ ឬឯកសារស្រដៀងគ្នាដើម្បីជាអំណះអំណាងនៅរោងចក្រស្របតាមប្រការ 3.3 នៃបទដ្ឋាន LABS	FP3
		5.2	កំណត់ត្រាតំហែទាំ	កំណត់ត្រាតំហែទាំសម្រាប់ប្រព័ន្ធផ្តល់សញ្ញាមិនគ្រប់គ្រាន់	ក.	អនុវត្តការថែទាំប្រព័ន្ធផ្តល់សញ្ញាអគ្គិភ័យដោយស្របតាមប្រការ 12.8 និង 12.10 នៃបទដ្ឋាន LABS និងធានាថាមានកំណត់ត្រាសកម្មភាពថែទាំទាំងអស់សម្រាប់ការត្រួតពិនិត្យនាពេលអនាគត	FP2
				កំណត់ត្រាតំហែទាំសម្រាប់ភ្លើងបំភ្លឺពេលមានអាសន្នមិនគ្រប់គ្រាន់	ក.	អនុវត្តការថែទាំប្រព័ន្ធភ្លើងបំភ្លឺពេលមានអាសន្នស្របតាមប្រការ 12.8 និង 12.12 នៃបទដ្ឋាន LABS និងធានាឱ្យបាននូវការកត់ត្រាអំពីសកម្មភាពថែទាំទាំងអស់សម្រាប់ការត្រួតពិនិត្យនាពេលអនាគត	FP2
				កំណត់ត្រាតំហែទាំសម្រាប់ម៉ាស៊ីនបូមទឹកនិងទុយោទឹកបាញ់ពន្លត់អគ្គិភ័យមិនគ្រប់គ្រាន់	ក.	ការធ្វើតេស្ត និងតំហែទាំត្រូវតែអនុវត្តចំពោះប្រព័ន្ធទុយោបាញ់ពន្លត់អគ្គិភ័យដោយស្របតាមប្រការ 5.6 នៃបទដ្ឋាន LABS	FP3
				កំណត់ត្រាតំហែទាំប្រព័ន្ធពន្លត់អគ្គិភ័យមិនគ្រប់គ្រាន់	ក.	ការធ្វើតេស្ត និងតំហែទាំត្រូវតែអនុវត្តចំពោះប្រព័ន្ធឧបករណ៍បាញ់ទឹកស្របតាមប្រការ 5.3 នៃបទដ្ឋាន LABS	FP3
		5.3	ផែនការគ្រោះអាសន្ន	ផែនការអាសន្នមិនបានចងក្រងជាឯកសារគ្រប់គ្រាន់ ឬមិនមានតែម្តង	ក.	ផែនការអាសន្នត្រូវតែផលិត/ធ្វើបច្ចុប្បន្នភាព និងចងក្រងជាឯកសារសម្រាប់ការត្រួតពិនិត្យ ដោយស្របតាមប្រការ 12.1 និង 12.3 នៃបទដ្ឋាន LABS	FP3
				បានចាត់តាំងបុគ្គលទទួលខុសត្រូវ និងបានចងក្រងជាឯកសារនូវកិច្ចការដែលបានចាត់តាំង	ក.	ផែនការអាសន្នត្រូវតែផលិត/ធ្វើបច្ចុប្បន្នភាព និងចងក្រងជាឯកសារសម្រាប់ការត្រួតពិនិត្យ ដោយស្របតាមប្រការ 12.1 និង 12.3 នៃបទដ្ឋាន LABS	FP3
				គំនូសព្រាងអាសន្នបាន	ក.	ផែនការអាសន្នត្រូវតែផលិត/ធ្វើបច្ចុប្បន្នភាព និង	FP3

				បិទនៅច្រកចេញតាមជាន់នីមួយៗ		ចងក្រងជាឯកសារសម្រាប់ការត្រួតពិនិត្យ ដោយស្របតាមប្រការ 12.1 និង 12.3 នៃបទដ្ឋាន LABS	
		5.4	ការបណ្តុះបណ្តាលអំពីសុវត្ថិភាពអគ្គិភ័យ	មិនមានភស្តុតាងអំពីការបណ្តុះបណ្តាលបុគ្គលិក និងភារកិច្ចពេលមានអាសន្ន	ក.	ការបណ្តុះបណ្តាលបុគ្គលិក និងភារកិច្ចពេលមានអាសន្ននឹងត្រូវចែងនៅក្នុងផែនការអាសន្នស្របតាមប្រការ 12.1 ដល់ 12.3 នៃបទដ្ឋាន LABS	FP3
				កំណត់ត្រាអំពីការហាត់សមពេលមានអគ្គិភ័យមិនគ្រប់គ្រាន់	ក.	ការហាត់សមពេលមានអគ្គិភ័យត្រូវតែអនុវត្ត និងកត់ត្រាស្របតាមប្រកាឬ 12.2 នៃបទដ្ឋាន LABS ដោយអនុវត្តតាមភាពញឹកញាប់ដូចដែលបានបញ្ជាក់ដោយលិខិតអនុញ្ញាតរបស់នគរបាលអគ្គិភ័យ	FP3
		5.5	ការថែរក្សាពោងចក្រ	ទំនិញរក្សាទុក របស់របរ រាំងនៅតាមផ្លូវជម្លៀសខ្លួន	ក.	ឃ្លាំងកំពុងដំណើរការ ឃ្លាំងនៅរង់ចាំការលើកដាក់ទំនិញ និងរបស់របរផ្សេងៗទៀតដែលត្រូវតែគ្រប់គ្រងឱ្យបានត្រឹមត្រូវស្របតាមប្រការ 12.6 និង 12.7 នៃបទដ្ឋាន LABS	FP1
				ទំនិញរក្សាទុក របស់របរ រាំងនៅតាមផ្លូវជណ្តើរ	ក.	ឃ្លាំងកំពុងដំណើរការ និងរបស់របរផ្សេងៗទៀតដែលត្រូវតែគ្រប់គ្រងឱ្យបានត្រឹមត្រូវស្របតាមប្រការ 12.6 និង 12.7 នៃបទដ្ឋាន LABS	FP1
				ទំនិញចំហេះដែលគរលើគ្នានៅក្បែរប្រភពកម្តៅ/អគ្គិសនី	ក.	ទំនិញចំហេះទាំងអស់ត្រូវគ្រប់គ្រងឱ្យបានត្រឹមត្រូវដោយស្របតាមប្រការ 12.6 និង 12.7 នៃបទដ្ឋាន LABS	FP2
				ផ្សេងៗ			

H2 ការកំណត់អាទិភាពវិធានការសុវត្ថិភាពអគ្គិភ័យ

ប្រភេទពណ៌	បៃតង	លឿង	លឿងទុំ	លឿងទុំ/ក្រហម	ក្រហម
អាទិភាព 1 ការអង្កេត	0	0	0 < n =< 7	7 < n =< 15	>15
អាទិភាព 2 ការអង្កេត	0	លេខណាមួយក៏បាន	លេខណាមួយក៏បាន	លេខណាមួយក៏បាន	លេខណាមួយក៏បាន
អាទិភាព 3 ការអង្កេត	លេខណាមួយក៏បាន	លេខណាមួយក៏បាន	លេខណាមួយក៏បាន	លេខណាមួយក៏បាន	លេខណាមួយក៏បាន
កំណត់សម្គាល់អំពីការកំណត់លេខកូដពណ៌រោងចក្រសម្រាប់សុវត្ថិភាពអគ្គិភ័យ					

ប្រព័ន្ធដាក់ពិន្ទុខាងលើដើម្បីកំណត់លេខកូដពណ៌រោងចក្រ គួរតែប្រើប្រាស់តែជាការណែនាំសម្រាប់ការកំណត់អាទិភាពភាពបន្ទាន់ក្នុងការដោះស្រាយទិដ្ឋភាពសុវត្ថិភាពអគ្គិភ័យនៅក្នុងរោងចក្រប៉ុណ្ណោះ។

អ្នកត្រួតពិនិត្យអគ្គិភ័យអាចជួបប្រទះស្ថានភាព ដែលចំណុចតែមួយមុខនៅក្នុងបញ្ជីត្រួតពិនិត្យមានលក្ខណៈមិនគ្រប់គ្រាន់ក្នុងការក្លាយជាបញ្ហា ឬបញ្ហាដែលគួបផ្គុំជាមួយបញ្ហាមួយចំនួនទៀត បង្កើតជាប្រភេទហានិភ័យខ្ពស់ ទោះបីជាប្រព័ន្ធដាក់ពិន្ទុខាងលើមិនផលិតបានពិន្ទុខ្ពស់ក៏ដោយ។ អ្នកត្រួតពិនិត្យគួរមានសុភវិនិច្ឆ័យដើម្បីសម្របសម្រួលប្រភេទហានិភ័យ។

នៅមុនពេលបញ្ចប់ការចាត់ប្រភេទពណ៌អគារជាស្តាពរ អ្នកត្រួតពិនិត្យអគ្គិភ័យគួរមានសុភវិនិច្ឆ័យដើម្បីវាយតម្លៃមើលថាតើការដាក់ពិន្ទុនោះឆ្លុះបញ្ចាំងអំពីស្ថានភាពសុវត្ថិភាពអគ្គិភ័យនៃអគារដែលបានអង្កេតឃើញជាក់ស្តែងដែរឬទេ។ ប្រសិនបើការដាក់ពិន្ទុបង្ហាញអំពីកម្រិតសុវត្ថិភាពខុសគ្នាអំពីអ្វី ដែលអ្នកត្រួតពិនិត្យអគ្គិភ័យបានអង្កេតឃើញនៅទីតាំងផ្ទាល់ អគារនោះគួរតែផ្តល់ប្រភេទពណ៌ដែលឆ្លើបតបទៅនឹងស្ថានភាពដែលបានអង្កេតឃើញ។

ឧបសម្ព័ន្ធ ។

ការចាត់ប្រភេទ និងការកំណត់អាទិភាពបញ្ហាអត្ថិសនី

I1 ការចាត់ថ្នាក់បញ្ហាអគ្គិសនី

ប្រភេទបញ្ហា	អនុបញ្ហា
E1៖ ការផ្គត់ផ្គង់ទៅកាន់ប្រព័ន្ធសុវត្ថិភាពអាយុជីវិត	
	ប្រព័ន្ធសុវត្ថិភាពអាយុជីវិត
	ឧបករណ៍ចាប់សញ្ញាអគ្គិភ័យ និងឧបករណ៍ផ្តល់សញ្ញាអគ្គិភ័យ
	ភ្លើងបំភ្លឺពេលមានអាសន្ន
	ម៉ូទ័របូមទឹកសម្រាប់អគ្គិភ័យ
	ស្ថានភាពបរិក្ខារ
	ផ្សេងៗ
E2៖ ខ្សែម៉ាសដី និងការតភ្ជាប់	
	ការតភ្ជាប់បរិក្ខារមិនគ្រប់គ្រាន់
	ដាច់តំណភ្ជាប់ខ្សែណឺត
	ខ្សែចម្លងម៉ាសដីខូចខាត/ដាច់
	ឧបករណ៍ចរន្តសំណល់
	ខ្សែចម្លងតភ្ជាប់ប៉ូតង់ស្យែលស្មើគ្នាមេ
	ស្ថានភាពទូទៅនៃប្រព័ន្ធការពារផ្ទុះ៖ ខ្សែចម្លង និងសមាសធាតុរកឃើញថាខូចខាត/មិនបានជួសជុល
	ស្ថានភាពទូទៅនៃប្រព័ន្ធការពារផ្ទុះ៖ រកឃើញមានច្រែះ
	មិនបានដំឡើងប្រព័ន្ធការពារផ្ទុះ
	មិនដឹងព័ត៌មានលម្អិតអំពីការការពារផ្ទុះ
	ផ្សេងៗ
E3៖ ម៉ាស៊ីនភ្លើង	
	ប្រភេទម៉ាស៊ីនភ្លើងមិនបានបញ្ជាក់នៅក្នុងឯកសារ/នៅលើបរិក្ខារ
	សមត្ថភាពម៉ាស៊ីនភ្លើង
	ការចាក់សោរ និងបណ្តោរ
	បេនឥន្ធនៈ
	ខ្សែម៉ាសដីរបស់ម៉ាស៊ីនភ្លើង
	លេចប្រេង

	មិនមានម៉ូទ័របូមប្រេងផ្គត់ផ្គង់ប្រព័ន្ធសុវត្ថិភាពអាយុជីវិត
	ការតាមដានត្រួតពិនិត្យឥន្ធន:
	អាគុយម៉ាស៊ីនភ្លើង
	ប្រព័ន្ធខ្យល់ចេញចូល
	ការថែរក្សារោងចក្រ
	ស្ថានភាពបរិក្ខារ
	ផ្សេងៗ
E4៖ អនុស្ថានីយ	
	ការថែរក្សារោងចក្រ
	ស្លាកសញ្ញាព្រមាន/គ្រោះថ្នាក់
	ប្រភពថាមពលចូលមេ
	ទីតាំងអនុស្ថានីយ
	ការតភ្ជាប់ប្រេង
	ច្រកទឹកចូល
	ការជួសជុលអនុស្ថានីយ
	ច្រកចេញចូលអនុស្ថានីយ
	ប្រព័ន្ធខ្យល់ចេញចូល
	ស្ថានភាពបរិក្ខារ
	ផ្សេងៗ
E5៖ បន្ទះចែកចាយ	
	ទម្រ/ ការដំឡើងខ្សែ
	សមត្ថភាពចម្លងចរន្តរបស់ខ្សែភ្លើង
	ការកំណត់អត្តសញ្ញាណខ្សែភ្លើង/ សៀគ្វី
	វត្តមានកម្ទេចក្រណាត់/ ធូលី
	ខ្សែភ្លើង/ ទុយោខូចខាត
	វត្ថុធាតុចំហេះ/ ងាយឆាបឆេះ
	តុល្យភាពបន្ទុក
	ការថែរក្សារោងចក្រ
E6៖ គំនូសប្លង់	

	មិនមាន ឬដ្យាក្រាមបន្ទាត់ទោលផុតសុពលភាព
	មិនមាន ឬដ្យាក្រាមខែម៉ាសដីផុតសុពលភាព
	មិនមាន ឬគំនូសព្រាងអគ្គិសនីផុតសុពលភាព
	មិនមាន ឬកាលវិភាគតុល្យភាពថាមពលផុតសុពលភាព
	មិនមានដ្យាក្រាមទូចែកចាយ
E7៖ តំហែទាំ និងកំណត់ត្រា	
	កាលវិភាគតំហែទាំ
	កំណត់ត្រាតំហែទាំ
E8៖ ការស្ពែនកម្តៅ	
	មិនមានការស្ទង់ / មិនពេញលេញ ដោយសារតែបញ្ហានៃការចេញចូល
	តំណភ្ជាប់ / ប៉ូលខ្សែភ្លើង
	ឌីសង់ទ័រ
	ឧបករណ៍ផ្សេងៗ

I2 ការកំណត់អាទិភាពបញ្ហាអគ្គិភ័យ

ដោយសារតែការវាយតម្លៃសុវត្ថិភាពអគ្គិសនី ពឹងផ្អែកយ៉ាងខ្លាំងទៅលើការវិនិច្ឆ័យស្ថានភាពរបស់អគារមានស្រាប់ និងសូចនាករផ្អែកលើភស្តុតាងជាច្រើននៃសមត្ថភាពដំណើរការរបស់ប្រព័ន្ធអគ្គិសនី និងប្រព័ន្ធសុវត្ថិភាពអាយុជីវិតជាច្រើន ការកំណត់អាទិភាពស្តាពរសម្រាប់បញ្ហានីមួយៗនៅក្នុងបញ្ជីត្រួតពិនិត្យអគ្គិសនីមិនអាចទៅរួចឡើយ។

ចំណុចនេះបង្កើតជាផ្នែកសំខាន់មួយនៃការបណ្តុះបណ្តាលរបស់ក្រុមហ៊ុនវាយតម្លៃ។ ឧទាហរណ៍អំពីវិធានការទូទៅពាក់ព័ន្ធនឹងបញ្ហាចម្បងៗដែលទំនងជាអាចរកឃើញ និងសេចក្តីណែនាំអំពីការកំណត់អាទិភាពអាចផ្តល់ជូននៅពេលនោះតែម្តង។

ទោះជាយ៉ាងណាក៏ដោយ សេចក្តីណែនាំខាងក្រោមនេះមានផ្តល់ជូនដើម្បីសម្រួលដល់វិស្វករដែលមានគុណវុឌ្ឍិសមស្របក្នុងការកំណត់កម្រិតអាទិភាពសមស្របបំផុតសម្រាប់លទ្ធផលរកឃើញ។ ចំណុចនេះគួរតែអាចអមជាមួយនឹងគោលការណ៍ដែលមានចែងនៅក្នុងផ្នែក 7.1។

EP1៖ វិធានការភ្លាមៗ

វិធានការ EP1 ត្រូវតែរក្សាទុក និងអនុវត្តនៅក្នុងករណីដែលអ្នកវាយតម្លៃអគ្គិសនីបានកំណត់ឃើញថាមានហានិភ័យធ្ងន់ធ្ងរចំពោះសុវត្ថិភាពអាយុជីវិត ឬមានអគ្គិភ័យកើតឡើង។

ការអង្កេត/វិធានការមួយចំនួនជាទូទៅនឹងត្រូវបានចាត់ទុកថានាំឱ្យ EP1៖

- មានសីតុណ្ហភាពខ្ពស់ដែលបានអង្កេតឃើញនៅក្នុងអំឡុងពេលស្ទង់កម្តៅទៅលើបរិក្ខារអគ្គិសនី/តំណភ្ជាប់/ខ្សែភ្លើង/ជានែល/ទូចែកចាយ
- ខ្សែចម្លងមានចរន្តស្រាតដែលស្ថិតនៅក្បែរមនុស្ស ឬក្បែរទៅនឹងវត្ថុធាតុងាយឆាបឆេះ
- បញ្ហាឡើងកម្តៅហួសប្រមាណចំពោះខ្សែភ្លើង/ទូអគ្គិសនី/ទូចែកចាយ
- បញ្ហាលើសបន្ទុកដែលបានកំណត់រកឃើញនៅក្នុងសៀគ្វី
- វេស៊ីស្តង់ខ្ពស់ដែលបានអង្កេតឃើញនៅក្នុងរណ្តៅខ្សែម៉ាសដី (បរិក្ខារ និងការការពារឧន្ទះ)
- មិនមានសៀគ្វីដែលត្រូវបានទាញចរន្តចេញសម្រាប់បន្ទុកដោយមិនមានការបញ្ចូលឧបករណ៍ការពារចរន្តលើសឡើយ (ឌីសង់ទ័រ)
- បន្ទប់អគ្គិសនី/ទូអគ្គិសនីមិនស្អាត និងមានធូលី មានកម្ទេចក្រណាត់ ទឹក ប្រេង និងកម្ទេចកម្ទី
- កម្ទេចក្រណាត់/ធូលីមានកម្រិតខ្ពស់ដែលមានសីតុណ្ហភាពខ្ពស់ត្រូវបានកត់ត្រាឃើញនៅក្នុងទូអគ្គិសនីអគ្គិសនីនៅក្នុងមូលដ្ឋានតែមួយ
- វត្ថុធាតុងាយឆាបឆេះដែលបានអង្កេតឃើញនៅក្នុងទូអគ្គិសនីអគ្គិសនី ឬទំនិញចំហេះដែលបានរក្សាទុកនៅក្នុងបន្ទប់អគ្គិសនី។

អគារដែលមានលទ្ធផល SP1 មិនល្អ ជារួម មានលេខកូដពណ៌ដូចខាងក្រោម។

ក្រហម/លឿងទុំ៖ ប្រសិនបើអ្នកពិគ្រោះយោបល់វិស្វកម្មគ្រឿងបង្គុំដែលមានគុណវុឌ្ឍិ (QSEC) ចាត់

ទុកថាមាន**វិធានការភ្លាមៗសំខាន់ក្នុងការរក្សាការចាត់ពណ៌លឿងទុំ** របាយការណ៍អាចនឹងចាត់ពណ៌លឿងទុំជាមួយនឹងវិធានការពណ៌ក្រហម។ វិធានការពណ៌ក្រហមត្រូវតែបំពេញក្នុងរយៈពេលពីរសប្តាហ៍ បើមិនដូច្នោះទេអោងចក្រទាំងមូលនឹងត្រូវចាត់ប្រភេទជាពណ៌ក្រហម។ វិធានការសំខាន់បំផុតត្រូវតែកំណត់តួលេខនៃបញ្ហាទាំងនោះ។ ឧទាហរណ៍នៃចំណុចនេះអាចជាក្នុងករណីដែលសីតុណ្ហភាពខ្ពស់ត្រូវបានអង្កេតឃើញនៅក្នុងទូអគ្គិសនីមួយចំនួន។
ផលិតកម្មទាំងមូលអាចនឹងរងការប៉ះពាល់។
ក្រហម៖ ការបិទអគារអោងចក្រភ្លាមៗ ឬផ្នែកសំខាន់នៃអគារគឺត្រូវបានណែនាំឱ្យអនុវត្ត។ ការបិទអគារស្របតាមពិធីសារ។ ចំណុចនេះគឺក្នុងករណីដែលមានវិធានការបន្ទាន់ច្រើន និង / ឬរកឃើញនៅពេញប្រព័ន្ធទាំងមូល។ ផលិតកម្មទាំងមូលអាចនឹងរងការប៉ះពាល់។

EP2៖ វិធានការរយៈពេល 2 សប្តាហ៍

EP2 អាចអនុវត្តចំពោះវិធានការ ដែលហានិភ័យអគ្គិភ័យចំពោះអាយុជីវិតមានកម្រិតទាបជាង EP1។ EP2 អាចប្រើប្រាស់ក្នុងករណីដែលតម្រូវឱ្យមានការអន្តរគមន៍ពីមនុស្ស ឬព្រឹត្តិការណ៍ផ្សេងទៀតសម្រាប់ហានិភ័យដែលមានគ្រោះថ្នាក់។ ការអង្កេត / វិធានការមួយចំនួនជាទូទៅនឹងត្រូវបានចាត់ថានាំឱ្យមាន EP2 អាចបណ្តាលមកពី៖

- អនុស្ថានីយ ឬបន្ទប់អគ្គិសនីមិនបានចាក់សោ

ហានិភ័យបង្ហាញឱ្យឃើញផ្ទាល់ជាក់ស្តែងក្នុងករណីដែលមានបុគ្គលមិនមានការអនុញ្ញាត ឬមិនមានការបណ្តុះបណ្តាលចូលទៅក្នុងបរិវេណ៖

- តំណខ្សែភ្លើងមិនល្អ ឬបិទស្កុត
- ការខូចនៅលើទូអគ្គិសនីឧបករណ៍ផ្តល់សញ្ញាអគ្គិភ័យ
- ការខូចនៅលើប្រភពផ្គត់ផ្គង់ថាមពលចម្បង ឬបន្សំទៅកាន់ឧបករណ៍សុវត្ថិភាពអាយុជីវិត
- កម្ទេចក្រណាត់/ធូលីមានកម្រិតខ្ពស់ខ្លាំង ដែលសីតុណ្ហភាពខ្ពស់មានកត់ត្រាឃើញនៅក្នុងទូអគ្គិសនីអគ្គិសនីនៅក្នុងមូលដ្ឋានតែមួយ។

បញ្ហានេះគួបផ្សំជាមួយនឹងសីតុណ្ហភាពមធ្យមទៅខ្ពស់ នៅលើបរិក្ខារតែមួយតំណាងឱ្យហានិភ័យអគ្គិភ័យ។
លឿងទុំ៖ មិនមានមូលហេតុដែលត្រូវផ្អាកប្រតិបត្តិការនៅក្នុងអោងចក្រឡើយ ប៉ុន្តែអាចតម្រូវឱ្យចាត់វិធានការនៅក្នុងអោងចក្រផ្ទាល់។ ផលិតកម្មអាចបន្តដំណើរការបានដោយត្រូវមានការព្រមព្រៀងដើម្បីធ្វើការវាយតម្លៃ និងធ្វើតេស្តបន្ថែមទៀត ព្រមទាំងវិធានការដើម្បីដោះស្រាយបញ្ហាដែលបានលើកឡើងជាមួយនឹងវិធានការអាទិភាពនៅក្នុងរបាយការណ៍។ បញ្ហានានាត្រូវតែដោះស្រាយនៅក្នុងរយៈពេល 2 សប្តាហ៍។ អាចបន្តដំណើរការផលិតកម្មបាន។

EP3៖ វិធានការរយៈពេល 4 សប្តាហ៍

EP3 អាចអនុវត្តចំពោះវិធានការដែលមានហានិភ័យសុវត្ថិភាពអាយុជីវិត និងហានិភ័យអគ្គិភ័យមានកម្រិតទាបជាង។ វិធានការទាំងនេះអាចរួមបញ្ចូលវិធានការដែលតម្រូវឱ្យមានប្រព័ន្ធ (សុវត្ថិភាព) ច្រើនមិនដំណើរការក្នុងពេលតែមួយ។ ឧទាហរណ៍អាចចាត់ទុកថាជា EP3 មាន៖

- តំណភ្ជាប់នៃគ្រោងលោហៈបន្ថែម។

បញ្ហានេះតម្រូវឱ្យគ្រោងលោហៈដែលមិនបានតភ្ជាប់នោះមានចរន្ត ហើយមាននរណាម្នាក់មកប៉ះផ្ទាល់ទើបអាចមានផលប៉ះពាល់។

- តំហែទាំលើប្រព័ន្ធផ្តល់ដំណឹងអគ្គិភ័យហួសរយៈពេលកំណត់។
- តណភ្ជាប់អគ្គិសនីនៅទូអគ្គិសនីគ្រប់គ្រងមិនបានធ្វើបច្ចុប្បន្នភាពនៅក្នុងដ្យាក្រាមបន្ទាត់ទោល
- មិនមានដ្យាក្រាមគំនូសខ្សែម៉ាសដីសម្រាប់ត្រួតពិនិត្យ
- បន្ទះចែកចាយអគ្គិសនីមានតំណភ្ជាប់មិនត្រឹមត្រូវ (ខ្ទះក្បាល និងប៊ូឡុងខ្សែភ្លើង)
- កម្រិត IP (ច្រកការពារ) បន្ទះចែកចាយអគ្គិសនីមិនត្រឹមត្រូវ។

អគារដែលមានតែលទ្ធផល EP3 ជារួម មានលេខកូដពណ៌លឿង។

ពណ៌លឿង៖ ជាទូទៅ មិនមានបញ្ហាអ្វីទាំងអស់ ដោយត្រូវមានការព្រមព្រៀងដោះស្រាយមតិយោបល់អាទិភាព ដែលអាចរួមបញ្ចូលលក្ខខណ្ឌតម្រូវសម្រាប់តំហែទាំដែលត្រូវអនុវត្តនៅលើប្រព័ន្ធសុវត្ថិភាពអាយុជីវិត។ មិនមានបញ្ហាធ្ងន់ធ្ងរដែលអាចអង្កេតឃើញចំពោះប្រព័ន្ធ ឬសមាសធាតុ មិនមានហានិភ័យភ្លាមៗដល់កម្មករដែលអង្កេតឃើញឡើយ។ អាចបន្តដំណើរការផលិតកម្មបាន។

EP4៖ វិធានការរយៈពេល 2 ខែ

បញ្ហាទាំងនេះ ប្រសិនបើមិនបានដោះស្រាយនៅក្នុងរយៈពេលកំណត់ទេ បញ្ហាទាំងនោះនឹងមានសភាពកាន់តែយ៉ាប់យ៉ឺន និងវិវត្តទៅជាហានិភ័យកាន់តែខ្ពស់។

EP4 ក៏អាចអនុវត្តបានក្នុងករណីដែលតម្រូវឱ្យធ្វើការថែទាំជាបន្តបន្ទាប់។ ឧទាហរណ៍៖

- ស្លាកសម្គាល់បរិក្ខារអគ្គិសនីបានបាត់ ឬមិនត្រឹមត្រូវ
- មិនបានអនុវត្ត ឬពុំមានកំណត់ត្រាអំពីការថែទាំសម្រាប់បរិក្ខារអគ្គិសនី
- កម្ទេចក្រណាត់/ធូលីកម្រិតទាបនៅក្នុងទូអគ្គិសនីដែលបង្ហាញថាមិនមានសញ្ញានៃការឡើងកម្តៅហួសប្រមាណ។
- ទីតាំងម៉ូទ័របូមទឹកសម្រាប់អគ្គិភ័យមិនមានផ្លូវចេញចូលត្រឹមត្រូវសម្រាប់មនុស្ស។
- បន្ទប់ទូអគ្គិសនីអគ្គិសនីមេមិនមានរបាំងបិទជិតពីស្ថានភាពអាកាសធាតុខាងក្រៅ។

អគារដែលមានតែលទ្ធផល EP4 ជារួម មានលេខកូដពណ៌បៃតង។

ពណ៌បៃតង៖ ជាទូទៅ មិនមានបញ្ហាអ្វីទាំងអស់ ដោយត្រូវមានការព្រមព្រៀងដោះស្រាយមតិយោបល់អាទិភាព ដែលអាចរួមមានលក្ខខណ្ឌតម្រូវសម្រាប់តំហែទាំដែលត្រូវអនុវត្តនៅលើប្រព័ន្ធ។ មិនមានបញ្ហាធ្ងន់ធ្ងរដែលអាចអង្កេតឃើញចំពោះប្រព័ន្ធ ឬសមាសធាតុ មិនមានហានិភ័យភ្លាមៗដល់កម្មករដែលអង្កេតឃើញឡើយ។ អាចបន្តដំណើរការផលិតកម្មបាន។

ឧបសម្ព័ន្ធ ၂

ទម្រង់របាយការណ៍ខាយតម្លៃសុវត្ថិភាព -គំរូ

J1 គំរូគ្រឿងបន្លុំ

កំណែ៖ កាលបរិច្ឆេទ XXX ចេញ៖ ថ្ងៃ ខែ ឆ្នាំ

ប្រភេទ (ពណ៌)

ឈ្មោះរោងចក្រ

អាសយដ្ឋានរោងចក្រ (និយាមការរបស់រោងចក្រ)

ថ្ងៃ ខែ ឆ្នាំ *(កាលបរិច្ឆេទវាយតម្លៃ)*

របាយការណ៍វាយតម្លៃសុវត្ថិភាពគ្រឿងបង្គុំ ការអភ្នែត និងវិធានការ

ក្រុមហ៊ុនវាយតម្លៃ៖ ឈ្មោះ

អ្នកនិពន្ធ៖ ឈ្មោះអ្នកនិពន្ធ

ត្រួតពិនិត្យដោយ៖ ឈ្មោះអ្នកត្រួតពិនិត្យ

អនុម័តដោយ៖ ឈ្មោះអ្នកអនុម័ត

រូបថតរោងចក្រ

LABS
Life And Building Safety

មាតិកា

1 សេចក្តីសង្ខេបប្រតិបត្តិ
2 វិសាលភាពអគារ
3 ប្រព័ន្ធគ្រឿងបង្គុំ
4 ការអង្កេត
5 វិធានការអាទិភាព
6 សេចក្តីសង្ខេបអំពីវិធានការអាទិភាព
7 ដែនកំណត់ និងការសន្មត

1 សេចក្តីសង្ខេបប្រតិបត្តិ

នៅថ្ងៃទី xx ខែ ឆ្នាំ ឈ្មោះ នាមត្រកូល នៃ ក្រុមហ៊ុនវាយតម្លៃ បានអនុវត្តការវាយតម្លៃគ្រឿងបង្គុំរោងចក្រដោយការពិនិត្យមើលនឹងភ្នែក ឈ្មោះរោងចក្រ នៅអាសយដ្ឋាន និងនិយាមកាមដែលបានបញ្ជាក់នៅទំព័រមុខនៃរបាយការណ៍នេះ។ ការវាយតម្លៃនេះជាការវាយតម្លៃមិនប៉ះផ្ទាល់ និងអនុវត្តស្របតាមបទដ្ឋាន LABS សម្រាប់ ឈ្មោះប្រទេស និងវិធីសាស្ត្រពាក់ព័ន្ធសម្រាប់ការវាយតម្លៃសុវត្ថិភាពបឋមសម្រាប់ឈ្មោះប្រទេស។

ឈ្មោះរោងចក្រកាន់កាប់បរិវេណអគារទាំងមូល (ឬអគារទាំងអស់នៅទីតាំង) និងផ្តល់ច្រកចេញចូលទៅកាន់គ្រប់បរិវេណទាំងអស់។

យើងបានជួបជាមួយអ្នកតំណាងរបស់គណៈគ្រប់គ្រងរោងចក្រ នាមត្រកូល (តំណែងការងារ) និង នាមត្រកូល (តំណែងការងារ) (បុគ្គលិកផ្សេងទៀតរបស់គណៈគ្រប់គ្រង)។ ដោយសារតែការវាយតម្លៃនេះត្រូវបានអនុវត្តជាផ្នែកមួយនៃលំហាត់វាយតម្លៃសាកល្បងទៅលើគ្រឿងបង្គុំ អគ្គិភ័យ និងអគ្គិសនី អ្នកតំណាងផ្សេងទៀតមកពី ក្រុមហ៊ុនវាយតម្លៃ ក៏មានវត្តមានផងដែរ អមជាមួយនឹងអ្នកអង្កេតមកពីក្រុមហ៊ុន និងក្រុមហ៊ុន។ [លុបចោលប្រសិនបើមិនពាក់ព័ន្ធ]

សេចក្តីពណ៌នាអំពីរោងចក្រ៖ ចំនួនអគារ ការប្រើប្រាស់អគារ
ឆ្នាំសាងសង់
តើរោងចក្រទាំងមូលជាកម្មសិទ្ធិរបស់ក្រុមហ៊ុនតែមួយឬទេ? ចំនួនកម្មករនិយោជិត

ឧទាហរណ៍ ជាទូទៅ រោងចក្រមានអគារផលិតកម្មចម្បងៗចំនួនពីរ (អគារ 5-10 និងអគារ 11 យោងតាមប្លង់ទីតាំង) និងមូលដ្ឋានបន្សំតូចៗជាច្រើន។ អគារ 5-10 ត្រូវប្រើប្រាស់សម្រាប់ផ្នែកដេរ កាត់ ទទួលទានអាហារ និងជាឃ្លាំងស្របពេលដែលអគារ 11 គឺជាអគារដេរ / កាត់។ អគារនេះសាងសង់នៅឆ្នាំ2008 ហើយបរិវេណរោងចក្រគឺជាកម្មសិទ្ធិ និងកាន់កាប់ទាំងស្រុងដោយ XXX។ រោងចក្រនេះមានកម្មករនិយោជិតប្រមាណជា 500 នាក់នៅក្នុងបរិវេណរោងចក្រ។

ទិដ្ឋភាពរួមនៃប្រព័ន្ធគ្រឿងបង្គុំនៅក្នុងអគាររោងចក្រ (ដែក/បេតុង គ្រោងចន្លោះ (portal frame)/ គ្រោងម៉ូម៉ង់ (moment frame) ។ល។
ឧទាហរណ៍ អគារផលិតកម្មជាអគារគ្រោងដែកមានកម្ពស់មួយជាន់។ អគារ 11 ជាអគារគ្រោងចន្លោះ (portal frame) មួយល្វែង ខណៈដែលអគារ 5-10 គឺជាអគារគ្រោងចន្លោះពីរល្វែង។

គំនូសប្លង់៖

តើមានគំនូសប្លង់អ្វីខ្លះដែលបានបង្ហាញ? ឧទាហរណ៍ គំនូសប្លង់រចនាគ្រឿងបង្គុំ របាយការណ៍ដីគំនូសប្លង់កែសម្រួល ពាក្យស្នើសុំលិខិតអនុញ្ញាត លិខិតអនុញ្ញាតបញ្ចប់ការសាងសង់
ឧទាហរណ៍ យើងបានទទួលពាក្យស្នើសុំលិខិតអនុញ្ញាត និងឯកសារអនុម័តសម្រាប់បរិវេណរោង

ចក្រ ដោយផ្អែកលើឯកសាររចនាដែលបានរៀបចំឡើងនៅមុនពេលចាប់ផ្តើមការសាងសង់។ មិនមានការផ្តល់ជូនអាជ្ញាប័ណ្ណ/ លិខិតអនុញ្ញាតបញ្ចប់ការសាងសង់ឡើយ។

គំនូសប្លង់រចនាគ្រឿងបង្គុំត្រូវបានផ្តល់ជូនសម្រាប់អគារចម្បងទាំងពីរ ដែលមានលក្ខណៈស្របគ្នាយ៉ាងទូលំទូលាយជាមួយគ្រឿងបង្គុំតាមការអង្កេតក្នុងអំឡុងពេលវាយតម្លៃ។
ពុំមានរបាយការណ៍ដីនោះទេ។ ទម្រគ្រឹះ គឺមានបង្ហាញនៅលើគំនូសប្លង់គ្រឿងបង្គុំ។

ឈ្មោះអគារ (ប្រសិនបើពាក់ព័ន្ធ) គឺជាចំណុចផ្តោតចម្បងនៃការវាយតម្លៃគ្រឿងបង្គុំ។ បញ្ជីអគារណាមួយផ្សេងទៀតដែឡបានវាយតម្លៃ និងកម្រិតនៃការវាយតម្លៃ ឧទាហរណ៍ ការវាយតម្លៃសង្ខេបអំពីអគារបន្សំ គឺត្រូវបានអនុវត្តដើម្បីកំណត់អត្តសញ្ញាណបញ្ហាសុវត្ថិភាពអាយុជីវិតសំខាន់ៗពីទិដ្ឋភាពនៃគ្រឿងបង្គុំ។ មិនមានបញ្ហាដែលបានកំណត់អត្តសញ្ញាណឡើយ។ *[ផ្លាស់ប្តូរតាមការសមស្រប]*

ប្រភេទលេខកូដពណ៌ទាំងមូលនៃរោងចក្រនេះគឺជាលេខកូដពណ៌។ ចំណុចនេះមានន័យថា យ៉ាងតិចមានវិធានការមួយចំនួនដែលត្រូវដោះស្រាយនៅក្នុងរយៈពេលកំណត់។ ប្រភេទលេខកូដពណ៌សម្រាប់អគារសំខាន់ៗដាច់ដោយឡែកនីមួយៗដែលបានវាយតម្លៃ (ប្រសិនបើពាក់ព័ន្ធ) មានដូចខាងក្រោម៖

- ឈ្មោះអគារ៖ ប្រភេទ Nn
- ឈ្មោះអគារ៖ ប្រភេទ Nn
- ឈ្មោះអគារ៖ ប្រភេទ Nn

បញ្ជីអំពីចំណុចព្រួយបារម្ភសំខាន់កម្រិតខ្ពស់ និងមិនគ្រប់ជ្រុងជ្រោយមាន៖

- បញ្ហា 1
- បញ្ហា 2
- បញ្ហា 3
- បញ្ហា 4

ផ្អែកលើស្ថានភាពនៃប្រព័ន្ធសុវត្ថិភាពគ្រឿងបង្គុំ និងស្ថានភាពនៃជាន់រោងចក្រដែលបានអង្កេតកម្រិតតំហែទាំបង្ហាញថា អាចទទួលយកបាន លុះត្រាណាតែបានអនុវត្ត ឬបន្តអនុវត្តសកម្មភាពតំហែទាំទៀងទាត់ ហើយបានរក្សាកំណត់ត្រាលម្អិតអំពីសកម្មភាពទាំងនោះនៅក្នុងពេលអនាគត។ *[ផ្លាស់ប្តូរតាមការសមស្រប]*

យើងបានអនុវត្តការវាយតម្លៃដីស្របតាមវិធីសាស្ត្ររបស់ LABS ដោយមិនមានលទ្ធផលរកឃើញសំខាន់ៗនោះទេ។ ការវាយតម្លៃដីបន្ថែមគឺមិនត្រូវបានតម្រូវជាផ្នែកមួយនៃគំនិតផ្តួចផ្តើម LABS នោះទេ។ ដោយសារតែចំណុចនេះមិនមែនជាការត្រួតពិនិត្យអនុលោមភាពតាមក្រមស្របតាមក្រមអគាររបស់កម្ពុជា គណៈគ្រប់គ្រងរោងចក្រអាចនឹងមានបំណងពិចារណាលើចំណុចនេះដាច់ដោយឡែក។ *[ផ្លាស់ប្តូរតាមការសមស្រប]*
យើងរកមិនឃើញពីមូលហេតុណាដែលត្រូវផ្អាកប្រតិបត្តិការនៅរោងចក្រដោយសារតែចំណុចបារម្ភ

ទាំងនេះឡើយ (យោងតាមវិធានការដែលតម្រូវជាចាំបាច់ដែលបានកត់សម្គាល់នៅចុងបញ្ចប់នៃរបាយការណ៍នេះ។) *[ផ្លាស់ប្តូរតាមការសមស្របដោយផ្អែកលើវិធានការតម្រូវចាំបាច់]*

វិធានការបន្ថែមជាមួយនឹងចំណុចអាទិភាព និងគ្រោងពេលវេលាពាក់ព័ន្ធមានផ្តល់ជូននៅចុងបញ្ចប់នៃរបាយការណ៍នេះ។ សូមកត់សម្គាល់ថា វិធានការទាំងនេះគួរបំពេញឱ្យបានលឿនតាមដែលអាចអនុវត្តទៅបានជាក់ស្តែង និងស្ថិតនៅក្នុងគ្រោងពេលវេលាដែលបានកត់សម្គាល់។

ដៃនកំណត់ និងការសន្មតរបស់យើង ក៏ត្រូវបានកត់សម្គាល់នៅចុងបញ្ចប់នៃរបាយការណ៍នេះផងដែរ។

2 ទិសាលភាពអគារ



រូបភាព 1 ប្លង់ទីតាំង (ប្រសិនបើមាន) ឬរូបភាពពីផ្កាយរណបសមស្រប



រូបភាព 2 ចំណុចប្រសព្វនៃអគារ និងបរិវេណកាន់កាប់



រូបភាព 3 រូបភាពពីចំហៀង ខាងជើង/ត្បូង/កើត/លិច



រូបភាព 4 រូបភាពពីចំហៀង ខាងជើង/ត្បូង/កើត/លិច



រូបភាព 4 រូបភាពពីចំហៀង ខាងជើង/ត្បូង/កើត/លិច

3 ប្រព័ន្ធគ្រឿងបង្គុំ

ឧទាហរណ៍អំពីគ្រឿងបង្គុំបេតុង



ប្រព័ន្ធកម្រាលខណ្ឌរាបស្មើបេតុងអាមេជាមួយនឹងបន្ទះទម្រ (drop panels) និងធ្នឹមជុំវិញ គ្រឿងបង្គុំដែកនៅទែរ៉ាស

ប្រព័ន្ធទប់លំនឹង៖ គ្រោងម៉ូម៉ង់ (Moment frame)

ទំហំសំណាញ់ដែកធម្មតា៖ 7.5m x 7.5m

កម្រាស់កម្រាលខណ្ឌ៖ មធ្យម 250mm ជាមួយនឹងបន្ទះទម្រ 3.4 x 3.4 x 0.18m នៅតាមសសរ

សសរបេតុងអាមេទូទៅ៖ ទំហំធ្នឹម 530mm x 530mm៖
ធ្នឹមជុំវិញទូទៅ៖ 530w x 650d
ធ្នឹមទូទៅនៅតំណរីករូមមាឌ៖ 530w x 800d

កម្ពស់ទូទៅពីជាន់មួយទៅជាន់មួយ៖ 3.8-

រូបភាព 5 អគារ – ប្រព័ន្ធគ្រឿងបង្គុំ (ជាន់ទូទៅ)

រូបភាព N កម្រាលខណ្ឌរាបស្មើទូទៅដែលមានបន្ទះទម្រ (drop panels)

រូបភាព N គ្រឿងបង្គុំជាន់ទូទៅនៅតំភ្លាប់រវាងផ្នែក ក និងផ្នែក ខ



រូបភាព N គ្រឿងបង្គុំឌុប និងធ្នឹមបញ្ឈរចុះក្រោមនៅតំណារីករូមមាឌ

រូបភាព N សសរឌុបនៅតំណារីករូមមាឌ

រូបភាព N ធុងទឹកនៅសសរជាន់ដំបូល – GL E/7-8. ចំណុះផ្ទុកប្រហាក់ប្រហែល – 24,000 លីត្រ ធុងទឹកស្រដៀងគ្នានៅ GL E/2-3

រូបភាព N ធុងទឹក 10,000 លីត្រនៅ GL 0- 11/D-E

ឧទាហរណ៍អំពីគ្រឿងបង្គុំដែក



គ្រោងចន្លោះ (portal frame) ពីរល្វែង; ល្វែងប្រវែង 24m
ប្រវែងបណ្តោយអគារទាំងមូល៖ 108m

ប្រព័ន្ធទប់លំនឹង៖ គ្រោងម៉ូម៉ង់ (Moment frame) កាត់ទទឹង និងបណ្តុំគ្រោងដំបូល និងមើលពីចំហៀងតាមបណ្តោយដំបូល

ទំហំសំណាញ់ដែក៖ គ្រោងចន្លោះ (Portal frame) នៅ 7.2m កណ្តាលគេ

ទំហំសសរដែក៖
សសរដែកជម្រៅ 250-500 x ទទឹង 180 (កម្រិតបន្ទះដែក 6- 10mm)

ទំហំផ្ទោងដំបូល៖
ធ្នឹមជម្រៅ 350-500 x ទទឹង 180 (កម្រាស់បន្ទះដែក 6- 10mm)

រូបភាព N អគារ 1 – ប្រព័ន្ធគ្រឿងបង្គុំ

រូបភាព N បណ្តុំគ្រោងទូទៅ – ពិតានយោល នៅពេញបរិវេណដូច្នេះមិនអាចមើលឃើញគ្រោងចន្លោះ (portal frames) នោះទេ។ ជញ្ជាំងកំបោរខាងក្រៅសាងសង់យ៉ាងណែននៅខាងក្រៅជើងសសរ

រូបភាព N ព័ត៌មានអំពីសំយ៉ាបដំបូលទូទៅ – អាចមើលឃើញធ្នឹមសំយ៉ាបដំបូល

4 ការអង្កេត

លេខយោង	STR 1
ការអង្កេត៖ សេចក្តីពណ៌នាអំពីការអង្កេតគ្រឿងបង្គុំ 1	
រូបថត	

រូបភាព N សេចក្តីពណ៌នាបន្ថែម ប្រសិនបើចាំបាច់

ឧទាហរណ៍

លេខយោង	**STRUC-1**
ការអង្កេត៖ ភាពកោងនៃជញ្ជាំងកំបោរមិនបានទប់លំនឹងនៅហោជាងខាងជើងនៃអគារ 5-10។ មើលឃើញមានការកោងខ្លាំងចំពោះសសរបេតុងនៅជញ្ជាំងនេះ។	

រូបភាព N ភាពកោងនៃជញ្ជាំងកំបោរដែលមិនបានទប់លំនឹងដោយសសរដែកនៅហោងជាង – កោង c.30-40mm នៅកម្ពស់ពាក់កណ្តាលនៃជញ្ជាំង

រូបភាព N ទិដ្ឋភាពនៃជញ្ជាំងហោជាងខាងជើងដែលឃើញមានការជួសជុល / កែកុនថ្មី។ សសរបេតុងឃើញថាកោង

លេខយោង	**STRUC - n+1**
ការអង្កេត៖ សេចក្តីពណ៌នាអំពីការអង្កេតគ្រឿងបង្គុំ 2	
រូបថត	*រូបថត*
រូបភាព N សេចក្តីពណ៌នាបន្ថែមប្រសិនបើចាំបាច់	រូបភាព N សេចក្តីពណ៌នាបន្ថែមប្រសិនបើចាំបាច់

លេខយោង	**STRUC - n+2**
ការអង្កេត៖ សេចក្តីពណ៌នាអំពីការអង្កេតគ្រឿងបង្គុំ 3	
រូបថត	***រូបថត***
រូបភាព N សេចក្តីពណ៌នាបន្ថែមប្រសិនបើចាំបាច់	រូបភាព N សេចក្តីពណ៌នាបន្ថែមប្រសិនបើចាំបាច់

លេខយោង	**STRUC – n+3**
ការអង្កេត៖ សេចក្តីពណ៌នាអំពីការអង្កេតគ្រឿងបង្គុំ 4	
រូបថត	***រូបថត***

រូបភាព N៖ សេចក្តីពណ៌នាបន្ថែមប្រសិនបើចាំបាច់

លេខយោង	**STRUC – n+4**
ការអង្កេត៖ សេចក្តីពណ៌នាអំពីការអង្កេតគ្រឿងបង្គុំ 5	
រូបថត	***រូបថត***

រូបភាព N៖ សេចក្តីពណ៌នាបន្ថែមប្រសិនបើចាំបាច់

5 វិធានការអាទិភាព

វិធានការនីមួយៗត្រូវបានកំណត់អាទិភាពដូចខាងក្រោម៖

អាទិភាព 1 (SP1) - វិធានការភ្លាមៗ ឧទាហរណ៍ ការជម្លៀសខ្លួនទាំងស្រុង ឬដោយផ្នែក បញ្ឈប់ការសាងសង់ ដកបន្ទុកចេញ -ល- (វិធានការពណ៌ក្រហម លឿងទុំ)

អាទិភាព 2 (SP2) - វិធានការដែលត្រូវអនុវត្តនៅក្នុងរយៈពេល 6 សប្តាហ៍

អាទិភាព 3 (SP3) – វិធានការដែលត្រូវអនុវត្តនៅក្នុងរយៈពេល 6 ខែ។

វិធានការដែលបានណែនាំនីមួយៗរួមបញ្ចូលនូវប្រការពាក់ព័ន្ធដោយយោងតាមបទដ្ឋាន LABS សម្រាប់ប្រទេសកម្ពុជា។

លទ្ធផលរកឃើញ និងការកែតម្រូវបញ្ហាពី FFC ត្រូវបញ្ចូលនៅចំណុចនេះ

6 សេចក្តីសន្ទូបអំពីវិធានការអាទិភាព

CAP អាទិភាព	ការឆ្លើយតប	ប្រភេទបញ្ហា	ផែនការសកម្មភាពរបស់ក្រុមហ៊ុន
SP2	STRUC-1	S7៖ សមត្ថភាពសំណង់ត/សំណង់បន្ថែម	រោងចក្រត្រូវតែងតាំងវិស្វករគ្រឿងបង្គុំឱ្យពិនិត្យមើលលំនឹងជណ្តើរ រួមទាំងតំណរទៅកាន់អគារមានស្រាប់ និងស្នើឡើងនូវវិធានការកែតម្រូវប្រសិនបើចាំបាច់។ សូមមើលប្រការ xxx នៃបទដ្ឋាន LABS។
SP2	STRUC-2	S7៖ សមត្ថភាពសំណង់ត/សំណង់បន្ថែម	រោងចក្រត្រូវតែងតាំងវិស្វករគ្រឿងបង្គុំដើម្បីផលិតប្លង់បន្ទុកសុវត្ថិភាពសម្រាប់ទែរ៉ាសមានស្រាប់ដែលនឹងត្រូវប្រើប្រាស់សម្រាប់ឃ្លាំងដោយពិចារណាទៅលើសមត្ថភាពជាន់ និងសមត្ថភាពសសរ រោងចក្រត្រូវគ្រប់គ្រងបន្ទុកជាន់ឱ្យសកម្ម សូមមើលប្រការ xxx នៃបទដ្ឋាន LABS។
SP2	STRUC-2	S7៖ សមត្ថភាពសំណង់ត/សំណង់បន្ថែម	រោងចក្រត្រូវតែងតាំងវិស្វករគ្រឿងបង្គុំដើម្បីពិនិត្យមើលសមត្ថភាពនៃទែរ៉ាសដំបូលមានស្រាប់ដើម្បីយកមកធ្វើជាបរិវេណឃ្លាំង។ សូមមើលប្រការ xxx នៃបទដ្ឋាន LABS។
SP3	STRUC-1	S7៖ សមត្ថភាពសំណង់ត/សំណង់បន្ថែម	អនុវត្តវិធានការកែតម្រូវ។ សូមមើលប្រការ xxx នៃបទដ្ឋាន LABS។
SP3	STRUC-3	S1៖ សមត្ថភាពសំណង់ត/សំណង់បន្ថែម	រោងចក្រត្រូវតែងតាំងវិស្វករគ្រឿងបង្គុំដើម្បីផលិតប្លង់បន្ទុកសុវត្ថិភាពសម្រាប់ចន្លោះជាន់ទាំងអស់ ដោយពិចារណាទៅលើសមត្ថភាពជាន់ និងសមត្ថភាពសសរ។ រោងចក្រត្រូវតែគ្រប់គ្រងបន្ទុកជាន់ឱ្យបានសកម្ម។ សូមមើលប្រការ xxx នៃបទដ្ឋាន LABS។
SP3	STRUC-4	S6៖ សមត្ថភាពសំណង់ត/សំណង់បន្ថែម	រោងចក្រត្រូវតែងតាំងវិស្វករគ្រឿងបង្គុំដើម្បីពិនិត្យមើលលក្ខណៈវិសាលភាពនៃស្មាមប្រេះ និង monoid តាមការចាំបាច់។ វិធានការកែតម្រូវដែលនឹងត្រូវអនុវត្តរួមមានការទប់ស្កាត់កុំឱ្យទឹកចូល។ សូមមើលប្រការ xxx នៃបទដ្ឋាន LABS។
SP3	STRUC-5	S3៖ សមត្ថភាពសំណង់ត/សំណង់បន្ថែម	រោងចក្រត្រូវតែងតាំងវិស្វករគ្រឿងបង្គុំ ដើម្បីវាយតម្លៃការរចនាសសរសម្រាប់ការប៉ះទង្គិចជាមួយនឹងយានយន្តស្របតាមប្រការ xxx នៃបទដ្ឋាន LABS របាំងការពារសសរសមស្របនឹងត្រូវរចនា និងសាងសង់..
SP3	STRUC-6	S8៖ សមត្ថភាពសំណង់ត/សំណង់បន្ថែម	រោងចក្រត្រូវតែងតាំងវិស្វករគ្រឿងបង្គុំ ដើម្បីរៀបចំគំនូសប្លង់គ្រឿងបង្គុំកែសម្រួលសម្រាប់រោងចក្រ។ សូមមើលប្រការ xxx នៃបទដ្ឋាន LABS។

អាទិភាព CAP	ការឆ្លើយតប	
	SP1	ភ្លាមៗ
	SP2	ក្នុងរយៈពេល 6 សប្តាហ៍
	SP3	ក្នុងរយៈពេល 6 ខែ

ឧទាហរណ៍អំពីខ្លឹមសារដែលបានបង្ហាញនៅក្នុងចំណុចនេះ៖ អាទិភាព CAP គួរតែរៀបចំតាមលំដាប់ពីកម្រិតខ្ពស់បំផុតមកទាបបំផុត។

7 ដែនកំណត់ និងការសន្មត

របាយការណ៍នេះរៀបចំឡើងសម្រាប់ការប្រើប្រាស់ឯកជន និងជារបាយការណ៍សម្ងាត់របស់ LABS ដែលត្រូវបានរៀបចំរួមគ្នាជាមួយ ទីប្រឹក្សាវិជ្ជាជីវៈរបស់ខ្លួនតាមការសមស្រប។ របាយការណ៍នេះមិនត្រូវផលិតឡើងវិញទាំងស្រុង ឬដោយផ្នែកខ្លះ ឬពឹងផ្អែកលើភាគីទីបីសម្រាប់ការប្រើប្រាស់ណាមួយដោយមិនបានទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីក្រុមហ៊ុនវាយតម្លៃឡើយ។ ការវាយតម្លៃត្រូវបានអនុវត្តដើម្បីកំណត់អត្តសញ្ញាណ និងដោះស្រាយបញ្ហាសុវត្ថិភាពអាយុជីវិតសំខាន់ៗ ដោយស្របតាមបទដ្ឋានកែសម្រួលតាមមូលដ្ឋានរបស់គំនិតផ្តួចផ្តើម LABS សម្រាប់រោងចក្រកាត់ដេរសម្លៀកបំពាក់ ស្បែកជើង កាបូប និងផលិតផលធ្វើដំណើរនៅក្នុងប្រទេសកម្ពុជា។

ប្រភេទបន្ទាប់នៃបញ្ហា	ទ្វារច្រកចេញ
លេខយោង	អគ្គិភ័យ-2
សេចក្តីពិស្តារនៃបញ្ហាដែលបានរកឃើញ	ទ្វារច្រកចេញនៅក្នុងអគារ A មិនមែនជាទ្វារបើកចេញទៅចំហៀងម្ខាងបានត្រឹមត្រូវនោះទេ។
អាទិភាព CAP	FP1
វិធានការដែលបានណែនាំ កាលបរិច្ឆេទផុតកំណត់	ថ្ងៃទី14 ខែមីនា ឆ្នាំ2022
បុគ្គលដែលត្រូវទទួលខុសត្រូវ	
វិធានការដែលបានណែនាំ	ផ្លាស់ប្តូរទ្វាច្រកចេញ ដោយប្រើទ្វារបើកទៅចំហៀងម្ខាងដែលអាចបើកបានបែរទៅរកទិសដៅរត់គេចចេញពីអគ្គិភ័យ ស្របតាមស្តង់ដារសុវត្ថិភាពរបស់កម្មវិធីគំនិតផ្តួចផ្តើមស្តីពីសុវត្ថិភាពអាយុជីវិតនិងអគារ (LABS) Cl. 6.1, 6.3 និង 6.9
មតិយោបល់	
រូបភាព	F1.4.2.1_ទ្វាច្រកចេញមិនមែនជាទ្វារបើកទៅជំហៀងម្ខាង F1.4.2.2_ទ្វាច្រកចេញមិនមែនជាទ្វារបើកទៅជំហៀងម្ខាង
F1: មធ្យោបាយរត់គេចពីអគ្គិភ័យ - ជាន់ច្រកចេញ	
ប្រភេទនៃបញ្ហា	F1: មធ្យោបាយរត់គេចពីអគ្គិភ័យ
ប្រភេទនៃបញ្ហាបន្ទាប់	ជាន់ច្រកចេញ
លេខយោង	អគ្គិសនី-4
សេចក្តីពិស្តារនៃបញ្ហាដែលបានរកឃើញ	រយៈចម្ងាយដើរពីជាន់ច្រកចេញទៅកាន់ច្រកចេញផ្សេងទៀតមានចម្ងាយឆ្ងាយហួសពេក នៅក្នុងអគារ B
បុគ្គលដែលត្រូវទទួលខុសត្រូវ	
វិធានការដែលបានណែនាំ	ត្រូវបង្កើតជាន់ច្រកចេញបន្ថែម ដើម្បីធានាឱ្យបានថារយៈចម្ងាយរត់គេចចេញពីអគ្គិភ័យមិនមានចម្ងាយឆ្ងាយហួសពេក ស្របតាមស្តង់ដារសុវត្ថិភាពរបស់កម្មវិធីគំនិតផ្តួចផ្តើមស្តីពីសុវត្ថិភាពអាយុជីវិតនិងអគារ (LABS) Cl 6.7
មតិយោបល់	
រូបភាព	F1.1.4_រយៈចម្ងាយដើរឆ្ពោះទៅកាន់ច្រកចេញមានចម្ងាយឆ្ងាយហួសពេក
F2: ការសាងសង់ប្រព័ន្ធការពារសុវត្ថិភាពអគារពេលមានអគ្គិភ័យ	
ប្រភេទនៃបញ្ហា	F2: ការសាងសង់ប្រព័ន្ធសុវត្ថិភាពអគ្គិភ័យ
ប្រភេទនៃបញ្ហាបន្ទាប់	ប្រព័ន្ធទប់ស្កាត់ការពារភ្លើងអគ្គិភ័យមិនឱ្យឆេះរាលទៅទីកន្លែងឬផ្នែកផ្សេងនៃអគារ
លេខយោង	អគ្គិភ័យ - 5
សេចក្តីពិស្តារនៃបញ្ហាដែលបានរកឃើញ	ការញែកផ្តាច់បន្ទប់ក្នុងអគារចេញពីគ្នាកុំឱ្យភ្លើងឆេះឆាបឆួងពីបន្ទប់មួយទៅបន្ទប់មួយ នៅមិនទាន់រៀបចំបានរួចរាល់នៅឡើយទេ

អាទិភាព CAP	FP2
វិធានការដែលបានណែនាំ កាលបរិច្ឆេទផុតកំណត់	ថ្ងៃទី22 ខែ
បុគ្គលដែលត្រូវទទួលខុសត្រូវ	
វិធានការដែលបានណែនាំ	ត្រូវបំពាក់បន្ទប់ឬទីកន្លែងស្នាក់នៅនីមួយៗនៅក្នុងអគារ ជាមួយនឹងជញ្ជាំងខ័ណ្ឌខ្ទប់ភ្លើងដែលធន់នឹងភ្លើងបានរយៈពេល1ម៉ោង ជាមួយនឹងទ្វាខ័ណ្ឌខ្ទប់ភ្លើងដែលធន់នឹងភ្លើងបានរយៈពេល45នាទីនិងបិទដោយស្វ័យប្រវត្តិ ស្របតាមស្តង់ដារសុវត្ថិភាពរបស់កម្មវិធីគំនិតផ្តួចផ្តើមស្តីពីសុវត្ថិភាពអាយុជីវិតនិងអគារ (LABS) Cl.3.10 និង 3.11
រូបភាព	F2.2.1_កន្លែងស្តុបទុកទំនិញមិនទាន់បានញែកផ្តាច់ពីគ្នា F2.2.2_កន្លែងស្តុបទុកទំនិញមិនទាន់បានញែកផ្តាច់ពីគ្នា
F3: ប្រព័ន្ធការពារសុវត្ថិភាពអាយុជីវិតពេលមានអគ្គិភ័យ - ការតម្លើងអំពូលភ្លើងបំភ្លឺក្នុងគ្រាអាសន្ន	
ប្រភេទនៃបញ្ហា	F3: ប្រព័ន្ធការពារសុវត្ថិភាពអាយុជីវិតពេលមានអគ្គិភ័យ
ប្រភេទនៃបញ្ហាបន្ទាប់	ការតម្លើងអំពូលភ្លើងបំភ្លឺក្នុងគ្រាអាសន្ន
លេខយោង	អគ្គិភ័យ-6
សេចក្តីពិស្តារនៃបញ្ហាដែលបានរកឃើញ	មិនមានថាមពលអគ្គិសនីបម្រុងទុកគ្រប់គ្រាន់ សម្រាប់បើកអំពូលភ្លើងបំភ្លឺក្នុងគ្រាអាសន្ន
អាទិភាព CAP	FP1
វិធានការដែលបានណែនាំ កាលបរិច្ឆេទផុតកំណត់	ថ្ងៃទី14 ខែមីនា ឆ្នាំ2022
បុគ្គលដែលត្រូវទទួលខុសត្រូវ	
វិធានការដែលបានណែនាំ	ត្រូវមានថាមពលអគ្គិសនីបម្រុងទុក សម្រាប់បើកបំភ្លឺភ្លើងសញ្ញាច្រកចេញ និងបើកអំពូលភ្លើងបំភ្លឺក្នុងគ្រាអាសន្ន នៅផ្លូវច្រកចេញ ស្របតាមស្តង់ដារសុវត្ថិភាពរបស់កម្មវិធីគំនិតផ្តួចផ្តើមស្តីពីសុវត្ថិភាពអាយុជីវិតនិងអគារ (LABS) Cl.3.10 និង 3.11Cl.6.8.3
យោបល់	
រូបភាព	F3.3.3_មិនមានថាមពលអគ្គីសនីបម្រុងទុកគ្រប់គ្រាន់ សម្រាប់បើកបំភ្លឺអំពូលភ្លើងបំភ្លឺក្នុងគ្រាអាសន្ន
F3: ប្រព័ន្ធការពារសុវត្ថិភាពអាយុជីវិតពេលមានអគ្គិភ័យ - កណ្តឹងរោទ៍ប្រកាសអាសន្នអំពីអគ្គិភ័យ	
ប្រភេទនៃបញ្ហា	F3: ប្រព័ន្ធការពារសុវត្ថិភាពអាយុជីវិតពេលមានអគ្គិភ័យ
ប្រភេទនៃបញ្ហាបន្ទាប់	កណ្តឹងរោទ៍ប្រកាសអាសន្នអំពីអគ្គិភ័យ
លេខយោង	អគ្គិភ័យ - 7
សេចក្តីពិស្តារនៃបញ្ហាដែលបានរកឃើញ	មិនមានផ្ទាំងបញ្ជាកណ្តឹងរោទ៍ប្រកាសអាសន្នអំពីអគ្គិភ័យ
អាទិភាព CAP	FP1
វិធានការដែលបានណែនាំ កាលបរិច្ឆេទផុតកំណត់	ថ្ងៃទី14 ខែមីនា ឆ្នាំ2022
បុគ្គលដែលត្រូវទទួលខុសត្រូវ	
វិធានការដែលបានណែនាំ	ត្រូវបំពាក់ប្រព័ន្ធកណ្តឹងរោទ៍ប្រកាសអាសន្នអំពីអគ្គិភ័យ ស្របតាមស្តង់ដាររបស់កម្មវិធីគំនិតផ្តួចផ្តើមស្តី

	ពីសុវត្ថិភាពអាយុជីវិតនិងអគារ (LABS) Cl.4.12, 5.2.4 និង 5.9
រូបភាព	
ប្រភេទនៃបញ្ហា	F3: ប្រព័ន្ធការពារសុវត្ថិភាពអាយុជីវិតពេលមានអគ្គិភ័យ
ប្រភេទនៃបញ្ហាបន្ទាប់	កណ្តឹងរោទ៍ប្រកាសអាសន្នអគ្គិភ័យ
លេខយោង	អគ្គិភ័យ - 8
សេចក្តីពិស្តារនៃបញ្ហាដែលបានរកឃើញ	មិនមានឧបករណ៍តាមចាប់សញ្ញាលេចសាយភាយហ្គេស សម្រាប់ធុងស្តុបទុកហ្គេស នៅក្បែរអគារ A
អាទិភាព CAP	FP2
វិធានការដែលបានណែនាំកាលបរិច្ឆេទផុតកំណត់	ថ្ងៃទី22 ខែមេសា ឆ្នាំ2022
បុគ្គលដែលត្រូវទទួលខុសត្រូវ	
វិធានការដែលបានណែនាំ	ត្រូវបំពាក់ឧបករណ៍តាមចាប់សញ្ញានៅគ្រប់ទីកន្លែងដែលបិទជិត ដើម្បីធានាឱ្យបាននូវការអនុលោមតាមស្តង់ដារសុវត្ថិភាពរបស់កម្មវិធីគំនិតផ្តួចផ្តើមស្តីពីសុវត្ថិភាពអាយុជីវិតនិងអគារ (LABS) Cl5.9
មតិយោបល់	
រូបភាព	
F3: ប្រព័ន្ធសុវត្ថិភាពអាយុជីវិតពេលមានអគ្គិភ័យ - ឧបករណ៍ចាប់សញ្ញាអគ្គិភ័យ	
ប្រភេទនៃបញ្ហា	F3: ប្រព័ន្ធការពារសុវត្ថិភាពអាយុជីវិតពេលមានអគ្គិភ័យ
ប្រភេទនៃបញ្ហាបន្ទាប់	ឧបករណ៍ចាប់សញ្ញាអគ្គិភ័យ
លេខយោង	អគ្គិភ័យ - 9
សេចក្តីពិស្តារនៃបញ្ហាដែលបានរកឃើញ	មិនមានអំពូលភ្លើងបំភ្លឺផ្លូវក្នុងគ្រាមានអាសន្នគ្រប់គ្រាន់ សម្រាប់បើកបំភ្លឺផ្លូវច្រករត់គេចចេញពីអគ្គិភ័យ
អាទិភាព CAP	FP2
វិធានការដែលបានណែនាំកាលបរិច្ឆេទផុតកំណត់	ថ្ងៃទី22 ខែមេសា ឆ្នាំ2022
បុគ្គលដែលត្រូវទទួលខុសត្រូវ	
វិធានការដែលបានណែនាំ	ត្រូវបំពាក់អំពូលភ្លើងបំភ្លឺផ្លូវក្នុងគ្រាមានអាសន្ននៅតាមផ្លូវច្រករត់គេចចេញពីអគ្គិភ័យ ស្របតាមស្តង់ដារសុវត្ថិភាពរបស់កម្មវិធីគំនិតផ្តួចផ្តើមស្តីពីសុវត្ថិភាពអាយុជីវិតនិងអគារ (LABS) Cl.6.8
រូបភាព	 
ប្រភេទនៃបញ្ហា	F3: ប្រព័ន្ធការពារសុវត្ថិភាពអាយុជីវិតពេលមានអគ្គិភ័យ
ប្រភេទនៃបញ្ហាបន្ទាប់	ឧបករណ៍ចាប់សញ្ញាអគ្គិភ័យ
លេខយោង	អគ្គិភ័យ - 10

សេចក្តីពិស្តារនៃបញ្ហាដែលបានរកឃើញ	ចំនួនឧបករណ៍ចាប់សញ្ញាអគ្គិភ័យដែលបានតម្លើង មិនបានគ្រប់ដណ្តប់គ្រប់គ្រាន់នៅតាមទីតាំងដែលមាន
អាទិភាព CAP	FP2
វិធានការដែលបានណែនាំ កាលបរិច្ឆេទផុតកំណត់	ថ្ងៃទី22 ខែមេសា ឆ្នាំ2022
បុគ្គលដែលត្រូវទទួលខុសត្រូវ	
វិធានការដែលបានណែនាំ	ត្រូវបំពាក់ប្រព័ន្ធកណ្តឹងរោទ៍ប្រកាសអាសន្នអគ្គិភ័យ ស្របតាមស្តង់ដាសុវត្ថិភាពរបស់កម្មវិធីគំនិតផ្តួចផ្តើមស្តីពីសុវត្ថិភាពអាយុជីវិតនិងអគារ (LABS) Cl.5.9
មតិយោបល់	
រូបភាព	F3.1.2.1. _មិនមានឧបករណ៍ចាប់យកសញ្ញាផ្សែងឆេះអគ្គិភ័យគ្រប់គ្រាន់ F3.1.2.2. _មិនមានឧបករណ៍ចាប់យកសញ្ញាផ្សែងឆេះអគ្គិភ័យគ្រប់គ្រាន់
F4: ការបំពាក់នូវឧបករណ៍ពន្លត់អគ្គិភ័យ - ការប្រើប្រាស់	
ប្រភេទនៃបញ្ហា	F4: ការបំពាក់នូវឧបករណ៍ពន្លត់អគ្គិភ័យ
ប្រភេទនៃបញ្ហាបន្ទាប់	ការប្រើប្រាស់
លេខយោង	អគ្គិភ័យ -11
សេចក្តីពិស្តារនៃបញ្ហាដែលបានរកឃើញ	មិនមានប្រព័ន្ធក្បាលបាញ់ទឹកស្រោច សម្រាប់ពន្លត់អគ្គិភ័យនៅឃ្លាំងស្តុបទុកទំនិញ និងកន្លែងស្តុបទុកទំនិញ
អាទិភាព CAP	FP3
វិធានការដែលបានណែនាំ កាលបរិច្ឆេទផុតកំណត់	ថ្ងៃទី07 ខែកញ្ញា ឆ្នាំ2022
បុគ្គលដែលត្រូវទទួលខុសត្រូវ	
វិធានការដែលបានណែនាំ	ត្រូវបំពាក់ប្រព័ន្ធក្បាលបាញ់ទឹកស្រោចពន្លត់អគ្គិភ័យដែលស្របតាមស្តង់ដារសុវត្ថិភាពរបស់កម្មវិធីគំនិតផ្តួចផ្តើមស្តីពីសុវត្ថិភាពអាយុជីវិតនិងអគារ (LABS) Cl.5.3.2.2
មតិយោបល់	
រូបភាព	F4.3.2.1. _មិនមានប្រព័ន្ធក្បាលបាញ់ទឹកស្រោចពន្លត់អគ្គិភ័យ F4.3.2.2. _មិនមានប្រព័ន្ធក្បាលបាញ់ទឹកស្រោចពន្លត់អគ្គិភ័យ
ប្រភេទនៃបញ្ហា	F4: ការបំពាក់នូវឧបករណ៍ពន្លត់អគ្គិភ័យ
ប្រភេទនៃបញ្ហាបន្ទាប់	ការប្រើប្រាស់
លេខយោង	អគ្គិភ័យ -12
សេចក្តីពិស្តារនៃបញ្ហាដែលបានរកឃើញ	ឡានទឹកពន្លត់អគ្គិភ័យមិនអាចចូលទៅដល់គ្រប់ចំហៀងឬជ្រុងនៃអាគារបាន
អាទិភាព CAP	FP3
វិធានការដែលបានណែនាំ កាលបរិច្ឆេទផុតកំណត់	ថ្ងៃទី07 ខែកញ្ញា ឆ្នាំ2022
បុគ្គលដែលត្រូវទទួលខុសត្រូវ	
វិធានការដែលបានណែនាំ	ត្រូវមានផ្លូវចូលសម្រាប់ឡានទឹកពន្លត់អគ្គិភ័យចូលទៅបាញ់ពន្លត់ភ្លើងបាន ស្របតាមស្តង់ដាសុវត្ថិភាព

	របស់កម្មវិធីគំនិតផ្តួចផ្តើមស្តីពីសុវត្ថិភាពអាយុជីវិតនិងអគារ (LABS) Cl.5.12
មតិយោបល់	
រូបភាព	F4.4.3.1. _មិនមានផ្លូវចូលសម្រាប់ឡានទឹកពន្លត់អគ្គិភ័យចូលទៅបាញ់ពន្លត់ភ្លើងបាន F4.4.3.2. _មិនមានផ្លូវចូលសម្រាប់ឡានទឹកពន្លត់អគ្គិភ័យចូលទៅបាញ់ពន្លត់ភ្លើងបាន
F4: ការបំពាក់ឧបករណ៍ពន្លត់អគ្គិភ័យ - ប្រព័ន្ធពន្លត់អគ្គិភ័យ	
ប្រភេទនៃបញ្ហា	F4: ការបំពាក់នូវឧបករណ៍ពន្លត់អគ្គិភ័យ
ប្រភេទនៃបញ្ហាបន្ទាប់	ប្រព័ន្ធពន្លត់អគ្គិភ័យ
លេខយោង	អគ្គិភ័យ -13
សេចក្តីពិស្តារនៃបញ្ហាដែលបានរកឃើញ	បំពង់បាញ់ពន្លត់អគ្គិភ័យកាន់នឹងដៃបាន មិនធ្លាប់បានត្រួតពិនិត្យ (បន្ទប់ស្នាក់នៅរបស់កម្មករ)
អាទិភាព CAP	FP3
វិធានការដែលបានណែនាំកាលបរិច្ឆេទផុតកំណត់	ថ្ងៃទី07 ខែកញ្ញា ឆ្នាំ2022
បុគ្គលដែលត្រូវទទួលខុសត្រូវ	
វិធានការដែលបានណែនាំ	ត្រូវធ្វើការត្រួតពិនិត្យថែទាំបំពង់បាញ់ពន្លត់អគ្គិភ័យទាំងអស់ឱ្យបានទៀងទាត់ និងត្រូវធានាឱ្យបានថារាល់ការត្រួតពិនិត្យត្រូវបានកត់ត្រាទុកបានសមរម្យ ស្របតាមស្តង់ដារសុវត្ថិភាពរបស់កម្មវិធីគំនិតផ្តួចផ្តើមស្តីពីសុវត្ថិភាពអាយុជីវិតនិងអគារ (LABS) Cl.5.8
មតិយោបល់	
រូបភាព	F4.2.8.1 _បំពង់បាញ់ពន្លត់អគ្គិភ័យមិនធ្លាប់បានត្រួតពិនិត្យទេ F4.2.8.2 _បំពង់បាញ់ពន្លត់អគ្គិភ័យមិនធ្លាប់បានត្រួតពិនិត្យទេ
F4: ការបំពាក់ឧបករណ៍ពន្លត់អគ្គិភ័យ - ការផ្គត់ផ្គង់ទឹក	
ប្រភេទនៃបញ្ហា	F4: ការបំពាក់នូវឧបករណ៍ពន្លត់អគ្គិភ័យ
ប្រភេទនៃបញ្ហាបន្ទាប់	ការផ្គត់ផ្គង់ទឹក
លេខយោង	អគ្គិភ័យ -14
សេចក្តីពិស្តារនៃបញ្ហាដែលបានរកឃើញ	មិនមានក្បាលម៉ាស៊ីនបូមទឹកសម្រាប់ពន្លត់អគ្គិភ័យ
អាទិភាព CAP	FP2
វិធានការដែលបានណែនាំកាលបរិច្ឆេទផុតកំណត់	ថ្ងៃទី22 ខែមេសា ឆ្នាំ2022
បុគ្គលដែលត្រូវទទួលខុសត្រូវ	
វិធានការដែលបានណែនាំ	ត្រូវបំពាក់ប្រព័ន្ធក្បាលម៉ាស៊ីនបូមទឹកសម្រាប់ពន្លត់អគ្គិភ័យ ដោយមានបំពង់បង្ហូរទឹកគ្រប់គ្រាន់ ដើម្បីធានាឱ្យបានថាក្បាលម៉ាស៊ីនបូមទឹកសម្រាប់ពន្លត់អគ្គិភ័យបានគ្របដណ្តប់នៅគ្រប់ទីកន្លែងនៃបរិវេណអគា ស្របតាមស្តង់ដារសុវត្ថិភាពរបស់កម្មវិធីគំនិតផ្តួចផ្តើមស្តីពីសុវត្ថិភាពអាយុជីវិតនិងអគារ (LABS) Cl.5.6 និង 5.7
មតិយោបល់	
រូបភាព	

	F4.2.1.1 _មិនមានក្បាលម៉ាស៊ីនបូមទឹកសម្រាប់ពន្លត់អគ្គិភ័យ	F4.2.1.2 _មិនមានក្បាលម៉ាស៊ីនបូមទឹកសម្រាប់ពន្លត់អគ្គិភ័យ
F5: ការថែទាំ និងការគ្រប់គ្រងអគារ - ផែនការជួយសង្គ្រោះក្នុងគ្រាមានអាសន្ន		
ប្រភេទនៃបញ្ហា	F5: ការថែទាំ និងការគ្រប់គ្រងអគារ	
ប្រភេទនៃបញ្ហាបន្ទាប់	ផែនការជួយសង្គ្រោះក្នុងគ្រាមានអាសន្ន	
លេខយោង	អគ្គិភ័យ -15	
សេចក្តីពិស្តារនៃបញ្ហាដែលបានរកឃើញ	មិនមានផែនការជួយសង្គ្រោះក្នុងគ្រាមានអាសន្នគ្រប់គ្រាន់	
អាទិភាព CAP	FP3	
វិធានការដែលបានណែនាំ កាលបរិច្ឆេទផុតកំណត់	ថ្ងៃទី07 ខែកញ្ញា ឆ្នាំ2022	
បុគ្គលដែលត្រូវទទួលខុសត្រូវ		
វិធានការដែលបានណែនាំ	ត្រូវបង្កើត ធ្វើបច្ចុប្បន្នភាព និងចងក្រង ផែនការជួយសង្គ្រោះក្នុងគ្រាអាសន្ន សម្រាប់ធ្វើការត្រួតពិនិត្យស្របតាមស្តង់ដារសុវត្ថិភាពរបស់កម្មវិធីគំនិតផ្តួចផ្តើមស្តីពីសុវត្ថិភាពអាយុជីវិតនិងអគារ (LABS) Cl.12.1 និង 12.3	
មតិយោបល់		
រូបភាព	F5.3.1.1 _មិនមានប្លង់ជួយសង្គ្រោះក្នុងគ្រាអាសន្នឡើយ	F5.3.1.2 _មិនមានប្លង់ជួយសង្គ្រោះក្នុងគ្រាអាសន្នឡើយ
F5: ការថែទាំ និងការគ្រប់គ្រងអគារ - ការគ្រប់គ្រងអគារ		
ប្រភេទនៃបញ្ហា	F5: ការថែទាំ និងការគ្រប់គ្រងអគារ	
ប្រភេទនៃបញ្ហាបន្ទាប់	ការគ្រប់គ្រងអាគារ	
លេខយោង	អគ្គិភ័យ -16	
សេចក្តីពិស្តារនៃបញ្ហាដែលបានរកឃើញ	ស្តុបទុកធុងហ្គេសនៅក្នុងអគារ B លើចំណុះ	
អាទិភាព CAP	FP2	
វិធានការដែលបានណែនាំ កាលបរិច្ឆេទផុតកំណត់	ថ្ងៃទី22 ខែមេសា ឆ្នាំ2022	
បុគ្គលដែលត្រូវទទួលខុសត្រូវ		
វិធានការដែលបានណែនាំ	ស្របតាមស្តង់ដារសុវត្ថិភាពរបស់កម្មវិធីគំនិតផ្តួចផ្តើមស្តីពីសុវត្ថិភាពអាយុជីវិតនិងអគារ (LABS) Cl.3.11.6.4 បរិមាណអតិបរមានៃឧស្ម័នហ្គេស LPG ដែលអនុញ្ញាតឱ្យរក្សាទុកនៅក្នុងកន្លែងគ្រប់គ្រងនីមួយៗ មិនគួរលើពី 400គីឡូឡើយ	
មតិយោបល់		
រូបភាព	F5.2.4.1 _ការស្តុបទុកធុងហ្គេសនៅក្នុងអគារ B លើសចំណុះ	

3. សេចក្តីសង្ខេបនៃសកម្មភាពអាទិភាព

អាទិភាព CAP	ការឆ្លើយតប	ប្រភេទនៃបញ្ហា	ផែនការសកម្មភាពរបស់ក្រុមហ៊ុន
FP1	អគ្គិភ័យ-01	F1: ធម្មោបាយរត់គេចពីអគ្គិភ័យ	យោងតាមស្តង់ដារសុវត្ថិភាពរបស់កម្មវិធីគំនិតផ្តួចផ្តើមស្តីពីសុវត្ថិភាពអាយុជីវិតនិងអគារ (LABS) Cl.6.3 ត្រូវធានាឱ្យបានថា ផ្លូវច្រកចេញមិនមានវត្ថុរាវាំង និងការស្តុបទុកទំនិញជាបណ្តោះអាសន្នណាមួយឡើយ
FP1	អគ្គិភ័យ-02	F1: ធម្មោបាយរត់គេចពីអគ្គិភ័យ	យោងតាមស្តង់ដារសុវត្ថិភាពរបស់កម្មវិធីគំនិតផ្តួចផ្តើមស្តីពីសុវត្ថិភាពអាយុជីវិតនិងអគារ (LABS) Cl. 6.1, 6.3 និង 6.9 ត្រូវប្តូរទ្វារច្រកចេញ ដោយប្រើទ្វារបើកទៅចំហៀងម្ខាងដែលអាចបើកបែរទៅរកទិសរត់គេចចេញពីអគ្គិភ័យ
FP1	អគ្គិភ័យ-03	F1: ធម្មោបាយរត់គេចពីអគ្គិភ័យ	យោងតាមស្តង់ដារសុវត្ថិភាពរបស់កម្មវិធីគំនិតផ្តួចផ្តើមស្តីពីសុវត្ថិភាពអាយុជីវិតនិងអគារ (LABS) Cl.6.1 និង 6.9 ត្រូវជំនួសការប្រើសោរចាក់ពីខាងក្រៅ ដោយប្រើឧបករណ៍ចាក់បិទខ្ជប់ទ្វាដែលងាយស្រួលបើកចេញពីខាងក្នុងដោយមិនចាំបាច់ប្រើកូនសោរ
FP1	អគ្គិភ័យ-6	F3: ប្រព័ន្ធការពារសុវត្ថិភាពអាយុជីវិតពេលមានអគ្គិភ័យ	ត្រូវមានថាមពលអគ្គិសនីបម្រុងទុក សម្រាប់បើកបំភ្លឺភ្លើងសញ្ញាផ្លូវច្រកចេញនិងអំពូលភ្លើងបំភ្លឺក្នុងគ្រាអាសន្ន នៅផ្លូវច្រកចេញ ស្របតាមស្តង់ដារសុវត្ថិភាពរបស់កម្មវិធីគំនិតផ្តួចផ្តើមស្តីពីសុវត្ថិភាពអាយុជីវិតនិងអគារ (LABS) Cl.6.8.3
FP1	អគ្គិភ័យ-7	F3: ប្រព័ន្ធការពារសុវត្ថិភាពអាយុជីវិតពេលមានអគ្គិភ័យ	ត្រូវបំពាក់ប្រព័ន្ធកណ្តឹងរោទ៍ប្រកាសអាសន្នអគ្គិភ័យ ស្របតាមស្តង់ដាសុវត្ថិភាពរបស់កម្មវិធីគំនិតផ្តួចផ្តើមស្តីពីសុវត្ថិភាពអាយុជីវិតនិងអគារ (LABS) Cl.4.12, 5.2.4 និង 5.9
FP2	អគ្គិភ័យ-04	F1: ធម្មោបាយរត់គេចពីអគ្គិភ័យ	ត្រូវបង្កើតជាន់ច្រករត់គេចចេញពីអគ្គិភ័យបន្ថែម ដើម្បីធានាឱ្យបានថារយៈចម្ងាយរត់គេចចេញពីអគ្គិភ័យមិនមានចម្ងាយឆ្ងាយហួសពេក ស្របតាមស្តង់ដារសុវត្ថិភាពរបស់កម្មវិធីគំនិតផ្តួចផ្តើមស្តីពីសុវត្ថិភាពអាយុជីវិតនិងអគារ (LABS) Cl 6.7

FP2	អគ្គិភ័យ-5	F2: ការសាងសង ប្រព័ន្ធការពារសុវត្ថិភាពអគារពេលមានអគ្គិភ័យ	យោងតាមស្តង់ដារសុវត្ថិភាពរបស់កម្មវិធីគំនិតផ្តួចផ្តើមស្តីពីសុវត្ថិភាពអាយុជីវិតនិងអគារ (LABS) Cl.3.10 និង 3.11 ត្រូវបំពាក់បន្ទប់ឬទីកន្លែងស្នាក់នៅនីមួយៗនៅក្នុងអគារ ជាមួយនឹងជញ្ជាំងខ័ណ្ឌខ្ទប់ភ្លើងដែលធន់នឹងភ្លើងបានរយៈពេល1ម៉ោង ជាមួយនឹងទ្វាខ័ណ្ឌខ្ទប់ភ្លើយដែលធន់នឹងភ្លើងបានរយៈពេល45 នាទីនិងបិទដោយស្វ័យប្រវត្តិ

FP2	អគ្គិភ័យ-08	F3: ប្រព័ន្ធការពារសុវត្ថិភាពអាយុជីវិតពេលមានអគ្គិភ័យ	ត្រូវបំពាក់ឧបករណ៍តាមចាប់សញ្ញានៅគ្រប់ទីកន្លែងដែលបិទជិត ដើម្បីធានាឱ្យបាននូវការអនុលោមតាមស្តង់ដារសុវត្ថិភាពរបស់កម្មវិធីគំនិតផ្តួចផ្តើមស្តីពីសុវត្ថិភាពអាយុជីវិតនិងអគារ (LABS) Cl 5.9
FP2	អគ្គិភ័យ-09	F3: ប្រព័ន្ធការពារសុវត្ថិភាពអាយុជីវិតពេលមានអគ្គិភ័យ	ត្រូវបំពាក់អំពូលភ្លើងបំភ្លឺផ្លូវក្នុងគ្រាអាសន្ន នៅតាមគ្រប់ផ្លូវច្រករត់គេចចេញពីអគ្គិភ័យទាំងអស់ ស្របតាមស្តង់ដារសុវត្ថិភាពរបស់កម្មវិធីគំនិតផ្តួចផ្តើមស្តីពីសុវត្ថិភាពអាយុជីវិតនិងអគារ (LABS) Cl.6.8
FP2	អគ្គិភ័យ-10	F4: ប្រព័ន្ធសុវត្ថិភាពអគ្គិភ័យ	ផ្តល់ប្រព័ន្ធសុវត្ថិភាពផ្តល់សញ្ញាគ្រោះអគ្គិភ័យ ដើម្បីអនុលោមតាមប្រការ 5.9 នៃស្តង់ដារ LABS
FP2	អគ្គិភ័យ-14	F4: ការបំពាក់នូវឧបករណ៍ពន្លត់អគ្គិភ័យ	ត្រូវបំពាក់ប្រព័ន្ធក្បាលម៉ាស៊ីនបូមទឹកសម្រាប់ពន្លត់អគ្គិភ័យដោយមានបំពង់បង្ហូរទឹកគ្រប់គ្រាន់ ដើម្បីធានាឱ្យបានថាក្បាលម៉ាស៊ីនបូមទឹកសម្រាប់ពន្លត់អគ្គិភ័យបានគ្របដណ្តប់នៅគ្រប់ទីកន្លែងនៃបរិវេណអគារ ស្របតាមស្តង់ដារសុវត្ថិភាពរបស់កម្មវិធីគំនិតផ្តួចផ្តើមស្តីពីសុវត្ថិភាពអាយុជីវិតនិងអគារ (LABS) Cl.5.6 និង 5.7
FP2	អគ្គិភ័យ_16	F5: ការថែទាំ និងការគ្រប់គ្រងអគារ	ស្របតាមស្តង់ដារសុវត្ថិភាពរបស់កម្មវិធីគំនិតផ្តួចផ្តើមស្តីពីសុវត្ថិភាពអាយុជីវិតនិងអគារ (LABS) Cl.3.11.6.4 បរិមាណអតិបរមានៃឧស្ម័នហ្គេស LPG ដែលអនុញ្ញាតឱ្យរក្សាទុកនៅក្នុងកន្លែងគ្រប់គ្រងនីមួយៗ មិនគួរលើពី 400គីឡូឡើយ
FP3	អគ្គិភ័យ-11	F4: ការបំពាក់នូវឧបករណ៍ពន្លត់អគ្គិភ័យ	ត្រូវបំពាក់ប្រព័ន្ធក្បាលបាញ់ទឹកស្រោចពន្លត់អគ្គិភ័យដែលស្របតាមស្តង់ដារសុវត្ថិភាពរបស់កម្មវិធីគំនិតផ្តួចផ្តើមស្តីពីសុវត្ថិភាពអាយុជីវិតនិងអគារ (LABS) Cl.5.3.2.2
FP3	អគ្គិភ័យ-12	F4: ការបំពាក់នូវឧបករណ៍ពន្លត់អគ្គិភ័យ	ត្រូវមានផ្លូវចូលសម្រាប់ឡានទឹកពន្លត់អគ្គិភ័យចូលទៅបាញ់ពន្លត់ភ្លើងបាន ស្របតាមស្តង់ដារសុវត្ថិភាពរបស់កម្មវិធីគំនិតផ្តួចផ្តើមស្តីពីសុវត្ថិភាពអាយុជីវិតនិងអគារ (LABS) Cl.5.12
FP3	អគ្គិភ័យ-13	F4: ការបំពាក់នូវឧបករណ៍ពន្លត់អគ្គិភ័យ	ត្រូវធ្វើការត្រួតពិនិត្យថែទាំបំពង់បាញ់ពន្លត់អគ្គិភ័យទាំងអស់ឱ្យបានទៀងទាត់ និងត្រូវធានាឱ្យបានថារាល់ការត្រួតពិនិត្យត្រូវបានកត់ត្រាទុកបានសមរម្យ ស្របតាមស្តង់ដារសុវត្ថិភាពមន្ទីរពិសោធន៍ Cl.5.8
FP3	អគ្គិភ័យ-15	F5: ការថែទាំ និងការគ្រប់គ្រងអគារ	ត្រូវបង្កើត ធ្វើបច្ចុប្បន្នភាព និងចងក្រង ផែនការជួយសង្គ្រោះក្នុងគ្រាមានអាសន្ន សម្រាប់ធ្វើការត្រួតពិនិត្យ ស្របតាមស្តង់ដារសុវត្ថិភាពរបស់កម្មវិធីគំនិតផ្តួចផ្តើមស្តីពីសុវត្ថិភាពអាយុជីវិតនិងអគារ (LABS) Cl.12.1 និង 12.3
អាទិភាព CAP	FP1	វិធានការបន្ទាន់	

	FP2	សម្រាប់រយៈពេល6 សប្តាហ៍	
	FP3	សម្រាប់រយៈពេល 6 ខែ	

3.ការសន្និដ្ឋាន និងដែនកំណត់

របាយការណ៍នេះគឺសម្រាប់ការប្រើប្រាស់ជាឯកជននិងជាការសម្ងាត់របស់កម្មវិធីគំនិតផ្តួចផ្តើមស្តីពីសុវត្ថិភាពអាយុជីវិតនិងអគារ (LABS) សម្រាប់អ្នកដែលរបាយការណ៍នេះត្រូវបានរៀបចំជូន រួមទាំងសម្រាប់អ្នកទីប្រឹក្សាប្រកបដោយវិជ្ជាជីវៈរបស់ LABS ទាំងនោះយកទៅប្រើប្រាស់តាមការគួរផងដែរ។ ភាគីទីបីមិនអាចប្រើប្រាស់ ឬថតចម្លងរបាយការណ៍នេះទាំងមូលឬដោយផ្នែកណាមួយ សម្រាប់យកទៅប្រើប្រាស់ក្នុងគោលបំណងណាមួយ ដោយមិនមានការយល់ព្រមជាលាយលក្ខណ៍អក្សរពី ក្រុមហ៊ុន ARCHETYPE បានឡើយ។

ការវាយតម្លៃនេះត្រូវបានធ្វើឡើងដើម្បីស្វែងរក និងដោះស្រាយបញ្ហាសុវត្ថិភាពអាយុជីវិតដ៏សំខាន់នៅក្នុងរោងចក្រ ដោយអនុលោមតាមស្តង់ដារកម្រិតតំបន់របស់កម្មវិធីគំនិតផ្តួចផ្តើមស្តីពីសុវត្ថិភាពអាយុជីវិតនិងអគារ (LABS) ពាក់ព័ន្ធនឹងសុវត្ថិភាពកម្មករនៅក្នុងរោងចក្រគ្រឿងបន្លាស់និងគ្រឿងតុបតែង កាបូប ស្បែកជើង សម្លៀកបំពាក់ និងវាយនភ័ណ្ឌ នៅកម្ពុជា។

របាយការណ៍នេះអាចយកទៅប្រើប្រាស់ក្នុងការពិភាក្សាជាមួយអ្នកផ្គត់ផ្គង់ឬម្ចាស់រោងចក្រ សម្រាប់ធ្វើជាមធ្យោបាយក្នុងការកែលម្អឬដោះស្រាយរាល់បញ្ហាដែលបានអង្កេតរកឃើញ។ របាយការណ៍នេះមិនគ្រប់ជ្រុងជ្រោយនោះទេ និងគ្រប់ដណ្តប់ទៅលើអ្វីដែលអាចអង្កេតរកឃើញនៅអំឡុងពេលចុះទៅធ្វើអធិការកិច្ចឬត្រួតពិនិត្យអគារដោយផ្ទាល់ភ្នែក។

របាយការណ៍នេះមិនមានបំណងចង់ឱ្យគេចាត់ទុកថាជាការធ្វើអធិការកិច្ចទូទៅមួយនោះទេ និងមិនបានគ្របដណ្តប់ទៅលើចំណុចអាក្រក់នៃវិធានការសាងសង់ប្រព័ន្ធការពារសុវត្ថិភាពអគារពេលមានអគ្គិភ័យ ឬប្រព័ន្ធការពារសុវត្ថិភាពអាយុជីវិតពេលមានអគ្គិភ័យ ដែលបណ្តាលមកពីកង្វះខាតនៃការថែទាំនោះទេ។ ចំណុចផ្សេងៗទៀតនៃអគារ ដែលមិនប៉ះពាល់ដល់សុវត្ថិភាពអាយុជីវិតរបស់អ្នកនៅក្នុងអគារពោងចក្រ មិនត្រូវបានធ្វើការវាយតម្លៃនៅក្នុងការអង្កេតត្រួតពិនិត្យនេះទេ។

ក្រៅពីអ្វីដែលបានកត់សម្គាល់ នៅមានផ្នែកសេវាកម្មផ្សេងទៀតដែលមិនត្រូវបានត្រួតពិនិត្យឬធ្វើតេស្តនៅក្នុងអំឡុងពេលនៃការធ្វើអធិការកិច្ចរបស់យើងខ្ញុំ ដូច្នេះផ្នែកសេវាកម្មនោះមិនត្រូវបានដាក់បញ្ចូលនៅក្នុងរបាយការណ៍នេះឡើយ។ យើងខ្ញុំមិនបានធ្វើអធិការកិច្ចត្រួតពិនិត្យមើលផ្នែកមួយចំនួននៃអគារ ដែលត្រូវបានលាក់បាំង ចាត់ទុកជាកន្លែងសម្ងាត់ ឬហាមឃាត់មិនឱ្យចូលឡើយ ដូច្នេះយើងខ្ញុំមិនអាចធ្វើការរាយការណ៍ថាផ្នែកទាំងនោះនៃអគារគឺមិនមានចំណុចខ្វះចន្លោះឬចំណុចអាក្រក់ បានឡើយ។

មិនមានការបើកចំហរអនុញ្ញាតឱ្យយើងខ្ញុំចូលទៅធ្វើការត្រួតពិនិត្យមើលផ្នែកនៃអគារដែលបានហាមឃាត់ទាំងនោះឡើយ (ក្រៅពីអ្វីដែលបានកត់សម្គាល់) ហើយយើងខ្ញុំបានពឹងផ្អែកទាំងស្រុងលើរូបភាពដែលវិស្វករនិងស្ថាបត្យករប្រគល់ជូនមកយើងខ្ញុំ សម្រាប់ធ្វើការត្រួតពិនិត្យមើលផ្នែកនៃអគារដែលត្រូវបានលាក់បាំងទាំងនោះ។ ការធ្វើតេស្តពិនិត្យមើលប្រព័ន្ធការពារសុវត្ថិភាពអាយុជីវិតពេលមានអគ្គិភ័យ មិនមែនជាផ្នែកមួយនៃការធ្វើអធិការកិច្ចទាំងនេះនោះទេ ហើយយើងខ្ញុំសូមណែនាំឱ្យម្ចាស់រោងចក្រ និងវិស្វករសាងសង់អគារនេះធ្វើតេស្តត្រួតពិនិត្យនិងធ្វើការថែទាំប្រព័ន្ធទាំងនេះតាមស្តង់ដារ ដើម្បីបំពេញតម្រូវការរបស់ពួកគេក្នុងការធានាឱ្យបាននូវដំណើរការល្អត្រឹមត្រូវរបស់រោងចក្រពួកគេ។

ការណែនាំទៅលើចំណុចដែលបានគូសបញ្ជាក់គឺសម្រាប់តែក្នុងគោលបំណងផ្តល់នូវដំបូន្មានចង្អុលបង្ហាញតែប៉ុណ្ណោះ មិនពាក់ព័ន្ធទាល់តែសោះនឹងការស្វែងរកចំណុចខ្វះចន្លោះជាក់លាក់និងសំខាន់ណាមួយរបស់ហេដ្ឋរចនាសម្ព័ន្ធអាគារ ដូចដែលបានធ្វើការកត់សម្គាល់នៅក្នុងការពន្យល់បង្ហាញនេះឡើយ និងមិនមែនជាការលក្ខខ័ណ្ឌការងារដែលតម្រូវឱ្យធ្វើឡើយ។យើងខ្ញុំមិនទទួលខុសត្រូវលើការងារដែលបានធ្វើរួចហើយនោះទេ។

របាយការណ៍នេះមិនជ្រៀតជ្រែកដល់ ការទទួលខុសត្រូវរបស់វិស្វករសាងសង់អគារ រោងចក្រនិងម្ចាស់រោងចក្រ ចំពោះដំណើរការប្រព័ន្ធការពារសុវត្ថិភាពអគ្គិភ័យរបស់អគាររោងចក្រនេះឡើយ។ វិស្វករសាងសង់អគារនេះ នៅតែទទួលខុសត្រូវទាំងស្រុងចំពោះគុណភាពប្រព័ន្ធការពារសុវត្ថិភាពអគ្គិភ័យរបស់អគារនេះ។

រាល់ព័ត៌មាននៅក្នុងរបាយការណ៍ស្តីពីការធ្វើអធិការកិច្ចត្រួតពិនិត្យប្រព័ន្ធការពារសុវត្ថិភាពអគ្គិភ័យ ត្រូវបានប្រមូលបាននៅក្នុងអំឡុងពេលចុះធ្វើទស្សនកិច្ចសិក្សាក្នុងរយៈពេលមួយថ្ងៃនៅទីតាំងរោងចក្រផ្ទាល់ ដែលជាកន្លែងដែលយើងខ្ញុំបានធ្វើការសម្ភាសជាមួយអ្នកគ្រប់គ្រងរោងចក្រនៅតាមតំបន់ និងបានធ្វើការត្រួតពិនិត្យប្លង់អាគាររោងចក្រនិងឯកសារបើកចំហរ ដែលត្រូវបានប្រគល់ជូនឱ្យយើងខ្ញុំ នៅក្នុងកិច្ចប្រជុំនោះ។ យើងខ្ញុំមិនមានលទ្ធភាពធ្វើការផ្ទៀងផ្ទាត់ដោយឯករាជ្យចំពោះរាល់គ្រប់ព័ត៌មាននិងទិន្នន័យដែលប្រមូលបានទាំងអស់នោះទេ ដូច្នេះក្រុមហ៊ុន ARCHETYPE យើងខ្ញុំមិន

អាចទទួលយកការទទួលខុសត្រូវទូទៅចំពោះភាពខ្វះចន្លោះឬកំហុសខុសឆ្គង នៅក្នុងរបាយការណ៍នេះ ដែលកើតចេញពីភាពមិនត្រឹមត្រូវនៃព័ត៌មានដែលប្រមូលបាន។

លទ្ធផលនៃការអង្កេតស្រាវជ្រាវនិងការណែនាំនៅក្នុងរបាយការណ៍នេះមិនមានបំណងធ្វើការបញ្ជាក់ ធានា ឬអះអាងអំពីការអនុលោមតាមច្បាប់ជាតិ ឬបទប្បញ្ញត្តិរដ្ឋាភិបាលឡើយ។ ការចុះធ្វើអធិការកិច្ចនៅទីតាំងរោងចក្រ និងការសរសេរចងក្រងរបាយការណ៍នេះជាការអនុវត្តស្រដៀងទៅនឹង ការធ្វើអធិការកិច្ចនិងការត្រួតពិនិត្យប្លង់អគាររោចក្រដោយអាជ្ញាធរមានសមត្ថកិច្ចដែលជាផ្នែកមួយនៃដំណើរការអនុវត្តច្បាប់ដែលមានជាធរមាន។

លើសពីនេះទៅទៀត លទ្ធផលនៃការអង្កេតស្រាវជ្រាវនេះ មិនបានបញ្ជាក់ដោយប្រការណាមួយថាការអនុលោមតាមលទ្ធផលនៃការអង្កេតស្រាវជ្រាវឬការណែនាំនៅក្នុងរបាយការណ៍នេះនឹងអាចជួយលុបបំបាត់រាល់គ្រោះថ្នាក់ ហានិភ័យ ឬការប្រឈមនានា ឬក៏បានបញ្ជាក់ថាគ្រោះថ្នាក់ ហានិភ័យ ឬការប្រឈមនានាដែលមិនបានរំលេចនៅក្នុងរបាយការណ៍នេះនឹងមិនអាចកើតមានឡើងនោះទេ។

ការអនុវត្តតាមការណែនាំនៅក្នុងរបាយការណ៍នេះ មិនបានធ្វើឱ្យម្ចាស់រោងចក្ររួចផុតពីកាតព្វកិច្ចក្នុងការគោរពឬអនុលោមតាមលក្ខខ័ណ្ឌកំណត់របស់គម្រោង ស្តង់ដារឧស្សាហកម្ម ឬខដែលមានចែងនៅក្នុងបទបញ្ញត្តិរបស់រដ្ឋបាលមូលដ្ឋានឡើយ។

សេចក្តីអះអាងធ្វើការបដិសេធទទួលខុសត្រូវ របស់កម្មវិធីគំនិតផ្តួចផ្តើមស្តីពីសុវត្ថិភាពអាយុជីវិតនិងអគារ (LABS)

របាយការណ៍នេះគឺជាលទ្ធផលនៃការធ្វើការវាយតម្លៃដែលបានធ្វើឡើងដោយប្រើប្រាស់វិធីសាស្ត្រវាយតម្លៃប្រព័ន្ធការពារសុវត្ថិបបមសម្រាប់ស្តង់ដារកម្ពុជា (the "Methodology") និងពិធីសារនិងស្តង់ដារគោលរួមរបស់ LABS (ស្តង់ដារ LABS)។

ស្តង់ដារ LABS និងវិធីសាស្ត្រវាយតម្លៃ Methodology មានពន្យល់រៀបរាប់អំពីលក្ខខ័ណ្ឌតម្រូវសម្រាប់ដោះស្រាយបញ្ហាសុវត្ថិភាពអាយុជីវិតនៅក្នុងរោងចក្រ ពាក់ព័ន្ធនឹងបញ្ហាសុវត្ថិភាពអគ្គិភ័យ សុវត្ថិភាពអគ្គិសនី និងសុវត្ថិភាពហេដ្ឋារចនាសម្ព័ន្ធអគាររោងចក្រ ក៏ប៉ុន្តែ មូលនិធី LABS មិនទទួលខុសត្រូវ ឬអាចធានាថារោងចក្រពិតជាមានបំពាក់ពេញលេញនូវប្រព័ន្ធការពារសុវត្ថិភាពអាយុជីវិតពីគ្រោះអគ្គិភ័យ សុវត្ថិភាពអគ្គិសនី ឬសុវត្ថិភាពហេដ្ឋារចនាសម្ព័ន្ធអគាររោងចក្រ បានទេ។ ទន្ទឹមនេះ មូលនិធី LABS ក៏មិនទទួលខុសត្រូវក្នុងការធានាអះអាងថា រោងចក្រ និង/ឬ ក្រុមហ៊ុនអធិការកិច្ចដែលបានធ្វើការសិក្សាវាយតម្លៃ បានគោរពតាមលក្ខខ័ណ្ឌតម្រូវរបស់ស្តង់ដារ LABS និង/ឬ វិធីសាស្ត្រវាយតម្លៃ Methodology បានឡើយ។

ក្រុមហ៊ុនអធិការកិច្ចដែលធ្វើការសិក្សាវាយតម្លៃ ត្រូវចេះធ្វើការពន្យល់បកស្រាយ និង

កែម្រូលស្តង់ដារ LABS និងវិធីសាស្ត្រវាយតម្លៃ Methodology តាមការចំបាច់ ដើម្បីឱ្យស្របទៅតាមបរិបទរបស់តំបន់និងរោងចក្រជាក់លាក់ណាមួយ ដែលការវាយតម្លៃត្រូវបានធ្វើឡើង។ ក្រុមហ៊ុនអធិការកិច្ចត្រូវទទួលខុសត្រូវតែចំពោះការវាយតម្លៃ និងលទ្ធផលនៃការវាយតម្លៃនោះតែប៉ុណ្ណោះ ប៉ុន្តែមិនមែនត្រឹមតែអ្វីដែលមាននៅក្នុងរបាយការណ៍នេះទេតែប៉ុណ្ណោះទេ។ ពាក់ព័ន្ធនឹងរបាយការណ៍នេះ ឬផ្នែកណាមួយនៃរបាយការណ៍នេះ មូលនិធិ LABS មិនមានទំនួលខុសត្រូវតាមច្បាប់ (មិនថាក្នុងកិច្ចសន្យា ឬច្បាប់ស្តីពីបទល្មើសឬនៅក្រោមច្បាប់ទូទៅ ឬអ្វីផ្សេងទៀតនោះទេ) ក្នុងការធ្វើជាអាណាព្យាបាលទទួលខុសត្រូវចំពោះបុគ្គលណាមួយឬភាគីណាមួយ ដែលបានទទួលរបាយការណ៍នេះឡើយ ហើយមូលនិធី LABS ក៏មិនទទួលខុសត្រូវចំពោះភាគីណាមួយ ដែលបានប្រើប្រាស់របាយការណ៍ ឬធ្វើសកម្មភាពតាមខ្លឹមសារនៅក្នុងរបាយការណ៍នេះឡើយ។ មូលនិធិ LABS មិនទទួលខុសត្រូវ និងមិនអាចបង្ខំឱ្យទទួលត្រូវសងរាល់ការខូចខាតឬបាត់បង់ណាមួយ ដែលរោងចក្រ ក្រុមហ៊ុនអធិការកិច្ច និង/ឬជនពាក់ព័ន្ធទីបី បានទទួលរង ដោយសារបញ្ហាប្រព័ន្ធការពារសុវត្ថិភាពអាយុជីវិតក្នុងគ្រោះអគ្គិភ័យ ប្រព័ន្ធសុវត្ថិភាពអគ្គិសនី និងប្រព័ន្ធសុវត្ថិភាពហេដ្ឋារចនាសម្ព័ន្ធរោងចក្រ, ស្តង់ដារ LABS, វិធីសាស្ត្រវាយតម្លៃ Methodology, ការវាយតម្លៃ, របាយការណ៍, លទ្ធផលនៃការវាយតម្លៃ, និង/ឬ ផលវិបាករបស់ការវាយតម្លៃ ដរាបណារោងចក្រ ក្រុមហ៊ុនវាយតម្លៃ ឬជនទីបីមិនបានធ្វើការបង្ហាញឬលាតត្រដាងអំពីទង្វើទុចរិតដោយចេតនា ឬការធ្វេសប្រហែសធ្ងន់ធ្ងររបស់មូលនិធិ LAB Foundation។

តាមរយៈការអានរបាយការណ៍នេះ អ្នកអានរបាយការណ៍នេះត្រូវបានចាត់ទុកថាយល់ព្រមទទួលយកតាមលក្ខខ័ណ្ឌដែលបានលើកឡើងនៅខាងលើនេះហើយ។

K3 របាយការណ៍គម្រូអគ្គិសនី

វគ្គ: ចេញផ្សាយលើកទី1
កាលបរិច្ឆេទ៖ ថ្ងៃទី11 ខែកុម្ភៈ ឆ្នាំ2022 11

ពណ៌ក្រហម/ពណ៌ទំលឿង

ក្រុមហ៊ុននីយ៉ាន់ ឃីដ (ខេមបូឌា) អិលធីឌី - 2

ភូមិបន្លាស្ពិត សង្កាត់ខ្ទួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

(11.602821790941281, 104.87109037711541)

ថ្ងៃទី21 ខែមករា ឆ្នាំ2022

របាយការណ៍វាយតម្លៃប្រព័ន្ធសុវត្ថិភាពអគ្គិសនី

ការអង្កេតស្រាវជ្រាវ & វិធានការ

ក្រុមហ៊ុនធ្វើការវាយតម្លៃ: Archetype
អ្នកនិពន្ធជនជាតិខ្មែរ: ម៉ាន់ គីមហ័រ
ពិនិត្យផ្ទៀងផ្ទាត់ដោយ: ចៃមី ឃ្វីឡាឡា
អនុម័តយល់ព្រមដោយ: ចៃមី ឃ្វីឡាឡា

LABS
Life And Building Safety

មាតិកា

		ទំព័រ
1	**សេចក្តីសង្ខេបអំពីប្រតិបត្តិការណ៍របស់ក្រុមហ៊ុន**	**3**
2	**ព័ត៌មានទូទៅ**	**6**
2.1	ព័ត៌មានទូទៅអំពីរោងចក្រ	6
2.2	ព័ត៌មានទូទៅអំពីអគាររោងចក្រ	10
3	**ប្រព័ន្ធអគ្គិសនី**	**10**
3.1	ការផ្គត់ផ្គង់អគ្គិសនីដល់ប្រព័ន្ធការពារសុវត្ថិភាពអាយុជីវិត	10
3.2	អំពូលភ្លើងបំភ្លឺផ្លូវក្នុងគ្រាអាសន្ន	11
3.3	ឧបករណ៍ចាប់សញ្ញាអគ្គិភ័យនិងប្រព័ន្ធប្រកាសអាសន្ន	11
3.4	ប្រព័ន្ធខ្សែម៉ាស និងការតភ្ជាប់បណ្តាញអគ្គិសនី and Bonding	13
3.5	ប្រព័ន្ធការពាររន្ទះ	15
3.6	ថាមពលអគ្គិសនី	16
3.7	ប្រព័ន្ធចែកចាយអគ្គិសនី	18
3.8	ការថែទាំ និងកំណត់ហេតុ	21
4	**ការអង្កេតស្រាវជ្រាវ**	**22**
5	**វិធានការអាទិភាព**	**46**
6	**សេចក្តីអំពីវិធានការអាទិភាព**	**68**
7	**សេចក្តីសន្និដ្ឋាន និងដែនកំណត់**	**73**

1. សេចក្តីសង្ខេបអំពីប្រតិបត្តិការណ៍របស់ក្រុមហ៊ុន

កាលពីថ្ងៃសុក្រ ទី21 ខែមករា ឆ្នាំ2022 លោក ម៉ាន់ គីមហ័រ ដែលជាអ្នកជំនាញផ្នែកធ្វើការវាយតម្លៃ មកពីក្រុមហ៊ុនអាគីថាយកម្ពុជា (Archetype Cambodia) បានចុះទៅធ្វើការវាយតម្លៃប្រព័ន្ធសុវត្ថិភាពអគ្គិសនីរបស់រោងចក្រក្រុមហ៊ុន នីយ៉ាន់ ឃីដ (ខេមបូឌា) អិលធីឌី -2 ដែលមានអាសយដ្ឋាននិងទីតាំង ដូចមានខាងក្រោម នៅត្រង់ចំណុចស្តីពី " ព័តិមានទូទៅអំពីរោចចក្រ"។ ការវាយតម្លៃនេះមិនមានការរំខានឡើយ និងត្រូវបានធ្វើឡើងស្របតាមស្តង់ដារកម្មវិធីគំនិតផ្តួចផ្តើមស្តីពីសុវត្ថិភាពអាយុជីវិតនិងអគារ(LABS) សម្រាប់កម្ពុជា និងវិធីសាស្ត្រវាយតម្លៃបឋម (Methodology)។ ការធ្វើតេស្តត្រួតពិនិត្យប្រព័ន្ធអគ្គិសនីក្នុងកម្រិតមានកំណត់ត្រូវបានធ្វើឡើង។

ក្រុមហ៊ុននីយ៉ាន់ ឃីដ (ខេមបូឌា) អិលធីឌី -2 នៅកាន់កាប់អគារទាំងមូល និងបានផ្តល់ផ្តល់ការអនុញ្ញាតឱ្យដើរចូលទៅត្រួតពិនិត្យគ្រប់ទីកន្លែង។

យើងខ្ញុំបានជួបជាមួយអ្នកតំណាងរបស់ក្រុមហ៊ុនមួយចំនួនរួមមាន លោក ផេង កាង (អ្នកគ្រប់គ្រង់ធនធានមនុស្ស) លោក សារ៉ា (អ្នកគ្រប់គ្រងផលិតកម្ម) លោក សុខ វណ្ណា (ជំនួយការផ្នែកគ្រប់គ្រងធនធានមនុស្ស) និង លោក កុក ចុក ស៊ុន (អ្នកបច្ចេកទេសជាន់ខ្ពស់ខាងថែទាំគ្រឿងយន្ត) ហើយនិយោជិកមួយចំនួនទៀតក៏បានអមដំណើរពួកយើងនៅក្នុងអំឡុងពេលធ្វើការសិក្សាវាយតម្លៃផងដែរ។ ស្របពេលដែលការវាយតម្លៃកំពុងតែត្រូវបានធ្វើឡើងជាផ្នែកមួយនៃកិច្ចការសិក្សាវាយតម្លៃសាកល្បងខ្នាតតូចចំពោះប្រព័ន្ធសុវត្ថិភាពអគ្គិសនី អគ្គិភ័យ និងហេដ្ឋារចនាសម្ព័ន្ធ អ្នកតំណាងដទៃទៀតមកពីក្រុមហ៊ុន អាគីថាយ (Archetype) រួមជាមួយនឹងអ្នកអង្កេតការមកពីកម្មវិធីគំនិតផ្តួចផ្តើមស្តីពីសុវត្ថិភាពអាយុជីវិតនិងអគារ(LABS) ក៏មានវត្តមាននៅទីនោះដែរ។

រោងចក្ររបស់ក្រុមហ៊ុននីយ៉ាន់ ឃីដ (ខេមបូឌា) អីលធីឌី-2 មាន៖ អគារ A ជាអគារផលិតកម្ម ដែលក្នុងនោះមានអគារការិយាល័យដែលមានជាន់ឡៅតឿ, បន្ទប់ផ្នែកកាត់សាច់ក្រណាត់, បន្ទប់ផ្នែកដេរភ្ជាប់សាច់ក្រណាត់ បន្ទប់ផ្នែកព្រីន បន្ទប់ផ្នែកស្តុបទុកទំនិញចេញ/ចូល បន្ទប់ផ្នែកស្តុបទុកសម្លៀកបំពាក់សម្រេច និងបន្ទប់ដាក់ទូភ្លើងមេ។ អគារ B ជាអគារផលិតកម្ម ដែលក្នុងនោះមានបន្ទប់ខ្សែសង្វាក់កាត់សាច់ក្រណាត់, បន្ទប់ការិយាល័យ, បន្ទប់តេស្តពិនិត្យភាពយឺតរបស់សាច់ក្រណាត់, បន្ទប់ស្តុបទុកសាច់ក្រណាត់, បន្ទប់ត្រួតពិនិត្យគុណភាពសាច់ក្រណាត់, បន្ទប់វេចខ្ចប់សម្លៀកបំពាក់សម្រេចដាក់ក្នុងក្រដាស់កាតុង, បន្ទប់ខ្សែសង្វាក់តុបត់សម្រាប់អ៊ុតសម្លៀកបំពាក់ និងបន្ទប់ដាក់ទូចែកចាយភ្លើង។ អគារ C ជាអគារឃ្លាំងស្តុបទុកទំនិញ ដែលមានបន្ទប់ការិយាល័យ, ទីធ្លាសម្រាប់ដាក់ទំនិញ, បន្ទប់ដាក់ទូភ្លើងមេ, កន្លែងត្រួតពិនិត្យសាច់ក្រណាត់, កន្លែងដាក់ម៉ាស៊ីនបន្ទន់សាច់ក្រណាត់។ អគារស្នាក់នៅ ជាអគារស្នាក់នៅរបស់កម្មករនិងបុគ្គលិក។ ទីធ្លាក្រៅអាគារ មានប៉ុស្តិ៍យាមសន្តិសុខ, ទីកន្លែងចំណតយានន្ត

យន្ត, ទីកន្លែងចំណតម៉ូតូ 01 & 02, បន្ទប់ម៉ាស៊ីនភ្លើង 01 & ទូភ្លើងមេតង់ស្បុងទាប, កន្លែងអាងស្តុបទុកប្រេងឥន្ធន:, បន្ទប់ម៉ាស៊ីនភ្លើង 02, បន្ទប់ឡចំហាយទឹក, ម៉ាស៊ីនបូមឬបង្ហាប់ខ្យល់ ស្ថាននីយបូមទឹកពន្លត់អគ្គិភ័យ និងរោងទទួលទានអាហារ (កង់ទីន)។

ជារួម រោងចក្រនេះមានអគារមេចំនួនបី។ អគារពីរ (អគារ A និង អគារ B) ត្រូវបានសាងសង់ឡើងនៅក្នុងឆ្នាំ1999 ហើយអគារ C ត្រូវបានសងសង់នៅក្នុងឆ្នាំ2018។ មានកម្មករប្រមាណ 1500 នាក់ នៅក្នុងអគាររោងចក្រនេះ។

ចំណាត់ថ្នាក់លេខកូដពណ៌របស់រោងចក្រនេះគឺ ពណ៌ក្រហម/ពណ៌លឿងទំ ។ នេះមានន័យថា មានបញ្ហាយ៉ាងហោចណាស់មួយចំនួន ដែលត្រូវដោះស្រាយ នៅក្នុងរយៈពេលកំណត់ណាមួយ។

បញ្ជីត្រួសៗនៃបញ្ហាបារម្ភសំខាន់ៗ៖

- ការត្រួតពិនិត្យមើលកម្រិតសីតុណ្ហភាពកម្តៅនៅក្នុងទូភ្លើងឬទូចែកចាយអគ្គិសនី៖
  - សីតុណ្ហភាពកម្តៅខ្ពស់/សីតុណ្ហភាពកម្តៅហួសកម្រិតចំនួន 81,1 អង្សារ ត្រូវបានរកឃើញមាននៅក្នុងទូភ្លើងឬបន្ទះចែកចាយអគ្គិសនី "MDB-001B" នៅក្នុងអគារ A។
  - សីតុណ្ហភាពកម្តៅខ្ពស់/សីតុណ្ហភាពកម្តៅហួសកម្រិតចំនួន 78,5 អង្សារ ត្រូវបានរកឃើញមាននៅក្នុងទូភ្លើងផ្គង់ផ្គង់ទៅម៉ាស៊ីនព្រីនស្ង៊ុយប្រវត្តិ "DB-002B" នៅក្នុងអគារ A។
  - សីតុណ្ហភាពកម្តៅខ្ពស់/សីតុណ្ហភាពកម្តៅហួសកម្រិតចំនួន 71,8 អង្សារ ត្រូវបានរកឃើញមាននៅក្នុងទូភ្លើងឬបន្ទះចែកចាយអគ្គិសនី "DB-0013B" នៅក្នុងអគារ B។
  - សីតុណ្ហភាពកម្តៅខ្ពស់/សីតុណ្ហភាពកម្តៅហួសកម្រិតចំនួន 97,0 អង្សារ ត្រូវបានរកឃើញមាននៅក្នុងទូភ្លើងឬបន្ទះចែកចាយអគ្គិសនី "DB-003B" នៅក្នុងបន្ទប់ម៉ាស៊ីនបូមឬបង្ហាប់សម្ពាធខ្យល់។
  - សីតុណ្ហភាពកម្តៅខ្ពស់/សីតុណ្ហភាពកម្តៅហួសកម្រិតចំនួន 66,2 អង្សារ ត្រូវបានរកឃើញមាននៅក្នុងទូភ្លើងឬបន្ទះចែកចាយអគ្គិសនី "DB-005B" នៅក្នុងអគារ A ។
- ប្រព័ន្ធចែកចាយអគ្គិសនី៖
  - មានប្រើប្រាស់បន្ទះកម្រាលជាតិកៅស៊ូអ៊ីសូឡង់ការពារកម្តៅនៅក្នុងទូភ្លើងមិនគ្រប់គ្រាន់, មានការដំឡើងខ្សែភ្លើងមិនត្រឹមត្រូវ, មានកម្ទេចក្រណាត់និងធូលីនៅក្នុងទូភ្លើង។
  - មានការប្រើប្រាស់ទំហំផ្ទៃមុខកាត់ខ្សែភ្លើងតូចពេកជាច្រើន បើប្រៀបធៀបទៅនឹងកម្រិតចរន្តអគ្គិសនីដែលមានបញ្ហាក់នៅលើឧបករណ៍ការពារចរន្តអគ្គិសនី។
  - មានប្រើប្រាស់វត្ថុធាតុដែលងាយឆាបឆេះ (ឈើ) នៅក្នុងទូភ្លើង SDB-001B នៅ

ក្នុងអគារ A និង ទូភ្លើងកូន SDB-0016B នៅក្នុងអគារ B។

- មានប្រើខ្សែភ្លើង/សៀគ្វី (សៀគ្វី) តចេញពីបន្ទះចែកចាយអគ្គិសនីរបស់ម៉ាស៊ីនភ្លើង 01 ភ្ជាប់ទៅបន្ទះបិតបើកភ្លើងដោយប្រើដៃ01&02 (MTS) ដែលមិនមានឧបករណ៍ការពារទប់ចរន្តអគ្គិសនី។

- ការបំពាក់ឧបករណ៍ការពារសុវត្ថិភាពអាយុជីវិតពេលមានគ្រោះអគ្គិភ័យ៖
  - មិនមានដំឡើងអំពូលភ្លើងបំភ្លឺធម្មតា/អំពូលភ្លើងបំភ្លឺពេលមានគ្រោះអាសន្ន សម្រាប់បំភ្លឺបន្ទប់បច្ចេកទេស (បន្ទប់ទូភ្លើងមេតង់ស្យុងទាប-LVMSB/ទូភ្លើងបិតបើកដោយដៃ-MTS, បន្ទប់ម៉ាស៊ីនភ្លើង, បន្ទប់ទូភ្លើងមេ-MDB)
  - អំពូលភ្លើងបំភ្លឺពេលមានគ្រោះអាសន្នមួយចំនួនបែកខូចអស់ហើយ និងមួយចំនួនទៀតអាចបំភ្លឺបានតិចជាង10នាទីដោយប្រើប្រាស់ថាមពលអាគុយបម្រុង។
  - មិនមានទូរបញ្ជាគ្រប់គ្រងប្រព័ន្ធកណ្តឹងរោទ៍ប្រកាសអាសន្នពេលមានអគ្គិភ័យសម្រាប់រោងចក្រទាំងមូល។

- ប្រព័ន្ធខ្សែម៉ាស និងការតភ្ជាប់បណ្តាញអគ្គិសនី៖ មិនមានប្រើប្រាស់ខ្សែម៉ាស (PE) នៅក្នុងទូភ្លើងមួយចំនួន ហើយនិងមានការប្រើប្រាស់ខ្សែម៉ាស (PE) ដែលមានមុខកាត់តូចពេកនៅក្នុងទូភ្លើងនោះ។

- ម៉ាស៊ីនភ្លើង៖ មានលិចធ្លាយចេញប្រេងខ្លះៗនៅក្នុងបន្ទប់ម៉ាស៊ីនភ្លើង 01, បន្ទប់ម៉ាស៊ីនភ្លើង01&02 ត្រូវបានប្រើប្រាស់ជាកន្លែងស្តុបទុកទំនិញ, មិនមានផ្លូវដើរចូលទៅក្នុងបន្ទប់ម៉ាស៊ីនភ្លើង01 គ្រប់គ្រាន់។

- អនុស្ថានីយ៖ គម្របការពារទូភ្លើងមេតង់ស្យុងទាប-LVMSB/ទូភ្លើងបិតបើកដោយដៃ-MTSនៅក្នុងបន្ទប់ម៉ាស៊ីនភ្លើង01មានការខូចខាត, ចំនួនអំពូលភ្លើងបំភ្លឺធម្មតា/អំពូលភ្លើងបំភ្លឺពេលមានគ្រោះអាសន្នដែលបានដំឡើងគឺមិនគ្រប់គ្រាន់, មិនមានផ្លូវដើរចូលទៅកាន់បន្ទប់ទូភ្លើងមេចែកចាយអគ្គិសនី-MDBគ្រប់គ្រាន់, មិនមានប្រើប្រាស់បន្ទះកម្រាលជាតិកៅស៊ូអ៊ីសូឡង់ការពារកម្តៅគ្រប់គ្រាន់សម្រាប់ទូភ្លើងមេរ-MSB/ទូភ្លើងបិតបើកដោយដៃ-MTS/ ទូភ្លើងមេចែកចាយអគ្គិសនី-MDB និងសម្រាប់បន្ទះចែកចាយអគ្គិសនី-DB នៅក្នុងទីតាំងមួយចំនួននៃអគារ A, B, និង C.....

- រូបភាព៖ មិនមានរូបភាពនៃការតភ្ជាប់ខ្សែភ្លើងនៅក្នុងរោចចក្រឡើយ (មិនមានដ្យាក្រាមខ្សែភ្លើងមេសម្រាប់វិភាគប្រព័ន្ធចែកចាយអគ្គិសនី, មិនមានដ្យាក្រាមជាសញ្ញានិមិត្តរូបសម្រាប់សម្គាល់ខ្សែម៉ាស, មិនមានប្លង់មេស្តីពីប្រព័ន្ធចែកចាយអគ្គិសនី..)

- កំណត់ហេតុអំពីតំហែទាំ៖ មិនមានកំណត់ហេតុស្តីពីការធ្វើតំហែទាំ (អនុស្ថានីយម៉ាស៊ីនភ្លើង និងកណ្តឹងរោទ៍ប្រកាសអាសន្នពេលមានអគ្គិភ័យ)

សេចក្តីសង្ខេបនៃវិធានការ ដែលពាក់ព័ន្ធនឹងវិធានការអាទិភាពនិងកាលកំណត់សម្រាប់ការចាត់វិធានការ មាននៅក្នុងទំព័រចុងក្រោយនៃរបាយការណ៍នេះ។

ផ្អែកលើស្ថានភាពរបស់ប្រព័ន្ធការពារសុវត្ថិភាពអគ្គិសនី និងលក្ខខ័ណ្ឌរបស់បុគ្គលិក រោងចក្រដែលត្រូវបានស៊ើបអង្កេត កម្រិតនៃការធ្វើតំហែទាំទំនងជាមិនអាចទទួលយកបាន។ មិនមានកំណត់ហេតុស្តីពីតំហែទាំ សម្រាប់ធ្វើការត្រួតពិនិត្យវាយតម្លៃចំពោះអនុស្ថានីយ (របស់អគ្គិសនីកម្ពុជា EDC), ម៉ាស៊ីនភ្លើង និងទូភ្លើងឬបន្ទះចែកចាយភ្លើង។ ម៉ាស៊ីនភ្លើង និងទូភ្លើង ត្រូវបានឆែកពិនិត្យ និងថែទាំ ដោយក្រុមបច្ចេកទេសប្រចាំរោងចក្រ។ មិនមានការវាស់គុណភាពខ្សែម៉ាសតាមកាលកំណត់ឡើយ និងមិនមានកំណត់ហេតុស្តីពីការវាស់គុណភាពខ្សែម៉ាសសម្រាប់យកមកធ្វើការត្រួតពិនិត្យឡើយ។ ប្រព័ន្ធការពាររន្ទះថ្មីត្រូវបានសាងសង់ឡើងនៅថ្ងៃទី5 ខែមករា ឆ្នាំ2021។ ដូច្នេះមិនមានរបាយការណ៍ និងព័ត៌មានលម្អិតគ្រប់គ្រាន់ សម្រាប់យកមកត្រួតពិនិត្យឡើយ។

សូមកត់សម្គាល់ថា វិធានការទាំងនេះត្រូវចាត់ធ្វើឡើងឱ្យបានឆាប់បំផុតតាមការអនុវត្តជាក់ស្តែង និងស្របតាមកាលកំណត់ដែលបានបញ្ជាក់។

សេចក្តីសន្និដ្ឋាន និងដែនកំណត់នៃការសិក្សាវាយតម្លៃរបស់យើងខ្ញុំក៏មានបញ្ជាក់នៅទំព័រចុងក្រោយនៃរបាយការណ៍នេះផងដែរ។

1. ព័ត៌មានទូទៅ

1.1. ព័ត៌មានទូទៅអំពីរោងចក្រ

ឈ្មោះរោងចក្រ	រោងចក្រនីយ៉ាន់ ឃីដ (ខេមបូឌា) អិលធីឌី-2
អាសយដ្ឋានរោងចក្រ	ភូមិបន្លាស្នឹត, សង្កាត់ខ្ជួញ, ខ័ណ្ឌសែនសុខ, រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា
ទីតាំង GPS រោងចក្រ	11.602821790941281, 104.87109037711541
បុគ្គលទំនាក់ទំនង	លោក ផេង កាង (អ្នកគ្រប់គ្រងធនធានមនុស្ស)
អ្នកចូលរួមក្នុងសកម្មភាពអធិការកិច្ច	លោក កុក ចុក ស៊ុន (អ្នកបច្ចេកទេសជាន់ខ្ពស់ផ្នែកថែទាំគ្រឿងយន្ត លោក ម៉ាន់ គីមហ័រ (តំណាងរបស់ក្រុមហ៊ុន អាគីថាយ (Archetype)
នាមប័ណ្ណ	
ភតិកដទៃទៀត	✓

រូបភាពទី1៖ រូបភាពអគារពោងចក្រថតពីផ្កាយរណប



រូបភាពទី2៖ ប្លង់ទីតាំងទូទៅរបស់ពោងចក្រ

រូបភាពទី3៖ រូបភាពខាងមុខអគារ A

រូបភាពទី4៖ រូបភាពខាងមុខអគារ B

រូបភាពទី5៖ រូបភាពខាងមុខអគារ C

រូបភាពទី6៖ ទិដ្ឋភាពទូទៅរបស់អគាស្នាក់នៅ

1.1. ព័តិមានទូទៅអំពីអគារ

អគារមេ	មានចំនួន 4
ការប្រើប្រាស់ និងចាត់ចែងបែងចែកអគារ	• អគារ A៖ ជាន់ផ្ទាល់ដីត្រូវបានប្រើប្រាស់ជាអគារផលិតកម្ម • អគារ A៖ ជាន់ឡៅតឿត្រូវបានប្រើប្រាស់ជាការិយាល័យ • អគារ B៖ ជាន់ផ្ទាល់ដីត្រូវបានប្រើប្រាស់ជាអគារផលិតកម្ម • អគារ C ត្រូវបានប្រើប្រាស់ជាអគារឃ្លាំងស្តុបទុកទំនិញ • អគារស្នាក់នៅ ត្រូវបានប្រើប្រាស់ជាអគារសម្រាប់កម្មករនិងបុគ្គលិកស្នាក់នៅ
ជាន់ក្រោមដី	គ្មាន
ជាន់ឡៅតឿ	• ជាន់ឡៅតឿនៅអគារ A
ជាន់ជុតពីជាន់ក្រោមដី	គ្មាន
ទីតាំង/ក្រឡាផ្ទៃជាន់អគារ	• អគារ A៖ មានផ្ទៃក្រឡា 9200ម៉ែត្រការ៉ែ • អគារ A៖ ជាន់ឡៅតឿមានផ្ទៃក្រឡា 370 ម៉ែត្រការ៉ែ • អគារ B៖ មានផ្ទៃក្រឡា 5250 ម៉ែត្រការ៉ែ • អគារ C៖ មានក្រឡាផ្ទៃ 4500 ម៉ែត្រការ៉ែ • អគារស្នាក់នៅ មានក្រឡាផ្ទៃ 400 ម៉ែត្រការ៉ែ
ឆ្នាំនៃការសាងសង់	• អគារ A និង B ត្រូវបានសាងសង់នៅឆ្នាំ1999 • អគារ C ត្រូវបានសាងសង់នៅឆ្នាំ2018
ការកែកុនបន្ថែមបន្ថយ	គ្មាន
ប្លង់បន្ទប់នៅក្នុងជាន់នីមួយៗនៃអគារ	គ្មាន

2. ប្រព័ន្ធភ្លើងអគ្គិសនី

1.1. ថាមពលអគ្គិសនីផ្គត់ផ្គង់ទៅប្រព័ន្ធការពារសុវត្ថិភាពអាយុជីវិត

ប្រព័ន្ធការពារសុវត្ថិភាពអាយុជីវិតចំនួនបី និងថាមពលអគ្គិសនីផ្គត់ផ្គង់ដល់ប្រព័ន្ធ
ការពារសុវត្ថិភាពអាយុជីវិតទាំងបីនោះត្រូវបានអង្កេតស្រាវជ្រាវនៅក្នុងអំឡុងពេលធ្វើ
ការវាយតម្លៃ ដូចខាងក្រោម៖

ប្រព័ន្ធការពារសុវត្ថិភាពអាយុជីវិត	ថាមពលអគ្គិសនីដើម	ថាមពលអគ្គិសនីបម្រុង
អំពូលបំភ្លឺពេលមានអាសន្ន	ប្រភពផ្គង់ផ្គង់ថាមពលអគ្គិសនីដើម ឬមេ	ប្រភពផ្គត់ផ្គង់ថាមពលអគ្គិសនីបម្រុងចេញពីអាគុយ
ប្រព័ន្ធប្រកាសអាសន្នពេលមានអគ្គិភ័យ និងចាប់សញ្ញាភ្លើងឆេះអគ្គិភ័យ	ប្រភពផ្គង់ផ្គង់ថាមពលអគ្គិសនីដើម ឬមេ	ប្រភពផ្គត់ផ្គង់ថាមពលអគ្គិសនីបម្រុងចេញពីអាគុយ

ទុយោបាញ់ទឹកពន្លត់អគ្គិភ័យ របស់អោងចក្រ (ម៉ាស៊ីនបូមទឹក បាញ់ពន្លត់អគ្គិភ័យមេ ដើរដោយ ថាមពលអគ្គិសនីចំនួន2 នៅ ស្ថាននីយបូមទឹកពន្លត់អគ្គិភ័យ)	ប្រភពផ្គង់ផ្គង់ថាមពលអគ្គិសនី ដើម ឬមេ	ប្រភពផ្គត់ផ្គង់ថាមពលអគ្គិសនី បម្រុងចេញពីម៉ាស៊ីនភ្លើង 01

ស្ថានីយបូមទឹកពន្លត់អគ្គិភ័យមានម៉ាស៊ីនបូមទឹកបាញ់ពន្លត់អគ្គិភ័យមេចំនួន2ដែលដើរ ដោយថាមពលអគ្គិសនីក្នុងចំនួន11គីឡូវ៉ាត់ និងមិនមានម៉ាស៊ីនបូមទឹកបាញ់ពន្លត់អគ្គិភ័យមេ ដែលដើរដោយប្រេងឥន្ធន:នោះទេ។ ម៉ាស៊ីនបូមទឹកបាញ់ពន្លត់អគ្គិភ័យនេះ មានដំណើរការ ទៅធម្មតា នៅពេលធ្វើតេស្តពិនិត្យមើល។

រូបភាពទី7៖សកម្មភាពធ្វើតេស្តទុយោបាញ់ទឹកពន្លត់អគ្គិភ័យ និងស្ថានីយបូមទឹកបាញ់ពន្លត់អគ្គិភ័យ

1.1. អំពូលភ្លើងបំភ្លឺពេលមានអាសន្ន

អំពូលភ្លើងបំភ្លឺក្នុងគ្រាអាសន្ននៅគ្រប់ទីកកន្លែងមានអំពូលភ្លោះពីរគ្រាប់ជាប់គ្នា បំពាក់តោងនៅលើមាត់ទ្វាច្រកចូល និងច្រកចេញចុងក្រោយ

រូបភាពទី8៖ ពេលធ្វើតេស្តបើកបំភ្លឺភ្លើងសញ្ញាច្រកចេញ និងអំពូលភ្លើងបំភ្លឺក្នុងគ្រាអាសន្ន នៅអគារ A

បំភ្លឺភ្លើងសញ្ញាច្រកចេញ និងអំពូលភ្លើងបំភ្លឺក្នុងគ្រាអាសន្នត្រូវបានជ្រើសរើសយកមកធ្វើតេស្ត

ដោយចៃដន្យនៅអគារផលិតកម្មមេ ហើយមើលឃើញថាមួយចំនួនមិនដំណើរការ និងមួយចំនួនទៀតដំណើរការបានតិចជាង10នាទីដោយប្រើថាមពលអាគុយឬថ្ម

1.1.ប្រព័ន្ធប្រកាសអាសន្នពេលមានអគ្គិភ័យ និងចាប់សញ្ញាភ្លើងឆេះអគ្គិភ័យ

ប្រព័ន្ធចាប់សញ្ញាអគ្គិភ័យ	ឧបករណ៍ចាប់សញ្ញាផ្សែងឆេះអគ្គិភ័យមិនមានបំពាក់នៅក្នុងបន្ទប់ស្នាក់នៅរបស់កម្មករនិងបុគ្គលិកទេ។ ឧបករណ៍ចាប់សញ្ញាផ្សែងឆេះអគ្គិភ័យនេះមានបំពាក់តែនៅក្នុងអគា A (10គ្រឿង), អគារ B (13គ្រឿង), អគារ C (26គ្រឿង)។ ឧបករណ៍ចាប់សញ្ញាផ្សែងឆេះអគ្គិភ័យនេះមិនមាននៅក្នុងបន្ទប់ម៉ាស៊ីនភ្លើង 01&02។ ឧបករណ៍ចាប់សញ្ញាផ្សែងឆេះអគ្គិភ័យផលិតក្នុងស្រុក មានថាមពលអគ្គិសនីបម្រុងផ្គត់ផ្គង់ដោយថ្មពិលឬអាគុយដែលមានភ្ជាប់មកជាមួយនឹងឧបករណ៍នេះ។ ទីកន្លែងដទៃទៀតត្រូវធ្វើការបញ្ជាប្រកាសអាសន្នអគ្គិភ័យដោយដៃ ដោយប្រើប្រាស់កណ្តឹងរោទ៍ប្រកាសអាសន្នអំពីអគ្គិភ័យដែលបញ្ជាដោយដៃ (MCP)។ រាល់គ្រប់សញ្ញាប្រកាសអាសន្នអំពីអគ្គិសនីទាំងអស់មិនបានភ្ជាប់ទៅនឹងប្រព័ន្ធស្នូលទេព្រោះរោងចក្រមិនមានទូរឬផ្ទាំងបញ្ជាគ្រប់គ្រងកណ្តឹងរោទ៍ប្រកាសអាសន្នពេលមានអគ្គិភ័យទេ (FACP)។
កណ្តឹងរោទ៍ប្រកាសអាសន្នពេលមានអគ្គិភ័យ	ឧបករណ៍កណ្តឹងរោទ៍ប្រកាសអាសន្នពេលមានអគ្គិភ័យមានបំពាក់នៅគ្រប់ជាន់។ ត្រូវធ្វើការបញ្ជាប្រកាសអាសន្នអគ្គិភ័យដោយដៃ ដោយប្រើប្រាស់កណ្តឹងរោទ៍ប្រកាសអាសន្នអំពីអគ្គិភ័យដែលបញ្ជាដោយដៃ (MCP) ដែលមាននៅឯទ្វារច្រកចេញ នៅគ្រប់ទីកន្លែង។ រោងចក្រមិនមានទូរឬផ្ទាំងបញ្ជាគ្រប់គ្រងកណ្តឹងរោទ៍ប្រកាសអាសន្នពេលមានអគ្គិភ័យទេ (FACP)។

ការពិនិត្យមើលដោយផ្ទាល់ភ្នែកលើដំណើរការប្រព័ន្ធកណ្តឹងរោទ៍ប្រកាសអាសន្នពេលមានអគ្គិភ័យ ដែលត្រូវបានធ្វើតេស្តសាកល្បងជាមួយនឹងឧបករណ៍ចាប់សញ្ញាផលិតក្នុងស្រុក និងកណ្តឹងរោទ៍ប្រកាសអាសន្នអំពីអគ្គិភ័យដែលបញ្ជាដោយដៃ (MCP) នៅអគារផលិតកម្ម B។

រូបភាពទី9៖ ឧបករណ៍ចាប់សញ្ញាអគ្គិភ័យ និងកណ្តឹងរោទ៍ប្រកាសអាសន្នអំពីអគ្គិភ័យ ដែលបញ្ជាដោយដៃ (MCP) ត្រូវបានធ្វើតេស្ត នៅអគារ B

រូបភាពទី10៖ ឧបករណ៍ចាប់សញ្ញាអគ្គិភ័យ និងកណ្តឹងរោទ៍ប្រកាសអាសន្នអំពីអគ្គិភ័យ ដែលបញ្ជាដោយដៃ (MCP) ត្រូវបានធ្វើតេស្ត នៅអគារ C

1.1. ប្រព័ន្ធខ្សែម៉ាស និងការតភ្ជាប់បណ្តាញអគ្គិសនី

ការតភ្ជាប់គ្រឿងឧបករណ៍អគ្គិសនី (គ្រឿងចក្រ, ទូភ្លើង, ត្រង់ស្វូ, ម៉ាស៊ីនភ្លើងដើរដោយថាមពលប្រេងឥន្ធនៈ) ត្រូវបានបើកពិនិត្យមើលផ្ទាល់ភ្នែក។ ខ្សែម៉ាស (PE) ត្រូវបានដំឡើងនៅក្នុងទូភ្លើងមេ និងតភ្ជាប់ទៅនឹងទូភ្លើងកូន ហើយបន្ទះចែកចាយអគ្គិសនីមួយចំនួនបានប្រើប្រាស់ប្រព័ន្ធខ្សែម៉ាសផលិតក្នុងស្រុក ដែលឃើញមានដំឡើងនៅជាប់បន្ទះចែកចាយអគ្គិសនី(DB)នីមួយៗ។ មិនឃើញមានដ្យាក្រាមខ្សែម៉ាសនិងឧបរណ៍ការពាររន្ទះដែលប្រើនិមិត្តសញ្ញាសំគាល់ នៅក្នុងរោងចក្របច្ចុប្បន្ននេះទេ។ ទំហំមុខកាត់របស់ខ្សែម៉ាសចម្លងអគ្គិសនីដែលមិនមានទំហំធំគ្រប់គ្រាន់សមស្របត្រូវបានអង្កេតរកឃើញនៅក្នុងអំឡុងពេលធ្វើអធិការកិច្ចពិនិត្យរោងចក្រ។ ម៉ូទ័រ និងបន្ទះចែកចាយអគ្គិសនី មិនបានភ្ជាប់ជាមួយនឹងប្រព័ន្ធខ្សែម៉ាស(PE)។ មិនមានកំណត់ធ្វើតេស្តខ្សែម៉ាស សម្រាប់យកមកធ្វើការត្រួតពិនិត្យឡើយ។

រូបភាពទី11៖ ខ្សែម៉ាស PE ដែលមានទំហំមុខកាត់មិនត្រឹមត្រូវ ដែលត្រូវបានយកមកតភ្ជាប់ទៅនឹងម៉ាស៊ីនភ្លើង នៅក្នុងបន្ទប់ម៉ាស៊ីនភ្លើង។

រូបភាពទី12៖ ខ្សែម៉ាស PE ដែលមានទំហំមុខកាត់មិនត្រឹមត្រូវ ដែលត្រូវបាន

យកមកតភ្ជាប់ជាមួយនឹងទូម៉ាស៊ីនភ្លើង នៅក្នុងបន្ទប់ម៉ាស៊ីនភ្លើង។



រូបភាពទី13៖ ការដំឡើងខ្សែម៉ាស PE មិនត្រឹមត្រូវ សម្រាប់ទូភ្លើង នៅក្នុងអគារ A

រូបភាពទី14៖ ការដំឡើងខ្វះបន្ទះអគ្គិសនីរបស់ខ្សែម៉ាសPE សម្រាប់ទូភ្លើង នៅក្នុងអគារ A

1.1. ប្រព័ន្ធការពាររន្ទះ

ប្រព័ន្ធការពាររន្ទះថ្មីមួយឈ្មោះថា ប្រព័ន្ធបញ្ចៀសចរន្តរន្ទះ (ESE) ត្រូវបានបំពាក់នៅលើដំបូលខាងលើអគារផលិតកម្មមេ។ ក៏ប៉ុន្តែ មិនមានរូបប្លង់ប្រព័ន្ធការពាររន្ទះ និងរបាយការណ៍ឬកំណត់ហេតុអំពីការធ្វើតេស្តប្រព័ន្ធការពាររន្ទះ សម្រាប់យកមកធ្វើការពិនិត្យវាយតម្លៃនោះទេ។



រូបភាពទី15៖ តំបន់ដែនអាកាសការពាររន្ទះរបស់ប្រព័ន្ធការពាររន្ទះ01 ដែលបានដំឡើងនៅលើសរសរដែកថែបក្បែរអគារA និងរបាយការណ៍ធ្វើតេស្តមពិនិត្យមើលភាពធន់របស់ខ្សែម៉ាស



រូបភាពទី16៖ តំបន់ដែនអាកាសការពាររន្ទះរបស់ប្រព័ន្ធការពាររន្ទះ02 ដែលត្រូវបានដំឡើងនៅលើសរសរដែកថែបក្បែរអគារC និងរបាយការណ៍ធ្វើតេស្តមពិនិត្យមើលភាពធន់របស់

ខ្សែម៉ាស

1.1. ថាមពលអគ្គិសនី

ថាមពលអគ្គិសនីបានបញ្ជូនទៅទីតាំងមួយ តាមរយៈប្រព័ន្ធបណ្តាញផ្គង់ផ្គង់ភ្លើង22គីឡូវ៉ាត់ផុតលើក្បាល ដែលត្រូវបានភ្ជាប់ទៅនឹងត្រង់ស្វូចែកចាយ400គីឡូវ៉ាត់ចំនួន2គ្រឿងដែលបំពាក់លើសរសរភ្លើង រួចភ្ជាប់បន្តទៅបន្ទប់ម៉ាស៊ីនភ្លើងនិងបន្ទះបិតបើកភ្លើងដោយប្រើដៃ(MTS) 01 នៅក្បែរអគារ A និងតាមរយៈប្រព័ន្ធបណ្តាញផ្គង់ផ្គង់ភ្លើង22គីឡូវ៉ាត់មួយទៀតដែលត្រូវបានភ្ជាប់ទៅនឹងត្រង់ស្វូចែកចាយ400គីឡូវ៉ាត់មួយគ្រឿងដែលបានបំពាក់នៅលើសរសរភ្លើងនៅតាមបណ្តោយផ្លូវក្រោយអគារ C។ ត្រង់ស្វូរបំពាក់លើសរសរភ្លើងទាំងអស់នេះត្រូវបានតំឡើងនៅខាងក្រៅបរិវេណអគាររោងចក្រ (ជារបស់អគ្គិសនីកម្ពុជា EDC) ដែលមិនអនុញ្ញាតឱ្យចូលទៅប្រើប្រាស់បានទេ។ ខ្សែភ្លើងតង់ស្យុងទាប តចេញពីត្រង់ស្វូចែកចាយបំពាក់លើសសរភ្លើងភ្ជាប់ទៅបន្ទប់ទូភ្លើងមេតង់ស្យុងទាប-LVMSB/ទូភ្លើងបិតបើកដោយដៃ-MTS/ទូភ្លើងបិទបើកដោយស្វ័យប្រវត្តិ-ATS ត្រូវបានដំឡើងផុតពីក្បាល។

រូបភាពទី17៖ត្រង់ស្វូរបំពាក់លើសរសរភ្លើងនៅខាងក្រៅបរិវេណអគាររោងចក្រ (ជារបស់អគ្គិសនីកម្ពុជា EDC) ដែលមានតភ្ជាប់ខ្សែភ្លើងLV ទៅនឹងទូភ្លើងមេតង់ស្យុងទាប-LVMSB/ទូភ្លើងបិតបើកដោយដៃ-MTSនៅក្នុងបន្ទប់ម៉ាស៊ីនភ្លើង 01 នៅក្បែរអគារ A.

រូបភាពទី18៖ ខ្សែភ្លើងLVផុតលើក្បាល ចេញពីត្រង់ស្វូរ400គីឡូវ៉ាត់បំពាក់លើសរសរភ្លើងមួយផ្សេងទៀត តភ្ជាប់ទៅនឹងទូភ្លើងមេតង់ស្យុងទាប-LVMSB/ទូភ្លើងបិតបើកសៀគ្វីស្វ័យប្រវត្តិ-ATS នៅក្នុងបន្ទប់ភ្លើង 01 នៅក្នុងអគារ C.

មានម៉ាស៊ីនភ្លើងបម្រុងដើរដោយថាមពលប្រេងឥន្ធន:ចំនួន02 ត្រូវបានប្រើប្រាស់សម្រាប់ផ្គត់ផ្គង់ថាមពលអគ្គិសនីដល់តំបន់អោងចក្រទាំងមូល។

- ម៉ាស៊ីនភ្លើងផលិតថាមពល900គីឡូវ៉ាត់ចំនួន1 ជាមួយនឹងអាងស្តុបប្រេងឥន្ធន:ចំណុះ1000 លីត្រមួយឈុត មាននៅក្នុងបន្ទប់ម៉ាស៊ីនភ្លើង01 នៅឯជាន់ផ្ទាល់ដី ក្បែរអគារ A។ ស៊ីទែនប្រេងខ្ពាតធំតម្កល់លើផ្ទៃដី មាននៅក្បែរបន្ទប់ម៉ាស៊ីនភ្លើង01។ នៅក្នុងករណីប្រភពផ្គត់ផ្គង់ថាមពលអគ្គិសនីដើមដាច់ ម៉ាស៊ីនភ្លើងទី1 អាចបញ្ជោះបានដោយស្វ័យប្រវត្តិជាមួយនឹងទូភ្លើងបិទបើកសៀគ្វីពេលដាច់ភ្លើងមិនស្វ័យប្រវត្ត (MTS)។ ថាមពលអគ្គិសនីចំនួន900គីឡូវ៉ាតនេះ បានបញ្ជូនថាមពលអគ្គិសនីផ្គត់ផ្គងទៅទូរMTSពីរដាច់ដោយឡែកពីគ្នា ដែលមាននៅក្នុងបន្ទប់ម៉ាស៊ីនភ្លើង01 ហើយបន្ទាប់បញ្ជូនថាមពលអគ្គិសនីផ្គត់ផ្គង់ទៅទូភ្លើងមេMDB-001B និងទូភ្លើងមេ MDB-002B នៅក្នុងនៅក្នុងបន្ទប់អគ្គិសនី នៅក្នុងអគារ A។ ខ្សែភ្លើងតង់ស្យុងទាប (LV cables) តចេញពីទូរMTS ត្រូវបានតំឡើងផុតពីក្បាល។

រូបភាពទី19៖ បន្ទប់ម៉ាស៊ីនភ្លើងថាមពល900គីឡូវ៉ាត់ 01 ដែលមិនមានកង្ហារស្រូបខ្យល់ចេញចូលបន្ទប់នៅក្បែរអគារ A។





រូបភាពទី20៖

- A: ចំហៀងម្ខាងនៃទូរ MTS 01 ដែលតភ្ជាប់ទៅនឹងត្រង់ស្វូរថាមពល400គីឡូវ៉ាត់ដែលបំពាក់លើបង្គោលភ្លើង និងចំហៀងម្ខាងទៀតតភ្ជាប់ចេញពីម៉ាស៊ីនភ្លើងលេខ01 ដែលដើរដោយថាមពលប្រេង

ឥន្ធន: និងបញ្ចេញថាមពលបាន900គីឡូវ៉ាត់

- B: ចំហៀងម្ខាងនៃទូរ MTS 02 ដែលតភ្ជាប់ទៅនឹងត្រង់ស្វូរថាមពល400គីឡូវ៉ាត់ដែលបំពាក់លើបង្គោលភ្លើង និងចំហៀងម្ខាងទៀតតភ្ជាប់ចេញពីម៉ាស៊ីនភ្លើងលេខ01 ដែលដើរដោយថាមពលប្រេងឥន្ធនៈ និងបញ្ចេញថាមពលបាន900គីឡូវ៉ាត់

➢ ម៉ាស៊ីនភ្លើងផលិតថាមពល900គីឡូវ៉ាត់ចំនួន1 ជាមួយនឹងអាងស្តុបប្រេងឥន្ធនៈចំណុះ1500 លីត្រមួយឈុត មាននៅក្នុងបន្ទប់ម៉ាស៊ីនភ្លើង02 នៅឯជាន់ផ្ទាល់ដី ខាងក្រោយអគារ C។ អាងស្តុបប្រេងឥន្ធនៈសម្រាប់ម៉ាស៊ីនភ្លើងទី2នេះ នឹងត្រូវបានបូមបំពេញដោយដៃដោយអ្នកបច្ចេកទេសប្រចាំនៅរោងចក្រ។ នៅក្នុងករណីប្រភពផ្គត់ផ្គង់ថាមពលអគ្គិសនីដើមដាច់ ម៉ាស៊ីនភ្លើងទី2អាចបញ្ជោះបានដោយស្វ័យប្រវត្តិជាមួយនឹងទូភ្លើងបិទបើកសៀគ្វីស្វ័យប្រវត្តិពេលដាច់ភ្លើង (ATS)នៅក្នុងបន្ទប់ដាក់ទូភ្លើងមេMDB-003B នៅក្នុងអគារ C។

រូបភាពទី21៖ បន្ទប់ម៉ាស៊ីនភ្លើងផលិតថាមពល500គីឡូវ៉ាត់លេខ02 ដែលមិនមានប្រព័ន្ធកង្ហារស្រូបខ្យល់ចេញចូលបន្ទប់ នៅខាងក្រោយអគារ C

1.1. ប្រព័ន្ធចែកចាយអគ្គិសនី

ថាមពលតង់ស្យុងទាបចេញពីទូភ្លើងមេតង់ស្យុងទាប(LVMSB)/ទូភ្លើងបិទបើកសៀគ្វីពេលដាច់ភ្លើងមិនស្វ័យប្រវត្ត (MTS) នៅក្នុងបន្ទប់ម៉ាស៊ីភ្លើងលេខ 01&02 ត្រូវបានផ្ទេរបញ្ជូនទៅកាន់ទូភ្លើងមេ(MDB) នៅក្នុងអគារមេ A និង C ហើយបន្ទាប់មកបញ្ជូនចែកចាយអគ្គិសនីបន្តទៅបន្ទះចែកចាយអគ្គិសនីសម្រាប់ប្រតិបត្តិការនិងបន្ទះចែកចាយអគ្គិសនីកូននៅក្នុងបន្ទប់នីមួយ និងបញ្ជូនទៅបន្ទប់ដទៃទៀត។

រូបភាពទី22៖ ទូភ្លើងមេ (MDBs) នៅខាងក្នុងអគារ A.

រូបភាពទី23៖ បន្ទះចែកចាយអគ្គិសនី (DBs) នៅខាងក្នុងអគារ A.

រូបភាពទី24៖ បន្ទះចែកចាយអគ្គិសនីកូន (SDBs) នៅខាងក្នុងអគារ A.

រូបភាពទី25៖ បន្ទះចែកចាយអគ្គិសនី (DBs) នៅខាងក្នុងអគារ B.

រូបភាពទី26៖ បន្ទះចែកចាយអគ្គិសនីកូន (SDBs) នៅខាងក្នុងអគារ B.

រូបភាពទី27៖ ទូភ្លើងមេ (MDBs) នៅខាងក្នុងអគារ C

រូបភាពទី28៖ បន្ទះចែកចាយអគ្គិសនី (DB) នៅខាងក្នុងអគារស្នាក់នៅ

1.8. ការថែទាំ និងកំណត់ហេតុអំពីការថែទាំ

មិនមានកំណត់ហេតុអំពីការថែទាំ/កាលវិភាគធ្វើការថែទាំត្រង់ស្ទូ, ទូភ្លើងមេ, ម៉ាស៊ីនភ្លើង ជាដើម សម្រាប់យកមកធ្វើការត្រួតពិនិត្យនៅក្នុងអំឡុងពេលចុះធ្វើការវាយតម្លៃនោះទេ។

2. ការអង្កេតស្រាវជ្រាវ

លេខយោង	ប្រភេទនៃបញ្ហា	ប្រភេទនៃបញ្ហាបន្ទប់
អគ្គិសនី-1	E1: ថាមពលអគ្គិសនីផ្គង់ផ្គង់ទៅប្រព័ន្ធការពារសុវត្ថិភាពអាយុជីវិត	ថាមពលអគ្គិសនីផ្គង់ផ្គង់ទៅអំពូលភ្លើងបំភ្លឺក្នុងពេលមានអាសន្ន
ការអង្កេតស្រាវជ្រាវ៖ ភ្លើងសញ្ញាច្រកចេញ និងអំពូលភ្លើងបំភ្លឺក្នុងគ្រាអាសន្នត្រូវបានជ្រើសរើសយកមកធ្វើតេស្តដោយចៃដន្យនៅអគារផលិតកម្ម A&B ហើយមើលឃើញថាមួយចំនួនមិនដំណើរការ និងមួយចំនួនទៀតដំណើរការបានតិចជាង10នាទីដោយប្រើថាមពលអាគុយឬថ្មផលិតក្នុងស្រុក		
រូបភាពទី29៖ ថាមពលអគ្គិសនីបម្រុងមិនអាចផ្គត់ផ្គង់ដល់ការបើកភ្លើងសញ្ញាច្រកចេញ និងអំពូលភ្លើងបំភ្លឺក្នុងគ្រាអាសន្ននៅក្នុងអគារផលិតកម្ម នៅក្នុងអំឡុងពេលធ្វើតេស្ត		

លេខយោង	ប្រភេទនៃបញ្ហា	ប្រភេទនៃបញ្ហាបន្ទប់
អគ្គិសនី-2	E1: ថាមពលអគ្គិសនីផ្គង់ផ្គង់ទៅប្រព័ន្ធការពារសុវត្ថិភាពអាយុជីវិត	ថាមពលអគ្គិសនីផ្គង់ផ្គង់ទៅទូរបញ្ជាគ្រប់គ្រងកណ្តឹងរោទ៍ប្រកាសអាសន្នពេលមានអគ្គិភ័យ
ការអង្កេតស្រាវជ្រាវ៖ មិនមានដំឡើងទូរបញ្ជាគ្រប់គ្រងកណ្តឹងរោទ៍ប្រកាសអាសន្នពេលមានអគ្គិភ័យសម្រាប់ទីតាំងរោងចក្រទាំងមូល ដែលការណ៍នេះមិនអាចផ្តល់សញ្ញាអាសន្នដល់អ្នកសន្តិសុខបាន នៅក្នុងករណីមានអគ្គិភ័យកើតឡើង ឬក៏នរណាម្នាក់បាត់ពីក្នុងអគាររោងចក្រ។		

លេខយោង	ប្រភេទនៃបញ្ហា	ប្រភេទនៃបញ្ហាបន្ទប់
អគ្គិសនី-2	E2៖ ប្រព័ន្ធខ្សែម៉ាស និងខ្សែចាប់ភ្ជាប់	ការដាច់ខ្សែភ្លើងទប់ចរន្តភ្លើង (Break in neutral connection)
ការអង្កេតស្រាវជ្រាវ៖ មិនមានរបាយដែកណឺតសម្រាប់៖ - បន្ទះចែកចាយអគ្គិសនីកូន SDB-0015B នៅក្នុងអគារ B - បន្ទះចែកចាយអគ្គិសនីកូន SDB-0019B នៅក្នុងបន្ទប់ឡចំហាយទឹក		

រូបភាពទី30៖ មិនមានដំឡើងរបារដែកណឹតនៅខាងក្នុងបន្ទះចែកចាយអគ្គីសនីកូន SDB-0015B and SDB-0019B.

លេខយោង	**ប្រភេទនៃបញ្ហា**	**ប្រភេទនៃបញ្ហាបន្ទប់**
អគ្គិសនី-4	E2៖ ប្រព័ន្ធខ្សែម៉ាស និងខ្សែចាប់ភ្ជាប់	មិនមានខ្សែចាប់ភ្ជាប់គ្រប់គ្រាន់តភ្ជាប់ជាមួយនឹងឧបករណ៍

ការអង្កេតស្រាវជ្រាវ៖ មានការភ្លេចមិនបានប្រើប្រាស់ខ្សែម៉ាសចាប់ភ្ជាប់ជាច្រើន សម្រាប់តភ្ជាប់ទៅជាមួយនឹង៖

- ឧបករណ៍ទុកដាក់ការពារខ្សែភ្លើងមិនអោយដាច់រយៈ (ធ្នើរដាក់តម្រាបខ្សែភ្លើង, ជណ្តើរដាក់តម្រាបខ្សែភ្លើង, ហ្គែនខ្សែភ្លើង) នៅគ្រប់ទីតាំងទាំងអស់។
- អាងស្តុបប្រេងប្រចាំថ្ងៃ នៅក្នុងបន្ទប់ម៉ាស៊ីនភ្លើង 01 & 02
- ស៊ីវ៉ែនប្រេងខ្នាតធំតម្កល់ផុតពីដី
- ស៊ុមទ្វាទូអគ្គិសនី (ទូភ្លើងមេតង់ស្បុងទាប(LVMSB)/ទូភ្លើងបិទបើកសៀគ្វីពេលដាច់ភ្លើងមិនស្ម័យប្រវត្ត (MTS 01&02, ទូបិទបើកចរន្ត ...នៅក្នុងបន្ទប់ម៉ាស៊ីនភ្លើង 01)
- ស៊ុមទ្វាទូអគ្គិសនី (បន្ទះចែកចាយអគ្គិសនីកូន SDB-0019B នៅក្នុងបន្ទប់ឡចំហាយទឹក)
- ស៊ុមទ្វាទូអគ្គិសនី (បន្ទះចែកចាយអគ្គិសនី DB-0010B នៅក្នុងអគារ B)
- ប្រអប់ឡចំហាយទឹក និងម៉ូទ័របូមទឹកក្តៅ
- ម៉ាស៊ីនបោកសម្លៀកបំពាក់នៅក្នុងអគារ B



រូបភាពទី31៖: មិនមិនខ្សែម៉ាសចាប់ភ្ជាប់តភ្ជាប់ទៅនឹងឧបករណ៍ទុកដាក់ការពារខ្សែភ្លើងមិនអោយដាច់រយៈ (ផ្នើរដាក់តម្រាបខ្សែភ្លើង, ជណ្តើរដាក់តម្រាបខ្សែភ្លើង, ហ្គែនខ្សែភ្លើង)

រូបភាពទី32៖ មិនមានខ្សែម៉ាសចាប់ភ្ជាប់តភ្ជាប់ទៅនឹងអាងស្តុបប្រេងប្រចាំថ្ងៃ និងស៊ីវិទនប្រេងខ្នាតធំ



រូបភាពទី33៖ មិនមានខ្សែម៉ាសចាប់ភ្ជាប់តភ្ជាប់ទៅនឹងស៊ុមទ្វាទូអគ្គិសនីនៅក្នុងបន្ទប់ម៉ាស៊ីនភ្លើង 01.



រូបភាពទី34៖ មិនមានខ្សែម៉ាសចាប់ភ្ជាប់តភ្ជាប់ទៅនឹង:

1. ស៊ុមទ្វាទូអគ្គីសនី (បន្ទះចែកចាយអគ្គីសនីកូន SDB-0019Bនៅក្នុងបន្ទប់ឡចំហាយទឹក)
2. ស៊ុមទ្វាទូអគ្គីសនី (បន្ទះចែកចាយអគ្គីសនី DB-0010B នៅក្នុងអគារ B)
3. ម៉ាស៊ីនបោកខោអាវនៅក្នុងអគារ B

រូបភាពទី35៖ មិនមានខ្សែម៉ាសចាប់ភ្ជាប់តភ្ជាប់ទៅនឹងប្រអប់ឡចំហាយទឹក និងម៉ូទ័របូមទឹកក្តៅ

លេខយោង	**ប្រភេទនៃបញ្ហា**	**ប្រភេទនៃបញ្ហាបន្ទប់**
អគ្គិសនី-5	E2៖ ប្រព័ន្ធខ្សែម៉ាស និងខ្សែចាប់ភ្ជាប់	មិនមានខ្សែចាប់ភ្ជាប់គ្រប់គ្រាន់តភ្ជាប់ជាមួយនឹងឧបករណ៍
ការអង្កេតស្រាវជ្រាវ៖ មានភ្លើចប្រើប្រាស់របារខ្សែម៉ាស/ខ្សែម៉ាសសម្រាប់ការដំឡើង៖ - បន្ទះចែកចាយអគ្គិសនីកូន SDB-0017B នៅក្នុងអគារ B - បន្ទះចែកចាយអគ្គិសនីកូន SDB-0019B នៅក្នុងបន្ទប់ឡចំហាយទឹក		



រូបភាពទី36៖ មិនបានប្រើប្រាស់របារខ្សែម៉ាស/ខ្សែម៉ាសសម្រាប់ការដំឡើង៖
1.បន្ទះចែកចាយអគ្គីសនីកូន SDB-0017B នៅក្នុងអគារ B
2.បន្ទះចែកចាយអគ្គីសនីកូន SDB-0019B នៅក្នុងបន្ទប់ឡចំហាយទឹក

លេខយោង	**ប្រភេទនៃបញ្ហា**	**ប្រភេទនៃបញ្ហាបន្ទប់**
អគ្គិសនី-6	E3: ម៉ាស៊ីនភ្លើង	មិនមានខ្យល់ចេញចូលក្នុងបន្ទប់រោងម៉ាស៊ីនគ្រប់គ្រាន់
ការអង្កេតស្រាវជ្រាវ៖ បន្ទប់រោងម៉ាស៊ីនភ្លើង 01 & 02 ត្រូវបានប្រើប្រាស់ធ្វើជាកន្លែងស្តុបទុកទំនិញដែលមានអង្គធាតុងាយឆាបឆេះ		

រូបភាពទី37៖ អង្គធាតុងាយឆាបឆេះរក្សាទុកនៅក្នុងបន្ទប់រោងម៉ាស៊ីនភ្លើង 01.

រូបភាពទី38៖ អង្គធាតុងាយឆាបឆេះរក្សាទុកនៅក្នុងបន្ទប់រោងម៉ាស៊ីនភ្លើង 02.

លេខយោង	ប្រភេទនៃបញ្ហា	ប្រភេទនៃបញ្ហាបន្ទប់
អគ្គិសនី-7	E3: ម៉ាស៊ីនភ្លើង	មិនមានខ្យល់ចេញចូលក្នុងបន្ទប់រោងម៉ាស៊ីនគ្រប់គ្រាន់

ការអង្កេតស្រាវជ្រាវ៖ រកឃើញថាផ្លូវដើរនៅក្នុងបន្ទប់រោងម៉ាស៊ីន01 មានលក្ខណៈតូចចង្អៀត នៅត្រង់ចំណុចរវាងទូភ្លើងបិទបើកសៀគ្វីពេលដាច់ភ្លើងមិនស្វ័យប្រវត្ត (MTS-02) និងម៉ាស៊ីនភ្លើង 01 ក្បែរអគារ A.





រូបភាពទី39៖ ផ្លូវដើរមានលក្ខណៈតូចចង្អៀត នៅត្រង់ចំណុចរវាងទូភ្លើងបិទបើកសៀគ្វីពេលដាច់ភ្លើងមិនស្វ័យប្រវត្ត (MTS-02) និងម៉ាស៊ីនភ្លើង 01

លេខយោង	ប្រភេទនៃបញ្ហា	ប្រភេទនៃបញ្ហាបន្ទប់
អគ្គិសនី-8	E3: ម៉ាស៊ីនភ្លើង	ការប្រើប្រាស់ខ្សែម៉ាសមិនគ្រប់គ្រាន់សម្រាប់ដំឡើងជាមួយម៉ាស៊ីនភ្លើង 01
ការអង្កេតស្រាវជ្រាវ៖ មានការប្រើប្រាស់ខ្សែម៉ាសមិនគ្រប់គ្រាន់សម្រាប់ដំឡើងជាមួយម៉ាស៊ីនភ្លើង 01&02 នៅត្រង់ចំណុច2ដាច់ដោយឡែកពីគ្នា។		

រូបភាពទី40៖ ការប្រើប្រាស់ខ្សែម៉ាសមិនគ្រប់គ្រាន់សម្រាប់ដំឡើងជាមួយម៉ាស៊ីនភ្លើង 01 នៅត្រង់ចំណុច2ដាច់ដោយឡែកពីគ្នា។



រូបភាពទី41៖ ការប្រើប្រាស់ខ្សែម៉ាសមិនគ្រប់គ្រាន់សម្រាប់ដំឡើងជាមួយម៉ាស៊ីនភ្លើង02 នៅត្រង់ចំណុច2ដាច់ដោយឡែកពីគ្នា។

លេខយោង	ប្រភេទនៃបញ្ហា	ប្រភេទនៃបញ្ហាបន្ទប់
អគ្គិសនី-9	E3: ម៉ាស៊ីនភ្លើង	លិចប្រេងចេញពីទុយោ/ធុងប្រេង/ម៉ាស៊ីន
ការអង្កេតស្រាវជ្រាវ៖ មានការលិចប្រេងចេញពីអាងស្តុបប្រេងឥន្ធនៈប្រចាំថ្ងៃចំណុះ1000លីត្រ នៅក្នុងបន្ទប់រោងម៉ាស៊ីន01 នៅក្បែរអគារ A		

រូបភាពទី42៖ ប្រេងលិចចេញពីអាងស្តុបប្រេងឥន្ធនៈប្រចាំថ្ងៃ

លេខយោង	ប្រភេទនៃបញ្ហា	ប្រភេទនៃបញ្ហាបន្ទប់
អគ្គិសនី-10	E4: អនុស្ថានីយ	បញ្ហាចូលទៅប្រើប្រាស់
ការអង្កេតស្រាវជ្រាវ៖ រកឃើញថាផ្លូវដើរចូលមានលក្ខណៈចង្អៀតនៅទីតាំងបន្ទះចែកចាយអគ្គិសនី DBs នៅក្នុងអគារ A		

រូបភាពទី43៖ ផ្លូវដើរចូលទៅប្រើប្រាស់បន្ទះចែកចាយអគ្គិសនីDBsព្យួរលើជញ្ជាំង មានលក្ខណៈតូចចង្អៀតឬមិនគ្រប់គ្រាន់ ដោយសារត្រូវបាំងដោយឧបករណ៍រក្សាលំនឹងតង់ស្បូងដែលដាក់បញ្ឈរនៅលើឥដ្ឋ

លេខយោង	ប្រភេទនៃបញ្ហា	ប្រភេទនៃបញ្ហាបន្ទប់
អគ្គិសនី-11	E4: អនុស្ថានីយ	ទូភ្លើងមេតង់ស្យុងទាប(LVMSB)មានលក្ខណៈខូច
ការអង្កេតស្រាវជ្រាវ៖គម្របទូភ្លើងមេតង់ស្យុងទាប(LVMSB)/ទូភ្លើងបិទបើកសៀគ្វីពេលដាច់ភ្លើងមិនស្វ័យប្រវត្តិ (MTS) មានលក្ខណៈខូច ហើយបានយករបាំងផ្លាតមកប្រើជំនួសដែលមិនមានសុវត្ថិភាពពេលត្រូវការបើកគម្រប LVMSB/MTS 01 & 02 នៅក្នុងបន្ទប់ម៉ាស៊ីភ្លើង 01 ក្បែរអគារ A.		
រូបភាពទី44៖ គម្របទូភ្លើងខូច ហើយបានយករបាំងផ្លាតមកប្រើជំនួសដែលមិនមានសុវត្ថិភាពពេលត្រូវការបើកគម្រប LVMSB/MTS 01 & 02		

លេខយោង	ប្រភេទនៃបញ្ហា	ប្រភេទនៃបញ្ហាបន្ទប់
អគ្គិសនី-12	E4: អនុស្ថានីយ	អនុស្ថានីយមិនមានសុវត្ថិភាព
ការអង្កេតស្រាវជ្រាវ៖ ខ្វះចំនួនឬមិនមានអំពូលភ្លើងធម្មតា/អំពូលភ្លើងបំភ្លឺពេលមានអាសន្ននៅក្នុង: 1. បន្ទប់រោងម៉ាស៊ីនភ្លើងចំនួន2 (ម៉ាស៊ីនភ្លើង 01 &02) 2. បន្ទប់ទូភ្លើងមេ (MDB)/ បន្ទះចែកចាយអគ្គិសនី (DB) /ទីតាំងខាងក្នុងអគារ A, B និង C		

រូបភាពទី45៖ខ្វះចំនួនឬមិនមានអំពូលភ្លើងធម្មតា/អំពូលភ្លើងបំភ្លឺពេលមានអាសន្ននៅក្នុង:

1. បន្ទប់រោងម៉ាស៊ីន 01ក្បែរអគារ A
2. បន្ទប់រោងម៉ាស៊ីន 02 ខាងក្រោយអគារ C
3. បន្ទប់អគ្គីសនីដាក់ទូអគ្គិសនីមេ (MDBs) នៅខាងក្នុងអគារ A
4. បន្ទប់អគ្គីសនីដាក់បន្ទះចែកចាយអគ្គីសនី (DBs)នៅខាងក្នុងអគារB
5.បន្ទប់អគ្គីសនីដាក់ទូអគ្គិសនីមេ (MDBs) នៅខាងក្នុងអគារ C

លេខយោង	**ប្រភេទនៃបញ្ហា**	**ប្រភេទនៃបញ្ហាបន្ទប់**
អគ្គិសនី-13	E4: អនុស្ថានីយ	អនុស្ថានីយមិនមានសុវត្ថិភាព
ការអង្កេតស្រាវជ្រាវ៖ មិនបានប្រើប្រាស់បន្ទះកម្រាជាតិកៅស៊ូបានគ្រប់គ្រាន់សម្រាប់៖ 1. ទូភ្លើង MSB/ទូភ្លើងបិទបើកសៀគ្វីពេលដាច់ភ្លើងមិនស្ម័យប្រវត្ត (MTS) នៅក្នុងបន្ទប់រោងម៉ាស៊ីន 01 2. ទូភ្លើងមេ (MDB) និងបន្ទះចែកចាយអគ្គិសនី (DB) នៅក្នុងទីតាំងមួយចំនួន នៅខាងក្នុងអគារ A, B និង C.		

រូបភាពទី46៖ មិនបានប្រើប្រាស់បន្ទះកម្រាជាតិកៅស៊ូបានគ្រប់គ្រាន់សម្រាប់ទូអគ្គិសនីMTS-01,ទូភ្លើងMDBS និងបន្ទះភ្លើងDBs

លេខយោង	ប្រភេទនៃបញ្ហា	ប្រភេទនៃបញ្ហាបន្ទប់
អគ្គិសនី-14	E5: ប្រព័ន្ធចែកចាយអគ្គិសនី	មានអង្គធាតុងាយឆាបឆេះ/ងាយមានអណ្តាតភ្លើង
ការអង្កេតស្រាវជ្រាវ៖ មានអង្គធាតុងាយឆាបឆេះ/ងាយមានអណ្តាតភ្លើង (ឈើ) ដំឡើងនៅខាងក្នុងបន្ទះចែកចាយអគ្គិសនីកូន(SDB-001B) នៅក្នុងអគារ A និងនៅខាងក្នុងបន្ទះចែកចាយអគ្គិសនីកូន (SDB-0016B) នៅក្នុងអគារ B.		

រូបភាពទី47៖អង្គធាតុងាយឆាបឆេះ/ងាយមានអណ្តាតភ្លើង (ឈើ) ដំឡើងនៅខាងក្នុងបន្ទះចែកចាយអគ្គិសនីកូន (SDB-001B)

រូបភាពទី48៖អង្គធាតុងាយឆាបឆេះ/ងាយមានអណ្តាតភ្លើង (ឈើ) ដំឡើងនៅខាងក្នុងបន្ទះចែកចាយអគ្គិសនីកូន SDB-0016B)

